# ទំនុកតម្កើង

# និង

# បទឯទៀតៗ

# តាមគម្ពីរ

# ពាក្យគាព្យថ្មី

ព្រះសហគមន៍កាតូលិក
ភ្នំពេញ
ឆ្នាំ ២០១៩
បោះពុម្ពលើកទី ៣

# លំនាំដើម

***

តាំងពីដើមរៀងមក ប្រជាជនអ៊ីស្រាអែលតែងតែនាំគ្នាគោរពព្រះជាម្ចាស់ ទាំងនៅគ្រាលំបាកក្ដី ទាំងនៅគ្រាសុខស្រួលក្ដី ពួកគេតែងតែនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងអរព្រះគុណព្រះអង្គ ។ មិនតែប៉ុណ្ណោះ ពួកគេសូមព្រះអង្គលើកលែងទោសឲ្យពួកគេ សូមទទួលសារភាពនូវអំពើបាបរបស់ខ្លួន សូមអង្វរព្រះជាម្ចាស់ឲ្យសង្គ្រោះប្រជាជនរបស់គេ ។ល ។

ហេតុដូចខាងលើនេះ បានជាអ្នកស្រុកនាំគ្នាតែងអត្ថបទជាច្រើន ជាពាក្យកាព្យហើយនាំគ្នាសូត្រ ជួនកាលម្នាក់ឯង ជួនកាលរួមគ្នា ព្រមទាំងដេញគ្រឿងតូរ្យតន្ត្រីផង ។ យើងសន្មតហៅអត្ថបទទាំងនេះថា «ទំនុកតម្កើង» គឺជាបទចម្រៀងសម្រាប់កោតសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់ ។

ក្នុងចំណោមគម្ពីរទាំងអស់ «ទំនុកតម្កើង» មានសារៈសំខាន់បំផុត ព្រោះអត្ថបទទាំងនោះ បង្ហាញអំពីរបៀបដែលប្រជាជនអ៊ីស្រាអែល ធ្លាប់ទូលសន្ទនាជាមួយព្រះជាម្ចាស់គ្រប់ពេលប្រចាំជីវិតរបស់គេ ។

ព្រះយេស៊ូក៏បានសូត្រទំនុកទាំងនោះដែរ ។ ពេលយើងសូត្រទំនុកតម្កើងទាំងនោះ យើងពោលព្រះបន្ទូលផ្ទាល់របស់ព្រះអង្គ ដែលមានទំនាក់ទំនងនឹងព្រះបិតា ។

តាំងពីដើមដំបូង គ្រីស្តបរិស័ទបានយកចិត្តទុកដាក់នឹងទំនុកតម្កើងទាំងនោះ ឯព្រះសហគមន៍ ក៏បានបាត់បែងឲ្យសូត្រទំនុកតម្កើង ក្នុងពេលធ្វើពិធីផ្សេងៗ ជាពិសេសពេលថ្វាយអភិបូជា ។ អស់លោកអ្នកបួសក៏តែងសូត្រទំនុកតម្កើងនេះជារៀងរាល់ថ្ងៃ ក្នុងនាមមនុស្សលោកទាំងអស់ដែរ ។ រីឯយើងជាគ្រីស្តបរិស័ទវិញ យើងគួរតែយកចិត្តទុកដាក់សូត្រទំនុកតម្កើងទាំងអស់នេះដែរ ដើម្បីឲ្យមានចិត្តគំនិតស្របទៅតាមព្រះគម្ពីរ ។

អ្នកនិពន្ធទំនុកតម្កើង មានបំណងបង្ហាញចិត្តគំនិតរបស់ខ្លួន តាមព្រឹត្តិការផ្សេងៗដែលកើតមានក្នុងឆាកជីវិតរបស់គេ ឬក្នុងប្រទេសគេ ។ ដូច្នេះអត្ថបទទាំងនោះ មានអត្ថន័យផ្សេងៗពីគ្នា ។

លេខទំនុកតម្កើងមានសរសេរពីរយ៉ាង ៖ ឧ. ទំនុកតម្កើងលេខ ១២៥ (១២៤) គឺថា លេខក្រៅរង្វង់ក្រចក បង្ហាញអំពីរបៀបរាប់ក្នុងគម្ពីរជាភាសាហេប្រឺ លេខក្នុងរង្វង់ក្រចក បង្ហាញអំពីរបៀបរាប់ក្នុងភាសាក្រិក ហើយលេខនេះ ព្រះសហគមន៍ធ្លាប់ប្រើតាំងពីដើមរៀងមក ។

កណ្ឌទំនុកតម្កើងមាន ១៥០ បទ តែក្នុង ១៥០ បទនេះ យើងបានបន្ថែមបទផ្សេងៗ ដែលមានចែងក្នុងកណ្ឌផ្សេងនៃគម្ពីរសម្ពន្ធមេត្រីចាស់ផង និងសម្ពន្ធមេត្រីថ្មីផង ។

ខាងក្រោមនេះ យើងសូមជូនបញ្ជីទំនុកតម្កើងតាមអត្ថន័យ សម្រាប់ជួយអ្នក រើសបទមួយក្នុងពេលសូត្រម្នាក់ឯង ឬក្នុងពេលរៀបពិធីផ្សេងៗ ។ ពេលនោះគួររើសយកទំនុកតម្កើងមួយ ឲ្យស្របទៅតាមពិធីនោះ និងស្របទៅតាមចិត្តគំនិតរបស់ខ្លួន (សប្បាយ កើតទុក្ខ អង្វរ សូមទោស) ដែលយើងមានបំណងទូលថ្វាយទៅព្រះជាម្ចាស់ ៖

***១-ទំនុកតម្កើងសម្រាប់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់និងសម្រាប់ថ្វាយបង្គំព្រះអង្គ ៖***

*ក)-បទលើកតម្កើងព្រះជាម្ចាស់ ដែលប្រកបដោយឫទ្ធានុភាព និងធម៌មេត្តាករុណា*

*លេខរៀងទំនុកតម្កើង*


| | | | |
|---|---|---|---|
| ៨- | ឱ! ព្រះអម្ចាស់ | ព្រះអង្គជាព្រះ | ទំព័រ ១៥ |
| ១៩- | ផ្ទៃមេឃថ្លាថ្លៃង | រុងរឿងស្ញប់ស្ញែង | - ២៩ |
| ២៩- | ទេវតាទាំងឡាយ | ចូរនាំគ្នាថ្វាយ | - ៤១ |
| ៣៣- | មនុស្សដែលសុចរិត | អបអរពិតលើកតម្កើង | - ៤៦ |
| ១០០- | មនុស្សលើផែនដី | ទាំងប្រុសទាំងស្រី | - ១៤៧ |
| ១០៤- | ខ្ញុំសូមតម្កើងព្រះអម្ចាស់ | ប្រសើរខ្លាំងណាស់អស់ពីចិត្ត | - ១៥៣ |
| ១១១- | ចូរលើកតម្កើងព្រះជាម្ចាស់ | ប្រសើពេកណាស់លើលោកា | - ១៧១ |
| ១១៣- | អស់អ្នកបម្រើព្រះ | ជាអម្ចាស់ចូរនាំគ្នា | - ១៧៣ |
| ១១៤- | ពេលអ៊ីស្រាអែលបានចាកចេញ | ពីអេស៊ីបវិញហើយពេលនោះ | - ១៧៤ |
| ១១៧- | ឱប្រជាជនទាំងឡាយអើយ | ចូរសរសើរហើយលើកតម្កើង | - ១៧៧ |

| | | | |
|---|---|---|---|
| ១៣៥- | អាលេលូយ៉ា | ចូរគ្រប់អាត្មា | - ២០៣ |
| ១៣៦- | សូមតម្កើងព្រះ | ដែលជាអម្ចាស់ | - ២០៥ |
| ១៤៥- | បពិត្រព្រះម្ចាស់ | ជាក្សត្ររបស់ | - ២១៦ |
| ១៤៦- | ឱ! ព្រះអម្ចាស់អើយខ្ញុំសូម | តម្កើងទាំងព្រមដោយចិត្តស្មោះ | - ២១៨ |
| ១៤៧- | យើងស្មូត្របទថ្វាយព្រះ | ជាម្ចាស់របស់យើង | - ២១៩ |
| ១៤៨- | ចូរលើកតម្កើងព្រះអម្ចាស់ | ទ្រង់គឺជាព្រះដ៏វិសុទ្ធ | - ២២១ |
| ១៤៩- | ចូរច្រៀងបទថ្មី | ថ្វាយព្រះម្ចាស់ថ្លៃ | - ២២២ |
| ១៥០- | ចូរកោតសរសើរព្រះ | ជាអម្ចាស់ក្នុងវិហារ | - ២២៣ |


### *ខ)-បទលើកតម្កើងព្រះអម្ចាស់ ជាព្រះមហាក្សត្រសោយរាជ្យលើពិភពលោក*


| | | | |
|---|---|---|---|
| ២៤- | អ្វីៗដែលនៅលើផែនដី | កើតមកច្រើនក្រៃមីរដេរដាស | - ៣៥ |
| ៤៧- | ឱជនទាំងឡាយ | ចូរអរសប្បាយ | - ៦៩ |
| ៦៨- | ពេលព្រះម្ចាស់ក្រោកឡើង | សត្រូវបើងបាក់បបខ្លាច | - ៩៤ |
| ៩៣- | ព្រះអម្ចាស់ជា | មហាក្សត្រា | - ១៤០ |
| ៩៦- | ចូរច្រៀងបទថ្មីថ្វាយ | ព្រះម្ចាស់ថ្លៃកុំឈរឈប់ | - ១៤៣ |
| ៩៧- | ព្រះជាអម្ចាស់ទ្រង់គ្រងរាជ្យ | ពេញដោយអំណាចដ៏យូរលង់ | - ១៤៥ |
| ៩៨- | ចូរច្រៀងបទថ្មី | ថ្វាយព្រះម្ចាស់ថ្លៃ | - ១៤៦ |
| ៩៩- | ពេលព្រះអម្ចាស់ទ្រង់គ្រងរាជ្យ | ប្រជាជនខ្លាចភ័យញាប់ញ័រ | - ១៤៦ |


### *គ)-បទលើកតម្កើងព្រះជាម្ចាស់ដែលគង់នៅជាមួយប្រជាជន ក្នុងព្រះវិហារក្រុងយេរូសាឡឹម និងក្នុងព្រះសហគមន៍*


| | | | |
|---|---|---|---|
| ៤៦- | ព្រះអម្ចាស់ជាទីជម្រក | ឲ្យយើងចូលជ្រករាល់ខែឆ្នាំ | - ៦៨ |
| ៤៨- | ព្រះអម្ចាស់ជាព្រះឧត្តម | ប្រសើរសក្តិសមខ្ពស់បំផុត | - ៧០ |
| ៨៤- | ព្រះម្ចាស់លើពិភព | ទូទាំងសព្វលើផែនដី | - ១២៥ |
| ៨៧- | ព្រះម្ចាស់សង់ក្រុង | ឧត្តមឧត្តុង្គ | - ១៣០ |
| ១២២- | គេប្រាប់ខ្ញុំថា | យើងនាំគ្នីគ្នា | - ១៩៥ |

### *ឃ)- បទលើកតម្កើងព្រះគ្រីស្ត ដែលជាព្រះមហាក្សត្រ យាងមកសង្គ្រោះប្រជាជនព្រះអង្គ*


| | | | |
|---|---|---|---|
| ២- | ហេតុអ្វីបានជាប្រជាជាតិ | នាំគ្នាខ្ទឹងឃ្នាតកើងកង្វលើ | - ៩ |
| ១៨- | ឱ! ព្រះអម្ចាស់អើយ | ខ្ញុំកោតហើយលើកព្រះអង្គ | - ២៥ |
| ២១- | បពិត្រអម្ចាស់ | រាជាអរណាស់ | - ៣១ |
| ៤៥- | ពាក្យខ្ញុំពោលពិរោះ | ជីស្ម័គ្រស្មោះអស់ពីចិត្ត | - ៦៧ |
| ៧២- | ព្រះជាម្ចាស់អើយ | សូមប្រទានឲ្យ | - ១០៣ |
| ៨៩- | ឱ! ព្រះជាម្ចាស់ | ខ្ញុំមិនគេចប្រាស | - ១៣២ |
| ១០១- | បពិត្រព្រះម្ចាស់ខ្ញុំនឹងច្រៀង | រៀបរាប់មិនល្បើងពីព្រះទ័យ | - ១៤៨ |
| ១១០- | ព្រះអម្ចាស់មាន | បន្ទូលមកកាន់ | - ១៧០ |
| ១៣២- | ឱ! ព្រះម្ចាស់ឧត្តម | សូមនឹកចាំដល់ដាវីឌ | - ២០១ |
| ១៤៤- | សូមលើកតម្កើងព្រះ | ជាអម្ចាស់ដ៏ឧត្តម | - ២១៥ |


## ២-ទំនុកតម្កើងសម្រាប់ទូលអង្វរព្រះជាម្ចាស់ ៖

### *ក)- បទអង្វរព្រះជាម្ចាស់ដោយម្នាក់ឯង*


| | | | |
|---|---|---|---|
| ៥- | ឱ! ព្រះអម្ចាស់អើយ | កុំកន្តើយផ្ទៀងព្រះកាណ៌ | - ១២ |
| ៧- | ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ | ខ្ញុំសូមពឹងហើយលើព្រះអង្គ | - ១៤ |
| ១៣- | បពិត្រព្រះអម្ចាស់អើយ | តើនៅកន្តើយ | - ២១ |
| ១៧- | ឱ! ព្រះម្ចាស់សូសណ្តាប់ | ទូលបង្គំប្រាប់សំណុមពរ | - ២៤ |
| ២២- | ឱ! ព្រះអម្ចាស់អើយ | ចុះហេតុម្តេចឡើយ | - ៣២ |
| ២៥- | ឱ! ព្រះអម្ចាស់ខ្ញុំផ្ចង់ចិត្ត | ផ្ចង់ទាំងគំនិតឥតរវាត | - ៣៦ |
| ២៦- | ឱ! ព្រះអម្ចាស់អើយ | ខ្ញុំស្រែកហើយរកព្រះអង្គ | - ៤១ |
| ៣១- | ឱ! ព្រះអម្ចាស់ | ខ្ញុំសូមប្រកាស | - ៤៣ |
| ៣៦- | ខ្ញុំនឹកឃើញអស់ | ពាក្យពោលទ្រគោះ | - ៥២ |
| ៤០(៧..) | ព្រះអង្គមិនចង់បានតង្វាយ | យញ្ញបូជាថ្វាយអ្វីទាល់សោះ | - ៦០ |
| ៤២- | បពិត្រព្រះម្ចាស់ | ខ្ញុំប្រាថ្នាណាស់ | - ៦៣ |

| | | | |
|---|---|---|---|
| ៤៣- | ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ | សូមកុំកន្តើយរកយុត្តិធម៌ | - ៦៤ |
| ៥១- | ឱ! ព្រះជាម្ចាស់ទូលបង្គំ | សូមលើកទោសខ្ញុំហើយមេត្តា | - ៧៥ |
| ៥៤- | ឱ! ព្រះជាម្ចាស់អើយ | កុំកន្តើយសូមជួយផង | - ៧៩ |
| ៥៥- | ឱ! ព្រះម្ចាស់អើយសូមមេត្តា | សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យខ្ញុំ | - ៧៩ |
| ៥៦- | ឱ! ព្រះម្ចាស់ថ្លាថ្លៃ | សូមប្រណីហើយមេត្តា | - ៨១ |
| ៥៧- | ឱ! ព្រះជាម្ចាស់ | សូមមេត្តាប្រោស | - ៨២ |
| ៥៩- | ឱ! ព្រះម្ចាស់អើយ | សូមកុំកន្តើយ | - ៨៤ |
| ៦៩- | ឱ! ព្រះជាម្ចាស់ | សូមជួយសង្គ្រោះ | - ៩៨ |
| ៧១- | បពិត្រព្រះម្ចាស់ខ្ញុំសូមជ្រក | ក្រោមម្លប់ជម្រកនៃព្រះអង្គ | - ១០១ |
| ៨៦- | ឱ! ព្រះអម្ចាស់អើយ | កុំកន្តើយផ្ទៀងព្រះកាណ៌ | - ១២៨ |
| ៨៨- | បពិត្រព្រះអម្ចាស់ | ទ្រង់ជាព្រះសង្គ្រោះខ្ញុំ | - ១៣០ |
| ១០២- | ឱ! ព្រះអម្ចាស់អើយ | សូមផ្ទៀងហើយព្រះសណ្តាប់ | - ១៤៩ |
| ១០៩- | ឱ! ព្រះអម្ចាស់ | ខ្ញុំសូមប្រកាស | - ១៦៨ |
| ១៣០- | បពិត្រព្រះជាអម្ចាស់អើយ | ខ្ញុំស្រែកដង្ហើយរកព្រះអង្គ | - ២០០ |
| ១៤១- | ឱ! ព្រះអម្ចាស់ | ខ្ញុំសូប្រកាស | - ២១២ |
| ១៤៣- | ឱ! ព្រះម្ចាស់អើយសូមសណ្តាប់ | ពាក្យខ្ញុំរ៉ាយរ៉ាប់ទូលអង្វរ | - ២៦៦ |


## ខ)- បទអង្វរព្រះជាម្ចាស់រួមគ្នា


| | | | |
|---|---|---|---|
| ១២- | ឱ! ព្រះអម្ចាស់សូមជួយផង | មនុស្សច្រើនកន្លងសឹងលែងមាន | - ២០ |
| ៤៤(១០..) | តែឥឡូវនេះ | ព្រះអង្គបានលះ | - ៦៥ |
| ៦០- | ឱ! ព្រះជាម្ចាស់អើយ | ហេតុម្តេចឡើយក៏បោះបង់ | - ៨៦ |
| ៧៤- | បពិត្រព្រះម្ចាស់អើយ | ចុះម្តេចឡើយក៏ព្រះអង្គ | - ១០៧ |
| ៧៧(១២..) | បពិត្រព្រះម្ចាស់ | ខ្ញុំរំឭកច្បាស់ | - ១១២ |
| ៧៩- | បពិត្រព្រះជាអម្ចាស់អើយ | ជនជាតិទាំងឡាយចូលឈ្លានពាន | - ១១៩ |
| ៨០- | ព្រះម្ចាស់ជាគង្វាល | អ៊ីស្រាអែលសូមសណ្តាប់ | - ១២០ |
| ៨៥- | បពិត្រព្រះអម្ចាស់ | ព្រះអង្គគាប់ព្រះ | - ១២៧ |
| ៩០- | បពិត្រព្រះម្ចាស់ដ៏ប្រសើរ | ព្រះអង្គធ្លាប់ធ្វើជាជម្រក | - ១៣៦ |
| ៩៤(៥..) | បពិត្រព្រះជាម្ចាស់ | ពួកគេជិះជាន់សង្កត់ | - ១៤១ |

| | | |
|---|---|---|
| ១២៣-ឱ! ព្រះជាអម្ចាស់ | គង់ខ្ពស់ណាស់ស្ថានសុខអើយ | - ១៩៦ |
| ១២៦- ពេលព្រះដឹកនាំអ្នក | ដែលជំពាក់ខ្លួនជាឈ្លើយ | - ១៩៨ |
| ១៣៧- យើងអង្គុយនឹកគិតរិះរេ | នៅមាត់ទន្លេបាប៊ីឡូន | - ២០៧ |


## ៣- ទំនុកតម្កើងបង្ហាញចិត្តជឿសង្ឃឹមលើព្រះជាម្ចាស់ ៖


| | | |
|---|---|---|
| ៣- ឱ! ព្រះអម្ចាស់ | សត្រូវច្រើនណាស់ជិតជុំ | - ១០ |
| ៤- ឱ! ព្រះអម្ចាស់ថ្លៃបវរ | ដែលរកយុត្តិធម៌ឲ្យយើងខ្ញុំ | - ១១ |
| ១១(៤..)ព្រះម្ចាស់គង់ក្នុង | វិហារព្រះអង្គ | - ២០ |
| ១៦- ឱ! ព្រះជាម្ចាស់ដ៏ឧត្តម | សូមការពារខ្ញុំឲ្យសុខសាន្ត | - ២៣ |
| ២៣- ឱ! ព្រះអម្ចាស់ជាគង្វាល | មើលឥតឃាលណែនាំខ្ញុំ | - ៣៥ |
| ២៧- ព្រះអម្ចាស់ទ្រង់ជាពន្លឺ | នាមល្បីរន្ទឺព្រះសង្គ្រោះ | - ៣៩ |
| ១១៥- បពិតព្រះម្ចាស់ | ខ្ញុំមិនគួរសោះ | - ១៧៤ |
| ១២១- ខ្ញុំងើបមុខឡើងភ្នែកសម្លឹង | ឯនាយល្វើយល្វឹងទៅដល់ភ្នំ | - ១៩៥ |
| ១៣១- បពិត្រព្រះម្ចាស់ | ខ្ញុំជាមនុស្ស | - ២០១ |


## ៤- ទំនុកតម្កើងសម្រាប់អរព្រះគុណព្រះជាម្ចាស់ ៖

### ក)- បទអរព្រះគុណម្នាក់ឯង


| | | |
|---|---|---|
| ៩- បពិត្រព្រះម្ចាស់ជាទីពឹង | ទូលបង្គំនឹងលើកតម្កើង | - ១៦ |
| ១០- ឱ! ព្រះជាម្ចាស់អើយ | ហេតុអ្វីឡើយក៏ព្រះអង្គ | - ១៨ |
| ៣០- បពិត្រព្រះម្ចាស់ដ៏ឧត្តម | ទូលបង្គំសូមលើកតម្កើង | - ៤២ |
| ៣២- អ្នកដែលព្រះជាម្ចាស់ | លើកលែងទោសប្រោសប្រណី | - ៤៥ |
| ៣៤- ខ្ញុំអរព្រះគុណ | អម្ចាស់ពេកពន់ | - ៤៨ |
| ៤០- ខ្ញុំខំព្យាយាមចាំព្រះម្ចាស់ | ព្រះអង្គបានប្រោសព្រះកាណ៌ផ្ទៀង | - ៦០ |
| ៩២- បពិត្រព្រះអម្ចាស់ខ្ញុំអើយ | ទូលបង្គំនេះហើយស្មូត្រតម្កើង | - ១៣៩ |
| ១១៦- ខ្ញុំស្រឡាញ់ព្រះម្ចាស់ | ដ្បិតទ្រង់ព្រះសណ្ដាប់ខ្ញុំ | - ១៧៦ |
| ១៣៨- ខ្ញុំសូមតម្កើង | ព្រះម្ចាស់ខ្ពស់ឡើង | - ២០៨ |

### ២)- បទអរព្រះគុណរួមគ្នា


| | | | |
|---|---|---|---|
| ៦៦- | ប្រជាប្រុសស្រី | នៅលើផែនដី | - ៩២ |
| ៦៧- | ឱ! ព្រះម្ចាស់អើយសូមមេត្តា | សន្តោសករុណាដល់យើងខ្ញុំ | - ៩៤ |
| ៦៨(៥..) | ចូរច្រៀងលើកតម្កើង | ព្រះនៃយើងកុំក្រឡះ | - ៩៤ |
| ១០៧- | ចូរលើកតម្កើងព្រះ | ជាអម្ចាស់មានព្រះទ័យ | - ១៦៣ |
| ១១៨- | សូមលើកតម្កើងព្រះអម្ចាស់ | ប្រសើរពេកណាស់ព្រះទ័យថ្លៃ | - ១៧៨ |
| ១២៤- | ប្រសិនបើគ្មានព្រះអម្ចាស់ | មិនជួយសន្តោសគាំទ្រទេ | - ១៩៦ |


## ៥- ទំនុកតម្កើងសម្រាប់រំពឹងគិតអំពីប្រវត្តិសាស្ត្រ ៖


| | | | |
|---|---|---|---|
| ៧៨- | ឱ! ប្រជាជនអើយ | ខ្ញុំនេះហើយប្រៀនប្រដៅ | - ១១៣ |
| ១០៥- | ចូរយើងតម្កើង | លើកព្រះខ្ពស់ឡើង | - ១៥៥ |
| ១០៦- | ចូរលើកតម្កើងព្រះអម្ចាស់ | ព្រះអង្គមានព្រះទ័យសន្តោស | - ១៥៩ |


## ៦- ទំនុកតម្កើងសម្រាប់ទូន្មានអ្នកទូត ៖


| | | | |
|---|---|---|---|
| ៥០- | ព្រះអម្ចាស់ជាព្រះ | ប្រសើរណាស់លើសអ្វីៗ | - ៧៣ |
| ៥២- | អ្នកខ្លាំងពូកែ | ហេតុម្តេចបេះតែ | - ៧៧ |
| ៨១- | នាំគ្នាបន្លឺ | សំឡេងឲ្យឮ | - ១២២ |


## ៧- ទំនុកតម្កើងសម្រាប់ដាស់តឿនប្រជាជនឲ្យធ្វើបូជនីយសថ៍ទៅព្រះវិហារ ៖


| | | | |
|---|---|---|---|
| ១៥- | បពិត្រព្រះអម្ចាស់ | នរណាខ្លះអាចរស់កនុង | - ២២ |
| ២៤- | អ្វីៗដែលនៅលើផែនដី | កើតមកច្រើនក្រៃមីរដេរដាស | - ៣៥ |
| ៩៥- | យើងស្រែកច្រៀងឡើង | សរសើរតម្កើង | - ១៤២ |


## ៨- ទំនុកតម្កើងសម្រាប់ប្រៀនប្រដៅតាមរបៀបអ្នកសុចរិតជំនាន់ដើម ៖

### ក)- អំពីធម្មវិន័យ


| | | | |
|---|---|---|---|
| ១- | អ្នកមិនប្រព្រឹត្ត | តាមមនុស្សទុច្ចរិត | - ៩ |
| ១៩(៨..) | ព្រះធម្មវិន័យ | ល្អល្អះប្រពៃ | - ៣០ |
| ៨២- | ព្រះម្ចាស់គង់ក្នុងអង្គប្រជុំ | នៃស្ថានបរមសុខពេកក្រៃ | - ១២៣ |
| ១១៩- | អ្នកណាដែលមាន | កិរិយាជាប់ប្រាណ | - ១៨០ |

## ខ)- អំពីកិរិយាថ្លែងថ្នូររបស់មនុស្សទៀងត្រង់


| | | | |
|---|---|---|---|
| ១១២- | អ្នកឱនកោតខ្លាចព្រះអម្ចាស់ | ប្រតិបត្តិច្បាស់តាមព្រះទ័យ | - ១៧២ |
| ១៣៩- | បពិត្រព្រះម្ចាស់ដ៏សប្បុរស | ទ្រង់ឈ្វេងយល់អស់ជម្រៅចិត្ត | - ២០៩ |


## គ)- អំពីរង្វាន់ដែលព្រះជាម្ចាស់ប្រទានឲ្យមនុស្សសុចរិត


| | | | |
|---|---|---|---|
| ៣៧- | សូមកុំចងកំហឹង | ប្រណៃននឹងអ្នកប្រព្រឹត្ត | - ៥៣ |
| ៤៩- | ឱជនទាំងឡាយ | ចូរកុំខ្វល់ខ្វាយ | - ៧១ |
| ១២៨- | អ្នកណាកោតខ្លាច | គោរពអំណាច | - ១៩៩ |


**សូមបងប្អូនសូត្រ និង ច្រៀង ដើម្បីលើកតម្កើងព្រះអម្ចាស់តាមទំនុកបទ**
**ដែលមានជាបន្តបន្ទាប់ដូចតទៅ ៖**

## ទំនុកតម្កើងលេខ ១ បទភាគគតិ

១- អ្នកមិនប្រព្រឹត្ត តាមមនុស្សទុច្ចរិត មិនស្តាប់ទូន្មាន ហើយមិនចូលចិត្ត
ដើរតាមស្នាមដាន អ្នកនោះនឹងមាន មង្គលពេកក្រៃ ។
២- តែតាមការពិត ពួកគេចូលចិត្ត នឹងធម្មវិន័យ របស់ព្រះម្ចាស់
ទាំងយប់ទាំងថ្ងៃ សញ្ជឹងរំពៃ ឥតមានភ្លេចភ្លឹក ។
៣- អ្នកនោះប្រៀបបាន ដើមឈើល្អថ្កាន ដុះក្បែរផ្លូវទឹក មិនស្លោកស្រពោន
ឲ្យផលផ្លែស្លឹក ចម្រើនសន្ធឹក តាមកាលរដូវ ។
៤- រីមនុស្សអាក្រក់ មានចិត្តគម្រក់ កេរ្តិ៍ឈ្មោះអាស្រូវ ពួកគេប្រៀបបាន
អង្កាមដែលត្រូវ ខ្យល់ផាត់បើងទៅ បាចសាចខ្ចាត់ខ្ចាយ ។
៥- ថ្ងៃព្រះអម្ចាស់ វិនិច្ឆ័យទោស ជនពាលទាំងឡាយ ព្រមទាំងមនុស្សបាប
មិនស្ថិតស្ថេរឡើយ ត្រូវតែឃ្លាតឆ្ងាយ ពីអ្នកសុចរិត ។
៦- ដ្បិតព្រះអម្ចាស់ ស្គាល់ប្រាកដណាស់ មាគ៌ាប្រណីត នៃមនុស្សល្អ
ស្មោះសរសុចរិត មាគ៌ាឧក្រិដ្ឋ នាំខ្លួនអន្តរាយ ។

## ទំនុកតម្កើងលេខ ២ បទពាក្យ ៧

១- ហេតុអ្វីបានជាប្រជាជាតិ នាំគ្នាខឹងឃ្នាតកើតកង្វល់
បង្កើតវឹកវរចលាចល រអ៊ូខ្វាយខ្វល់គ្មានខ្លឹមសារ ។
២- ពួកស្តេចនៅលើភពផែនដី បះបោរពួតដៃឃុបឃិតគ្នា
ប្រឆាំងព្រះម្ចាស់ឥតរួញរា និងព្រះគ្រីស្តជាបុត្រព្រះអង្គ ។
៣- គេពោលថា ៖ «យើងទៅបំបាក់ នឹមព្រះអម្ចាស់កុំរេរង់
គ្រវែងប្រវាក់កុំបង្អង់ របស់ព្រះអង្គបោលចេញទៅ! » ។
៤- ប៉ុន្តែព្រះអម្ចាស់គ្រងរាជ្យ ពេញដោយអំណាចមិនអាស្រូវ
នាស្ថានបរមសុខគ្មានហ្មងសៅ ចំអកដាក់ទៅខ្មាំងល្ងង់ឆោត ។
៥- ព្រះអង្គមានព្រះបន្ទូលទៅ ពួកខ្មាំងសត្រូវដោយក្រេវក្រោធ
ទ្រង់ធ្វើឲ្យគេភ័យតក់ស្លុត ដោយព្រះពិរោធដូច្នេះថា ៖

| | | | |
|---|---|---|---|
| ៦- | « គឺយើងនេះហើយដែលអភិសេក | ឲ្យទៅជាស្ដេចយើងនោះណា | |
| | នៅលើស៊ីយ៉ូនភ្នំដែលជា | ទីដ៏សុខាសែនវិសុទ្ធ » | ។ |
| ៧- | ខ្ញុំនឹងថ្លែងក្រឹត្យព្រះអម្ចាស់ | មានបន្ទូលច្បាស់យ៉ាងមោះមុត | |
| | ថា៖ « ព្រះអង្គនេះពិតជាបុត្រ | ដែលយើងបង្កើតនៅថ្ងៃនេះ » | ។ |
| ៨- | បើព្រះអង្គសុំយើងនឹងផ្ដល់ | ប្រជាជាតិដល់ទ្រង់ទាំងអស់ | |
| | ឲ្យព្រះអង្គទុកជាមត៌ក | ដែនដីទាំងអស់ជាកម្មសិទ្ធិ | ។ |
| ៩- | ទ្រង់នឹងបង្ក្រាបមិនទុកទេ | ឲ្យអស់ពួកគេទើបអស់ចិត្ត | |
| | ដំបងដែកវាយជនទុច្ចរិត | កំពាចកំពិតដូចភាជន៍បែក | ។ |
| ១០- | ស្ដេចទាំងឡាយអើយឥឡូវនេះ | ចូរគិតត្រិះរិះកុំរារែក | |
| | អស់អ្នកគ្រប់គ្រងកុំអស់អែក | ត្រូវចេះបែងចែកទទួលយក | ។ |
| ១១- | នូវការអប់រំដ៏ប្រពៃ | បម្រើម្ចាស់ថ្លៃដោយចូលមក | |
| | គោរពកោតខ្លាចក្រាបលុតក្រោក | គាល់រកព្រះអង្គទាំងញាប់ញ័រ | ។ |
| ១២- | ចូរថ្វាយបង្គំព្រះរាជបុត្រ | ក្រែងទ្រង់ពិរោធនាំបង្ក | |
| | វិនាសអន្តរាយទាំងមាគ៌ា | នៃអ្នករាល់គ្នាគ្មានប្រណី | ។ |
| | ដ្បិតព្រះពិរោធនៃព្រះអង្គ | នឹងឆាបឆេះឡើងឆាប់ៗក្រៃ | |
| | អ្នកដែលជ្រកកោនក្រោមបារមី | ពិតជាមានជ័យសុភមង្គល | ។ |

## ទំនុកតម្កើងលេខ ៣ — បទបន្ទោលកាក

| | | | |
|---|---|---|---|
| ២- | ឱ! ព្រះអម្ចាស់ | សត្រូវច្រើនណាស់ជិតជុំ | |
| | អ្នកប្រឆាំងខ្ញុំ | ក៏មកមូលជុំច្រើនដែរ | ។ |
| ៣- | អ្នកខ្លះពោលថា ៖ | « អង្គម្ចាស់ក្បត្រាងាកបែរ | |
| | មិនសង្គ្រោះទេ | ទ្រង់ទុកឲ្យគេឯកា» | ។ |
| ៤- | ឱ! ព្រះអម្ចាស់ | ទ្រង់វិសេសណាស់អស្ចារ្យ | |
| | ជាខែលការពារ | ដល់ខ្ញុំនេះណាពិតណាស់ | ។ |
| | ព្រះអង្គប្រទាន | សិរីឲ្យមានត្រចះ | |
| | ហើយព្រះអង្គប្រោស | ឲ្យខ្ញុំងើបមុខវិញបាន | ។ |

| | |
|---|---|
| ៥- ខ្ញុំហៅរកព្រះ | ជាម្ចាស់អស់ពីចិត្តប្រាណ |
| ព្រះអង្គក៏បាន | តបឆ្លើយពីភ្នំឥតសល់ ។ |
| ៦- ខ្ញុំទម្រេតខ្លួន | លង់លក់សមស្ងួនស្កប់ស្កល់ |
| ភ្ញាក់ឡើងឥតខ្វល់ | ដ្បិតទ្រង់ផ្តល់ការគាំទ្រ ។ |
| ៧- ទោះបីមានមនុស្ស | លើកគញនាស្រីប្រុសឈូឆរ |
| ប្រឆាំងតបត | ក៏ខ្ញុំមិនភ័យខ្លាចដែរ ។ |
| ៨- ព្រះអម្ចាស់អើយ | សូមកុំព្រងើយងាកបែរ |
| សូមកុំកែប្រែ | មេត្តាជួយរូបខ្ញុំផង ។ |
| ព្រះអង្គមិនខ្លាច | ទ្រង់ប្រើអំណាចតែម្តង |
| បំបាក់ធ្មេញផង | ទះកំផ្លៀងខ្មាំងសត្រូវ ។ |
| ៩- ឱ! ព្រះអម្ចាស់ | ទ្រង់ពិតជាព្រះនាំផ្លូវ |
| សូមប្រទាននូវ | ព្រះពរដល់ទៅរាស្ត្រផង ។ |

## ទំនុកតម្កើងលេខ ៤ បទពាក្យ ៧

| | |
|---|---|
| ២- ឱព្រះអម្ចាស់ថ្លៃបវរ | ដែលរកយុត្តិធម៌ឲ្យយើងខ្ញុំ |
| ពេលទូលបង្គំអង្វរសុំ | សូមតបមកខ្ញុំកុំបង្អង់ ។ |
| ពេលយើងខ្ញុំមានទុក្ខធុរៈ | ព្រះអង្គថ្នមថ្នាក់មិនឲ្យឆ្គង |
| យើងបានធូរស្បើយផុតសៅហ្មង | សូមសណ្តាប់ផងដោយមេត្តា ។ |
| ៣- តើពួកមនុស្សទាំងអស់នោះ | ជាន់ឈ្លីកិត្តិយសខ្ញុំដល់ណា |
| ហើយចូលចិត្តអ្វីមិនបានការ | និយាយមុសាដល់ណាទៀត ? ។ |
| ៤- ត្រូវដឹងថាព្រះជាអម្ចាស់ | តែងប្រណីប្រោសមិនរវាត |
| ពេលខ្ញុំស្រែករកព្រះអង្គឆ្លៀត | ស្តាប់ខ្ញុំមិនឃ្លាតជាប់ជានិច្ច ។ |
| ៥- ចូរស្អប់អំពើណាអាក្រក់ | ស្មោកគ្រោកកខ្វក់មានកលល្បិច |
| កុំប្រព្រឹត្តបាបទោះច្រើនតិច | ពេលដេកកុំភ្លេចពិចារណា ។ |
| ៦- ថ្វាយយញ្ញបូជាតាមវិន័យ | ពឹងផ្អែកក្សត្រថ្លៃគ្រងលោកា |
| លះបង់ឲ្យអស់ក្តីមុសា | ថ្វាយ កាយ វាចា ចិត្ត ស្មោះត្រង់ ។ |

| | | | |
|---|---|---|---|
| ៧- | មានមនុស្សជាច្រើនតែងពោលថា | តើមាននរណានាំតម្រង់ | |
| | សុភមង្គលដ៏ត្រចង់ | ឲ្យយើងខ្ញុំផងសូមទតចុះ | ។ |
| ៨- | ព្រះអង្គបានដាក់ក្ដីអំណរ | សប្បាយអបអរចិត្តស្រស់បស់ | |
| | ជាងពេលប្រមូលផលទាំងអស់ | និងពេលប្រចូតបេះផលផ្លែផ្កា | ។ |
| ៩- | ពេលទូលបង្គំចូលដំណេក | ទូលបង្គំដេកស្កប់កាយា | |
| | ព្រះអង្គឲ្យមនុស្សក្នុងលោកា | បានសុខរមនាតទៅអើយ | ។ |

## ទំនុកតម្កើងលេខ ៥ — បទព្រហ្មគីតិ

| | | | |
|---|---|---|---|
| ២- | ឱ! ព្រះអម្ចាស់អើយ | កុំកន្តើយផ្សៀងព្រះកាណ៌ | |
| | ស្ដាប់ស័ព្ទខ្ញុំវាចា | ខ្ញុំឈឺថ្ងូរពន់ពេកក្រៃ | ។ |
| ៣- | ឱ! ព្រះជាអម្ចាស់ | ទ្រង់ជាព្រះមហាក្សត្រថ្លៃ | |
| | សូមយកព្រះហឫទ័យ | នឹងសម្រែកទូលបង្គំ | ។ |
| ៤- | នាពេលអារុណរះ | ព្រះអម្ចាស់សណ្ដាប់ខ្ញុំ | |
| | ដែលចូលមកគាល់សុំ | ពីព្រលឹមមិនទៅណា | ។ |
| ៥- | ទ្រង់មិនសព្វព្រះទ័យ | អំពើព្រៃផ្សៃឫស្យា | |
| | ជនអាក្រក់មុសា | ក្បែរភក្ត្រាព្រះអង្គឡើយ | ។ |
| ៦- | ព្រះអង្គមិនចង់ឃើញ | ជនព្រហើនចូលកៀកកើយ | |
| | មិនសព្វព្រះទ័យឡើយ | ជនណាហើយធ្វើអាក្រក់ | ។ |
| ៧- | អស់អ្នកបង្ខូរឈាម | អស់អ្នកបៀមល្បិចខ្វក់ | |
| | ពួកអ្នកភូតកុហក | បោកវិវក់វិនាសបង់ | ។ |
| ៨- | រីឯទូលបង្គំ | ចូលក្នុងដំណាក់ព្រះអង្គ | |
| | ដោយព្រះហឫទ័យទ្រង់ | សប្បុរសខ្លាំងអស្ចារ្យ | ។ |
| | រូបខ្ញុំសូមឱនក្រាប | បង្គំទាបទាំងកាយា | |
| | តម្រង់ទៅវិហារ | ដ៏វិសុទ្ធទាំងកោតខ្លាច | ។ |
| ៩- | ឱ! ព្រះជាអម្ចាស់ | មនុស្សច្រើនណាស់ឃ្លាំព្រឹកល្ងាច | |
| | សូមនាំឲ្យខ្ញុំអាច | ធ្វើតាមរាជហឫទ័យផង | ។ |

សូមជួយពង្រាបផ្លូវ ខ្ញុំដើរទៅឲ្យបានត្រង់
ជាផ្លូវនៃព្រះអង្គ នាំតម្រង់ខ្ញុំតទៅ ។

១០- អ្នកទាំងនោះស្រដី ពាក្យគ្មានន័យមិនត្រឹមត្រូវ
អណ្ដាតគ្រលាស់នូវ ពាក្យអាស្រូវដោយពិសពុល ។

១១- ឱ! ព្រះជាម្ចាស់អើយ សូមកុំឲ្យមានយោគយល់
ឲ្យវិនាសគ្មានសល់ ដោយគម្រោងការជងខ្លួន ។
ពួកគេបានប្រព្រឹត្ត រឿងទុច្ចរិតច្រើនផ្ទួនៗ
ប្រឆាំងនឹងក្សត្រខ្លួន ល្មមសមសួនកាត់កាល់ចុះ ។

១២- រីឯអ្នកជ្រកកោន ដោយថ្វាយខ្លួនសុំរួមរស់
ក្រោមបារមីសន្ដោស សូមសង្គ្រោះថែរក្សា ។

១៣- បពិត្រព្រះអម្ចាស់ ប្រាកដណាស់មានមេត្តា
ប្រទានពរថ្លៃថ្លា ដល់មនុស្សម្នាដែលសុចរិត ។
ហឫទ័យករុណា ប្រៀបឧបមាខែលជុំជិត
ការពារជនសុចរិត ឲ្យរួចផុតក្ដីសៅហ្មង ។

## ទំនុកតម្កើងលេខ ៦ បទពាក្យ ៧

២- សូមព្រះអម្ចាស់កុំពិរោធ បើទ្រង់ខ្ញាល់ក្រោធសូមដាក់ទោស
ដល់ទូលបង្គំតាមកំហុស ដែលបានធ្វើខុសកុំចាប់ថ្នាក់ ។

៣- ព្រះអម្ចាស់អើយប្រណីប្រោស ខន្តីសន្ដោសបង្គំជាក់
សូមប្រោសឲ្យជាកុំអន់អាក់ ដ្បិតកាយញ័រញាក់សែនរងា ។

៤- ក្នុងចិត្តគំនិតទាល់ថប់ធុញ តប់ប្រមល់សុញសែនវេទនា
ឱ! ព្រះអម្ចាស់សូមករុណា ឲ្យខ្ញុំឈឺជ្យាដល់ណាទៀត ។

៥- ឱ! ព្រះអម្ចាស់សូមយាងមក សង្គ្រោះមនុស្សលោកកុំរវាត
កុំឲ្យរូបខ្ញុំជួបទុក្ខទៀត កុំបីឃ្លាងឃ្លាតពីហឫទ័យ ។

៦- ពេលដែលគេស្លាប់ផុតទៅហើយ ពុំដែលមានឡើយនឹកស្រមៃ
ដល់នាមព្រះអង្គម្ចាស់ថ្លាថ្លៃ នៅនាស្ថាននៃមនុស្សស្លាប់ឡើយ ។

៧- ទូលបង្គំយំស្រែកទូញថ្ងូរ គ្មានឈប់គ្មានឈរព្ធល្ងើយៗ
រៀងរាល់ថ្ងៃយប់ទុក្ខឥតស្បើយ ទឹកភ្នែកជោកខ្នើយនៅលើគ្រែ ។
៨- ទុក្ខកង្វល់ច្រើនធ្វើឲ្យខ្ញុំ ស្លេកស្លាំងស្គមគ្មានពេលល្ហែ
ឯភ្នែកខ្ញុំក៏ស្រវាំងដែរ នេះពីព្រោះតែបច្ចាមិត្ត ។
៩- ចូរចៀសចេញចាកឆ្ងាយពីខ្ញុំ កុំពួនសំងំមនុស្សទុច្ចរិត
ដ្បិតព្រះអម្ចាស់សណ្តាប់ពិត រៀងរាល់យប់ព្រឹកខ្ញុំស្រែកយំ ។
១០- ព្រះអម្ចាស់ទ្រង់ព្រះសណ្ដាប់ ពាក្យខ្ញុំរ៉ាយរ៉ាប់ដោយក្រៀមក្រំ
ព្រះអង្គទទួលអង្វរខ្ញុំ ឥតមានបន្ទំមួយម៉ាត់សោះ ។
១១- សូមខ្មាំងសត្រូវទាំងប៉ុន្មាន ចិត្តជាតិរច្នានត្រូវអាម៉ាស់
ដកខ្លួនថយទៅទាំងអៀនខ្មាស់ ខ្វាត់ខ្វាយព្រាត់ប្រាសបាត់សោះសូន្យ ។

## ទំនុកតម្កើងលេខ ៧ បទពាក្យ ៧

២- ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ ខ្ញុំសូមពឹងហើយលើព្រះអង្គ
សង្គ្រោះរំដោះនិងទ្រទ្រង់ រួចពីអន្លង់អ្នកបៀតបៀន ។
៣- ក្រែងលោគេហែកទូលបង្គំ ដូចសត្វសិង្ហខាំដោយស្រេកឃ្លាន
នោះគ្មាននរណាអាចនឹងហ៊ាន រំដោះឲ្យបានរួចជីវិត ។
៤- ឱ! ព្រះអម្ចាស់ទូលបង្គំ ប្រសិនបើខ្ញុំបានប្រព្រឹត្ត
ដូចពាក្យគេថាដោយគ្មានគិត ប្រឡាក់ដាមជិតក្ដីកខ្វក់ ។
៥- ប្រសិនបើទូលបង្គំបាន ប្រព្រឹត្តសាមាន្យចិត្តអាក្រក់
តបនឹងមិត្តភក្តិដោយគម្រក់ រឹបអូសលួចឆក់យកទ្រព្យា ។
៦- សូមឲ្យសត្រូវខ្មាំងដេញទាន់ និងឲ្យគេជាន់ឈ្លីប្រហារ
ព្រមទាំងកិត្តិយសខ្ញុំនេះណា ទម្លាក់អាត្មាក្នុងភក់ចុះ ។
៧- ឱ! ព្រះអម្ចាស់សូមតើនឡើង ពិរោធឲ្យបើងតបចំពោះ
អំពើឃោរឃៅសត្រូវនោះ ដ្បិតអង្គសប្បុរសតែងតាំងច្បាប់ ។
៨- សូមឲ្យប្រជាជាតិនានា បោមរោមនាំគ្នាមកត្រេងត្រាប់
ជុំវិញព្រះអង្គល្អគួរគាប់ លើអស់មនុស្សសព្វសត្វនានា ។

៩- ព្រះអង្គជាចៅក្រមវិនិច្ឆ័យ ប្រជាប្រុសស្រីគ្រប់អង្គា
ព្រះអម្ចាស់អើយសូមមេត្តា រូបខ្ញុំនេះណាអ្នកស្លូតត្រង់ ។
១០- សូមឈប់ធ្វើអំពើទុច្ចរិត ជួយគាំទ្រចិត្តមនុស្សរឹងប៉ឹង
បពិត្រព្រះដ៏វិសុចរិតថ្កើង ព្រះអង្គតែងឈ្វេងយល់ចិត្តមនុស្ស ។
១១- ព្រះអង្គជាខែលការពារខ្ញុំ ទ្រង់ជួយឧបត្ថម្ភនិងសង្គ្រោះ
អ្នកដែលមានចិត្តទៀងត្រង់ស្មោះ បានភ្លឺត្រចះត្រចង់ជាក់ ។
១២- ព្រះម្ចាស់ជាចៅក្រមសុចរិត ព្រះអង្គតែងគិតដាក់ទោសអ្នក
ប្រព្រឹត្តអាក្រក់ឥតមានអាក់ គ្មាននរណាម្នាក់រួចខ្លួនទេ ។
១៣- ជនអាក្រក់មិនដូរគំនិត សំលៀងកាំបិតដាវរិះរេ
យិតធ្នូប្រុងបាញ់ប្រហារគេ ព្រៃផ្សៃម្លេះទេជនអប្រិយ៍ ។
១៤- គេនឹងរៀបចំអាវុធស្នា ដើម្បីប្រហារអ្នកដទៃ
ព្រមទាំងត្រៀមបាញ់ព្រួញភ្លើងជ័យ សម្លឹងរំពៃចាំជាស្រេច ។
១៥- អ្នកណាគិតតែពីប្រព្រឹត្ត អំពើទុច្ចរិតមួលបង្កាច់
សាងរឿងឧក្រិដ្ឋជាចំាបាច់ ចូលចិត្តសម្រេចរឿងបោកប្រាស ។
១៦- រីអ្នកដែលខំជីករណ្ដៅ ឲ្យកាន់តែជ្រៅអ្នកនោះច្បាស់
នឹងធ្លាក់ខ្លួនឯងប្រាកដណាស់ ព្រោះខ្លួនគេនោះជីកកកាយ ។
១៧- អំពើទុច្ចរិតដែលគេបាន ធ្វើមិនស្រាកស្រាន្តមិនជិនណាយ
អំពើឃោរឃៅនាំអន្តរាយ ធ្លាក់លើរូបកាយក្បាលគេពិត ។
១៨- ខ្ញុំនឹងសរសើរតម្កើងព្រះ អម្ចាស់មានហឫទ័យសុចរិត
ខ្ញុំនឹងច្រៀងលើកតម្កើងឫទ្ធិ ព្រះនាមបរិសុទ្ធខ្ពស់ឧត្ដម ។

## ទំនុកតម្កើងលេខ ៨ — បទភាកគតិ

២- ឱ! ព្រះអម្ចាស់ ព្រះអង្គជាព្រះ របស់យើងខ្ញុំ ព្រះនាមព្រះអង្គ
រុងរឿងឧត្ដម ពាសពេញជិតជុំ ផ្ទៃមេឃផែនដី ។
៣- ព្រះអង្គបានប្រើ ពាក្យកោតសរសើរ តម្កើងថ្វាថ្លៃ របស់ក្មេងៗ
និងទារកក្ដី ជាកម្លាំងជ័យ លើសត្រូវមារ ។

៤- ពេលទូលបង្គំ សម្លឹងមើលចំ ទៅផ្ទៃមេឃា មើលហ្វូងតារា
មើលព្រះចន្ទ្រា ដ៏ស្រស់សោភា ស្នាព្រះហស្តថ្លៃ ។
៥- ខ្លួនខ្ញុំសួរថា តើមនុស្សយើងណា មានឋានៈអ្វី បានជាព្រះអង្គ
នឹកគិតរំពៃ យកព្រះហឫទ័យ ទុកដាក់ដូច្នោះ? ។
៦- ព្រះអង្គប្រទាន ឲ្យមនុស្សយើងមាន កិត្តិយសខ្ពង់ខ្ពស់ ទាបជាងទេវតា
បន្តិចប៉ុណ្ណោះ ទៅដល់មនុស្ស ទុកជាមកុដរាជ្យ ។
៧- ព្រះអម្ចាស់ទ្រង់ ឲ្យគេគ្រប់គ្រង រាល់ថ្ងៃព្រឹកល្ងាច លើអ្វីទាំងអស់
ពេញដោយអំណាច ព្រមទាំងបង្ក្រាប នៅក្រោមជើងគេ ។
៨- ដោយសារអំណាច អ្វីៗមិនអាច ផ្លាស់ប្តូរប្រួលប្រែ ទាំងចៀមទាំងគោ
សត្វព្រៃផងដែរ ឲ្យមនុស្សមើលថែ ប្រើប្រាស់គ្រប់គ្រង
៩- ព្រមទាំងបក្សី នៅលើផែនដី នៅលើមេឃផង ត្រីក្នុងសមុទ្រ
សព្វសត្វតែម្តង សត្វលូនវារផង មកនៅជួបជុំ ។
១០-បពិត្រព្រះម្ចាស់ ព្រះអង្គជាព្រះ របស់យើងខ្ញុំ ព្រះនាមព្រះអង្គ
រុងរឿងឧត្តម ពាសពេញជិតជុំ ផ្ទៃមេឃផែនដី ។

## ទំនុកតម្កើងលេខ ៩ បទពាក្យ ៧

២- បពិត្រព្រះម្ចាស់ជាទីពឹង ទូលបង្គំនឹងលើកតម្កើង
និទានពីការអស្ចារ្យឡើង មានទាំងប៉ុន្មានឲ្យគេស្តាប់ ។
៣- ព្រោះតែព្រះអង្គខ្ញុំត្រេកអរ រីករាយសាទរជាដរាប
បពិត្រព្រះអង្គខ្ពស់ឥតប្រៀប សូមទ្រង់សណ្តាប់ចម្រៀងខ្ញុំ ។
៤- ពួកខ្មាំងសត្រូវដកខ្លួនថយ សូមព្រះអង្គជួយទូលបង្គំ
ឲ្យវាជំពប់ជើងដួលគ្រាំ វិនាសនៅចំពោះព្រះភក្ត្រ ។
៥- ទ្រង់រកយុត្តិធម៌ល្អថ្លៃថ្លា ឲ្យគេឃើញថារូបខ្ញុំជាក់
គ្មានទោសពៃរ៍អ្វីគួរចាប់ថ្នាក់ ក្នុងព្រះឋានៈជាចៅក្រម ។
៦- ព្រះអង្គគំរាមសាសន៍នានា ពួកមនុស្សពាលាវិនាសព្រម
កេរ្តិ៍ឈ្មោះពួកគេត្រូវរលំ ខ្ចាត់ខ្ចាយទ្រុឌទ្រោមឥតមានសល់ ។

៧- ពួកខ្មាំងសត្រូវនឹងខ្ទាត់ខ្ទាយ　　វិនាសអន្តរាយច្រើនកប្បកល្ប
ទីក្រុងនានារលាយខ្សុល　　គ្មានគេនឹកដល់ឃើញទៀតឡើយ ។
៨- ព្រះជាអម្ចាស់ឡើងគ្រងរាជ្យ　　ពេញដោយអំណាចសុខឥតស្បើយ
ឡើងគ្រងនៅលើបល្ល័ង្កហើយ　　ដើម្បីវិនិច្ឆ័យគ្រប់កិច្ចការ ។
៩- ព្រះអង្គគ្រប់គ្រងលើផែនដី　　ប្រកបដោយក្ដីសុចរិតថ្លា
ទ្រង់វិនិច្ឆ័យទោសប្រជា　　យុត្តិធម៌ឥតរាមិនអាស្រូវ ។
១០- សូមព្រះអម្ចាស់ជាបន្ទាយ　　ការពាររាងកាយអ្នកដែលត្រូវ
គេជិះគេជាន់កប់សែនជ្រៅ　　សូមការពារនៅពេលអាសន្ន ។
១១- សូមឲ្យអស់អ្នកដែលស្គាល់ព្រះ　　នាមព្រះអម្ចាស់ឆាប់រួសរាន់
ទុកចិត្តព្រះអង្គជាបន្ទាន់　　ទ្រង់មិនធុញទ្រាន់បោលអ្នកឡើយ ។
១២- ចូរនាំគ្នាច្រៀងលើកតម្កើង　　ព្រះអម្ចាស់យើងដែលគង់កើយ
នៅក្រុងស៊ីយ៉ូនណាអ្នកអើយ　　ប្រកាសប្រាប់ហើយជនទាំងឡាយ ។
១៣- ដ្បិតព្រះអង្គដាក់ទោសអ្នកដែល　　សម្លាប់គេក្រៃលឥតសោកស្ដាយ
ព្រះអង្គមិនភ្លេចក្ដីអន្តរាយ　　សម្រែកជិតឆ្ងាយជនរងគ្រោះ ។
១៤- សូមព្រះមេត្តាទូលបង្គំ　　ទតមករូបខ្ញុំដែលជាមនុស្ស
រកទុក្ខលំបាកស្ទើរមិនរស់　　ព្រោះខ្មាំងទុយ៌សមកពាធា ។
១៥- ទូលបង្គំសរសើរលើកតម្កើង　　ព្រះអង្គគ្រប់យ៉ាងនៅមាត់ទ្វារ
ទីក្រុងស៊ីយ៉ូនរាល់ទិវា　　សប្បាយគ្រប់គ្នាអរពេកពន់ ។
១៦- ប្រជាជាតិនានាធ្លាក់ទៅ　　ក្នុងរណ្ដៅជ្រៅដ៏សែនធ្ងន់
ជើងជាប់អន្ទាក់យ៉ាងទារុណ　　ដែលពួកគេបានដាក់បង្កប់ ។
១៧- ព្រះជាអម្ចាស់បានសម្ដែង　　ឲ្យដល់គេឯងបានស្គាល់សព្វ
ព្រះអង្គកាត់ទោសមិនឈរឈប់　　ឲ្យពួកគេជាប់អន្ទាក់ខ្លួន ។
១៨- សូមឲ្យពពួកជនអាក្រក់　　ជនជាតិកខ្វក់ទាំងប៉ុន្មាន
ដែលគេបំភ្លេចម្ចាស់ថ្កើងថ្កាន　　វិលរកទីស្ថានមនុស្សស្លាប់ចុះ ។
១៩- ព្រះអង្គមិនភ្លេចជនក្រក្រី　　នៅលើផែនដីនេះទាំងអស់
ឯក្ដីសង្ឃឹមដ៏ស្ម័គ្រស្មោះ　　អ្នកវេទនានោះមិនសូន្យឡើយ ។

២០- សូមកុំឲ្យមនុស្សលោកមានជ័យ　　ស៊ូវិនិច្ឆ័យកុំកន្តើយ
ដាក់ទោសប្រជាជាតិនោះហើយ　　នៅជិតបង្កើយព្រះភក្ត្រទ្រង់ ។
២១- សូមព្រះអម្ចាស់ធ្វើឲ្យគេ　　តក់ស្លុតផតរខេ្ជះខ្ចីពឹង
ឲ្យជាតិទាំងឡាយបានយល់ដឹង　　ថារូបគេហ្នឹងមនុស្សធម្មតា ។

## ទំនុកតម្កើងលេ ១០ (៩ ឥ)　　បទព្រហ្មគីតិ

១- ឱ! ព្រះជាម្ចាស់អើយ　　ហេតុអ្វីឡើយក៏ព្រះអង្គ
បាកឆ្ងាយយាងទៅគង់　　សម្ងំឈឹងដូច្នេះណា? ។
២- មនុស្សពាលតាមធ្វើបាប　　អ្នកទន់ទាបរងសោកា
គេប្រើល្បិចឫស្យា　　ឲ្យអ្នកជាជាប់អន្ទាក់ ។
៣- មនុស្សពាលតែងតែអួត　　កុហកភូតភរលួចលាក់
ពេលបានជោគជ័យជាក់　　គេចំអកដាក់ព្រះអង្គ ។
៤- ពួកគេវាយឫកខ្ពស់　　ពោលទ្រគោះដោយមិនចង់
រវល់នឹងព្រះអង្គ　　គិតលះបង់ព្រះអម្ចាស់ ។
៥- អ្វីៗដែលគេធ្វើ　　តែងប្រសើរចម្រើនណាស់
មិនដែលគិតថាព្រះ　　វិនិច្ឆ័យច្បាស់ទោសនោះឡើយ ។
៦- គេតែងនឹកគិតថា　　« អញនេះណាមាំមួនហើយ
មិនរង្កើសោះឡើយ　　ទុក្ខទាំងឡាយមិនហ៊ានបៀត » ។
៧- មាត់គាត់ជេរផ្ដាសា　　មិនបានការពាក្យបោលម្សៀត
បង្កាច់កុហកទៀត　　ស្ដែងមារយាទមិនគួររាប់ ។
៨- គេតែងពួនស្ទាក់ចាំ　　នៅក្បែរភូមិត្រៀមសន្ទាប់
គេចាំឃ្លាំមើលជាប់　　រួចសម្លាប់ជនត្រង់ស្លូត ។
៩- គេពួនដូចសត្វសិង្ហ　　សំងំឈឹងតាមគម្ពោត
ស្ទាក់ចាប់ជនទុរគត　　ទាក់ទាញព័ទ្ធចូលអន្ទាក់ ។
១០- គេក្រាបពួននៅដី　　ហើយឃ្មាតខ្មីទាញទម្លាក់
ស្ទុះចាប់មិនសល់ម្នាក់　　សាហាវជាក់គ្មានបន្ធូរ ។

១១- ជនពាលគិតថា ៖ «ព្រះ ជាអម្ចាស់មិនបារម្ភ
ព្រះនេត្របិទសំងំ មិនទតចំទាល់តែសោះ » ។
១២- ឱ! ព្រះអម្ចាស់អើយ ពេលនេះហើយកុំបង់បោះ
តើនឡើងបង្ហាញអស់ ឫទ្ធិតេជះនៃព្រះអង្គ ។
១៣- ហេតុអ្វីមនុស្សអាក្រក់ ពោលចំអកព្រះយ៉ាងហ្នឹង!
ចិត្តគេតែងរំពឹង ថា « ព្រះអង្គមិនរករឿង » ។
១៤- ព្រះអង្គទតឃើញទុក្ខ លំបាកសុខនៃមនុស្សយើង
កម្សត់អត់ទីពឹង ព្រះអង្គនឹងជួយជានិច្ច ។
មនុស្សដែលទន់ទាប ជាជរាបផ្ញើជីវិត
លើព្រះម្ចាស់ជានិច្ច ទ្រង់មិនភ្លេចជនទុរគត ។
១៥- សូមទ្រង់កាច់បំបាក់ ដៃអស់អ្នកពាលឧក្រិដ្ឋ
ដាក់ទោសពួកទុច្ចរិត ឲ្យគេឈប់ប្រព្រឹត្តពាល ។
១៦- ព្រះអម្ចាស់ជាព្រះ ខ្ពង់ខ្ពស់ណាស់ជាក្សត្រដែល
គ្រងរាជ្យអស់កល្បក្រៃល បំបាត់បោលសាសន៍ដទៃ ។
១៧- បពិត្រព្រះអម្ចាស់ ឈ្វេងយល់ច្បាស់បំណងថ្មី
នៃមនុស្សទន់ទាបក្ដី អង្គក្សត្រថ្លៃលើកទឹកចិត្ត ។
១៨- ព្រះអង្គរកយុត្តិធម៌ ឲ្យអ្នកក្រមនុស្សសុចរិត
ត្រូវគេជាន់សង្កត់ ពួកទុច្ចរិតមិនឲ្យមាន ។
មនុស្សនៅលើដែនដី ជនប្រុសស្រីទាំងប៉ុន្មាន
មិនអាចនឹងជិះជាន់ អ្នកខ្សោយអន់ទៀតបានទេ ។

## **ទំនុកតម្កើងលេខ ១១(១០)** **បទភាគតតិ**

១- ខ្ញុំបានជ្រកកោន មិនដែលស្រពោន ក្រោមម្លប់បារមី នៃព្រះអម្ចាស់
ចុះរឿងហេតុអ្វី អ្នករាល់គ្នាស្ដី ឲ្យជ្រកតាមភ្នំ ? ។
២- ជនពាលយិតធ្នូ ព្រួញខ្សែទាំងគូ បម្រុងបាញ់ផ្ដុំ ពីទីងងឹត
ដែលគេសំងំ ត្រៀមបាញ់ឲ្យចំ ពួកអ្នកត្រង់ស្មោះ ។

៣- បើសិនបើច្បាប់ ជាគ្រឹះមាំជាប់ ត្រូវរលំអស់ តើមនុស្សសុចរិត
ទាំងស្រីទាំងប្រុស ធ្វើអ្វីកើតនោះ សូមជួយរិះគិត ។
៤- ព្រះម្ចាស់គង់ក្នុង វិហារព្រះអង្គ ដ៏វិសុទ្ធពិត បល្ល័ង្ករបស់
ព្រះអង្គស្ថេរស្ថិត ឈ្វេងយល់គំនិត របស់មនុស្សលោក ។
៥- ព្រះអង្គពេញចិត្ត នឹងមនុស្សសុចរិត តែមិនព្រមយក មនុស្សកាចពាលា
ចូលចិត្តឆបោក តែងតែរិះរក ប្រព្រឹត្តឃោរឃៅ ។
៦- សូមទ្រង់ដាក់ទោស មនុស្សពាលទាំងនោះ ដោយភ្លើងសន្ធៅ មានទាំងស្ពាន់ធម៌
បង្អុរចុះទៅ មានទាំងខ្យល់ក្ដៅ បក់បោកមកដែរ ។
៧- ដ្បិតព្រះអម្ចាស់ មានហឫទ័យស្មោះ ឥតមានបែកបែរ មនុស្សទៀងត្រង់
គ្មានចិត្តវៀចវេរ នឹងបាននៅក្បែរ ឃើញភក្ត្រព្រះអង្គ ។

## ទំនុកតម្កើងលេខ ១២ (១១) បទពាក្យ ៧

២- ឱ! ព្រះអម្ចាស់សូមជួយផង មនុស្សច្រើនកន្លងសឹងលែងមាន
ក្នុងចំណោមមនុស្សរាប់សែនលាន បាត់បង់អស់គ្មានអ្នកត្រង់ស្មោះ ។
៣- ម្នាក់ៗគិតតែមួលបង្កាច់ ដាក់គ្នាមិនដាច់ឥតឈប់សោះ
ពាក្យគេនិយាយស្ទើរទាំងអស់ សុទ្ធតែបញ្ឆោះបញ្ឆៀចគ្នា ។
៤- សូមព្រះអម្ចាស់បំបិទមាត់ ដែលពោលបញ្ឆៀចកុំរួញរា
និងកាត់អណ្ដាតដែលមុសា និយាយឫស្យាយ៉ាងព្រហើន ។
៥- ពួកគេពោលថា «ដោយសារមាត់ របស់យើងពិតអ្វីក៏បាន
ជោគជ័យជរាបឥតស្រាកស្រាន្ត គ្មាននរណាហ៊ានត្រួតលើយើង» ។
៦- ពេលព្រះអង្គឃើញគេជាន់ជិះ ជនទុរគតនេះនៅនឹងជើង
និងឮសម្រែកអ្នកក្រផង ដែលទទួលរងទុក្ខលំបាក ។
ព្រះអម្ចាស់មានបន្ទូលថា «ឥឡូវនេះណាកុំកំសាក
យើងក្រោកឡើងមកជួយអស់អ្នក ដែលមនុស្សគម្រក់គេមើលងាយ » ។
៧- បន្ទូលរបស់ព្រះអម្ចាស់ គួរទុកចិត្តណាស់ពេញអង្គកាយ
បរិសុទ្ធជាងប្រាក់ភ្លឺពណ្ណរាយ ដែលដុតរំលាយប្រាំពីរដង ។

៨- ព្រះអម្ចាស់ដែលគ្រប់គ្រងវៃ ព្រះអង្គតែងតែធ្វើឥតឆ្គង
តាមព្រះបន្ទូលគ្មានសៅហ្មង ជានិច្ចសព្វដងប្រពៃពិត ។
៩- ទោះបីជនពាលដើរក្រឡឹង ទោះបីមនុស្សប្រឹងតែប្រព្រឹត្ត
អំពើទុយ៌សច្រើនឥតគិត ព្រះអង្គនៅជិតការពារខ្ញុំ ។

## ទំនុកតម្កើងលេខ ១៣ (១២) បទពំនោល

២- បពិត្រព្រះអម្ចាស់អើយ តើនៅកន្លើយ ព្រងើយនឹងខ្ញុំដល់ណា? ។
ម្ដេចនៅតែងាកភក្ត្រា ចេញពីកាយា ទូលបង្គំដល់ណាទៀត? ។
៣- តើទ្រូងខ្ញុំត្រូវចង្អៀត កង្វល់ឥតឃ្លាត ក្នុងចិត្តរហូតដល់ណា? ។
តើចិត្តខ្ញុំត្រូវខ្លោចជ្យា កើតក្ដីទុក្ខា អាត្មាព្រួយដល់អង្កាល់? ។
តើខ្មាំងមានប្រៀបផ្ទាញ់ផ្ទាល លើខ្ញុំអង្កាល់ ទើបស្រាលនឹងបានល្ហែល្ហើយ? ។
៤- ឱ! ព្រះជាអម្ចាស់អើយ សូមទតហើយឆ្លើយ ចម្លើយមកទូលបង្គំ ។
សូមមេត្តាប្រោសឲ្យខ្ញុំ ឃើញពន្លឺចំ សូមកុំទុកខ្ញុំឲ្យស្លាប់ ។
៥- ក្រែងខ្មាំងសត្រូវបង្អាប់ ថា៖ អញសម្លាប់ អញចាប់បានឈ្នះវាហើយ» ។
ពួកសត្រូវឥតកន្តើយ ត្រេកអរសប្បាយ ព្រោះតែខ្ញុំបរាជ័យ ។
៦- ចំពោះរូបខ្ញុំឃ្មៀតខ្មី ទុកចិត្តហឫទ័យ ប្រណីរបស់ព្រះអង្គ ។
សូមឲ្យខ្ញុំត្រេកអរផង ពីព្រោះព្រះអង្គ បានសង្គ្រោះទូលបង្គំ ។
សូមឲ្យខ្ញុំច្រៀងរងំ សរសើរឧត្ដម ដល់ខ្ញុំព្រះអង្គប្រណី ។

## ទំនុកតម្កើងលេខ ១៤ (១៣) បទកាកគតិ

១- ពួកមនុស្សលេលា គេតែងនាំគ្នា គិតថាគ្មានព្រះ ចូលចិត្តប្រព្រឹត្ត
ជោកទាបផ្ដេសផ្ដាស គួរស្អប់ខ្ពើមណាស់ គ្មានអ្នកល្អសោះ ។
២- ព្រះម្ចាស់ទតមក មើលមនុស្សលោក ឥតមានចន្លោះ ក្រែងមានអ្នកណា
មានប្រាជ្ញាខ្ពស់ ហើយមានចិត្តស្មោះ ស្វែងរកព្រះអង្គ ។
៣- ពួកគេសុទ្ធតែ វង្វេងបែកបែរ ឥតមានស្មោះត្រង់ រួមគ្នាប្រព្រឹត្ត
ទុច្ចរិតយង់ឃ្នង សូម្បីម្នាក់ផង ក៏គ្មានល្អដែរ ។

៤- មនុស្សដែលប្រព្រឹត្ត អំពើទុច្ចរិត ឥតមានទំនេរ តើពួកទាំងនោះ
ឆោតល្ងង់ឬទេ រកស៊ីព្រោះតែ កឹបកែប្រជា ។
៥- ពួកគេភ័យញ័រ ព្រោះព្រះបវរ គាំទ្រមនុស្សម្នា ជាអ្នកសុចរិត
ស្មោះត្រង់ល្អជា ព្រះម្ចាស់ជានា មិនឲ្យភ័យស្លុត ។
៦- អ្នករាល់គ្នាឲ្យ អ្នកក្រទន់ខ្សោយ និងជនទុរគត បាត់ក្ដីសង្ឃឹម
ភិតភ័យរន្ធត់ តែព្រះមានឫទ្ធិ ជាជម្រកគេ ។
៧- សូមព្រះអង្គដែល គង់នៅជាខែល សង្គ្រោះកុំរេ ជួយអ៊ីស្រាអែល
កុំនៅទំនេរ រំដោះពួកគេ ត្រឡប់ទៅស្រុក ។
ពូជលោកយ៉ាកុប ត្រេកអរឥតឈប់ រួចពីទោសទុក្ខ ពូជអ៊ីស្រាអែល
ជួបតែក្ដីសុខ ពីនេះទៅមុខ សប្បាយពេកហោង ។

## ទំនុកតម្កើងលេខ ១៥ (១៤) បទព្រហ្មគីតិ

១- បពិតព្រះអម្ចាស់ នរណាខ្លះអាចរស់ក្នុង
ព្រះពន្លាព្រះអង្គ ស្ថិតនៅលើភ្នំវិសុទ្ធ ។
២- គឺមានតែមនុស្ស ដែលគ្មានទោសនិងប្រព្រឹត្ត
អំពើសុចរិត និយាយពិតជាដរាប ។
៣- គេមិននិយាយមួល បង្កាច់ផ្ដួលមិនធ្វើបាប
បងប្អូនដែលទន់ទាប មិនបង្អាប់កិត្តិយស ។
៤- គេមិនរាប់រកអ្នក ដែលព្រះម្ចាស់មិនស្ម័គ្រស្មោះ
តែគេលើកកិត្តិយស អ្នកគោរពកោតព្រះអង្គ ។
បើគេសន្យាអ្វី ឬទោះបីខូចខាតបង់
ក៏គេមិនបង្វង់ គេគោរពពាក្យសម្ដី ។
៥- បើមាននរណាម្នាក់ មករកប្រាក់គេឲ្យខ្ចី
មិនចង់បានកំរៃ ច្រើនតិចក្ដីគេមិនយក ។
អ្នកប្រព្រឹត្តដូច្នេះ ជាមនុស្សបេះអាចចូលជ្រក
ក្រោមបារមីរៀងមក នឹងបានសុខជានិរន្តរ ។

## ទំនុកតម្កើងលេខ ១៦ (១៥) បទពាក្យ ៧

១- ឱ! ព្រះជាម្ចាស់ដ៏ឧត្ដម សូមការពារខ្ញុំឲ្យសុខសាន្ដ
ដ្បិតទូលបង្គំសុំផ្ញើប្រាណ ជ្រកក្រោមទីស្ថានម្លប់បារមី ។
២- ខ្ញុំសូមទូលថ្វាយព្រះម្ចាស់ថា ព្រះអង្គពិតជាអម្ចាស់ថ្លៃ
ក្រៅពីព្រះអង្គឥតមានអ្វី ផ្ដល់មង្គលជ័យគ្រាអាសន្ន ។
៣- អារុក្ខអារក្សអ្នកតាព្រៃ ម្ចាស់ទឹកម្ចាស់ដីកាលពីមុន
ដែលខ្ញុំពេញចិត្តខ្លាំងពេកពន់ ផ្ដល់តែទារុណរាល់វេលា ។
៤- ទូលបង្គំនឹងមិនចូលរួម មិនទទួលព្រមរួមជាគ្នា
គោរពនិងថ្វាយយញ្ញបូជា មិនពោលនាមាព្រះក្លែងក្លាយ ។
៥- បពិត្រព្រះអម្ចាស់ឧត្ដម ព្រះអង្គជាចំណែកស្រស់ស្រាយ
មត៌កនៃខ្ញុំឥតក្លែងក្លាយ ផ្ដល់អ្វីទាំងឡាយតាមប្រាថ្នា ។
៦- ព្រះអង្គប្រទានកេរមត៌ក វិសេសឥតអាក់ដ៏ថ្លៃថ្លា
មកទូលបង្គំខ្ញុំនេះណា ជាកេរអស្ចារ្យប្រសើរផុត ។
៧- ខ្ញុំសូមតម្កើងព្រះអម្ចាស់ ព្រោះព្រះអង្គនេះសែនមោះមុត
ទ្រង់ផ្ដល់យោបល់ខ្ញុំម្នាក់គត់ ទោះយប់ងងឹតក៏តឿនដែរ ។
៨- ខ្ញុំនឹកដល់ព្រះអម្ចាស់ជាប់ ដែលជាទម្លាប់ទ្រង់គង់ក្បែរ
ខាងស្ដាំរូបខ្ញុំឥតប្រួលប្រែ ខ្ញុំមិនបែកបែរញាប់ញ័រឡើយ ។
៩- ហេតុនេះបានជាខ្ញុំរីករាយ ត្រេកអរសប្បាយបានល្ហែល្ហើយ
ខ្ញុំបានសម្រាកកាយធូរស្បើយ ដោយសុខសាន្ដហើយផុតកង្វល់ ។
១០- ដ្បិតព្រះអង្គមិនបោះបង់ខ្ញុំ ឲ្យរងទុក្ខធំស្លាប់សោតសល់
ព្រះអង្គក៏មិនបណ្ដោយដល់ សពបម្រើផ្ទាល់ស្អុយរលួយ ។
១១- ព្រះអង្គបង្ហាញផ្លូវជីវិត ឲ្យខ្ញុំឃើញពិតគ្មានភ័យព្រួយ
ដោយព្រះអង្គគង់នៅជាមួយ ទូលបង្គំគ្មានព្រួយអរសប្បាយ ។
ដោយព្រះអង្គគង់នៅខាងស្ដាំ ជាប់ជាប្រចាំមិនជិនណាយ
ទូលបង្គំសែនរីករាយសប្បាយ អស់កល្បវែងឆ្ងាយតរៀងទៅ ។

## ទំនុកតម្កើងលេខ ១៧ (១៦) បទពាក្យ ៧

១- ឱ! ព្រះអម្ចាស់សូមសណ្ដាប់ ទូលបង្គំប្រាប់សំណូមពរ
ដីល្អត្រឹមត្រូវស្រស់បវរ សូមរកយុត្តិធម៌ឲ្យរូបខ្ញុំ ។
សូមយកព្រះហឫទ័យវែកញែក និងសូរសម្រែកទូលបង្គំ
សូមផ្ទៀងព្រះកាណ៌ស្ដាប់ពាក្យខ្ញុំ ដែលអង្វរសុំដោយត្រង់ស្មោះ ។
២- សូមរកយុត្តិធម៌ឲ្យខ្ញុំផង កុំបីសៅហ្មងឬបង់បោះ
សូមព្រះអង្គទតឲ្យច្បាស់ចុះ អ្វីទៅដែលខុសអ្វីត្រឹមត្រូវ ។
៣- ព្រះអង្គឈ្វេងយល់ចិត្តខ្ញុំច្បាស់ ហើយព្រះអង្គត្រាស់ពិនិត្យនូវ
ល្បងលចិត្តខ្ញុំទាំងយប់ជ្រៅ មិនឃើញអាស្រូវឬឆ្គាំឆ្គង ។
៤- ទូលបង្គំខំយកចិត្តទុកដាក់ តាមបន្ទូលដាក់ព្រះអង្គផង
ហើយប្រព្រឹត្តខ្លួនមិនឲ្យហ្មង ដូចមនុស្សយង់ឃ្នងឯទៀតឡើយ ។
៥- ទូលបង្គំខំដើរតាមមាគ៌ា នៃអង្គក្សត្រាខ្ជាប់ខ្ជួនហើយ
ក៏បោះជំហានដើរតាមក្រោយ មិនឲ្យថ្លោះធ្លោយលំអៀងបែរ ។
៦- ឱព្រះអម្ចាស់នៃខ្ញុំអើយ ខ្ញុំស្រែកដង្ហោយមិនប្រួលប្រែ
ហៅរកព្រះម្ចាស់មិនបែកបែរ សូមកុំងាករេផ្ទៀងព្រះកាណ៌ ។
៧- ព្រះអង្គតែងតែសង្គ្រោះអ្នក ដែលមកជ្រកស្នាក់ដោយមេត្តា
ក្រោមម្លប់បារមីដ៏អស្ចារ្យ ឲ្យរួចពីការគាបសង្កត់ ។
៨ - សូមថែរក្សាទូលបង្គំ ដូចកែវភ្នែកកុំឲ្យបង់បាត់
ការពារខ្ញុំដូចបក្សីសត្វ ក្រុងកូនកម្បត់របស់វា ។
៩- សូមកុំឲ្យពួកមនុស្សពាល ចាក់រុកឆ្កិះឆ្កៀលខ្ញុំវេទនា
កុំឲ្យពួកខ្មាំងមកទាមទារ ក្រសោបប្រហាររូបខ្ញុំឡើយ ។
១០- ពួកគេគ្មានចិត្តត្រាប្រណី មាត់ចេចេញស្ដីពាក្យជម្លើយ
អួតបំប៉ោងខ្លួនគ្មានកោះត្រើយ ព្រះអង្គម្ចាស់អើយមិនអៀនខ្មាស ។
១១- ពេលដែលពួកគេដេញតាមទាន់ គេនឹងដើរជាន់ខ្ញុំអាម៉ាស់
សំឡក់សម្លឹងខ្ញុំខ្លាំងណាស់ បម្រុងព្រលះជីវិតបង់ ។

១២- ចិត្តរបស់គេសែនឃោឃៅ កំណាចអាស្រូវដូចសត្វសិង្ហ
ដែលតែងតែពួនចាំរំពឹង សំងំសម្លឹងចាប់រំពា ។
១៣- ឱព្រះម្ចាស់អើយសូមតើនឡើង ឲ្យសត្រូវបើងកុំរួញរា
សូមយកព្រះខ័នមកការពារ រំដោះខ្ញុំពីជនទុរយស ។
១៤- សូមប្រើអំណាចឫទ្ធិចេស្តា ដេញតាមប្រហារដោយតេជះ
ដាក់ទោសពួកគេកុំស្រណោះ ឲ្យអន្តរាយអស់ដល់កូនចៅ ។
១៥- ចំពោះខ្ញុំវិញគឺប្រព្រឹត្ត តាមក្ដីសុចរិតមិនអាស្រូវ
ខ្ញុំឃើញព្រះភក្ត្រទ្រង់គង់នៅ ទើបផុតហ្មងសៅពេលភ្ញាក់ឡើង ។

## ទំនុកតម្កើងលេខ ១៨ (១៧) បទព្រហ្មគីតិ

២- ឱ! ព្រះអម្ចាស់អើយ ខ្ញុំកោតហើយលើកព្រះអង្គ
ព្រោះទ្រង់ជាកម្លាំង របស់ខ្ញុំធំមាំមួន ។
៣- ព្រះម្ចាស់ជាថ្មដា រឹងអស្ចារ្យខ្ញុំលាក់ខ្លួន
ជាខែលមាំបាំហួន ខ្ញុំរួចខ្លួនមានជោគជ័យ ។
៤- ពេលខ្ញុំស្រែកដង្ហោយ ព្រះម្ចាស់ជួយឲ្យផុតភ័យ
ផុតពីខ្មាំងចង្រៃ សូមលើកដៃថ្កើងព្រះអង្គ ។
៥- ក្ដីស្លាប់រួបរឹតខ្ញុំ ដូចទឹកធំហូរតម្រង់
កួចឆក់មិនបង្អង់ អន្តរាយបង់សូន្យឥតអាក់ ។
៦- ក្ដីស្លាប់បានរួមរិត ខ្ញុំសែនភិតភ័យញ័រញាក់
ដូចចូលក្នុងអន្ទាក់ ដែលគេដាក់ចង់ប្រល័យ ។
៧- នៅពេលខ្ញុំកើតទុក្ខ ខ្ញុំស្រែករកព្រះម្ចាស់ថ្លៃ
ទ្រង់សណ្ដាប់សម្ដី ដោយមេត្រីវិហារ ។
សំឡេងរបស់ខ្ញុំ លាន់រងំឮខ្ទ័រខ្ទារ
ទៅប៉ះដល់ព្រះកាណ៌ ក្នុងសោតាព្រះម្ចាស់ខ្ញុំ ។
៨- ផែនដីកក្រើកញ័រ លាន់ខ្ទារខ្ទ័រគ្រប់ជ្រោយជ្រុង
ភ្នំក៏មិនគង់វង្ស ព្រោះព្រះអង្គខ្ញាល់ពេកក្រៃ ។

៩- ផ្សែងចេញពីនាសា　　អង្គក្សត្រាព្រះម្ចាស់ថ្លៃ
ភ្លើងឆេះច្រើនឥតបី　　ច្រើនពេកក្រៃពីព្រះឱស្ឋ ។
១០- ព្រះអង្គផ្អៀងមេឃា　　រួចម្ទីម្នាទ្រង់យាងចុះ
មានទាំងពពកក្រាស់　　ពណ៌សក្បុសទ្រាប់បាទា ។
១១- គង់លើខេរ៉ូប៊ីន　　ដែលជាយានហោះម្ទីម្នា
ទ្រង់យកវាយោជា　　យានបក្សានៃក្សត្រថ្លៃ ។
១២- ហើយយកភាពងឹត　　មកបាំងបិទស្នាក់អាស្រ័យ
ពពកខ្មៅក្រាស់ក្រៃ　　ទ្រង់លកលៃជាពន្លា ។
១៣- ផ្លេកបន្ទោរបែងបាំង　　ពីមុខទ្រង់ភ្លឺមហិមា
ធ្លាក់ព្រឹលសែនរងារ　　លើពសុជាមានភ្លើងធ្លាក់ ។
១៤- ព្រះអម្ចាស់ធ្វើឲ្យ　　មេឃរញ្ជួយផ្គរឥតអាក់
ព្រះដ៏ខ្ពស់ផុតថ្នាក់　　សូរសៀងធ្លាក់ពីលើមក ។
១៥- ទ្រង់បាញ់ព្រួញតម្រង់　　ទៅលើខ្មាំងច្រើនគរគោក
បាញ់ផ្លេកបន្ទោរមក　　ខ្ទេចជម្រកបាក់ទ័ពអស់ ។
១៦- បពិត្រព្រះអម្ចាស់　　បន្ទូលច្បាស់ដូចខ្យល់ព្យុះ
ឲ្យបាតសមុទ្រផុស　　ហើយលេចគ្រឹះផែនដីមក ។
១៧- ព្រះអង្គលាតព្រះហស្ត　　ពីស្ថានខ្ពស់បីទ្រយក
ស្រង់ខ្ញុំឲ្យរួចមក　　ពីរលកសមុទ្រជ្រៅ ។
១៨- ព្រះអង្គបានរំដោះ　　ឲ្យផុតគ្រោះផុតសត្រូវ
ផុតពីមនុស្សឃោរឃៅ　　មនុស្សកម្ហៅខ្លាំងជាងខ្ញុំ ។
១៩- ពេលមានទុក្ខវេទនា　　គេនាំគ្នាចងគំនុំ
គេវាយប្រហារខ្ញុំ　　ព្រះឧត្តមជួយការពារ ។
២០- ព្រះអង្គនាំខ្ញុំផុត　　ក្តីតក់ស្លុតទុក្ខគ្រាំគ្រា
រំដោះផុតវេទនា　　ទ្រង់គាំពារទូលបង្គំ ។
២១- ព្រះអម្ចាស់ប្រព្រឹត្ត　　តាមសុចរិតរបស់ខ្ញុំ
តបមកទូលបង្គំ　　ស្របតាមខ្ញុំដែលបរិសុទ្ធ ។

២២- ដ្បិតខ្ញុំបានប្រណិប័តន៍ យ៉ាងទៀងទាត់ល្អបំផុត
តាមមាគ៌ាមោះមុត តែមួយគត់នៃព្រះអង្គ ។

២៣- ខ្ញុំប្រព្រឹត្តវិន័យ ល្អឥតបីហើយស្មោះត្រង់
តាមមាគ៌ាព្រះអង្គ មិនបោះបង់បទបញ្ញា ។

២៤- ខ្ញុំគ្មានក្តីសៅហ្មង ឥតមានឆ្គងឥតវេរា
ប្រយ័ត្នខ្លួនការពារ ឲ្យល្អជាគ្មានកំហុស ។

២៥- ព្រះអម្ចាស់ប្រណី តាមសេចក្តីសុចរិតស្មោះ
អំពើខ្ញុំទាំងអស់ បែបជាមនុស្សបរិសុទ្ធ ។

២៦- បពិត្រព្រះអម្ចាស់ ហឫទ័យស្មោះត្រង់បំផុត
អ្នកដែលគ្មានពុតត្បុត ចិត្តបរិសុទ្ធស្មោះសរក្រៃ ។

២៧- ចំពោះអ្នកមានចិត្ត បរិសុទ្ធតាមព្រះទ័យ
ចំពោះមនុស្សអប្រីយ៍ ព្រះអង្គលៃប្រើកល្បិច ។

២៨- ព្រះអង្គជួយសង្គ្រោះ មនុស្សទាំងអស់គ្មានកលកិច្ច
បន្ទាបជាន់ពន្លិច មនុស្សមានល្បិចចិត្តឆ្មើងឆ្មៃ ។

២៩- បពិត្រព្រះម្ចាស់អើយ ព្រះអង្គហើយគឺរង្សី
ពន្លឺភ្លឺពេកក្រៃ មានសិរីជុតងងឹត

៣០- ទ្រង់ប្រទានកម្លាំង ឲ្យឈ្នះខ្មាំងដែលជុំជិត
ហើយទូលបង្គំពិត ជាលោតផុតកំពែងក្រុង ។

៣១- មាគ៌ាព្រះអម្ចាស់ សែនល្អល្អះច្បាស់យល់យង់
បន្ទូលពិតទាំងស្រុង ជាខែលរងរាំងការពារ

៣២- មានតែព្រះអម្ចាស់ ដែលជាព្រះពិតសត្យា
គ្មានព្រះដទៃឯណា ជាថ្មដាឲ្យជ្រកសោះ ។

៣៣- ទ្រង់ប្រទានកម្លាំង ឲ្យខ្ញុំខ្លាំងក្លាមុតមោះ
មាគ៌ាខ្ញុំទាំងអស់ ឥតមានទាស់សោះឡើយណា ។

៣៤- ព្រះអម្ចាស់ប្រទាន ឲ្យខ្ញុំមានល្បឿនអស្ចារ្យ
ដូចក្តាន់ក្នុងព្រៃក្បា ខ្ញុំយាត្រាឈរទីខ្ពស់ ។

| | | |
|---|---|---|
| ៣៥- ព្រះអង្គបានបង្ហាត់ | ខ្ញុំឲ្យស្ទាត់បេះទាំងអស់ | |
| ធ្វើសឹកក៏មិនទាស់ | ជំនាញខ្ពស់ឃើតធ្នូបាន | ។ |
| ៣៦- បពិត្រព្រះអម្ចាស់ | ប្រពៃណាស់ការពារប្រាណ | |
| សង្គ្រោះឲ្យថ្កើងថ្កាន | រស់សុខសាន្តដោយបារមី | ។ |
| ព្រះអង្គគាំទ្រខ្ញុំ | ទូលបង្គំដោយប្រពៃ | |
| លើកឡើងខ្ពង់ខ្ពស់ក្រៃ | ដោយហឫទ័យមានមេត្តា | ។ |
| ៣៧- ព្រះអង្គប្រោសប្រទាន | ឲ្យខ្ញុំមានល្បឿនអស្ចារ្យ | |
| មិនឲ្យខ្មាំងឫស្យា | ដេញអាត្មាភ្លាត់ជើងឡើយ | ។ |
| ៣៨- ខ្ញុំដេញតាមពួកខ្មាំង | ចាប់ឃុំឃាំងមិនកន្តើយ | |
| កម្ទេចពួកវាហើយ | មិននៅឡើយវិលទីស្ថាន | ។ |
| ៣៩- ខ្ញុំកម្ទេចពួកវា | ឲ្យវេទនាងើបមិនបាន | |
| ដេកដួលស្លាប់ទាំងប្រាណ | ដូចតិរច្ឆានក្រោមជើងខ្ញុំ | ។ |
| ៤០- ព្រះអង្គបានប្រទាន | ឲ្យខ្ញុំមានកម្លាំងមាំ | |
| តយុទ្ធមិនបាច់ខំ | ជោគជ័យធំឈ្នះសត្រូវ | ។ |
| ៤១- ទ្រង់ឲ្យគេបាក់ទ័ព | រត់ទៅស្លាប់សែនអាស្រូវ | |
| អ្នកប្រឆាំងអស់ផ្លូវ | មិនឲ្យនៅវិនាសសូន្យ | ។ |
| ៤២- គេស្រែករកជំនួយ | គ្មានអ្នកជួយមុខស្រពោន | |
| ព្រះម្ចាស់ក៏លាក់ខ្លួន | សំងំពួនមិនតបឆ្លើយ | ។ |
| ៤៣- ទូលបង្គំកម្ទេច | មិនឲ្យគេចផុតរួចឡើយ | |
| ដូចខ្យល់បក់រួចហើយ | បោសខ្ចាត់ខ្ចាយជ្រាំតាមផ្លូវ | ។ |
| ៤៤- ព្រះអង្គជួយរំដោះ | ផុតពីគ្រោះកាចអាស្រូវ | |
| ហើយទ្រង់ត្រួសត្រាយផ្លូវ | តែងតាំងនូវទូលបង្គំ | ។ |
| ធ្វើជាអ្នកដឹកនាំ | ឲ្យរឹងមាំផុតទុក្ខធំ | |
| ប្រជាមកមូលផ្តុំ | ចុះចូលខ្ញុំជាប្រញាប់ | ។ |
| ៤៥- ជនបរទេសនាំគ្នា | មកម្នីម្នាប្រុងចាំស្តាប់ | |
| តាមពាក្យខ្ញុំបង្គាប់ | ដូចកូនត្រាប់តាមមាតា | ។ |

| | | |
|---|---|---|
| ៤៦- | បរទេសបាក់ទឹកចិត្ត | សែនភ័យភិតខ្លាចមរណា |
| | ភ័យញាប់ញ័រកាយា | ចេញអាត្មាពីជីរក ។ |
| ៤៧- | ជយោ! ព្រះជាម្ចាស់ | ព្រះអង្គច្បាស់មានជ័យជោគ |
| | ជាថ្មដែលយើងជ្រក | យើងរត់រកការសង្គ្រោះ ។ |
| ៤៨- | ឲ្យរូបទូលបង្គំ | មានជ័យធំដឹមុតមោះ |
| | ព្រះអង្គបង្ក្រាបអស់ | ជនទាំងនោះឲ្យចូលចុះ ។ |
| ៤៩- | ទ្រង់ប្រោសទូលបង្គំ | ផុតទុក្ខធំសត្រូវអស់ |
| | ហើយលើកឲ្យបានខ្ពស់ | រួចរំដោះផុតបច្ចា ។ |
| ៥០- | ហេតុនេះទូលបង្គំ | សូមប្រណម្យអង្គក្សត្រា |
| | កណ្តាលសាសន៍នានា | លើកនាមាព្រះអង្គថ្លៃ ។ |
| ៥១- | ព្រះអង្គប្រោសឲ្យអ្នក | ដែលទ្រង់ស្ម័គ្រឲ្យមានជ័យ |
| | ជម្នះយ៉ាងប្រពៃ | ដែលល្បាញល្បីដ៏អស្ចារ្យ ។ |
| | ទ្រង់មានហឫទ័យស្មោះ | ស្ម័គ្រចំពោះព្រះគ្រីស្តណា |
| | បាក់ប្រេងលើសិរសា | ទាំងវង្សាស្តេចដាវីឌ ។ |

## ទំនុកតម្កើងលេខ ១៩ (១៨) — បទភាកគតិ

| | | | | |
|---|---|---|---|---|
| ២- | ផ្ទៃមេឃថ្លាថ្លែង | រុងរឿងស្ញប់ស្ញែង | របស់ព្រះម្ចាស់ | អាកាសវេហាស៍ |
| | ក៏បានប្រកាស | ពីស្នាព្រះហស្ត | របស់ព្រះអង្គ | ។ |
| ៣- | ថ្ងៃមួយពោលប្រាប់ | ថ្ងៃមួយទៀតស្តាប់ | មិនទៅវេរង់ | យប់មួយទៀតប្រាប់ |
| | យប់ជ្រៀងឲ្យដឹង | អំពីដំណឹង | ល្បីល្បាញអស្ចារ្យ | ។ |
| ៤- | មិនប្រើសម្តី | មិនបារសេចក្តី | ឬប្រើភាសា | ហើយក៏មិនចេញ |
| | សូរស័ព្ទវាចា | បន្តិចឡើយណា | ឲ្យគេដឹងឮ | ។ |
| ៥- | ដំណឹងទាំងនោះ | ឮឆ្ងាយសាយសុះ | ពេញពាសវន្ទី | លើភពផែនដី |
| | ទីងងឹតភ្លឺ | លាន់ល្បីរន្ទឺ | គ្មានសល់ចន្លោះ | ។ |
| ៦- | ព្រះអាទិត្យរះ | ផ្តល់ពន្លឺច្បាស់ | ដូចកូនកំលោះ | ចេញមកក្រោបផ្ទឹម |
| | សែនសង្ហាស្រស់ | ដូចវីរបុរស | ដ៏ខ្លាំងពូកែ | ។ |

៧- ព្រះអាទិត្យក៏ យាត្រាបន្ត មិននៅអស់អែ ពីជើងមេឃម្ខាង
ទៅម្ខាងទៀតដែរ គ្មានអ្វីបំបែរ កម្ដៅនោះបាន ។
៨- ព្រះធម្មវិន័យ ល្អល្អះប្រពៃ ប្រសើរថ្កើងថ្កាន ផ្ដល់កម្លាំងចិត្ត
ឥតមានស្រាកស្រាន្ត អ្នកល្ងង់ប្រែប្រាណ ជាមានប្រាជ្ញា ។
៩- បញ្ញារបស់ ព្រះម្ចាស់ទាំងអស់ ត្រឹមត្រូវសត្យា ឲ្យចិត្តអំណរ
សប្បាយក្រៃណា បំភ្លឺចិន្ដា ថ្លៃថ្លាត្រចង់ ។
១០- ការគោរពកោត ព្រះអម្ចាស់លោត វិសេសយល់យង់ ស្ថិតស្ថេរចិរកាល
តទៅគង់វង្ស ការវិនិច្ឆ័យទ្រង់ ក៏ត្រង់ត្រឹមត្រូវ ។
១១- គួរឲ្យប្រាថ្នា ចង់បានណាស់ណា ជាងមាសឆ្អិនឆ្អៅ ផ្អែមជាងទឹកឃ្មុំ
ខែចែត្រខែក្ដៅ ហូរជោរចេញទៅ ចាកពីបង្គង ។
១២-ព្រះធម្មវិន័យ បំពេញសេចក្ដី ខ្ញុំភ្លឺឥតហ្មង ខ្ញុំអ្នកបម្រើ
របស់ព្រះអង្គ ធ្វើតាមគ្មានឆ្គង បានផលប្រណីត ។
១៣-គ្មាននរណាម្នាក់ ឃើញកំហុសជាក់ ដែលខ្លួនប្រព្រឹត្ត ដោយអចេតនា
មិនបាននិះគិត សូមទ្រង់អាណិត លើកលែងទោសា ។
១៤- សូមការពារខ្ញុំ ឲ្យរួចទុក្ខធំ អំនួតឫស្យា សូមកុំឲ្យចិត្ត
អួតអាងអាត្មា សោយរាជ្យត្រួតត្រា លើទូលបង្គំ ។
១៥- ទ្រង់ជាថ្មដា ជាព្រះរក្សា ការពាររូបខ្ញុំ សូមប្រោសប្រណី
តាមពាក្យទូលសុំ សេចក្ដីនៃខ្ញុំ ចំពោះព្រះអង្គ ។

## ទំនុកតម្កើងលេខ ២០ (១៩) បទពាក្យ ៧

២- សូមព្រះអម្ចាស់ជួយតបឆ្លើយ ទៅនឹងចម្លើយព្រះករុណា
សូមនឹកនាមព្រះយ៉ាកុបណា ជួយថែរក្សាការពារស្ដេច ។
៣- សូមព្រះអង្គជួយព្រះរាជា ពីព្រះវិហារឲ្យសម្រេច
គាំទ្រករុណាដែលជាស្ដេច ឲ្យបានសម្រេចពីស៊ីយ៉ូន ។
៤- សូមទ្រង់នឹកឃើញផលតង្វាយ ដែលរាជាថ្វាយកុំសោះសូន្យ
ឲ្យគាប់ហឫទ័យកុំស្រពោន រាជាបញ្ជូនមកបូជា ។

៥- សូមទ្រង់ប្រទាននូវអ្វីៗ ដែលមហាក្សត្រថ្លៃប៉ងប្រាថ្នា
ឲ្យសម្រេចតាមគម្រោងការ សូមព្រះករុណាបានជោជជ័យ ។
៦- យើងនាំគ្នាសើចហ៊ោរសប្បាយ សំណើចក្អាកក្អាយគ្មានព្រួយភ័យ
នាំគ្នាជួយលើកជងទង់ជ័យ ក្នុងនាមម្ចាស់ថ្លៃព្រះខ្ពង់ខ្ពស់ ។
៧- ឥឡូវនេះខ្ញុំបានដឹងច្បាស់ ថាព្រះអម្ចាស់ព្រះសង្គ្រោះ
បាក់ប្រេងអភិសេកព្រះគ្រីស្តនោះ បានថ្កើងកថ្កានខ្ពស់ឆ្ពោះបរមសុខ ។
៨- អ្នកខ្លះពឹងផ្អែករទេះច្បាំង ខ្លះពឹងកម្លាំងសេះនាំមុខ
រីឯយើងវិញបានក្តីសុខ ព្រោះតែយើងទុកចិត្តព្រះម្ចាស់ ។
៩- ពួកគេបាក់ទ័ពបរាជ័យ ដេកដួលនៅដីរត់ព្រាត់ប្រាស
រីឯយើងវិញមាំមួនណាស ជំហរឈរច្បាស់យ៉ាងរឹងប៉ឹង ។
១០- សូមព្រះជាម្ចាស់ជួយសង្គ្រោះ ព្រះរាជានោះមានលំនឹង
សំឡេងយើងខ្ញុំរកទីពឹង សូមទ្រង់ឆ្លើយវិញកុំបីខាន ។

## ទំនុកតម្កើងលេខ ២១ (២០) បទកាកគតិ

២- បពិត្រអម្ចាស់ រាជាអរណាស់ ព្រោះតែឫទ្ធា នុភាពព្រះអង្គ
ដែលជួយការពារ ឲ្យព្រះករុណា មានជោគមានជ័យ ។
៣- ព្រះអង្គប្រទាន ឲ្យរាជាបាន ទទួលអ្វីៗ ទ្រង់មិនបដិសេធ
ពាក្យអង្វរស្តី ទៅតាមព្រះទ័យ របស់រាជា ។
៤- ព្រះអង្គប្រទាន ពរជ័យឲ្យមាន ដល់ស្តេចគ្រប់គ្រា ទ្រង់ពាក់មកុដមាស
ពីលើសិរសា នៃព្រះករុណា រុងរឿងប្រណីត ។
៥- រាជាទូលសូម ព្រះអង្គក៏ព្រម ប្រទានជីវិត ឲ្យព្រះករុណា
ព្រះជន្មវែងពិត ដោយគ្មានកម្រិត អង្វែងឥតស្រាន្ត ។
៦- ដោយព្រះអម្ចាស់ មានជ័យជម្នះ រាជាក៏បាន ទទួលសិរី
រុងរឿងថ្កើងថ្កាន អម្ចាស់ប្រទាន ថ្លៃថ្លាឧត្តម ។
៧- ព្រះអង្គតែងតាំង រាជាឲ្យនាំ ព្រះពរសក្តិសម ទ្រង់គង់ជាមួយ
រាជរឹងមាំ ហើយមានទាំងព្រម អំណរបរិបូណ៌ ។

៨- រាជាផ្អែកពឹង បង្អែកពំនឹង គ្មានចិត្តផ្លាស់ប្តូរ ហឫទ័យស្មោះត្រង់
បរិសុទ្ធហៃហូរ ព្រះរាជ្យយឺនយូរ ឥតមានរង្គោះ ។
៩- ព្រះករុណាចាប់ ខ្មាំងសត្រូវជាប់ ឲ្យបានទាំងអស់ ទ្រង់ប្រើអំណាច
ឫទ្ធិខ្ពង់ខ្ពស់ ចាប់ពួកទាំងនោះ ដែលស្អប់រាជា ។
១០- ករុណាមកដល់ កម្ទេចគ្មានសល់ ឲ្យគេវេទនា ដូចភ្លើងឆេះសុស
ព្រះម្ចាស់មុខជា រំលាយពួកវា ដោយព្រះអង្គខ្ញាល់ ។
១១- ព្រះករុណាទ្រង់ នឹងលប់ពូជពង្ស វាមិនឲ្យសល់ អស់ពីដែនដី
រហូតកប្បកល្ប មិនឲ្យកង្វល់ ប្រហារផុតពូជ ។
១២- បើគេឃុបឃិត រួមផ្សំគំនិត អំពើខិលខូច នោះគេមិនអាច
ធ្វើទៅបានរួច កម្រោងការដូច ចិត្តគេប៉ុនប៉ង ។
១៣-រាជាទ្រង់ឫទ្ធិ ទ្រង់ទាញធ្នូយឺត បាញ់សត្រូវផង ព្រះករុណាធ្វើ
ឲ្យភ័យកន្លង ពួកខ្មាំងយង់ឃ្នង ត្រូវបរាជ័យ ។
១៤- ឱព្រះអម្ចាស់ សូមទតឲ្យច្បាស់ កុំផ្ទុំទៀតអី មេត្តាតើនឡើង
សម្តែងបារមី ខ្ញុំច្រៀងបទថ្វាយ តម្កើងព្រះអង្គ ។

## ទំនុកតម្កើងលេខ ២២ (២១) បទកាកគតិ

២- ឱ! ព្រះម្ចាស់អើយ ចុះហេតុម្តេចឡើយ ក៏ព្រះអង្គបោះ បង់ចោលរូបខ្ញុំ
ឥតមានស្រណោះ ខ្ញុំស្រែកស្ទើរខ្សោះ ពុំឃើញទ្រង់ជួយ ។
៣- ឱ! ព្រះម្ចាស់អើយ ខ្ញុំស្រែកដង្ហោយ រកព្រះតែមួយ ស្រែករកពេលថ្ងៃ
ក៏ទ្រង់មិនជួយ ពេលយប់ដេកព្រួយ ក៏មិនស្បើយដែរ ។
៤- ប៉ុន្តែព្រះអង្គ វិសុទ្ធឥតហ្មង គង់នៅឥតប្រែ លើបល្ល័ង្គរាជ្យ
អ៊ីស្រាអែលតែងតែ នាំគ្នាដង្ហែ តម្កើងព្រះអង្គ ។
៥- បុព្វបុរស យើងខ្ញុំទាំងអស់ ផ្ញើចិត្តទាំងស្រុង ផ្ញើទាំងជីវិត
ទាំងរូបកាយផង សូមឲ្យព្រះអង្គ រំដោះពួកគាត់ ។
៦- ដូនតាយើងខ្ញុំ អង្វរទូលសុំ ព្រះអង្គកម្ចាត់ អស់ពួកសត្រូវ
ដោយផ្ញើជីវិត នឹងមិនខកចិត្ត ព្រោះព្រះអង្គឡើយ ។

៧- រីឯខ្ញុំវិញ ទុក្ខសោកទោម្នេញ ឥតបីល្ហែល្ហើយ គេលែងបាត់ទុក
ជាមនុស្សទៀតហើយ មើលងាយឥតស្បើយ ប្រមាថជេរស្តី ។
៨- អស់អ្នកឃើញខ្ញុំ ឡកឡឺយដាក់ចំ គ្មានត្រាប្រណី គេពេបជ្រាយដាក់
ឥតមានគិតអ្វី ហើយមិនចេញស្តី គ្រវីក្បាលដាក់ ។
៩- គេពោលពាក្យថា កាត់ផ្ញើវាសនា ព្រះជាម្ចាស់ជាក់ ឲ្យព្រះអង្គជួយ
រំដោះគ្រោះថ្នាក់ បើព្រះអង្គជាក់ ពិតជាស្ម័គ្រស្មោះ ។
១០- ឱព្រះម្ចាស់អើយ ព្រះអង្គនេះហើយ ដែលជួយរំដោះ ឲ្យទូលបង្គំ
ចេញពីផ្ទៃពោះ ផ្ញើខ្ញុំឲ្យរស់ ឲ្យម្តាយបំបៅ ។
១១- កាលខ្ញុំកើតមក ទ្រង់ទទួលយក ខ្ញុំជាកូនចៅ ព្រះអង្គជាព្រះ
ដែលបានត្រាស់ហៅ តាំងពីខ្ញុំនៅ ពុំស្គាល់ពន្លឺ ។
១២- ពេលខ្ញុំជួបភ័យ អាសន្នខ្លាំងក្រៃ គ្មានអ្នកដឹងឮ មិនមានអ្នកជួយ
ជុតភ័យព្រួយព្រឺ សូមទ្រង់ដឹងឮ កុំទៅឆ្ងាយខ្ញុំ ។
១៣- សត្រូវច្រើននាក់ បោមរោមពួនស្ទាក់ រួមរឹតជិតជុំ ប្រៀបបានគោបា
ឡោមព័ទ្ធរូបខ្ញុំ ដូចគោមកបោម ពីស្រុកបាសាន ។
១៤- ពួកគេប្រឹងបើក មាត់គេកម្រើក ប្រឆាំងឥតស្រាន្ត នឹងទូលបង្គំ
ដូចសិង្ហសាមាន្យ បម្រុងហែកប្រាណ ស៊ីជាអាហារ ។
១៥- កម្លាំងខ្ញុំខ្សោយ មិនត្រឡប់ឡើយ ដូចខ្សែជលសា ដែលហូរធ្លាក់ទៅ
មិនវិលឡើយណា ឆ្អឹងសាច់ជងរ៉ា រលេះបាត់អស់ ។
ទឹកចិត្តក្លាហាន ដែលខ្ញុំធ្លាប់មាន ប្រែជាហេវខ្សោះបីដូចក្រមួន
រលាយរលោះ ឥតមានសល់សោះ ព្រោះកម្តៅថ្ងៃ ។
១៦- បំពង់កស្ងួត ដូចដីប្រេះហួត ស្គមស្គាំងរីងរៃ អណ្តាតខ្ញុំស្អិត
ជិតជាប់ពេកក្រៃ ទ្រង់ឲ្យខ្ញុំក្ស័យ ក្លាយជាធូលី ។
១៧- ពួកឆ្កែព័ទ្ធខ្ញុំ មានជនមួយក្រុម វាមកញាំញី ជាជនទុរយ៌ស
ក្រវែលគ្រប់ទី ទម្លុះជីវី ជើងដៃខ្លួនប្រាណ ។
១៨- រូបខ្ញុំអាចរាប់ ឆ្អឹងជំនីរគ្រប់ មានទាំងប៉ុន្មាន សត្រូវទុយ៌ស
ចិត្តដូចតិរច្ឆាន សម្លក់រំខាន សម្លឹងមកខ្ញុំ ។

១៩- ពួកគេដោះយក ខោអាវខ្ញុំមក ចែកបាយគ្នាជុំ នាំគ្នាចាប់ឆ្នោត
យកខោអាវខ្ញុំ ធ្វើដោយមិនសម ជាល្បែងសប្បាយ ។
២០- ឱព្រះម្ចាស់អើយ កុំនៅកន្តើយ ឲ្យខ្ញុំឃ្លាតឆ្ងាយ ទ្រង់ជាកម្លាំង
គាំទ្ររាងកាយ សូមយាងមកអាយ សង្គ្រោះប្រញាប់ ។
២១- សូមដោះលែងខ្ញុំ ឲ្យផុតទុក្ខធំ បានលឿនឆាប់ៗ ផុតពីមុខដាវ
ដែលគេបាក់កាប់ សូមជួយប្រញាប់ ពីចង្កូមឆ្កែ ។
២២-សូមសង្គ្រោះខ្ញុំ ឲ្យផុតទុក្ខធំ ពីមាត់សិង្ហដែរ ឲ្យផុតពីស្នែង
សូមជួយបំបែរ ឆ្លើយតបកុំល្ហែ មកទូលបង្គំ ។
២៣-ខ្ញុំនឹងថ្លាថ្លែង ព្រះនាមស្ញប់ស្ញែង ឲ្យបងប្អូនខ្ញុំ បានស្គាល់ព្រះអង្គ
ខ្ពង់ខ្ពស់ឧត្តម ក្នុងអង្គប្រជុំ សូមលើកតម្កើង ។
២៤- អ្នករាល់គ្នាអើយ កុំនៅកន្តើយ នាំគ្នាក្រោកឡើង សរសើរព្រះអង្គ
ថ្លាថ្លៃរុងរឿង ឲ្យលើកតម្កើង អម្ចាស់ក្សត្រា ។
អស់អ្នកដែលជា ពូជពង្សសោភា យ៉ាកុបថ្លៃថ្លា ព្រមទាំងអស់ពូជ
អ៊ីស្រាអែលផងណា កុំនៅរួញរា ស្ញែងខ្លាចព្រះអង្គ ។
២៥- ទ្រង់មិនព្រងើយ ឬធ្វើកន្តើយ នឹងជនស្លូតត្រង់ ដែលស្រែកហៅរក
សូមជួយស្រោចស្រង់ ទាំងសណ្ដាប់ផង មិនលាក់ព្រះភក្ត្រ ។
២៦- ព្រះអង្គបានប្រោស ប្រណីសន្តោស ជាម្លប់ត្រជាក់ ខ្ញុំលើកតម្កើង
ដោយចិត្តស្មោះស្ម័គ្រ នៅមុខអស់អ្នក ក្នុងអង្គប្រជុំ ។
២៧- មនុស្សទន់ទាប ស្លូតបូតសុភាព បានក្តីសុខជុម បរិភោគឆ្អែតឆ្អល់
ឥតព្រួយបារម្ភ រកព្រះឧត្តម សរសើរបារមី ។
២៨- មនុស្សទាំងប៉ុន្មាន ដែលរស់សុខសាន្ត នៅលើផែនដី នឹកឃើញព្រះម្ចាស់
ត្រឡប់វិលវៃ នាំគ្នាឃ្មាតខ្មី ក្រាបថ្វាយបង្គំ ។
២៩- ព្រះជាអម្ចាស់ ជាមហាក្សត្រច្បាស់ ប្រពៃសក្តិសម គ្រប់គ្រងទាំងអស់
លើជាតិតូចធំ រស់នៅជួបជុំ ក្សេមក្សាន្តរមនា ។
៣០- អ្នកធំទាំងឡាយ នៅជិតឬឆ្ងាយ ក្រាបថ្វាយគ្រប់គ្នា បង្គំព្រះអង្គ
ទោះមនុស្សធម្មតា តែងក្ស័យអាត្មា ក៏ចូលមកដែរ ។

៣១- ជនជំនាន់ក្រោយ គោរពព្រះដោយ ចិត្តមិនបែកបែរ បម្រើព្រះម្ចាស់
មិនមានវៀចវេរ ហើយគេតែងតែ ថ្លែងប្រាប់កូនចៅ ។
៣២- គេប្រកាសប្រាប់ ឲ្យប្រជាស្ដាប់ តអស់ពង្សដៅ ពីក្ដីសុចរិត
ទៀងត្រង់ត្រឹមត្រូវ ទ្រង់ត្រួសត្រាយផ្លូវ រំដោះប្រជា ។

## ទំនុកតម្កើងលេខ ២៣ (២២) បទពាក្យ ៧

១- ឱ! ព្រះអម្ចាស់ជាគង្វាល មើលឥតរយាលណែនាំខ្ញុំ
ឲ្យដើរតាមផ្លូវដែលសក្ដិសម ភោគផលជិតជុំឥតខ្វះឡើយ ។
២- ព្រះអង្គឲ្យខ្ញុំសម្រាកនៅ លើវាលមានស្មៅបានធូរស្បើយ
នាំខ្ញុំទៅក្បែរមាត់ទឹកហើយ ប្រទានឲ្យកាយមានកម្លាំង ។
៣- ទ្រង់នាំខ្ញុំតាមផ្លូវសុចរិត ល្អល្អះប្រណីតភ្លឺបែងចាំង
ព្រះកិត្តិនាមល្បីក្លាខ្លាំង គ្មានអ្វីរារាំងព្រះអង្គឡើយ ។
៤- ទោះបីរូបខ្ញុំដើរកាត់ភ្នំ ជ្រលងតូចធំស្លាប់ក៏ដោយ
ក៏ខ្ញុំមិនភ័យខ្លាចអ្វីឡើយ ទ្រង់គង់ជាមួយតាមការពារ ។
៥- ព្រះអង្គរៀបចំឲ្យបរិភោគ អាហារគរគោកមុខបច្ចា
រួចទ្រង់ចាក់ប្រេងលើសិរសា បំពេញពែងស្រាខ្ញុំហៀរហូរ ។
៦- ព្រះអង្គប្រទានសុភមង្គល ហឫទ័យខ្វាយខ្វល់ដោយអាសូរ
មកទូលបង្គំជាហែហូរ ឥតមានឈប់ឈរមួយជីវិត ។
ដរាបណាជីវិតនៅមាន ខ្ញុំសែនសុខសាន្តឥតមានគិត
ក្នុងព្រះដំណាក់ល្អប្រណីត ព្រះអម្ចាស់ស្ថិតស្ថេរជានិច្ច ។

## ទំនុកតម្កើងលេខ ២៤ (២៣) បទពាក្យ ៧

១- អ្វីៗដែលនៅលើដែនដី កើតមកច្រើនក្រៃមីរដេរដា
សុទ្ធជាកម្មសិទ្ធព្រះអម្ចាស់ ជាស្នាព្រះហស្តនៃព្រះអង្គ ។
២- គឺព្រះអង្គហើយដែលបាក់គ្រឹះ គ្រប់ទីគ្រប់ទិសគ្រប់ជ្រោយជ្រុង
ធ្វើឲ្យដែនដីនៅរឹងប៊ឹង ធំធេងល្វើយល្វឹងលើសមុទ្រ ។

៣- តើនរណាអាចឡើងលើភ្នំ　　វិហារឧត្តមដ៏វិសុទ្ធ
ដែលជាទីស្ថានតែមួយគត់　　ល្អល្អះបំផុតសែនសុខសាន្ត ។
៤- គឺមានតែអ្នកត្រឹមត្រូវល្អ　　ទឹកចិត្តស្មោះសរបរិសុទ្ធថ្កាន
មិនបណ្ដោយខ្លួនស្បថបំពាន　　នោះទើបអាចបានឡើងទីខ្ពស់ ។
៥- ព្រះជាអម្ចាស់ប្រទានពរ　　ជោគជ័យបវរសព្វទាំងអស់
ហើយព្រះអង្គបានជួយសង្គ្រោះ　　ទាំងប្រោសឲ្យរស់មានជីវិត ។
៦- អ្នកទាំងនេះហើយគឺប្រជា　　ស្វះស្វែងម្នីម្នាចូលមកជិត
ជាអ្នកស្វែងរកព្រះម្ចាស់ពិត　　ព្រះភក្ត្រល្អល្អិតព្រះយ៉ាកុប ។
៧- ឱទ្វារទាំងឡាយចូរកក្រើក　　ចូរអ្នកខំបើកកុំឈរឈប់
ចូរបើកចំហទាំងថ្ងៃយប់　　មហាក្សត្រជាម្លប់យាងចូលមក ។
៨- តើព្រះមហាក្សត្រជានរណា　　រុងរឿងថ្លៃថ្លាជាជម្រក
គឺព្រះដែលខ្លាំងធ្លាប់ច្បាំងមក　　មានជ័យមានជោគលើពិភព ។
៩- ឱទ្វារទាំងឡាយចូរកក្រើក　　ចូរអ្នកខំបើកកុំឈរឈប់
ចូរបើកចំហទាំងថ្ងៃយប់　　មហាក្សត្រជាម្លប់យាងចូលមក ។
១០- តើព្រះមហាក្សត្រជានរណា　　រុងរឿងថ្លៃថ្លាជាជម្រក
គឺទ្រង់ជាម្ចាស់ពិភពលោក　　ពីដើមរៀងមកលុះឥឡូវ ។

## ទំនុកតម្កើងលេខ ២៥ (២៤)　　បទពាក្យ ៧

១- ឱ! ព្រះអម្ចាស់ខ្ញុំផ្ចង់ចិត្ត　　ផ្ចង់ទាំងគំនិតឥតរវាត
ទៅលើព្រះអង្គមិនឃ្លាងឃ្លាត　　នឹកហើយគិតទៀតមិនបែកចិត្ត ។
២- បពិត្រព្រះម្ចាស់ទូលបង្គំ　　ពេលនេះរូបខ្ញុំផ្ញើជីវិត
សូមកុំឲ្យខ្ញុំត្រូវខកចិត្ត　　ព្រោះខ្មាំងជុំជិតមានជោគជ័យ ។
៣- អស់អ្នកសង្ឃឹមលើព្រះអង្គ　　នឹងមិនត្រូវបង់ខកចិត្តអ្វី
គឺមានតែអ្នកក្បត់ម្ចាស់ថ្លៃ　　ទើបខកចិត្តក្រៃអ្វីក៏គ្មាន ។
៤- ឱព្រះអម្ចាស់ទូលបង្គំ　　សូមជួយណែនាំនិងបង្រៀន
ឲ្យស្គាល់មាគ៌ាល្អថ្កើងថ្កាន　　វិសុទ្ធហួសស្មាននៃព្រះអង្គ ។

| | | |
|---|---|---|
| ៥- សូមជួយអប់រំខ្ញុំឲ្យរស់ | តាមក្ដីពិតស្មោះព្រះអង្គផង | |
| ដ្បិតទ្រង់សង្គ្រោះខ្ញុំឥតហ្មង | សង្ឃឹមព្រះអង្គរៀងរាល់ថ្ងៃ | ។ |
| ៦- ឱព្រះអម្ចាស់សូមកុំភ្លេច | ចាំជាប់ជានិច្ចពេញព្រះទ័យ | |
| ដែលធ្លាប់អាណិតពន់ពេកក្រៃ | ករុណាប្រណីខ្ញុំជានិច្ច | ។ |
| ៧- សូមបំភ្លេចបាបនិងកំហុស | ដែលខ្ញុំមានទោះច្រើនឬតិច | |
| នៅពីក្មេងខ្ចីសូមបំភ្លេច | ទ្រង់គ្មានកលកិច្ចធ្លាប់មេត្តា | ។ |
| ៨- ព្រះអម្ចាស់មានព្រះហឫទ័យ | សប្បុរសពេកក្រៃករុណា | |
| សូមជួយបង្ហាញពីមាគ៌ា | មនុស្សបាបរាល់គ្នាបានស្គាល់ផង | ។ |
| ៩- ព្រះអង្គនាំមនុស្សដែលមានចិត្ត | សុភាពសុចរិតតាមគន្លង | |
| មាគ៌ាត្រឹមត្រូវល្អផ្លូវផង់ | មិនឲ្យមានហ្មងស្គាល់ផ្លូវល្អ | ។ |
| ១០- មាគ៌ារបស់ព្រះអម្ចាស់ | សម្ដែងយ៉ាងច្បាស់ករុណាធំ | |
| ដល់អ្នកគោរពទោះក្រីក្រ | ខ្ពង់ខ្ពស់បវរតាមសម្ពន្ធ | ។ |
| ១១- ឱ! ព្រះអម្ចាស់ប្រណីប្រោស | កុំប្រកាន់ទោសខ្ញុំធ្ងរធ្ងន់ | |
| អំពើទុច្ចរិតមានពីមុន | សូមក្រាបកាយលន់តួព្រះម្ចាស់ | ។ |
| ១២- អស់អ្នកគោរពហើយកោតខ្លាច | ឫទ្ធិអំណាចបានស្គាល់ច្បាស់ | |
| ទ្រង់បង្ហាញផ្លូវឥតក្រឡះ | ដែលគេត្រូវជ្រើសតាមចិន្ដា | ។ |
| ១៣- នោះគាត់បានសុខមានមង្គល | ឥតមានខ្វាយខ្វល់គ្រប់វេលា | |
| ពូជពង្សកូនចៅទាំងអស់គ្នា | គ្រងស្រុកទុកជាកេរមត៌ក | ។ |
| ១៤- ព្រះតែងសម្ដែងភក្ដីភាព | អ្នកតូចខ្ពស់ទាបយ៉ាងស្ម័គ្រស្មោះ | |
| អ្នកដែលកោតខ្លាចទ្រង់សប្បុរស | ឲ្យគេទាំងអស់ស្គាល់មេត្រី | ។ |
| ១៥- រូបខ្ញុំសម្លឹងរកព្រះអង្គ | ឥតមានភ្លេចម្ដងរៀងរាល់ថ្ងៃ | |
| ព្រះអង្គរំដោះផុតទុក្ខភ័យ | ផុតពីក្បិណក្ប័យផុតអន្ទាក់ | ។ |
| ១៦- សូមព្រះអង្គបែរព្រះភក្ត្រមក | សណ្ដោងយោងយកកុំអន់អាក់ | |
| ប្រណីសន្ដោសផុតគ្រោះថ្នាក់ | ដ្បិតរូបខ្ញុំម្នាក់នៅឯកា | ។ |
| ១៧- រូបខ្ញុំលំបាកចិត្តពេកក្រៃ | រាល់ពេលយប់ថ្ងៃសែនខ្លោចផ្សា | |
| មេត្តាដកយកទុក្ខនេះណា | ធុញថប់គ្រាំគ្រាពីចិត្តខ្ញុំ | ។ |

១៨- សូមទតមកមើលទុកវេទនា ចុកចាប់ឈឺជ្រាទូលបង្គំ
អត់ទោសឲ្យរួចពីទុក្ខធំ វេទនាទ្រូញយំផុតបាបផង ។
១៩- សូមទតមកមើលខ្មាំងសត្រូវ គ្នាច្រើនពេកក្រូវចិត្តយង់ឃ្នង
គេស្អប់គេខ្ញើមក្រៃកន្លង ចិត្តគេប៉ុនប៉ងចងគួនគុំ ។
២០- មេត្តាជួយការពារជីវិត រំដោះឲ្យផុតពីទុក្ខធំ
ខ្ញុំសូមពឹងលើព្រះឧត្តម កុំឲ្យរូបខ្ញុំខកចិត្តឡើយ ។
២១- រូបខ្ញុំទុកចិត្តលើព្រះអង្គ សូមមេត្តាផងកុំកន្តើយ
រក្សាជីវិតខ្ញុំបានស្បើយ ព្រោះខ្ញុំនេះហើយចិត្តសប្បុរស ។
២២- ឱព្រះអម្ចាស់នៃខ្ញុំអើយ សូមកុំព្រងើយធ្វើជួប្នោះ
រំដោះអ៊ីស្រាអែលឲ្យរួចទោស វេទនាទាំងអស់បានសុខសាន្ត ។

## ទំនុកតម្កើងលេខ ២៦ (២៥) បទកាកគតិ

១- ឱព្រះអម្ចាស់ ព្រះអង្គជាព្រះ ប្រពៃឧត្តម សូមរកយុត្តិធម៌
ឲ្យទូលបង្គំ ដែលអស់យើងខ្ញុំ ទុកចិត្តព្រះអង្គ ។
២- ឱព្រះអម្ចាស់ សូមស្ទង់ឲ្យច្បាស់ លចិត្តមើលផង ពិនិត្យរូបខ្ញុំ
ហើយពិសោធន៍ល្បង ចិត្តខ្ញុំឥតហ្មង ស្មោះស្ម័គ្រជានិច្ច ។
៣- ទូលបង្គំស្រមៃ នឹកពីព្រះទ័យ ព្រះអង្គឥតភ្លេច ហើយបានធ្វើតាម
ឥតមានកែគេច តាមជាប់ជានិច្ច មិនគេចបែកបែរ ។
៤- ទូលបង្គំមិនធ្លាប់ អង្គុយអែបជាប់ ពួកពាលប៉ោឡៃ ឬមនុស្សខិលខូច
ជនអាវ៉ាសែ ពុតត្បុតហូរហែ ក៏មិនសេពគប់ ។
៥- ខ្ញុំមិនចូលចិត្ត ពួកអ្នកប្រព្រឹត្ត អាក្រក់ងល់ងប់ ខ្ញុំមិនល្ងីល្ងើ
អង្គុយរួមរូប ទោះថ្ងៃឬយប់ នឹងពួកពាលា ។
៦- ឱព្រះអម្ចាស់ ខ្ញុំសូមប្រកាស ស្មោះឥតរួញរា ខ្ញុំសម្អាតដៃ
គឺបញ្ជាក់ថា រូបខ្ញុំគឺជា មនុស្សឥតសៅហ្មង ។
៧- ព្រមទាំងបន្លឺ សំឡេងរន្ទឺ អរគុណព្រះអង្គ និងរៀបរាប់ពី
ការអស្ចារ្យផង របស់ព្រះអង្គ មានទាំងប៉ុន្មាន ។

៨- បពិត្រព្រះម្ចាស់ ខ្ញុំចូលចិត្តណាស់ ដំណាក់សុខសាន្ត របស់ព្រះអង្គ
គឺជាទីស្ថាន សិរីថ្កើងថ្កាន ព្រះអង្គស្ថិតនៅ ។
៩- សូមកុំទុកឲ្យ ខ្ញុំស្លាប់ជាមួយ មនុស្សបាបអាស្រូវ កុំដកជីវិត
របស់ខ្ញុំទៅ នឹងពួកឃោរឃៅ ធ្លាប់បង្ហូរឈាម ។
១០- ពួកនោះចូលចិត្ត នាំគ្នាប្រព្រឹត្ត ផ្ទុយពីបំរាម អំពើទុច្ចរិត
ដែលព្រះលោកហាម ខំបង្ហូរឈាម ឬស៊ីសំណូក ។
១១- ឯខ្ញុំចូលចិត្ត ធ្វើតែសុចរិត មិនព្រមប្រឡូក ប្រឡល់នឹងពួក
ធ្លាប់ស៊ីធ្លាប់សូក សូមរំដោះយក រូបខ្ញុំនេះផង ។
១២- រូបខ្ញុំឈរនៅ កន្លែងត្រឹមត្រូវ សុចរិតទៀងត្រង់ ខ្ញុំនឹងលើកថ្កើង
តម្កើងព្រះអង្គ ឲ្យខ្ពស់ឧត្តុង្គ ក្នុងប្រជុំធំ ។

## ទំនុកតម្កើងលេខ ២៧ (២៦) បទពាក្យ ៧

១- ព្រះអម្ចាស់ទ្រង់ជាពន្លឺ នាមល្បីរន្ទឺព្រះសង្គ្រោះ
មិនឲ្យខ្ញុំខ្លាចនរណាសោះ ជាកំពែងខ្ពស់ជួយជីវិត ។
២- ពេលពួកជនពាលជាបច្ចា រូតរះម្ទីម្ទាចូលមកជិត
ពួកគេចង់មកផ្តាច់ជីវិត តែពួកឧក្រិដ្ឋត្រូវភ្លាត់ដួល ។
៣- ទោះមានទ័ពច្រើនមករោមរិត ឡោមព័ទ្ធខ្ញុំជិតក៏មិនច្រួល
ទោះលើកគ្នាច្បាំងខ្ញុំសុខស្រួល ចិត្តមិនប្រែប្រួលសង្ឃឹមព្រះ ។
៤- ខ្ញុំទូលព្រះម្ចាស់នូវសេចក្តី តែមួយគត់ខ្លីឲ្យបានច្បាស់
គឺចង់ស្នាក់នៅដំណាក់ព្រះ ឥតមានក្រឡះមួយជីវិត ។
ដើម្បីខ្ញុំបានកោតស្ញែងស្ញប់ ឫទ្ធានុភាពថ្កុំថ្កើងពិត
នឹងថ្វាយបង្គំម្ចាស់ជីវិត ព្រះអង្គគង់ស្ថិតក្នុងវិហារ ។
៥- ពេលខ្ញុំជួបគ្រោះអាសន្នភ័យ ព្រះអង្គដឹកដៃខ្ញុំម្ទីម្ទា
ចូលខ្លួនជ្រកក្នុងព្រះពន្លា បំពួនអាត្មាថ្មដាបាំង ។
៦- ឥឡូវព្រះអង្គលើករូបខ្ញុំ ឲ្យខ្ពស់ឧត្តមហួសពួកខ្មាំង
ថ្វាយយញ្ញបូជាហើយព្រមទាំង ស្រែកជ័យឃោសផងស្មូតតម្កើង ។

៧- ឱព្រះម្ចាស់អើយសូមសណ្ដាប់ ស្នូរខ្ញុំស្រែកប្រាប់ឮលាន់ឡើង
អាណិតឆ្លើយតបកុំធ្វេសធ្មើង មកខ្ញុំវិញផងកុំកន្ដើយ ។
៨- ខ្ញុំនឹកទៅដល់ព្រះបន្ទូល ព្រះអង្គថ្លែងពោលទុកមកហើយ
ចូរស្វែងរកយើងនឹងបានស្បើយ ខ្ញុំមិនព្រងើយស្វែងរកភក្ត្រ ។
៩- សូមទ្រង់អាណិតដល់រូបខ្ញុំ កុំពួនសំងំនៅលួចលាក់
កុំព្រះពិរោធកុំអន់អាក់ កុំបណ្ដេញអ្នកបម្រើបោល ។
ព្រះអង្គសង្គ្រោះទូលបង្គំ កុំទុករូបខ្ញុំនៅតែលតោល
ឱព្រះសង្គ្រោះទូលបង្គំ កុំទុករូបខ្ញុំបោលដូច្នេះណា ។
១០- ទោះឪពុកម្ដាយទូលបង្គំ បោះបង់បោលខ្ញុំឲ្យឯកា
ព្រះម្ចាស់នៅតែថែរក្សា ប្រណីមេត្តាជាប់ជានិច្ច ។
១១- សូមព្រះអម្ចាស់បង្រៀនខ្ញុំ ស្គាល់ផ្លូវឧត្ដមគ្មានកលកិច្ច
ដើរតាមមាគ៌ាមិនបែរគេច ព្រោះខ្មាំងមានល្បិចចាំឃ្លាំមើល ។
១២- សូមកុំបណ្ដោយឲ្យខ្ញុំធ្លាក់ ចូលក្នុងអន្ទាក់ខ្មាំងងងើល
សាក្សីក្លែងក្លាយបង្កាច់មួល អ្នកនោះតែងពោលពាក្យឃោរឃៅ ។
១៣- ខ្ញុំជឿជាក់ថាខ្ញុំនឹងបាន ឃើញសុខក្សេមក្សាន្តមិនអាស្រូវ
មង្គលកើតពីព្រះម្ចាស់នៅ ក្នុងលោកតទៅជាមិនខាន ។
១៤- ចូរទុកចិត្តលើព្រះអម្ចាស់ ព្រះអង្គជាព្រះដ៏ថ្កើងថ្កាន
ចូរមានកម្លាំងចិត្តក្លាហាន នោះអ្នកនឹងមានសុខមង្គល ។

## ទំនុកតម្កើងលេខ ២៨ (២៧) បទព្រហ្មគីតិ

១- ឱព្រះអម្ចាស់អើយ ខ្ញុំស្រែកហើយរកព្រះអង្គ
ទ្រង់ជាថ្មជាបាំង ការពារឃាំងទូលបង្គំ ។
សូមទ្រង់ស្ដាប់សម្រែក ដែលខ្ញុំស្រែកស្ទើរទ្រូញយំ
បើទ្រង់នៅសំងំ នោះរូបខ្ញុំធ្លាប់មរណា ។
២- ពេលខ្ញុំដង្ហោយហៅ លើកដៃទៅទីសក្ការ
គ្រប់ពេលតែងវាចា សូមមេត្តាសណ្ដាប់ផង ។

៣- កុំឲ្យខ្ញុំមានទោស ដូចកំហុសពួកយង់ឃ្នង
គេរាក់ទាក់ឥតឆ្គង តែបំណងមានកលល្បិច ។
៤- សូមទ្រង់ជួយដាក់ទោស តាមកំហុសកុំបីភ្លេច
ឲ្យសមតាមកលល្បិច កុំឲ្យគេចរួចខ្លួនឡើយ ។
៥- ពួកគេមិនយល់សោះ ស្នាព្រះហស្តនៅបង្ហើយ
សូមទ្រង់ផ្តួលគេហើយ កុំបីឡើយឲ្យងើបបាន ។
៦- សូមនាំគ្នាលើកឡើង ជួយតម្កើងព្រះថ្កើងថ្កាន
ដ្បិតព្រះអម្ចាស់បាន ព្រះសណ្តាប់ពាក្យផងខ្ញុំ ។
៧- ព្រះម្ចាស់ជាបន្ទាយ កំពែងរាយខែលព័ទ្ធជុំ
ការពារសង្គ្រោះខ្ញុំ ទូលបង្គំគួរទុកចិត្ត ។
ខ្ញុំរីករាយសប្បាយ លែងខ្វល់ខ្វាយឈប់ភ័យភិត
សរសើរព្រះម្ចាស់ពិត ដោយមានបទច្រៀងតម្កើង ។
៨- ព្រះម្ចាស់ជាកម្លាំង ការពារពាំងរាស្ត្រព្រះអង្គ
ទ្រង់ជាកំពែងផង សម្រាប់សង្គ្រោះព្រះគ្រីស្ត ។
៩- ឱព្រះជាអម្ចាស់ សូមសង្គ្រោះប្រជារាស្ត្រ
ទ្រង់ជាគង្វាលឃ្លាស វែរវាលថែទាំគេ ។

## ទំនុកតម្កើងលេខ ២៩ (២៨) បទកាកគតិ

១- ទេវតាទាំងឡាយ ចូរនាំគ្នាថ្វាយ តម្កើងព្រះម្ចាស់ លើកស្ទួយសេរី
រុងរឿងត្រចះ អនុភាពតេជះ របស់ព្រះអង្គ ។
២- ចូរលើកតម្កើង ព្រះនាមថ្កុំថ្កើង ក្នុងពេលនេះផង ចូរនាំគ្នាថ្វាយ
បង្គំព្រះអង្គ វិសុទ្ធឥតហ្មង ព្រះនាមល្បាញល្បី ។
៣- សូរសៀងព្រះម្ចាស់ លាន់ឮយ៉ាងច្បាស់ ពាសពេញដែនដី ពីលើសាគរ
សមុទ្រធំក្រៃ ព្រះអម្ចាស់ថ្លៃ គង់នៅលើទឹក ។
៤- សូរសៀងព្រះម្ចាស់ ស្ទើរបែកអាកាស លាន់ឮសន្ធឹក ឫទ្ធានុភាព
គគ្រឹមគគ្រឹក ទោះយប់ល្ងាចព្រឹក នៅតែថ្កុំថ្កើង ។

៥- សូរសៀងព្រះម្ចាស់ មានបារមីណាស់ ដើមឈើដួលបើង ដើមធំបាក់មែក
ដើមតូចរលើង នៅភ្នំលីបង់ ខ្ទេចខ្ទីគ្មានសល់ ។
៦- ព្រះអង្គឲ្យភ្នំ ស៊ីរីយ៉ូនធំ លោតឥតមានខ្វល់ ដូចកូនក្របី
កូនគោគ្មានក្រោល ត្រូវមេដើរបោល គ្មានអ្នករក្សា ។
៧- សូរសៀងព្រះម្ចាស់ ខ្ទ័រខ្ទារខ្លាំងណាស់ ពាសពេញវេហាស៍ មានទាំងរន្ទះ
បាញ់រះផងណា នេះគឺចេស្ដា បារមីថ្កើងថ្កាន ។
៨- សូរសៀងរបស់ ព្រះម្ចាស់ទាំងអស់ ឲ្យរហោស្ថាន កក្រើកញាប់ញ័រ
គ្មានអ្វីស្មើបាន ទាំងរហោស្ថាន កាដែសរញ្ជួយ ។
៩- សូរសៀងព្រះម្ចាស់ អង្រួនទាំងអស់ ឲ្យក្ដាន់ញីព្រួយ កំពុងកើតកូន
អារម្មណ៍រញ្ជួយ ព្រមទាំងធ្វើឲ្យ ស្លឹកឈើជ្រុះអស់ ។
ពេលនោះមនុស្សម្នា ទាំងអស់នាំគ្នា ស្រែកដោយស្រួលស្រុះ ក្នុងវិហារថា
តម្កើងព្រះម្ចាស់ ព្រះនាមរបស់ អម្ចាស់ថ្លាថ្លៃ ។
១០- ព្រះអង្គគ្រប់គ្រង ទឹកជំនន់ផង ធំធេងពេកក្រៃ ទ្រង់គឺជាព្រះ
មហាក្សត្រថ្លៃ ព្រះនាមល្បាញល្បី គ្រងរាជ្យតទៅ ។
១១- សូមព្រះអម្ចាស់ ប្រណីសន្ដោស កុំបង្អង់នៅ ប្រទានកម្លាំង
ឲ្យរាស្ត្រតទៅ កុំបីហ្មងសៅ ឲ្យគេសុខសាន្ត ។

## ទំនុកតម្កើងលេខ ៣០ (២៩) បទពាក្យ ៧

២- បពិត្រព្រះម្ចាស់ដ៏ឧត្ដម ទូលបង្គំសូមលើកតម្កើង
ព្រោះព្រះអង្គបានស្រង់ខ្ញុំឡើង មិនឲ្យពួកខ្មាំងលេងសើចបាន ។
៣- ឱព្រះអម្ចាស់ដែលជាព្រះ ប្រសើរពេកណាស់ខ្ពស់ថ្កើងថ្កាន
ខ្ញុំអង្វរសុំក្ដីសុខសាន្ត ហើយទ្រង់ប្រោសប្រាណឲ្យបានជា ។
៤- បពិត្រព្រះម្ចាស់ដ៏ឧត្ដម ស្រង់ទូលបង្គំផុតវេទនា
ចេញពីរណ្ដៅជនមរណា ប្រទានជីវ៉ារស់ជាថ្មី ។
៥- ឱអ្នករាល់គ្នាដែលជារាស្ត្រ របស់ព្រះម្ចាស់ដ៏ប្រពៃ
ចូរច្រៀងតម្កើងនាមម្ចាស់ថ្លៃ វិសុទ្ធពេកក្រៃនៃព្រះអង្គ ។

| | | | |
|---|---|---|---|
| ៦- | ព្រះអង្គខ្ញាល់តែមួយភ្លែតសោះ | ប្រណីសន្ដោសមនុស្សទាំងពួង | |
| | ពេលល្ងាចគេយំចិត្តមួរហ្មង | ព្រលឹមស្រាងឡើងអរសប្បាយ | ។ |
| ៧- | ពេលទូលបង្គំរស់បានសុខ | មិនដែលមានទុក្ខមកបៀតកាយ | |
| | ខ្ញុំពោលឡើងថាព្រះម្ចាស់ថ្លៃ | រូបខ្ញុំគ្មានអ្វីរលំឡើយ | ។ |
| ៨- | បពិត្រព្រះម្ចាស់ដែលធ្លាប់ប្រោស | ប្រណីសន្ដោសមិនកន្ដើយ | |
| | ឲ្យខ្ញុំរឹងប៉ឹងដូចភ្នំហើយ | កុំលាក់ភក្រ្ដឡើយខ្ញុំតក់ស្លុត | ។ |
| ៩- | ឱព្រះជាអម្ចាស់ខ្ញុំអើយ | ខ្ញុំស្រែកដង្ហោយមិនកំណត់ | |
| | អង្វរព្រះអង្គតែមួយគត់ | រាល់ពេលទៀងទាត់ទទូចថា | ។ |
| ១០- | « បើព្រះអង្គទុកឲ្យរូបខ្ញុំ | ទុក្ខសោកក្រៀមក្រំបង់សង្ខារ | |
| | តើបានប្រយោជន៍អ្វីទៅណា | ខ្ញុំក្ស័យសង្ខារក្នុងរណ្ដៅ | ។ |
| | តើមនុស្សស្លាប់ឬដែលសរសើរ | ព្រះគ្មានអ្វីស្មើគ្មានហ្មងសៅ | |
| | តើគេអាចថ្លែងដូចម្ដេចទៅ | ពីទឹកព្រះទ័យព្រះអង្គបាន | ។ |
| ១១- | ឱព្រះអម្ចាស់សូមមេត្តា | សណ្ដាប់ករុណាកុំខកខាន | |
| | ឱព្រះម្ចាស់អើយសូមវិលថ្កាន | សង្គ្រោះប្រោសប្រាណរូបខ្ញុំផង » | ។ |
| ១២- | ព្រះអង្គធ្វើឲ្យផុតអស់ទុក្ខ | អាប់អួរសព្វមុខមិនមានហ្មង | |
| | ឥតមានកាន់ទុក្ខរីករាយម្ដង | ខោអាវល្អផងពាក់សប្បាយ | ។ |
| ១៣- | ខ្ញុំមិននៅស្ងៀមធ្វើផ្ទៃធ្មើង | ស្មូតបទតម្កើងមិនជិនណាយ | |
| | ឱព្រះម្ចាស់អើយខ្ញុំឱនកាយ | ក្រាបបង្គំថ្វាយលើកតម្កើង | ។ |

## ទំនុកតម្កើងលេខ ៣១ (៣០) — បទភាគគតិ

| | | | | |
|---|---|---|---|---|
| ២- | ឱព្រះអម្ចាស់ | ខ្ញុំសូមប្រកាស | សូមជ្រកក្រោមម្លប់ | ជារៀងរហូត |
| | ឥតមានឈរឈប់ | ទាំងថ្ងៃទាំងយប់ | សូមរំដោះផង | ។ |
| ៣- | សូមទ្រង់ផ្ទៀងស្ដាប់ | ពាក្យខ្ញុំរៀបរាប់ | មិនឲ្យមានឆ្គង | សូមរំដោះខ្ញុំ |
| | ឲ្យឆាប់តែម្ដង | ជាកំពែងផង | សង្គ្រោះរូបខ្ញុំ | ។ |
| ៤- | ទ្រង់ជាសិលា | កំពែងឫជា | ពាំងទូលបង្គំ | សូមជួយដឹកនាំ |
| | ឆ្លងផ្លូវតូចធំ | តម្រង់ទិសខ្ញុំ | ដោយយល់ព្រះនាម | ។ |

៥- សូមប្រោសឲ្យរួច  ពីពួកមនុស្សខូច  ពួនឃ្លាំចាំយាម  សូមជួយរំដោះ
ពីអន្ទាក់ភ្លាម  ដ្បិតតែព្រះនាម  ទ្រង់ជួយការពារ  ។
៦- ខ្ញុំសូមប្រគល់  វិញ្ញាណនិមល  ថ្វាយអង្គក្សត្រា  ទៅក្នុងព្រះហស្ត
ព្រះម្ចាស់ហើយណា  ព្រោះព្រះអង្គជា  ព្រះទុកចិត្តបាន  ។
៧- ទូលបង្គំសូមផ្ញើ  ជីវិតទៅលើ  ព្រះម្ចាស់ថ្កើងថ្កាន  ហើយខ្ញុំក៏ស្អប់
មនុស្សចិត្តសាមាន្យ  ស្មោះស្ម័គ្រផ្ញើប្រាណ  លើព្រះក្លែងក្លាយ  ។
៨- ចិត្តខ្ញុំស្រស់ថ្លា  អរឥតឧបមា  រីករាយសប្បាយ  ដោយសារព្រះអង្គ
ទ្រង់មានព្រះទ័យ  ករុណាប្រណី  ពេលខ្ញុំវេទនា  ។
៩- ទ្រង់មិនបណ្ដោយ  ឲ្យរូបខ្ញុំធ្លោយ  ខ្លោចផ្សាគ្រាំគ្រា  ធ្លាក់ទៅក្នុងដៃ
របស់បច្ចា  សូមទ្រង់ករុណា  មេត្តាប្រណី  ។
១០- ឱព្រះម្ចាស់អើយ  សូមអាណិតហើយ  សន្ដោសខន្តី  ដ្បិតទូលបង្គំ
ជួបអាសន្នភ័យ  យំស្ទើររីងរៃ  បាក់ធ្លាក់ទឹកចិត្ត  ។
១១- លុះដល់ខ្ញុំចាស់  ទុក្ខនោះធ្ងន់ណាស់  អស់មួយជីវិត  កម្លាំងចុះខ្សោយ
កំហុសជុំជិត  ខ្ញុំខុសមែនពិត  ឆ្អឹងឆ្អែងពុកផុយ  ។
១២- សត្រូវទាំងអស់  ពោលពាក្យគំរោះ  ប្រមាថជេរស្ដី  ទោះអ្នកជិតខាង
ធ្លាប់មានមេត្រី  ពេលខ្ញុំដេកដី  គេនាំគ្នាគេច  ។
១៣- គេមិនខ្វីនឹក  គេមិនរំឭក  គេខំបំភ្លេច  ដូចបោលអ្នកស្លាប់
គ្មានគិតតូចតិច  ដូចឆ្នាំងកំបែក  ត្រូវគេបង់បោះ  ។
១៤- ខ្ញុំឮគេពោល  ពាក្យបង្កាច់មួយ  ថាមនុស្សទាំងអស់  នៅជុំវិញខ្ញុំ
មានចិត្តមិនស្មោះ  ពួកគេទាំងនោះ  បម្រុងប្រហារ  ។
១៥- បពិត្រព្រះម្ចាស់  ទូលបង្គំភ័យណាស់  សូមផ្ញើជីវ៉ា  ទៅលើព្រះអង្គ
ហើយសូមពោលថា  ព្រះអង្គពិតជា  ព្រះរបស់ខ្ញុំ  ។
១៦- អាយុជីវិត  របស់ខ្ញុំស្ថិត  ដោយក្ដីសុខដុម  នៅក្នុងព្រះហស្ត
ព្រះម្ចាស់ឧត្តម  សូមរំដោះខ្ញុំ  ផុតពីដៃខ្មាំង  ។
១៧- សូមបែរព្រះភក្ត្រ  ទតមកមើលអ្នក  បម្រើព្រះអង្គ  មេត្តាសង្គ្រោះ
ទូលបង្គំផង  ដោយហឫទ័យទ្រង់  ប្រណីករុណា  ។

១៨- ឱព្រះអម្ចាស់ ខ្ញុំអង្វរព្រះ ដែលធ្លាប់មេត្តា កុំឲ្យរូបខ្ញុំ
ខកចិត្តឡើយណា ឲ្យមនុស្សពាលា ទៅជួបមច្ចុរាជ ។
១៩- សូមឲ្យអស់អ្នក តែងតែកុហក និងពួកកំណាច ពួកធ្លាប់និយាយ
ព្រហើនកោងកាច បាត់បង់អំណាច ហារស្ដីមិនបាន ។
២០- បពិត្រព្រះម្ចាស់ ព្រះទ័យសន្ដោស វិសេសថ្កើងថ្កាន ដល់អ្នកគោរព
កោតខ្លាចគ្រប់ប្រាណ មិនដែលរំខាន អ្នកជ្រកជាមួយ ។
២១- ព្រះអង្គទ្រង់លាក់ គេនៅក្បែរភក្ត្រ ឲ្យផុតពីព្រួយ ពីមនុស្សទុច្ចរិត
ព្រះអង្គតែងជួយ ឲ្យនៅជាមួយ ក្នុងព្រះពន្លា ។
២២-សូមលើកតម្កើង សិរីរុងរឿង ពេលដែលបច្ចា ឡោមព័ទ្ធរូបខ្ញុំ
ច្រើនឥតឧបមា ហឫទ័យមេត្តា អស្ចារ្យពេកក្រៃ ។
២៣- ពេលខ្ញុំខ្វល់ចិត្ត វិលវល់គំនិត ជួបទុក្ខគ្រោះភ័យ ខ្ញុំនឹកស្មានថា
ទ្រង់លែងប្រណី តែពេលខ្ញុំស្ដី ទ្រង់ស្ដាប់ពាក្យខ្ញុំ ។
២៤- សូមឲ្យអស់អ្នក គោរពស្មោះស្ម័គ្រ ព្រះម្ចាស់ជាធំ នាំគ្នាស្រឡាញ់
ព្រះខ្ពស់ឧត្ដម ការពារឧបត្ថម្ភ រក្សាអ្នកជឿ ។
តែព្រះអង្គដាក់ ទោសតឹងដល់ថ្នាក់ អ្នកគ្មានជំនឿ មនុស្សព្រហើន
កាចកោងមិនជឿ អ្នកគ្មានជំនឿ ព្រះអង្គផ្ដន្ទា ។
២៥- អស់អ្នកទុកចិត្ត សង្ឃឹមស្មោះពិត ព្រះម្ចាស់លោកា ចូរមានកម្លាំង
ទឹកចិត្តហានក្លា នោះព្រះមុខជា ការពារសុខសាន្ត ។

## ទំនុកតម្កើងលេខ ៣២(៣១) — បទព្រហ្មគីតិ

១- អ្នកដែលព្រះជាម្ចាស់ លើកលែងទោសប្រោសប្រណី
រួចពីបាបទុក្ខភ័យ មានសេរីសុខមង្គល ។
២- អស់អ្នកដែលព្រះម្ចាស់ មិនចាប់ទោសផុតអំពល់
គ្មានចិត្តវៀចវិលវល់ មានមង្គលសុខឥតល្ហែ ។
៣- ដរាបណារូបខ្ញុំ នៅមិនព្រះសារភាពទេ
នោះខ្ញុំកើតទុក្ខទ្វេ មិនឈប់ទេចុកចាប់ក្រៃ ។

៤- ដ្បិតព្រះអង្គដាក់ទោស    ព្រោះខ្ញុំខុសទាំងយប់ថ្ងៃ
ហេវខ្សោះស្មើរក្សិណក្ស័យ    ដូចជាដីហួតទឹកអស់ ។
៥- រូបខ្ញុំបានសារភាព    អំពើបាបមុខព្រះម្ចាស់
ខ្ញុំមិនលាក់លៀមសោះ    នូវកំហុសខ្ញុំនោះឡើយ ។
ទូលបង្គំពោលថា    ខ្ញុំនេះណាសារភាពហើយ
ទោសខ្ញុំធ្ងន់ឥតស្បើយ    ទ្រង់លើកឲ្យរួចពីបាប ។
៦- ហេតុនេះហើយបានជា    អ្នករាល់គ្នាប្រណិប័តន៍ក្រាប
ព្រះម្ចាស់ជាដរាប    ជាប់រៀងរៀបមិនភិតភ័យ ។
ទោះជាមានកង្វល់    ជួបព្យុះខ្យល់ទឹកជន់ក្តី
ព្រះម្ចាស់តែងប្រណី    មិនឲ្យក្ស័យឬលិចលង់ ។
៧- ព្រះអង្គជាជម្រក    ឲ្យខ្ញុំជ្រកមិនឲ្យហ្មង
ការពាររូបខ្ញុំផង    កម្ចាត់បង់អាសន្នភ័យ ។
៨- យើងនឹងប្រដៅអ្នក    ឲ្យស្គាល់ដាក់ផ្លូវប្រពៃ
ផ្តល់យោបល់ថ្លាថ្លៃ    ថែរាល់ថ្ងៃមិនឲ្យឆ្គង ។
៩- កុំឆោតល្ងង់ដូចលា    ឬសេះជាជំនិះម្តង
ដាក់ដែកបង្ខាំផង    រួចមានចងទាំងបង្ហៀរ ។
១០- ជនពាលត្រូវរងគ្រប់    ទុក្ខទោសសព្វវេទនា
ព្រះម្ចាស់តែងមេត្តា    ដល់អ្នកណាពឹងព្រះអង្គ ។
១១- មនុស្សសុចរិតអើយ    កុំកន្តើយសប្បាយឡើង
អស់អ្នកដែលទៀងត្រង់    ស្រែកហ៊ោរផងដោយអំណរ ។

**ទំនុកតម្កើងលេខ ៣៣ (៣២)    បទព្រហ្មគីតិ**

១- មនុស្សដែលសុចរិត    អបអរពិតលើកតម្កើង
មានតែមនុស្សទៀងត្រង់    ដែលចិត្តចង់កោតសរសើរ ។
២- ដេញពិណលើកតម្កើង    ព្រះនៃយើងគ្មានអ្វីស្មើ
លេងចាប៉ីបណ្តើរ    ដេញបង្ហើរខ្សែដប់ថ្វាយ ។

៣- ចូរច្រៀងទំនុកថ្មី ទាំងតន្ត្រីកុំជិនណាយ
សូរសៀងពិរោះក្រៃ ពេលសប្បាយអបអរទ្រង់ ។
៤- ដ្បិតព្រះជាអម្ចាស់ បន្ទូលច្បាស់ពិតទៀងត្រង់
ព្រះអង្គតែងផ្ចិតផ្ចង់ ហើយតម្រង់តាមសន្យា ។
៥- ព្រះអង្គសព្វព្រះទ័យ នឹងសេចក្ដីពិតសត្យា
សុចរិតគ្រប់ប្រការ ហើយរក្សាយុត្តិធម៌ ។
ផែនដីទាំងមូលថ្លែង ខំសម្ដែងដោយអំណរ
ពីហឫទ័យបវរ ករុណាល្អព្រះជាម្ចាស់ ។
៦- ផ្ទៃមេឃហ្វូងតារា កើតដោយសារបន្ទូលច្បាស់
ដោយបញ្ជារបស់ ព្រះជាអម្ចាស់នៃយើង ។
៧- ព្រះអង្គបានធ្វើឲ្យ សមុទ្រជយផ្ដុំគ្នាឡើង
រួចទ្រង់ក៏បង្ខាំង សមុទ្រគាំងមួយកន្លែង ។
៨- សូមឲ្យមនុស្សទាំងអស់ ដែលនៅរស់កោតស្ញប់ស្ញែង
ព្រះមានឫទ្ធិក្រៃលែង គួរស្ញប់ស្ញែងកោតព្រះអង្គ ។
៩- ដ្បិតពេលមានបន្ទូល អ្វីមកមូលមិនរេរង់
តាមបង្គាប់ព្រះអង្គ សព្វអ្វីផងមានទាំងអស់ ។
១០- ទ្រង់បំបែកផែនការ នៃប្រជាអសប្បុរស
កម្រោងការរបស់ ជនទាំងនោះត្រូវរលាយ ។
១១- ឯផែនការព្រះអង្គ ស្ថិតនៅគង់មិនអន្តរាយ
កម្រោងការទាំងឡាយ មិនរលាយនៅស្ថិតស្ថេរ ។
១២- ប្រជាដែលគោរព បម្រើគ្រប់គ្មានទំនេរ
ទុកជាព្រះឥតប្រែ នោះជួយតែសុខគ្រប់គ្រា ។
ជនដែលព្រះអង្គជ្រើស ឥតមានឃ្មើសជាទ្រព្យា
ជារាស្ត្រផ្ទាល់អង្គា នោះមុខជារួចផុតទុក្ខ ។
១៣- ព្រះម្ចាស់ទតមកពី ស្ថានរមណីបរមសុខ
ទតមើលពីលើមក ឃើញមនុស្សយើងទាំងអស់ ។

១៤- ពីព្រះរាជដំណាក់ ល្អសមសក្តិឥតមានទាស់
ទតមើលជនទាំងអស់ ដែលនៅរស់លើផែនដី ។
១៥- គឺពិតជាព្រះអង្គ ដែលបង្កើតចិត្តប្រុសស្រី
ទ្រង់ពិនិត្យរំពៃ មើលសព្វអ្វីដែលគេធ្វើ ។
១៦- ពុំដែលមានស្តេចណា ឈ្នះដោយសារទ័ពពូកែ
ហើយក៏ពុំមានដែរ អ្នកពូកែដោយកម្លាំង ។
១៧- ឯសេះចេះប្រយុទ្ធ ស្ទាត់បំផុតធ្វើចម្បាំង
ទោះបីវាក្លាខ្លាំង ក៏នៅតាំងមិនអាចឈ្នះ ។
១៨- ព្រះអង្គតាមរក្សា អស់អ្នកណាដែលខ្លាចព្រះ
អ្នកពឹងលើអម្ចាស់ ដ៏សប្បុរសមានមេត្តា ។
១៩- ព្រះអង្គបានសង្គ្រោះ ឲ្យគេរស់មានសង្ខារ
ផុតពីក្តីមរណា នៅក្នុងគ្រាដែលអត់ឃ្លាន ។
២០- យើងសូមផ្ញើជីវិត លើព្រះពិតឥតខកខាន
ជាខែលដ៏ចំណាន សង្គ្រោះប្រាណផុតភិតភ័យ ។
២១- យើងខ្ញុំសែនរីករាយ ចិត្តសប្បាយអរពេកក្រៃ
សូមផ្ញើជីវិតថ្លៃ លើព្រះទ័យល្អបំផុត ។
២២- សូមព្រះជាអម្ចាស់ សម្តែងព្រះទ័យវិសុទ្ធ
មេត្តាខ្ពស់បំផុត កាយជីវិតផ្ញើព្រះអង្គ ។

## ទំនុកតម្កើងលេខ ៣៤ (៣៣) បទភាកគតិ

២- ខ្ញុំអរព្រះគុណ អម្ចាស់ពេកពន់ គ្រប់ពេលវេលា សូមលើកតម្កើង
ព្រះអង្គគ្រប់គ្រា ឥតមានរួញរា ឈប់ឈរសោះឡើយ ។
៣- ខ្ញុំខ្ពស់មុខព្រោះ ព្រះម្ចាស់សង្គ្រោះ ខ្ញុំមិនកន្តើយ ចូរអ្នកទន់ទាប
ស្តាប់កុំព្រងើយ នឹងបានធូរស្បើយ អំណរខ្លាំងក្លា ។
៤- សូមមកប្រកាស នឹងខ្ញុំឲ្យច្បាស់ ដោយពោលឡើងថា ព្រះម្ចាស់ថ្កុំថ្កើង
រុងរឿងក្រៃណា យើងនាំគ្នីគ្នា តម្កើងព្រះអង្គ ។

៥- ខ្ញុំបានស្វែងរក ព្រះម្ចាស់តបមក ឥតមានបង្អង់ ទ្រង់បានរំដោះ
ខ្ញុំអស់ទុក្ខផង តក់ស្លុតម្ហូរហ្មង ឆ្លងផុតទាំងអស់ ។
៦- អ្នកដែលសម្លឹង ឆ្ពោះទៅព្រះអង្គ បានសុខឥតមោះ ផុតអស់ទុក្ខសោក
វិយោគរងគ្រោះ ពួកគេទាំងនោះ មិនខកចិត្តឡើយ ។
៧- អស់អ្នកកម្សត់ និងមនុស្សទុរគត គេស្រែកដង្ហោយ ហៅរកព្រះម្ចាស់
ទ្រង់សណ្ដាប់ហើយ សង្គ្រោះគេឲ្យ ផុតពីគ្រោះកាច ។
៨- ទេវទូតរបស់ ព្រះម្ចាស់ទាំងអស់ ថែទាំអ្នកខ្លាច រក្សាការពារ
គេក្រោមអំណាច រំដោះឲ្យរួច ផុតពីទុក្ខភ័យ ។
៩- ចូរអ្នកផ្អែកពឹង ពិសោធន៍ឲ្យដឹង ថាព្រះម្ចាស់ថ្លៃ ទ្រង់មានមេត្តា
សប្បុរសពេកក្រៃ អស់ជនប្រុសស្រី មានជ័យមង្គល ។
១០- ឱប្រជារាស្ត្រ របស់ព្រះម្ចាស់ ចូរកោតខ្លាចដល់ ព្រះម្ចាស់នៃយើង
បានសុខឥតខ្វល់ មិនជួបអំពល់ ឬខ្វះខាតអ្វី ។
១១- អ្នកមានមុខជា ជួបទុក្ខវេទនា ខ្វះម្ហូបចំណី តែអ្នកដែលស្វែង
រកព្រះម្ចាស់ថ្លៃ នឹងមិនខ្វះអ្វី សុខសាន្តតទៅ ។
១២ -ឱកូនចៅអើយ កុំនៅព្រងើយ ស្ដាប់ខ្ញុំប្រដៅ ឲ្យចេះគោរព
ដរាបតទៅ កុំធ្វើល្ងង់ខ្លៅ ត្រូវកោតខ្លាចព្រះ ។
១៣- តើមាននរណា ចង់បានសង្ខារ យឺនយូរត្រចះ មានអ្វីគ្រប់យ៉ាង
មិនខ្វះទាស់សោះ ហើយចង់នៅរស់ សុខសាន្តឬទេ? ។
១៤- ចូរទប់អណ្ដាត កាន់ចិត្តឲ្យស្អាត កុំពោលវៀចវេរ និយាយកុហក
បោកបញ្ឆោតគេ ឬក៏ដៀលដេរ នាំឲ្យអាស្រូវ ។
១៥- ចូរងាកចេញឆ្ងាយ អំពើអន្តរាយ អាក្រក់ជាផ្លូវ សាងអំពើល្អ
ខំស្វែងរកទៅ សុខសាន្តទុកនៅ យ៉ាងអស់ពីចិត្ត ។
១៦- ព្រះម្ចាស់តែងតែ រំពៃមើលថែ អស់មនុស្សសុចរិត ទ្រង់យកព្រះទ័យ
ទុកដាក់ពិតៗ ថែទាំនៅជិត រាល់ទិនទិវា ។
១៧- ព្រះជាអម្ចាស់ តែងតែប្រកាស ប្រឆាំងគ្រប់គ្រា នឹងមនុស្សអាក្រក់
ទុច្ចរិតពាលា កុំមាននរណា នឹកនាដល់ឡើយ ។

១៨- ពេលអ្នកទៀងត្រង់ ស្រែករកព្រះអង្គ ទ្រង់មិនកន្តើយ ព្រះអង្គសណ្ដាប់
ពាក្យគេរួចហើយ រំដោះគេឲ្យ ផុតគ្រោះទាំងឡាយ ។
១៩- ព្រះម្ចាស់គង់ស្ថិត ក្បែរអ្នកគ្រាំចិត្ត មានទុក្ខខ្វល់ខ្វាយ ព្រះអង្គសង្គ្រោះ
អស់អ្នកទាំងឡាយ បានសុខសប្បាយ ផុតទុក្ខវឹងវៃ ។
២០- មនុស្សសុចរិត រមែងជួបពិត ទុក្ខលំបាកក្រៃ ប៉ុន្តែព្រះម្ចាស់
តែងជួយលកលៃ រំដោះផុតភ័យ បានសុខគ្រប់គ្រា ។
២១- ព្រះជាអម្ចាស់ ទ្រង់សប្បុរសណាស់ តាមថែរក្សា ដល់មនុស្សសុចរិត
គ្រប់ៗអាត្មា គ្មានឆ្អឹងមួយណា ត្រូវបាក់បែកឡើយ ។
២២- អំពើអាក្រក់ ខ្ជួលខ្មៅកខ្វក់ នាំឲ្យគេព្រួយ រហូតដល់ស្លាប់
មិនមានអ្នកជួយ គ្មានអ្នកលើកស្ទួយ ដល់ក្ស័យជីវិត ។
អ្នកដែលប្រឆាំង ប្រយុទ្ធតតាំង នឹងមនុស្សសុចរិត តែងតែទទួល
ទុក្ខទោសពិតៗ ក្នុងមួយជីវិត មិនមានខកខាន ។
២៣- ព្រះម្ចាស់សង្គ្រោះ ជីវិតទាំងអស់ ដល់អ្នកដែលបាន បម្រើព្រះអង្គ
ពឹងផ្អែកផ្ញើប្រាណ តែងទទួលបាន សុខផុតទុក្ខទោស ។

## ទំនុកតម្កើងលេខ ៣៥ (៣៤) បទពាក្យ ៧

១- ឱព្រះជាអម្ចាស់ខ្ញុំអើយ កុំនៅកន្តើយសូមប្រឆាំង
តទល់អស់អ្នកដែលចង់ច្បាំង សូមជួយតតាំងកុំសុំថៃ ។
២- ខ្ញុំសូមពឹងផ្អែកលើព្រះអង្គ មេត្តាសូមទ្រង់កុំឆ្មើងឆ្មៃ
យកខែលអាវក្រោះតើនឃ្មាតខ្មី សម្ដែងបារមីសង្គ្រោះផង ។
៣- សូមហូតលំពែងនិងពូថៅ ប្រហារសំដៅពួកយង់ឃ្នង
សូមមានបន្ទូលមកខ្ញុំផង មានតែព្រះអង្គព្រះសង្គ្រោះ ។
៤- សូមឲ្យអ្នកដែលចង់ប្រហារ ជីវិតជីវ៉ារូបខ្ញុំនោះ
ឲ្យវាខកចិត្តបាក់មុខចុះ ដល់ក្ដីអាម៉ាស់ដកខ្លួនថយ ។
៥- នៅពេលទេវទូតព្រះអម្ចាស់ បណ្ដេញគេប្រាសវិលទៅក្រោយ
សូមឲ្យពួកគេខ្ទាតទៅឆ្ងាយ ដូចអង្កាមរាយដោយខ្យល់ផាត់ ។

៦- ទេវទូតព្រះម្ចាស់ដេញមិនឈប់ ទោះថ្ងៃឬយប់មិនឲ្យបាត់
ឲ្យផ្លូវធ្លាប់ភ្លឺប្រែងងឹត ភក់រអិលស្អិតទៅមិនបាន ។
៧- ពួកគេបានដាក់រាយអន្ទាក់ លបពួនចាំស្ទាក់ប៉ងរំខាន
គេជីករណ្ដៅឲ្យធ្លាក់ប្រាណ ដោយចិត្តសាមាន្យមិនទោរទន់ ។
៨- សូមឲ្យពួកគេត្រូវវិនាស ដោយមិនដឹងច្បាស់ទុកជាមុន
ឲ្យជាប់អន្ទាក់របស់សខ្លួន អន្តរាយផ្ទួនៗកុំរំលង ។
៩- ពេលនោះរូបខ្ញុំនឹងត្រេកអរ រីករាយសាទរអស់មួរហ្មង
សប្បាយពន់ពេកគ្រានេះម្ដង ព្រោះតែព្រះអង្គជួយសង្គ្រោះ ។
១០- ខ្ញុំសូមក្រាបទូលយ៉ាងជាក់ច្បាស់ ស្មោះឥតក្រឡះអស់ពីពោះ
គ្មាននរណាដូចព្រះអង្គសោះ ព្រះអង្គរំដោះអ្នកទន់ខ្សោយ ។
ទ្រង់ជួយឲ្យរួចផុតពីដៃ ពួកជនអម្រឹយ៍មិនថ្លោះធ្លោយ
រំដោះអ្នកក្រទុរគតឲ្យ រួចផុតពីដៃមនុស្សទុច្ចរិត ។
១១- សាក្សីក្លែងក្លាយឈរប្រឆាំង រារាំងតតាំងដោយប្រឌិត
ចោទសួរមកខ្ញុំរឿងមិនពិត ដែលខ្ញុំមិនគិតដល់ទាល់សោះ ។
១២- គេធ្វើអាក្រក់មកតបត នឹងអំពើល្អខ្ញុំទាំងអស់
ដែលខ្ញុំបានធ្វើលើគេនោះ ម្ដេចមិនគិតសោះឲ្យទោសពៃរ៍ ។
១៣- ពេលដែលពួកគេមានជំងឺ ចុកចាប់ផ្សាឈឺខ្ញុំលកលៃ
បន្ទាបទាំងខ្លួនតមចំណី អង្វររាល់ថ្ងៃឲ្យពួកគេ ។
១៤- ខ្ញុំបានប្រព្រឹត្តអំពើល្អ ដោយចិត្តស្មោះសរឥតវៀចវេរ
ដូចធ្វើចំពោះមិត្តភក្ដិដែរ ព្រួយចិត្តឥតល្ហែសោកសង្រេង ។
១៥- តែពេលរូបខ្ញុំមានជំងឺ គេមកបញ្ឆឺសើចជាល្បែង
រួមគ្នាប្រឆាំងមិនរអែង ហែកហួរគ្មានក្រែងមិនឈប់ឡើយ ។
១៦- ពួកគេចូលដៃជនពាលា ចោមរោមជន្ទាមិនល្ហែល្ហើយ
មិនឈប់មិនឈរមិនកន្តើយ មិនបង្អង់ឡើយខាំធ្មេញជាក់ ។
១៧- ឱព្រះអម្ចាស់ម្ដេចព្រងើយ ម្ដេចទ្រង់មិនជួយផុតគ្រោះថ្នាក់
ជួយការពារខ្ញុំកុំឲ្យធ្លាក់ ទៅក្នុងអន្ទាក់ពួកសិង្ហសត្វ ។

១៨- ខ្ញុំសូមថ្លែងពាក្យអរព្រះគុណ ព្រះអម្ចាស់ធ្ងន់មិនឲ្យស្ងាត់
សរសើរតម្កើងពន់ពេកក្តាត់ ព្រះតែមួយគត់នៃប្រជា ។
១៩- សូមកុំបណ្តោយឲ្យសត្រូវ ខ្ញុំបានរស់នៅដោយសុខា
កុំឲ្យអ្នកស្អប់ខ្ញុំជន្ទា ពេបជ្រាយលេលាដាក់រូបខ្ញុំ ។
២០- ពួកគេមិនដែលនិយាយល្អ បេះតែភូតភរបងគំនុំ
ប្រឌិតរឿងផ្សេងទោះតូចធំ បោទអ្នកសន្សំសុខក្នុងស្រុក ។
២១- ពួកគេពោលពាក្យបោទដាក់ទោស ថាខ្ញុំធ្វើខុសឲ្យកើតទុក្ខ
គេស្រែកចំអកដាក់នឹងមុខ ថាខ្ញុំគម្រក់គេឃើញហើយ ។
២២- ឱព្រះអម្ចាស់ទតឃើញស្រាប់ សូមទ្រង់ត្រងត្រាប់កុំកន្តើយ
ឱព្រះអង្គអើយជួយឲ្យស្បើយ កុំទៅណាឆ្ងាយពីរូបខ្ញុំ ។
២៣- ឱព្រះអម្ចាស់សូមតើនឡើង កុំនៅផ្ទៃផ្ទើងពួនសំងំ
សូមរកយុត្តិធម៌ឲ្យរូបខ្ញុំ កុំបីបង្អង់សូមជួយផង ។
២៤- ឱព្រះម្ចាស់នៃទូលបង្គំ សូមជួយរូបខ្ញុំសុចរិតត្រង់
កុំបណ្តោយខ្ញុំឲ្យមួរហ្មង គេសប្បាយផងព្រោះតែឈ្នះ ។
២៥- កុំឲ្យគេនាំគ្នាពោលថា ខ្ញុំនេះចាញ់ជាប្រាកដណាស់
កុំឲ្យវាពោលពាក្យផ្តេសផ្តាស ថាអាចបោកប្រាសរូបខ្ញុំបាន ។
២៦- សូមឲ្យអស់អ្នកដែលសប្បាយ រីករាយក្អាកក្អាយទាំងប៉ុន្មាន
ត្រូវអាម៉ាស់មុខទុក្ខពេញប្រាណ កិត្តិយសប៉ុន្មានត្រូវបាត់អស់ ។
២៧- រីអ្នកដែលបានរកយុត្តិធម៌ សុចរិតបវរឲ្យខ្ញុំនោះ
ឲ្យគេពោលពាក្យថ្កើងព្រះម្ចាស់ អ្នកបម្រើព្រះបានសុខសាន្ត ។
២៨- ពេលនោះខ្ញុំនឹងថ្លែងអំពី សុចរិតគ្រប់ទីព្រះថ្កើងថ្កាន
តម្កើងព្រះអង្គខ្ពស់ហួសស្មាន ខ្ពស់ហួសអស់ស្ថានរៀងរាល់ថ្ងៃ ។

## ទំនុកតម្កើងលេខ ៣៦ (៣៥) បទភាគគតិ

២- ខ្ញុំនឹកឃើញអស់ ពាក្យពោលទ្រគោះ របស់ជនពាល ក្នុងពេលបះបោរ
បាក់រុកផ្តិះផ្តៀល ប្រមាថតិះដៀល មិនកោតខ្លាចព្រះ ។

៣- គេពោលបញ្ចើច បញ្ចើសំណើច ជាខ្លួនគ្រាន់ណាស់ មិនទទួលដឹង
ថាមានកំហុស អំពើបាបនោះ គួរស្អប់ពេកក្រៃ ។
៤- គេពោលអាក្រក់ ពាក្យភូតកុហក បោកប្រាសរាល់ថ្ងៃ គេលែងស្គាល់ខុស
ស្គាល់ត្រូវជាអ្វី ពាលាអប្រិយ៍ ប្រព្រឹត្តយង់ឃ្នង ។
៥- ពេលគេនិទ្រា ក៏គេនាំគ្នា រិះគិតកម្រោង អំពើអាក្រក់
មិនព្រមលះបង់ មានះមិនត្រង់ ដើរផ្លូវមិនល្អ ។
៦- បពិត្រព្រះម្ចាស់ ហប្ញទ័យល្អណាស់ ខ្ពង់ខ្ពស់ស្មោះសរ សប្បុរសស្មោះស្ម័គ្រ
ដោយមេត្តាធម៌ ខ្ពស់ស្មើព្ធដី វេហាស៍អាកាស ។
៧- ព្រះហប្ញទ័យ សុចរិតប្រពៃ ត្រចង់ត្រចះ តម្រិះព្រះអង្គ
ជ្រាលជ្រៅខ្លាំងណាស ទ្រង់ជាអម្ចាស់ សង្គ្រោះមនុស្សសត្វ ។
៨- បពិត្រព្រះម្ចាស់ ទ្រង់សប្បុរសណាស់ ករុណាអាណិត ហប្ញទ័យព្រះអង្គ
ខ្ពង់ខ្ពស់ពេកក្តាត់ ទាំងមនុស្សទាំងសត្វ ជ្រកក្រោមបារមី ។
៩- ព្រះអង្គបានផ្តល់ អាហារស្កប់ស្កល់ ឲ្យជនប្រុសស្រី ពីព្រះដំណាក់
មានម្ហូបចំណី ហូរហៀរពេកក្រៃ ឆីតាមសប្បាយ ។
១០-ទ្រង់ជាប្រភព ជីវិតសព្វគ្រប់ ទាំងរូបទាំងកាយ ឲ្យខ្ញុំមានភ្នែក
មើលឃើញវែងឆ្ងាយ ពន្លឺពណ្ណរាយ របស់ព្រះអង្គ ។
១១-សូមទ្រង់ករុណា ផ្តល់ក្តីមេត្តា ដល់អ្នកទៀងត្រង់ សម្តែងហប្ញទ័យ
សុចរិតត្រចង់ ដល់អស់អ្នកជង ស្គាល់ទ្រង់តទៅ ។
១២-សូមកុំឲ្យមនុស្ស កោងកាចទុយ៌ស មិនដឹងខុសត្រូវ ព្រមទាំងជនពាល
អាក្រក់ឃោរឃៅ បណ្តេញខ្ញុំទៅ ឆ្ងាយពីព្រះអង្គ ។
១៣-ជនដែលប្រព្រឹត្ត អំពើទុច្ចរិត បិត្តវៀចមិនត្រង់ ត្រូវបរាជ័យ
មិនអាចស្រោចស្រង់ ទោះបីជាចង់ ក៏ងើបពុំរួច ។

## ទំនុកតម្កើងលេខ ៣៧ (៣៦) បទព្រហ្មគីតិ

១- សូមកុំចងកំហឹង ប្រណែននឹងអ្នកប្រព្រឹត្ត
អំពើទុច្ចរិត និងចូលចិត្តពោលមុសា ។

២- ជ្បិតគេនឹងវិនាស មិនអាចចៀសផុតឡើយណា
ប្រៀបដូចស្មៅឬផ្កា អស់ខ្លឹមសារស្រពោនស្វិត ។
៣- ចូរធ្វើអំពើល្អ ចិត្តស្មោះសរផ្ញើជីវិត
លើព្រះដ៏សក្តិសិទ្ធ នោះអ្នកពិតជាសុខសាន្ត ។
៤- ចូរស្វែងរកមង្គល កុំបីខ្វល់ឬខកខាន
ព្រះអង្គនឹងប្រទាន ឲ្យអ្នកមានតាមបំណង ។
៥- ចូរផ្ញើព្រេងវាសនា ក្នុងហត្ថាព្រះអង្គផង
ព្រះអង្គនឹងគ្រប់គ្រង ឥតមានហ្មងតាមសន្យា ។
៦- ព្រះអង្គនឹងបង្ហាញ ឲ្យគេឃើញយ៉ាងច្បាស់ថា
អ្នកសុចរិតថ្លៃថ្លា ដូចសុរិយាពេញរស្មី ។
៧- ចូរស្ងប់ស្ងៀមចំពោះ ព្រះភក្ត្រព្រះអម្ចាស់ថ្លៃ
កុំខឹងប្រណែនអី នឹងជោគជ័យមនុស្សសុចរិត ។
៨- កំហឹងបោលឲ្យឆ្ងាយ ក្តៅក្រហាយត្រូវឈប់គិត
ព្រោះនាំឲ្យខូចចិត្ត នាំគំនិតកករល្អក់ ។
៩- ព្រះម្ចាស់នឹងកាត់កាល់ អស់អ្នកដែលធ្វើអាក្រក់
តែអ្នកសង្ឃឹមដាក់ ទៅលើព្រះនឹងបានកេរ ។
១០- នៅតែបន្តិចទៀត មនុស្សមានស្នៀតមិនមានទេ
ទោះអ្នកខិរិះរេ រកមើលគេក៏គ្មានអ្វី ។
១១- មនុស្សស្លូតស្មោះសរ គេនឹងទទួលទឹកដី
ជាមត៌កប្រពៃ លែងព្រួយភ័យបានសុខសាន្ត ។
១២- ជនពាលតែងឃុបឃិត រឿងឧក្រិដ្ឋចិត្តសាមាន្យ
ប្រឆាំងឥតស្រាកស្រាន្ត ទៅរំខានមនុស្សសុចរិត ។
១៣- តែព្រះម្ចាស់ចំអក ដាក់ឲ្យពួកជនឧក្រិដ្ឋ
ព្រះអង្គជ្រាបរឿងពិត ព្រោះគេជិតវិនាសហើយ ។
១៤- គេខំហូតផ្ទដាវ យ៉ាងសាហាវមិនកន្តើយ
ប្រហារមិនទុកឡើយ អ្នកខ្សត់ខ្សោយទុរគតត្រង់ ។

១៥- ប៉ុន្តែជាវពួកគេ    នឹងវិលវេបែរតម្រង់
ចាក់ទម្លុះបេះដូង    គេតែម្តងមិនរារែក ។
១៦- ទ្រព្យនៃជនសុចរិត    តិចមែនពិតតែល្អឯក
ប្រសើរជាពន់ពេក    ជាងសម្បត្តិមនុស្សអាក្រក់ ។
១៧- ព្រះអង្គនឹងទម្លាក់    កាច់បំបាក់មនុស្សគម្រក់
តែទ្រង់បែរថ្នមថ្នាក់    ថែទាំអ្នកដែលសុចរិត ។
១៨- ព្រះម្ចាស់យកព្រះទ័យ    ទុកដាក់ក្រៃនឹងជីវិត
រក្សាមិនឲ្យបាត់    នៅស្ថេរស្ថិតជាកេរកោះ ។
១៩- នៅពេលមានអាសន្ន    គេមិនស្លន់ឬអាម៉ាស់
មានអាហារមិនខ្វះ    ទោះប្រទះគ្រោះទុរ្ភិក្ស ។
២០- រីឯមនុស្សអាក្រក់    ចិត្តគម្រក់ទ្រង់មិននឹក
សត្រូវច្រើនសន្ធឹក    ជួបវរវីកវិនាសអស់ ។
២១- បើមនុស្សពាលខ្ចីអ្វី    មិនដែលលៃសងវិញសោះ
រីអ្នកសុចរិតស្មោះ    បេះរំដោះទ្រព្យឥតស្តាយ ។
២២- អ្នកដែលព្រះអម្ចាស់    តែងសន្តោសប្រោសប្រណី
ទ្រង់ប្រទានពរជ័យ    ទាំងទឹកដីទុកជាកេរ ។
រីអ្នកដែលមិនគាប់    មិនសំណព្វទ្រង់បង្វែរ
បណ្តាសាទៅគេ    មិនទុកទេទ្រង់កាត់ចិត្ត ។
២៣- ព្រះម្ចាស់បានពង្រឹង    ជំហរនឹងមនុស្សសុចរិត
ឲ្យបានមាំមួនពិត    រួចទ្រង់គិតសព្វព្រះទ័យ ។
២៤- ទោះបីបើគេភ្លាត់    ជើងមិនស្ទាត់ក៏មិនភ័យ
មិនដួលធ្លាក់ដល់ដី    ព្រោះបារមីព្រះអម្ចាស់ ។
២៥- តាំងពីខ្ញុំក្មេងខ្ចី    មិនដឹងអីលុះចំណាស់
មិនដែលឃើញព្រះម្ចាស់    ទ្រង់បង់បោះអ្នកសុចរិត ។
២៦- មនុស្សស្លូតទៀងត្រង់    ឥតសៅហ្មងតែងអាណិត
អាសូរញាតិឆ្ងាយជិត    គ្មានគំនិតគេកឹបទេ ។

២៧- ចូរកុំធ្វើអាក្រក់ រឿងគម្រក់កុំទៅក្បែរ
នោះអ្នកនឹងស្ថិតស្ថេរ លើដីកេរតរៀងទៅ ។
២៨- ព្រះម្ចាស់សព្វព្រះទ័យ ពន់ពេកក្រៃគ្មានហ្មងសៅ
យុត្តិធម៌ត្រង់ត្រឹមត្រូវ តរៀងទៅទ្រង់មិនភ្លេច ។
ព្រះអង្គមិនបង់បោះ គេទាំងនោះដោយកលល្បិច
ព្រះអង្គជាន់ពន្លិច វិនាសខ្ទេចពូជអាក្រក់ ។
២៩- អ្នកត្រង់នឹងទទួល ដីនិមលជាកេរកោះ
ជីវិតគេនឹងរស់ លើដីនោះរហូតទៅ ។
៣០- មនុស្សសុចរិត គេចូលចិត្តត្រង់ត្រឹមត្រូវ
ពោលពាក្យមិនអាស្រូវ ឥតហ្មងសៅឥតងាករេ ។
៣១- វិន័យព្រះអម្ចាស់ ដិតជាប់ច្បាស់ក្នុងចិត្តគេ
មិនឃ្លាតបាកបែកបែរ ពីមាគ៌ាព្រះអង្គឡើយ ។
៣២- ពួកពាលចាំឃ្លាំមើល យ៉ាងងើលមិនកន្តើយ
លើមនុស្សសុចរិតហើយ មិនព្រងើយរកសម្លាប់ ។
៣៣- ប៉ុន្តែព្រះអម្ចាស់ មិនបង់បោះឲ្យគេស្លាប់
ធ្លាក់ចូលដោយមិនប្រាប់ ជាចំណាប់ជនអាក្រក់
៣៤- ចូរសង្ឃឹមទុកចិត្ត ផ្ញើជីវិតកុំរំអក់
លើព្រះដ៏សប្បុរស ទ្រង់នឹងប្រោសហើយលើកអ្នក ។
ឲ្យគ្រប់គ្រងលើដី មត៌កថ្លៃប្រាកដជាក់
អ្នកនឹងឃើញប្រត្យក្ស មនុស្សអាក្រក់ ។
៣៥- ខ្ញុំឃើញជនបាបកាច ប្រើអំណាចបែបកំរោល
គេលូតលាស់ឡើងផ្គោល ដូចដើមឈើឈើស្លឹកខជវខ្ចី ។
៣៦- ក្រោយមកគេរលាយ សូន្យទៅឆ្ងាយមិនសល់អ្វី
ខ្ញុំខំរករំពៃ មិនឃើញអ្វីទាល់តែសោះ ។
៣៧- ចូរមើលមនុស្សទៀងត្រង់ មិនវៀចវង់ពិតជាស្មោះ
សន្សំសុខទាំងអស់ ខាងមុខនោះនឹងរុងរឿង ។

៣៨- រីឯពួកមនុស្សបាប ដូចភ្លើងឆាបឬខ្យល់បើង
ព្រះអង្គកាត់ពូជពង្ស ពួកមនុស្សពាលទមិឡបោលចេញ ។
៣៩- ព្រះម្ចាស់តែងសង្គ្រោះ មនុស្សទាំងអស់ឥតទោរម្ចេញ
ជាកំពែងពោរពេញ ការពារពាំងគ្រោះអាសន្ន ។
៤០- ព្រះអម្ចាស់សង្គ្រោះ និងរំដោះមិនភាំងភាន់
សង្គ្រោះគេបន្ទាន់ ព្រោះជ្រកកោនក្រោមបារមី ។

## ទំនុកតម្កើងលេខ ៣៨ (៣៧) បទពាក្យ ៧

២- ឱព្រះជាអម្ចាស់ខ្ញុំអើយ សូមកុំកន្ដើយដាក់ទោសខ្ញុំ
សូមកុំពិរោធហើយគួនគុំ សូមដាក់ទោសខ្ញុំតាមកំហុស ។
៣- ព្រួញនៃព្រះអង្គខ្ញុំចុកចាប់ ឈឺស្មើរតែស្លាប់គ្មានស្រណោះ
ព្រះហស្តសង្កត់មិនព្រមប្រោស រូបខ្ញុំធ្វើខុសសែនឈឺជ្យា ។
៤- ពេលដែលព្រះអង្គពិរោធ ខ្ញុំឈឺចាក់ដោតឥតឧបមា
ឆ្អឹងឆ្អែងពុកផុយអស់ហើយណា ព្រោះមានវេរាបាបអនេក
៥- មែនហើយខ្ញុំខុសច្រើនពេកពន់ រហូតជោរជន់ស្មើរដល់មេឃ
ហាក់ដូចបន្ទុកធ្ងន់អនេក ទ្រូងខ្ញុំស្មើរបែកស្រែកក៏មិនបាន ។
៦- របួសខ្ញុំក្លាយជាដំបៅ រលួយយូរទៅស្អុយពេញប្រាណ
ព្រោះគំនិតខ្ញុំដូចតិរច្ឆាន លេលាសាមាន្យមិនសមសួន ។
៧- ទូលបង្គំឈឺចាប់យ៉ាងខ្លាំង រហូតចំកោងអស់ទាំងខ្លួន
ទុក្ខធ្ងន់ក៏ធ្លាក់មកជួនៗ ស្ថិតនៅខ្វាប់ខ្លួនពេញមួយថ្ងៃ ។
៨- ខ្ញុំសែនរងារក្តៅទាំងប្រាណ ទ្រាំស្មើរមិនបានសព្វរាងកាយ
ឈឺចុកចាប់ណាស់ព្រះម្ចាស់អើយ ស្លាប់ឥឡូវហើយសូមមេត្តា ។
៩- ខ្ញុំអស់កម្លាំងហេវខ្សោះល្ងើយ ស្រែកហៅខ្ញើយៗញ័រកាយា
ខ្ញុំស្រែកថ្ងូរថ្ងូចចុកពើតជ្យា ឈឺឥតឧបមាស្មើរក្ស័យប្រាណ ។
១០- បពិត្រម្ចាស់អើយព្រះអង្គ ឈ្វេងយល់ចិត្តបងទាំងប៉ុន្មាន
ទ្រង់សណ្ដាប់ខ្ញុំមិនដែលខាន សំឡេងខ្ញុំបានថ្ងូរស្រែកហៅ ។

១១- បេះដូងខ្ញុំចាប់ផ្ដើមញាប់ញ័រ ឯកម្លាំងក៏ចុះខ្សោយទៅ
ភ្នែកប្រែស្រវាំងជាមិនត្រូវ ទោះជាមើលផ្លូវក៏មិនបាន ។
១២- មិត្តភក្ដិទាំងអ្នកធ្លាប់ជិតស្និទ្ធ មិនហ៊ានចូលជិតនាំរំខាន
ព្រោះខ្លាចដំបៅសព្វទាំងប្រាណ ទោះញាតិសន្ដានក៏គេចឆ្ងាយ ។
១៣- ពួកគេចាំឃ្លាំចាប់ប្រហារ ឲ្យខ្ញុំមរណាគេសប្បាយ
គេដាក់អន្ទាក់សើចក្អាកក្អាយ ឲ្យខ្ញុំអន្តរាយវិនាសបង់ ។
១៤- ខ្ញុំធ្វើមិនឮសព្វអ្វីៗ ទោះជិតឆ្ងាយក្ដីដូចមនុស្សថ្លង់
មាត់មិននិយាយចិត្តមិនចង់ ធ្វើដូចមនុស្សល្ងង់គមិនស្ដី ។
១៥- រូបខ្ញុំដូចជាមនុស្សដែលឈឺ អ្នកមានជំងឺមិនឮអ្វី
និយាយមិនរួចពិបាកក្រៃ ទោះជាចង់ស្ដីក៏មិនបាន ។
១៦- បពិត្រព្រះម្ចាស់ខ្ញុំសូមថ្វាយ ទាំងជីវិតកាយទាំងអង្គប្រាណ
ព្រះម្ចាស់ជាព្រះដ៏ថ្កើងថ្កាន ទ្រង់តបមិនខានឆ្លើយមកខ្ញុំ ។
១៧- សូមកុំបណ្ដោយឲ្យពួកខ្មាំង សប្បាយចិត្តខ្លាំងពេលខ្ញុំយំ
វេទនាឈឺចាប់រងទុក្ខធំ ឬឃើញរូបខ្ញុំទន់ជើងដួល ។
១៨- ខ្ញុំធ្លាក់ខ្លួនស្គមស្គាំងរីងរៃ ទុក្ខព្រួយរាល់ថ្ងៃទ្រូងឆាបឆួល
ឈឺចាប់ជានិច្ចឥតប្រែប្រួល ខ្លួនខ្ញុំចង់ដួលកាយទោរទន់ ។
១៩- ពេលនេះរូបខ្ញុំសុំសារភាព កំហុសទោសបាបកាលគ្រាមុន
ទុក្ខព្រួយក្នុងចិត្តច្រើនពេកពន់ ដូចលីសែងធ្ងន់ព្រោះបាបកម្ម ។
២០- ឯខ្មាំងសត្រូវខ្ញុំទាំងអស់ សាច់ឈាមស្រស់បស់រាងកាយមាំ
អស់អ្នកដែលធ្លាប់ស្អប់រូបខ្ញុំ គេចូលមកជុំគ្នាច្រើនណាស់ ។
២១- ពួកអ្នកដែលប្រព្រឹត្តមិនល្អ នាំគ្នាឈូរឆមីរដេរដាស
បោទប្រកាន់ខ្ញុំឥតអៀនខ្មាស ព្រោះរូបខ្ញុំនេះខំធ្វើល្អ ។
២២- ឱព្រះម្ចាស់អើយកុំបង់បោះ បោលខ្ញុំឲ្យរស់ទាំងត្រដរ
មេត្តារូបខ្ញុំសូមអង្វរ កុំយាងចេញចរខ្ញុំខ្លោចផ្សារ ។
២៣- ឱព្រះអម្ចាស់ព្រះសង្គ្រោះ សូមជួយឲ្យរស់ផុតមរណា
យាងមកឆាប់ៗស្រង់សង្ខារ នោះទើបជីវាផុតក្សិណក្ស័យ ។

## ទំនុកតម្កើងលេខ ៣៩ (៣៨) បទកាកគតិ

២- ខ្ញុំនឹកគិតថា នូវគ្រប់កិច្ចការ ដែលខ្ញុំប្រព្រឹត្ត ខ្ញុំត្រូវប្រយ័ត្ន
ខ្លាចមនុស្សឆ្ងាយជិត នាំបាបឧក្រិដ្ឋ ឲ្យខ្លួនអប្រិយ៍ ។
ខ្ញុំខ្លាចមានបាប អាក្រក់ឆ្អេះឆ្អាប ដោយពាក្យសម្ដី ដរាបណាមនុស្ស
ទុយ៌សព្រៃផ្សៃ នៅក្បែររាល់ថ្ងៃ ខ្ញុំមិនស្ដីទេ ។
៣- ខ្ញុំតែងបិទមាត់ ទោះបីឃើញគាត់ បម្រើនឡើងទ្វេ ខ្ញុំមិននិយាយ
មិនបញ្ចេញស្ដីទេ ដូច្នេះកាន់តែ ឈឺចាប់ខ្លាំងក្រៃ ។
៤- ខ្ញុំក្ដៅចិត្តខ្លាំង ដូចជាមានភ្លើង ឆាបឆេះក្នុងកាយ រហូតលែងទ្រាំ
តទៅទៀតហើយ ខ្ញុំក៏ដង្ហោយ ស្រែកពោលឡើងថា ។
៥- ឱព្រះម្ចាស់អើយ សូមសម្ដែងឲ្យ ខ្ញុំដឹងអាត្មា ថាជីវិតខ្ញុំ
មានដល់ត្រឹមណា ចុះតើសង្ខារ ជុំយយ៉ាងដូចម្ដេច? ។
៦- ព្រះម្ចាស់នាំយក កំណើតខ្ញុំមក ដូចទឹកប្រេីនតិច ដក់លើស្លឹកឈូក
ជួនងើបជួនលិច តាមខ្យល់ខ្លាំងតិច ដែលបានបោកបក់ ។
ជីវិតសត្វលោក ដែលបានកើតមក ចំពោះព្រះភក្ត្រ អាយុសង្ខារ
នៃជនម្នាក់ៗ ប្រៀបបានខ្យល់បក់ មួយដង្ហើមខ្លី ។
៧- ជីវិតអណ្ដែត រសាត់ត្រសែត គ្មានគោលដៅអ្វី ដូចជាស្រមោល
តាមប្រាណរាល់ថ្ងៃ ទោះធ្វើអ្វីៗ ក៏ឥតបានការ ។
គេប្រមូលទ្រព្យ សម្បត្តិគួរគាប់ នៅក្បែរអាត្មា តែគេពុំដឹង
ទ្រព្យសព្វប្រការ បានលើនរណា នៅគ្រាចុងក្រោយ ។
៨- ឱព្រះអម្ចាស់ បើសិនដូច្នោះ ម្ដេចទ្រង់បណ្ដោយ ឲ្យទូលបង្គំ
ពឹងអ្វីថ្ងៃក្រោយ មានតែទ្រង់ហើយ ដែលខ្ញុំសង្ឃឹម ។
៩- សូមជួយរំដោះ ឲ្យខ្ញុំផុតគ្រោះ រួចពីបាបកម្ម ដែលខ្ញុំបានសាង
យូរថ្ងៃខែឆ្នាំ កុំទុកឲ្យខ្ញុំ ត្រូវគេមើលងាយ ។
១០-ខ្ញុំស្ងៀមមិនស្ដី មិននិយាយអ្វី នាំចិត្តរាយមាយ ស៊ូសំងំស្ងៀម
បៀមទុកក្នុងកាយ ដ្បិតព្រះអង្គហើយ ដាក់ទោសរូបខ្ញុំ ។

១១- សូមទ្រង់មេត្តា កុំដាក់ទោសា មកទូលបង្គំ ខ្ញុំស្ទើរតែស្លាប់
ឈឺចាប់អួលធំ កើតទុក្ខរណ្តំ ព្រោះព្រះអង្គវាយ ។
១២- ពេលទ្រង់ប្រដៅ មនុស្សល្ងង់ខ្លៅ មិនដឹងសេចក្តី ព្រះអង្គធ្វើឲ្យ
របស់ទាំងឡាយ វិនាសអន្តរាយ អស់មិនសល់ទេ ។
១៣- ឱព្រះម្ចាស់អើយ កុំគង់កន្តើយ សណ្តាប់កុំប្រែ ពាក្យខ្ញុំអង្វរ
មានជាហូរហែ កុំក្រឡះកែ គេចបែរពីខ្ញុំ ។
សូមកុំព្រងើយ ពេលនេះឯងហើយ ស្តាប់ទំនួញយំ ខ្ញុំគ្រាន់តែស្នាក់
មានអ្វីមិនសម ដូចបុព្វបុរសខ្ញុំ ពេលមុនប៉ុណ្ណោះ ។
១៤- សូមបែរភក្ត្រា ដោយក្តីមេត្តា ឲ្យខ្ញុំស្រឡះ ផុតទុក្ខសោយសោក
បាបកម្មដ៏ក្រាស់ មុនរូបខ្ញុំនេះ លាចាកលោកទៅ ។

## ទំនុកតម្កើងលេខ ៤០ (៣៩) បទពាក្យ ៧

២- ខ្ញុំខំព្យាយាមចាំព្រះម្ចាស់ ព្រះអង្គបានប្រោសព្រះកាណ៌ផ្ទៀង
ស្តាប់សូរសម្រែកមិនលំអៀង ពាក្យខ្ញុំពិតទៀងស្មោះឥតអាក់ ។
៣- ព្រះអង្គយកខ្ញុំពីរណ្តៅ ពីភក់ជ្រាំជ្រៅយកមកដាក់
នៅលើថ្មដាគ្មានថ្នាំងថ្នាក់ ថែទាំទុកដាក់ខ្ញុំរុងរឿង ។
៤- ព្រះអង្គប្រទានខ្ញុំឲ្យច្រៀង បទថ្មីសំនៀងលើកតម្កើង
មនុស្សច្រើននឹងឃើញក្អាកក្អាយឡើង ព្រះម្ចាស់ថ្កុំថ្កើងគេកោតខ្លាច ។
៥- ជនណាដែលបានផ្ញើជីវិត លើព្រះមានឫទ្ធិដ៏អង់អាច
មិនបែរគោរពទៅខ្លួបខ្លាច ព្រះមានអំណាចព្រះបោកប្រាស ។
៦- បពិត្រព្រះម្ចាស់ព្រះនៃខ្ញុំ ព្រះអង្គឧត្តមប្រសើរណាស់
ការអស្ចារ្យទ្រង់ច្រើនដេរដាស ជាព្រះសង្គ្រោះមិនបែកបែរ ។
ព្រះអង្គក៏មានកម្រោងការ ច្រើនឥតឧបមាឥតងាករេ
គ្មាននរណាស្មើព្រះអង្គទេ ការអស្ចារ្យទ្រង់រាប់មិនអស់ ។
៧- ព្រះអង្គមិនចង់បានតង្វាយ យញ្ញបូជាថ្វាយអ្វីទាល់សោះ
ទ្រង់បើកត្រចៀកខ្ញុំទាំងអស់ ស្តាប់ព្រះតម្រិះនៃព្រះអង្គ ។

៨- ដូច្នេះរូបខ្ញុំសូមពោលថា បពិត្រករុណាដ៏ឧត្តុង្គ
ខ្ញុំប្រព្រឹត្តតាមឥតវេរង់ តាមសេចក្ដីក្នុងព្រះគម្ពីរ ។
៩- ខ្ញុំសែនពេញចិត្តធ្វើតាមព្រះ ហឫទ័យអម្ចាស់គ្រប់ទិសទី
វិន័យទ្រង់ជិតជាប់ជីវី ក្នុងចិត្តគិតពីទ្រង់ជានិច្ច ។
១០- ខ្ញុំនឹងប្រកាសធម៌មេត្តា ធម៌ករុណាធម៌សុចរិត
ព្រះអង្គជ្រាបហើយទ្រង់អាណិត ខ្ញុំថ្លាថ្លែងឥតឈរឈប់សោះ ។
១១- ខ្ញុំមិនលាក់ទេក្ដីសុចរិត ទុកក្នុងដួងចិត្តតែងប្រកាស
ព្រះហឫទ័យនៃព្រះអម្ចាស់ ដែលបានសង្គ្រោះទូលបង្គំ ។
រូបខ្ញុំពុំបាននៅស្ងាត់ស្ងៀម សំងំអឹមអៀនក្នុងប្រជុំ
ពីព្រះហឫទ័យដ៏ឧត្ដម ព្រះម្ចាស់ដ៏ធំលើលោកា ។
១២- បពិត្រព្រះម្ចាស់តែងអាណិត អាសូរពេកពិតករុណា
ខ្ញុំមិនឈប់ទេថ្លែងវាចា ពីព្រះមេត្តាដ៏ស្មោះត្រង់ ។
១៣- ទុក្ខលំបាកច្រើនឥតគណនា រួបរិតអាត្មាមិនវេរង់
កំហុសខ្ញុំផ្ទាល់តាមញុះញង់ ឥតមានបង្អង់គ្មានប្រណី ។
ធ្វើឲ្យរូបខ្ញុំប្រែងងឹត មើលមិនឃើញពិតសព្វអ្វីៗ
កំហុសខ្ញុំមានច្រើនពេកក្រៃ ច្រើនជាងសរសៃសក់ទៅទៀត ។
១៤- ឱព្រះអម្ចាស់សូមរំដោះ រូបខ្ញុំឲ្យរស់កុំបីឃ្លាត
យាងមកសង្គ្រោះកុំរវាត ជួយប្រោសម្ដងទៀតឲ្យបានរស់ ។
១៥- ឲ្យអ្នកដែលចង់ដកជីវិត ជួបភាពងងឹតរងទុក្ខទោស
សប្បាយព្រោះឃើញខ្ញុំរងគ្រោះ បាក់មុខអាប់យសដកខ្លួនថយ ។
១៦- សូមឲ្យអស់អ្នកដែលពេបជ្រាយ ចំអកមើលងាយជាញឹកញយ
ត្រូវអាម៉ាស់មុខទាំងមុខក្រោយ រួចហើយសូមឲ្យបរាជ័យ ។
១៧- រីឯអស់អ្នកដែលស្វែងសួះ រកព្រះអម្ចាស់បានរីករាយ
ថ្លែងឥតឈប់ឈរអរក្អាកក្អាយ យើងខ្ញុំឱនកាយថ្កើងព្រះអង្គ ។
១៨- រូបខ្ញុំជាមនុស្សក្រីក្រពិត តែព្រះគួរគិតខ្ញុំឥតហ្មង
ព្រះអង្គតែងតែជួយចម្លង សង្គ្រោះសណ្ដោងមិនដែលខាន ។

## ទំនុកតម្កើងលេខ ៨១ (៨០) បទកាកគតិ

២- អ្នកដែលយកចិត្ត នឹងមនុស្សកម្សត់ ទុរគតក្រីក្រ នឹងបានក្ដីសុខ
សិរីបវរ ពេលអាសន្នក្រ ព្រះនឹងរំដោះ ។
៣- ទ្រង់នឹងរក្សា អាយុសង្ខារ ឲ្យផុតពីគ្រោះ ហើយឲ្យអ្នកនោះ
បានសុខឥតមោះ មង្គលឥតខ្ចោះ នៅលើដែនដី ។
ទ្រង់មិនបណ្ដោយ ឲ្យរូបគេធ្លាយ ធ្លាក់ទៅក្នុងដៃ ពួកមនុស្សខិលខូច
កោងកាចព្រៃផ្សៃ ជនពាលចង្រៃ ទាំងនោះបានឡើយ ។
៤- ទ្រង់រក្សាថែ ថ្នាក់ថ្នមរូបគេ មិននៅកន្ដើយ ពេលឈឺចុកចាប់
នឹងបានធូរស្បើយ ទ្រង់មិនបណ្ដោយ ឲ្យគេគ្រាំគ្រា ។
៥- ខ្ញុំតែងតែនឹក រាល់ល្ងាចយប់ព្រឹក នឹកគ្រប់វេលា ឱព្រះម្ចាស់អើយ
សូមទ្រង់មេត្តា ដ្បិតខ្ញុំនេះណា សាងបាបដ៏ធ្ងន់ ។
៦- សត្រូវរបស់ ខ្ញុំនេះទាំងអស់ នាំគ្នារិះគន់ និយាយអាក្រក់
រួចគេបែរបន់ ឲ្យរូបខ្ញុំសូន្យ វិនាសបង់ទៅ ។
៧- អ្នកដែលបានមក សាកសួរសុខទុក្ខ ចិត្តគេអាស្រូវ គេមកប្រមូល
ដំណឹងមិនត្រូវ លុះពេលចេញទៅ និយាយបរិហារ ។
៨- អស់អ្នកដែលស្អប់ និយាយខ្សៀវខ្សឹប ដាក់គ្រប់គ្នីគ្នា ពីទូលបង្គំ
រូបខ្ញុំនេះថា នឹងរងវេទនា រហូតដល់ក្ស័យ ។
៩- គេពោលឡើងថា ឈឺមើលមិនជា រស់នៅធ្វើអ្វី គាត់ក្រោកពុំរួច
រស់មិនប្រពៃ នាំធ្ងន់ដែនដី គួរតែស្លាប់ទៅ ។
១០- សូម្បីមិត្តភក្តិ ធ្លាប់ស្និទ្ធស្មោះស្ម័គ្រ ក៏គេមិនត្រូវ បែរមកប្រឆាំង
ដូចខ្មាំងសត្រូវ ធ្លាប់ដើររួមផ្លូវ រួមតុអាហារ ។
១១- ព្រះអម្ចាស់អើយ សូមកុំកន្ដើយ ប្រោសខ្ញុំឲ្យជា ខ្ញុំនឹងតបត
ទៅលើពួកវា សូមទ្រង់ករុណា ឲ្យខ្ញុំសមចិត្ត ។
១២- បើសិនពួកខ្មាំង លែងមកប្រឆាំង នោះខ្ញុំនឹកគិត ថាព្រះអម្ចាស់
ស្រឡាញ់ខ្ញុំពិត ព្រោះបច្ចាមិត្ត ត្រូវបរាជ័យ ។

១៣- ព្រះអង្គជួយខ្ញុំ ផុតអស់ទុក្ខធំ រោគាទាំងឡាយ បានជាទាំងស្រុង
ទាំងប្រទានឲ្យ ខ្ញុំគង់ជាមួយ ព្រះអង្គតទៅ ។
១៤- សូមលើកព្រះម្ចាស់ ខ្ពង់ខ្ពស់ខ្លាំងណាស់ មិនដែលអាស្រូវ ជាព្រះរបស់
អ៊ីស្រាអែលតទៅ ព្រះអង្គគង់នៅ អង្វែងវៀងអើយ ។

## ទំនុកតម្កើងលេខ ៤២ (៣១) បទកាកគតិ

២- បពិត្រព្រះម្ចាស់ ខ្ញុំប្រាថ្នាណាស់ ចង់នៅជាមួយ គិតដេកមិនលក់
យប់នឹកថ្ងៃព្រួយ ចង់នៅជាមួយ ដូចក្តាន់រកទឹក ។
៣- ខ្ញុំស្រេកខ្ញុំឃ្លាន ព្រះម្ចាស់ដ៏មាន បារមីមានឫទ្ធិ ព្រះជន្មគង់នៅ
ស្ថិតស្ថេរពិតៗ ខ្ញុំចង់នៅជិត ព្រះភក្ត្រព្រះអង្គ ។
៤- ខ្ញុំស្រក់ទឹកភ្នែក ស្រែកទួញយំយែក ឥតមានបង្អង់ ទាំងយប់ទាំងថ្ងៃ
ចិត្តនៅតែចង់ ស្វែងរកព្រះអង្គ គង់នៅឯណា ។
៥- ខ្ញុំយំខ្ញុំសោក ស្រណោះស្រណោក នឹកឃើញកាលគ្រា ខ្ញុំដឹកនាំមុខ
អស់ទាំងប្រជា ច្រើនឥតគណនា ឆ្ពោះទៅដំណាក់ ។
គេស្រែកគេហ៊ោ គេមោទនអំណរ ក្អាកក្អាយឥតអាក់ គេអរព្រះគុណ
ព្រះខ្ពស់ហួសថ្នាក់ មិនដែលអន់អាក់ សប្បាយពេកក្រៃ ។
៦- ខ្ញុំនឹកគិតថា តើខ្ញុំនេះណា ស្រយុតចិត្តថ្វី តូចចិត្តខ្លួនឯង
តើបានការអី ផ្ញើជីវិតថ្លៃ លើព្រះម្ចាស់ទៅ ។
ខ្ញុំមុខជានឹង សរសើរតម្កើង មិនបង្អង់នៅ ពីនេះទៅមុខ
រហូតតទៅ ព្រះអង្គគង់នៅ ជាព្រះសង្គ្រោះ ។
៧- ព្រះអម្ចាស់អើយ រូបខ្ញុំនេះហើយ ស្រយុតចិត្តណាស់ ហេតុនេះទើបខ្ញុំ
នឹកដល់ព្រះម្ចាស់ ឥតមានក្រឡះ មួយវេលាណា ។
៨- ព្រះអង្គធ្វើឲ្យ កង្វល់មុខក្រោយ ធ្លាក់ជួនៗគ្នា មកលើរូបខ្ញុំ
បីដូចគង្ការ ហូរធ្លាក់ខ្ទ័រខ្ទារ ពីគីរីខ្ពស់ ។
៩- សូមព្រះមេត្តា សម្តែងករុណា ស្មោះស្ម័គ្រចំពោះ ខ្ញុំនៅពេលថ្ងៃ
ពេលយប់ស្រណោះ ខ្ញុំច្រៀងពិរោះ តម្កើងព្រះអង្គ ។

| | | | | |
|---|---|---|---|---|
| ១០- | ខ្ញុំទូលព្រះម្ចាស់ | ហេតុអ្វីពេលនេះ | ព្រះអង្គបោះបង់ | ទ្រង់ជាថ្មដា |
| | ស្ថិតស្ថេរគង់វង្ស | ហេតុអ្វីឲ្យខ្មាំង | បៀតបៀនរូបខ្ញុំ | ។ |
| ១១- | ខ្មាំងសត្រូវដៀល | ប្រមាថឆ្កឹះឆ្កៀល | ខ្ញុំស្ទើរស្រែកយំ | គេចេះតែពោល |
| | មកទូលបង្គំ | ថាតើព្រះខ្ញុំ | នោះនៅឯណា? | ។ |
| | ខ្ញុំឈឺចុកចាប់ | ដូចគេបាក់កាប់ | សព្វពេញកាយា | គេស្រែកក្ដែងៗ |
| | គ្រប់ពេលវេលា | ខ្ញុំស្ទើរមរណា | លាភពដែនដី | ។ |
| ១២- | ខ្ញុំនឹកគិតថា | តើខ្ញុំនេះណា | ស្រយុតចិត្តថ្វី | តូចចិត្តខ្លួនឯង |
| | តើបានការអ្វី | ផ្ញើជីវិតថ្លៃ | លើព្រះម្ចាស់ទៅ | ។ |
| | ខ្ញុំមុខជានឹង | សរសើរតម្កើង | មិនបង្អង់នៅ | ពីនេះទៅមុខ |
| | រហូតតទៅ | ព្រះអង្គគង់នៅ | ជាព្រះសង្គ្រោះ | ។ |

## ទំនុកតម្កើងលេខ ៤៣ (៤២) — បទពាក្យ ៧

| | | | |
|---|---|---|---|
| ១- | ឱព្រះជាអម្ចាស់ខ្ញុំអើយ | សូមកុំកន្តើយរកយុត្តិធម៌ | |
| | សូមជួយកាន់ក្ដីទល់តបត | ពួកមនុស្សមិនល្អមនុស្សទុច្ចរិត | ។ |
| ២- | បពិត្រព្រះជាអម្ចាស់អើយ | ព្រះអង្គនេះហើយជួយជីវិត | |
| | ទ្រង់ជាកំពែងបាំងជុំជិត | សូមទ្រង់អាណិតកុំបោះបង់ | ។ |
| ៣- | សូមផ្ដល់ពន្លឺនិងក្ដីពិត | ឲ្យនៅស្ថេរស្ថិតហើយតម្រង់ | |
| | ទៅភ្នំវិសុទ្ធដ៏ផូរផង់ | ដំណាក់ព្រះអង្គសមសព្វគ្រប់ | ។ |
| ៤- | ខ្ញុំនឹងឆ្ពោះទៅទីអាសនៈ | ព្រះអង្គឥតអាក់ជាប្រភព | |
| | នៃក្ដីអំណរដ៏លើសលប់ | តម្កើងមិនឈប់ដោយតន្ត្រី | ។ |
| ៥- | ខ្ញុំតែងតែនឹកគិតឥតភ្លេច | «តើខ្ញុំស្រយុតចិត្តធ្វើអ្វី | |
| | ចូរផ្ញើជីវិតកុំសោកស្ដាយ | ផ្ញើទាំងរូបកាយនឹងទ្រង់ទៅ» | ។ |
| | ខ្ញុំមុខជានឹងលើកតម្កើង | ព្រះអង្គខ្ពស់ឡើងមិនអាស្រូវ | |
| | ជាព្រះសង្គ្រោះល្អត្រឹមត្រូវ | ឈ្នះអស់សត្រូវគ្រប់ទិសទី | ។ |

## ទំនុកតម្កើងលេខ ៤៤ ៩៤៣) បទកាកគតិ

២- បពិត្រព្រះម្ចាស់ ដូនតាចាស់ៗ ធ្លាប់រៀបរាប់ប្រាប់ ឲ្យយើងខ្ញុំឮ
ហើយបានត្រងត្រាប់ ស្នាព្រះហស្តគ្រប់ ដែលទ្រង់ប្រព្រឹត្ត ។
៣- ព្រះអង្គប្រដេញ ជាតិនានាចេញ មិនឲ្យនៅជិត ដោយសារបារមី
ព្រះអង្គមានឫទ្ធិ ឲ្យរាស្ត្រមកស្ថិត ជុំជិតការពារ ។
៤- ទឹកដីទាំងអស់ គឺមិនមែនរាស្ត្រ ឈ្នះមកដោយសារ កម្លាំងអាវុធ
ខ្លួនគេឡើយណា ឬឈ្នះដោយសារ កម្លាំងខ្លួនអី ។
គឺគេបានឈ្នះ ដោយសារតេជះ ឫទ្ធីបារមី និងព្រះបេស្តា
ព្រះអង្គខ្លាំងក្រៃ ព្រោះព្រះអង្គថ្លៃ ស្រឡាញ់គេណាស់ ។
៥- បពិត្រព្រះអើយ ព្រះអង្គនេះហើយ ជាក្សត្រជាក់ច្បាស់ មានតែទ្រង់ទេ
ផ្តល់ជ័យជម្នះ ដល់ប្រជារាស្ត្រ បានសុខសិរី ។
៦- ដោយសារទ្រង់ហើយ យើងខ្ញុំបានស្បើយ យកជម្នះជ័យ លើបច្ចាមិត្រ
ដោយព្រះនាមល្បី បង្ក្រាបអស់ដៃ អ្នកដែលប្រឆាំង ។
៧- ខ្ញុំមិនផ្អែកពឹង ទៅលើពំនឹង ធ្នូជាកម្លាំង ក៏មិនមានជ័យ
ដោយដាវចម្បាំង គឺពឹងរនាំង របាំងព្រះម្ចាស់ ។
៨- មានតែព្រះអង្គ ដែលបានតម្រង់ ឲ្យខ្ញុំបានឈ្នះ លើពួកបច្ចា
និងមនុស្សទាំងអស់ ដែលស្អប់ខ្ញុំនោះ អាម៉ាស់មុខក្រៃ ។
៩- យើងខ្ញុំទាំងអស់ ថ្កើងសិរីយស ព្រះអម្ចាស់ថ្លៃ ខ្ញុំលើកតម្កើង
ទាំងយប់ទាំងថ្ងៃ តម្កើងបារមី របស់ព្រះអង្គ ។
១០- តែឥឡូវនេះ ព្រះអង្គបានលះ បោលខ្ញុំសូន្យបង់ មិនយាងជាមួយ
មិនជួយតម្រង់ មិននាំទ័ពផង ឲ្យខ្ញុំបាក់មុខ ។
១១- ព្រះអង្គធ្វើឲ្យ ខ្ញុំដកទ័ពថយ នៅមិនបានសុខ មុខបច្ចាមិត្ត
ដែលបានសម្រុក ប្រមូលទ្រព្យទុក ធ្វើជាជយភណ្ឌ ។
១២- ព្រះអង្គប្រគល់ រូបយើងខ្ញុំផ្ទាល់ ឲ្យខ្មាំងជិះជាន់ គេលេបត្របាក់
សង្កត់សង្កិន ក៏ចាយរូបខ្ញុំ ទៅស្រុកនានា ។

១៣- ព្រះអង្គបានលក់ រាស្ត្រអស់ទាំងស្រុក ថោកឥតឧបមា ខ្ញុំស្មានមិនយល់
ទ្រង់គ្មានករុណា ម្តេចធ្វើច្នេះណា លក់មិនចំណេញ ។
១៤- ព្រះអង្គបណ្តោយ ប្រទេសមុខក្រោយ ជិតខាងជុំវិញ មើលងាយយើងខ្ញុំ
ចំអកជ្រក់ជ្រេញ ខ្ញុំសែនទោម្នេញ ដោយក្តីអាម៉ាស់ ។
១៥- ព្រះអង្គធ្វើឲ្យ ប្រជាជិតឆ្ងាយ យករឿងខ្ញុំនេះ ជាល្បែងលេងសើច
ចំអកដៀលត្មះ ឲ្យពួកទាំងនេះ មើលងាយយើងខ្ញុំ ។
១៦- ខ្ញុំសែនអៀនខ្មាស មនុស្សម្នាដេរដាស មើលងាយសើចយំ ថ្ងៃដេកកើតទុក្ខ
យប់ដេកសំងំ អាម៉ាស់មុខធំ និយាយមិនបាន ។
១៧- ពេលខ្ញុំឮសូរ សម្រែកខ្លាំងហ៊ោរ ប៉ុនប៉ងរំខាន ចង់ចងគំនុំ
ឥតឈប់ស្រាកស្រាន្ត បន្ទោកទាំងប្រាណ យើងដូចសត្វជាតុ ។
១៨- ឱព្រះម្ចាស់អើយ ហេតុទាំងនេះអើយ កើតហើយកើតទៀត យើងខ្ញុំពុំភ្លេច
មិនបែកឃ្លាឃ្លាត ហើយមិនរវាត សម្ពន្ធមេត្រី ។
១៩- យើងខ្ញុំពុំបាន បែកចិត្តគេចប្រាណ ពីព្រះម្ចាស់ថ្លៃ ឬធ្វើព្រងើយ
កាត់ផ្តាច់និស្ស័យ ក៏ពុំឃ្លាតឆ្ងាយ ពីព្រះមាគ៌ា ។
២០- មិនគួរព្រះអង្គ បំបរបំបង់ ឲ្យខ្ញុំកំព្រា នៅក្នុងកន្លែង
ខ្លាសិង្ហស្វានស្វា ខ្ញុំសែនវេទនា ក្នុងដៃមច្ចុរាជ ។
២១- ប្រសិនបើខ្ញុំ បំភ្លេចព្រះនាម ឬមានកលកិច្ច បែរទៅគោរព
ព្រះផ្សេងមានល្បិច ឬចង់កែគេច នោះទ្រង់នឹងដឹង ។
២២-ទ្រង់ជ្រាបចិត្តមនុស្ស ទោះស្រីឬប្រុស គ្មានអ្វីកំបាំង អ្វីក៏ទ្រង់យល់
សព្វអស់ទាំងពួង ដែលលាក់កំបាំង នៅក្នុងចិត្តមនុស្ស ។
២៣- ពួកគេប្រហារ យើងខ្ញុំគ្រប់គ្រា ឥតមានចន្លោះ ព្រោះតែព្រះអង្គ
គេទុកខ្ញុំនេះ ដូចចៀមគោសេះ សម្រាប់ប្រហារ ។
២៤- ឱព្រះម្ចាស់អើយ កុំបង្អង់ឡើយ សូមប្រែកាយា ម្តេចក៏ព្រះអង្គ
ផ្ទំលក់ច្នេះណា កុំដាច់មេត្តា ខ្ញុំរហូតឡើយ ។
២៥- ហេតុអ្វីព្រះអង្គ បែរភក្ត្រចេញរឹង គ្មានស្រណោះ ស្តាយធ្វើដូចមិនស្គាល់
បំភ្លេចព្រងើយ ខ្ញុំវេទនាហើយ ត្រូវគេជិះជាន់ ។

២៦- គេបានជាន់ឈ្លី ខ្ញុំក្នុងធូលី ចុកចាប់ពេកពន់ ខ្ញុំបរាជ័យ
ធ្ងន់អើយសែនធ្ងន់ ស្ទើរតែក្ស័យជន្ម ផុតពីផែនដី ។
២៧-ព្រះអើយក្រោកឡើង កុំនៅផ្ទៃផ្ទើង សូមទ្រង់ប្រណី យាងមករំដោះ
ដោយទឹកព្រះទ័យ ករុណាប្រណី សង្គ្រោះកុំខាន ។

## ទំនុកតម្កើងលេខ ៤៥ (៤៤)

**បទព្រហ្មគីតិ**

២- ពាក្យខ្ញុំពោលពិរោះ ដ៏ស្ម័គ្រស្មោះអស់ពីចិត្ត
តែងបទថ្វាយមហាក្សត្រ សូមឲ្យបទដូចកវី ។
៣- ព្រះអង្គល្អជាងគេ រកគ្មានទេវោហារស្ដី
ព្រះប្រទានពរជ័យ មានសិរីទាំងអំណាច ។
៤- វីរៈបុរសឫទ្ធិ គន់គាប់ចិត្តសែនអង់អាច
សូមពាក់ព្រះខ័ន្ធរាជ្យ ភ្លឺចិញ្ចាចចិញ្ចែងទៅ ។
៥- សូមគង់លើរាជរថ យាងតយុទ្ធនឹងសត្រូវ
ការពារពាំងទុកនូវ រឿងត្រឹមត្រូវនិងសុចរិត ។
សូមទ្រង់បានជោគជ័យ ក៏ថ្វាថ្លៃអស់ពីចិត្ត
ដោយបារមីមានឫទ្ធិ ដ៏ប្រណីតនៃព្រះអង្គ ។
៦- សូមឲ្យព្រួញដ៏មុត ស្រួចបំផុតជួយតម្រង់
ឲ្យព្រួញនៃព្រះអង្គ បាញ់តម្រង់ទ្រូងបច្ចា ។
សូមគ្រប់ប្រជាជាតិ កុំបីឃ្លាតឃ្លាទៅណា
ឲ្យធ្លាក់ក្រោមបាទា ព្រះរាជាដ៏មានឫទ្ធិ ។
៧- រាជាដ៏ខ្ពស់ខ្ពង់ បល្ល័ង្កទ្រង់នៅស្ថេរស្ថិត
គ្រងរាជ្យមិនរខិត គង់នៅពិតដោយយុត្តិធម៌ ។
៨- ព្រះអង្គសព្វព្រះទ័យ នឹងសេចក្ដីសុចរិតល្អ
អំពើអយុត្តិធម៌ ទ្រង់មិនគាប់ព្រះហឫទ័យ ។
ហេតុនេះព្រះជាម្ចាស់ ដែលជាព្រះដ៏ប្រពៃ
ជ្រើសរើសអង្គក្សត្រថ្លៃ ពីចំណោមមិត្តព្រះអង្គ ។

| | | | |
|---|---|---|---|
| | បាក់ប្រេងអភិសេក | មិនអល់អែកល្អផូរផង់ | |
| | ប្រទានឲ្យព្រះអង្គ | មានសព្វទាំងក្ដីសប្បាយ | ។ |
| ៩- | រាជាគ្រងភូសា | ល្អអស្ចារ្យក្រអូបសាយ | |
| | តន្ត្រីប្រគុំថ្វាយ | ក្នុងប្រាសាទភ្លុកដរិ៍ | |
| ១០- | ស្រីស្នំទាំងប៉ុន្មាន | ស្រស់ភុំជានជាបុត្រី | |
| | របស់ស្ដេចផែនដី | អង្គក្សត្រីយ៍គង់ខាងស្ដាំ | ។ |
| ១១- | ព្រះម្ចាស់ក្សត្រីយ៍អើយ | កុំកន្តើយសណ្ដាប់ខ្ញុំ | |
| | កុំនឹកនាពូនយំ | ដល់រាជវង្សព្រះនាងអី | ។ |
| ១២- | សូមឲ្យមហាក្សត្រ | បានគាប់ចិត្តអង្គក្សត្រីយ៍ | |
| | បង្គំគាល់ក្រាបថ្វាយ | កុំនឿយណាយទ្រង់ជាម្ចាស់ | ។ |
| ១៣- | អ្នកមានក្រុងទីរ៉ុស | ទាំងស្រីប្រុសមានច្រើនណាស់ | |
| | នាំតង្វាយទាំងអស់ | តម្រង់ឆ្ពោះផ្គាប់ក្សត្រី | ។ |
| ១៤- | ព្រះនាងគង់នៅក្នុង | ព្រះរាជវាំងសុខពេកក្រៃ | |
| | រូបឆោមស្រស់ឥតបី | ព្រះភូសារំលេចមាស | ។ |
| ១៥- | គេដង្ហែព្រះនាង | ចូលក្នុងវាំងមនុស្សដេរដាស | |
| | ភីលៀងមានច្រើនណាស់ | ហែទៅគាល់ព្រះរាជា | ។ |
| ១៦- | ព្រះនាងចូលទៅកាន់ | វិមានស្ថានអង្គក្សត្រា | |
| | អស់ទាំងរាស្ត្រប្រជា | គ្រប់ៗគ្នារីករាយក្រៃ | ។ |
| ១៧- | បពិត្រព្រះមហាក្សត្រ | មេត្ដាចាត់បុត្រថ្លាថ្លៃ | |
| | គ្រងរាជ្យដ៏ប្រពៃ | តពីព្រះអយ្យកោស្ដេច | ។ |
| ១៨- | ទូលបង្គំនឹងថ្លែង | រំលឹកចែងឥតមានភ្លេច | |
| | ព្រះនាមល្អបណ្ដាច់ | នាំគ្នាលើកថ្កើងព្រះអង្គ | ។ |

**ទំនុកតម្កើងលេខ ៤៦ (៤៥)** **បទពាក្យ ៧**

| | | | |
|---|---|---|---|
| ២- | ព្រះអម្ចាស់ជាទីជម្រក | ឲ្យយើងចូលជ្រករាល់ខែឆ្នាំ | |
| | ព្រះអង្គតែងតែប្រុងប្រៀបចាំ | មិនមើលបំណាំពេលអាសន្ន | ។ |

៣- ទោះបីដែនដីប្រែរញ្ជួយ ភ្នំប្រែរលួយដោយទាន់ហន់
ទោះធ្លាក់សមុទ្រជ្រៅរាប់ពាន់ ជាច្រើនរយជាន់ខ្ញុំមិនភ័យ ។
៤- ទោះទឹកសមុទ្របោកបាចសាច ជួនជោរជួននាចយ៉ាងណាក្ដី
ទោះភ្នំកក្រើកខ្ទ័រដែនដី ក៏យើងមិនភ័យមិនខ្វីខ្លាច ។
៥- មានទន្លេមួយនាំអំណរ សិរីបវរស្រោចបាចសាច
បុរីព្រះម្ចាស់មានអំណាច វិសុទ្ធក្រៃពេកព្រះដំណាក់ ។
៦- ព្រះម្ចាស់មានអំណាច បានក្ដីសុខាមិនអន់អាក់
ព្រោះទ្រង់សង្គ្រោះមិនថ្នាំងថ្នាក់ តាំងពីថ្ងៃរះព្រឹកព្រលឹម ។
៧- ជនជាតិនានាតែងគំរាម ស្រុកកើតសង្គ្រាមភ័យជ្រួលជ្រើម
ព្រះម្ចាស់បន្លឺសូរសៀងឡើង ដែនដីត្រូវបើងបែកខ្ទាត់ខ្ទាយ ។
៨- ព្រះជាអម្ចាស់នៃពិភព ទ្រង់គង់ប្រសព្វមិនឃ្លាតឆ្ងាយ
ព្រះលោកយ៉ាកុបមិនទទន់ជ្រាយ កំពែងមាំក្រៃនៃយើងខ្ញុំ ។
៩- ចូរនាំគ្នាមើលស្នាព្រះហស្ត របស់ព្រះម្ចាស់ដ៏ឧត្ដម
កិច្ចការអស្ចារ្យទាំងតូចធំ ដែលទ្រង់ខិតខំលើដែនដី ។
១០- ទ្រង់បានប្រមូលផ្ដួលលំពែង ខែលដាវខ្លីវែងគ្មានសល់អ្វី
រទេះគ្រឿងក្រោះបោះទៅដី ដុតខ្ទេចគ្មានស្ដាយមិនស្រណោះ ។
១១- ចូរឈប់ច្បាំងទៅត្រូវដឹងថា គឺយើងនេះណាជាព្រះម្ចាស់
យើងគ្រប់គ្រងលើជាតិទាំងអស់ មិនសល់ចន្លោះលើលោកា ។
១២- ព្រះអម្ចាស់នៃភពដែនដី ស្ម័គ្រស្មោះមេត្រីគ្រប់ៗគ្រា
គង់នៅជាមួយរាល់វេលា កំពែងការពារដ៏មាំមួន ។

## ទំនុកតម្កើងលេខ ៤៧ (៤៦) — បទកាកគតិ

២- ឱជនទាំងឡាយ ចូរអរសប្បាយ ទះដៃអបអរ ច្រៀងលើកតម្កើង
ព្រះម្ចាស់បវរ ទទួលអំណរ ដោយចិត្តរីករាយ ។
៣- ដ្បិតព្រះអម្ចាស់ ព្រះខ្ពង់ខ្ពស់ណាស់ គួរស្ញប់ស្ញែងក្រៃ ព្រោះតែព្រះអង្គ
ជាមហាក្សត្រថ្លៃ ឧត្ដមប្រពៃ លើដីទាំងអស់ ។

៤- ព្រះអង្គបង្ក្រាប គ្រប់ជាតិឲ្យរាប មកជាចំណុះ មិនឲ្យរួចខ្លួន
ជាតិណាមួយសោះ ស្ម័គ្រចិត្តស្រួលស្រុះ ក្រោមអំណាចយើង ។
៥- ព្រះអង្គជ្រើសរើស ទឹកដីគ្រប់ទិស ជាមរតកថ្កើង ឲ្យយ៉ងខ្ពស់មុខ
គ្មានអ្វីកើតឡើង វិសេសរុងរឿង យ៉ាកុបល្អឯក ។
៦- ព្រះអម្ចាស់យាង ឡើងក្រោមសូរសៀង ខ្សែវខ្វាអនេក ទ្រង់យាងទៅខ្ពស់
ឥតមានរារែក អមដោយសម្រែក ស្នូរត្រែតន្ត្រី ។
៧- ចូរយើងនាំគ្នា រូតរះម្នីម្នា ថ្វាយពរសិរី ព្រះជាអម្ចាស់
រុងរឿងពេកក្រៃ ស្មូតលាយតន្ត្រី ថ្វាយព្រះនៃយើង ។
៨- ដ្បិតព្រះអង្គជា ព្រះមហាក្សត្រា វិសេសថ្កុំថ្កើង នៅលើដែនដី
ជាព្រះនៃយើង ចូរនាំគ្នាថ្កើង សូតកំណាព្យថ្វាយ ។
៩- ព្រះម្ចាស់គ្រងរាជ្យ ពេញដោយអំណាច លើជាតិជិតឆ្ងាយ គង់លើបល្ល័ង្ក
ឥតបីនឿយណាយ វិសុទ្ធពេកក្រៃ រាស្ត្របានសុខសាន្ត ។
១០- ពួកមេដឹកនាំ មកមីរជួបជុំ ឥតមានខកខាន ជាប្រជាជន
វិសុទ្ធថ្កើងថ្កាន ព្រះដ៏ចំណាន អប្រាហាំថ្លៃ ។
ដ្បិតមហាក្សត្រ ម្ចាស់ដែនដីស្ថិត ក្រោមម្លប់បារមី អំណាចព្រះម្ចាស់
ខ្លាំងលើសអ្វីៗ ក្នុងនាលោកីយ៍ គ្មានអ្វីស្មើជង ។

## ទំនុកតម្កើងលេខ ៤៨ (៤៧) បទពាក្យ ៧

២- ព្រះម្ចាស់ជាព្រះឧត្តម ប្រសើរសក្តិសមខ្ពស់បំផុត
ស៊ីយ៉ូនបុរីតែមួយគត់ ភ្នំដ៏វិសុទ្ធនៃព្រះអង្គ ។
៣- ភ្នំជារបស់ព្រះអម្ចាស់ ល្អប្រណីតណាស់ឥតមានហ្មង
ស៊ីយ៉ូនជាកំពូលភពផង មហាក្សត្រទូទាំងភពដែនដី ។
៤- ព្រះម្ចាស់សម្តែងឲ្យដឹងថា ព្រះអង្គគឺជាកំពែងជ័យ
រឹងប៉ឹងមាំមួនពន់ពេកក្រៃ នៅក្នុងបុរីនោះប្រាកដ ។
៥- មានស្តេចនានាច្រើនគរគោក បំណងវាយយកតាមកំណត់
កម្ទេចស៊ីយ៉ូនភ្នំឲ្យម៉ត់ យកឈ្នះប្រាកដតាមកម្លាំង ។

៦- ពេលដែលគេឃើញភ្នំស៊ីយ៉ូន ទើបគេភ្ញាក់ខ្លួនស្រឡាំងកាំង
តក់ស្លុតព្រឺព្រួចភ័យភាន់ភាំង នាំគ្នាឈប់ច្បាំងរត់ចូលព្រៃ ។
៧- គេភ័យញាប់ញ័រដូចកូនសត្វ ឈឺចាប់ពេកក្តាត់ដូចស្រ្តី
ហៀបនឹងសម្រាលបុត្រក្នុងផ្ទៃ ទន់ជើងទន់ដៃស្ទើររលំ ។
៨- ដូចជាខ្យល់ព្យុះបោកបក់មក ប៉ះទឹករលកបោកគគ្រឹម
កម្ទេចនាវាឲ្យខ្ទេចខ្ទាំ ពីទិសបស្ចិមសែនភិតភ័យ ។
៩- យើងបានឮគេថ្លែងវាចា សព្វអំពីស្នាព្រះហស្តថ្លៃ
ឥឡូវឃើញផ្ទាល់ក្នុងបុរី ព្រះអម្ចាស់ថ្លៃលើលោកា ។
១០- បពិត្រព្រះម្ចាស់ដ៏ឧត្តុង្គ រូបខ្ញុំនៅក្នុងព្រះវិហារ
ខ្ញុំនឹកពីព្រះទ័យមេត្តា សប្បុរសករុណានៃព្រះអង្គ ។
១១- បពិត្រព្រះជាអម្ចាស់ថ្លៃ ព្រះនាមល្បាញល្បីរបស់ទ្រង់
មនុស្សម្នាគ្រប់គ្នាលើកតម្កើង ព្រះនាមព្រះអង្គដល់ទីឆ្ងាយ ។
១២- សូមឲ្យអ្នកទីក្រុងស៊ីយ៉ូន កុំបីស្រពោនចូរស្រស់ស្រាយ
អ្នកស្រុកយូដាអរសប្បាយ ព្រោះព្រះវិនិច្ឆ័យដោយយុត្តិធម៌ ។
១៣- ចូរនាំគ្នាហែកុំទោម្ទេញ ហែព័ទ្ធជុំវិញក្រុងបវរ
រាប់ចំនួនប៉មជាបន្ត របស់ក្រុងល្អនេះមើលទៅ ។
១៤- ចូរស្ទើចសរសើរកំពែងក្រុង ពិនិត្យផ្ចិតផ្ចង់កុំសល់នៅ
ដើម្បីអ្នករាល់គ្នាយកទៅ ថ្លែងប្រាប់មនុស្សនៅក្រោយគ្រប់គ្នា ។
១៥- ថាព្រះជាម្ចាស់ពិតជាព្រះ យើងប្រាកដណាស់ពីយូរយារ
ព្រះអង្គដឹកនាំយើងឥតរា តទៅមុខជាអង្វែងអើយ ។

## ទំនុកតម្កើងលេខ ៤៩ (៤៨) បទកាកគតិ

២- ឱជនទាំងឡាយ ចូរកុំខ្វល់ខ្វាយ នាំគ្នាត្រងត្រាប់ មនុស្សរស់លើដី
ណែនណាន់តាន់តាប់ ត្រូវតែប្រុងស្តាប់ ដោយចិត្តទុកដាក់ ។
៣- គឺទូទាំងអស់ មនុស្សទាំងស្រីប្រុស កុំបីអន់អាក់ ទាំងអ្នកតូចទាប
អ្នកធំហួសថ្នាក់ អ្នកសម្បូរប្រាក់ អ្នកក្រវេទនា ។

៤- ខ្ញុំនឹងបរិយាយ ឲ្យបានក្បោះក្បាយ ដល់អ្នករាល់គ្នា អំពីគតិ
បណ្ឌិតភ្លឺថ្លា ពិតដោយប្រាជ្ញា ខ្លឹមសារប្រពៃ ។
៥- ខ្ញុំនឹងផ្ចិតផ្ចង់ ដាក់ចិត្តតម្រង់ ស្តាប់ពាក្យសម្តី របស់អ្នកប្រាជ្ញ
ដែលធ្លាប់ល្បាញល្បី ដោះប្រស្នាក្តី ដោយមានដេញពិណ ។
៦- ពេលមានទុក្ខភ័យ ជួបគ្រោះចង្រៃ ឬភ័យអាសន្ន សត្រូវឡោមព័ទ្ធ
ក៏ខ្ញុំមិនស្លន់ វង្វេងវង្វាន់ ភ័យមិនបានការ ។
៧- មនុស្សទុច្ចរិត តែងតែទុកចិត្ត លើទ្រព្យមហិមា គេអួតគេអាង
ព្រោះខ្លួនគេជា អ្នកមានទ្រព្យា មហាសេដ្ឋី ។
៨- គ្មាននរណាម្នាក់ អាចនឹងបង់ប្រាក់ លោះអ្នកដទៃ ហើយមិនអាចបង់
ថ្វាយព្រះម្ចាស់ថ្លៃ កុំឲ្យខ្លួនក្ស័យ ជីវិតនោះដែរ ។
៩- ថ្លៃលោះជីវិត មនុស្សយើងពិតៗ កាត់មិនបានទេ ទោះជាខំបង់
មួយកើនជាទ្វេ ក៏មិនគ្រប់ដែរ ចៀសស្លាប់មិនបាន ។
១០-តើមនុស្សនេះណា អាចមានជីវ៉ា រស់បានប៉ុន្មាន ផុតពីរណ្តៅ
អាចនៅសុខសាន្ត ឬអាចរស់បាន រហូតមិនស្លាប់ ។
១១-យើងឃើញច្បាស់ថា អ្នកមានប្រាជ្ញា ក៏ដូចអ្នកអាប់ អ្នកល្ងង់ឥតប្រាជ្ញ
ក៏គង់តែស្លាប់ ទុកទ្រព្យច្រើនកប្ប ឲ្យអ្នកដទៃ ។
១២-គេនឹកគិតថា រស់បានយូរយារ ក្នុងលំនៅថ្មី បាននៅស្ថិតស្ថេរ
ក្នុងផ្ទះល្អក្រៃ បានដាក់ឈ្មោះដី ទៅគ្រប់ជំនាន់ ។
១៣-មនុស្សមានកិត្តិយស រុងរឿងខ្ពង់ខ្ពស់ ក៏គេចមិនបាន គង់តែនឹងស្លាប់
ដូចសត្វតិរច្ឆាន ជាក់ជាមិនខាន ឥតបីឃ្លាងឃ្លាត ។
១៤-អ្នកដែលទុកចិត្ត លើខ្លួនឯងពិត នោះគ្មានមារយាទ ពេញចិត្តពាក្យខ្លួន
ជាមនុស្សមានស្នៀត អនាគតទៀត យ៉ាប់យ៉ឺនពេកក្រៃ ។
១៥- អ្នកនោះប្រៀបបាន ចៀមសត្វតិរច្ឆាន ដែលគេប្រល័យ មច្ចុរាជឃុំគ្រង
វាយឥតសំចៃ ឃ្វាលរាល់យប់ថ្ងៃ មិនឲ្យឃ្លាតឆ្ងាយ ។
រីមនុស្សសុចរិត នឹងជាន់ឈ្លីពិត លើរូបរាងកាយ របស់ពួកគេ
រលាយអន្តរាយ ទៅដល់ទីឆ្ងាយ ក្នុងស្ថានមនុស្សស្លាប់ ។

១៦- ប៉ុន្តែព្រះម្ចាស់ មានឫទ្ធិខ្លាំងណាស់ រំដោះខ្ញុំឆាប់ ផុតពីអំណាច
នៃសេចក្ដីស្លាប់ ព្រះអង្គប្រញាប់ មកយកខ្ញុំទៅ ។
១៧- ពេលអ្នកឃើញគេ សម្បត្តិឡើងទ្វេ កុំបីហ្មងសៅ ឃើញទ្រព្យគេច្រើន
ចម្រើនតទៅ សំងំពួននៅ កុំភ័យខ្លាចអី ។
១៨- ពេលដែលគេស្លាប់ គេពុំអាចចាប់ យករបស់អ្វី អស់ទាំងសម្បត្តិ
ទ្រព្យធនផ្សេងក្ដី ចូលទៅក្នុងដី អ្នកក្ស័យបានឡើយ ។
១៩- ពេលមានជីវិត គេតែងនឹកគិត ថាសុខឥតស្បើយ ថាខ្លួនគេនឹង
មិនខ្វល់អ្វីឡើយ អ្នកផងកោតហើយ ដែលគេមានបាន ។
២០- គេគង់នឹងត្រូវ ធ្លាក់ខ្លួនចុះទៅ ជួបនឹងសន្ដាន ជីតាជីដូន
មានទាំងប៉ុន្មាន ទៅក្នុងទីស្ថាន ដែលគ្មានពន្លឺ ។
២១- អ្នកមានកិត្តិយស រុងរឿងខ្ពង់ខ្ពស់ ល្បីល្បាញរន្ទឺ មិនយល់អ្វីសោះ
មិនភ័យព្រួយព្រី អ្នកនោះហើយគឺ ដូចសត្វដែលស្លាប់ ។

## ទំនុកតម្កើងលេខ ៥០ (៤៩) — បទព្រហ្មគីតិ

១- ព្រះអង្គម្ចាស់ជាព្រះ ប្រសើរណាស់លើសអ្វីៗ
ទ្រង់កោះហៅផែនដី ខាងលិចក្ដីដល់ខាងកើត ។
២- ព្រះជាម្ចាស់ចែងចាំង ពីទីក្រុងស៊ីយ៉ូនឆើត
ដែលជាក្រុងល្អស្អាត ត្រូវតាមខ្នាតឥតមានខ្ចោះ ។
៣- សូមព្រះអង្គយាងមក ជាជម្រកយើងរួមរស់
កុំនៅស្ងៀមដូច្នោះ សូមសន្ដោសត្រួសត្រាយផ្លូវ ។
ពេលព្រះអង្គយាងមក ខ្យល់បក់បោកខ្លាំងពេកកូវ
មានភ្លើងឆេះសន្ធៅ ជុំវិញនៅមុខព្រះអង្គ ។
៤- ព្រះអង្គហៅមេឃដី ធ្វើសាក្សីគ្រានោះផង
វិនិច្ឆ័យទោសខុសឆ្គង រាស្ត្រព្រះអង្គទាំងប៉ុន្មាន ។
៥- ព្រះអង្គមានបន្ទូល ថាប្រមូលកុំខកខាន
គឺអស់អ្នកដែលបាន ចងសម្ពន្ធជាមួយគ្នា ។

៦- ផ្ទៃមេឃប្រកាសប្រាប់ ឲ្យបានឆាប់ឥតរួញរា
ព្រះម្ចាស់មានឫទ្ធា ជាចៅក្រមដ៏សុចរិត ៕
៧- ប្រជាជនបវរ នាំគ្នាមកស្តាប់ពាក្យពិត
អ៊ីស្រាអែលកុំគិត យើងនេះពិតព្រះអ្នកហើយ ៕
៨- យើងមិនស្តីបន្ទោស អ្នកទាំងអស់ដែលបានថ្វាយ
យញ្ញបូជាទាំងឡាយ អចិន្ត្រៃយ៍មិនដែលអាក់ ៕
៩- យើងមិនត្រូវការយក គោបាមកពីផ្ទះអ្នក
ពពែជាត់ដល់ថ្នាក់ ពីក្រោលអ្នកនោះឡើយណា ៕
១០- ដ្បិតសត្វទាំងប៉ុន្មាន ដែលធ្លាប់មានក្នុងព្រឹក្សា
សត្វរាប់សែននោះណា គឺសុទ្ធជាកម្មសិទ្ធិយើង ៕
១១- យើងស្គាល់អស់បក្សី នៅតាមព្រៃមិនរំលង
សត្វរស់តាមភ្នំផង ជារបស់យើងមិនសល់ ៕
១២- ប្រសិនបើយើងឃ្លាន យើងនឹងហ៊ានមិនបាច់ខ្វល់
អ្វីៗគ្មានសេសសល់ លើសកលយើងជាម្ចាស់ ៕
១៣- យើងមិនដែលត្រូវការ សាច់គោបាយើងស្អប់ណាស់
ហើយក្រៅអំពីនោះ យើងមិនប៉ះឈាមពពែ ៕
១៤- តង្វាយផងទាំងឡាយ ដែលអ្នកថ្វាយជាហូរហែ
គឺពាក្យតម្កើងដែរ អ្នកត្រូវតែគោរពតាម ៕
១៥- នៅពេលមានអាសន្ន កុំស្លោស្លន់រកយើងភ្លាម
យើងនឹងមិននៅស្ងៀម យើងមកភ្លាមរំដោះអ្នក ៕
១៦- ព្រះម្ចាស់មានបន្ទូល ទៅមនុស្សពាលឥតស្ទើរស្ទាក់
ហេតុអ្វីបានជាអ្នក សូត្រឥតអាក់ក្រឹត្យវិន័យ ៕
ហើយបេះតែទន្ទេញ ឥតទោម្ទេញរៀងរាល់ថ្ងៃ
ពាក្យសម្ពន្ធមេត្រី ជាមួយយើងដូច្នេះណា? ៕
១៧- ប៉ុន្តែអ្នកថ្លោះធ្លោយ មិនស្តាប់ឡើយនូវវាចា
ទូន្មានគ្រប់អាត្មា អ្នកបែរជាបោលបង់បោះ ៕

១៨- ពេលណាអ្នកជួបចោរ អ្នកអបអរខ្ជួមស្ម័គ្រស្មោះ
ចូលដៃគិតរួមរស់ ពួកទុយ៌សពិតជាក់ច្បាស់ ។
១៩- មាត់អ្នកតែងស្រដី ពាក្យអប្រិយ៍ឥតអៀនខ្មាស
អណ្ដាតអ្នកគ្រលាស់ ពាក្យបោកប្រាសមិនដែលភ្លេច ។
២០- អ្នកត្រៀមចិត្តត្រៀមកាយ ឥតជិនណាយជាប់ជានិច្ច
ចោទបងប្អូនដោយល្បិច ទោះជាសាច់ខ្លួនបង្កើត ។
២១- អ្នកដែលធ្លាប់ប្រព្រឹត្ត រឿងឧក្រិដ្ឋឥតកំណើត
យើងនៅស្ងៀមម្ដេចកើត គ្មានកំណើតយើងដាក់ទោស ។
២២- អស់អ្នកដែលកែគេច ខំបំភ្លេចព្រះជាម្ចាស់
ចូរិះគិតឲ្យច្បាស់ សេចក្ដីនេះទាំងអស់ទៅ ។
ក្រែងយើងបំផ្លាញអ្នក ពិតជាជាក់មិនទុកទៅ
ហើយគ្មានអ្នកណាទៅ ជួយរំដោះយកអ្នកឡើយ ។
២៣- អ្នកណាថ្វាយពាក្យថ្លើង មកដល់យើងជាតង្វាយ
យើងរីករាយស្រស់ស្រាយ យើងសប្បាយជួយសង្គ្រោះ ។

## ទំនុកតម្កើងលេខ ៥១ (៥០) បទពាក្យ ៧

៣- ឱព្រះជាម្ចាស់ទូលបង្គំ សូមលើកទោសខ្ញុំហើយមេត្តា
តាមព្រះហឫទ័យករុណា លើសលប់អស្ចារ្យព្រះអង្គផង ។
សូមលើកទោសឲ្យទូលបង្គំ ផុតទុក្ខក្រៀមក្រំគ្រានេះម្ដង
ព្រះទ័យអាណិតអាសូរផង ព្រោះតែព្រះអង្គឥតមានខ្ចោះ ។
៤- សូមជួយលុបលាងខ្ញុំឲ្យជ្រះ ឲ្យស្អាតស្រឡះពីកំហុស
ជួយជម្រះខ្ញុំស្អាតផងចុះ ឲ្យបរិសុទ្ធអស់អំពើបាប ។
៥- ខ្ញុំដាក់ខ្លួនប្រាណសុំទទួល ឥតមានប្រែប្រួលសុំសារភាព
រូបទូលបង្គំបានសាងបាប ជិតដក់នៅជាប់ក្នុងអារម្មណ៍ ។
៦- ខ្ញុំបានប្រព្រឹត្តអំពើទាស់ ព្រះហឫទ័យស្មោះព្រះនៃខ្ញុំ
ហើយប្រព្រឹត្តរឿងមិនសក្ដិសម ក្បត់ព្រះឧត្ដមធ្វើពាលា ។

ទោះជាព្រះអង្គដាក់ទុក្ខទោស ទៅតាមកំហុសខ្ញុំយ៉ាងណា
ទ្រង់នៅសុចរិតបរិសុទ្ធថ្លា ទោះជាម្តេចម្តាទ្រង់គ្មានខុស ។

៧- ខ្ញុំមានកំហុសពីកំណើត តាំងតែពីកើតមកឯណោះ
បាបខ្ញុំជាប់ប្រាណមិនបេះអស់ មកទល់ពេលនេះមិនរសាយ ។

៨- ប៉ុន្តែព្រះម្ចាស់សព្វព្រះទ័យ ជ្រាបអស់សេចក្តីពិតទាំងឡាយ
សូមប្រោសឲ្យអស់មនុស្សគ្រប់កាយ ស្គាល់ជម្រៅនៃប្រាជ្ញាញាណ ។

៩- សូមជម្រះខ្ញុំឲ្យបរិសុទ្ធ នោះរូបខ្ញុំពិតជានឹងបាន
សជាងសំឡីជាមិនខាន បរិសុទ្ធថ្លើងថ្កានមិនអប្រិយ៍ ។

១០- សូមប្រាប់ឲ្យទូលបង្គំដឹង ថាព្រះអង្គហ្នឹងអត់ទោសពៀរ៍
នោះខ្ញុំនឹងមានអំណរក្រៃ ចិត្តសោករីងរៃប្រែរីករាយ ។

១១- ព្រះម្ចាស់អើយសូមកុំទតមក បាបច្រើនគរគោកខ្ញុំនោះឡើយ
សូមលុបកំហុសដែលមានហើយ ឲ្យបានធូរស្បើយល្អបំផុត ។

១២- ឱព្រះជាអម្ចាស់ខ្ញុំអើយ សូមជួយប្រោសឲ្យបរិសុទ្ធ
បង្កើតចិត្តថ្មីមាំមោះមុត រឹងប៉ឹងបំផុតដល់ខ្ញុំផង ។

១៣- សូមកុំបោះបង់រូបខ្ញុំចោល ឲ្យនៅតែលតោលឆ្ងាយព្រះអង្គ
កុំដកវិញ្ញាណដ៏ត្រចង់ វិសុទ្ធព្រះអង្គពីខ្ញុំឡើយ ។

១៤- សូមប្រោសឲ្យខ្ញុំអរសប្បាយ ព្រោះព្រះម្ចាស់ថ្លៃសង្គ្រោះហើយ
សូមគាំទ្រខ្ញុំកុំកន្តើយ ដោយប្រទានឲ្យធ្វើតាមផង ។

១៥- រូបខ្ញុំនឹងខំប្រៀនប្រដៅ មនុស្សពាលកម្លៅមិនឲ្យហ្មង
ឲ្យស្គាល់មាគ៌ាដ៏ត្រចង់ របស់ព្រះអង្គជាដរាប ។

១៦- ឱព្រះជាម្ចាស់ព្រះសង្គ្រោះ សូមជួយរំដោះខ្ញុំពីស្លាប់
ខ្ញុំនឹងទន្ទេញប្រកាសប្រាប់ សុចរិតគួរគាប់នៃព្រះអង្គ ។

១៧- ឱព្រះអម្ចាស់កុំស្ទាក់ស្ទើរ ជួយខ្ញុំបន្លឺសំឡេងផង
ខ្ញុំនឹងប្រកាសឲ្យរំពង ពាក្យលើកតម្កើងទ្រង់ឥតភ្លេច ។

១៨- ព្រះអង្គមិនដែលសព្វព្រះទ័យ ឲ្យដាក់យញ្ញថ្វាយច្រើនឬតិច
ទោះតង្វាយដុតទាំងមូលស្រេច ក៏ទ្រង់គ្មានកិច្ចចង់បានដែរ ។

១៩- យញ្ញដែលព្រះអង្គសព្វព្រះទ័យ ឲ្យរូបខ្ញុំថ្វាយរាល់ថ្ងៃខែ
គឺចិត្តសោកសៅទុក្ខឥតល្ហែ និងចិត្តកែប្រែលែងក្អេងក្អាង ។
២០- ឱព្រះម្ចាស់អើយសូមប្រណី ក្រុងស៊ីយ៉ូនថ្មីស្រស់ស្រឡាង
មេត្តាសូមទ្រង់ជួយកសាង សាឡឹមថ្កើងថ្កានឡើងវិញផង ។
២១- ពេលនោះព្រះអង្គមុខជាសព្វ ព្រះហឫទ័យគាប់មិនសៅហ្មង
តង្វាយដុតនិងយញ្ញតែម្តង គោឈ្មោលមកផងថ្វាយអាសនៈ ។

## ទំនុកតម្កើងលេខ ៥២ (៥១) — បទកាកគតិ

៣- អ្នកខ្លាំងពូកែ ហេតុម្តេចបេះតែ អួតពីអាក្រក់ ព្រះម្ចាស់មាន
ហឫទ័យត្រង់ស្មោះ ករុណាសន្តោស ដល់អ្នកជានិច្ច ។
៤- រៀងរាល់ខែថ្ងៃ អ្នកតែងស្រមៃ ឥតមានពេលភ្លេច ចង់តែប្រព្រឹត្ត
ដោយមិនកែគេច ចង់ធ្វើជានិច្ច អំពើទុច្ចរិត ។
ពាក្យពេចន៍សម្តី ចេញវាចាស្តី មិនដែលសុក្រឹត្យ កុហកភូតភរ
បញ្ឆៀងបញ្ឆិត មុតជាងកាំបិត ដែលគេសំលៀង ។
៥- ចូលចិត្តអាក្រក់ ល្បិចខ្មៅកខ្វក់ មិនសុចរិតទៀង និយាយកុហក
អាក្រក់លំអៀង វៀចវេរមិនទៀង ជាជាងការល្អ ។
៦- បើអ្នកហារស្តី វោហារឥតន័យ អសប្បុរសធម៌ ពាក្យកុហកភូត
ចិត្តមិនស្មោះសរ អ្វីដែលចេញមក សុទ្ធតែបោកប្រាស ។
៧- ព្រះនឹងកម្ទេច រូបអ្នកជានិច្ច ឲ្យអស់ស្រឡះ ដកហូតរូបអ្នក
ឲ្យចេញពីផ្ទះ មិនឲ្យសល់សោះ ពីលើដែនដី ។
៨- មនុស្សសុចរិត នឹងឃើញការពិត កោតខ្លាចបារមី គេសើចសប្បាយ
ក្អាកក្អាយពេកក្រៃ រួចគេនិយាយ ចំអកពោលថា ។
៩- «មើលន៍! អ្នកនោះ ពុំបានយកព្រះ ដែលមានចេស្តា ធ្វើជាទីពឹង
លំនៅអាត្មា ដោយគាត់ស្មានថា គាត់ខ្លាំងពូកែ» ។
១០- រីឯខ្ញុំវិញ ចិត្តខ្ញុំពោរពេញ គ្មានគេចកែប្រែ នៅក្នុងដំណាក់
ព្រះម្ចាស់ឥតបែរ រៀងរាល់ថ្ងៃខែ នៅក្បែរព្រះអង្គ ។

ដូចដើមខៀវខ្ចី　អូលីវស្រស់ថ្មី　ល្អល្អះដូរផង　ដោយពឹងផ្អែកលើ
បារមីព្រះអង្គ　ត្រចះត្រចង់　រៀងទៅឥតភ្លេច　។
១១- ទូលបង្គំនឹង　សរសើរតម្កើង　ព្រះអង្គជានិច្ច　ចំពោះគ្រប់កិច្ច
ការទ្រង់ប្រព្រឹត្ត　ខ្ញុំសូមទុកចិត្ត　ព្រះនាមព្រះអង្គ　។
នៅមុខអស់អ្នក　គោរពស្មោះស្ម័គ្រ　ប្រណិប័តន៍ទ្រង់　ព្រោះព្រះហឫទ័យ
សប្បុរសទៀងត្រង់　យើងខ្ញុំជ្ជិតជ្ជង់　តាមទ្រង់ទៅអើយ　។

## ទំនុកតម្កើងលេខ ៥៣ (៥២) — បទពាក្យ ៧

២- ពួកមនុស្សលេលានាំគ្នាគិត　ថាតាមការពិតគ្មានព្រះទេ
គេខំប្រព្រឹត្តមិនកែប្រែ　រឿងថោកមិនកែគួរអាម៉ាស់　។
៣- ព្រះម្ចាស់ទតពីស្ថានលើមក　ឃើញមនុស្សលោកមិរដេរដាស
ក្រែងលោមានម្នាក់វាងវៃឈ្លាស　រវៃរវាសរកព្រះអង្គ　។
៤- ពួកគេវង្វេងទាំងអស់គ្នា　ជាមនុស្សពាលាកាចយង់ឃ្នង
រកអ្នកដែលមានចិត្តទៀងត្រង់　សូម្បីម្នាក់ផងក៏មិនបាន　។
៥- តើអ្នកដែលចូលចិត្តប្រព្រឹត្ត　អំពើទុច្ចរិតទាំងប៉ុន្មាន
សុទ្ធតែល្ងង់ល្ងិតខ្វះវិញ្ញាណ　ទើបពួកគេហ៊ានធ្វើច្នោះឬ ?　។
ជីវិតគេរស់ព្រោះកិបកេង　លើរាស្ត្ររាល់ថ្ងៃទាំងបញ្ហើ
គេធ្វើមិនដឹងធ្វើមិនឮ　មិនដែលព្រួយព្រឺស្រែករកព្រះ　។
៦- ទោះបីជាគ្មានមូលហេតុអ្វី　គួរឲ្យភិតភ័យទាល់តែសោះ
ក៏ពួកគេភ័យស្លន់ទាំងអស់　គ្មានដឹងអីសោះជាន់ជើងគ្នា　។
ដ្បិតព្រះជាម្ចាស់ធ្វើឲ្យខ្មាំង　ដែលធ្លាប់ប្រឆាំងនឹងប្រជា
ស្លាប់ខ្លួនបោលឆ្អឹងគ្រប់ៗគ្នា　ដោយសារឫទ្ធាព្រះខ្ពង់ខ្ពស់　។
៧- សូមព្រះអង្គគង់ក្នុងបុរី　ស៊ីយ៉ូនប្រិមប្រិយ៍ជួយសង្គ្រោះ
ជនជាតិអ៊ីស្រាអែលទាំងនោះ　ឲ្យវិលមករស់ក្នុងស្រុកវិញ　។
ពូជលោកយ៉ាកុបអរសប្បាយ　សំណើចក្អាកក្អាយឥតទោម្នេញ
ឯពូជលោកអ៊ីស្រាអែលវិញ　អំណរពោរពេញដីលើសលប់　។

## ទំនុកតម្កើងលេខ ៥៤ (៥៣) បទព្រហ្មគីតិ

៣- ឱព្រះជាម្ចាស់អើយ កុំកន្តើយសូមជួយផង
ដោយបារមីព្រះអង្គ មេត្តាទ្រង់រកយុត្តិធម៌ ។
៤- ឱព្រះជាម្ចាស់អើយ កុំព្រងើយស្ដាប់អង្វរ
សម្រែកខ្ញុំស្រែករក សូមស្ដាប់មកពាក្យខ្ញុំផង ។
៥- ដ្បិតមានជនបរទេស រឹងចចេសមកប៉ុនប៉ង
ប្រឆាំងខ្ញុំតែម្ដង ចិត្តគេចង់ផ្ដាច់ជីវិត ។
៦- ព្រះម្ចាស់ទ្រង់យាងមក សង្គ្រោះយកទាំងអាណិត
រូបខ្ញុំឲ្យនៅជិត ទាំងជីវិតទ្រង់ការពារ ។
៧- សូមព្រះអង្គតតាំង នឹងពួកខ្មាំងចិត្តពាលា
តាមអំពើពាលា ដែលពួកវាតែងប្រព្រឹត្ត ។
៨- រូបខ្ញុំនឹងដាក់ថ្វាយ យញ្ញតង្វាយអស់ពីចិត្ត
សូមឲ្យទ្រង់អាណិត ខ្ញុំថ្កើងពិតនាមព្រះអង្គ ។
៩- ព្រះអង្គបានរំដោះ ឲ្យផុតគ្រោះអាសន្នផង
ផុតពួកពាលយង់ឃ្នង សត្រូវផងបរាជ័យ ។

## ទំនុកតម្កើងលេខ ៥៥ (៥៤) បទពាក្យ ៧

២- ឱព្រះម្ចាស់អើយសូមមេត្តា សូមផ្ទៀងព្រះកាណ៌ស្ដាប់ពាក្យខ្ញុំ
ដែលខំអង្វរទទូចសុំ សូមទ្រង់សណ្ដាប់កុំគេចចេញ ។
៣- ពេលទ្រង់ស្ដាប់ពាក្យខ្ញុំរួចហើយ សូមកុំន្តើយតបមកវិញ
ព្រោះខ្ញុំចុកចាប់ទុក្ខទោម្នេញ ទុក្ខព្រួយពោរពេញក្នុងអាត្មា ។
៤- ពេលឮសម្រែកខ្មាំងសត្រូវ មនុស្សពាលកម្លៅចិត្តឫស្យា
ឲ្យរូបខ្ញុំរងទុក្ខវេទនា ហើយតាមប្រហារដោយកំហឹង ។
៥- ខ្ញុំសែនតក់ស្លុតពន់ពេកក្រៃ ញាប់ញ័រភិតភ័យអស់ព្រលឹង
ស្រយង់ស្រយុតនៅមិននឹង ដូចគ្មានព្រលឹងខ្លាចមរណា ។
៦- ខ្ញុំសែនរន្ធត់ពន់ពេកក្រៃ ដូចជាមានអ្វីផ្ដាច់សង្ខារ
ព្រឺព្រួចក្នុងចិត្តឥតឧបមា ដូចមនុស្សជវាឈឺដុនដាប ។

៧- ទូលបង្គំតែងនឹកគិតថា បើខ្ញុំនេះណាប្រែមានស្លាប
ខ្ញុំនឹងហោះហើររៀងដរាប រកទីសម្រាប់ជ្រកលាក់ខ្លួន ។

៨- ខ្ញុំនឹងហោះហើរទៅឲ្យឆ្ងាយ ទៅឯទីនាយសំងំពួន
ដេកទាំងយប់ថ្ងៃឲ្យបាត់សូន្យ ក្នុងរហោស្ថានស្មសានស្ងាត់ ។

៩- ខ្ញុំនឹងភៀសខ្លួនទៅឲ្យឆ្ងាយ មិននៅរវៀងអាយទៅឲ្យបាត់
បើទៅយ៉ាងឆាប់ល្អពេកក្ដាត់ ចៀសឲ្យរួចផុតព្យុះសង្ឃរា ។

១០- ឱព្រះអម្ចាស់ថ្លៃខ្ញុំអើយ សូមជួយកុំឲ្យពួកបច្ចា
និយាយស្ដាប់បានគ្រប់អាត្មា ព្រោះតែពួកវាចិត្តអប្រិយ៍ ។

១១- ទាំងយប់ទាំងថ្ងៃមានសុទ្ធតែ ទាស់ទែងឥតល្ហែមិនដឹងអី
អំពើពាលាកាប់ប្រល័យ សាហាវពេកក្រៃទាំងក្រៅក្នុង ។

១២- ក្នុងក្រុងមានតែឧក្រិដ្ឋកម្ម រាល់ថ្ងៃខែឆ្នាំមិនរំលង
នៅតាមទីផ្សារតាមភូមិផង ជិះជាន់ប៉ុនប៉ងបោកប្រាសគ្នា ។

១៣- ពួកអ្នកដែលតែងជេរតិះដៀល មិនមែនពួកពាលចិត្តឫស្យា
បើវាជាពួកធ្លាប់ជុន្នា នោះខ្ញុំពាំងវាជាមិនខាន ។

១៤- គឺឯងធ្លាប់នៅជាមួយខ្ញុំ ធ្លាប់នៅជួបជុំសែនសុខសាន្ត
ជាអ្នកជិតស្និទ្ធឥតរំខាន ជាមិត្រកល្យាណធ្លាប់ស្ម័គ្រស្មោះ ។

១៥- យើងធ្លាប់ស្និទ្ធស្នាលជាមួយគ្នា គ្រប់ពេលវេលាមិនទំនាស់
ធ្លាប់ថ្វាយបង្គំព្រះជាម្ចាស់ វិសុទ្ធពេកណាស់ក្នុងដំណាក់ ។

១៦- សូមឲ្យបច្ចាមិត្តត្រូវស្លាប់ ទាន់ហន់ឆុតឆាប់កុំបីអាក់
ឲ្យពួកគេទាំងអស់នោះធ្លាក់ ក្នុងឋាននរកទាំងនៅរស់ ។

១៧- រីឯខ្ញុំវិញសូមស្រែករក ព្រះម្ចាស់ឲ្យមកជួយសង្គ្រោះ
ព្រះអង្គនឹងយាងមករំដោះ ខ្ញុំផុតពីគ្រោះជាមិនខាន ។

១៨- ពេលតប់ប្រមល់ខ្ញុំស្រែកថ្ងូរ ឥតមានឈប់ឈរគ្មានស្រាកស្រាន្ត
ទាំងព្រឹកថ្ងៃត្រង់ល្ងាចឥតខាន ព្រះអង្គទ្រង់បានសណ្ដាប់ខ្ញុំ ។

១៩- ទោះបីសត្រូវលើកគ្នីគ្នា មកវាយប្រហារទូលបង្គំ
ក៏ទ្រង់រំដោះផុតទុក្ខធំ ជួយឲ្យរូបខ្ញុំរស់ជីវិត ។

២០- ព្រះម្ចាស់គ្រងរាជ្យពីដើមមក ធ្វើជាជម្រកដ៏ស្ថេរស្ថិត
ព្រះសណ្ដាប់ពាក្យខ្ញុំពិត ឲ្យបច្ចាមិត្តបាក់មុខអស់ ។
ពួកគេទាំងនោះមិនព្រមផ្លាស់ ប្ដូរគំនិតបាស់ទាល់តែសោះ
ធ្វើមិនដឹងឮអ្វីទាំងអស់ មិនគោរពស្មោះស្ម័គ្រខ្លាចព្រះ ។
២១- អ្នកនោះតែងតែវាយប្រហារ មិត្តភក្ដិជងណាមិនគិតសោះ
បំពានសន្យាពីមុនអស់ ដែលគេធ្លាប់ស្មោះទៅទៀតផង ។
២២- ពាក្យគេផ្អែមល្ហែមជាងទឹកឃ្មុំ ពិរោះរងំឥតមានហ្មង
ចិត្តកាចឃោរឃៅពាលយង់ឃ្នង គេមានបំណងតែប្រយុទ្ធ ។
២៣- ចូរផ្ញើជីវិតលើព្រះម្ចាស់ នោះមិនប្រទះក្ដីតក់ស្លុត
ព្រះអង្គគាំទ្រអ្នកឲ្យផុត ពីភ័យរន្ធត់មានសេរី ។
២៤- សូមព្រះជាម្ចាស់ឲ្យគេធ្លាក់ ជួយប្រានទម្លាក់កុំប្រណី
ព្រោះគេសុទ្ធតែជនអប្រិយ៍ ឃាតករប្រល័យជីវិតមនុស្ស ។
សូមកុំឲ្យពួកគេរស់រាន អាយុវែងបានយូរឲ្យសោះ
ចំណែកឯរូបខ្ញុំវិញនោះ ទុកចិត្តស្ម័គ្រស្មោះតែព្រះអង្គ ។

## ទំនុកតម្កើងលេខ ៥៦ (៥៥) បទព្រហ្មគីតិ

២- ឱព្រះម្ចាស់ថ្លាថ្លៃ សូមប្រណីហើយមេត្តា
មនុស្សច្រើនណាស់ណា វាយប្រហារទូលបង្គំ ។
៣- ជារៀងរាល់ខែឆ្នាំ សត្រូវចាំចងគំនុំ
ដេញវាយប្រហារខ្ញុំ ធ្វើឫកធំមកប្រយុទ្ធ ។
៤- ឱព្រះជាម្ចាស់អើយ ថ្ងៃនេះហើយខ្ញុំតក់ស្លុត
ភ័យខ្លាចញ័ររន្ធត់ ផ្ញើរជីវិតលើព្រះអង្គ ។
៥- ខ្ញុំកោតសរសើរព្រះ បន្ទូលច្បាស់មិនដែលឆ្គង
ទុកចិត្តលើព្រះអង្គ ខ្ញុំគ្មានហ្មងមិនខ្លាចអ្វី ។
៦- ជារៀងរាល់ថ្ងៃខែ គេតែងតែតិះដៀលស្ដី
ឱរាខ្ញុំរីងរៃ មនុស្សបង្វែរតាមផ្គន្ទា ។

| | | | |
|---|---|---|---|
| ៧- | គេឃ្លាំចាំតាមដាន | មិនដែលខានរាល់វេលា | |
| | រកឱកាសជ្គន្ទា | ចង់ប្រហារខ្ញុំឲ្យក្ស័យ | ។ |
| ៨- | ឱព្រះជាអម្ចាស់ | សូមដាក់ទោសកុំប្រណី | |
| | តាមតែមនុស្សព្រៃផ្សៃ | កុំប្រណីដល់សោះឡើយ | ។ |
| ៩- | ព្រះអង្គជ្រាបយ៉ាងច្បាស់ | ខ្ញុំរងទោសទុក្ខឥតស្បើយ | |
| | ទ្រង់ជ្រាបមិនកន្តើយ | ទឹកភ្នែកខ្ញុំរាល់វេលា | ។ |
| ១០- | ថ្ងៃខ្ញុំស្រែករកព្រះ | ជាអម្ចាស់លើលោកា | |
| | សត្រូវថយគ្រប់គ្នា | ខ្ញុំដឹងថាព្រះជួយខ្ញុំ | ។ |
| ១១- | ខ្ញុំកោតខ្លាចខ្លាំងណាស់ | សន្យាច្បាស់ឥតបន្លំ | |
| | ព្រះបន្ទូលរងំ | ធ្វើឲ្យខ្ញុំស្ញប់ស្ញែងក្រៃ | ។ |
| ១២- | ខ្ញុំទុកចិត្តលើព្រះ | ជាអម្ចាស់រៀងរាល់ថ្ងៃ | |
| | មនុស្សដែលតែងតែក្ស័យ | អាចធ្វើអ្វីរូបខ្ញុំបាន ? | ។ |
| ១៣- | ឱព្រះជាម្ចាស់អើយ | ពេលនេះហើយមិនហ៊ានខាន | |
| | ថ្វាយតង្វាយប៉ុន្មាន | ដែលខ្ញុំបានពោលបែរបន់ | ។ |
| ១៤- | ដ្បិតទ្រង់បានរំដោះ | ខ្ញុំឲ្យរស់រានមានជន្ម | |
| | ការពារគ្រាអាសន្ន | មិនឲ្យមានអ្វីរំខាន | ។ |
| | ឲ្យខ្ញុំបានដើរឆ្ពោះ | រកភក្ត្រព្រះដោយសុខសាន្ត | |
| | ក្រោមពន្លឺថ្លើងថ្កាន | បំភ្លឺស្ថានមនុស្សលោក | ។ |

## ទំនុកតម្កើងលេខ ៥៧ (៥៦) — បទកាកគតិ

| | | | | |
|---|---|---|---|---|
| ២- | ឱព្រះជាម្ចាស់ | សូមមេត្តាប្រោស | អាណិតមេត្តា | ដ្បិតទូលបង្គំ |
| | ពឹងរាល់វេលា | ជ្រកក្រោមឫទ្ធា | បេស្តាបារមី | ។ |
| ៣- | ខ្ញុំស្រែកហៅរក | សូមព្រះយាងមក | ប្រញាប់ឃ្មាតខ្មី | ព្រះខ្ពស់បំផុត |
| | លើភពផែនដី | ប្រទានសព្វអ្វី | តាមខ្ញុំប្រាថ្នា | ។ |
| ៤- | សូមទ្រង់ប្រទាន | សង្គ្រោះពីស្ថាន | បរមសុខណា | សូមជួយកម្ចាត់ |
| | សត្រូវឫស្យា | សម្តែងមេត្តា | ករុណាដល់ខ្ញុំ | ។ |

៥- សត្រូវនាំគ្នា ព័ទ្ធខ្ញុំដូចជា សត្វសិង្ហដ៏ធំ ចាំស៊ីសាច់មនុស្ស
ដូចមានគំនុំ វាមើលមកខ្ញុំ ដូចនំចំណី ។
៦- ឱព្រះម្ចាស់អើយ កុំគង់កន្តើយ សម្តែងបារមី ឧត្តុង្គឧត្តម
ជុំថ្កើងថ្លាថ្លៃ ចែងចាំងលើដី រស្មីត្រចង់ ។
៧- សត្រូវរបស់ រូបខ្ញុំទាំងអស់ ប្រុងប្រៀបប៉ុនប៉ង គេរាយអន្ទាក់
ចាំដាក់ខ្ញុំផង ចាប់ខ្ញុំតែម្តង យកទៅសម្លាប់ ។
គេជីករណ្តៅ ធំហើយសែនជ្រៅ ហើយគេពួនស្តាប់ ពេលណាខ្ញុំធ្លាក់
គេនឹងមកចាប់ តែមិនចំណាប់ ភ្លាត់ធ្លាក់ខ្លួនឯង ។
៨- បពិត្រព្រះម្ចាស់ ខ្ញុំទុកចិត្តច្បាស់ លើទ្រង់ក្រៃលែង ទុកចិត្តទាំងស្រុង
បារមីជាក់ស្តែង ខ្ញុំសូមសម្តែង បទទំនុកថ្មី ។
៩- ព្រលឹងខ្ញុំអើយ កុំនៅកន្តើយ ប្រញាប់ឃ្មាតខ្មី ឱឃឹមនិងពិណ
កុំនៅស្ងៀមអី បន្លឺបទថ្មី ដាស់ថ្ងៃឲ្យរះ ។
១០- ឱព្រះម្ចាស់អើយ រូបខ្ញុំនេះហើយ នឹងតម្កើងព្រះ នៅក្នុងចំណោម
ប្រជាទាំងអស់ លើកព្រះដោយស្មោះ ឲ្យជាតិជ្រៀងយល់ ។
១១- ដ្បិតព្រះហឫទ័យ ករុណាប្រណី ព្រះម្ចាស់ខ្ពស់ដល់ ទៅលើផ្ទៃមេឃ
ឥតមានកិច្ចកល បារមីខ្ពស់ដល់ វេហាស៍អាកាស ។
១២- ព្រះជាម្ចាស់អើយ កុំនៅកន្តើយ បង្ហាញឲ្យច្បាស់ បារមីឧត្តុង្គ
ឧត្តមត្រចះ ព្រះខ្ពង់ខ្ពស់ណាស់ នៅលើមេឃា ។
សូមឲ្យសិរី រុងរឿងថ្លាថ្លៃ ភ្លឺមហិមា រស្មីចែងចាំង
នៅលើវេហាស៍ ភ្លឺខ្លាំងអស្ចារ្យ លើដីទាំងមូល ។

## ទំនុកតម្កើងលេខ ៥៨ (៥៧) បទពាក្យ ៧

២- ឱពួកចៅក្រមទាំងឡាយអើយ ពាក្យអ្នកនិយាយពេលកាត់ក្តី
ជាពាក្យត្រឹមត្រូវល្អប្រពៃ ហើយមានអត្ថន័យពិតឬទេ ? ។
៣- តែផ្ទុយទៅវិញតាមការពិត ពួកអ្នកប្រព្រឹត្តទុច្ចរិតទ្វេ
ដោយចិត្តចេតនាឥតកែប្រែ ចូលចិត្តគិតតែរឿងឃោរឃៅ ។

៤- ឯមនុស្សវៀចវេរចិត្តអាក្រក់ ល្បិចខ្មៅកខ្វក់សែនអាស្រូវ
មានតាំងពីខ្លួនគេស្ថិតនៅ មិនដឹងខុសត្រូវក្នុងផ្ទៃម្តាយ ។
៥- ខ្លួនគេមានពិសដូចសត្វពស់ មិនខ្វីស្រណោះមិនខ្វល់ខ្វាយ
ធ្វើថ្លង់មិនឮសព្វស័ព្ទអ្វី ដូចពស់ចង្រៃដ៏កំណាច ។
៦- មិនដែលបេះឮសូរសំឡេង ទោះគ្រូបាស់ក្មេងមានអំណាច
គ្រូអាលម្ពាយបាប់ពស់កាច អ្នកមានអំណាចពូកែក្តី ។
៧- ឱព្រះជាអម្ចាស់ខ្ញុំអើយ សូមកុំកន្តើយកុំប្រណី
កាច់បំបាក់ធ្មេញមនុស្សអប្រីយ៍ ចង្កូមសត្វព្រៃអស់ទាំងនោះ ។
៨- សូមឲ្យជីវិតគេរសាត់ បើងបក់ទៅបាត់កុំស្រណោះ
ដូចទឹកដែលហូរធ្លាក់ពីជ្រោះ ឲ្យពួកគេនោះរាបដូចស្មៅ ។
៩- សូមឲ្យពួកគេដូចជន្លេន ដងខ្លួនពត់ពេនហើយវារទៅ
ស្ងួតខ្លួនក្រៀមក្រោះដោយកម្តៅ ដូចកូនដែលត្រូវធ្លាក់រលូត ។
១០- ព្រះម្ចាស់ធ្វើឲ្យពួកមនុស្ស ចិត្តពាលទុយ៌សវិនាសផុត
ដូចជាបន្លាដ៏ស្រួចមុត ត្រូវក្រៀមក្រោះស្វិតខ្យល់ផាត់ទៅ ។
១១- រីឯពួកមនុស្សសុចរិត រីករាយក្នុងចិត្តមិនអាស្រូវ
ដោយព្រះសងសឹកនឹងសត្រូវ ឲ្យគេស្គាល់នូវក្តីវិនាស ។
១២- មនុស្សម្នានាំគ្នាពោលថា អ្នកត្រង់ល្អជាចម្រើនច្បាស់
ព្រោះយើងមានព្រះជាអម្ចាស់ នៅជួយជម្រះក្តីមនុស្សលោក ។

## ទំនុកតម្កើងលេខ ៥៩ (៥៨) បទភាគគតិ

២- ឱព្រះម្ចាស់អើយ សូមកុំកន្តើយ ជួយរំដោះខ្ញុំ ឲ្យរួចពីខ្មាំង
សត្រូវតូចធំ វាមានគំនុំ ចង់ចាប់ធ្វើបាប ។
៣- សូមជួយរំដោះ ជីវិតឲ្យរស់ ជារៀងដរាប ផុតពីពួកពាល
ពីអ្នកសាងបាប អាក្រក់ឆ្មេះឆ្មាប ពួកជនស្រេកឈាម ។
៤- ឱព្រះអម្ចាស់ ទោះខ្ញុំពុំខុស ក៏គេព្យាយាម ចាំស្ទាក់ប្រហារ
ជីវិតខ្ញុំភ្លាម ពួកគេព្យាយាម ប្រឆាំងជានិច្ច ។

៥- ទោះខ្ញុំមិនខុស ក៏ពួកទាំងនោះ នៅតែមានល្បិច ពួនចាំស្ទាក់ចាប់

រូបខ្ញុំមិនភ្លេច សូមកុំកែគេច បែរភក្ត្រមើលផង ។

៦- ឱព្រះម្ចាស់អើយ ព្រះអង្គនេះហើយ ជាព្រះខ្ពស់ខ្ពង់ លើពិភពលោក

គ្មានអ្វីស្មើទ្រង់ សូមជួយខ្ញុំផង ដាក់ទោសពួកក្បត់ ។

៧- ល្ងាចគេនាំគ្នា រូតរះម្ទីម្ទា តាមពេលកំណត់ ដើរលូដូចឆ្កែ

ដែលរសាត់ព្រាត់ ដើរក្រឡឹងព័ទ្ធ ជុំក្រុងទាំងអស់ ។

៨- មាត់របស់គេ ពោលមិនគិតទេ ពាក្យអសុរស ដូចដាវដ៏មុត

និយាយគំរោះ ពួកគេទាំងនោះ ថាគ្មានគេឮ ។

៩- ឱព្រះម្ចាស់អើយ ព្រះអង្គនេះហើយ អ្នកសើចបញ្ឈឺ ឲ្យពួកទាំងនោះ

ចុកចាប់ផ្សាឈឺ គ្រប់ជាតិដឹងឮ ទ្រង់សើចចំអក ។

១០- រូបខ្ញុំខំប្រឹង មើលទៅព្រះអង្គ មិនឲ្យខានខក ទ្រង់ជាកម្លាំង

កំពែងជម្រក មិនឲ្យខ្មាំងមក ពាជាបំភ័យ ។

១១- ព្រះរបស់ខ្ញុំ ហឫទ័យទូលំ ទូលាយឥតបី មេត្តាករុណា

សន្តោសប្រណី ឲ្យខ្ញុំសប្បាយ ដោយខ្មាំងចាញ់ដៃ ។

១២- ព្រះម្ចាស់ជាខែល ការពារក្រវែល រក្សាយប់ថ្ងៃ សូមកុំប្រហារ

ជីវិតគេក្ស័យ ក្រែងជនប្រុសស្រី ភ្លេចជ័យព្រះអង្គ ។

១៣- ពេលគេហាមាត់ និយាយស្តីសុទ្ធ ពាក្យមិនទំនង សូមឲ្យពួកគេ

ជាប់អន្ទាក់ផង ព្រោះចិត្តគេប៉ង កុហកផ្តាសា ។

១៤- សូមបំផ្លាញឲ្យ ពួកគេអន្តរាយ វិនាសអសារ នោះទើបពួកគេ

បានដឹងច្បាស់ថា ព្រះគឺក្សត្រា ជាម្ចាស់ពិភព ។

១៥- ល្ងាចគេនាំគ្នា រូតរះម្ទីម្ទា ឥតមានឈរឈប់ ដើរលូដូចឆ្កែ

ទាំងថ្ងៃទាំងយប់ ដើរព័ទ្ធឥតឈប់ ជុំវិញទីក្រុង ។

១៦- ពួកគេដើរជ្រក តត្រុកទៅមក ដោយក្តីសៅហ្មង ស្វែងរកអាហារ

ចម្អែតពោះផង គ្រហឹមម្តងៗ ព្រោះស៊ីមិនគ្រប់ ។

១៧- រីឯខ្ញុំវិញ ក្នុងចិត្តពោរពេញ សរសើរមិនឈប់ ច្រៀងលើកតម្កើង

ព្រះម្ចាស់ជាម្លប់ ថ្លែងមិនឈរឈប់ ហឫទ័យមេត្តា ។

| | | | |
|---|---|---|---|
| ពេលព្រឹកព្រលឹម | ថ្លែងទាំងញញឹម | ពីក្ដីករុណា | របស់ព្រះអង្គ |
| ជាកំពែងការ | ជួយខ្ញុំនេះណា | ពេលអាសន្នភ័យ | ។ |
| ១៨- បពិត្រព្រះម្ចាស់ | ព្រះអង្គជាព្រះ | មានឫទ្ធិបារមី | ខ្ញុំនឹងច្រៀងស្មូត |
| បទតម្កើងថ្វាយ | ព្រះអង្គនេះហើយ | ជាកំពែងមាំ | ។ |

## ទំនុកតម្កើងលេខ ៦០ (៥៩) — បទព្រហ្មគីតិ

៣- ឱព្រះជាម្ចាស់អើយ ហេតុម្ដេចឡើយក៏បោះបង់
បោលខ្ញុំនៅត្រមង់ ព្រមទាំងឲ្យបរាជ័យ ។
ទោះបីទ្រង់ពិរោធ ឬខ្ញាល់ក្រោធសូមប្រណី
ជួយខ្ញុំជុតពីក្ស័យ រួចពីដែសត្រូវផង ។
៤- ព្រះអង្គប្រើបារមី ឲ្យដែនដីប្រេះតែម្ដង
របេះចេញទៀតផង សូមជួយចងភ្ជិតឲ្យជាប់ ។
៥- ព្រះអង្គធ្វើឲ្យរាស្ត្រ ទ្រង់ទាំងអស់រស់មិនគាប់
វេទនាមិនឈរឈប់ រងទោសទុក្ខក្ដៅឈឺជ្រា ។
៦- ព្រះអង្គបានប្រទាន ទង់ជ័យមានជាសញ្ញា
ដល់អ្នកខ្លាចចេស្ដា អាចជុតពីបរាជ័យ ។
៧- សូមយាងមកសង្គ្រោះ យើងទាំងអស់ដោយបារមី
តបកុំបង្អង់អី រាស្ត្រប្រុសស្រីរួចជីវិត ។
៨- ព្រះមានបន្ទូលពី ដែលជាទីដ៏វិសុទ្ធ
ទ្រង់យកជ័យបំផុត ទាំងចែកស្រុកស៊ីគែមឲ្យ
យើងនឹងវាស់ជ្រលង ស៊ូកូតផងមិនបណ្ដោយ
ទុកឲ្យរាស្ត្រចែកបាយ ជាអំណោយដ៏ថ្លាថ្លៃ ។
៩- កាឡាតស្រុកយើងទេ ម៉ាណាសេដ៏ប្រពៃ
នោះសុទ្ធតែជាដី ដ៏ថ្លថ្លៃរបស់យើង ។
ប្រាអ៊ីមដូចមួកដែក ល្អនេកគួរតម្កើង
យូដាជាស្រុកយើង ដូចដំបងរាជ្យវិសេស ។

១០- ម៉ូអាប់ជាកន្លែង ដែលយើងស្វែងមិនប្រហែស
ស្បែកជើងយើងលាងបោះ លើដីនោះគឺអេដុម ។
១១- លោកនេះមាននរណា ចិត្តហានក្លាអាចដឹកនាំ
រូបខ្ញុំឲ្យចូលចំ ក្រុងអេដុមដ៏អស្ចារ្យ ។
១២- ឱព្រះជាម្ចាស់អើយ ព្រះអង្គហើយដែលហានក្លា
តែទ្រង់ប្រែទៅជា មិនមេត្តាប្រែបោះបង់ ។
១៣- សូមយាងជួយយើងខ្ញុំ ឲ្យប្រឆាំងសត្រូវផង
ដ្បិតអ្វីសព្វទាំងពួង មកពីមនុស្សជួយមិនបាន ។
១៤- បើទ្រង់គង់ជាមួយ ខ្ញុំមិនព្រួយមិនរំខាន
ព្រះអង្គបង្ក្រាបបាន ពួកសាមាន្យឲ្យវិនាស ។

## ទំនុកតម្កើងលេខ ៦១(៦០) បទកាកគតិ

២- ឱព្រះម្ចាស់អើយ កុំគង់ព្រងើយ សូមព្រះសណ្ដាប់ យកហឫទ័យទុក
ដាក់ហើយត្រងត្រាប់ ពាក្យអង្វរគាប់ ទូលបង្គំផង ។
៣- ពេលខ្ញុំនៅឆ្ងាយ សន្លឹមអន្ទាយ ហាក់អស់កម្លាំង ខ្ញុំស្រែកហៅរក
ព្រះនាមព្រះអង្គ សូមដឹកនាំខ្ញុំ ទៅកាន់ថ្មខ្ពស់ ។
៤- ព្រះអង្គជាទី ជម្រករមណី រឹងមាំឥតខ្ចោះ ជាប៉មមាំមួន
កំពែងដ៏ខ្ពស់ ព្រះជាអម្ចាស់ តទល់សត្រូវ ។
៥- ទូលបង្គំចង់ រស់និត្យនៅក្នុង ពន្លាពេកកូវ របស់ព្រះអង្គ
រហូតតទៅ ហើយសូមក្រាបនៅ ក្រោមម្លប់ព្រះអង្គ ។
៦- ឱព្រះម្ចាស់អើយ ព្រះអង្គនេះហើយ តែងស្ដាប់ពាក្យខ្ញុំ ព្រះអង្គប្រទាន
មកទូលបង្គំ មរតកដ៏ធំ បម្រុងទុកឲ្យ ។
៧- សូមទ្រង់ប្រទាន ព្រះរាជាមាន ជន្មាមិនថយ អាយុយឺនយូរ
សតវត្សទៅក្រោយ ជាម្លប់ផ្ដល់ឲ្យ ប្រជាប្រុសស្រី ។
៨- សូមឲ្យមហាក្សត្រ គ្រងរាជ្យរហូត ក្រោមភ័ក្ត្រម្ចាស់ថ្លៃ រហូតតទៅ
ដោយព្រះហឫទ័យ មេត្តាប្រណី ករុណាស្មោះស្ម័គ្រ ។

៩- ខ្ញុំនឹងតម្កើង ព្រះម្ចាស់ខ្ពស់ឡើង រាល់ថ្ងៃឥតអាក់ ឥតឈប់ឥតឈរ
ឲ្យសមនឹងពាក្យ សន្យាលាយល័ក្ខណ៍ ចំពោះព្រះអង្គ ។

## ទំនុកតម្កើងលេខ ៦២ (៦១) បទពាក្យ ៧

២- ពេលខ្ញុំនៅក្បែរព្រះអម្ចាស់ ចិត្តរីករាយណាស់មិនព្រួយសោះ
ព្រោះតែព្រះអង្គជួយសង្គ្រោះ ជីវិតខ្ញុំរស់ផុតមរណា ។
៣- ព្រះអង្គប្រៀបដូចជាបន្ទាយ វាយបុកមិនធ្លាយដូចថ្មដា
ជាកំពែងមាំរងការពារ ខ្ញុំមិនវេទនាមិនព្រួយភ័យ ។
៤- តើអ្នករាល់គ្នានៅតែចង់ ប្រហារបំបង់អ្នកនេះថ្វី
ដូចចង់រំលំកំពែងជ័យ ដែកដួលទៅដីឬយ៉ាងណា ? ។
៥- គេចង់ឲ្យអ្នកនោះអាប់យស និយាយកុហកពាក្យមុសា
មាត់គេឲ្យពរចិត្តឬស្យា ដាក់បណ្ដាសាមិនស្រណោះ ។
៦- មែនហើយខ្ញុំនឹងបានស្ងប់ចិត្ត ពេលបាននៅជិតព្រះអម្ចាស់
ខ្ញុំតែងសង្ឃឹមគ្មានក្រឡះ លើព្រះអម្ចាស់របស់ខ្ញុំ ។
៧- ព្រះអង្គតែមួយជាថ្មដា សង្គ្រោះពាំងពារខ្មាំងជិតជុំ
ទ្រង់ជាកំពែងដ៏រឹងមាំ ខ្ញុំផុតទុក្ខធំគ្មានសៅហ្មង ។
៨- ឯការសង្គ្រោះនិងសិរី រុងរឿងថ្លាថ្លៃខ្ញុំតែម្ដង
ស្ថិតលើព្រះអម្ចាស់ទាំងស្រុង ព្រោះតែព្រះអង្គជាថ្មដា ។
៩- ឱប្រជាជនទាំងអស់អើយ ចូរកុំកន្ដើយនាំគ្នីគ្នា
ផ្ញើកាយផ្ញើចិត្តទាំងជន្មា លើព្រះគ្រប់គ្រាតរៀងទៅ ។
ចូរទូលទុក្ខសោកក្ដីកង្វល់ សព្វអស់អំពល់កុំទុកនៅ
ទ្រង់ជាជម្រកមិនអាស្រូវ ដរាបរៀងទៅជាប់ជានិច្ច ។
១០- ជីវិតដូចមួយដង្ហើមខ្លី ដូចជាគ្មានន័យគ្មានប្រាកដ
រួមទាំងរូបកាយទាំងដួងចិត្ត ស្រាលហួសបើគិតឥតតម្លៃ ។
១១- មិនត្រូវប្រកាន់ចិត្តហឹង្សា ឬក៏ប្រាថ្នាការកេងគៃ
ទោះកើតសម្បត្តិធនច្រើនក្ដី កុំនឹកមមៃជាប់ឲ្យសោះ ។

១២- ខ្ញុំឮព្រះម្ចាស់បន្ទូលថា អំណាចចេស្ដាគ្រប់ទាំងអស់
ស្ថិតលើព្រះអង្គព្រះសង្គ្រោះ មានអំណាចខ្ពស់ហួសផែនដី ។
១៣- ព្រះអង្គប្រកបដោយចេស្ដា ហឫទ័យករុណាត្រាប្រណី
ព្រះអង្គតបស្នងមនុស្សប្រុសស្រី តាមតែអ្វីៗគេប្រព្រឹត្ត ។

## ទំនុកតម្កើងលេខ ៦៣ (៦២) បទកាកគតិ

២- បពិត្រព្រះម្ចាស់ ទ្រង់ពិតជាព្រះ នៃទូលបង្គំ ខ្ញុំខំស្វែងរក
មិននៅសំងំ តាំងពីព្រលឹម ស្ទះស្វែងដើររក ។
រូបខ្ញុំស្រេកឃ្លាន ព្រះប្រាជ្ញាញាណ អាល័យនឹងភ្នក ដូចដីប្រេះបែក
គ្មានភ្លៀងធ្លាក់មក ខ្ញុំដើរកាត់ជ្រក គ្រប់ទីទិសា ។
៣- សូមឲ្យរូបខ្ញុំ បានឃើញព្រះអង្គ ក្នុងទីសក្ការ ខ្ញុំចង់ឃើញណាស់
បារមីឫទ្ធា អំណាចចេស្ដា របស់ព្រះអង្គ ។
៤- ព្រះទ័យមេត្តា សន្ដោសករុណា ប្រសើរឥតហ្មង ខ្ញុំនឹងពោលពាក្យ
សរសើរតម្កើង សិរីរុងរឿង ព្រះម្ចាស់មានឫទ្ធិ ។
៥- ខ្ញុំសូមថ្លាថ្លែង អំណរក្រៃលែង អស់មួយជីវិត ខ្ញុំសូមលើកដៃ
បង្គំថ្វាយថ្វាត់ ព្រះនាមវិសុទ្ធ ព្រះអង្គតែមួយ ។
៦- ខ្ញុំនឹងសប្បាយ ឥតមានខ្វល់ខ្វាយ ព្រោះមានព្រះជួយ បានសុខរមនា
គ្មានភ័យគ្មានព្រួយ ព្រះម្ចាស់តែមួយ ខ្ញុំច្រៀងតម្កើង ។
៧- រៀងរាល់រាត្រី ខ្ញុំនឹកស្រមៃ ទៅដល់ព្រះអង្គ អស់ពេញមួយយប់
រាត្រីកន្លង នឹកដល់ព្រះអង្គ ឥតមានពេលភ្លេច ។
៨- ព្រោះតែព្រះអង្គ បានជួយតម្រង់ រូបខ្ញុំជានិច្ច ខ្ញុំច្រៀងខ្ញុំរាំ
សប្បាយពន់ពេក ឥតមានរារែក ក្រោមម្លប់បារមី ។
៩- ចិត្តខ្ញុំជំពាក់ ឥតមានស្រាន្តស្រាក នឹកគិតអាល័យ ទៅដល់ព្រះម្ចាស់
ទោះយប់ឬថ្ងៃ ទ្រង់គាំទ្រឲ្យ រីកមុខស្រស់ថ្លា ។
១០- រីឯអស់អ្នក ដែលចំាពួនស្ទាក់ ចង់ផ្ដាច់សង្ខារ សូមឲ្យគេធ្លាក់
ជ្រោះជ្រៅក្រៃណា ជ្រៅឥតឧបមា រកស្ថានមិនត្រូវ ។

១១- ឲ្យពួកគេស្លាប់ ដោយមុខដាវកាប់ កុំបីសល់នៅ សាច់ឈាមរហែក
ខ្មោចខ្ចីដូចម្សៅ ដូចសាច់សត្វត្រូវ ចចកខាំហែក ។
១២- ព្រោះតែព្រះម្ចាស់ ស្ដេចត្រេកអរណាស់ រីករាយអនេក អ្នកស្បថក្នុងនាម
ព្រះម្ចាស់ល្អឯក ឯអ្នកដែលវៀច បាត់មាត់ស្ងួនឈឺង ។

## ទំនុកតម្កើងលេខ ៦៤ (៦៣) បទព្រហ្មគីតិ

២- ឱព្រះជាម្ចាស់អើយ សូមប្រោសហើយព្រះសណ្ដាប់
រូបខ្ញុំភ័យញ័រញាប់ ជួយការពារជីវិតផង ។
៣- រារាំងរួចពីដៃ ពួកព្រៃផ្សៃពាលយង់ឃ្នង
ឃុបឃិតចិត្តប៉ុនប៉ង សូមព្រះអង្គជួយឲ្យផុត ។
៤- គេប្រើពាក្យសម្ដី មិនប្រពៃដូចអាវុធ
ដូចដាវដែលស្រួចមុត ផ្ដាច់ជីវិតមិនបង្អង់ ។
៥- ពួកគេលួចប្រហារ មនុស្សធម្មតាស្លូតទៀងត្រង់
លបលួចពីក្រោយខ្នង ដោយមិនក្រែងរអែងចិត្ត ។
៦- គេនាំគ្នានិយាយ ពួកគេឲ្យធ្វើទុច្ចរិត
រួចហើយគេឃុបឃិត រួមគំនិតដាក់អន្ទាក់ ។
៧- បង្កើតឧក្រិដ្ឋ ទុច្ចរិតឥតស្ទើរស្ទាក់
ទាំងពោលស្ដីបញ្ជាក់ ថាគ្មានអ្នកដឹងឮឡើយ ។
៨- តែព្រះមានឫទ្ធា បានប្រហារពួកគេហើយ
មិនឲ្យដឹងខ្លួនឡើយ គេដេកដួលរងរបួស ។
៩- ពាក្យពេចន៍គ្មានអត្ថន័យ និយាយស្ដីច្រើនតែហួស
នាំឲ្យពួកគេនោះ ត្រូវវិនាសអន្តរាយ ។
១០- មនុស្សនាំគ្នាស្ញែង ប្រកាស្លែងគ្រប់ៗគ្នា
ពីស្នាព្រះហស្ដថ្លៃ ហើយយល់អ្វីដែលទ្រង់ធ្វើ ។
១១- អ្នកសុចរិតសប្បាយ គេឱនកាយក្រោមបន្ទើរ
ព្រះម្ចាស់ដែលជាផ្ចើ អ្នកទៀងត្រង់លើកតម្កើង ។

## ទំនុកតម្កើងលេខ ៦៥ (៦៤) បទពាក្យ ៧

| | | | |
|---|---|---|---|
| ២- | ឱព្រះម្ចាស់អើយខ្ញុំតម្កើង | លើកព្រះអង្គឡើងនៅក្នុងក្រុង | |
| | ស៊ីយ៉ូនហើយថ្វាយតង្វាយផង | ស្របតាមពាក្យប៉ងបន់សន្យា | ។ |
| ៣- | ព្រះអង្គតែងតែព្រះសណ្ដាប់ | ពាក្យមនុស្សរ៉ាយរ៉ាប់សព្វវេលា | |
| | មនុស្សលោកក៏អាចចរយាត្រា | រកព្រះនាមាទ្រង់បានដែរ | ។ |
| ៤- | ខ្ញុំមានកំហុសទោសធ្ងន់ណាស់ | មានតែព្រះអង្គទើបជួយប្រែ | |
| | លើកលែងកំហុសទោសបង្វែរ | ឲ្យខ្ញុំល្ហើយល្ហែរួចទុក្ខភ័យ | ។ |
| ៥- | អស់អ្នកដែលទ្រង់បានជ្រើសរើស | គេនឹងប្រទះសុខសិរី | |
| | រស់ក្នុងសក្ការដ៏ប្រពៃ | វិសេសថ្លៃថ្លាលើលោកា | ។ |
| | យើងខ្ញុំនឹងបានស្កប់ស្កល់ចិត្ត | ព្រោះបាននៅជិតក្នុងវិហារ | |
| | ទទួលព្រះពរក្នុងពន្លា | ដំណាក់ថ្លៃថ្លាដ៏វិសុទ្ធ | ។ |
| ៦- | បពិត្រព្រះម្ចាស់ព្រះសង្គ្រោះ | ទ្រង់គឺជាព្រះដ៏សុចរិត | |
| | ប្រជាជិតឆ្ងាយនាយសមុទ្រ | គេផ្ញើជីវិតលើព្រះអង្គ | ។ |
| ៧- | ព្រះអង្គពង្រឹងភ្នំទាំងឡាយ | មិនឲ្យទន់ជ្រាយរឹងមាំមុឹង | |
| | ដោយសារបេស្ដាព្រះថ្កុំថ្កើង | រុងរឿងខ្ពស់ឡើងដោយបារមី | ។ |
| ៨- | ព្រះអង្គធ្វើឲ្យទឹកសមុទ្រ | រលកបោកផុតស្ងប់ធ្វើហី | |
| | ទាំងចលាចលមនុស្សប្រុសស្រី | ស្ងប់គ្មានឮអ្វីគួរតក់ស្លុត | ។ |
| ៩- | អ្នកដែលរស់នៅដាច់ស្រយាល | នាំគ្នាជ្រួលប្រាលភ័យរន្ធត់ | |
| | ឃើញទីសម្គាល់អស្ចារ្យផុត | លែងភ័យតក់ស្លុតសប្បាយសើច | ។ |
| ១០- | ព្រះអង្គថែទាំមើលរក្សា | បោចស្មៅបន្លារែកទឹកស្រោច | |
| | ដែនដីជោកសព្វមិនឲ្យខ្លោច | រួចបានបង្កើតជលបរិបូរណ៍ | |
| | អស់ទាំងទន្លេព្រែកបឹងស្ទឹង | ព្រៀបពេញទំហឹងពេញហៀរហូរ | |
| | ពេញទាំងបឹងបួរដងអូរ | ព្រះអង្គចាប់ផ្លូវដូចតទៅ | ។ |
| ១១- | ព្រះអង្គស្រោចស្រពស្រែចំការ | ទាំងដីជងណារាបគ្មានស្មៅ | |
| | មានភ្លៀងធ្លាក់មកទឹកដក់នៅ | តាមវាលស្រែស្រូវពូជជាដុះ | ។ |

១២- ដល់ពេលច្រូតកាត់ព្រះអង្គបាន ផ្តល់ស្រូវជាទានដ៏សប្បុរស
ដែលជាអំណោយដ៏ខ្ពង់ខ្ពស់ សម្បូរទាំងអស់ឥតមានខ្វះ ។
១៣- រីឯនៅវាលរហោស្ថាន មានស្មៅដុះច្រើនពោរពេញពាស
ភ្នំតូចភ្នំធំភ្នំទាំងអស់ ញញឹមស្រស់បស់ដោយអំណរ ។
១៤- ហ្វូងសត្វពាសពេញតាមវាលស្មៅ ជ្រលងពេញទៅស្រូវដ៏ល្អ
អ្វីសព្វសារពើសូរអ៊ូអរ ច្រៀងដោយអំណរដ៏លើសលប់ ។

## ទំនុកតម្កើងលេខ ៦៦ (៦៥) បទកាកគតិ

១- ប្រជាប្រុសស្រី នៅលើដែនដី ទាំងអស់គ្នាអើយ នាំគ្នាអបអរ
កុំបីកន្តើយ អបអរសប្បាយ សាទរព្រះម្ចាស់ ។
២- ចូរច្រៀងតម្កើង សិរីរុងរឿង ព្រះនាមរបស់ ព្រះម្ចាស់នៃយើង
បារមីខ្ពង់ខ្ពស់ តម្កើងថ្កើងយស ថ្វាយដល់ព្រះអង្គ ។
៣- ចូរទូលទ្រង់ថា បពិត្រព្រះជា អម្ចាស់នៃយើង គ្រប់ស្នាព្រះហស្ត
វិសេសថ្កុំថ្កើង យើងសូមលើកឡើង ឲ្យខ្ពស់ដរាប ។
ពួកខ្មាំងសត្រូវ ព្រះអង្គចំនៅ នាំគ្នាលុតក្រាប ដោយឃើញចេស្តា
ឫទ្ធានុភាព ព្រះអង្គរៀងរៀប ជំផេងកន្លង ។
៤- មនុស្សលើដី ទាំងប្រុសទាំងស្រី ក្រាបថ្វាយព្រះអង្គ គេនាំគ្នាច្រៀង
លើកសិរីផង ច្រៀងបទតម្កើង ព្រះនាមល្បាញល្បី ។
៥- ចូរយើងនាំគ្នា ពីគ្រប់ទិសា កុំនៅធ្វើហី មើលស្នាព្រះហស្ត
សុទ្ធតែប្រពៃ ដែលទ្រង់លកលៃ ធ្វើមកមនុស្សលោក ។
៦- ទ្រង់ធ្វើឲ្យទឹក សមុទ្រគគ្រឹក ប្រែជារីងគោក ឲ្យប្រជាជន
ដើរឆ្លងទៅមក យើងជុតទុក្ខសោក ប្រែជាសប្បាយ ។
៧- ព្រះអង្គគ្រប់គ្រង អស់កល្បយូរលង់ ដោយឫទ្ធិបារមី ទ្រង់ត្រួតពិនិត្យ
ប្រជាប្រុសស្រី កុំឲ្យគ្រប់កាយ ក្រោកប្រឆាំងបាន ។
៨- ប្រជាជនអើយ កុំនៅកន្តើយ រួញរាខកខាន តម្កើងព្រះអង្គ
ខ្ពស់ហួសអស់ស្ថាន នោះយើងនឹងបាន សុខដោយបារមី ។

៩- ព្រះអង្គប្រទាន ពួកយើងឲ្យមាន ជីវិតស្រស់ថ្មី ទ្រង់មិនបណ្តោយ
ឲ្យភ្លាត់ដល់ដី មិនឲ្យយើងក្ស័យ រូបរស់ជីវិត ។
១០- បពិត្រព្រះម្ចាស់ ព្រះអង្គជ្រាបច្បាស់ ល្បងលមើលចិត្ត ព្រះអង្គលុតដំ
យើងខ្ញុំពិតៗ ដូចគេបន្សុទ្ធ ដុតមើលមាសប្រាក់ ។
១១- ព្រះអង្គបាននាំ ឲ្យពួកយើងខ្ញុំ ជួបទុក្ខលំបាក ឲ្យរស់វេទនា
កំព្រាតោកយ៉ាក ឈឺចាប់ឥតស្រាក ឥតស្រាន្តពេលណា ។
១២- ព្រះអង្គបណ្តោយ សត្រូវមុខក្រោយ ជិះជាន់សិរសា យើងឆ្លងកាត់ភ្លើង
ក្តៅឥតឧបមា ឆ្លងទឹកជងណា ឈឺផ្សារពេកពន់ ។
ប៉ុន្តែព្រះអង្គ មិនបានបោះបង់ នាំប្រជាជន ហើយទ្រង់ប្រទាន
ភោគផលជានធន ឲ្យប្រជាជន សម្បូណ៌មិនខ្វះ ។
១៣- រូបខ្ញុំចូលស្នាក់ ក្នុងព្រះដំណាក់ របស់ព្រះម្ចាស់ ទាំងនាំតង្វាយ
ដុតមកថ្វាយព្រះ ឥតមានចន្លោះ ពាក្យដែលបានបន់ ។
១៤- ពាក្យពេចន៍អ្វីណា ដែលខ្ញុំសច្ចា កាលគ្រាអាសន្ន ពេលនេះដាក់ថ្វាយ
លាពាក្យបំណន់ ដែលខ្ញុំបានបន់ គ្រប់គ្រាគ្រប់កាល ។
១៥- ខ្ញុំជ្រើសរើសយក សត្វធាត់ៗមក ពពែគោឈ្មោល ព្រមទាំងចៀមផង
យកចេញពីក្រោល ក្លិនសាយភាយដល់ ទៅឯព្រះអង្គ ។
១៦- សូមអ្នកទាំងអស់ ដែលធ្លាប់ស្ម័គ្រស្មោះ លើព្រះគ្មានហ្មង ខ្ញុំនឹងរៀបរាប់
គ្រប់កិច្ចដែលទ្រង់ មានមកកន្លង លើរូបកាយខ្ញុំ ។
១៧- ខ្ញុំស្រែកហៅរក សូមព្រះយាងមក កុំគង់សំងំ ខ្ញុំស្រែកដង្ហោយ
រកព្រះឧត្តម សូរសំឡេងខ្ញុំ តម្កើងទ្រង់ផង ។
១៨- បើខ្ញុំជាមនុស្ស ទុច្ចរិតទុយ៌ស អាក្រក់សៅហ្មង នោះព្រះអង្គនឹង
ជ្រាបមិនសល់ហោង ទោះវាចាផង ក៏ទ្រង់មិនស្តាប់ ។
១៩- ប៉ុន្តែព្រះម្ចាស់ សព្វព្រះទ័យណាស់ ទ្រង់ព្រះសណ្តាប់ ហឫទ័យទូលាយ
ស្ម័គ្រស្មោះដរាប ទ្រង់ចូលចិត្តស្តាប់ ពាក្យខ្ញុំអង្វរ ។
២០- សូមថ្កើងព្រះម្ចាស់ ខ្ពង់ខ្ពស់ពេកណាស់ ដោយចិត្តស្មោះសរ ទ្រង់ពុំបដិសេធ
ពាក្យខ្ញុំអង្វរ ទ្រង់ប្រទានពរ ដល់ខ្ញុំជានិច្ច ។

## ទំនុកតម្កើងលេខ ៦៧ (៦៦) — បទពាក្យ ៧

២- ឱព្រះម្ចាស់អើយសូមមេត្តា សន្តោសករុណាដល់យើងខ្ញុំ
ប្រទានព្រះពរដ៏ឧត្តម ទតមើលយើងខ្ញុំដោយសប្បុរស ។
៣- ដូច្នេះមនុស្សលើផែនដី ស្គាល់មាគ៌ាថ្លៃព្រះអម្ចាស់
ក្នុងចំណោមជនជាតិទាំងអស់ ស្គាល់ការសង្គ្រោះនៃព្រះអង្គ ។
៤- បពិត្រព្រះម្ចាស់អើយសូមឲ្យ ប្រជាទាំងឡាយនាំគ្នាថ្កើង
ព្រះនាមព្រះអង្គឲ្យខ្ពស់ឡើង នាមព្រះនៃយើងគ្រប់ៗកាយ ។
៥- ប្រជាទាំងឡាយនាំគ្នាច្រៀង បន្លឺសំនៀងដោយសប្បាយ
ដ្បិតទ្រង់គ្រប់គ្រងគ្មាននឿយណាយ ប្រជាទាំងឡាយមិនផ្ទៃឆ្អើង ។
៦- បពិត្រព្រះម្ចាស់អើយសូមឲ្យ ប្រជាទាំងឡាយនាំគ្នាថ្កើង
ព្រះនាមព្រះអង្គឲ្យខ្ពស់ឡើង នាមព្រះនៃយើងគ្រប់ៗកាយ ។
៧- ផែនដីបង្កើតនូវភោគផល មិនឲ្យយើងខ្វល់ពីអន្តរាយ
ព្រះម្ចាស់ជាព្រះយើងទាំងឡាយ ប្រទានពរឲ្យសុខគ្រប់គ្រា ។
៨- សូមទ្រង់ប្រទានពរឲ្យយើង និងមនុស្សទាំងពួងគ្រប់អាត្មា
ទាំងអ្នករស់នៅឆ្ងាយជងណា មនុស្សលើលោកាខ្លាចព្រះអង្គ ។

## ទំនុកតម្កើងលេខ ៦៨ (៦៧) — បទព្រហ្មគីតិ

២- ពេលព្រះម្ចាស់ក្រោកឡើង សត្រូវបើងបាក់បបខ្លាច
បេស្តាឫទ្ធិអំណាច អ្នកកោងកាចក៏រត់ចេញ ។
៣- ទ្រង់ឲ្យគេរលាយ សូន្យរូបកាយដូចជាផ្សែង
ដូចថ្ងៃក្តៅហួតហែង ឲ្យក្រមួនរលាយអស់ ។
៤- រីឯជនសុចរិត មិនប្រព្រឹត្តរឿងទុយ៌ស
គេរីករាយខ្លាំងណាស់ នៅចំពោះភក្ត្រព្រះម្ចាស់ ។
៥- ចូរច្រៀងលើកតម្កើង ព្រះនៃយើងកុំក្រឡះ
ត្រួសត្រាយផ្លូវថ្វាយព្រះ ជិះរទេះកាត់វេហាស៍ ។
៦- ព្រះម្ចាស់គង់នៅក្នុង ដំណាក់ទ្រង់ល្អអស្ចារ្យ
ព្រះអង្គជាបិតា អស់កុមារដែលកំព្រា ។

ព្រះអង្គទ្រង់កាត់ក្តី ឲ្យអស់ស្រីដែលវេទនា
មេម៉ាយគ្រប់ៗគ្នា អ្នកវេទនាឲ្យមានផ្ទះ ។
៧- រីអ្នកនៅជាប់គុក មិនស្រណុកស្ទើរព្រាត់ប្រាស
ទ្រង់បើករួចស្រឡះ បានភ្លឺច្បាស់ចិត្តរីករាយ ។
ឯពួកអ្នកបះបោរ គេឆោឡោមិនសប្បាយ
គេនឹងទៅរស់ឆ្ងាយ នៅឯនាយដីហួតហែង ។
៨- បពិត្រព្រះជាម្ចាស់ មានឫទ្ធិច្បាស់គួរស្ញប់ស្ញែង
នៅពេលដែលទ្រង់យាង នាំរាស្ត្រនៅរហោស្ថាន ។
៩- ផែនដីស្ទើរប្រេះបែក ទាំងផ្ទៃមេឃមិនស្រាកស្រាន្ត
ភ្លៀងធ្លាក់គ្រប់ទីស្ថាន ដូចកាលយាងពីស៊ីណៃ ។
១០- បពិត្រព្រះអម្ចាស់ ព្រះអង្គប្រោសយើងគ្មានភ័យ
ភ្លៀងធ្លាក់ត្រជាក់ដី រាស្ត្រក្រក្រីរស់ឡើងវិញ ។
១១- ប្រជារាស្ត្រព្រះអង្គ បានមកតាំងលំនៅពេញ
ដោយទ្រង់បានបញ្ចេញ ក្តីសប្បុរសដល់ទុរគត ។
១២- ពេលព្រះចេញបញ្ជា ស្ត្រីមានគ្នាច្រើនបំផុត
ដូចទ័ពស្រួចមោះមុត ចេញប្រកាសជាដំណឹង ។
១៣- ពេលនោះស្តេចបាក់ទ័ព ពលខ្លះស្លាប់បាត់សូន្យឈឹង
ស្ត្រីៗដែលនៅក្នុង ស្ទុះមករឹងចែកជយភណ្ឌ ។
១៤- ចុះតើអ្នករាល់គ្នា ម្តេចប្រែជាពួនសំងំ
សម្រាកក្នុងជំរំ ម្តេចមិនខំមើលបក្សា ។
សូម្បីតែសត្វព្រាប មានមាសជាប់ពេញស្លាបវា
រោមមានរស្មីថ្លា ខ្លួនបក្សាភ្លឺរន្ទាល ។
១៥- ពេលព្រះម្ចាស់មានឫទ្ធិ ធ្វើឲ្យស្តេចនិងជនពាល
បាក់ទ័ពមានទាំងពីរ ធ្លាក់មកកើលភ្នំសាលម៉ូន ។
១៦- បាសានគឺជាភ្នំ ដីសែនធំកំពូលច្រើន
ជាសក្ការសំខាន់ គួរគយគន់ដីស្មោះស្ម័គ្រ ។

១៧- ហេតុម្តេចមកក្រវែល	នឹងភ្នំដែលព្រះជ្រើស្នាក់
ប្រណៃននឹងដំណាក់	ព្រះជាម្ចាស់គង់រហូត ។

១៨- ទ័ពសេះរបស់ទ្រង់	ច្រើនរញ្ជង់រាប់លានកោដិ
ព្រះអង្គគង់រហូត	លើស៊ីណៃជាសក្ការ ។

១៩- ឱព្រះម្ចាស់ថ្កើងថ្កាន	យាងឡើងស្ថានខ្ពស់អស្ចារ្យ
នាំឈ្លើយទៅផងណា	យញ្ញសក្ការទ្រង់ព្រមយក ។
សូម្បីអ្នកប្រឆាំង	ធ្លាប់តតាំងច្រើនគរគោក
ក៏ទ្រង់នៅតែយក	មិនឲ្យគេខកចិត្តឡើយ ។

២០- សូមសរសើរតម្កើង	ព្រះនៃយើងមិនកន្តើយ
ដ្បិតមានតែទ្រង់ហើយ	ជួយគាំទ្រសង្គ្រោះយើង ។

២១- ព្រះម្ចាស់ព្រះសង្គ្រោះ	យើងឲ្យរស់ទ្រង់មិនឆ្មើង
ព្រះម្ចាស់អាចជួយយើង	ឲ្យរួចផុតពីមរណា ។

២២-ពួកខ្មាំងទុកសក់វែង	ចង់ប្រជែងនឹងសាសនា
ប៉ុន្តែគេច្បាស់ជា	ត្រូវផ្តន្ទាជាមិនខាន ។

២៣-ទ្រង់មានព្រះបន្ទូល	នឹងប្រមូលពីបាសាន
ត្រឡប់វិលវិញថ្កាន	មកពីបាតសមុទ្រភ្លាម ។

២៤- ដើម្បីឲ្យអស់អ្នក	ដែលច្បាស់ជាក់ដើរលុយឈាម
ពួកឆ្កែមិនទាមទាម	មកលិទ្ធឈាមពួកសត្រូវ

២៥- ឱព្រះជាអម្ចាស់	មនុស្សឃើញច្បាស់មិនអាស្រូវ
ទ្រង់ឈ្នះអស់សត្រូវ	ទ្រង់ចូលទៅទីសក្ការ ។

២៦- អ្នកច្រៀងដើរខាងមុខ	អ្នកភ្លេងទុកខាងក្រោយណា
នារីច្រើនអត្តា	ដើរត្រៀបត្រាទាំងវាយភ្លេង ។

២៧-ចូរលើកតម្កើងព្រះ	ជាអម្ចាស់ខ្ពស់ក្រៃលែង
តម្កើងកុំរអែង	ទាំងពូជពង្សអ៊ីស្រាអែល ។

២៨- មានទាំងកុលសម្ពន្ធ	បេនយ៉ាមីនដើរអ៊ើរអែ
បន្ទាប់មកហូរហែ	ជាសម្ពន្ធនៃយូដា ។

មានសម្លេងបំពាក់ ល្អឥតអាក់ដីថ្លៃថ្លា
រួចអ្នកនាំមាគ៌ា សាប់ប៊ីឡូនណែថាលី ។

២៩- ព្រះអ្នកសព្វព្រះទ័យ ឲ្យអ្នកថ្លៃខ្លាំងគ្មានពីរ
សូមព្រះម្ចាស់ជីវី បង្ហាញឫទ្ធីសង្គ្រោះ ។

៣០- ពីដំណាក់ព្រះអង្គ ក្រុងយេរូសាឡឹមខ្ពស់
កន្លែងស្តេចទាំងនោះ យកតង្វាយថ្វាយសក្ការ ។

៣១- សូមព្រះអង្គគំរាម កុំទីមទាមសូមផ្ដន្ទា
ពួកនោះវាដូចជា សត្វនានាតាមដើមត្រែង ។
ពួកអ្នកដឹកនាំស្រុក ដើរតត្រុកគ្មានកោតក្រែង
ដូចជាគោបាតែង តែរត់លេងពីរនាក់កូន ។
ពួកគេនឹងចុះចូល មកមីរម្ហូលឱនក្រាបលូន
យកប្រាក់ជាជំនូន តង្វាយជូនព្រះជាម្ចាស់ ។

៣២- អេស៊ីបបាត់ទូតមក លើកដៃរកដោយរូតរះ
អេត្យូពីស្វែងស្វះ រកព្រះម្ចាស់ពីចម្ងាយ ។

៣៣- នគរនានាអើយ! កុំកន្តើយចូរច្រៀងថ្វាយ
ព្រះម្ចាស់ដូចពណ្ណរាយ លេងភ្លេងថ្វាយកុំរួញរា ។

៣៤- ទ្រង់គង់លើរាជរថ ឡើងខ្ពស់ផុតផ្ទៃមេឃា
បន្លឺសូរខ្ទ័រខ្ទារ ព្រះសូរសៀងនៃព្រះអង្គ ។

៣៥- ចូរយើងប្រកាសថា ឫទ្ធិចេស្ដារបស់ទ្រង់
បេស្ដានៃព្រះអង្គ ទ្រង់គ្រងលើអ៊ីស្រាអែល ។

៣៦- ឱព្រះជាម្ចាស់អើយ ព្រះអង្គហើយជាព្រះដែល
មានឫទ្ធិបារមីក្រៃល អ៊ីស្រាអែលកោខ្លបខ្លាច ។
ព្រះអង្គទ្រង់ប្រទាន រាស្ត្រឲ្យមានចិត្តអង់អាច
មានកម្លាំងអំណាច សូមសរសើរច្រើងព្រះអង្គ ។

## ទំនុកតម្កើងលេខ ៦៩ (៦៨) បទកាកគតិ

២- ឱ! ព្រះជាម្ចាស់ សូមជួយសង្គ្រោះ ឲ្យរួចខ្លួនផង ទឹកដល់ច្រមុះ
ខ្ញុំភ័យកន្លង ស្លាប់គ្រានេះម្តង តែហោងសូន្យបង់ ។
៣- ខ្ញុំផុងក្នុងភក់ ស្រូបបឹតជញ្ជក់ ធ្លាក់ចុះលិចលង់ ធ្លាក់ជ្រៅសែនជ្រៅ
គ្មានអ្វីទ្រទ្រង់ ហើយខ្ញុំកំពុង កាន់តែលិចទៅ ។
៤- ខ្ញុំអស់កម្លាំង ស្រែកមិនបានខ្លាំង នៅខំស្រែកហៅ ស្រែកឡើងស្ងួតក
ទន្ទឹងមើលផ្លូវ ផ្សាភ្នែកពេកកូវ មើលផ្លូវយូរពេក ។
៥- ខ្មាំងទូលបង្គំ នាំគ្នាស្អប់ខ្ញុំ មានច្រើនអនេក ពួកវាទាំងនោះ
ពុំអាចដាក់លេខ ច្រើនក្រាស់ស្កុះស្កេក ជាងសរសៃសក់ ។
ពួកគេទាំងនោះ កម្លាំងខ្លាំងហួស មិននៅដំអក់ គេចង់ព្យាបាទ
ខ្ញុំមនុស្សត្រង់ស្មោះ មិនលួចអ្វីសោះ ឲ្យខ្ញុំសងគេ ។
៦- ឱ! ព្រះជាម្ចាស់ ព្រះអង្គជ្រាបច្បាស់ ទោសខ្ញុំឡើងទ្វេ បាបទាំងប៉ុន្មាន
លាក់មិនបានទេ ព្រះម្ចាស់មុខតែ ជ្រាបអស់គ្មានសល់ ។
៧- ឱព្រះជាម្ចាស់ ទ្រង់ពិតជាព្រះ លើភពទាំងមូល សូមកុំឲ្យអ្នក
ជឿសង្ឃឹមដល់ មានទុក្ខកង្វល់ ត្រូវខ្មាសគេអី ។
៨- ខ្ញុំទ្រាំឲ្យគេ ប្រមាថជៀលជេរ មើលងាយពេកក្រៃ ព្រោះតែព្រះអង្គ
ខ្មាសគេស្ទើរក្ស័យ អាប់ឱនសិរី ព្រោះតែព្រះអង្គ ។
៩- ញាតិទូលបង្គំ មិនរាប់អានខ្ញុំ ពួកគេបោះបង់ បងប្អូនបង្កើត
ក៏មិនស្មោះត្រង់ ចាត់ទុកខ្ញុំនឹង ដូចជនបរទេស ។
១០- នោះមកពីខ្ញុំ ចិត្តនៅមូលផ្តុំ ស្រឡាញ់ខ្លាំងណាស់ ដំណាក់ព្រះអង្គ
គេតិះដៀលត្មះ តែពាក្យទាំងនោះ ត្រូវធ្លាក់លើខ្ញុំ ។
១១- ខ្ញុំយំសោយសោក តមមិនបរិភោគ បាយចំណីនំ ធ្វើឲ្យមនុស្សម្នា
រឹតតែជេរខ្ញុំ ប្រមាថគួនគុំ ថែមហើយថែមទៀត ។
១២- រូបខ្ញុំស្លៀកពាក់ របៀបជាអ្នក កាន់ទុក្ខឥតឃ្លាត ពួកគេនាំគ្នា
ខំប្រឹងឈ្លបឆ្លៀត យករឿងនេះទៅ សើចលេងសប្បាយ ។

១៣- មិនតែប៉ុណ្ណោះ គេទាំងស្រីប្រុស នាំគ្នានិយាយ ដៀលត្មះពីខ្ញុំ
តាមផ្សារជិតឆ្ងាយ ចំអកឡកឡឺយ អាក្រក់ក្រៃលែង ។
១៤- ឱ! ព្រះអម្ចាស់ ពេលឥឡូវនេះ សូមទ្រង់សម្តែង ហឫទ័យសន្តោស
ករុណាធំធេង សង្គ្រោះកុំលែង សូមឆ្លើយតបផង ។
១៥- សូមរំដោះខ្ញុំ រួចពីភក់ជ្រាំ ទុក្ខសោកសៅហ្មង ពីកណ្តាប់ដៃ
អ្នកស្អប់ខ្ញុំផង សូមជួយស្រោចស្រង់ ឲ្យផុតទឹកជ្រៅ ។
១៦- កុំឲ្យខ្សែទឹក ត្របាញ់គគ្រឹក ទាញរឹងយកទៅ រូបខ្ញុំឲ្យលង់
ក្នុងទឹកជ្រោះជ្រៅ កុំឃុំខ្ញុំនៅ ក្នុងអណ្តូងអី ។
១៧- ឱព្រះអម្ចាស់ ព្រះអង្គមានព្រះ ហឫទ័យប្រណី ដ្បិតព្រះអង្គមាន
ករុណាឥតបី មេត្តាប្រណី ទតមកខ្ញុំផង ។
១៨- សូមព្រះអង្គកុំ លាក់ភក្ត្រពីខ្ញុំ សូមឆ្លើយទាក់ទង ខ្ញុំអ្នកបម្រើ
វេទនាកន្លង ក្នុងគ្រានេះម្តង ជួយខ្ញុំប្រញាប់ ។
១៩- សូមយាងមកជិត ហើយលោះជីវិត រំដោះខ្ញុំឆាប់ សូមជួយពីខ្មាំង
ឲ្យខ្ញុំត្រឡប់ វិលទៅកាន់កាប់ មាតុភូមិវិញ ។
២០- ព្រះអង្គជ្រាបច្បាស់ ថាខ្ញុំគេត្មះ បន្ថោកជ្រក់ជ្រេញ បង្អាប់កិត្តិយស
ខ្ញុំខ្មាសគេពេញ តែអ្នកនោះវិញ ព្រះអង្គស្គាល់ជាក់ ។
២១- ពាក្យត្មះតិះដៀល បាក់រុកឆ្កឹះឆ្កៀល ឈឺស្មើទាត់ជាក់ ចិត្តខ្ញុំខ្លោចផ្សា
ឈឺចុកញ័រញាក់ គិតថាមានម្នាក់ នឹងអាណិតខ្ញុំ ។
ក្រែងមានអ្នកជួយ តែឥតមានមួយ ខ្ញុំកើតទុក្ខធំ សង្ឃឹមថាមាន
គេមកលួងលោម រំលកទុក្ខខ្ញុំ តែរកមិនបាន ។
២២-ខ្ញុំឃ្លានបរិភោគ គេមិនបានយក អាហារហូបបាន បែរយកថ្នាំពុល
ឲ្យខ្ញុំក្ស័យប្រាណ ទោះស្រេកពុំបាន ស្គាល់រសជាតិទឹក ។
២៣-សូមឲ្យពិធី ជប់លៀងវក់វី ក្លាយជាវរវីក ចាប់គេចងជាប់
គ្នាច្រើនសន្ធឹក ទាំងយប់ល្ងាចព្រឹក ឲ្យវិនាសខ្ទាយ ។
២៤- ឲ្យភ្នែកពួកគេ ស្រវាំងឡើងទ្វេ មើលមិនយល់អ្វី កុំឲ្យគេឈ្នះ
ឲ្យបរាជ័យ វិនាសក្សិណក្ស័យ រហូតតទៅ ។

២៥- សូមព្រះអង្គជះ ពិរោធទាំងអស់ លើពួកសត្រូវ ធ្វើទារុណកម្ម
គេឆាប់ៗទៅ កុំបង្អង់នៅ យល់ដល់គេឡើយ ។
២៦- សូមឲ្យលំនៅ របស់គេត្រូវ ស្ងាត់ជ្រងំហើយ កុំឲ្យមានម្នាក់
រស់នៅបានឡើយ ទីនោះឯងហើយ ជារហោស្ថាន ។
២៧- ដ្បិតគេបានធ្វើ ទុក្ខម្នេញមិនស្មើរ ព្យាបាទរំខាន ដល់អ្នកដែលព្រះ
បានដាក់ទោសទណ្ឌ របួសសែនធ្ងន់ គេឃើចាប់ណាស់ ។
២៨- សូមព្រះអង្គដាក់ ទោសឲ្យដល់ថ្នាក់ កុំប្រែក្រឡះ តាមគេប្រព្រឹត្ត
ចិត្តពាលទុយ៉ស សូមកុំស្រណោះ អាឡោះមេត្តា ។
២៩- សូមទ្រង់លប់ឈ្មោះ គេចេញពីមនុស្ស ឲ្យគេមរណា សូមដកគេចេញ
ពីឈ្មោះមនុស្សា សុចរិតមេត្តា កុំឲ្យមានសល់ ។
៣០- រីឯរូបខ្ញុំ ទុរគតក្រៀមក្រំ ចុកចាប់ខ្វាយខ្វល់ ឱ! ព្រះម្ចាស់អើយ
ជួយសង្គ្រោះដល់ ខ្ញុំអ្នកទីទ័ល សូមស្តារវិញផង ។
៣១- ខ្ញុំនឹងច្រៀងកោត សរសើរបំផុត ព្រះនាមព្រះអង្គ ប្រកាសពីភាព
ថ្កុំថ្កើងរុងរឿង របស់ព្រះអង្គ បម្រើគោរព ។
៣២- តម្កើងដូច្នេះ ប្រសើរត្រចះ និងជាទីសព្វ ព្រះហឫទ័យ
ព្រះអម្ចាស់គាប់ លើសពីការដុត កូនគោទៅថ្វាយ ។
៣៣- អស់អ្នកទុរគត វេទនាក្រខ្សត់ ចិត្តគេសប្បាយ គេមានអំណរ
ឥតមានខ្វល់ខ្វាយ នឹងរស់វែងឆ្ងាយ អាយុយឺនយូរ ។
៣៤- ដ្បិតទ្រង់សណ្ដាប់ ពាក្យអ្នកសុភាព និយាយទូលថ្វូរ ទ្រង់មិនលះបង់
អ្នកជាប់ឃុំឃូរ ឲ្យទួញទ្រហោរ នៅឯកោទេ ។
៣៥- ផែនដីផ្ទៃមេឃ សមុទ្រជ្រៅជ្រែក កុំនៅទំនេរ សត្វក្នុងសមុទ្រ
ទាំងអស់ហែលរេ ចូរតម្កើងដែរ សិរីរុងរឿង ។
៣៦- ដ្បិតព្រះជាម្ចាស់ ទ្រង់នឹងសង្គ្រោះ ក្រុងយើងខ្ពស់ឡើង ទីក្រុងនានា
ស្រុកយូដាផង ព្រះអង្គកសាង ថ្មីវិញទាំងអស់ ។
ឲ្យប្រជាជន ចូលមកបន្ទន់ ចូលជ្រកនៅរស់ កន្លែងដើមវិញ
ឥតមានបង់បោះ សុខស្រួលឥតខ្ចោះ កាន់កាប់ជាថ្មី ។

| | | | |
|---|---|---|---|
| ៣៧- កូនចៅរបស់ | អ្នកបម្រើស្មោះ | នឹងទទួលដី | មកទុកជាកេរ |
| មរតកប្រពៃ | បវរថ្លៃថ្លា | តាំងជាលំនៅ | ។ |

## ទំនុកតម្កើងលេខ ៧០ (៦៩) បទពាក្យ ៧

២- ឱព្រះជាម្ចាស់នៃខ្ញុំអើយ សូមយាងមកហើយជួយរំដោះ
កណ្ណាអាសូរដោយសង្គ្រោះ ប្រោសខ្ញុំឲ្យរស់បានឆាប់ៗ ។
៣- ឲ្យអ្នកព្យាបាទជីវិតខ្ញុំ ត្រូវជួបទុក្ខធំកេរ្តិ៍ឈ្មោះអាប់
ទាំងអ្នកដែលប៉ងចង់ធ្វើបាប វិនាសផុតឆាប់ត្រូវដកខ្លួន ។
៤- សូមឲ្យអ្នកដែលសើចចំអក លែបខាយឡើយឡកវិនាសសូន្យ
ត្រូវបរាជ័យមិនរួចខ្លួន កេរ្តិ៍ឈ្មោះសាបសូន្យអន្តរាយ ។
៥- រីអ្នកស្រឡាញ់ការសង្គ្រោះ ឲ្យគេទាំងនោះជួបសប្បាយ
ថ្លែងឥតឈប់ឈរទាំងយប់ថ្ងៃ សូមលើកសិរីថ្កើងព្រះម្ចាស់ ។
៦- ឱព្រះអម្ចាស់ទូលបង្គំ រស់រងទុក្ខធំវេទនាណាស់
សូមយាងមកជួយដោយរូតរះ មេត្តាសង្គ្រោះកុំបង្អង់ ។

## ទំនុកតម្កើងលេខ ៧១ (៧០) បទពាក្យ ៧

១- បពិត្រព្រះម្ចាស់ខ្ញុំសូមជ្រក ក្រោមម្លប់ជម្រកនៃព្រះអង្គ
កុំឲ្យរូបខ្ញុំត្រូវបាត់បង់ ទាំងកេរ្តិ៍ឈ្មោះផងអាប់អាសារ ។
២- ដោយព្រះអង្គមានព្រះហឫទ័យ សុចរិតថ្លាថ្លៃសូមមេត្តា
ផ្ទៀងព្រះកាណ៌ស្ដាប់ខ្ញុំវាចា សង្គ្រោះជីវាឲ្យបានរស់ ។
៣- សូមព្រះអង្គទៅជាថ្មដា លាក់ពួនអាត្មាខ្ញុំផុតគ្រោះ
ទ្រង់សព្វព្រះទ័យប្រណីប្រោស ជីវិតខ្ញុំរស់បានសុខសាន្ត ។
៤- ឱព្រះជាម្ចាស់សូមរំដោះ ខ្ញុំពីឃ្នាងខ្នោះពួកតិរច្ឆាន
រួចផុតពីដៃជនសាមាន្យ មនុស្សទាំងប៉ុន្មានប៉ងយាយី ។
៥- បពិត្រព្រះជាអម្ចាស់អើយ រូបខ្ញុំនេះហើយផ្ញើជីវី
ជីវិតលើទ្រង់គ្រប់នាទី សង្ឃឹមតាំងពីនៅក្មេងវ័យ ។

| | | |
|---|---|---|
| ៦- ខ្ញុំសូមពឹងផ្អែកលើព្រះអង្គ | តាំងពីនៅក្នុងផ្ទៃម្ដាយថ្លៃ | |
| ព្រះអង្គតែមួយសព្វព្រះទ័យ | ជុសខាត់កែឆ្នៃខ្ញុំឥតឈប់ | ។ |
| ៧- មនុស្សម្នាជាច្រើនបេះតែនឹក | ឆ្ងល់ខ្ញុំល្ងាចព្រឹកទាំងថ្ងៃយប់ | |
| តាមពិតខ្ញុំមានព្រះជាម្លប់ | ជីវិតខ្ញុំស្ងប់រៀងរហូត | ។ |
| ៨- ខ្ញុំតែងពោលពាក្យកោតសរសើរ | ព្រះគ្មានអ្វីស្មើខ្ពស់បំផុត | |
| តម្កើងសិរីទ្រង់រហូត | ព្រះតែមួយគត់ទាំងយប់ថ្ងៃ | ។ |
| ៩- ឥឡូវនេះខ្ញុំចាស់ជរា | ទ្រុឌទ្រោមគ្រាំគ្រាកម្លាំងថយ | |
| មេត្តាកុំបោះបង់ខ្ញុំឡើយ | កុំទុកខ្ញុំឲ្យនៅឯកា | ។ |
| ១០- ដ្បិតខ្មាំងសត្រូវរបស់ខ្ញុំ | គេនៅជួបជុំពោលមុសា | |
| អស់អ្នកដែលឃ្លាំចាំប្រហារ | គេពិភាក្សាឃោបល់គ្នា | ។ |
| ១១- គេថាព្រះម្ចាស់លែងអើពើ | លែងការពារមើលថែគាំពារ | |
| ចូរដេញតាមចាប់គាត់គ្រប់គ្នា | ព្រោះគ្មាននរណាជួយគាត់បាន | ។ |
| ១២- ឱ! ព្រះជាម្ចាស់អើយសូមកុំ | យាងចាកបោលខ្ញុំចេញចាកស្ថាន | |
| សូមយាងមកជួយកុំបីខាន | ឆាប់ៗនឹងបានខ្ញុំធូរស្បើយ | ។ |
| ១៣- សូមឲ្យអស់អ្នកដែលប៉ុនប៉ង | ប្រហារខ្ញុំបង់ត្រូវអន្តរាយ | |
| សាបសូន្យទាំងឈ្មោះបាត់ទាំងកាយ | កិត្តិយសប្រែក្លាយបាត់សូន្យឈឹង | ។ |
| ១៤- រីឯរូបខ្ញុំ ខ្ញុំសង្ឃឹម | លើព្រះជាធំជាពំនឹង | |
| នៅតែសរសើរគិតសញ្ជឹង | កោតក្រែងព្រះអង្គជាដរាប | ។ |
| ១៥- ពីព្រឹកដល់ល្ងាចខ្ញុំនៅតែ | តំណាលហូរហែនិយាយប្រាប់ | |
| ពីស្នាព្រះហស្តថ្លៃគួរគាប់ | ពីដើមរៀបរាប់ច្រើនមហិមា | ។ |
| ១៦- បពិត្រព្រះជាម្ចាស់ខ្ញុំអើយ | ព្រោះព្រះអង្គហើយយកអាសា | |
| ខ្ញុំថ្កើងរំលឹកធម៌ករុណា | សុចរិតថ្លៃថ្លារបស់ទ្រង់ | ។ |
| ១៧- បពិត្រព្រះជាម្ចាស់ខ្ញុំអើយ | ទ្រង់អប់រំហើយគ្មានសៅហ្មង | |
| តាំងពីក្មេងទល់គ្នានេះម្ដង | ចិត្តនៅចាំចងតែព្រះអង្គ | ។ |
| ១៨- ឱ! ព្រះជាម្ចាស់ថ្លៃខ្ញុំអើយ | សក់សទៅហើយធ្មេញបាក់ផង | |
| ខ្ញុំចាស់ជរាគ្រានេះម្ដង | សូមកុំបោះបង់ខ្ញុំបោលឡើយ | ។ |

| | | | |
|---|---|---|---|
| | ដើម្បីឲ្យខ្ញុំអាចប្រកាស | ពីស្នាព្រះហស្តព្រះម្ចាស់ថ្លៃ | |
| | ប្រាប់អ្នកជាន់ក្រោយឲ្យយល់ន័យ | ឫទ្ធាបារមីព្រះជាម្ចាស់ | ។ |
| ១៩- | បពិត្រព្រះជាម្ចាស់ខ្ញុំអើយ | ហឫទ័យល្ងឹងល្ងើយសុចរិតណាស់ | |
| | ដ្បិតទ្រង់ធ្វើការអស្ចារ្យខ្ពស់ | ឱព្រះជាម្ចាស់គ្មានអ្នកដូច | ។ |
| ២០- | ព្រះអង្គបានធ្វើឲ្យយើងខ្ញុំ | ជួបអាសន្នធំឈឺចុករចួច | |
| | ព្រះអង្គនឹងស្រង់ខ្ញុំឲ្យរួច | ជីវិតខ្ញុំដូចកើតជាថ្មី | ។ |
| ២១- | ព្រះនឹងប្រទានឲ្យរូបខ្ញុំ | មានកិត្តិយសធំវិតប្រពៃ | |
| | ព្រះអង្គសម្រាលទុក្ខជាថ្មី | ខ្ញុំរាល់ខែថ្ងៃមិនដែលខាន | ។ |
| ២២- | រីឯរូបខ្ញុំនឹងរៀបចំ | បាប់ទាញប្រគុំឥតស្រាកស្រាន្ត | |
| | ចាប៉ីកំដរលេងកំសាន្ត | ថ្លែងអរព្រះគុណព្រះអង្គខ្លាំង | ។ |
| | ដ្បិតព្រះអង្គមានព្រះហឫទ័យ | ស្មោះស្ម័គ្រប្រពៃខ្ញុំព្រមទាំង | |
| | ដេញពិណច្រៀងរាំថ្វាយព្រះអង្គ | ព្រះម្ចាស់ដ៏វិសុទ្ធរបស់អ៊ីស្រាអែល | ។ |
| ២៣- | ខ្ញុំនឹងលេងភ្លេងច្រៀងអំណរ | ព្រោះទ្រង់បន្តប្រោសឥតដែល | |
| | ឲ្យខ្ញុំមានទុក្ខធ្ងន់ក្រាស់ក្រែល | រំដោះជីវិតខ្ញុំតទៅ | ។ |
| ២៤- | ខ្ញុំនឹងពោលថ្លែងពីសេចក្តី | សុចរិតប្រពៃគ្មានហ្មងសៅ | |
| | ដ្បិតអ្នកដែលមានចិត្តអាស្រូវ | អ្នកនោះនឹងត្រូវអាម៉ាស់មុខ | ។ |

## ទំនុកតម្កើងលេខ ៧២ (៧១) — បទកាកគតិ

| | | | | |
|---|---|---|---|---|
| ១- | ព្រះជាម្ចាស់អើយ | សូមប្រទានឲ្យ | រាជបុត្រនេះចេះ | វិនិច្ឆ័យក្តី |
| | តាមព្រះតម្រិះ | សុចរិតវិសេស | របស់ព្រះអង្គ | ។ |
| ២- | សូមឲ្យរាជា | គ្រប់គ្រងគ្រប់គ្នា | ប្រជារាស្ត្រទ្រង់ | ដោយយុត្តិធម៌ |
| | សុចរិតផូរផង់ | វិសេសឥតហ្មង | ត្រឹមត្រូវតាមច្បាប់ | ។ |
| ៣- | សូមឲ្យអស់ភ្នំ | ទាំងតូចទាំងធំ | ផ្តល់ផលគួរគាប់ | សម្បូរសប្បាយ |
| | ឲ្យបានសព្វគ្រប់ | នាំមកស្រោចស្រព | ក្តីសុចរិតផង | ។ |
| ៤- | សូមរាជារក | យុត្តិធម៌មក | កុំបីមានហ្មង | ដល់ជនក្រីក្រ |
| | កម្សត់ទាំងពួង | ហើយកម្ទេចផង | អ្នកដែលជិះជាន់ | ។ |

៥- បើព្រះអាទិត្យ នៅតែរះពិត ព្រមទាំងព្រះច័ន្ទ នៅតែបញ្ចេញ
រស្មីស្រទន់ សូមទ្រង់មានជន្ម យឺនយូរប្រពៃ ។

៦- សូមផ្តល់ព្រះពរ សិរីបវរ ដល់រាស្ត្រប្រុសស្រី ដូចជាភ្លៀងធ្លាក់
មកលើផែនដី ត្រជាក់ឥតបី គ្មានសល់ចន្លោះ ។

៧- សូមឲ្យសេចក្តី សុចរិតថ្លាថ្លៃ ចម្រើនខ្ពង់ខ្ពស់ នៅក្នុងរជ្ជកាល
រាជាអង្គនោះ កុំបីមានទាស់ សុខសាន្តតទៅ ។

៨- សូមព្រះរាជា គ្រប់គ្រងកុំរា កុំឲ្យហ្មងសៅ ពីសមុទ្រមួយ
មិនបង្អង់នៅ រហូតដល់ទៅ ស្រុកដាច់ស្រយាល ។

៩- ប្រជាដែលរស់ តាមវាលទាំងនោះ នឹងត្រេកត្រអាល ក្រាបថ្វាយបង្គំ
គ្រប់សម័យកាល សត្រូវច្រួលច្រាល វិនាសអាសារ ។

១០-អស់ស្តេចទាំងឡាយ នឹងយកតង្វាយ មកថ្វាយករុណា ឥតមានខកខាន
មួយវេលាណា ទាំងកោះនានា យកមកទាំងអស់ ។

១១- ស្តេចទាំងប៉ុន្មាន ឥតមានខកខាន ចូលរួមដោយស្មោះ ក្រាបថ្វាយបង្គំ
រាជាទាំងអស់ ប្រជាទាំងនោះ បម្រើករុណា ។

១២- ទ្រង់នឹងរំដោះ អ្នកក្រទាំងអស់ ដោយធម៌មេត្តា អ្នកទុរគតស្រែក
សុំក្តីករុណា ព្រះអង្គរក្សា អ្នកគ្មានទីពឹង ។

១៣- ទ្រង់សែនអាណិត អាសូរពេកពិត អ្នកអត់លំនឹង និងជនកម្សត់
គ្មានអ្វីរំពឹង ព្រះអម្ចាស់នឹង សង្គ្រោះជីវិត ។

១៤- ទ្រង់នឹងរំដោះ ពួកគេឲ្យរស់ ពីពួកឧក្រិដ្ឋ ជនកាចសាហាវ
ពាលាទុច្ចរិត ព្រោះតែជីវិត ថ្លៃថ្លាក្រៃលែង ។

១៥- សូមឲ្យរាជា មានព្រះជន្មា យឺនយូរអង្វែង គេនឹងយកមាស
មកថ្វាយទ្រង់ផង អង្វរព្រះអង្គ ឥតមានឈប់ឈរ ។

១៦- សូមឲ្យក្នុងស្រុក ស្រូវពេញជង្រុក ផ្តល់ភោគផលល្អ តាមកំពូលភ្នំ
ក៏ឲ្យសម្បូរ ប្រជាកុះករ កើនឡើងដូចស្មៅ ។

១៧- សូមឲ្យរាជា មានព្រះនាមា ល្បីល្បាញតទៅ នាមព្រះករុណា
ស្ថិតស្ថេរគង់នៅ ដរាបរៀងតទៅ លើដីក្រោមមេឃ ។

១៨- សូមលើកតម្កើង ព្រះអង្គខ្ពស់ឡើង ឥតមានអល់អែក ព្រះអ៊ីស្រាអែល
ល្អល្អះអនេក ការអស្ចារ្យពេក ដែលទ្រង់សម្ដែង ។
១៩- សូមលើកតម្កើង ព្រះនាមថ្កុំថ្កើង ព្រះអង្គគួរស្ញែង សូមឲ្យដែនដី
ទាំងមូលកោតក្រែង សិរីចាំងចែង របស់ព្រះអង្គ ។

## ទំនុកតម្កើងលេខ ៧៣ (៧២) បទពាក្យ ៧

១- ព្រះម្ចាស់ពិតជាមានព្រះទ័យ សប្បុរសប្រពៃថ្លៃក្រៃក្រៃល
ចំពោះជនជាតិអ៊ីស្រាអែល និងអស់អ្នកដែលចិត្តបរិសុទ្ធ ។
២- ចំពោះខ្ញុំផ្ទាល់ហៀបភ្លាត់ជើង ទប់ខ្លួនមិននឹងស្ទើរតែដុត
បាប់អ្វីមិនជាប់ចង់របូត បើសិនខ្ញុំភ្លាត់ច្បាស់ជាដួល ។
៣- ព្រោះខ្ញុំមានចិត្តប្រណែនខឹង ពួកពាលអស់ហ្នឹងរស់សុខស្រួល
គេរីកចម្រើនកើនពាសវាល ទោះរឿងធ្ងន់ស្រាលគ្មានទុក្ខា ។
៤- គេរស់ដូចជាគ្មានភិតភ័យ គ្មានកង្វល់អ្វីសោះឡើយណា
ក្នុងមួយជីវិតមិនវេទនា មានសាច់ឈាមថ្លាល្អម៉ត់ហ្មង ។
៥- គេពុំដែលស្គាល់ទុក្ខលំបាក វេទនាតោកយ៉ាកដូចអ្នកផង
មិនដែលស្គាល់អត់ឃ្លានបានម្ដង ដូចអស់អ្នកផងដែលវេទនា ។
៦- ពួកគេជាជនមានអំនួត ចូលចិត្តអាងអួតខុសធម្មតា
អំពើឃោរឃៅកាចឫស្សា គេទុកដូចជាខោអាវពាក់ ។
៧- ពួកគេមានចិត្តសែនអាក្រក់ វៀចវេរវីវក់អបលក្ខណ៍
មិនអាចបាំងបាត់ឬពួនលាក់ គឺលេចច្បាស់ជាក់ដោយខ្លួនឯង ។
៨- គេនាំគ្នាពោលសើចចំអក ពាក្យសែនអាក្រក់មិនរអែង
គេពោលប្រកាសស្រែកក្ដែងៗ ជិះជាន់គ្មានក្រែងអ្នកដទៃ ។
៩- មាត់ពោលព្រហើនពាក្យផ្ដេសផ្ដាស ប្រមាថព្រះម្ចាស់មិនដឹងអី
អណ្ដាតទៀតសោតឥតសំចៃ ពេលគេហារស្ដីឥតមានគិត ។
១០- សូម្បីប្រជារាស្ត្រព្រះម្ចាស់ ក៏វង្វេងប្រាសក្បត់ក្រមក្រឹត្យ
ចូលចិត្តស្ដាប់ពាក្យដែលមិនពិត ពួកពាលឧក្រិដ្ឋដូចផឹកទឹក ។

១១- គេពោលមើលងាយព្រះជាម្ចាស់ ព្រះដ៏ខ្ពង់ខ្ពស់ទាំងយប់ព្រឹក
គេថាព្រះនោះកុំនៅនឹក ព្រះនោះសំពីកមិនដឹងអ្វី ។
១២- នេះហើយជនពាលដៀលស្ដីដេរ គ្មានព្រួយអ្វីទេគ្មានភិតភ័យ
បានសុខជានិច្ចមិនខ្វល់អី ចម្រើនឆាប់ក្រៃកេតរៀងទៅ ។
១៣- ឯទូលបង្គំខំកាន់ចិត្ត បរិសុទ្ធពេកពិតឥតអាស្រូវ
មិនប្រព្រឹត្តបាបសោកហ្មងសៅ ទោះជាធ្វើត្រូវក៏គ្មានផល ។
១៤- ខ្ញុំមានទុក្ខព្រួយសែនសោយសោក ទឹកភ្នែកស្រក់ជោគហូរដូចជល
រងទារុណកម្មទុក្ខកង្វល់ ម្ដេចទ្រង់មិនខ្វល់នឹងប្រណី ។
១៥- ប្រសិនបើរូបទូលបង្គំ ព្រមស៊ីគ្រលុំមនុស្សអប្រីយ៍
នោះដូចក្បត់បងប្អូនប្រុសស្រី បុត្រធីតាថ្លៃទ្រង់មិនខាន ។
១៦- រាល់ខែរាល់ថ្ងៃខ្ញុំសញ្ជឹង រំពឹងចង់ដឹងហេតុដើមដាន
ពីបញ្ហានេះមិនដែលខាន តែយល់មិនបានពិបាកហួស ។
១៧- ទាល់តែដល់ទីសក្ការៈ ទើបបានយល់ជាក់ដឹងទាំងអស់
ថាចុងបញ្ចប់ពួកគេនោះ នឹងរងទុក្ខទោសរបៀបណា ។
១៨- តាមពិតព្រះអង្គដាក់គេនៅ ទីជំរាលជ្រៅគួររអា
ព្រះអង្គឲ្យគេធ្លាក់អាត្មា ក្នុងជ្រោះអន្ទិកា មហន្តរាយ ។
១៩- ក្នុងពេលតែមួយប៉ព្រិចភ្នែក ពួកគេបាក់បែកសែនសោកស្ដាយ
ជួបតែវិនាសប្រាសអន្តរាយ សាបសូន្យរលាយគួររន្ធត់ ។
២០- បពិត្រព្រះម្ចាស់សូមតើនឡើង កុំនៅឆ្មៃឆ្មើងជួយកម្ចាត់
កម្ចាយពួកគេឲ្យខ្ចាតបាត់ រលាយរលត់ដូចយល់សប្ដិ ។
២១- ពេលខ្ញុំឆ្អែតចិត្តឈឺចុកចាប់ អារម្មណ៍អ្សូរអាប់ដូចមិនស្ងប់
២២-ខ្ញុំដូចតិរច្ឆានគេបោមស្នប់ នៅចំពោះភក្ត្រព្រះជាម្ចាស់
២៣-តែខ្ញុំរស់នៅជាមួយព្រះ គ្មានខ្វល់អ្វីសោះភ្លឺស្រឡះ
ទ្រង់កាន់ដៃខ្ញុំមិនរបេះ ខ្ញុំមិនភ័យសោះអស់សៅហ្មង ។
២៤- ព្រះអង្គដឹកនាំទូលបង្គំ ឲ្យដើរតាមព្រមព្រះទ័យទ្រង់
នៅចុងបញ្ចប់នោះព្រះអង្គ យកខ្ញុំផ្ចិតផ្គង់នៅជាមួយ ។

២៥- ឯស្ថានបរមសុខខ្ញុំគ្មានពឹង ព្រះក្រៅពីហ្នឹងទេព្រះអើយ
មានតែព្រះមួយអង្គនេះហើយ បានសុខឥតស្បើយគ្មានទុក្ខា ។
បើលើផែនដីព្រះគង់ជិត នោះខ្ញុំមិនភិតភ័យឡើយណា
មិនចង់បានអ្វីសព្វប្រការ អរឥតឧបមាគ្មានព្រួយភ័យ ។
២៦- ចិត្តគំនិតកាយបេះតែខ្សោយ មិនដែលល្ហែល្ហើយទេព្រះអើយ
ប៉ុន្តែព្រះម្ចាស់មិនកន្តើយ ព្រះអង្គនោះហើយជាបង្អែក ។
២៧-ឯអ្នកដែលងាកចេញចាកឆ្ងាយ នឹងត្រូវអន្តរាយខ្លាំងអនេក
អ្នកដែលក្បត់ទ្រង់នឹងសង្វេគ ស្រណោះខ្លួនពេកស្មើរក្សិណក្ស័យ ។
២៨-រីទូលបង្គំមានមង្គល ឥតមានអំពល់ឥតព្រួយភ័យ
ពេលណានៅជិតព្រះម្ចាស់ថ្លៃ នោះសព្វអ្វីៗស្រស់ផូរផង់ ។
បពិត្រព្រះម្ចាស់សូមមេត្តា ជីវិតជីវ៉ាផ្ញើព្រះអង្គ
ទូលបង្គំសូមប្រកាសផង ស្នាព្រះហស្តទ្រង់ដ៏អស្ចារ្យ ។

**ទំនុកតម្កើងលេខ ៧៥ (៧៣)** **បទព្រះហ្មគីតិ**

១- បពិត្រព្រះម្ចាស់អើយ ចុះម្ដេចឡើយក៏ព្រះអង្គ
ឈប់នឹកហើយបោះបង់ ឲ្យរញ្ជង់នៅកំព្រា ។
ម្ដេចក៏ទ្រង់ពិរោធ យើងរហូតឲ្យវេទនា
ភ្លេចអស់រាស្ត្រប្រជា ជ្លាប់គំាពារគ្រាប្រណី ។
២- កុំភ្លេចព្រះសហគមន៍ ដែលទ្រង់សុំមកថ្មមបី
ជាកម្មសិទ្ធិប្រពៃ សូមអាល័យភ្ញាកនឹកនា ។
គឺពួកកុលសម្ពន្ធ ដែលទ្រង់បានលោះមកជា
មរតកថ្លៃមហិមា រកពណ៌នាក៏ពុំបាន ។
សូមនឹកដល់បងប្អូន ភ្នំស៊ីយ៉ូនល្អថ្កើងថ្កាន
ទ្រង់យកជាទីស្ថាន គង់នៅបានក្ដីសុខដុម ។
៣- សូមយាងមកវិហារ ដែលគ្រាំគ្រាយូរខែឆ្នាំ
សក្ការៈត្រូវខ្មៅចខ្ទាំ លែងរឹងមាំខ្លាំងបំផ្លាញ ។

៤- បច្ចាមិត្រព្រះអង្គ ស្រែករំពងគ្រប់ទីស្ថាន
ដែលព្រះអង្គធ្លាប់បាន ជួបនឹងយើងរៀងរាល់ថ្ងៃ ។
៥- ពួកគេប្រៀបបានទៅ ផ្លែពូថៅអ្នកកាប់ព្រៃ
គេប្រឹងឥតសំចៃ រៀងរាល់ថ្ងៃឥតឈប់ឈរ ។
៦- គេយកផ្លែពូថៅ វាយសំដៅក្បាច់ដ៏ល្អ
រចនាស្រស់បវរ មិនឈប់ឈរមិនស្រណោះ
៧- គេដុតទីសក្ការ ដ៏ថ្លៃថ្លាបោលទាំងអស់
បន្ថោកដំណាក់ព្រះ ជាអម្ចាស់ឥតមានក្រែង ។
៨- គេនាំគ្នាគិតថា នឹងផ្ដន្ទាឲ្យជាក់ស្ដែង
ដុតបំផ្លាញកន្លែង គ្មានរអែងនៅក្នុងស្រុក ។
៩- យើងខ្ញុំលែងឃើញអ្វី ដែលប្រពៃតទៅមុខ
ជាទីសម្គាល់ទុក ថាទៅមុខយើងជាតិអ្វី ? ។
យើងលែងមានទាំងអស់ បាត់ទាំងឈ្មោះព្យាការី
គ្មាននរណាដឹងអី ថាយើងនៅច្នេះដល់ណា ។
១០- បពិត្រព្រះម្ចាស់អើយ ហេតុម្ដេចឡើយនៅមេត្តា
ឲ្យអស់ពួកបច្ចា ដៀលមុសាដល់ណាទៀត ?
១១- សូមបារមីព្រះអង្គ សង្គ្រោះផងកុំបីឃ្លាត
លាក់ទុកធ្វើអ្វីទៀត ឲ្យខ្មាំងឃ្លាតបាក់ខ្វាយខ្វាត់ ។
១២- ឱព្រះជាម្ចាស់អើយ ព្រះអង្គហើយគឺជាក្សត្រ
នៃខ្ញុំពីដើមពិត ទ្រង់តែងគិតជួយច្រើនសា ។
១៣- ទ្រង់បង្ក្រាបសមុទ្រ ដោយសារឫទ្ធិខ្លាំងអស្ចារ្យ
រួចហើយក៏ប្រហារ ផ្តាច់សិរសានាគសាមាន្យ ។
១៤- ព្រះអង្គវាយកម្ទេច សិរសាស្ដេចក្រពើបាន
ឲ្យអស់សត្វតិរច្ឆាន ក្នុងរហោស្ថានជាអាហារ ។
១៥- ទ្រង់ធ្វើឲ្យទឹកផុស ដូចទឹកជ្រោះខ្លាំងអស្ចារ្យ
ទន្លេសព្វទិសា រីងសោកាស្ងួតហួតហែង ។

១៦- ទ្រង់ជាម្ចាស់លើថ្ងៃ ឬយប់ក្ដីគ្រប់កន្លែង
ព្រះច័ន្ទនិងសូរ្យសែង ព្រះអង្គតែងដាក់បញ្ជា ។
១៧- ព្រះអង្គបានកំណត់ ជាប្រាកដដែនពសុធា
មានរដូវរងា ដាច់ពីគ្នាប្រាំវស្សា ។
១៨- ឱព្រះដ៏ត្រូចង់ សូមព្រះអង្គកុំភ្លេចថា
សាសន៍ល្ងីល្ងើនោះណា ជេរផ្ដន្ទានាមព្រះអង្គ ។
១៩- កុំប្រគល់ជីវិត រាស្ត្រកម្សត់របស់ទ្រង់
ទៅក្នុងដៃពួកខ្លាំង បែរប្រឆាំនឹងទ្រង់ឡើយ ។
២០- សូមនឹងដល់សម្ពន្ធ ច្រើនជំនាន់យូរមកហើយ
រាស្ត្រភ័យព្រួយឥតស្បើយ ពាលនៅឡើយពាសពេញស្រុក ។
២១- សូមឲ្យពួកអស់អ្នក ធ្លាប់លំបាកឈប់កើតទុក្ខ
អ្នកក្រខ្សត់បានសុខ តទៅមុខថ្កើងព្រះអង្គ ។
២២-ឱព្រះជាម្ចាស់អើយ កុំកន្តើយការពារផង
ព្រះនាមល្អឥតហ្មង ពួកល្ងើល្ងង់ជេរខ្លាំងណាស់ ។
២៣- កុំភ្លេចសូរសម្រែក សត្រូវជ្រែកនឹងព្រះម្ចាស់
គេស្រែកអឺងកងណាស់ ទាស់ព្រះម្ចាស់ឥតឈប់ឡើយ ។

## ទំនុកតម្កើងលេខ ៧៥ (៧៤) បទកាកគតិ

២- ឱព្រះអម្ចាស់ យើងសូមប្រកាស សរសើរតម្កើង ព្រះនាមព្រះអង្គ
ដែលគង់ជិតយើង ស្នាព្រះហស្តថ្កើង ដែលខ្ញុំរៀបរាប់ ។
៣- ទ្រង់បន្ទូលថា នេះគឺវេលា ដែលកំណត់ស្រាប់ យើងវិនិច្ឆ័យ
ឲ្យបានសព្វគ្រប់ ទាំងថ្ងៃទាំងយប់ យុត្តិធម៌ក្រៃណា ។
៤- ដែនដីសត្វលោក រស់នៅគរគោក លើដែនពសុធា នឹងត្រូវរលាយ
ប៉ុន្តែយើងជា អ្នកធ្វើឲ្យវា រឹងមាំមិនស្រុត ។
៥- យើងធ្លាប់និយាយ ប្រាប់ជារឿយៗ ពួកមានអំនួត ថាកុំបំប៉ោង
កុំអាងកុំអួត វាយឫកហួសមាឌ គ្មានប្រយោជន៍ទេ ។

៦- កុំធ្វើឫពេក ខ្ពង់ខ្ពស់កប់មេឃ ងាកមើលឯងគេ ពោលពាក្យព្រហើន
កោងកាចជ្រៀលជ្រេរ ឥតប្រយោជន៍ទេ ល្មមឈប់ពោលហើយ ។
៧- អ្នកដែលវិនិច្ឆ័យ កាត់សព្វសេចក្ដី មិនមកពីឆ្ងាយ ឬពីលិចកើត
ត្បូងជើងនាយអាយ នៅរាល់តែថ្ងៃ ជិតៗយើងដែរ ។
៨- គឺព្រះអម្ចាស់ ទើបទ្រង់ជ្រាបច្បាស់ ឥតមានគេចកែ ជាអ្នកវិនិច្ឆ័យ
ឥតមានវៀចវេរ អ្នកនេះអាចកែ អ្នកនោះអាចដោះ ។
៩- ទ្រង់កាន់ពែងទុក នឹងចាក់សម្រុក ពិរោធទាំងអស់ ទៅលើផែនដី
នោះពួកអាក្រក់ នឹងទទួលទោស ចៀសមិនផុតឡើយ ។
១០- រីឯខ្ញុំវិញ ឥតមានទោម្នេញ មិននៅកន្តើយ ប្រកាសព្រះនាម
មិនឈប់ឈរឡើយ រហូតទៅអើយ តម្កើងព្រះអង្គ ។
១១- ទ្រង់នឹងបំបាក់ អំនួតពួកអ្នក ពាលាយង់ឃ្នង តែព្រះអង្គលើក
អ្នកសុចរិតឡើង ខ្ពង់ខ្ពស់ថ្កុំថ្កើង ជានិច្ចរៀងទៅ ។

**ទំនុកតម្កើងលេខ ៧៦ (៧៥)** **បទពាក្យ ៧**

២- ព្រះម្ចាស់សម្តែងឲ្យគេស្គាល់ រូបព្រះអង្គផ្ទាល់នៅយូដា
នៅអ៊ីស្រាអែលល្បីអស្ចារ្យ ព្រះនាមនេះណាឮឆ្ងាយក្រៃ ។
៣- ព្រះពន្លាជ័យល្អប៉ប្រិម យេរូសាឡឹមក្រុងល្បាញល្បី
ដំណាក់ព្រះអង្គដ៏ប្រិមប្រិយ៍ ស្ថិតនៅលើដីក្រុងស៊ីយ៉ូន ។
៤- គឺទីនោះហើយទ្រង់សម្រេច ព្រះអង្គកម្ទេចឲ្យម៉ត់សូន្យ
គ្រឿងសស្ត្រាវុធច្រើនរាប់ផ្លូន ធ្នូដាវមាំមួនកប់ក្នុងដី ។
៥- បពិត្រព្រះម្ចាស់ដ៏ឧត្តម ព្រះអង្គជិតជុំដោយសិរី
រុងរឿងចិញ្ចែងចិញ្ចាចក្រៃ ពេលត្រឡប់វិលមកពីភ្នំ ។
៦- ទ្រង់ដកអាវុធពីអ្នកច្បាំង គេហេវហត់ខ្លាំងស្ទើររលំ
ទាហានពូកែដេកសំងំ មិនមកជួបជុំលែងប្រយុទ្ធ ។
៧- ឱព្រះនៃលោកយ៉ាកុបអើយ ទ្រង់គំរាមហើយគេតក់ស្លុត
រទេះចម្បាំងគាំងរហូត សេះដើរមិនរួចលែងអង់អាច ។

៨- បពិត្រព្រះអង្គគួរស្ញប់ស្ញែង    បារមីសម្ដែងដោយអំណាច
ពេលទ្រង់ពិរោធគួរឲ្យខ្លាច    តើនរណាអាចឈរនៅបាន ៕
៩- បន្ទូលព្រះអង្គកាត់ជម្រះ    ពីលើមេឃច្បាស់មិនរំខាន
លើដែនដីស្ងាត់ដូចស្មសាន    មនុស្សម្នាគ្រប់ប្រាណខ្លាចបារមី ៕
១០- នៅពេលព្រះអង្គយាងក្រោកឡើង    វិនិច្ឆ័យមិនឆ្មើងមនុស្សលោកីយ៍
សង្គ្រោះអ្នកទន់ទាបក្រក្រី    នៅលើដែនដីមិនឲ្យសល់ ៕
១១- ទ្រង់ធ្វើឲ្យកំហឹងមនុស្ស    ដែលធ្លាប់ពោរពុះក្ដៅក្រហល់
បែរទៅតម្កើងថ្កើងវិបុល    រុងរឿងមង្គលព្រះខ្ពង់ខ្ពស់ ៕
អស់អ្នកដែលសេសសល់ជីវិត    ពីសង្គ្រាមពិតមិនជ្រុលហួស
នាំគ្នាឱនកាយថ្វាយចំពោះ    ព្រះដែលសង្គ្រោះជីវិតយើង ៕
១២- អស់អ្នកនៅជិតជុំវៀងអាយ    កុំបីរាយមាយមកឆាប់ឡើង
ចូរយកតង្វាយថ្វាយព្រះយើង    ជាព្រះថ្កុំថ្កើងគួរស្ញែងខ្លាច ៕
១៣- ព្រះអង្គបំបាក់ស្ដេចនានា    ធ្វើឲ្យក្សត្រាបាត់អំណាច
ភិតភ័យតក់ស្លុតលែងអង់អាច    ស្ញប់ស្ញែងខ្លបខ្លាចព្រះបារមី ៕

## ទំនុកតម្កើងលេខ ៧៧ (៧៦) បទកាកគតិ

២- ខ្ញុំស្រែកហៅរក    ព្រះម្ចាស់យាងមក    ខ្ញុំអង្វរទ្រង់    ព្រះអង្គផ្ទៀងស្ដាប់
ឥតមានបង្អង់    ខ្ញុំស្រែកហៅផង    ព្រះអង្គសណ្ដាប់ ៕
៣- ថ្ងៃមានអាសន្ន    ខ្ញុំខំបែរបន់    ឲ្យទ្រង់មកឆាប់    នាពេលសន្ធិយា
ខ្ញុំចង់ប្រញាប់    អង្វរឥតឈប់    ស្រែករកព្រះជួយ ៕
៤- នឹកដល់ព្រះម្ចាស់    ចិត្តខ្លោចផ្សាណាស់    ស្រែកយំភ័យព្រួយ    ពេលរំពឹងគិត
ស្ទើរតែរលួយ    ទឹកចិត្តរញ្ជួយ    ហេវហត់ក្រៀមក្រោះ ៕
៥- ឱព្រះម្ចាស់អើយ    ព្រះអង្គធ្វើឲ្យ    ខ្ញុំហត់ហេវខ្សោះ    ដេកក៏មិនលក់
គំនិតខ្ចីអស់    គិតមិនចេញសោះ    និយាយមិនបាន ៕
៦- ខ្ញុំតែងសញ្ជឹង    នឹកគិតរំពឹង    សព្វរឿងប៉ុន្មាន    ពីអតីតៈ
ពីញាតិសន្តាន    តាំងពីបុរាណ    ដើមដីយូរលង់ ៕

៧- មិនឆ្ងាយមិនឆ្ងះ គិតឡើងគិតចុះ ខ្ញុំនៅតែល្ងង់ អស់ពេញមួយយប់

មិនឃើញដើមចុង ក្នុងចិត្តតែងប្រុង ព្រោះចង់យល់ថា ។

៨- តើព្រះអម្ចាស់ បោះបោលស្រឡះ យើងឬយ៉ាងណា ឬក៏ព្រះអង្គ

មិនគាប់ចិន្តា ផ្ដាច់ធម៌មេត្តា ពីយើងធ្វើហី ។

៩- ហេតុអ្វីព្រះម្ចាស់ ភ្លេចព្រះទ័យព្រះ គង់នៅមិនស្ដី តើព្រះអង្គឈប់

មេត្តាប្រណី នៅស្ងៀមលែងស្ដី រហូតតែម្ដង ។

១០- ម្ដេចក៏ព្រះអង្គ ភ្លេចបាត់សូន្យឈឹង សូមមេត្តាផង ទ្រង់ធ្លាប់ប្រណី

សន្ដោសឥតហ្មង ឬក៏ព្រះអង្គ ទ្រង់ព្រះពិរោធ ។

១១- ខ្ញុំនឹកគិតថា នឹងរងវេទនា ទណ្ឌកម្មឧក្រិដ្ឋ មកពីព្រះម្ចាស់

ទ្រង់លែងអាណិត បារមីទ្រង់ឫទ្ធិ លែងជួយយើងហើយ ។

១២- បពិត្រព្រះម្ចាស់ ខ្ញុំរំឭកច្បាស់ មិនប្រហែសឡើយ ខ្ញុំនឹកដល់ការ

អស្ចារ្យទាំងឡាយ ដែលទ្រង់ត្រួសត្រាយ ធ្វើពីពេលមុន ។

១៣-ខ្ញុំរៀបរាប់ស្នា ព្រះហស្ដថ្លៃថ្លា ច្រើនក្រៃលើសលន់ ខ្ញុំនឹករំពឹង

សង្ឃឹមពេកពន់ កិច្ចការគ្រាមុន មានច្រើនអនេក ។

១៤- បពិត្រព្រះម្ចាស់ មាគ៌ាត្រចះ វិសុទ្ធពន់ពេក កិច្ចការទាំងអស់

វិសេសល្អឯក គ្មានព្រះណាអាច ធ្វើដូចទ្រង់ឡើយ ។

១៥- មានតែព្រះអង្គ បារមីត្រចង់ ទ្រង់មិនកន្ដើយ សព្វការអស្ចារ្យ

ប្រព្រឹត្តរួចហើយ សម្ដែងឫទ្ធិឲ្យ សាសន៍ដទៃបានយល់ ។

១៦- ព្រះអង្គប្រើឫទ្ធិ បារមីបំផុត ឥតមានខ្វាយខ្វល់ លោះប្រជារាស្ត្រ

ផុតអស់អំពល់ អ្នកក្រអស់ខ្វល់ ផុតទុក្ខទាំងពួង ។

គេជាកូនចៅ សន្ដានញាតិដៅ លោកយ៉ាកុបផង ទាំងលោកយ៉ូសែប

ផុតអស់សៅហ្មង រួចពីចំណង ពីស្រុកអេស៊ីប ។

១៧- សមុទ្រគ្រាំគ្រេង ក៏ចេះកោតក្រែង ឫទ្ធានុភាព ទោះបាតសមុទ្រ

ក៏គង់តែជ្រាប រញ្ជួយញ័រញាប់ ខ្លបខ្លាចឫទ្ធា ។

១៨- ភ្លៀងធ្លាក់ជោគជាំ គគ្រឹកគគ្រាំ ផ្គរលាន់ខ្ញុំរខ្ញារ រន្ទះព្រះអង្គ

ភ្លឺផ្លេកមហិមា ពេញផ្ទៃមេឃា ដោយសារបារមី ។

១៩- ពេលឮសំឡេង ផ្គរលាន់ក្តែងៗ ខ្ទ័រខ្ទារផែនដី មានផ្លេកបន្ទោរ
ចែងចាំងរស្មី ធ្វើឲ្យផែនដី ញាប់ញ័ររញ្ជួយ ។
២០- ព្រះអង្គយាងកាត់ តាមបាតសមុទ្រ លឿនស្លេវបោះពួយ ទ្រង់យាងកាត់ទឹក
ឥតភិតភ័យព្រួយ គ្មានអ្នកណាមួយ រកទ្រង់ឃើញឡើយ ។
២១- ព្រះអង្គិរះរេ ឲ្យលោកម៉ូសេ ពិចារណាហើយ ទាំងលោកអារ៉ុន
ក៏មិនកន្តើយ ណែនាំកៀកកើយ ដូចគង្វាលចៀម ។

## ទំនុកតម្កើងលេខ ៧៨ (៧៧) — បទព្រហ្មគីតិ

១- ឱ! ប្រជាជនអើយ ខ្ញុំនេះហើយប្រៀនប្រដៅ
ផ្ទៀងត្រចៀកស្តាប់ទៅ ហើយអ្នកត្រូវប្រុងប្រៀបប្រាណ ។
២- ខ្ញុំរៀបរាប់ប្រវត្តិ តាមកំណត់មិនខកខាន
ប្រជាជនគ្រប់ប្រាណ ជាមេរៀនឲ្យបានដឹង ។
៣- យើងបានឮគេប្រាប់ ឲ្យយើងស្តាប់ជាដំណឹង
ជូនតាលោកខំប្រឹង តំណាលរឿងគ្រប់ទាំងអស់ ។
៤- តំណាលពីឫទ្ធា នុភាពជាស្នាព្រះហស្ត
អស្ចារ្យគ្មានចន្លោះ ល្អឥតខ្ចោះទ្រង់ប្រព្រឹត្ត ។
យើងនឹងនិយាយប្រាប់ កូនចៅស្តាប់តទៅពិត
កូនចៅត្រូវរិះគិត មានគំនិតយល់មិនខាន ។
៥- ព្រះអង្គបានតាក់តែង ច្បាប់សម្តែងដល់សន្តាន
លោកយ៉ាកុបស្តាប់បាន ទាំងប្រទានព្រះវិន័យ ។
ឲ្យពូជអ៊ីស្រាអែល កូនចៅដែលកើតមកក្រោយ
ព្រះអង្គបង្គាប់ឲ្យ កូនចៅក្រោយរៀនពីគេ ។
៦- ឲ្យកូនជាន់ក្រោយស្គាល់ ព្រះអង្គផ្ទាល់កុំងាករេ
កូនចៅកើតហូរហែ បង្រៀនគេតរហូត ។
៧- ឲ្យគេផ្ញើជីវិត ព្រះស្នេហ៍ស្និទ្ធមិនភរភូត
គោរពតាមបែបបទ ចាំឲ្យស្ទាត់ស្នាព្រះហស្ត ។

៨- កុំឲ្យប្រជាជន ចិត្តទោរទន់ប្រព្រឹត្តហួស
ដូចដូនតាទាំងនោះ ចិត្តរឹងរូសប៉ងប្រឆាំង ។
គំនិតវៀចវេរល្វៀង ចិត្តមិនទៀងមិនស្មោះត្រង់
នាំគ្នាក្បត់ព្រះអង្គ មិនទៀងត្រង់សោះឡើយណា ។
៩- កងទ័ពអេប្រាអ៊ីម ត្រូវនៅស្ងៀមលែងវាចា
បាក់ទ័ពញ៉័រកាយា ថ្ងៃនោះណាឈប់ចេញច្បាំង ។
១០- ពួកគេពុំគោរព ទៅតាមច្បាប់នៃព្រះអង្គ
មិនព្រមកាន់តាមផង វិន័យទ្រង់ល្អបរិសុទ្ធ ។
១១- គេភ្លេចស្នាព្រះហស្ត ព្រះម្ចាស់ខ្ពស់ខ្ពង់បំផុត
ឫទ្ធិអស្ចារ្យមោះមុត ព្រះវិសុទ្ធទ្រង់សម្ដែង ។
១២- នៅតំបន់សូអាន អេស៊ីបបានកោតស្ញប់ស្ញែង
ការអស្ចារ្យក្រៃលែង ទ្រង់សម្ដែងឲ្យគេយល់ ។
១៣- ទ្រង់ញែកទឹកសមុទ្រ គេឆ្លងផុតឥតខ្វាយខ្វល់
ឲ្យទឹកជុំនឹងថ្កល់ ដូចកំណល់កល់កំពែង ។
១៤- ពេលថ្ងៃទ្រង់ដឹកនាំ ដោយមានដុំពពកផ្សែង
ពេលយប់ព្រះអង្គតែង នាំសូរ្យសែងពន្លឺល្អ ។
១៥- ក្នុងវាលរហោស្ថាន ព្រះអង្គបានបំបែកថ្ម
ឲ្យទឹកហូរឈូឆរ រាស្ត្រអបអរអ្វីម្ល៉េះទេ ។
១៦- ទឹកហូរចេញពីថ្ម ធ្លាក់ឈូរឆដូចទន្លេ
បរិបូរមិនខ្វះទេ ដូចទន្លេទឹកច្រើនពិត ។
១៧- ទោះជាទ្រង់ធ្វើត្រូវ ពួកគេនៅតែប្រព្រឹត្ត
អំពើបាបទុច្ចរិត ដោយប្រព្រឹត្តទាស់ព្រះទ័យ ។
នៅវាលរហោស្ថាន ដូនតាបានគិតរំពៃ
ប្រឆាំងព្រះម្ចាស់ថ្លៃ មានបារមីឥតអ្វីប្រៀប ។
១៨- ពួកគេសម្រេចចិត្ត ល្បងឥតគិតអានុភាព
ទាមទារជាដរាប ឲ្យទ្រង់រៀបចំអាហារ ។

១៩- គេមានចិត្តសង្ស័យ លើម្ចាស់ថ្លៃយ៉ាងឫស្យា
ដោយពោលពាក្យវាចា ឲ្យក្បត្រាជប់លៀងគេ ។
២០- ព្រះអង្គអាចវាយថ្ម ទឹកឈូឆរដូចទន្លេ
តើព្រះអង្គអាចទេ ឲ្យសាច់គេនិងអាហារ ។
២១- ព្រះម្ចាស់ពិរោធក្រៃ ឮគេស្តីពាក្យមុសា
ទ្រង់ខឹងញ័រកាយា ពូជអ៊ីស្រាអែលយ៉ាកុប ។
២២-ព្រោះពួកគេពុំបាន ផ្ញើរខ្លួនប្រាណជ្រកក្រោមម្លប់
គេគ្មានជំនឿស៊ប់ លើទ្រង់គ្រប់វេលាឡើយ ។
២៣-ទោះជាយ៉ាងណាក្តី ទ្រង់ប្រណីអត់ទោសឲ្យ
បញ្ជាមិនថ្លោះធ្លោយ ពពកឲ្យបើកផ្ទៃមេឃ ។
២៤- ហើយប្រទានអាហារ នំម៉ាណ្ណាច្រើនក្រៃពេក
ធ្លាក់មកពីលើមេឃ ព្រះអង្គចែកពីសួគ៌ា ។
២៥- ពួកគេបរិភោគ អាហារយកពីទេវតា
ទ្រង់ប្រទានអាហារ គ្រប់អាត្មាឆ្អែតស្កប់ស្កល់ ។
២៦- ឯផ្ទៃមេឃខាងលើ ព្រះអង្គធ្វើឲ្យមានខ្យល់
បោកបាចបក់វិលវល់ ឥតមានសល់ពីកើតត្បូង
២៧-ទ្រង់ប្រទានសត្វស្លាប ហើរផ្ទៃលឆាបច្រើនទាំងហ្វូង
ទាំងសាច់សត្វទៀតផង ច្រើនកន្លងឥតគណនា ។
២៨- សាច់សត្វទាំងអស់នោះ បានធ្លាក់ចុះពីមេឃា
ចំកណ្តាលទីធ្លា ទីនានាដែលគេស្នាក់ ។
២៩- គេអាស្រ័យឆ្អែតឆ្អល់ បានស្កប់ស្កល់គ្មានសល់ម្នាក់
ព្រះជាម្ចាស់ថ្នមថ្នាក់ តាមចិត្តអ្នកប៉ងប្រាថ្នា ។
៣០- ប៉ុន្តែទោះគេមាន អាហារណែនមាត់យ៉ាងណា
ក៏ពួកជនសាវា មិនព្រមថាគេគ្រប់អី ។
៣១- ពេលនោះព្រះម្ចាស់ក្រោធ ទ្រង់គ្រវាត់លែងប្រណី
ប្រហារអ្នកខ្លាំងក្រៃ ទាំងយុវវ័យពេញកម្លាំង ។

៣២- ទោះបីយ៉ាងនេះក្តី ជនអប្រិយ៍នៅតែរឹង
ពុំព្រមជឿព្រះអង្គ មិនលះបង់ធ្វើព្រៃផ្សៃ
៣៣- ព្រះអង្គក៏ប្រហារ ផ្តាច់សង្ខារជនអប្រិយ៍
តែក្នុងពេលដ៏ខ្លី ពួកគេក្ស័យសែនវេទនា ។
៣៤- ពេលគេឃើញដូច្នេះ គេវេរិះឈប់រួញរា
ប្រែចិត្តគំនិតជា នាំគ្នីគ្នារកព្រះអង្គ ។
៣៥- ពួកគេនឹកឃើញថា អង្គក្សត្រាមិនបោះបង់
ជាថ្មដាបិទបាំង ការពារពាំងមាំមួនណាស់ ។
៣៦- ប៉ុន្តែតាមការពិត គេមានចិត្តចង់បោកប្រាស
និយាយពាក្យផ្តេសផ្តាស ឃើញជាក់ច្បាស់ពាក្យកុហក ។
៣៧- គេមានចិត្តវៀចវេរ មិនទៀងទេសែនអាក្រក់
គេភូតភរកុហក ក្បត់នឹងសម្ពន្ធមេត្រី ។
៣៨- រីឯព្រះអង្គវិញ ទ្រង់បញ្ចេញព្រះហឫទ័យ
មេត្តាករុណាក្រៃ លើកទោសពៃរ៍ដោយយល់យោគ ។
៣៩- ព្រះអង្គនៅចាំថា គ្រប់អាត្មាជាមនុស្សលោក
ជីវិតសែនសោយសោក ដូចខ្យល់បោកមិនត្រឡប់ ។
៤០- ពួកគេតែងប្រឆាំង នឹងព្រះអង្គឥតឈរឈប់
ឲ្យទ្រង់ព្រួយសព្វគ្រប់ នឹងទីភពវាលហួតហែង ។
៤១- ពួកគេនៅតែល្បួង ជាច្រើនដងឥតកោតក្រែង
ធ្វើឲ្យទ្រង់ចំបែង មិនរអែងព្រះចេស្តា ។
៤២- ពួកគេពុំបានគិត អំពីឫទ្ធាខ្លាំងក្លា
គេមិននឹកចាំថា ទ្រង់នេះណារំដោះគេ ។
៤៣- ពួកគេពុំនឹងដល់ ទីសម្គាល់អស្ចារ្យទេ
ដែលទ្រង់គិតគ្នាន់គ្នេរ នៅអេស៊ីបក្រុងសូអាន ។
៤៤- ឲ្យទឹកទន្លេនីល ប្រែឥតសល់ជាឈាមបាន
ជាតិអេស៊ីបគ្រប់ប្រាណ ព្រួយឥតស្រាន្តព្រោះគ្មានទឹក ។

៤៥- ទ្រង់បាត់កង្កែបមូស ឲ្យហើរចុះច្រើនសន្ធឹក
បំផ្លាញទាំងល្ងាចព្រឹក អេស៊ីបនឹកសែនភ័យព្រួយ ។
៤៦- មានកណ្តូបចង្រិត ទាំងឆ្ងាយជិតច្រើនរញ្ជួយ
ស៊ីបង្ហិនអស់ត្រួយ គ្មានសល់មួយផលដំណាំ ។
៤៧- ព្រមទាំងមានព្រឹលធ្លាក់ សែនត្រជាក់ជាប្រចាំ
បំផ្លាញឲ្យខ្ទេចខ្ទាំ ផលដំណាំខូចរេចរិល ។
៤៨- ហ្វូងគោត្រូវវិនាស មិនអាចចៀសដោយសារព្រឹល
ហ្វូងចៀមងាប់គ្មានសល់ ដោយសារខ្យល់និងរន្ទះ ។
៤៩- ព្រះម្ចាស់ទ្រង់ពិរោធ ទ្រង់ខ្ញាល់ក្រោធខឹងខ្លាំងណាស់
ជនជាតិអេស៊ីបច្បាស់ ជួបប្រទះក្តីអន្តរាយ ។
៥០- ទ្រង់ធ្វើតាមព្រះទ័យ គ្មានប្រណីជាតិនោះឡើយ
ព្រះអង្គបានធ្វើឲ្យ គ្រោះអន្តរាយកើតមានឡើង
៥១- ព្រះអង្គបានប្រហារ យកសង្ខារអស់កូនច្បង
ជាតិអេស៊ីបនេះផង ក្នុងពូជពង្សអេប្រាហាំ ។
៥២- ព្រះអង្គនាំប្រជា រូតម្ទឹម្ទាមិនរង់ចាំ
ដោយទ្រង់មើលថែឃ្លាំ ហើយដឹកនាំទៅរហោស្ថាន ។
៥៣- ព្រះអង្គដឹកនាំគេ មិនរារេដោយសុខសាន្ត
ឯសត្រូវសាមាន្យ ត្រូវលង់ប្រាណក្នុងសមុទ្រ ។
៥៤- ព្រះអង្គនាំពួកគេ ទៅកាន់ទីដ៏វិសុទ្ធ
ដូចគង្វាលចាំសត្វ ដើរឆ្លងកាត់វាលស្មៅខ្ចី ។
៥៥- ព្រះអង្គបានបណ្តេញ ជាតិដទៃចេញមិនប្រណី
ហើយទ្រង់ចែកទឹកដី ដ៏ថ្លាថ្លៃដល់ស្រាអែល ។
៥៦- ប៉ុន្តែពួកគេបាន ល្បងរំខានព្រះម្ចាស់ដែល
មានតេជះក្រាស់ក្រែល ដោយមិនធ្វើតាមបញ្ជា ។
៥៧- ពួកគេក្បត់ព្រះអង្គ មិនត្រាប់ត្រង់គ្រប់ៗគ្នា
ដូចដូនតាពួកគេ ចិត្តវៀចវេរដូចកណ្តៀវ ។

៥៨- គេបែរថ្វាយបង្គំ នៅលើភ្នំព្រះក្លែងក្លាយ
ដែលជាហេតុធ្វើឲ្យ ទាស់ព្រះហឫទ័យព្រះអង្គ ។
៥៩- ព្រះអង្គឃើញដូច្នេះ ទ្រង់ព្រះពិរោធយ៉ាងខ្លាំង
ហើយលែងរវល់នឹង ជាតិក្បាលរឹងអ៊ីស្រាអែល ។
៦០- ព្រះអង្គបានបង់បោះ មិនស្រណោះកន្លែងដែល
ជាដំណាក់នៅឯ ភូមិស៊ីឡូធ្លាប់អាស្រ័យ ។
៦១- ព្រះអង្គបណ្ដោយឲ្យ ខ្មាំងរាប់រយចិត្តអប្រិយ៍
យកហឹបសម្ពន្ធមេត្រី ជាបារមីនៃព្រះអង្គ ។
៦២- ហើយទ្រង់បណ្ដោយឲ្យ រាស្ត្រទន់ខ្សោយស្លាប់បាត់បង់
ដោយមុខដាវតម្រង់ សត្រូវប៉ងកាប់ប្រល័យ ។
៦៣- ឯយុវជនទាំងឡាយ ក៏អន្តរាយដោយក្សិណក្ស័យ
ក្នុងភ្លើងសង្គ្រាមជ័យ គ្មានសល់អ្វីនឹងរៀបការ ។
៦៤- មនុស្សស្មើរទាំងអស់ ជាពិសេសបូជាចារ្យ
ស្លាប់ដោយដាវប្រហារ គ្មានស្រីណាកាន់ទុក្ខបាន ។
៦៥- ពេលនោះទ្រង់តើនមក ដូចគេក្រោកពីសម្រាន្ត
ដូចអ្នកច្បាំងក្លាហាន ស្វាងស្រាកស្រាន្តពីសុរា ។
៦៦- ព្រះអង្គវាយសត្រូវ មិនឲ្យនៅសល់ឡើយណា
ពួកខ្មាំងគ្រប់អាត្មា បង់អសារជាដរាប ។
៦៧- ព្រះអង្គនៅតែខឹង នឹងពូជពង្សលោកយ៉ូសែប
ទ្រង់ក៏មិនជ្រើសបែប កុលសម្ពន្ធអេប្រាអ៊ីម ។
៦៨- ទ្រង់ពេញព្រះហឫទ័យ ពន់ពេកក្រៃយូដាវិញ
គាប់ចិត្តឥតទោម្នេញ ស៊ីយ៉ូនវិញភ្នំវិសុទ្ធ ។
៦៩- ទ្រង់សង់សក្ការៈ ល្អឥតអាក់ខ្ពស់បំផុត
ដូចមេឃរឹងមោះមុត ឥតជុងទ្រុឌដូចផែនដី ។
៧០- ដាវីឌដ៏ល្អឯក ទ្រង់ជ្រើសញែកជាទាសី
អ្នកបម្រើប្រពៃ យកស្ដេចថ្លៃពីឃ្វាលចៀម ។

៧១- ទ្រង់បានដកយកចេញ មិនទៅម្ដេញនៅទីមទាម
ឃ្វាលពូជយ៉ាកុបភ្លាម គឺជាតិនាមអ៊ីស្រាអែល ។
៧២-ស្ដេចដាវីឌដឹកនាំ យាតីរឹងមាំមិនអែកអល់
ស្មោះត្រង់គ្មានកិច្ចកល នាំគេដល់ត្រើយសុខសាន្ត ។

**ទំនុកតម្កើងលេខ ៧៩ (៧៨)** **បទពាក្យ ៧**

១- បពិត្រព្រះជាអម្ចាស់អើយ ជនជាតិទាំងឡាយចូលឈ្លានពាន
វិហារវិសុទ្ធត្រូវរុករាន សាឡឹមថ្កើងថ្កានខូចខ្ទេចខ្ទីរ ។
២- សាកសពអ្នកបម្រើព្រះអង្គ ត្រូវគេបោះបង់ឲ្យសត្វស៊ី
សាកសពអ្នកជឿពេញធរណី ត្រូវតិរច្ឆានស៊ីជាអាហារ ។
៣- គេបានសម្លាប់ប្រជាជន ជុំវិញទីក្រុងគ្មានមេត្តា
ឈាមរាស្ត្រហូរក្រាលពសុធា ចាស់ក្មេងមរណាគ្មានអ្នកកប់ ។
៤- អ្នកស្រុកជិតខាងនាំគ្នាជេរ ប្រមាថឥតល្ហែគេលែងរាប់
គេសើចចំអកឡកឡឺយសព្វ រូបខ្ញុំគេស្អប់គេមើលងាយ ។
៥- ឱ! ព្រះជាម្ចាស់ទូលបង្គំ ម្ដេចទ្រង់សំងំដូចជិនណាយ
តើថ្ងៃណាទៅទើបទ្រង់ស្រាយ ពិរោធឲ្យឆ្ងាយមកស្រោចស្រង់ ។
៦- សូមជះក្ដីក្រោធលើជាតិផ្សេង ឲ្យជនវង្វេងស្គាល់ព្រះអង្គ
និងនគរនានានោះផង ដែលមិនស្មោះត្រង់នឹងព្រះម្ចាស់ ។
៧- ដ្បិតពួកគេបានកាប់សម្លាប់ ពូជលោកយ៉ាកុបចោលទាំងអស់
បំផ្លាញទឹកដីជារបស់ មរតកកេរកោះលោកទៀតផង ។
៨- សូមកុំចាប់ទោសយកកំហុស ព្រោះបុព្វបុរសខ្ញុំខុសឆ្គង
មេត្តាលើកទោសកំហុសម្ដង អាណិតខ្ញុំផងដ្បិតលិចលង់ ។
៩- ឱព្រះជាម្ចាស់ព្រះសង្គ្រោះ សូមទ្រង់យាងចុះកុំបង្អង់
ដោយយល់សិរីដ៏រុងរឿង មេត្តាព្រះអង្គជួយផងណា ។
១០- ហេតុអ្វីបានជាទ្រង់បណ្ដោយ ជាតិផ្សេងៗឲ្យមកពោលថា
« តើព្រះគេនោះនៅឯណា សូមទ្រង់មេត្តាដាក់ទោសចុះ ។

១១- សូមស្តាប់សំឡេងឈ្លើយថ្ងូរថ្ងូច លាន់ឮគ្រលួចគួរស្រណោះ
សូមប្រើបារមីជួយរំដោះ អ្នកដែលមានទោសដល់មរណា ។
១២- សូមព្រះជាម្ចាស់កុំអាណិត ប្រជាជាតិជិតទាំងអស់គ្នា
ធ្វើឲ្យគេរស់ដោយវេទនា អាប់មុខមួយជាប្រាំពីរដង ។
១៣- ឯពួកយើងខ្ញុំដែលជារាស្ត្រ ដូចចៀមទាំងអស់របស់ទ្រង់
នាំគ្នាតម្កើងលើកព្រះអង្គ អស់កល្បយូរលង់អង្វែងទៅ ។

## ទំនុកតម្កើងលេខ ៨០ (៧៩) បទព្រហ្មគីតិ

២- ព្រះម្ចាស់ជាគង្វាល អ៊ីស្រាអែលសូមសណ្តាប់
ពូជពង្សលោកយ៉ូសែប ដែលព្រះអង្គបានដឹកនាំ ។
ដូចជាអ្នកគង្វាល ចាំយាមឃ្វាលចៀមថែទាំ
គេរស់ដោយសុខដុម សូមសម្តែងព្រះបារមី ។
៣- ឲ្យពួកកុលសម្ពន្ធ អេប្រាអ៊ីមឃើញស្នាដៃ
និងជាតិផ្សេងៗក្តី សូមទ្រង់លៃជួយសង្គ្រោះ ។
៤- ឱ! ព្រះជាម្ចាស់អើយ កុំកន្តើយសូមសន្តោស
ទតមើលដោយសប្បុរស នោះយើងខ្ញុំរួចជីវិត ។
សូមទ្រង់បែរព្រះភក្ត្រ ញញឹមដាក់យើងខ្ញុំពិត
សង្គ្រោះឲ្យនៅជិត កុំឲ្យបែកបាក់ខ្ចាត់ខ្ចាយ ។
៥- បពិត្រព្រះជាម្ចាស់ ទ្រង់ជាព្រះគង់ខ្ពស់ឆ្ងាយ
ខ្ពស់ហួសព្រះទាំងឡាយ ម្តេចមិនស្រាយពិរោធចេញ ។
៦- ម្តេចទ្រង់មកដាក់ទោស បាច់កំហុសយើងទៅវិញ
ឲ្យទឹកភ្នែកហូរចេញ ដូចគង្គាមិនចេះចប់ ។
៧- ទ្រង់ធ្វើឲ្យប្រជា ជិតខាងគ្នាឈ្លោះសំអប់
ដណ្តើមមិនចេះស្កប់ យកទឹកដីរបស់យើង ។
៨- ឱ! ព្រះជាអម្ចាស់ សូមសង្គ្រោះយើងឆាប់ឡើង
សូមជួយនាំពួកយើង ឲ្យត្រឡប់វិលមកវិញ ។

| | | |
|---|---|---|
| ៩- ព្រះអង្គគាស់រំលើង | ដើមទំពាំងបាយជូរចេញ | |
| រួចហើយទ្រង់បណ្ដេញ | ជាតិជ្រែងចេញពីទឹកដី | ។ |
| ព្រះអង្គយកមកដាំ | ដើមទំពាំងបាយជូរថ្មី | |
| ត្រួយលាស់ស្លឹកខៀវខ្ចី | ល្អពេកក្រៃស្រស់បំព្រង | ។ |
| ១០- ព្រះអង្គបានភ្ជួរដី | ឲ្យដើមថ្មីចាក់ឫសផង | |
| ដុះពេញស្រុកតែម្ដង | ល្អកន្លងសែនសុខដុម | ។ |
| ១១- មែកវាផ្ដល់ជាម្លប់ | គ្របដណ្ដប់ទៅលើភ្នំ | |
| គ្របដើមគគីរធំ | នៅលើភ្នំខ្ពស់បំផុត | ។ |
| ១២- បែកមែកម្លប់សាខា | បែកលុះត្រាដល់សមុទ្រ | |
| ពន្លកលាស់ចេញផុត | រហូតទន្លេអឺប្រាត | ។ |
| ១៣- ហេតុអ្វីក៏ព្រះអង្គ | ផ្ដួលរបងដោយក្រេវក្រោធ | |
| មនុស្សម្នាដែលដើរកាត់ | បេះបោចបាត់ផ្លែជូរច្នេះ | ។ |
| ១៤- សត្វជ្រូកមកបំផ្លិច | បំផ្លាញខ្ទេចមិនឈប់សោះ | |
| បង្ហិនគ្រប់ទាំងអស់ | ដំណាំនោះវាស៊ីម៉ត់ | |
| ១៥- ឱ! ព្រះជាម្ចាស់អើយ | កុំកន្តើយសូមទ្រង់ទត | |
| ពីស្ថានសួគ៌ាមក | ជួយយើងខ្ញុំកុំខានឡើយ | ។ |
| ១៦- សូមទ្រង់ជួយរក្សា | ថែចំការដែលមានហើយ | |
| ការពារកុំបណ្ដោយ | ក្រែងថ្លោះធ្លោយខ្លាំងញ៉ាំញី | ។ |
| ១៧- សូមឲ្យពួកបច្ចា | ដែលកាប់ភ្ជួរចំការថ្មី | |
| វិនាសកុំសល់អី | ដោយព្រះអង្គទ្រង់គំរាម | ។ |
| ១៨- សូមទ្រង់ដាក់ព្រះហស្ដ | លើស្ដេចនោះគង់ខាងស្ដាំ | |
| បុត្រមនុស្សដ៏ឧត្ដម | ដែលព្រះអង្គពង្រឹងឡើង | ។ |
| ១៩- យើងខ្ញុំមិនបែកបែរ | ចិត្តងាកវេរពីព្រះអង្គ | |
| សូមប្រោសប្រទានផង | ឲ្យយើងខ្ញុំមានជីវិត | ។ |
| ពេលខ្ញុំរស់ឡើងវិញ | ចិត្តពោរពេញនៅនែបនិត្យ | |
| គោរពបម្រើពិត | ឥតមានក្បត់ឆ្ងាយពីទ្រង់ | ។ |

២០- ឱ! ព្រះជាម្ចាស់ខ្ញុំ សូមជួយនាំកុំវេរង់
វិលមករកព្រះអង្គ ឲ្យយើងខ្ញុំក្រាបបង្គំ ។
សូមបែរព្រះភក្ត្រមក ញញឹមរកពួកយើងខ្ញុំ
ដោយព្រះទ័យឧត្តម នោះយើងខ្ញុំរួចជីវិត ។

## ទំនុកតម្កើងលេខ ៨១ (៨០) បទកាកគតិ

២- នាំគ្នាពន្លឺ សំឡេងឲ្យឮ ថ្វាយព្រះជាម្ចាស់ ដែលជាកម្លាំង
នៃយើងទាំងអស់ សាទរដល់ព្រះ របស់យ៉ាកុប ។
៣- ចូរយើងប្រគុំ តន្ត្រីរងំ ឲ្យបានឆាប់ៗ ដេញពិណវាយស្គរ
ចាប៉ីវាយក្រាប់ ប្រគុំឲ្យជាប់ កុំបីបង្អង់ ។
៤- ផ្លុំស្នែងប្រកាស ពេលដាច់ខែចាស់ ចូលដល់ថ្មីម្តង ថ្ងៃពេញវង់
ល្អល្អះបំព្រង ពេញបូណ៌មីផង ថ្ងៃបុណ្យដំណែល ។
៥- ព្រោះជាក្បួនច្បាប់ វៀងមកដរាប នៅអ៊ីស្រាអែល តាមបទបញ្ជា
មាគ៌ាក្រាស់ក្រែល របស់ព្រះដែល ជាព្រះយ៉ាកុប ។
៦- នេះជាវិន័យ ព្រះអង្គលកលៃ ពេលទ្រង់បង្គាប់ មកដល់ពូជពង្ស
របស់យ៉ូសែប នៅស្រុកអេស៊ីប ហើយខ្ញុំឮថា ។
៧- យើងដកអម្រែក ដ៏ធ្ងន់អនេក ចេញពីលើស្មា ហើយក៏បានដក
ការធ្ងន់អស្ចារ្យ ចេញពីហត្ថា របស់អ្នកដែរ ។
៨- ពេលអ្នកមានទុក្ខ អ្នកបានស្រែករក យើងគ្មានពេលល្ហែ យើងក៏រំដោះ
មិននៅទំនេរ ហើយយើងរិះរេ ល្បងមើលចិត្តអ្នក ។
៩- ឱប្រជារាស្ត្រ នៃយើងទាំងអស់ ចូរស្តាប់ឲ្យជាក់ ពាក្យយើងរំលឹក
យើងដាស់តឿនអ្នក កុំបីអន់អាក់ ត្រូវត្រាប់លកលៃ ។
១០- ក្នុងចំណោមអ្នក កុំទៅស្មោះស្ម័គ្រ នឹងព្រះដទៃ កុំទៅគោរព
កោតខ្លាចធ្វើអ្វី ព្រោះព្រះដទៃ ជាព្រះក្លែងក្លាយ ។
១១- យើងជាព្រះម្ចាស់ មិនមែនជាព្រះ ក្លែងក្លាយនោះឡើយ យើងបានយកអ្នក
ពីអេស៊ីបហើយ កុំនៅកន្តើយ ទទួលពរយើង ។

១២-តែរាស្ត្រមិនស្តាប់ ពាក្យយើងបង្គាប់ គេធ្វើឫកឆ្មើង ទោះអ៊ីស្រាអែល
ក៏លែងស្គាល់យើង ធ្វើតាមទំនើង អំពើអាក្រក់ ។

១៣-ហេតុដូច្នេះហើយ ទើបយើងបណ្តោយ ឲ្យពួកគេធ្លាក់ យើងឲ្យគេធ្វើ
តាមចិត្តគម្រក់ ប្រព្រឹត្តអាក្រក់ តាមទំនើងចិត្ត ។

១៤- តែបើប្រជា រាស្ត្រទាំងអស់គ្នា គេប្តូរគំនិត ស្តាប់សំឡេងយើង
ហើយគេប្រព្រឹត្ត តាមមាគ៌ាពិត របស់យើងនោះ ។

១៥- នោះយើងមុខជា បង្ក្រាបបច្ចា ជាខ្មាំងទាំងអស់ ហើយយើងសម្លាប់
មិនឲ្យសល់សោះ សត្រូវទាំងអស់ តែមួយរំពេច ។

១៦- អស់អ្នកដែលធ្លាប់ ស្អប់ព្រះម្ចាស់ជាប់ គេឈប់រត់គេច នាំគ្នាមកចូល
ព្រះអង្គជានិច្ច តែទ្រង់មិនភ្លេច ដាក់ទោសគេឡើយ ។

១៧-ព្រះអម្ចាស់បាន ផ្តល់ស្រូវជាទាន យ៉ាងល្អមកឲ្យ ពួកអ៊ីស្រាអែល
បរិភោគរួចហើយ ទាំងប្រទានឲ្យ ទឹកឃ្មុំបរិបូណ៌ ។

## **ទំនុកតម្កើងលេខ ៨២ (៨១)** **បទពាក្យ ៧**

១- ព្រះម្ចាស់គង់ក្នុងអង្គប្រជុំ នៃស្ថានបរមសុខពេកក្រៃ
ទ្រង់តែងតែយាងមកកាត់ក្តី ក្នុងចំណោមនៃពួកទេវតា ។

២- ពេលណាទើបអ្នកឈប់កាត់ក្តី ដោយចិត្តអប្រិយ៍ដូច្នេះណា
ឲ្យមនុស្សអាក្រក់ចិត្តឫស្យា ឈ្នះគេដល់ណា ត ទៅទៀត ? ។

៣- ព្រះម្ចាស់មានព្រះបន្ទូលថា ចូររកយុត្តិធម៌កុំរវាត
ឲ្យអ្នកក្រីក្រខ្សត់គ្មានញាតិ កូនកំព្រាអត់មានឪម៉ែ ។

៤- ចូរកុំនៅស្ងៀមចេញរំដោះ អ្នកទន់ខ្សោយខ្សោះគ្មានអ្នកថែ
ឲ្យគ្នារួចខ្លួនបានល្ហើយល្ហែ ជនពាលតែងតែតាមធ្វើបាប ។

៥- តែគេមិនដឹងមិនយល់សោះ ចិត្តគេទុយ៌សជាដរាប
អំពើយុត្តិធម៌ក៏សូន្យសាប ដែលទុកសម្រាប់គ្រឹះផែនដី ។

៦- យើងនឹងប្រកាសថាអស់អ្នក រាល់គ្នាពិតជាក់ជាបុត្រី
បុត្រារបស់ម្ចាស់ផែនដី ជាព្រះស្តឹមស្តែដ៏ខ្ពង់ខ្ពស់ ។

៧- តែអ្នកត្រូវស្លាប់ដូចមនុស្សលោក ដែលដួលដេកស្ដូកពុំអាចរស់
ស្លាប់ដូចជាមនុស្សទូទាំងអស់ ដូចអ្នកធំខ្ពស់បាត់តំណែង ។
៨- ឱព្រះម្ចាស់អើយសូមតើនឡើង វិនិច្ឆ័យកុំឆ្មើងឫទ្ធិគួរស្ញែង
ដ្បិតមនុស្សគ្រប់ជាតិទាំងនោះឯង ជារាស្ត្រឥតក្លែងនៃព្រះអង្គ ។

## ទំនុកតម្កើងលេខ ៨៣ (៨២) បទកាកគតិ

២- ឱព្រះម្ចាស់អើយ សូមកុំកន្តើយ គង់ស្ងៀមស្ងាត់ឈឹង សូមទ្រង់មេត្តា
កុំធ្វើមិនដឹង ម្ដេចព្រងើយធ្មឹង យ៉ាងដូច្នេះណា ។
៣- សត្រូវព្រះអង្គ គ្រប់គ្នាកំពុង បង្កបញ្ហា នាំកោលាហល
គ្រប់ៗអាត្មា អ្នកស្អប់ក្បត្រា កំពុងបះបោរ ។
៤- ពួកគេរៀបចំ គម្រោងការធំ ប្រឆាំងឆោឡោ គេឃុបឃិតគ្នា
ប្រឆាំងបះបោរ រាស្ត្រក្នុងនគរ របស់ព្រះម្ចាស់ ។
៥- គេពោលឡើងថា « តោះយើងនាំគ្នា ប្រហារឲ្យអស់ កុំឲ្យមានសល់
ជនជាតិទាំងនោះ កុំឲ្យនឹកឈ្មោះ អ៊ីស្រាអែលទៀត» ។
៦- គេពិភាក្សា គំនិតរួមគ្នា ពីរឿងបោលម្សៀត ចុះសិទ្ធិសញ្ញា
ពីការបៀនបៀត នឹងព្រះម្ចាស់ទៀត រួមគ្នាប្រឆាំង ។
៧- មានជាតិអេដំ អ៊ីស្មាអែលព្រម ម៉ូអាប់អ្នកខ្លាំង ជានជាតិហាកា
រួមគ្នាតតាំង ចូលមកប្រឆាំង នឹងព្រះអម្ចាស់ ។
៨- ជនជាតិកេបាល អាំម៉ូនរាលដាល អាម៉ាឡេករូវះ ទាំងភីលីស្ទីន
ទីរ៉ុសស្នេកស្ដុះ ប្រឆាំងព្រះម្ចាស់ ពីគ្រប់ទិសទី ។
៩- នៅមានច្រើនទៀត សូម្បីជនជាតិ ពួកអាស្ស៊ីរី ក៏បានចូលរួម
កុះកររមូលមីរ ចូលដៃគ្រប់ទី លោកឡុតសាមាន្យ ។
១០- សូមព្រះអង្គធ្វើ ដូចប្រព្រឹត្តលើ ពួកម៉ាឌីយ៉ាន លោកស៊ីសេរ៉ា
ស្តេចទាំងប៉ុន្មាន និងស្ដេចយ៉ាប៊ីន ឯជ្រោះគីសូន ។
១១- ព្រះអង្គប្រហារ ឲ្យគេមរណា វិនាសទាំងកូន ដូចនៅអែនឌ័រ
សពទាំងប៉ុន្មាន រលួយម៉ត់សូន្យ ជាជីរទាំងអស់ ។

១២-សូមព្រះអង្គដាក់ ទោសគេម្នាក់ៗ ដូចបានដាក់ទោស ដល់ស្ដេចអូរីប
និងស្ដេចសីបនោះ ហើយកុំស្រណោះ ពួកណោះឡើយណា ។
ដាក់ទោសទាំងមេ កុំបីរិះរេ ដូចជាសេបា កុំឲ្យរួចខ្លួន
មួយសោះឡើយណា ដូចដាក់ទោសា សាល់ម៉ូណាដែរ ។
១៣-គេនិយាយថា « យើងនាំគ្នីគ្នា កុំនៅរិះរេ វាយដណ្ដើមដី
មកធ្វើជាកេរ ដីនោះគឺជា របស់ព្រះម្ចាស់ » ។
១៤- ឱព្រះខ្ញុំអើយ កុំអែអង់ឡើយ ឲ្យគេនិរាស ដូចជាធូលី
ខ្យល់បកបញ្ច្រាស់ ដូចចំបើងវាស វាត់បើងតាមខ្យល់ ។
១៥- ដូចភ្លើងវក់វី ឆេះម៉ត់ខ្មេចខ្ទី ដុតអស់គ្មានសល់ អណ្ដាតស្កឹមស្កែ
ភ្លើងព្រៃត្រូវខ្យល់ ឆេះអស់មិនសល់ វិនាសអសារ ។
១៦- សូមប្រើព្យុះខ្យល់ បក់បោកឲ្យដល់ ដេញតាមពួកវា ហើយសូមបន្ថែម
ទាំងព្យុះសង្ឃរា ធ្វើឲ្យពួកវា រន្ធត់ញ័រញាប់ ។
១៧-ព្រះអម្ចាស់អើយ មេត្តាធ្វើឲ្យ ពួកគេមុខអាប់ និងឲ្យគេស្វែង
នាមព្រះអង្គគាប់ ពួកគេមុខអាប់ រហូតតទៅ ។
១៨-សូមឲ្យពួកគេ បាក់មុខខ្មាសអែ វិនាសមិននៅ ងើបមុខមិនរួច
គ្មានញាតិពូជដៅ ឈ្មោះគេអាស្រូវ គ្មានញាតិគ្មានមិត្រ ។
១៩-ឲ្យគេស្គាល់ថា ព្រះអម្ចាស់ជា ព្រះគង់នៅជិត ព្រះខ្ពស់ឧត្ដុង្គ
ឧត្ដមបំផុត ប្រសើរពេកពិត លើភពផែនដី ។

## ទំនុកតម្កើងលេខ ៨៥ (៨៤) បទព្រហ្មគីតិ

២- ព្រះម្ចាស់លើពិភព ទូទាំងសព្វលើផែនដី
ខ្ញុំស្ម័គ្រពន់ពេកក្រៃ តំណាក់ថ្លៃព្រះអង្គណាស់ ។
៣- ខ្ញុំសែនអន្ទះសារ ចិត្តប្រាថ្នាយ៉ាងជាក់ច្បាស់
ចង់ចូលវិហារព្រះ ជាអម្ចាស់ទាំងចិត្តកាយ ។
ចិត្តចង់នៅជាមួយ ព្រះអង្គជួយមិនរសាយ
អស់ពីកម្លាំងកាយ មិនមានណាយរួមទាំងចិត្ត ។

៤- ត្របៀកកាំនិងចាប ជាដរាបវានៃបនិត្យ
សំបុកធ្វើនៅជិត អាសនៈពិតនៃព្រះអង្គ ។

៥- អស់អ្នកដែលបានស្នាក់ ក្នុងដំណាក់ដ៏ត្រចង់
មានសុខ មង្គលផង សរសើរច្រើងទ្រង់មិនឈប់ ។

៦- អ្នកណាដែលផ្អែកពឹង លើកម្លាំងព្រះជាម្លប់
ដ្បិតគេស្វែងមិនឈប់ ដំណាក់គាប់ដោយស្មោះសរ ។

៧- នៅពេលគេដើរកាត់ ជ្រោះរីងស្ងួតគ្មានទឹកហូរ
ព្រះអង្គប្រទានពរ ទឹកធ្លាក់ឆរគ្រប់កន្លែង ។

៨- គេខិតកាន់តែជិត ឥតភ័យភិតព្រួយចំបែង
មានកម្លាំងក្រៃលែង នឹកស្ងប់ស្ងែងគ្រប់អាត្មា ។
នៅចំពោះព្រះភក្ត្រ ព្រះអម្ចាស់ដ៏ថ្លៃថ្លា
លើភ្នំដ៏អស្ចារ្យ ឈ្មោះហៅថាភ្នំស៊ីយ៉ូន ។

៩- ឱ! ព្រះជាអម្ចាស់ មានតេជះខ្លាំងពេកពន់
ស្ដាប់ពាក្យទូលបង្គំ អង្វរសុំក្ដីករុណា ។
ព្រះលោកយ៉ាកុបអើយ កុំកន្តើយផ្ទៀងព្រះកាណ៌
សណ្ដាប់យើងខ្ញុំណា ដោយមេត្តាករុណាផង ។

១០- ឱ! ព្រះជាអម្ចាស់ ទតឲ្យច្បាស់កុំរំលង
មើលស្ដេចដែលឃុំគ្រង ជាខែលរងបាំងការពារ ។
សូមទ្រង់ព្រះសន្ដោស មេត្តាប្រោសព្រះរាជា
ដែលព្រះអង្គគាំពារ តែងតាំងងារដោយប្រេងជ័យ ។

១១- មួយថ្ងៃដែលនៅក្នុង វិហារទ្រង់សប្បាយក្រៃ
ជាងរស់មួយពាន់ថ្ងៃ នៅកន្លែងដទៃទៀត ។
ខ្ញុំបានសម្រេចចិត្ត ឈរនៅជិតមិនចង់ឃ្លាត
ជាជាងស្នាក់នៅបៀត លំនៅញាតិមនុស្សអាក្រក់ ។

១២- ព្រះជាម្ចាស់ដូចជា ខែលការពារប្រាកដជាក់
ជាពន្លឺភ្លឺច្បាស់ យើងម្នាក់ៗមានសិរី ។

| | | |
|---|---|---|
| ព្រះអង្គតែងតែផ្ដល់ | សុខមង្គលដល់ប្រុសស្រី | |
| រស់នៅដោយប្រពៃ | គ្មានទុក្ខភ័យផុតកង្វល់ | ។ |
| ១៣- ឱ! ព្រះជាអម្ចាស់ | មានតេជះលើសាកល | |
| អ្នកផ្ញើកាយមិនខ្វល់ | មានមង្គលសុខរហូត | ។ |

## ទំនុកតម្កើងលេខ ៨៥ (៨៤) បទកាកគតិ

| | | | | |
|---|---|---|---|---|
| ២- | បពិត្រព្រះម្ចាស់ | ព្រះអង្គគាប់ព្រះ | ទ័យនឹងទឹកដី | ទ្រង់បានដឹកនាំ |
| | ពូជពង្សប្រពៃ | យ៉ាកុបថ្លៃថ្លៃ | ឲ្យវិលមកវិញ | ។ |
| ៣- | ព្រះអង្គលើកទោស | អស់ប្រជារាស្ត្រ | ឥតមានទោម្នេញ | ឲ្យគេរួចបាប |
| | មកល្អជាវិញ | ចិត្តគេពោរពេញ | អំណរសប្បាយ | ។ |
| ៤- | ទ្រង់លែងពិរោធ | ឈប់ខ្ញាល់លែងក្រោធ | ដល់យើងទាំងឡាយ | ទ្រង់តែងមេត្តា |
| | យើងលែងខ្វល់ខ្វាយ | បានសុខសប្បាយ | ដោយសារព្រះអង្គ | ។ |
| ៥- | ព្រះម្ចាស់ឧត្តម | សង្គ្រោះថ្នាក់ថ្នម | បីបមត្រកង | សូមប្រោសឲ្យខ្ញុំ |
| | ត្រឡប់វិញផង | ហើយសូមព្រះអង្គ | កុំយកទោសា | ។ |
| ៦- | តើព្រះអង្គខ្ញាល់ | ពួកយើងនេះដល់ | រហូតពេលណា | ឬទ្រង់ពិរោធ |
| | រៀងរាល់វេលា | ឬក៏អស់ជា | អង្វែងតទៅ | ។ |
| ៧- | តើទ្រង់មិនបាន | យាងមកទីស្ថាន | ឲ្យខ្ញុំរស់នៅ | មានទាំងជីវិត |
| | សែនល្អពេកក្រៃ | ពីនេះតទៅ | អំណរសប្បាយ | ។ |
| ៨- | ឱ! ព្រះអម្ចាស់ | សូមសម្ដែងព្រះ | ហឫទ័យទូលាយ | មេត្តាករុណា |
| | អាសូរប្រណី | មកខ្ញុំរាល់ថ្ងៃ | សូមសង្គ្រោះផង | ។ |
| ៩- | យើងខ្ញុំត្រងត្រាប់ | ត្រចៀកប្រុងស្ដាប់ | បន្ទូលព្រះអង្គ | ទ្រង់នឹងប្រទាន |
| | សុខសាន្តគ្មានហ្មង | លើរាស្ត្រទ្រង់ផង | ដែលមិនលេលា | ។ |
| ១០- | ក្នុងពេលឆាប់ៗ | ទ្រង់នឹងប្រញាប់ | ជួយយើងរាល់គ្នា | ដល់អ្នកកោតខ្លាច |
| | ព្រះអង្គគ្រប់គ្រា | សិរីមហិមា | នៅលើដីយើង | ។ |
| ១១- | ទ្រង់មានព្រះទ័យ | សប្បុរសថ្លាថ្លៃ | បារមីរុងរឿង | ព្រះអង្គស្មោះស្ម័គ្រ |
| | ករុណាមិនឆ្មើង | យុត្តិធម៌កើតឡើង | នៅលើលោកិយ៍ | ។ |

១២-សេចក្ដីទៀងត្រង់ ចាប់ដុះរបហង់ ពាសពេញផែនដី សេចក្ដីសុចរិត
ក៏លាស់ជាថ្មី ពីសួគ៌ាល័យ ចុះជួយរក្សា ។
១៣- ព្រះអម្ចាស់ផ្ទាល់ ប្រទានមង្គល ឲ្យយើងគ្រប់គ្នា ចំណែកផែនដី
បង្កើតផលា ភោគផលផ្លែផ្កា សម្បូរមិនខ្វះ ។
១៤- សេចក្ដីសុចរិត យុត្តិធម៌ប្រណីត នៅមុខព្រះម្ចាស់ សុខសាន្តតាមដាន
រៀបផ្លូវថ្វាយព្រះ ឥតមានក្រឡះ សុខសាន្តរហូត ។

## ទំនុកតម្កើងលេខ ៨៦ (៨៥) បទព្រហ្មគីតិ

១- ឱព្រះអម្ចាស់អើយ កុំកន្តើយផ្ទៀងព្រះកាណ៌
ស្ដាប់ស័ព្ទខ្ញុំវាចា ហើយមេត្តាតបវិញផង ។
ដ្បិតខ្ញុំជាមនុស្ស កម្សត់ខុសគេទាំងពួង
ទុរគតពេកកន្លង តោកយ៉ាកផងរាល់វេលា ។
២- សូមរក្សាជីវិត ឲ្យខ្ញុំស្ថិតផុតគ្រាំគ្រា
ដ្បិតខ្ញុំត្រង់ល្អជា ស្ម័គ្រគ្រប់គ្រាគ្មានគេចកែ ។
សូមមេត្តាសង្គ្រោះ ដ្បិតខ្ញុំស្មោះឥតប្រួលប្រែ
ជាបម្រើនៅក្បែរ ពឹងផ្អែកតែលើម្ចាស់ថ្លៃ ។
៣- ឱ! ព្រះអម្ចាស់អើយ អាណិតហើយសូមប្រណី
ខ្ញុំស្រែកទូលរាល់ថ្ងៃ រកព្រះអង្គមិនឈប់ឈរ ។
៤- ឱព្រះអម្ចាស់អើយ សូមប្រោសឲ្យបម្រើល្អ
មានសប្បាយអំណរ តម្រង់រកព្រះអម្ចាស់ ។
៥- បពិត្រព្រះម្ចាស់ខ្ញុំ ព្រះឧត្តមសប្បុរសណាស់
អត់ឱនមិនថ្កោលទោស តែងសន្ដោសខ្ញុំបរិបូណ៌ ។
ព្រះអង្គតែងអាណិត អ្នកផ្ដេកផ្ដិតទ្រង់អាសូរ
អ្នកដែលដង្ហោយថ្ងូរ ហៅព្រះអង្គមកសង្គ្រោះ ។
៦- ឱព្រះអម្ចាស់អើយ ទ្រង់ផ្ទៀងហើយសូមសន្ដោស
ពាក្យខ្ញុំស្រែករកនោះ សូមទ្រង់ប្រោសរូបខ្ញុំផង ។

៧- នៅថ្ងៃមានអាសន្ន ខ្ញុំបែរបន់មិនរំលង
អង្វររកព្រះអង្គ ទ្រង់ឆ្លើយត្រង់តបមកខ្ញុំ ។

៨- ឱព្រះជាអម្ចាស់ ទ្រង់ជាព្រះដ៏ឧត្ដម
ព្រះអង្គសែនសក្ដិសម គ្មានព្រះធំដូចទ្រង់ឡើយ ។

៩- បពិត្រព្រះអម្ចាស់ គ្រប់ជាតិសាសន៍ដែលកើតហើយ
គេនឹងមិនកន្តើយ តម្កើងកើយនាមព្រះអង្គ ។

១០- ព្រោះដ្បិតទ្រង់ជាព្រះ ដ៏ខ្ពង់ខ្ពស់អស្ចារ្យផ្ទង់
នោះគឺមានតែទ្រង់ ដែលជាអង្គលើលោកា ។

១- ឱ! ព្រះអម្ចាស់ខ្ញុំ មេត្តាសូមប្រាប់មាគ៌ា
ឲ្យខ្ញុំស្គាល់គ្រប់គ្រា នឹងយាត្រាចេញដើរតាម ។
យើងខ្ញុំនឹងប្រព្រឹត្ត តាមសុចរិតមាគ៌ាស្នាម
ឲ្យខ្ញុំបេះប្រណម្យ កោតឧត្ដមបរមនាម ។

១២- បពិត្រព្រះម្ចាស់ខ្ញុំ ទូលបង្គំមិនទីមទាម
ថ្លែងអរព្រះគុណភ្លាម ឥតលាក់លៀមពីដួងចិត្ត ។
ខ្ញុំនឹងលើកតម្កើង ព្រះនាមឡើងអស់កល្បពិត
ថ្កើងថ្កានខ្ពស់ប្រណីត រៀងស្ថេរស្ថិតជាប់រហូត ។

១៣- ដ្បិតទ្រង់មានព្រះទ័យ ករុណាក្រៃមិនរលត់
ជួយរំដោះជីវិត ខ្ញុំឲ្យផុតពីក្បិណក្ស័យ ។

១៤- បពិត្រព្រះជាម្ចាស់ ពួកមនុស្សច្រើនពេកក្រៃ
ព្រហើនមិនយល់អ្វី គេពួតដៃប្រឆាំងខ្ញុំ ។
មានអ្នកខ្លាំងពូកែ បានប្រឯប្រមូលផ្ដុំ
ចង់ដកជីវិតខ្ញុំ មិនបារម្ភព្រះអង្គសោះ ។

១៥- បពិត្រព្រះម្ចាស់អើយ ព្រះអង្គហើយព្រះទ័យស្មោះ
ករុណាទ្រង់សន្ដោស សប្បុរសមានមេត្តា ។

១៦- សូមទ្រង់បែរព្រះភក្ត្រ ទតឲ្យជាក់ខ្ញុំនេះណា
សូមអាណិតមេត្តា ខ្ញុំគ្រប់គ្រាកុំបីខាន ។

សង្គ្រោះខ្ញុំជាអ្នក    បម្រើស្ម័គ្រសូមឲ្យមាន
កម្លាំងខ្លាំងក្លាហាន    សូមផ្ញើប្រាណនឹងព្រះអង្គ ។
១៧- សូមមេត្តាសម្ដែង    ការស្ញប់ស្ញែងគេឃើញផង
អ្នកស្អប់ខ្ញុំកន្លង    ឃើញព្រះអង្គប្រោសសង្គ្រោះ ។
សូមឲ្យខ្មាំងសត្រូវ    វាអស់ផ្លូវត្រូវអាម៉ាស់
នៅពេលដែលទ្រង់ត្រាស់    ប្រោសសង្គ្រោះការពារខ្ញុំ ។

## ទំនុកតម្កើងលេខ ៨៧ (៨៦)    បទកាកគតិ

១- ព្រះម្ចាស់សង់ក្រុង    ឧត្តមឧត្តុង្គ    ល្អល្អះប៉ប្រិម    លើភ្នំវិសុទ្ធ
គ្មានអ្វីប្រៀបផ្ទឹម    យេរូសាឡឹម    ជាក្រុងថ្លៃថ្លា ។
២- ព្រះអង្គស្រឡាញ់    ស៊ីយ៉ូនពោរពេញ    ជាក្រុងអស្ចារ្យ    វិសេសវិសាល
លើសក្រុងនានា    លើទឹកដីជា    របស់យ៉ាកុប ។
៣- ឱក្រុងរបស់    ព្រះជាអម្ចាស់    គេនឹងរៀបរាប់    តម្កើងសិរី
រុងរឿងគួរគាប់    របស់អ្នកជាប់    ដោយពោលថ្លាថ្លែង ។
៤- ក្នុងចំណោមអ្នក    អេស៊ីបស្គាល់ជាក់    បាប៊ីឡូននេះឯង    អ្នកខ្លះកើតនៅ
ទីរ៉ូសធំខែង    ភីលីស្ទីនស្ដែង    អេត្យូពីដែរ ។
៥- ចំពោះបុរី    ស៊ីយ៉ូនស្រស់ខ្ចី    មិនរួញរាទេ    យើងទាំងអស់គ្នា
សុទ្ធកើតពីគេ    ព្រះម្ចាស់ជួយថែ    ឲ្យក្រុងរឹងមាំ ។
៦- ពេលនោះព្រះម្ចាស់    កត់ឈ្មោះទាំងអស់    ក្នុងបញ្ជីធំ    ប្រជាទាំងនេះ
សុទ្ធតែកើតក្នុង    ស៊ីយ៉ូនជាក្រុង    ដែលផ្ដល់កំណើត ។
៧- ពេលនោះមនុស្ស    គេលោតឡកគោះ    ច្រៀងរាំរហូត    ថាគេជាកូន
ដែលគេបានកើត    មានដើមកំណើត    ពីក្រុងស៊ីយ៉ូន ។

## ទំនុកតម្កើងលេខ ៨៨ (៨៧)    បទព្រហ្មគីតិ

២- បពិត្រព្រះអម្ចាស់    ទ្រង់ជាព្រះសង្គ្រោះខ្ញុំ
ថ្ងៃយប់ខ្ញុំស្រែកយំ    អង្វរសុំក្ដីមេត្តា ។

៣- សូមឲ្យពាក្យអង្វរ ខ្ញុំព្ញខ្ទ័រដល់សោតា
សូមទ្រង់ផ្ទៀងព្រះកាណ៌ ស្តាប់ផងណាសូរសម្រែក ។
៤- ព្រោះដឿតទូលបង្គំ មានទុក្ខធំខ្លាំងអនេក
ខ្លោចផ្សាជាពន់ពេក ក្តីស្លាប់ស្រែកហៅកៀកកិត ។
៥- គេបាត់ទុករូបខ្ញុំ ក្នុងចំណោមអ្នកដែលជិត
ហៀបនឹងអស់ជីវិត ឬនៅជិតអ្នកដែលស្លាប់ ។
៦- ខ្លួនខ្ញុំដេកស្តូកស្តឹង គ្មានទីពឹងសែនអួរអាប់
បីដូចមនុស្សស្លាប់ ទ្រង់លែងរាប់រកនឹកនា ។
៧- ព្រះអង្គបានបង់បោះ រូបខ្ញុំរស់នៅកំព្រា
ឲ្យរងទុក្ខវេទនា សែនរងាក្នុងរណ្តៅ ។
៨- ព្រះពិរោធព្រះអង្គ សង្កត់ចងខ្ញុំទុកនៅ
ដូចទឹកបោកសំដៅ រារាំងផ្លូវទូលបង្គំ ។
៩- ព្រះអង្គឲ្យអស់អ្នក ដែលធ្លាប់ស្ម័គ្រស្និទ្ធនឹងខ្ញុំ
ឆ្ងាយពីទូលបង្គំ ទាំងស្អប់ខ្ពើមថែមទៀតផង ។
១០- ភ្នែកខ្ញុំប្រែស្រវាំង វេទនាខ្លាំងពេកកន្លង
ខ្ញុំអង្វរព្រះអង្គ លើកដៃផងសូមប្រណី ។
១១- តើមនុស្សដែលស្លាប់ទៅ នឹងនិត្យនៅក្រោកឃ្មាតខ្មី
តម្កើងជោគសិរី ព្រះអង្គថ្លៃកើតឬទេ ? ។
១២- តើអ្នកនៅក្នុងផ្នូរ អាចថ្លែងអរគិតរិះរេ
ពីព្រះទ័យស្និទ្ធស្នេហ៍ ព្រះអង្គដែរកើតទេឬ ? ។
១៣- តើពួកអ្នកដែលស្ថិត ទីងងឹតអាចដឹងឮ
ស្គាល់ស្នាដៃរន្ធឺ ព្រះអង្គឬ ដូចម្តេចបាន ? ។
១៤- ឱព្រះអម្ចាស់អើយ ខ្ញុំដង្ហោយឥតស្រាកស្រាន្ត
អង្វរម្ចាស់ថ្កើងថ្កាន លំឱនប្រាណតាំងពីព្រឹក ។
១៥- ឱព្រះអម្ចាស់អើយ ហេតុម្តេចឡើយទ្រង់មិននឹក
បោលខ្ញុំឲ្យវិវរឹក មិននានឹកខ្ញុំយ៉ាងនេះ ? ។

| | | |
|---|---|---|
| ១៦- ខ្ញុំលំបាកកាយា | ជិតមរណាពីក្មេងម្ល៉េះ | |
| ព្រះអង្គធ្វើយ៉ាងនេះ | ឲ្យខ្ញុំអស់ក្តីសង្ឃឹម | ។ |
| ១៧- ព្រះពិរោធព្រះអង្គ | សង្កត់ត្រង់លើរូបខ្ញុំ | |
| ធ្វើឲ្យទូលបង្គំ | ភ័យអួលងំបាត់ស្មារតី | ។ |
| ១៨- ទុក្ខទោសនេះដូចជា | ផ្ទៃជលសាធំពេកក្រៃ | |
| ឡោមព័ទ្ធខ្ញុំរាល់ថ្ងៃ | គ្មានប្រណីគ្របពីលើ | ។ |
| ១៩- ព្រះអង្គបានដេញមិត្ត | ធ្លាប់ជិតស្និទ្ធមិនអើពើ | |
| ចេញឆ្ងាយលែងងាកមើល | ខ្ញុំស្នាក់ស្នើរនៅកំព្រា | ។ |
| រូបខ្ញុំប្រែធុញងប់ | លំបាកសព្វវេទនា | |
| ឃើញតែភាពអន្ធិកា | នៅជាគ្នាជាប់រហូត | ។ |

## ទំនុកតម្កើងលេខ ៨៩ (៨៨) — បទកាកគតិ

| | | | |
|---|---|---|---|
| ២- ឱ! ព្រះជាម្ចាស់ | ខ្ញុំមិនគេចប្រាស | នឹងច្រៀងតម្កើង | បង្គំព្រះអង្គ |
| ព្រះទ័យខ្ពស់ថ្កើង | អស់កល្បយូរលង់ | អង្វែងតទៅ | ។ |
| ៣- ខ្ញុំប្រកាសថា | ព្រះទ័យមេត្តា | ករុណាត្រឹមត្រូវ | របស់ព្រះអង្គ |
| ស្ថិតស្ថេរគង់នៅ | មាំមិនអាស្រូវ | ដូចផ្ទៃមេឃា | ។ |
| ៤- យើងចងសម្ពន្ធ | មេត្រីបន្ទាន់ | ចុះខសន្យា | ជ្រើសលោកដាវីឌ |
| ហើយតែងតាំងជា | បម្រើការពារ | ឥតមានប្រែប្រួល | ។ |
| ៥- យើងនឹងតាំងពង្ស | ពូជអ្នកឲ្យគង់ | នៅជុំត្រកូល | តាំងរាជ្យឲ្យអ្នក |
| នៅបានសុខស្រួល | គ្មានអ្វីប្រែប្រួល | អង្វែងជរាប | ។ |
| ៦- ឱព្រះម្ចាស់អើយ | ទេវតានេះហើយ | សរសើររៀងរាប់ | ពីស្នាព្រះហស្ត |
| អស្ចារ្យគួរគាប់ | ច្រៀងកោតមិនឈប់ | ពីព្រះទ័យស្ម័គ្រ | ។ |
| ៧- នៅស្ថានសួគ៌ា | ឥតមាននរណា | ស្មើរព្រះអង្គជាក់ | ពពួកទេវា |
| ក៏មិនមានអ្នក | ឲ្យបានដូចព្រះ | អម្ចាស់នោះទេ | ។ |
| ៨- ពពួកទេវតា | ក៏ខ្លាចឫទ្ធា | ព្រះអម្ចាស់ដែរ | អ្នកនៅជុំវិញ |
| កៀកកិតអែបក្បែរ | ខ្លបខ្លាចគ្មានប្រែ | ព្រះនាមព្រះអង្គ | ។ |

៩- បពិត្រព្រះម្ចាស់ ព្រះអង្គជាព្រះ នៃភពទូទាំង គ្មានអ្នកណាមាន
អនុភាពក្លាខ្លាំង បារមីប្រណាំង ព្រះអង្គបានឡើយ ។
១០- ព្រះអង្គបង្ក្រាប សមុទ្រឲ្យរាប ឈប់បោកបក់ហើយ ពេលវាកក្រើក
ទ្រង់មិនកន្តើយ បញ្ឈរវាហើយ ដោយឫទ្ធិបារមី ។
១១- ព្រះអង្គបានជាន់ កម្ទេចអង្គន់ មិនឲ្យសល់អី ប្រហារនាគរាជ
សត្រូវអប្រិយ៍ ដោយឫទ្ធិបារមី ចេស្តាខ្លាំងណាស់ ។
១២- ផែនដីនិងមេឃ គឺជាចំណែក នៃព្រះអម្ចាស់ ព្រះអង្គបង្កើត
អ្វីសព្វទាំងអស់ លើមេឃដីកោះ នៅក្នុងលោកនេះ ។
១៣- ព្រះអង្គបង្កើត ទិសត្បូងល្អឆើត ខាងជើងស្រឡះ មានភ្នំតាបិរ
ភ្នំហែរម៉ូននោះ សរសើរច្រៀងព្រះ នាមនៃព្រះអង្គ ។
១៤- ទ្រង់ប្រកបដោយ ចេស្តាមិនថយ ឫទ្ធាខ្ពស់ខ្ពង់ បារមីខ្លាំងក្រៃ
មិនចេះបាត់បង់ អានុភាពព្រះអង្គ លើសគេលើលោក ។
១៥- ព្រះម្ចាស់គ្រងរាជ្យ ដោយក្តីសុចរិត យុត្តិធម៌រៀងមក អ្វីដែលទ្រង់ធ្វើ
សុទ្ធល្អហ្មងម៉ត់ ហឫទ័យអំណត់ សន្តោសមេត្តា ។
១៦- បពិត្រព្រះម្ចាស់ ប្រជាអរណាស់ រស់ក្រោមចេស្តា ពន្លឺសប្បុរស
សន្តោសករុណា រាស្ត្រផុតទុក្ខា មានសុខមង្គល ។
១៧- គេនឹងសប្បាយ រីករាយរាល់ថ្ងៃ ដោយស្មោះទទួល ព្រះនាមព្រះអង្គ
ឥតមានប្រែប្រួល ខ្ពស់មុខសុខស្រួល ឥតមានសៅហ្មង ។
១៨- ព្រះម្ចាស់ប្រទាន ពួកគេឲ្យមាន ជោគសិរីផង ដោយព្រះសន្តោស
ប្រណីឥតហ្មង យើងខ្ញុំថ្កុំថ្កើង ព្រោះព្រះអង្គជួយ ។
១៩- ព្រះម្ចាស់វិសុទ្ធ ល្អល្អះបំផុត អ៊ីស្រាអែលតែមួយ ទ្រង់បានជ្រើសរើស
ស្តេចជាជំនួយ មិនឲ្យមានព្រួយ ជាខែលការពារ ។
២០- នាថ្ងៃមួយនោះ ព្រះអង្គមានព្រះ បន្ទូលមកថា យើងនឹងគាំទ្រ
អ្នកច្បាំងហានក្លា យុវជនសង្ហា ពីក្នុងរាស្ត្រយើង ។
២១- យើងឃើញដាវីឌ ជាអ្នកប្រណិប័តន៍ ឥតមានឆ្មៃឆ្មើង យើងក៏ចាក់ប្រេង
អភិសេកគេឡើង ជាស្តេចថ្កុំថ្កើង គ្រងរាជ្យរហូត ។

២២-ហើយយើងនឹងជួយ  ជ្រែងជាជំនួយ  មិនឲ្យរបូត  ទាំងផ្តល់កម្លាំង
រៀងរៀបមិនស្ងួត  ពូកែរហូត  អំណាចពេញប្រៀប ។
២៣-សត្រូវពុំអាច  ពង្រឹងអំណាច  ឬចង់មកគាប  ពួកអ្នកបះបោរ
ក៏មិនអាចជ្រៀប  វិនាសរៀងរៀប  ចេញពីមុខអស់ ។
២៤-យើងនឹងកម្ទេច  សត្រូវមានល្បិច  មិនទុកនៅសោះ  ព្រមទាំងប្រហារ
ពួកគេទាំងអស់  អ្នកស្អប់គាត់នោះ  មិនឲ្យនៅជិត ។
២៥-យើងនឹងបញ្ចេញ  ហឫទ័យពោរពេញ  ករុណាអាណិត  ចំពោះរូបគេ
នឹងបាននៃបនិត្យ  ថ្កើងរុងរឿងពិត  ដោយសារនាមយើង ។
២៦-យើងនឹងធ្វើឲ្យ  ដាវីឌពេញដោយ  អំណាចថ្កុំថ្កើង  រលើសមុទ្រ
និងត្រួតគ្រប់គ្រង  ដល់ទន្លេផង  ទាំងតូចទាំងធំ ។
២៧-ដាវីឌហៅយើង  បិតាមិនឆ្ងើង  ជាថ្មខែងហំ  ដែលបានសង្គ្រោះ
រំដោះរូបខ្ញុំ  បានឡើងឧត្តម  ខ្ពង់ខ្ពស់សង្ហារ ។
២៨-រីឯយើងវិញ  យើងនឹងបំពេញ  ដាវីឌស្ងួនភ្ងារ  តាំងជាបុត្រច្បង
របស់យើងណា  ស្តេចធំអស្ចារ្យ  នៅលើដែនដី ។
២៩-យើងនឹងបញ្ចេញ  ឥតមានទោម្នេញ  ដោយចិត្តប្រណី  នឹងរក្សាទុក
សម្ពន្ធមេត្រី  ចងជាប់មិនស្រាយ  មិនគេចប្រែប្រួល ។
៣០- យើងនឹងតែងតាំង  ត្រកូលពូជពង្ស  ឲ្យរស់សុខស្រួល  ស្ថិតស្ថេរអស់កល្ប
ដាវីឌតែមួយ  ល្បីល្បាញរញ្ជួយ  ដូចមេឃខៀវខ្ចី ។
៣១-បើសិនពូជពង្ស  ដាវីឌបោះបង់  បោលធម្មវិន័យ  ហើយឈប់ដើរតាម
មាគ៌ាប្រពៃ  ធ្វើងើយមិនស្តី  មិនតាមបញ្ជា ។
៣២-ប្រសិនបើគេ  បំពានវៀចវេរ  កែប្រែរេរា  ហើយលែងប្រតិបត្តិ
តាមបទបញ្ជា  វិន័យនានា  ជារបស់យើង ។
៣៣-យើងនឹងប្រដៅ  ពួកឆោតល្ងង់ខ្លៅ  បង្ករឿងឡើង  យើងដាក់ទណ្ឌកម្ម
ទារុណធ្ងន់ថ្កើង  កំហុសមានច្រើន  គេបានប្រព្រឹត្ត ។
៣៤-ប៉ុន្តែយើងតែង  បញ្ជាក់សម្តែង  សេចក្តីអាណិត  ស្មោះស្ម័គ្រនឹងគេ
ឥតប្រែប្រួលចិត្ត  ឬចង់បែរគេច  បែកចិត្តបោលឡើយ ។

៣៥-យើងនឹងមិនផ្តាច់ សម្ពន្ធមានស្រេច នោះទេអ្នកអើយ មិនក្បត់ក្រឡាស់
ប្រែមុខជាក្រោយ អ្វីនិយាយហើយ យើងមិនបំបាត់ ។

៣៦-យើងបានសន្យា យ៉ាងច្បាស់អស្ចារ្យ ឥតមានតក់ស្លុត នៅក្នុងនាមយើង
ជាព្រះវិសុទ្ធ ល្បីមិនរលត់ មិនភរបោកប្រាស ។

៣៧-ពូជរបស់គាត់ នឹងនៅស្ថេរស្ថិត សុខឥតក្រឡះ រាជ្យរបស់គេ
រុងរឿងខ្លាំងណាស់ រស្មីត្រចះ ដូចព្រះអាទិត្យ ។

៣៨-ឬដូចច័ន្ទថ្លៃ ដែលមានរស្មី គង់វង្សស្ថេរស្ថិត ធ្វើជាសាក្សី
អែបអង្គនៃបនិត្យ មិនអាចបំបិទ ឬមានល្បិចកល ។

៣៩-ប៉ុន្តែព្រះម្ចាស់ ព្រះអង្គបានលះ បង់បោលកាត់កាល់ ទ្រង់ព្រះពិរោធ
ព្រះរាជាដែល ថ្នាក់ថ្នមក្រវែល បាក់ប្រេងអភិសេក ។

៤០- ព្រះអង្គបានផ្តាច់ សម្ពន្ធបណ្តាច់ មេត្រីល្អឯក ជាមួយបម្រើ
ទម្លាក់មកុដរាជ្យ រាជានោះទៀត ឲ្យធ្លាក់ដល់ដី ។

៤១- កំពែងទាំងអស់ ត្រូវខូចធ្លាយធ្លុះ មិនមានសល់អ្វី ទាំងតួបន្ទាយ
រលំដល់ដី បាក់បែកខ្ទាត់ខ្ទាយ មិនសល់ចន្លោះ ។

៤២-អ្វីដែលស្តេចបាន គេប្លន់បំពាន រឹបអូសយកអស់ ប្រទេសជិតខាង
ពេបជ្រាយខាកស្តោះ មើលងាយចំពោះ អង្គព្រះរាជា ។

៤៣- ព្រះអង្គប្រទាន កម្លាំងឲ្យមាន ដល់ពួកបច្ចា ខ្លាំងក្លាពេកក្រៃ
ដូចដំរីសា សត្រូវនាំគ្នា រីករាយសប្បាយ ។

៤៤- ព្រះអង្គធ្វើឲ្យ សស្ត្រាវុធជយ ឫទ្ធីបារមី ឈប់ឲ្យសក្តិសិទ្ធិ
ព្រះអង្គមិនខ្វី អាណិតប្រណី ស្តេចក្នុងចម្បាំង ។

៤៥- ទ្រង់ដកអំណាច ដោយឥតមានខ្លាច ព្រះរាជាគាំង បន្ថយជន្មា
រំលំបល្ល័ង្ក ស្តេចភ័យស្លេកស្លាំង បាក់មុខអាប់យស ។

៤៦- ព្រះអង្គពុំឲ្យ ព្រះរាជាសោយ រាជ្យបានយូរសោះ ទ្រង់ធ្វើឲ្យស្តេច
ទទួលអាម៉ាស់ រងទុក្ខក្រៃក្រាស់ ខ្មាសអស់ប្រជា ។

៤៧-ឱព្រះម្ចាស់អើយ ម្តេចគង់ព្រងើយ ពុំព្រមវាចា សូមស្រាយពិរោធ
សង្គ្រោះសង្ខារ ឬមិនមេត្តា នៅតែឆាបឆេះ ។

៤៨- សូមទ្រង់ចាំថា អាយុសង្ខារ ខ្ញុំខ្លីអ្វីម្ល៉េះ ព្រះអង្គបង្កើត
មនុស្សលោកមកនេះ ដើម្បីបញ្ឆេះ រំលាយទៅវិញ ។
៤៩- គ្មាននរណាម្នាក់ រស់នៅទៀងជាក់ មិនដែលទៅម្ដេញ កើតហើយតែងស្លាប់
ទៅជាដីវិញ មិនអាចគេចចេញ ពីមច្ចុរាជបាន ។
៥០- ឱ! ព្រះអម្ចាស់ តើស្នាព្រះហស្ត ទ្រង់ទាំងប៉ុន្មាន មេត្តាករុណា
ដែលព្រះអង្គបាន ធ្លាប់ប្រោសប្រទាន ដាវីឌទៅណា ? ។
៥១- ព្រះអម្ចាស់អើយ សូមកុំព្រងើយ បំភ្លេចទាសា កំពុងបាក់មុខ
ស្ទើរក្ស័យសង្ខារ អស់រាស្ត្រប្រជា ក្នុងបន្ទុកខ្ញុំ ។
៥២- បពិត្រព្រះម្ចាស់ សត្រូវទាំងនោះ បំបាក់មុខចំ ស្ដេចដែលទ្រង់បាន
អភិសេកជាធំ ជេរ្យលជេរមិនសម រាជាឥតហេតុ ។
៥៣- សូមលើកតម្កើង សិរីរុងរឿង ថ្លៃខ្ពស់ត្រដែត របស់ព្រះម្ចាស់
ភ្លឺចំាងក្រឡែត អស់កល្បរហូត អង្វែងរៀងទៅ ។

## ទំនុកតម្កើងលេខ ៩០ (៨៩) បទពាក្យ ៧

១- បពិត្រព្រះម្ចាស់ដ៏ប្រសើរ ព្រះអង្គធ្លាប់ធ្វើជាជម្រក
ពីជំនាន់មុនរៀងមក ឲ្យយើងខ្ញុំជ្រកបានប្រពៃ ។
២- មុនពេលមានភ្នំកកើតឡើង មុនពេលព្រះអង្គបង្កើតដី
មុនពិភពលោកនិងអ្វីៗ ព្រះអម្ចាស់ថ្លៃជាបិតា ។
៣- ព្រះអង្គធ្វើឲ្យមនុស្សគ្រប់ទី ក្លាយជាធូលីដីវិញ្ញាណ
គឺព្រះអង្គមានបន្ទូលថា ៖ «អស់ពូជពង្សអដាំវិលវិញ! » ។
៤- ចំពោះព្រះអង្គរយៈពេល មួយពាន់ឆ្នាំក្រែលដូចម្សិលមិញ
ឬដូចជាពេលមួយយប់ពេញ កន្លងផុតចេញទៅថ្មីៗ ។
៥- ព្រះអង្គដកយកជីវិតមនុស្ស ជីវិតទាំងអស់សព្វអ្វីៗ
គឺប្រៀបបីដូចជាស្មៅខ្ចី មិនពិបាកអីដូចយល់សប្តិ ។
៦- នៅពេលព្រឹកព្រាងមានរស្មី ស្មៅដុះពីដីហើយត្រឡប់
ជាក្រៀមស្រពោនសែនអភ័ព្វ ពេលល្ងាចស្ងួតងាប់គ្មានសល់អ្វី ។

៧- យើងខ្ញុំនឹងត្រូវវិនាសបង់ ដោយសារព្រះអង្គមិនប្រណី
ពេលទ្រង់ខ្ញាល់ខ្លាំងខ្ញុំភិតភ័យ ព្រោះព្រះម្ចាស់ថ្លៃជាច់មេត្តា ។
៨- ព្រះអង្គចាប់យកកំហុសខ្ញុំ មកត្រដាងចំមុខភក្ត្រា
ពន្លឺព្រះអង្គចាំងកាលណា ឃើញអស់កិច្ចការខ្ញុំប្រព្រឹត្ត ។
៩- ដោយសារព្រះអង្គព្រះពិរោធ ជីវិតខ្ញុំសោតដុនដាបពិត
អាយុត្រូវចប់ផុតជីវិត ដង្ហើមបើកបិទកាន់តែខ្លី ។
១០- អាយុយើងខ្ញុំរស់បានត្រឹម តែចិតសិបឆ្នាំមិនវែងអី
បើបានប៉ែតសិបនោះប្រពៃ ក្រោយមកស្ងួលដីបែកខ្ចាត់ខ្ចាយ ។
ក្នុងពេលដែលខ្ញុំមានជីវិត ខ្ញុំតែងនឹកគិតតែងខ្វល់ខ្វាយ
និងជួបតែទុក្ខឥតស្រស់ស្រាយ ជីវិតឃ្លាតឆ្ងាយត្រូវមរណា ។
១១- តើនរណាស្គាល់កម្លាំងក្រោធ នៃព្រះពិរោធដ៏អស្ចារ្យ
ដើម្បីគោរពខ្លាចបេស្ដា ព្រះអង្គយ៉ាងណាឲ្យត្រឹមត្រូវ ។
១២- សូមណែនាំខ្ញុំឲ្យដឹងថា អាយុសង្ខារខ្ញុំឥឡូវ
កំណត់ប៉ុណ្ណាឲ្យត្រឹមត្រូវ ដើម្បីជាផ្លូវខ្ញុំរិះគិត ។
១៣- ឱព្រះអម្ចាស់សូមប្រញាប់ យាងមកឆាប់ៗប្រាប់ការពិត
កុំនៅបង្អង់សូមអាណិត អាសូរដល់ចិត្តអ្នកបម្រើ ។
១៤- សូមសម្ដែងហឫទ័យមេត្តា ដោយក្ដីករុណាដ៏ប្រសើរ
ចំពោះខ្ញុំជាអ្នកបម្រើ ខ្ញុំមានអំណរគ្រប់វេលា ។
១៥- ព្រះអង្គឲ្យខ្ញុំកើតទុក្ខធំ អស់ពេលច្រើនឆ្នាំខ្ញុំវេទនា
សូមប្រោសឲ្យខ្ញុំផុតទុក្ខា សប្បាយយូរយាយ៉ាងនោះដែរ ។
១៦- សូមសម្ដែងឲ្យខ្ញុំឃើញច្បាស់ ពីការសង្គ្រោះឥតកែប្រែ
ឲ្យកូនចៅខ្ញុំឃើញហូរហែ ភាពថ្កុំថ្កើងដែរនៃព្រះអង្គ ។
១៧- ឱព្រះម្ចាស់អើយសូមសម្ដែង សេចក្ដីស្រឡាញ់មកខ្ញុំផង
សូមជួយពង្រឹងការទាំងពួង ខ្ញុំឲ្យខ្ជាប់ខ្ជួនរៀងរហូត ។

## ទំនុកតម្កើងលេខ ៩១ (៩០) បទភាកគតិ

១- អ្នកដែលរស់ក្រោម ការថែគ្រប់គ្រង របស់ព្រះម្ចាស់ ជាព្រះខ្ពង់ខ្ពស់
វិសុទ្ធពេកណាស់ មានឫទ្ធិតេជះ បារមីខ្លាំងក្រៃ ។

២- ខ្ញុំសូមទូលថា « ព្រះអម្ចាស់ជា ជម្រកយប់ថ្ងៃ និងជាកំពែង
ជ្រកកោនផុតភ័យ មិនបង្អង់អី ផ្ញើកាយជីវិត » ។
៣- ព្រះម្ចាស់តែងតែ ជួយមិនគេចកែ ឲ្យអ្នករួចផុត ចេញពីអន្ទាក់
ពួកជនទុច្ចរិត ជំងឺរាតត្បាត ចង្រៃឧបទ្រព ។
៤- ទ្រង់នឹងការពារ រូបអ្នកគ្រប់គ្នា នៅជ្រកក្រោមម្លប់ បារមីព្រះអង្គ
ទាំងថ្ងៃទាំងយប់ ឥតមានឈរឈប់ ម្លប់ដ៏ត្រជាក់ ។
ព្រះហឫទ័យ មេត្តាប្រណី មិនដែលថ្នាំងថ្នាក់ របស់ព្រះអង្គ
ជួយការពារអ្នក ជាអាវក្រោះពាក់ របស់អ្នកហើយ ។
៥- នៅពេលរាត្រី អ្នកនឹងមិនភ័យ អំពីអ្វីឡើយ អាសន្នគ្រប់យ៉ាង
ចៀសផុតធូរស្បើយ ពេលថ្ងៃក៏ដោយ ក៏អាចរួចផុត ។
៦- អ្នកនឹងមិនអាច ជួបគ្រោះកំណាច ក្នុងយប់ងងឹត ទាំងមហន្តរាយ
ទោះនៅឆ្ងាយជិត ថ្ងៃត្រង់ក៏ផុត មិនអាចជួបសោះ ។
៧- ទោះបីជាមាន មនុស្សម៉ឺនពាន់ ដេកស្លាប់ទាំងអស់ ក៏មិនមានអ្វី
មកប៉ះអ្នកសោះ ផុតអស់ទុក្ខគ្រោះ គ្មានព្រួយភិតភ័យ ។
៨- បើអ្នកពិនិត្យ មើលឲ្យបានជិត ឃើញច្បាស់ដូចថ្ងៃ ពីពួកមនុស្ស
អបលក្ខណ៍អប្រីយ៍ រងទោសរាល់ថ្ងៃ មិនមានអាក់ខាន ។
៩- ព្រះអម្ចាស់ជា ជម្រកពន្លា គ្មានអ្វីស្មើបាន អ្នកជ្រកក្រោមម្លប់
ព្រះខ្ពស់ហួសស្មាន វិសុទ្ធថ្កើងថ្កាន នៅលើលោកីយ៍ ។
១០- គ្មានទុក្ខវេទនា ណាមកពាធា ធ្វើឲ្យអ្នកភ័យ ទោះជាគ្រោះកាច
ឧបសគ្គចង្រៃ ចូលមិនបានអី ដល់លំនៅអ្នក ។
១១- ដ្បិតព្រះអម្ចាស់ នឹងបញ្ជាច្បាស់ ទេវទូតគ្រប់ថ្នាក់ តាមជួយរក្សា
ការពាររូបអ្នក គ្រប់ទីសំណាក់ ដែលអ្នកនឹងនៅ ។
១២- ទេវទូតយកដៃ ចាំទ្រថ្នមបី មិនឲ្យហួងសៅ លើកអ្នកឲ្យឈរ
រឹងប៉ឹងពេកកូវ មិនឲ្យជើងត្រូវ ទង្គិចថ្មឡើយ ។
១៣- អ្នកនឹងដើរជាន់ សត្វមានរាប់ពាន់ នៅជិតបង្កើយ សត្វគោកសត្វទឹក
សត្វព្រៃក៏ដោយ ជាន់សិង្ហពស់ហើយ ទាំងសត្វនាគខ្លា ។

១៤- ព្រះអម្ចាស់មាន ព្រះបន្ទូលថ្កាន យ៉ាងច្បាស់មកថា យើងនឹងចេញមុខ
រំដោះរងការ ដ្បិតគេស្គាល់ថា យើងជាព្រះគេ ។
១៥- បើគេស្រែករក ហៅយើងឲ្យមក យើងតបមិនរេ ពេលមានអាសន្ន
យើងនៅនឹងគេ ឥតមានបែកបែរ ទាំងថ្កើងគេផង ។
១៦- យើងឲ្យគេបាន រស់នៅសុខសាន្ត យូរឆ្នាំកន្លង អាយុយឺនយូរ
មិនឲ្យមានហ្មង ឲ្យគេដឹងផង ថាយើងសង្គ្រោះ ។

## ទំនុកតម្កើងលេខ ៩២ (៩១) បទពាក្យ ៧

២- បពិត្រព្រះអម្ចាស់ខ្ញុំអើយ ទូលបង្គំនេះហើយស្មូត្រតម្កើង
ពិតជាការគួរប្រពៃផង ប្រសើរកន្លងថ្កើងព្រះនាម ។
៣- ខ្ញុំសូមប្រកាសពីព្រះទ័យ ករុណាប្រណីពីព្រហាម
ពេលយប់ក៏ថ្លែងមិននៅស្ងៀម ឥតរេទីមទាមមិនឈប់ឈរ ។
៤- យើងខ្ញុំបន្ទន់ឱនទាំងកាយ បង្គំក្រាបថ្វាយទាំងកំដរ
មានតូរ្យតន្ត្រីចាប៉ីស្គរ បន្ថែមបន្ទរពិណពីក្រោយ ។
៥- បពិត្រព្រះម្ចាស់គ្រប់កិច្ចការ ដ៏ល្អអស្ចារ្យទ្រង់ធ្វើហើយ
ខ្ញុំសែនរីករាយចិត្តល្ហែល្ហើយ ស្នាព្រះហស្តថ្លៃនៃព្រះអង្គ ។
៦- បពិត្រព្រះម្ចាស់ស្នាព្រះហស្ត ព្រះអង្គទាំងអស់ខ្ពស់ឧត្តុង្គ
សន្លឹមអន្លាយជ្រៅកន្លង ជាងសមុទ្រផងវាស់ពុំបាន ។
៧- មនុស្សល្ងីល្ងើទាំងប្រុសស្រី មិនយល់សេចក្តីគ្រប់ៗប្រាណ
ឯពួកអ្នកល្ងង់ក៏មិនបាន ចេះដឹងប្រមាណអ្វីនោះដែរ ។
៨- ពួកអ្នកអាក្រក់រីកចម្រើន លូតលាស់ដុះកើនមួយជាទ្វេ
ឯអ្នកទុច្ចរិតចម្រើនដែរ ប៉ុន្តែពួកគេវិនាសអស់ ។
៩- ទោះបីទ្រង់គង់លើអាកាស វិសុទ្ធពេកណាស់ហើយខ្ពង់ខ្ពស់
ជាស្ថានវិសេសឥតមានមោះ ទ្រង់នៅជាព្រះម្ចាស់ជានិច្ច ។
១០- បពិត្រព្រះម្ចាស់សត្រូវខ្មាំង របស់ព្រះអង្គវិនាសខ្ទេច
ពួកអ្នកទុច្ចរិតមានកលកិច្ច នឹងត្រូវកម្ទេចមិនសល់អី ។

១១- ព្រះអង្គប្រទានឲ្យរូបខ្ញុំ    មានកម្លាំងហំដូចដំរី
រួចទ្រង់បានបាក់ទាំងប្រេងថ្មី    ក្រអូបពេកក្រៃសព្វអង្គា ។
១២- ខ្ញុំឃើញពួកខ្មាំងសត្រូវឃ្លាំ    គេលបនៅចាំរាល់វេលា
ឮទាំងសម្រែកហ៊ោខ្សៀវខ្វា    របស់បច្ចាដែលស្អប់ខ្ញុំ ។
១៣- មនុស្សសុចរិតនឹងដុះដាល    លូតលាស់ត្រកាលដូចត្នោតធំ
បែកមែកសាខាម្លប់ត្រសុំ    ដូចគគីរផ្តុំនៅជិតគ្នា ។
១៤- ពួកគេប្រៀបបាននឹងដើមឈើ    លូតលាស់ដុះលើព្រះពន្លា
គេរីកដុះដាលក្នុងវិហារ    របស់ព្រះជាម្ចាស់ថ្លាថ្លៃ ។
១៥- ទោះបីគេមានវ័យចំណាស់    ទោះខ្លួនគេចាស់ដូចម្ដេចក្ដី
គេបង្កើតផ្លែពន្លកថ្មី    ស្លឹកលាស់ខៀវខ្ចីជាប់ជានិច្ច ។
១៦- ការនេះសម្ដែងឲ្យឃើញថា    ព្រះអម្ចាស់ជាថ្មមាំពិត
ទ្រង់មានព្រះទ័យត្រង់សុចរិត    ឥតប្រែប្រួលចិត្តសោះឡើយណា ។

## ទំនុកតម្កើងលេខ ៩៣ (៩២) បទភាគគតិ

១- ព្រះអម្ចាស់ជា    មហាក្សត្រា    រុងរឿងថ្កើងថ្កុំ    ទ្រង់ប្រកបដោយ
ចេស្ដាឧត្ដម    ផែនដីនៅមាំ    ឥតរង្គើឡើយ ។
២- បល្ល័ង្កព្រះអង្គ    ស្ថិតស្ថេររឿងរុង    យូរលង់មកហើយ    ជន្មាព្រះអង្គ
អស់កល្បអន្លាយ    ដើមមករៀងអាយ    អង្វែងជានិច្ច ។
៣- បពិត្រព្រះម្ចាស់    រលកលោតផ្លោះ    មុជងើបខ្លាំងតិច    ខ្ទ័រខ្ទារគគ្រឹក
ជួនជោរជួននាច    សំឡេងបាចសាច    សម្បើមអស្ចារ្យ ។
៤- ប៉ុន្តែព្រះម្ចាស់    គ្រងរាជ្យខ្ពស់ណាស់    រុងរឿងមហា    នៅបរមសុខ
មានឫទ្ធិចេស្ដា    ខ្លាំងមហិមា    ជាងមហាសមុទ្រ ។
៥- បពិត្រព្រះម្ចាស់    ក្រឹត្យវិន័យព្រះ    ត្រឹមត្រូវបរិសុទ្ធ    ដំណាក់ព្រះអង្គ
ល្អល្អះបំផុត    វិសេសវិសុទ្ធ    អស់កល្បតទៅ ។

## ទំនុកតម្កើងលេខ ៩៤ (៩៣) — បទព្រហ្មគីតិ

១- បពិត្រព្រះអម្ចាស់ ទ្រង់តែងប្រោសរកយុត្តិធម៌
ព្រះនាមល្បីខ្ចារខ្ចរ ដោយបេស្កាប្ញទ្ធិបារមី ។

២- ព្រះដែលជាចៅក្រម ដ៏ឧត្តមលើដែនដី
តើនឡើងដាក់ទោសពៃរ៍ មនុស្សអប្រិយ៍តាមអំពើ ។

៣- ឱព្រះអម្ចាស់អើយ តើទុកឲ្យមនុស្សល្ងីល្ងើ
អាក្រក់មានជ័យលើ តាមអំពើដល់ពេលណា ។

៤- គេពោលពាក្យក្អេងក្អាង អួតបំប៉ោងឫកសង្ហា
ចូលចិត្តពាក្យមុសា នាំអាត្មាធ្វើទុច្ចរិត ។

៥- បពិត្រព្រះជាម្ចាស់ ពួកគេជិះជាន់សង្កត់
ប្រជាជនសុចរិត ទឹកដីពិតជាអន្តរាយ ។

៦- ពួកវាកាប់សម្លាប់ ដោយសំអប់ស្រីមេម៉ាយ
អន្តោប្រវេសន៍ក្ស័យ ហើយប្រល័យក្មេងកំព្រា ។

៧- គេថាព្រះអម្ចាស់ ទតមិនច្បាស់មិនបានការ
ព្រះយ៉ាកុបនេះណា មិនបានការមិនយល់អ្វី ។

៨- មនុស្សល្ងីល្ងើអើយ អ្នកនេះហើយប្រាជ្ញាខ្លី
ចិត្តខ្មៅជួរអប្រិយ៍ មិនដឹងអីមិនចេះគិត ។

៩- ព្រះអង្គបង្កើតភ្នែក ឲ្យក្រឡេកមើលឆ្ងាយជិត
តើទ្រង់មិនចេះគិត មិនចេះទតអ្វីទេឬ ? ។
ឯត្រចៀកមនុស្ស ទាំងស្រីប្រុសឲ្យស្ដាប់ឮ
ព្រះអង្គធ្វើបញ្ជើ ឬមិនចេះស្ដាប់សំឡេង ។

១០- ព្រះអង្គវាយប្រដៅ មនុស្សល្ងង់ខ្លៅឲ្យចេះដឹង
ម្ដេចក៏ទ្រង់មិនខឹង មិនរំពឹងដាក់ទោសអី ? ។

១១- ទ្រង់ជ្រាបគំនិតអស់ របស់មនុស្សលើលោកីយ៍
គំនិតពួកគេខ្លី មិនដឹងអីមនុស្សខ្លៅ ។

| | | |
|---|---|---|
| ១២- បពិត្រព្រះអម្ចាស់ | អ្នកដែលព្រះបង្ហាញផ្លូវ | |
| អប់រំប្រៀនប្រដៅ | អ្នកនោះត្រូវមានមង្គល | ។ |
| ១៣- នៅថ្ងៃមានអាសន្ន | ទ្រង់បន្ធន់គេលែងខ្វល់ | |
| មានរណ្ដៅនៅសល់ | ទុកតម្កល់កប់ជនពាល | ។ |
| ១៤- ដ្បិតទ្រង់មិនបង់បោះ | ប្រជារាស្ត្រឲ្យគេដៀល | |
| ព្រះអង្គក៏មិនបោល | ចំណែកផ្ទាល់មរតកទ្រង់ | ។ |
| ១៥- ចៅក្រមនឹងកាត់ក្ដី | ដោយប្រពៃមិនបង្វង់ | |
| អ្នកដែលមានចិត្តត្រង់ | តាមគន្លងយុត្តិធម៌ | ។ |
| ១៦- តើមាននរណានឹង | ហ៊ានប្រឆាំងពួកមិនល្អ | |
| នរណាដែលហ៊ានឈរ | ប្រឆាំង ត ពួកអប្រិយ៍ | ។ |
| ១៧- ប្រសិនបើព្រះម្ចាស់ | មិនសង្គ្រោះខ្ញុំភិតភ័យ | |
| ច្បាស់ជាត្រូវក្សិណក្ស័យ | វិនាសឆ្ងាយជាមិនខាន | ។ |
| ១៨- ពេលខ្ញុំពោលថាអស់ | កម្លាំងខ្សោះជិតដួលប្រាណ | |
| ព្រះអង្គទ្រខ្ញុំបាន | មិនខកខានព្រះទ័យស្មោះ | ។ |
| ១៩- ពេលណាមានកង្វល់ | ទុក្ខខ្វាយខ្វល់រាប់មិនអស់ | |
| ព្រះអង្គទ្រង់សន្ដោស | ប្រោសខ្ញុំរស់អរសប្បាយ | ។ |
| ២០- តើទ្រង់មានជំពាក់ | ទៅស្មោះស្ម័គ្រមនុស្សព្រៃផ្សៃ | |
| យកយុត្តិធម៌ក្រឡៃ | ឬកែឆ្នៃទាំងច្បាប់ក្បួន | ។ |
| ២១- ពួកគេព្រួតព្យាបាទ | ពួកសុចរិតមិនសមសួន | |
| ប្រហារប្រជាជន | ដាក់ទោសទណ្ឌទាំងបង្ខំ | ។ |
| ២២-ទ្រង់គឺជាកំពែង | មាំហំហែងការពារខ្ញុំ | |
| ព្រះអង្គជាថ្មជុំ | សម្រាប់ខ្ញុំចូលពួនជ្រក | ។ |
| ២៣-ព្រះអង្គសងតប ត | មិនឈប់ឈររៀបរៀងមក | |
| តាមអំពើស្មោគគ្រោក | ល្បិចគរគោកខ្លួនគេផ្ទាល់ | ។ |
| ទ្រង់ឲ្យគេវិនាស | បាត់សូន្យឈ្មោះគ្មានគេស្គាល់ | |
| ព្រះជាម្ចាស់បានផ្ដល់ | តាមហេតុផលគេប្រព្រឹត្ត | ។ |

## ទំនុកតម្កើងលេខ ៩៥ (៩៤) បទកាកគតិ

១- យើងស្រែកច្រៀងឡើង សរសើរតម្កើង ថ្វាយព្រះអម្ចាស់ ដោយចិត្តអបអរ
សាទរថ្វាយព្រះ ជាថ្មមាំណាស់ ជួយសង្គ្រោះយើង ។
២- យើងនាំគ្នីគ្នា រួតរះម្នីម្នា ជួបភក្ត្រព្រះអង្គ ទាំងអរព្រះគុណ
ស្មូត្របទតម្កើង កោតសរសើរទ្រង់ អស់កល្បអង្វែង ។
៣- ដ្បិតព្រះអម្ចាស់ ប្រសើរពេកណាស់ វិសេសក្រៃលែង ទ្រង់គឺជាក្សត្រ
សោយរាជ្យអង្វែង ខ្ពស់ខ្ពង់ស្ងប់ស្ងែង លើសព្រះទាំងឡាយ ។
៤- ព្រះអង្គគ្រប់គ្រង លើអ្វីទាំងពួង ឥតមានខ្វល់ខ្វាយ តាំងពីបាតដី
សន្លឹមអន្លាយ ដល់ទីសែនឆ្ងាយ កំពូលភ្នំផង ។
៥- ព្រះអង្គជាម្ចាស់ សមុទ្រទាំងអស់ មើលថែគ្រប់គ្រង ព្រោះទ្រង់បង្កើត
សមុទ្រមកផង ដីល្អកន្លង ជាស្នាដៃទ្រង់ ។
៦- ចូរនាំគ្នីគ្នា គោរពវន្ទា ក្រាបថ្វាយព្រះអង្គ យើងក្រាបចំពោះ
ព្រះភក្ត្រជូរផង់ បារមីត្រចង់ ទ្រង់បង្កើតយើង ។
៧- ព្រះអង្គជាព្រះ នៃយើងទាំងអស់ បារមីថ្កុំថ្កើង ទ្រង់ជាគង្វាល
ដឹកនាំពួកយើង ថ្ងៃនេះព្រះអង្គ បន្លឺឡើងថា ។
៨- មិនត្រូវផ្ដេសផ្ដាស ដូចកាលបោរបះ នៅមេរីបា ដូចថ្ងៃល្បងល
នៅឯម៉ាសា ក្នុងវាលឯកា ទីរហោស្ថាន ។
៩- គឺបុព្វបុរស នៃអ្នកទាំងអស់ ចិត្តគេសាមាន្យ គេបានល្បងល
ទោះបីគេបាន ឃើញកិច្ចប៉ុន្មាន យើងបានប្រព្រឹត្ត ។
១០- ក្នុងអំឡុងពេល សែសិបឆ្នាំដែល យើងចាំមិនបាត់ មនុស្សជំនាន់នោះ
ឲ្យយើងឆ្អែតចិត្ត គេធ្វើទុច្ចរិត ឲ្យយើងពោលថា ។
ពួកគេទាំងនេះ ជាប្រជារាស្ត្រ មានចិត្តឫស្យា ជាមនុស្សវង្វេង
មិនស្គាល់មាគ៌ា ពួកគេគ្រប់គ្នា មិនស្ដាប់យើងឡើយ ។
១១- ហេតុនេះយើងខឹង ពួកគេយ៉ាងខ្លាំង ឥតមានល្ហែល្ហើយ យើងប្ដេជ្ញាចិត្ត
មិនជួយគេឡើយ ព្រមទាំងមិនឲ្យ គេចូលក្នុងស្រុក ។

## ទំនុកតម្កើងលេខ ៩៦ (៩៥) បទព្រហ្មគីតិ

១- ចូរច្រៀងបទថ្មីថ្វាយ ព្រះម្ចាស់ថ្លៃកុំឈរឈប់
មនុស្សនៅលើពិភព ច្រៀងកុំឈប់ថ្វាយព្រះអង្គ ។

២- ចូរច្រៀងថ្វាយព្រះម្ចាស់ តម្កើងព្រះនាមត្រចង់
ប្រកាសរាល់ថ្ងៃផង ពីបំណាងដ៏ថ្លាថ្លៃ ។
៣- ចូរប្រកាសនៅម្ដុំ ចំណោមក្រុមជាតិទីទៃ
នូវរុងរឿងសិរី ព្រះហស្តថ្លៃដ៏អស្ចារ្យ ។
៤- ដ្បិតព្រះម្ចាស់ឧត្តម យើងត្រូវខំសរសើរថា
អស់ពីដួងចិន្ដា ព្រះក្សត្រាប្រសើរខ្ពស់ ។
៥- ព្រះនៃសាសន៍ផ្សេងណា មិនបានការអ្វីទាំងអស់
រីឯព្រះអម្ចាស់ ទ្រង់ជាក់ច្បាស់សាងផ្ទៃមេឃ ។
៦- មានពន្លឺរស្មី ថែងចាំងក្រៃល្អពន់ពេក
ដំណាក់គន់គាប់ភ្នែក បារមីប្លែកថ្កើងត្រចង់ ។
៧- ប្រជាទាំងឡាយអើយ កុំកន្តើយចូរតម្រង់
លើកតម្កើងព្រះអង្គ ថ្លៃងឥតហ្មងពីឫទ្ធា ។
៨- លើកតម្កើងសិរី រុងរឿងជ័យព្រះនាមា
យកតង្វាយគ្រប់គ្នា ទៅព្រះវិហារថ្វាយក្សត្រា ។
៩- ចូរក្រាបថ្វាយបង្គំ ពេលទ្រង់សម្ដែងបាដិហារិយ៍
មនុស្សលើផែនលោកា ញ័រកាយាចំពោះភក្ដ្រ ។
១០- ចូរប្រកាសនៅម្ដុំ ចំណោមក្រុមជាតិច្រើននាក់
ថាទ្រង់គ្រងរាជ្យជាក់ ឥតបែកបាក់រឹងមាំល្អ ។
ព្រះម្ចាស់គ្រប់គ្រងលើ សព្វសារពើមានអំណរ
ពេញដោយយុត្តិធម៌ រាស្ត្រអបអរពន់ពេកក្រៃ ។
១១- សូមឲ្យអស់ផ្ទៃមេឃ ផែនដីស្រែកកុំសំចៃ
សមុទ្រមានទឹកប្រែ និងអ្វីៗមានសង្ឃឹម ។
១២- ចូរឲ្យស្រែចំការ អ្វីសព្វសារអរញញឹម
ឲ្យដើមឈើរេរាំ លោតទន្ទ្រាំមុខព្រះម្ចាស់ ។
១៣- ដ្បិតព្រះអង្គយាងមក វិនិច្ឆ័យរកយុត្តិធម៌ណាស់
កាត់ក្ដីប្រជាច្បាស់ គ្មានក្រឡះដោយទៀងត្រង់ ។

**ទំនុកតម្កើងលេខ ៩៧ (៩៦)** **បទពាក្យ ៧**

១- ព្រះជាអម្ចាស់ទ្រង់គ្រងរាជ្យ ពេញដោយអំណាចដ៏យូរលង់
ចូរឲ្យផែនដីរីករាយឡើង កោះទាំងឡាយផងអរសប្បាយ ។
២- មានពពកខ្មួលខ្មៅងងឹត ព័ទ្ធពេនជុំជិតព្រះម្ចាស់ថ្លៃ
ព្រះអង្គគ្រងរាជ្យដោយប្រពៃ សុចរិតថ្លាថ្លៃល្អត្រចង់ ។
៣- មានភ្លើងឆេះនៅមុខព្រះម្ចាស់ សត្រូវច្រើនណាស់ត្រូវបាត់បង់
អ្នកដែលប្រឆាំងច្បាំងព្រះអង្គ គ្មានសល់ម្នាក់ផងក្ស័យសង្ខារ ។
៤- មានផ្លេកបន្ទោរជះពន្លឺ ខ្ទររខ្ទារខ្ទើសព្វលោកា
ផែនដីតក់ស្លុតឥតឧបមា ញ័ររអស់កាយាដោយភិតភ័យ ។
៥- ភ្នំនានាដែលនៅចំពោះ ភក្ត្រព្រះអម្ចាស់ត្រូវអន្តរាយ
ដូចជាក្រមួនត្រូវរលាយ ដោយកម្ដៅថ្ងៃនៅមិនបាន ។
៦- ផ្ទៃមេឃក៏បានស្រែកប្រកាស ពីក្ដីសប្បុរសល្អថ្កើងថ្កាន
ឲ្យប្រជារាស្ត្រទាំងប៉ុន្មាន នៅគ្រប់ទីស្ថានបានដឹងយល់ ។
៧- អស់អ្នកដែលថ្វាយបង្គំព្រះ ក្លែងក្លាយទាំងអស់នឹងកង្វល់
អួតអាងពីការគោរពដល់ ព្រះឥតបានផលត្រូវអាម៉ាស់ ។
ឱព្រះទាំងឡាយមានគរគោក ច្រើននៅលើលោកចូររួតរះ
ក្រាបថ្វាយបង្គំព្រះអម្ចាស់ គឺទ្រង់ជាព្រះលើលោកា ។
៨- បពិត្រព្រះម្ចាស់ពេលដែលក្រុង ស៊ីយ៉ូនបានដឹងដំណឹងថា
ព្រះអង្គវិនិច្ឆ័យដូច្នេះណា អ្នកក្រុងយូដាសប្បាយក្រៃ ។
៩- បពិត្រព្រះជាអម្ចាស់ខ្ញុំ ព្រះអង្គឧត្ដមផុតផែនដី
ប្រសើរលើសអស់ព្រះដទៃ ទោះព្រះជ្រៀងក្ដីមិនស្មើផង ។
១០- អ្នកដែលស្រឡាញ់ព្រះអម្ចាស់ និងអ្នកដែលស្មោះស្ម័គ្រទៀងត្រង់
ចូរស្អប់អំពើកាចយង់ឃ្នង ព្រះអង្គនឹងរងថែរក្សា ។
១១- មានទាំងពន្លឺបំភ្លឺមនុស្ស មានចិត្តសប្បុរសសុចរិតថ្លា
ជនដែលទៀងត្រង់គ្រប់អាត្មា អរឥតឧបមាសប្បាយក្រៃ ។

១២- ឱពួកអ្នកសុចរិតទាំងឡាយ ចូរអ្នករីករាយកុំគិតអ្វី
ចំពោះកិច្ចការព្រះម្ចាស់ថ្លៃ ប្រព្រឹត្តរាល់ថ្ងៃកន្លងមក ។

## ទំនុកតម្កើងលេខ ៩៨ (៩៧) បទកាកគតិ

១- ចូរច្រៀងបទថ្មី ថ្វាយព្រះម្ចាស់ថ្លៃ កុំភ្លេចឡើយណា ដ្បិតទ្រង់ប្រព្រឹត្ត
សព្វកិច្ចអស្ចារ្យ ដោយឫទ្ធិចេស្តា យកជ័យជម្នះ ។
២- ព្រះម្ចាស់បង្ហាញ ប្រជាឲ្យឃើញ ពីកាសង្គ្រោះ ព្រះអង្គសម្ដែង
ឲ្យគេទាំងអស់ ឃើញសុចរិតស្មោះ របស់ព្រះអង្គ ។
៣- ព្រះអង្គនៅតែ សម្ដែងឥតប្រែ ករុណាត្រចង់ ព្រះទ័យស្មោះស្ម័គ្រ
អ៊ីស្រាអែលផង សុចរិតឥតហ្មង ចងចាំទាំងអស់ ។
មនុស្សម្នាមូលមីរ រស់នៅគ្រប់ទី ឆ្វាយទាំងស្រីប្រុស នៃភពផែនដី
ឃើញការសង្គ្រោះ ព្រះម្ចាស់របស់ យើងគ្រប់ៗគ្នា ។
៤- ជនទាំងប្រុសស្រី នៅលើផែនដី រៀបចំអង្គា អបអរសាទរ
ថ្វាយព្រះនាមា ស្រែកហ៊ោរខ្ញៀវខ្ញា ដោយតូរ្យតន្ត្រី ។
៥- សូមផ្ញើចិត្តកាយ ដេញទាំងពិណថ្វាយ ព្រះធ្លាប់ប្រណី ព្រោះព្រះអង្គនោះ
ធ្លាប់ថ្នមបមបី ថែទាំយប់ថ្ងៃ រៀងរាល់វេលា ។
៦- ចូរនាំគ្នាផ្លុំ ត្រែស្នែងប្រគុំ ថ្វាយព្រះរាជា អបអរសាទរ
អង្គព្រះនាមា ខ្ពស់លើពសុធា គ្មានអ្វីស្មើព្រះ ។
៧- ចូរសមុទ្រលាន់ រលករាប់ពាន់ រំពងអាកាស ចូរឲ្យផែនដី
និងអ្វីទាំងអស់ មានជីវិតរស់ ស្រែកឮអឺងកង ។
៨- ទន្លេទាំងឡាយ ចូរអសប្បាយ សាទរត្រសង ចូរភ្នំទាំងអស់
ស្រែកហ៊ោអឺងកង ព្រមៗគ្នាឡើង ដោយស័ព្ទខ្ញៀវខ្ញា ។
៩- ចំពោះព្រះភក្ត្រ ព្រះអម្ចាស់ជាក់ គ្រប់គ្រងលោកា លើភពផែនដី
យុត្តិធម៌ថ្លៃថ្លា អស់រាស្ត្រប្រជា ទៀងត្រង់បរិសុទ្ធ ។

## ទំនុកតម្កើងលេខ ៩៩ (៩៨) បទពាក្យ ៧

១- ព្រះជាអម្ចាស់ទ្រង់គ្រងរាជ្យ ប្រជារាស្ត្រខ្លាចភ័យមមើ
ផែនដីកក្រើកញ័ររង្គើ ព្រះអង្គគង់លើខេរ៉ូប៊ីន ។

| | | | |
|---|---|---|---|
| ២- | ព្រះអម្ចាស់ជាព្រះឧត្តម | ខ្ពង់ខ្ពស់ស្ដេស្ដីមលើស៊ីយ៉ូន | |
| | ព្រះអង្គខ្ពស់ហួសអស់ជាតិជន | គ្រប់ទីតំបន់លើលោកា | ។ |
| ៣- | មនុស្សម្នាគ្រប់រូបត្រូវតម្កើង | ព្រះនាមរុងរឿងដ៏អស្ចារ្យ | |
| | គួរឲ្យស្ញែងខ្លាចព្រះនាមា | ព្រះអង្គពិតបាឥតមានហ្មង | ។ |
| ៤- | បពិត្រព្រះម្ចាស់ជាមហាក្សត្រ | បារមីពេកក្លាត់ក្ដីភ្លឺត្រចង់ | |
| | ទ្រង់ជាក្សត្រាតែមួយអង្គ | សុចរិតត្រឹមត្រង់យុត្តិធម៌ | ។ |
| | ព្រះអង្គបានរៀបតាក់តែងច្បាប់ | ឲ្យមានសព្វគ្រប់ដោយស្មោះសរ | |
| | សុចរិតទៀងត្រង់ស្រស់បវរ | ក្នុងស្រុកដ៏ល្អអ៊ីស្រាអែល | ។ |
| ៥- | ចូរលើកតម្កើងព្រះអម្ចាស់ | ព្រះអង្គជាព្រះយើងមិនដែល | |
| | ស្គាល់ទុក្ខលំបាកដ៏ក្រាស់ក្រៃល | ព្រះអ៊ីស្រាអែលព្រះវិសុទ្ធ | ។ |
| ៦- | លោកម៉ូសេជាបូជាចារ្យ | ដែលមកត្រៀបត្រាពេញជុំជិត | |
| | អរ៉ុនជាបូជាចារ្យពិត | ចំណោមអ្នកស្និទ្ធនឹងព្រះអង្គ | ។ |
| | លោកសាមូអែលជាមនុស្សម្នាក់ | ក្នុងចំណោមអ្នកអង្វរទ្រង់ | |
| | ទាំងអស់គ្នាទូលថ្វាយព្រះអង្គ | នោះទ្រង់ឆ្លើយត្រង់មិនរារែក | ។ |
| ៧- | ព្រះអង្គមានព្រះបន្ទូលមក | ពីក្នុងពពកខ្មៅអនេក | |
| | លោកក៏កាន់តាមមិនអល់អែក | ឥតមានប្រកែកច្បាស់ព្រះអង្គ | ។ |
| ៨- | បពិត្រព្រះម្ចាស់ព្រះរបស់ | យើងខ្ញុំទាំងអស់ខ្ពស់ឧត្តុង្គ | |
| | ព្រះអង្គតបឆ្លើយមិនបង្អង់ | ទោះបីជាទ្រង់ដាក់ទោសក្ដី | ។ |
| | ព្រោះតែកំហុសលោកប្រព្រឹត្ត | មានពីអាឌីត (អតីត) មិនថាអី | |
| | ព្រះអង្គតែងមានព្រះហឫទ័យ | អត់ធ្មត់ខន្តីលោកជានិច្ច | ។ |
| ៩- | ចូរលើតម្កើងព្រះអម្ចាស់ | ជាព្រះរបស់យើងកុំភ្លេច | |
| | ចូរក្រាបបង្គំកុំកែព្រះ | តម្រង់ជានិច្ចភ្នំវិសុទ្ធ | ។ |
| | ដ្បិតព្រះអម្ចាស់គឺជាព្រះ | នៃយើងទាំងអស់ខ្ពស់បំផុត | |
| | ជាម្ចាស់ផែនដីមេឃសមុទ្រ | អស់ទាំងសព្វសត្វលើលោកា | ។ |

## ទំនុកតម្កើងលេខ ១០០ (៩៩) **បទកាកគតិ**

| | | | | |
|---|---|---|---|---|
| ១- | មនុស្សលើផែនដី | ទាំងប្រុសទាំងស្រី | ចូរអបអរឡើង | សាទរព្រះម្ចាស់ |
| | ជាព្រះថ្កុំថ្កើង | ព្រះម្ចាស់នៃយើង | កុំរាឡើយណា | ។ |

២- នាំគ្នាគោរព ទាំងថ្ងៃទាំងយប់ ដោយចិត្តជ្រះថ្លា នាំគ្នាមកជិត
អង្គព្រះបេស្កា ច្រៀងហោរខ្សៀវខ្សា ដោយអរសប្បាយ ។
៣- ចូរដឹងគ្រប់គ្នា ថាព្រះម្ចាស់ជា ព្រះយើងគ្រប់កាយ ជាព្រះអម្ចាស់
ពិតឥតក្លែងក្លាយ បង្កើតយើងហើយ ទ្រង់ថែថ្នាក់ថ្នម ។
៤- យើងនាំគ្នីគ្នា ចូលកុំរួញរា ដំណាក់សក្តិសម ទាំងអរព្រះគុណ
ព្រះម្ចាស់ឧត្តម សរសើរបង្គំ ព្រះនាមព្រះអង្គ ។
៥- ដ្បិតព្រះអម្ចាស់ ទ្រង់សប្បុរសណាស់ ករុណាហ្មត់ហ្មង គង់នៅស្ថិតស្ថេរ
អង្វែងកន្លង ស្មោះស្ម័គ្របា្រស់ច្បង អស់កល្បតទៅ ។

## ទំនុកតម្កើងលេខ ១០១ (១០០) បទពាក្យ ៧

១- បពិត្រព្រះម្ចាស់ខ្ញុំនឹងច្រៀង រៀបរាប់មិនល្អៀងពីព្រះទ័យ
មេត្តាករុណាដ៏ថ្លាថ្លៃ ទាំងស្មូត្របទថ្វាយព្រះអង្គផង ។
២- យើងខ្ញុំនឹងយកចិត្តទុកដាក់ នឹងមាគ៌ាដាក់ល្អឥតហ្មង
តើពេលណាទៅទើបព្រះអង្គ យាងរកខ្ញុំផងទាំងគ្រួសារ ។
៣- យើងខ្ញុំមិនដែលទៅចូលចិត្ត អំពើឧក្រិដ្ឋពាលឫស្យា
មិនចូលចិត្តអ្នកក្បត់សាវ៉ា ពាលឥតមេត្តាមិនចង់ជួប ។
៤- រូបខ្ញុំមិនឲ្យមនុស្សទុច្ចរិត ខិតចូលមកជិតទោះថ្ងៃយប់
ហើយក៏មិនចង់ទៅសេពគប់ ជំពាក់ជំពប់មនុស្សអាក្រក់ ។
៥- យើងខ្ញុំបិទមាត់អ្នកនិយាយ បរិហារពីក្រោយដោយគម្រក់
ខ្ញុំមិនអាចទ្រាំចំពោះអ្នក វាយឫកហួសថ្នាក់អួតបំប៉ោង ។
៦- ខ្ញុំនឹងស្វែងរកអ្នកមានចិត្ត ស្មោះត្រង់សុចរិតមិនកាចកោង
ឲ្យគេកាន់កាប់ក្នុងស្រុកយើង មិនបេះឆ្មៃឆ្មើងនៅជាមួយ ។
៧- រីឯមនុស្សដែលបោកប្រាស ខ្ញុំមិនឲ្យរស់ក្នុងផ្ទះឡើយ
អ្នកនិយាយភូតភរក៏ដោយ មិនអាចកៀកកើយជិតខ្ញុំបាន ។
៨- រាល់ព្រឹកខ្ញុំតែងតែបិទមាត់ ពួកមនុស្សទុច្ចរិតទាំងប៉ុន្មាន
ខ្ញុំនឹងដកពួកគេឲ្យបាន ពីក្រុងថ្កើងថ្កាននៃព្រះអង្គ ។

## ទំនុកតម្កើងលេខ ១០២ (១០១) បទព្រហ្មគីតិ

២- ឱព្រះអម្ចាស់អើយ សូមផ្ទៀងហើយព្រះសណ្ដាប់
សម្រែកខ្ញុំរ៉ាយរ៉ាប់ សូមទ្រង់ស្ដាប់យើងខ្ញុំផង ។
៣- ពេលខ្ញុំមានអាសន្ន កុំលាក់ពួនភក្ត្រព្រះអង្គ
ខ្ញុំស្រែកហៅរកទ្រង់ សូមឆ្លើយផងកុំស្ងៀមស្ងាត់ ។
៤- ព្រោះជន្មជីវិតខ្ញុំ ត្រូវរលំរលាយខ្ចាត់
ដូចផ្សែងត្រូវខ្យល់ផាត់ ខ្លួនប្រាណប្រើតស្គមរីងរៃ ។
៥- រូបខ្ញុំអស់ទឹកចិត្ត ដូចស្មៅស្វិតក្រៀមត្រូវថ្ងៃ
ទោះជាអាហារក្ដី ក៏ខ្ញុំលៃលែងនឹកនា ។
៦- រូបខ្ញុំចេះតែថ្ងូរ ទ្បូញទ្រហោររាល់វេលា
លែងជាមនុស្សល្អជា សែនវេទនាស្បែកគ្របឆ្អឹង ។
៧- រូបខ្ញុំដូចសត្វក្អែក ដែលតែងស្រែកហោះកាត់បឹង
ក្នុងព្រៃស្មសានឈឹង ដូចសត្វជ្រឹងក្នុងព្រឹក្សព្រៃ ។
៨- ខ្ញុំដេកមិនលក់សោះ សែនក្រៀមក្រោះអស់ជើងដៃ
បីដូចសត្វបក្សី ទាំងយប់ថ្ងៃទំលើផ្ទះ ។
៩- ជារៀងរាល់ខែថ្ងៃ ខ្មាំងចង្រៃមាក់ងាយណាស់
គេបានយកទាំងឈ្មោះ ទៅដាក់ដោះបណ្ដាសា ។
១០- ពេលខ្ញុំបរិភោគ ទាំងទុក្ខសោកឥតឧបមា
ខ្ញុំបរិភោគពេលណា ទឹកនេត្រាហូរសស្រាក់ ។
១១- ពីព្រោះព្រះពិរោធ ទ្រង់ខ្ញាល់ក្រោធតែខ្ញុំម្នាក់
ទ្រង់ឥតមានថ្នមថ្នាក់ បោះទម្លាក់ខ្ញុំវេទនា ។
១២- ជីវិតខ្ញុំហាក់ដូច ស្រមោលតូចពេលសន្ធ្យា
ដូចស្មៅខ្វះគង្គា គ្មានមនុស្សម្នានៅថែទាំ ។
១៣- បពិត្រព្រះអម្ចាស់ គ្រងរាជ្យអស់កល្បយូរឆ្នាំ
គេនឹងរំលឹកចាំ យូរខែឆ្នាំអង្វែងទៅ ។
១៤- ព្រះអង្គសព្វព្រះទ័យ នឹងបុរីនេះពេកក្រៃ
ស៊ីយ៉ូនពេលឥឡូវ ទ្រង់តម្រូវអាណិតហើយ ។

១៥- អ្នកបម្រើព្រះអង្គ ស្រឡាញ់ក្រុងមិនកន្តើយ
ទោះជាបែកបាក់ហើយ មិនបោលឡើយចាំជានិច្ច ។
១៦- សូមឲ្យជនគ្រប់សាសន៍ កោតខ្លាចព្រះកុំមានភ្លេច
សូមឲ្យអស់ទាំងស្ដេច ចាំជានិច្ចកោតខ្លាចទ្រង់ ។
១៧- នៅពេលព្រះអម្ចាស់ សាងស្រឡះស៊ីយ៉ូនក្រុង
ទ្រង់ស្ដែងសិរីរុង ដ៏ត្រចង់ឲ្យគេយល់ ។
១៨- ពេលនោះទ្រង់នឹងបែរ ព្រះភក្ត្រវេទតមកដល់
មនុស្សលែងខ្វាយខ្វល់ ទ្រង់ទទួលពាក្យយើងហើយ ។
១៩- សូមកត់ក្ដីនេះចុះ ទុកឲ្យមនុស្សជំនាន់ក្រោយ
ប្រជារាស្ត្រកើតហើយ កុំកន្តើយថ្កើងព្រះអង្គ ។
២០- ព្រះអម្ចាស់ទតពី សក្ការៈទីដ៏ត្រចង់
ស្ថានសួគ៌សុខឥតហ្មង មិនរំលងសព្វដែនដី ។
២១- ដើម្បីស្ដាប់សម្រែក ពួកឈ្លើយស្រែកទាំងយប់ថ្ងៃ
អ្នកដែលត្រូវក្សិណក្ស័យ គេកាត់ក្ដីមិនសុចរិត ។
២២-គេនឹងប្រកាសប្រាប់ ព្រះនាមគាប់ម្ចាស់វរមិត្ត
នៅក្រុងស៊ីយ៉ូនពិត តម្កើងឫទ្ធិនៅសាឡឹម ។
២៣-គឺពេលដែលប្រជា ជាតិនានាមកជួបជុំ
ដើម្បីគោរពសុំ បម្រើអម្ចាស់ជាព្រះ ។
២៤- ពេលខ្ញុំពេញកម្លាំង ខ្ញុំក្លាខ្លាំងមិនហេវខ្សោះ
ទ្រង់ឲ្យខ្ញុំទន់អស់ ហើយបន្សោះទាំងជីវិត ។
២៥- ហេតុនេះហើយទើបខ្ញុំ លើកដៃសុំទ្រង់អាណិត
សូមកុំដកជីវិត ពេលខ្ញុំឋិតមិនទាន់ចាស់ ។
២៦- ទ្រង់បង្កើតដែនដី យូរយារក្រៃអង្វែងណាស់
ផ្ទៃមេឃអ្វីទាំងអស់ ស្នាព្រះហស្តព្រះអង្គដែរ ។
២៧-ផ្ទៃមេឃនិងដែនដី ត្រូវរលាយបែកហូរហែ
តែទ្រង់ឥតកែប្រែ គង់ស្ថិតស្ថេរជាប់រហូត ។

២៨- ព្រះម្ចាស់គង់ជាខែល    នៅដៃដែលមិនរបូត
ព្រះជន្មមិនរលត់    មិនចេះផុតគ្មានបញ្ចប់ ។
២៩- កូនចៅរបស់ខ្ញុំ    នៅជួបជុំបម្រើស្រាប់
រស់ដោយសុខគួរគាប់    ទ្រង់គង់ជាប់ថែកូនចៅ ។

## ទំនុកតម្កើងលេខ ១០៣ (១០២)    បទកាកគតិ

១- ខ្ញុំសូមសរសើរ    ព្រះគ្មានអ្វីស្មើ    អស់ពីដួងចិត្ត    ខ្ញុំសូមតម្កើង
នាមដ៏វិសុទ្ធ    ព្រះដ៏មានឫទ្ធិ    ផុតលើលោកា ។
២- ខ្ញុំសូមតម្កើង    សរសើរលើកឡើង    អស់ពីចិន្ដា    ខ្ញុំសូមរំលឹក
ព្រះហស្តអស្ចារ្យ    សប្បុរសករុណា    មិនបំភ្លេចឡើយ ។
៣- ព្រះអង្គអត់ទោស    នូវរាល់កំហុស    ដែលមានមកហើយ    ខ្ញុំបានប្រព្រឹត្ត
ព្រះអង្គប្រោសឲ្យ    ខ្ញុំបានធូរស្បើយ    ផុតរោគសោកសៅ ។
៤- ព្រះអង្គរំដោះ    ជីវិតឲ្យរស់    ផុតពីរណ្ដៅ    ព្រះអង្គអាណិត
អាសូរពេកកូវ    ខ្ញុំផុតសោកសៅ    ដោយទ្រង់មេត្តា ។
៥- ព្រះអង្គប្រទាន    ឲ្យខ្ញុំរស់រាន    ដោយក្ដីសុខា    ឲ្យមានកម្លាំង
ដូចដំរីសារ    មានទាំងសង្ខា    វែងដូចឥន្ទ្រី ។
៦- ព្រះម្ចាស់ប្រព្រឹត្ត    សព្វអស់ការកិច្ច    ល្អល្អះគ្មានពីរ    ហឫទ័យសុចរិត
យុត្តិធម៌គ្រប់ទី    ដល់អស់ជីវី    ត្រូវគេជិះជាន់ ។
៧- ព្រះអង្គសម្ដែង    ឫទ្ធីគួរស្ញែង    ឲ្យម៉ូសេបាន    ស្គាល់មាគ៌ាទ្រង់
គ្មានអ្វីរំខាន    ប្រជាគ្រប់ប្រាណ    ដឹងហេតុអស្ចារ្យ ។
៨- ព្រះអម្ចាស់ថ្លៃ    មានព្រះហឫទ័យ    អាណិតករុណា    ប្រណីសន្ដោស
គ្រប់ពេលវេលា    ដល់ជនគ្រប់គ្នា    មិនឲ្យមានភ័យ ។
៩- ទ្រង់មិនបន្ទោស    ប្រើពាក្យគំរោះ    ដាក់យើងរាល់ថ្ងៃ    ទ្រង់មិនពិរោធ
មិនខឹងជេរស្ដី    ហើយតែងប្រណី    ដល់យើងគ្រប់គ្នា ។
១០- ព្រះអង្គមិនដាក់    ទោសយើងម្នាក់ៗ    ឲ្យឈឺគ្រាំគ្រា    សមតាមអំពើ
បាបច្រើនមហិមា    ទ្រង់តែងគាំពារ    មិនយកទោសពៃរ៍ ។

១១-មេឃនៅខ្ពស់ឆ្ងាយ សន្ធឹមអន្លាយ ពីភពផែនដី ព្រះទ័យព្រះម្ចាស់
ដែលធ្លាប់ប្រណី ក៏នៅខ្ពស់ឆ្ងាយ យ៉ាងដូច្នោះដែរ ។
១២-ទិសកើតទិសលិច ឆ្ងាយគ្នាមិនតិច ឥតមានកែប្រែ ព្រះអង្គធ្វើឲ្យ
អំពើបាបបែរ ឆ្ងាយមិនជិតទេ ពីយើងយ៉ាងនោះ ។
១៣-ឪពុកអាណិត ថ្នាក់ថ្នមផ្គេកផ្គិត កូនៗទាំងអស់ ព្រះក៏មេត្តា
អាសូរស្រណោះ ដល់អ្នកដែលស្មោះ គោរពរាល់ថ្ងៃ ។
១៤-ព្រះអង្គជ្រាបថា មនុស្សយើងនេះណា កើតមកពីអ្វី ព្រះអង្គមិនភ្លេច
យើងទាំងប្រុសស្រី គឺកើតពីដី ដែលសូនមកទេ ។
១៥- អាយុជីវិត មនុស្សយើងរីកស្វិត ផ្លាស់ប្តូរប្រួលប្រែ ដូចផ្កាដែលរីក
នៅតាមវាលដែរ ឬស្មៅតែងតែ ស្រពោនក្រៀមក្រំ ។
១៦- ពេលខ្យល់បក់បោកផ្កាក៏វិយោគ ទាំងទុក្ខរណ្តំ ត្រូវរោយលំអង
ស្រពោនខ្មេចខ្ទាំ ឥតមានទុកស្នាម វក់វីរខ្ទាំខ្មេច ។
១៧-តែព្រះហឫទ័យ ករុណាប្រណី ព្រះអង្គមិនភ្លេច មេត្តាដល់អ្នក
កោតខ្លាចជានិច្ច មិនដែលកែគេច ដរាបរៀងទៅ ។
១៨-ប្រសិនគេកាន់ ជាប់តាមសម្ពន្ធ មិនមានអាស្រូវ ទាំងប្រព្រឹត្តតាម
បញ្ញាជាផ្លូវ ព្រះល្អពេកក្រូវ ឥតភ្លេចសោះនោះ ។
១៩-ព្រះអង្គបានតាំង ព្រះរាជបល្ល័ង្ក នៅទីស្ថានខ្ពស់ គឺបរមសុខ
ឥតបីមានមោះ គ្រងរាជ្យទាំងអស់ មិនចន្លោះអ្វី ។
២០-ទេវទូតដ៏ខ្លាំង របស់ព្រះអង្គ ពូកែពេកក្រៃ លោកតែងអនុវត្ត
តាមបន្ទូលថ្លៃ ចូរកុំសង្ស័យ តម្កើងព្រះម្ចាស់ ។
២១-អស់ហ្វូងតារា នៅជុំត្រៀបត្រា មូលមីរដេរដាស អ្នកតែងបម្រើ
តាមព្រះទ័យព្រះ តម្កើងអម្ចាស់ ព្រះខ្ពស់ពេកក្រៃ ។
២២-គ្រប់ស្នាព្រះហស្ត ទាំងឡាយរបស់ ព្រះអម្ចាស់ថ្លៃ គឺទាំងសត្វលោក
ទាំងអស់លើដី នៅទីណាក្តី តម្កើងព្រះអង្គ ។

## ទំនុកតម្កើងលេខ ១០៤ (១០៣) បទពាក្យ ៧

១- ខ្ញុំសូមតម្កើងព្រះអម្ចាស់ ប្រសើរខ្លាំងណាស់អស់ពីចិត្ត
ព្រះអង្គជាព្រះនៃខ្ញុំពិត ឧត្តមបំផុតលើលោកា ។
២- ទ្រង់យកពន្លឺមកដណ្ដប់ គ្រងគ្រប់អង្គជាប់ជាភូសា
ទ្រង់លាតអស់ទាំងហ្វូងតារា ផ្ទៃមេឃផងណាជាពន្លា ។
៣- ទ្រង់សង់ដំណាក់ខ្ពស់អនេក ខ្ពស់លើសផ្ទៃមេឃអ្វីនានា
ទ្រង់យកពពកវាយោជា រាជរថបរពាជំនិះជ័យ ។
៤- ព្រះអង្គយកខ្យល់ឲ្យនាំសារ រន្ទះផងណាចាំរំពៃ
ទាំងផ្លេកបន្ទោរក៏ឃ្លាតឃ្លៃ បម្រើម្ចាស់ថ្លៃគ្រប់អន្លើ ។
៥- រីឯផែនដីមហាធំ ទ្រង់បានតាំងមាំឥតរង្គើ
នៅលើគ្រឹះរឹងឥតអ្វីស្មើ ឥតមានរង្គើមាំមួនក្រៃ ។
៦- ព្រះអង្គយកមហាសាគរ មកគ្របពីលើភពផែនដី
ដូចជាអាវប៉ាក់ល្អឥតបី លើភ្នំខ្ពស់ក្រៃមានទឹកដែរ ។
៧- ពេលឮព្រះអង្គស្រែកគំរាម ទឹកមិននៅស្ងៀមត្រឡប់បែរ
ផ្គរព្រះអម្ចាស់លាន់ហួរហែរ វាភ័យម្ល៉េះទេរត់បាត់អស់ ។
៨- ទឹកខ្លះនៅលើកំពូលភ្នំ ទឹកខ្លះទៅផ្ដុំធ្លាក់តាមជ្រោះ
ទៅកាន់កន្លែងដែលព្រះម្ចាស់ កំណត់មកនោះរួចស្រេចហើយ ។
៩- ព្រះអង្គដាក់ខណ្ឌសីមាពាំង បាំងការពាររាំងមិនកន្តើយ
ដើម្បីស្កាត់ទឹកទប់មិនឲ្យ ជន់លិចបានឡើយដីទាំងអស់ ។
១០- ទ្រង់បញ្ជូនទឹកពីប្រភព ឲ្យហូរសាយសព្វទៅក្នុងជ្រោះ
ហូរតាមជ្រលងភ្នំទាំងអស់ មិនមានចន្លោះសព្វទិសា ។
១១- សត្វទាំងប៉ុន្មានមកផឹកទឹក មានច្រើនសន្ធឹកសព្វម្រឹគា
លាព្រៃក៏រួតរះម្ទីម្ទា ផឹកទាំងអស់គ្នាបំបាត់ស្រេក ។
១២- បក្សីបក្សាធ្វើសំបុក រស់នៅអែអុកច្រើនពន់ពេក
នាំគ្នាយំពិរោះអនេក នៅគ្រប់តាមមែកដើមព្រឹក្សា ។

១៣- ព្រះអង្គស្រោចស្រពដីទាំងឡាយ　　ពីស្ថានខ្ពស់ឆ្ងាយឥតឧបមា
ទ្រង់ប្រទានឲ្យមានគង្គា　　បរិបូណ៌ហូរហៀរលើផែនដី ។
១៤- ព្រះអង្គធ្វើឲ្យមានដុះស្មៅ　　ឲ្យដល់សត្វទៅជាចំណី
ដំណាំស្អែកស្កុះច្រើនពេញដី　　ដល់មនុស្សប្រុសស្រីបរិភោគ្គា ។
១៥- មានទាំងស្រាទំពាំងបាយជូរ　　គេផឹកបរិបូណ៌ច្រើនក្រៃណា
មានប្រេងលាបមុខស្រស់សង្ហា　　ដោយចិត្តក្លៀវក្លាសប្បាយខ្លាំង ។
មិនតែប៉ុណ្ណោះមានអាហារ　　ឆីរួចកាលណាមានកម្លាំង
សាច់ឈាមស្រស់បស់លែងស្លេកស្លាំង　　ដូចមនុស្សរីងរាំងខ្វះចំណី ។
១៦- សូម្បីដើមឈើដែលទ្រង់ដាំ　　បែកមែកត្រសុំម្លប់ត្រឈៃ
មានទឹកគ្រប់គ្រាន់ជ្រើមជោគដី　　ដូចឈើក្នុងព្រៃភ្នំលីបង់ ។
១៧- បក្សាបក្សីធ្វើសំបុក　　លើដើមឈើញ៉ុកនៅរញ្ញង់
សត្វកុកមកធ្វើទ្រនំផង　　បានសុខឥតហ្មងហើរទៅមក ។
១៨- រីឯភ្នំធំខ្ពស់សន្ធឹម　　ខ្ពស់ឆ្ងាយត្រដឹមជាជម្រក
សត្វតែងពឹងពាក់ដើរទៅមក　　ទន្សាយរត់រកចូលនិទ្រា ។
១៩- ទ្រង់បានបង្កើតទាំងព្រះច័ន្ទ　　ដើម្បីចែកខ័ណ្ឌពេលវេលា
ព្រះអាទិត្យក៏ស្គាល់សីមា　　ដែលត្រូវយាត្រាឬឈរឈប់ ។
២០- ទ្រង់បាននាំយកភាពងឹត　　មកគ្របដុំជិតនៅពេលយប់
សត្វព្រៃចាប់ផ្ដើមពីព្រលប់　　ឥតមានសញ្ជប់ចេញរៀងខ្លួន ។
២១- តោសិង្ហគ្រហឹមបង្អើលម្រឹគ　　ស្ទុះបោលសន្ធឹកខ្លះគេចពួន
ទាមទារអាហារបម្អែតខ្លួន　　ព្រោះព្រះប្រទានវាឲ្យរស់ ។
២២- មនុស្សម្នាក៏ចេញអស់ពីផ្ទះ　　ម្ពីម្ពារូតរះដើរតម្រង់
ទៅចំការស្រែឥតបង្អង់　　ធ្វើការរញ្ញង់ល្ងាចវិលមក ។
២៤- បពិត្រព្រះអើយព្រះអម្ចាស់　　គ្រប់ស្នាព្រះហស្តច្រើនគរគោក
ផែនដីពេញដោយសិរីជោគ　　សុទ្ធតែកើតមកពីព្រះអង្គ ។
២៥- មើលហ្ន៎! សមុទ្រដ៏ធំធេង　　ឆ្ងាយដាច់សង្វែងក្រៃកន្លង
មានមច្ឆាជាតិតូចធំផង　　រវើករវ័ណ្ឌរាប់មិនអស់ ។

២៦- សំពៅទូកក្តោងដឹកទំនិញ ដឹកចូលនាំចេញមិនឈប់សោះ
នាគរាជដែលទ្រង់បង្កើតនោះ លេងទឹកបឹតព្រួសក្នុងសមុទ្រ ។
២៧- សត្វទាំងប៉ុន្មានផ្ញើជីវិត លើព្រះម្ចាស់ពិតដោយមោះមុត
រង់ចាំទទួលតាមកំណត់ ចំណីមិនអត់តាមត្រូវការ ។
២៨- ពេលដែលព្រះអង្គព្រះប្រទាន គេកំពុងឃ្លានបានអាហារ
ព្រះអង្គផ្គត់ផ្គង់គ្រប់អាត្មា ឆ្អែតគ្រប់កាយាបានតឹងពោះ ។
២៩- ប្រសិនបើទ្រង់មិនរវល់ នោះគេនឹងខ្វល់ជួបភ័យគ្រោះ
បើទ្រង់ដកយកខ្យល់ទាំងអស់ នោះគេលែងរស់នឹងក្សិណក្ស័យ ។
៣០- ពេលណាព្រះអង្គទ្រង់ប្រទាន ដង្ហើយឲ្យមានខ្យល់និស្ស័យ
គេកើតឡើងវិញពេញដែនដី សព្វអស់អ្វីៗមានព្រមគ្នា ។
៣១- សូមសិរីរុងរឿងរបស់ ព្រះអម្ចាស់អស់កល្បយូរយារ
សូមទ្រង់រីករាយដោយសារស្នា ព្រះហស្តអស្ចារ្យរបស់ទ្រង់ ។
៣២- ពេលព្រះអង្គទតមកដែនដី វាញាប់ញ័រក្រៃខ្លាចព្រះអង្គ
ពេលទ្រង់ប៉ះពាល់ភ្នំទាំងពួង មានផ្សែងហុយជងខ្មៅងងឹត ។
៣៣- ខ្ញុំច្រៀងតម្កើងព្រះអម្ចាស់ ឥតមានក្រឡះមួយជីវិត
ខ្ញុំច្រៀងទាំងស្មូត្រមានបែបបទ ថ្វាយព្រះម្ចាស់ពិតជាជរាប ។
៣៤- ឱ! ព្រះអម្ចាស់សូមឲ្យបទ ដែលខ្ញុំកំណត់បានគួរគាប់
ឲ្យខ្ញុំសប្បាយចិត្តអរជាប់ ដោយសារទម្លាប់ព្រះអម្ចាស់ ។
៣៥- សូមឲ្យអ្នកបាបវិនាសបាត់ រលាយខ្ចាយខ្ចាត់ផុតស្រឡះ
សូមឲ្យពួកគេអស់ទាំងនោះ រលាយបាត់អស់ក្លាយជាដី ។
រីឯរូបខ្ញុំសូមប្រណម្យ ហត្ថាបង្គំថ្វាយម្ចាស់ថ្លៃ
សូមលើកតម្កើងជោគសិរី រុងរឿងប្រពៃព្រះអម្ចាស់ ។

**ទំនុកតម្កើងលេខ ១០៥ (១០៤)** **បទកាកគតិ**

១- ចូរយើងតម្កើង លើកព្រះខ្ពស់ឡើង ព្រមទាំងប្រកាស ព្រះនាមព្រះអង្គ
ឲ្យបានឮច្បាស់ ពីស្នាព្រះហស្ត ប្រាប់ជាតិនានា ។

២- ចូរច្រៀងបទថ្វាយ តម្កើងកុំណាយ រៀងរាល់វេលា រៀបរាប់អំពី
សព្វអស់ការងារ អស្ចារ្យគ្រប់គ្រា ដែលទ្រង់ប្រព្រឹត្ត ។
៣- ចូរខ្ពស់មុខឡើង ព្រោះតែព្រះយើង ជាព្រះវិសុទ្ធ អ្នកស្វែងរកទ្រង់
ខ្ពង់ខ្ពស់បំផុត ចូរសប្បាយចិត្ត កុំបីសៅហ្មង ។
៤- ចូរស្វែងរកព្រះ ដែលមានតេជះ បារមីត្រចង់ ស្វែងរកព្រះភក្ត្រ
របស់ព្រះអង្គ កុំនៅវេរង់ ឈប់ឈរសោះឡើយ ។
៥- សូមនឹកដល់ការ សម្បើមអស្ចារ្យ ទ្រង់បានធ្វើហើយ នឹកដល់បាដិហារិយ៍
កុំនៅកន្តើយ និងការវិនិច្ឆ័យ ដែលទ្រង់សម្រេច ។
៦- ពូជពង្សរបស់ ប្រាហាំទាំងអស់ នៅបម្រើស្រេច កូនចៅយ៉ាកុប
ដ៏ល្អបណ្តាច់ ព្រះអង្គសម្រេច ជ្រើសយកយូរហើយ ។
៧- ព្រះជាអម្ចាស់ ទ្រង់គឺជាព្រះ របស់យើងអើយ កុំនៅបង្អង់
វេរង់តោះតើយ គឺព្រះនោះហើយ គ្រប់គ្រងផែនដី ។
៨- ព្រះអង្គតែងខ្វល់ នឹកគិតទៅដល់ សម្ពន្ធមេត្រី ជាព្រះបន្ទូល
សន្យាថ្លាថ្លៃ ស្ថិតស្ថេរយូរក្រៃ មួយពាន់តំណ ។
៩- សម្ពន្ធមេត្រី ដែលទ្រង់លកលៃ ដោយស្ម័គ្រស្មោះសរ នឹងអប្រាហាំ
ជាបន្ទូលល្អ សន្យាស្មោះសរ នឹងលោកអ៊ីសាក ។
១០- ទ្រង់បញ្ជាក់ន័យ សម្ពន្ធមេត្រី ឥតមានលៀមលាក់ ទុកជាចំណង
សម្ពន្ធជាជាក់ អស់កល្បឥតអាក់ នឹងអ៊ីស្រាអែល ។
១១- ទ្រង់មានបន្ទូល ថានឹងប្រគល់ ទុកជាតំណែល គឺស្រុកកាណាន
ជាកេរក្រាស់ក្រែល មរតកនេះដែល ដល់អ្នកគ្រប់ប្រាណ ។
១២- នៅក្នុងគ្រានោះ ប្រជាស្រីប្រុស តិចតួចរាប់បាន ចូលមករស់នៅ
លើដីកាណាន បានសុខក្សេមក្សាន្ត គ្មានភ័យព្រួយអ្វី ។
១៣- គេអាចចេញចរ ពីស្រុកមួយត ដល់ស្រុកទីទៃ ចេញពីស្រុកមួយ
ទៅស្រុកផ្សេងក្តី នោះក៏អាស្រ័យ នៅលើចិត្តចង់ ។
១៤- តែមិនអាចធ្វើ ទៅតាមអំពើ ដែលចិត្តខ្លួនប៉ង ទ្រង់មិនបណ្តោយ
ឲ្យមនុស្សទាំងពួង សង្កត់សង្កិន អ៊ីស្រាអែលថ្លៃ ។

១៥- ព្រះអង្គបន្ទោស ស្ដេចអស់ទាំងនោះ ឲ្យចេះប្រណី កុំប៉ះពាល់អ្នក
យើងអភិសេកថ្មី កុំធ្វើបាបអី ព្យាការីនោះ ។
១៦- ទ្រង់ធ្វើឲ្យមាន ទុរ្ភិក្សអត់ឃ្លាន អ្នកស្រុករងគ្រោះ កូនចៅគ្រប់កាយ
គ្មានអ្វីធីសោះ អ្នកភូមិស្រីប្រុស យំខ្វះអាហារ ។
១៧- តែទ្រង់ចាត់លោក យ៉ូសែបឲ្យមក ដើរមុខប្រជា តែទាស់បងប្អូន
មានចិត្តលេលា លក់លោកធ្វើជា ទាសករជាតិផ្សេង ។
១៨- គេធ្វើបាបគាត់ ដាក់ខ្នោះវាយវាត់ រំពាត់ខ្វាត់ខ្វែង គេយកច្រវាក់
ទាក់ ក គ្មានក្រែង ខ្នោះដាក់ខ្វាត់ខ្វែង រឹបជើងខ្លួនប្រាណ ។
១៩- រហូតហេតុការណ៍ កើតឡើងសព្វសារ តាមពាក្យលោកបាន ថ្លែងទុកជាយូរ
លុះព្រះម្ចាស់មាន បន្ទូលថ្កើងថ្កាន ថាគាត់ស្លូតត្រង់ ។
២០- ស្ដេចស្រុកអេស៊ីប ឲ្យលែងយ៉ូសែប ស្រាយទាំងចំណង ដោះលែងឲ្យរួច
ទាំងម្ចាស់រាស្ត្រផង ដ៏មានបំណង ដោះលែងលោកដែរ ។
២១- គ្រាបន្ទាប់មក ស្ដេចក៏តាំងលោក ឲ្យត្រួតមើលថែ រក្សារាជវាំង
នៅនែបនិត្យក្បែរ រាជទ្រព្យហូរហែ ទាំងអស់ទៀតផង ។
២២- ស្ដេចប្រទានឲ្យ ត្រួតសព្វគ្រប់ហើយ មន្ត្រីទាំងពួង ឲ្យប្រៀនប្រដៅ
មិនឲ្យមានឆ្គង ព្រឹទ្ធាចារ្យផង ឲ្យឆ្លាតវាងវៃ ។
២៣- ពេលនោះជនជាតិ អ៊ីស្រាអែលជ្រៀត រស់នៅលើដី របស់អេស៊ីប
ពូជយ៉ាកុបថ្លៃ រស់លើទឹកដី លោកអប្រាហាំ ។
២៤- ព្រះម្ចាស់ប្រទាន ប្រជាឲ្យមាន កើនឡើងរាល់ឆ្នាំ ឲ្យមានកម្លាំង
ក្លាខ្លាំងសម្បើម សត្រូវជ្រួលជ្រើម តទល់មិនបាន ។
២៥- ព្រះអង្គធ្វើឲ្យ ពួកអេស៊ីបល្លោយ ផ្លាស់ប្ដូរចិត្តប្រាណ ស្អប់ខ្ពើមប្រជា
រាស្ត្រទាំងប៉ុន្មាន បោកប្រាសបំភាន់ អ្នកបម្រើទ្រង់ ។
២៦- ព្រះអង្គបង្គាប់ ម៉ូសេប្រញាប់ មិននៅបង្អង់ អរ៉ុនជាអ្នក
ដែលទ្រង់ជ្រើសតាំង ឲ្យចេញតម្រង់ ទ្រង់បញ្ជោទៅ ។
២៧- លោកទាំងពីរនាក់ សម្ដែងបញ្ជាក់ សម្គាល់ត្រឹមត្រូវ ឫទ្ធិបាដិហារិយ៍
ផ្សេងៗទុកនៅ ព្រះម្ចាស់តម្រូវ ក្នុងស្រុកអេស៊ីប ។

២៨-ព្រះម្ចាស់ធ្វើឲ្យ អន្ធិកាកើតហើយ ពាសពេញទាំងទ្វីប បើទ្រង់បញ្ជា
ដោយមហិទ្ធិឫទ្ធិ គ្មាននរណាឃាត់ ជំទាស់បានឡើយ ។
២៩-ទ្រង់បានប្រែទឹក ត្រីច្រើនសន្ធឹក វិនាសអស់ហើយ ទឹកក្លាយជាឈាម
គ្មានអ្វីរស់ឡើយ រលេះរលួយ ខ្ទេចអស់គ្មានសល់ ។
៣០- មានទាំងកង្កែប យំឮអូបអែប ពាសពេញមណ្ឌល ឡើងមកស្នែកស្កះ
រហូតទៅដល់ ក្រឡានិមល ព្រះបន្ទំស្តេច ។
៣១- ពេលមានបន្ទូល មានរុយមកមូល ដូចមានទ្រនិច មានពិសមានពុល
មូសក៏មិនតិច ពាសពេញមិនដាច់ ក្នុងស្រុកភូមិគេ ។
៣២-ព្រឹលធ្លាក់ដូចភ្លៀង រន្ទះបាញ់ជាំង ឆេះមិនសល់ទេ ព្រះអង្គធ្វើឲ្យ
អន្តរាយបែកបែរ នោះដោយសារតែ ឫទ្ធីបារមី ។
៣៣-ទ្រង់បំផ្លាញទាំង ចំការទំពាំង បាយជូរខ្ចុកខ្ចី ព្រមទាំងបំបាក់
ដើមឈើស្រស់ខ្ចី នៅលើទឹកដី ពួកគេខ្ទេចខ្ទី ។
៣៤- ពេលមានបន្ទូល កណ្តូបមកមូល ដង្កូវមកមីរ ចេញមកពាសពេញ
សាសព្វទិសទី កើតច្រើនវក់វីរ ស្មានមិនត្រូវអី ។
៣៥- ទៅស៊ីដំណាំ ដែលអ្នកស្រុកដាំ មិនថាទុំខ្ចី បំផ្លាញបន្លែ
លើគោកក្នុងដី មិនឲ្យមានអ្វី នៅសល់មួយទង ។
៣៦- ព្រះអម្ចាស់វាយ សម្លាប់ឲ្យពាយ អស់ទាំងកូនច្បង ប៉ុន្មានក្នុងស្រុក
អេស៊ីបអឹងកង កូនសមបំណង ស្រឡាញ់លើសគេ ។
៣៧-ទ្រង់នាំប្រជា រូតរះម្នីម្នា ញាប់ឥតទំនេរ ប្រញាប់ជើងការ
យកមាសប្រាក់ព្រៃ កុលសម្ពន្ធគេ គ្មានអ្នកទន់ខ្សោយ ។
៣៨-ពួកនោះចេញទៅ អេស៊ីបរស់នៅ នាំគ្នាសប្បាយ ព្រោះតែគេខ្លាច
ពួកនោះពេកក្រៃ ពេលនេះលែងភ័យ ខ្លាចអ្វីទៀតទេ ។
៣៩-ព្រះអង្គបានដាក់ ពពកបាំងពាក់ គ្របលើពួកគេ ហើយទ្រង់ប្រទាន
ដុំភ្លើងងាករេ ជំនួសដួងខែ នៅពេលរាត្រី ។
៤០- គេសុំអាហារ ព្រះអង្គបញ្ជា សត្វក្រួចច្រើនក្រៃ គឺទ្រង់ប្រទាន
ពីសួគ៌ាល័យ លែងព្រួយលែងភ័យ បាឆីបរិបូណ៌ ។

៤១- ព្រះអង្គបំបែក ថ្មដូចគេហែក ឲ្យមានទឹកហូរ ដូចជាទន្លេ
ទឹកមិនដាច់សូរ រាស្ត្របានសម្បូរ ទឹកមិនបេះអត់ ។
៤២- ព្រះអម្ចាស់នឹក ចាំទាំងរឭក បន្ទូលវិសុទ្ធ សន្យានឹងលោក
អប្រាហាំពិត បម្រើពិសិដ្ឋ ព្រះអង្គពេកពន់ ។
៤៣- ព្រះអង្គបានប្រោស ប្រណីសន្តោស ឲ្យប្រជាជន ព្រះអង្គចេញទាំង
អំណរលើសលន់ កញ្ច្រៀវពេកពន់ សប្បាយគ្មានល្ហែ ។
៤៤- ព្រះអង្គយកដី ជាតិនានាលៃ ចែកឲ្យគេដែរ និងឲ្យទទួល
ភោគផលផ្កាផ្លែ ដែលជាតិខាងក្បែរ ទាំងនោះបានដាំ ។
៤៥- ទ្រង់ធ្វើដូច្នេះ ឲ្យពួកគេបេះ ប្រតិបត្តិតាម ពាក្យប្រៀនប្រដៅ
ដែលទ្រង់បានផ្ដាំ សុខចិត្តធ្វើតាម ឥតមានរួញរា ។

## ទំនុកតម្កើងលេខ ១០៦ (១០៥) បទពាក្យ ៧

១- ចូរលើកតម្កើងព្រះអម្ចាស់ ព្រះអង្គមានព្រះទ័យសន្ដោស
មេត្តាករុណាសប្បុរស ព្រះដ៏ខ្ពង់ខ្ពស់នៅរហូត ។
២- តើនរណាអាចរាប់ពីស្នា ព្រះហស្ដអស្ចារ្យដ៏វិសុទ្ធ
តើនរណាអាចថ្កើងបំផុត សរសើររហូតគ្រប់គ្រាន់បាន ? ។
៣- អ្នកណាប្រព្រឹត្តដោយយុត្តិធម៌ សុចរិតស្មោះសរឥតខកខាន
គ្រប់ពេលវេលានោះនឹងបាន ជួយក្ដីសុខសាន្តគ្មានសៅហ្មង ។
៤- បពិត្រព្រះជាអម្ចាស់ថ្លៃ ពេលគាប់ព្រះទ័យរាស្ត្រព្រះអង្គ
សូមនឹកដល់ទូលបង្គំផង កុំបីបោះបង់ខ្ញុំកំព្រា ។
៥- ដើម្បីឲ្យទូលបង្គំបាន ជួបក្ដីសុខសាន្តគ្រប់វេលា
អ្នកដែលទ្រង់ជ្រើសទុកជាគ្នា ខ្ញុំសូមរួមជាមួយគេផង ។
ឲ្យទូលបង្គំបានខ្ពស់មុខ រួមរស់សុខទុក្ខឥតមួរហ្មង
នឹងប្រជារាស្ត្រផ្ទាល់ព្រះអង្គ ក្នុងគ្រានេះម្ដងនិងតទៅ ។
៦- យើងខ្ញុំបានធ្វើអំពើបាប អាក្រក់ឆ្អេះឆ្អាបច្រើនពេកក្រៃ
ដូចបុព្វបុរសកន្លងទៅ ធ្វើរឿងអាស្រូវមិនទំនង ។

៧- កាលនៅអេស៊ីបបុព្វបុរស បំភ្លេចទាំងអស់គ្រាកន្លង
ពុំយល់ពីការអស្ចារ្យផង របស់ព្រះអង្គធ្វើនោះទេ ។
៨- ប៉ុន្តែព្រះអង្គបានសង្គ្រោះ ពួកគេឲ្យរស់បានល្វើយល្វែ
ដោយយល់ព្រះនាមទ្រង់ឥតប្រែ ទើបបង្ហាញគេស្គាល់អានុភាព ។
៩- ព្រះអង្គគំរាមសមុទ្រកក់ នោះវាភ័យតក់ស្លុតរីងជ្រាប
ទ្រង់ឲ្យគេដើរកាត់បាតរាប ដូចទីទំនាបរហោស្ថាន ។
១០- ព្រះអង្គសង្គ្រោះគេឲ្យផុត ពីមនុស្សទុច្ចរិតបិត្តតិរច្ឆាន
និងកណ្តាប់ដៃជនសាមាន្យ អស់ក្តីរំខានបានល្វើយល្វែរ ។
១១- ទ្រង់ឲ្យសមុទ្រគ្របបាំងជិត លើបច្ចាមិត្រមិនបង្វែរ
បង្អង់ឲ្យនៅសល់ម្នាក់ទេ មួយក៏គ្មានដែរដែលនៅរស់ ។
១២- ពេលបុព្វបុរសឃើញដូច្នោះ គេជឿលើព្រះជាអម្ចាស់
ទើបគេនាំគ្នាច្រៀងទាំងអស់ តម្កើងព្រះខ្ពស់លើលោកា ។
១៣- ក្រោយមកពួកគេឆាប់ភ្លេចភ្លឹក កិច្ចការសន្ធឹកច្រើនអស្ចារ្យ
គេពុំរង់ចាំពេលមួយណា សម្រេចកិច្ចការព្រះអង្គឡើយ ។
១៤- នៅរហោស្ថានគេមានចិត្ត លោភលន់មិនគិតធ្វើប្ញកដើយ
ល្បងលព្រះម្ចាស់លេងព្រងើយ ទីនោះឯងហើយដីហួតហែង ។
១៥- ព្រះអង្គប្រទានឲ្យគេឆី អាហារប្រពៃច្រើនក្រៃលែង
ពួកគេបានឆ្អែតពោះសំញែង គេធ្វើប្ញកខែងដូចជិនណាយ ។
១៦- នៅក្នុងជំរំគេនាំគ្នា ប្រណែននិន្ទាខ្លាំងពេកក្រៃ
ម៉ូសេអារ៉ុនទាំងពីរកាយ បម្រើប្រពៃនៃព្រះម្ចាស់ ។
១៧- ពេលនោះផែនដីញ័ររញ្ជួយ បែកប្រេះរលួយខ្ទេចខ្ទាំអស់
ស្រូបយកដាថានមិនឲ្យរស់ បក្សពួករបស់អប៊ីរ៉ាមផង ។
១៨- មានភ្លើងសន្ធៅមកឆាបឆេះ ពួកគេទាំងអស់ខ្ទេចសូន្យសុង
អណ្តាតភ្លើងឆេះមនុស្សយង់ឃ្នង ទាំងអស់តែម្តងគ្មានសល់មួយ ។
១៩- លើភ្នំហូរ៉ែបគេជួបជុំ យកមាសទាំងដុំនាំគ្នាជួយ
ឆ្លាក់ដាប់ដុតដំបានគោមួយ គេលែងភ័យព្រួយទុកជាព្រះ ។

២០- ពួកគេបែរជាយករូបសត្វ　　មកទុកថ្វាយថ្វាត់ក្រាបសំពះ
ជាសត្វស៊ីស្មៅដើរពេញពាស　　ទុកដូចជាព្រះគួរគោរព ។
២១- ពួកគេភ្លេចថាព្រះតែមួយ　　ជាព្រះដែលជួយទាំងថ្ងៃយប់
ដោយស្នាព្រះហស្តខ្ពស់លើសលប់　　ពាសពេញសាយសព្វស្រុកអេស៊ីប ។
២២- ការអស្ចារ្យទៀតដែលមាននៅ　　ក្នុងស្រុកកូនចៅប្រាប្រហាំស្រាប់
និងស្នាព្រះហស្តដ៏ចំណាប់　　គួរឲ្យស្ញែងស្ញប់ឯសមុទ្រ ។
២៣- ព្រះអង្គសម្រេចព្រះហឫទ័យ　　កម្ទេចប្រល័យគេឲ្យផុត
តែលោកម៉ូសេដ៏វិសុទ្ធ　　ចេញមកក្រាបលុតអង្វរសុំ ។
គាត់ឃាត់ព្រះអង្គមិនឲ្យលប់　　តាមព្រះពិរោធដោយគំនុំ
មិនឲ្យព្រះអង្គគិតគួនគុំ　　ពួកគេនឹងយំដោយទ្រង់ខ្ញាល់ ។
២៤- គេពុំព្រមចុះចូលទៅក្នុង　　ទឹកដីបំព្រងជារៀងរាល់
សម្បូណ៌សប្បាយដោយភោគផល　　ពុំទទួលស្គាល់បន្ទូលទេ ។
២៥- គេពោលរអ៊ូក្នុងជំរំ　　លាន់ឮរងំគ្មានពេលល្ហែ
មិនព្រមស្តាប់ព្រះសូរសៀងទេ　　គេមិនប្រួលប្រែជឿព្រះអង្គ ។
២៦- ដូច្នេះព្រះម្ចាស់ខ្ញាល់ខ្លាំងណាស់　　ទ្រង់ក៏ប្រកាសមិនរេរង់
នឹងបំផ្លាញគេឲ្យខ្ទេចផង　　ឲ្យវិនាសក្នុងរហោស្ថាន ។
២៧- ទ្រង់នឹងកម្ចាត់ឲ្យរលាយ　　វិនាសអន្តរាយគ្រប់ៗប្រាណ
ដោយឲ្យគេស្លាប់ចៀសមិនបាន　　លើទឹកដីស្ថានសាសន៍ដទៃ ។
២៨- នៅឯពេអ៊័រគេនាំគ្នា　　ឱនកាយវន្ទាទាំងលើកដៃ
គោរពព្រះបាលរាល់ខែថ្ងៃ　　ជាព្រះអប្រិយ៍គ្មានវិញ្ញាណ ។
២៩- ពួកគេប្រព្រឹត្តអំពើទាស់　　នឹងព្រះអម្ចាស់មិនខកខាន
ទ្រង់ព្រះពិរោធពន់ប្រមាណ　　នាំឲ្យកើតមានគ្រោះកង្វល់ ។
៣០- លោកភេនេអាសក្រោកដាក់ទោស　　គេតាមកំហុសឥតមានសល់
គ្រោះកាចស្ងប់ស្ងៀមលែងអំពល់　　ពួកគេបានស្គាល់តែសុខសាន្ត ។
៣១- ព្រោះតែកើតហេតុការណ៍ទាំងនេះ　　ព្រះអម្ចាស់ប្រោសលោកឲ្យបាន
ជាមនុស្សសុចរិតឥតសាមាន្យ　　អស់កល្បសុខសាន្យអង្វែងទៅ ។

៣២- នៅប្រភពទឹកមេរីបា　គេគ្រប់កាយាធ្វើអាស្រូវ
នាំឲ្យព្រះម្ចាស់ខ្វាល់ពេកក្រៃ　លោកម៉ូសេត្រូវទទួលទោស ។
៣៣- គេធ្វើឲ្យរូបលោកឆ្អែតចិត្ត　ថប់ក្នុងគំនិតមិនដឹងខុស
ជាហេតុឲ្យលោកវិលវល់អស់　ហើយមានប្រសាសន៍ដោយមិនគិត ។
៣៤- ពួកគេពុំបានវាយប្រហារ　ប្រជានានាប្រែទៅស្និទ្ធ
រួមរស់នឹងគេដោយមិនគិត　ហើយបានក្បត់ជិតនឹងបញ្ញា ។
៣៥- ពួកគេបែរទៅជាប់ព័ន្ធពាក់ជា　មួយពួកអ្នកសាសន៍នានា
ហើយគេបានរៀនតៗគ្នា　ប្រព្រឹត្តពាលាតាមសាសន៍ផ្សេង ។
៣៦- គេថ្វាយបង្គំព្រះក្លែងក្លាយ　រៀងរាល់តែថ្ងៃគ្មានកោតក្រែង
ថ្ងៃក្រោយគេនឹងសោកសង្រេង　ដោយសារខ្លួនឯងនាំវិនាស ។
៣៧- គេយកបុត្រភ្ញារទាំងស្រីប្រុស　ធ្វើយញ្ញទាំងខុសគ្មានអៀនខ្មាស
ទៅថ្វាយអារក្សដោយផ្តេសផ្តាស　ថ្វាយទៅដល់ព្រះមិនដឹងអី ។
៣៨- គេបានប្រហារជីវិតកូន　ប្រុសស្រស់ស្រីស្ងួនទាំងក្មេងខ្ចី
ដែលគ្មានកំហុសមិនដឹងអី　ធ្វើឲ្យទឹកដីលែងវិសុទ្ធ ។
៣៩- អំពើដែលពួកគេប្រព្រឹត្ត　ធ្វើឲ្យដក់ជិតរៀងរហូត
គេបានក្បត់ព្រះតែមួយគត់　ព្រោះគេមានពុតមិនព្រមកែ ។
៤០- ពេលនោះព្រះអម្ចាស់មិនទ្រាំ　នឹងប្រជាជនទ្រង់ទៀតទេ
ទ្រង់ព្រះពិរោធនឹងពួកគេ　ដែលជាប្រជាផ្ទាល់ព្រះអង្គ ។
៤១- ព្រះអង្គបញ្ជូនគេឲ្យធ្លាក់　ទៅក្នុងអន្ទាក់ជាតិផ្សេងម្តង
ឲ្យពួកបច្ចាមិត្រគ្រប់គ្រង　លើពួកនោះផងឲ្យដឹងដៃ ។
៤២- ខ្មាំងសត្រូវជិះជាន់សង្កត់　ពួកគេតាមចិត្តមិនប្រណី
បង្ក្រាបពួកគេទាំងយប់ថ្ងៃ　ចុះចូលក្នុងដៃគេទៀតផង ។
៤៣- ទ្រង់សង្គ្រោះគេច្រើនលើកគ្រា　គេនៅនាំគ្នាចង់ប៉ុនប៉ង
បះបោរប្រឆាំងនឹងព្រះអង្គ　បាបច្រើនកន្លងមិនព្រមឈប់ ។
៤៤- ពេលព្រះអង្គឮពួកគេស្រែក　ថ្ងូរថ្ងូចអនេកទាំងយប់ ។
ព្រះអង្គក៏មានព្រះទ័យស្ងប់　លែងខឹងលែងស្អប់ថែមអាណិត ។

| | | | |
|---|---|---|---|
| ៤៥- | ព្រះអង្គសន្ដោសប្រោសប្រណី | នឹកដល់មេត្រីចងចុំជិត | |
| | ព្រះទ័យទ្រង់ដូចមកអាណិត | មេត្តាធម៌ស្ថិតនៅលើសលប់ | ។ |
| ៤៦- | ទ្រង់បានធ្វើឲ្យខ្មាំងដែលកៀរ | ពួកគេទៅជាឈ្លើយសំអប់ | |
| | មានចិត្តអាណិតពួគេគ្រប់ | លែងខឹងលែងស្អប់លែងធ្វើបាប | ។ |
| ៤៧- | ឱព្រះអម្ចាស់យើងខ្ញុំអើយ | ក្នុងពេលនេះហើយសូមប្រញាប់ | |
| | យាងមកសង្គ្រោះយើងជុតស្លាប់ | ឲ្យបានឆាប់ៗកុំបង្អង់ | ។ |
| | ដើម្បីឲ្យខ្ញុំថ្វាយបង្គំ | ព្រះនាមឧត្តមសែនខ្ពស់ខ្ពង់ | |
| | វិសុទ្ធវិសាលល្អត្រចង់ | បានខ្ពស់មុខជងដោយថ្កើងទ្រង់ | ។ |
| ៤៨- | សូមលើកតម្កើងព្រះអម្ចាស់ | ប្រសើរពេកណាស់មានយូរលង់ | |
| | ជាព្រះអ៊ីស្រាអែលតពូជពង្ស | ដរាប់ទៅជងរៀងទៅអើយ | ។ |

**ទំនុកតម្កើងលេខ ១០៧ (១០៦)** **បទព្រហ្មគីតិ**

| | | | |
|---|---|---|---|
| ១- | ចូរលើកតម្កើងព្រះ | ជាអម្ចាស់មានព្រះទ័យ | |
| | ដ្បិតទ្រង់សប្បុរសក្រៃ | ត្រាប្រណីរៀងរហូត | ។ |
| ២- | អ្នកដែលព្រះជាអម្ចាស់ | បានរំដោះឲ្យរបូត | |
| | ពោលពាក្យនេះរហូត | កុំភរភូតត្រូវស្ម័គ្រស្មោះ | ។ |
| ៣- | ព្រះអង្គប្រមូលជុំ | មកពីភូមិគ្មានចន្លោះ | |
| | នាំយកមកទាំងអស់ | ពីកើតកោះលិចជើងត្បូង | ។ |
| ៤- | អ្នកខ្លះត្រូវវង្វេង | វាលបែកជ្រែងដីប្រេះខូង | |
| | រកស្រុកភូមិទាំងពួង | ស្នាក់នៅជងអ្វីក៏គ្មាន | ។ |
| ៥- | គេស្ទើតែដាច់ពោះ | សឹងមិនរស់ព្រោះតែឃ្លាន | |
| | រកទឹកក៏មិនបាន | បាត់បងប្រាណទាំងទឹកចិត្ត | ។ |
| ៦- | ក្នុងពេលមានអាសន្ន | គេស្រែកកបន់គួរអាណិត | |
| | សូមព្រះជួយជីវិត | ទ្រង់អាណិតក៏រំដោះ | ។ |
| ៧- | ព្រះអង្គបានដឹកនាំ | គេដាក់ចំក្រុងល្អស្រស់ | |
| | ដែលគេបានសង្គ្រោះ | អាស្រ័យរស់ដោយសុខសាន្ត | ។ |

៨- គេត្រូវលើកតម្កើង ព្រះខ្ពស់ឡើងហួសទីស្ថាន
ករុណាដែលទ្រង់មាន ប្រោសប្រទានគ្មានជិនណាយ ។
៩- ដ្បិតទ្រង់ប្រទានទឹក ឲ្យអ្នកផឹកលែងខ្វល់ខ្វាយ
ប្រទានម្ហូបនិងបាយ អ្នកទាំងឡាយឆីតាមចង់ ។
១០- អ្នកខ្លះទៀតរស់នៅ ទីជម្រោងងឹតស្លុង
ជាអ្នកជាប់នៅក្នុង ប្រវាក់ឃាំងយ៉ាងវេទនា ។
១១- ដ្បិតគេបានតតាំង បះប្រឆាំងព្រះដែលជា
ម្ចាស់ដែលតែងការពារ មិននឹកនាពាក្យប្រដៅ ។
១២- ព្រះអង្គលុតដំគេ ឲ្យជួបតែទុក្ខសោកសៅ
វេទនាគ្មានអ្នកហៅ ពួកគេត្រូវធ្លាក់ទឹកចិត្ត ។
១៣- ក្នុងពេលមានអាសន្ន គេស្រែកបន់គួរអាណិត
សូមព្រះជួយជីវិត ទ្រង់អាណិតក៏រំដោះ ។
១៤- ព្រះអង្គនាំគេគេច ពីអំណាចស្លាប់ឲ្យរស់
ទ្រង់ផ្ដាច់ចេញទាំងអស់ ប្រវាក់ខ្នោះផុតពីដៃ ។
១៥- គេត្រូវលើកតម្កើង ព្រះម្ចាស់ឡើងឲ្យប្រពៃ
ដែលសម្ដែងព្រះទ័យ ប្រោសប្រណីចំពោះមនុស្ស ។
១៦- ដ្បិតព្រះអង្គបំបាក់ សោរប្រវាក់ដែកទាំងអស់
ឯទ្វារលង្ហិននោះ ទ្រង់បោកបោះបំបែកបាន ។
១៧- ខ្លះទៅជាល្ងីល្ងើ ព្រោះអំពើបាបរំខាន
កំហុសទាំងប៉ុន្មាន ធ្វើឲ្យប្រាណគេខ្លោចផ្សា ។
១៨- គេព្រួយបារម្ភខ្លាំង លែងចង់ទាំងលេបអាហារ
ព្រួយខ្លាចសូន្យសង្ខារ ក្ដីមរណាកាន់តែជិត ។
១៩- ក្នុងពេលមានអាសន្ន គេស្រែកបន់គួរអាណិត
សូមព្រះជួយជីវិត ទ្រង់អាណិតក៏រំដោះ ។
២០- ព្រះអង្គមានបន្ទូល ឲ្យប្រមូលពួកទាំងនោះ
ឲ្យគេបានជាអស់ និងរំដោះបានប្រពៃ ។

២១- ពួកគេត្រូវតម្កើង ព្រះខ្ពស់ឡើងផុតផែនដី
និងស្នាព្រះហស្តថ្លៃ ទ្រង់ប្រណីមកមនុស្សា ។
២២- គេត្រូវតែដាក់ថ្វាយ យញ្ញទាំងឡាយជាសក្ការ
អរគុណសព្វប្រការ ថ្លែងពីស្នាព្រះហស្តផង ។
២៣- អ្នកដែលដើររកស៊ី គ្រប់ទិសទីកុំមានហ្មង
តាមផ្លូវសមុទ្រផង គ្រានេះម្តងយល់ហេតុការណ៍ ។
២៤- បានឃើញស្នាព្រះហស្ត ព្រះអម្ចាស់ដ៏ថ្លៃថ្លា
សព្វកិច្ចដ៏អស្ចារ្យ គ្រប់ប្រការនៅសមុទ្រ ។
២៥- ពេលព្រះជាអម្ចាស់ បន្ទូលច្បាស់លាស់បំផុត
ខ្យល់បោកបក់គួរស្លុត ទឹកសមុទ្ររលកខ្លាំង ។
២៦- ធ្វើឲ្យតួនាវា សែនគ្រាំគ្រាបោកគ្រាំគ្រាំង
ជួនលិចជួនងើបឡើង ជួនជាត់បើងស្ទើរមរណា ។
២៧- ពួកគេវិលវល់ខ្លាំង ដូចស្រវឹងគ្រប់អាត្មា
ថែមទាំងលែងដឹងថា ធ្វើយ៉ាងណារួចជីវិត ។
២៨- ក្នុងពេលមានអាសន្ន គេស្រែកបន់គួរអាណិត
សូមព្រះជួយជីវិត ទ្រង់អាណិតក៏រំដោះ ។
២៩- ព្រះអង្គបានបង្ក្រាប សមុទ្ររាបព្យុះស្ងាត់អស់
រលកក៏ថយចុះ ឈប់ទាំងអស់នៅស្ងាត់ស្ងៀម ។
៣០- គេត្រេកអរខ្លាំងណាស់ ដោយដឹងច្បាស់ព្រះគំរាម
រលកសមុទ្រស្ងៀម ទ្រង់ដឹងនាំឲ្យផុតភ័យ ។
៣១- ពួកគេលើកតម្កើង ព្រះម្ចាស់ឡើងដោយប្រពៃ
ដែលសម្តែងព្រះទ័យ ប្រោសប្រណីគ្រប់មនុស្សម្នា ។
៣២- គេថ្កើងនាមព្រះអង្គ ក្នុងប្រជុំជននានា
ក្នុងក្រុមចាស់ព្រឹទ្ធា ឲ្យគ្រប់គ្នាបានយល់ដឹង ។
៣៣- ព្រះអង្គឲ្យទន្លេ ហួររាល់ខែវស្សាប្រាំង
ទៅជាវាលស្ងាត់ឈឹង ទឹកក៏រាំងរីងហួតហែង ។

៣៤- ទ្រង់ធ្វើឲ្យទឹកដី    ទៅជាប្រែគ្រប់កន្លែង
ដីស្ងួតប្រេះក្រហែង    ព្រោះខ្លាចក្រែងគេមិនត្រង់ ។
៣៥- ព្រះអង្គអាចធ្វើឲ្យ    ទីវាលក្លាយប្រែជាបឹង
ដីហួតស្ងួតប្រេះរឹង    វាលស្ងាត់ឈើងប្រែមានទឹក ។
៣៦- ទ្រង់នាំអ្នកស្រេកឃ្លាន    ទៅរស់រានច្រើនសន្ទឹក
ទៅរស់នៅជិតទឹក    ក្រុងសន្ទឹកនៅទៀតផង ។
៣៧- ពួកគេបានសាបព្រោះ    ដំណាំដុះស្រស់ហ្មត់ហ្មង
ទំពាំងបាយជូរផង    ល្អបំព្រងបេះយកផល ។
៣៨- ព្រះអង្គប្រទានពរ    ជ័យបវរសុខមង្គល
កកើតឲ្យបានដល់    ទាំងហ្វូងសត្វក៏មិនអន់ ។
៣៩- ពេលពួកគេថយចុះ    បាត់កិត្តិយសគ្រោះអាសន្ន
ពួកសត្រូវជិះជាន់    ឥតស្រាកស្រាន្តរងទុក្ខសោក ។
៤០- ព្រះអង្គធ្វើឲ្យអ្នក    មានបុណ្យសក្តិចុះទាបថោក
វង្វេងមិនអាចរក    ផ្លូវទៅមកឃើញសោះឡើយ ។
៤១- តែទ្រង់តែងសង្គ្រោះ    អ្នកគ្មានយសក្រខ្សត់ខ្សោយ
អ្នកទាបបានធូរស្បើយ    បានកូនសាយច្រើនពន់ពេក ។
៤២- ពេលពួកអ្នកសុចរិត    ឃើញរឿងពិតអរអនេក
អ្នកទុច្ចរិតលែងស្រែក    គួរសង្វេគនៅស្ងៀមស្ងាត់ ។
៤៣- អស់អ្នកមានប្រាជ្ញា    ត្រូវកត់ត្រាកុំឲ្យបាត់
ទុកជាទីកំណត់    យល់ឲ្យហ្មត់ស្នាព្រះហស្ត ។
មានច្រើនមហិមា    អស្ចារ្យជារាប់មិនអស់
ព្រះហឫទ័យសន្ដោស    ប្រណីប្រោសនៃព្រះម្ចាស់ ។

## ទំនុកតម្កើងលេខ ១០៨ (១០៧)    បទពាក្យ ៧

២- ឱព្រះជាអម្ចាស់ខ្ញុំអើយ    ខ្ញុំមិនកន្តើយត្រៀមកាយចិត្ត
ទូលបង្គំនឹងច្រៀងស្មូតបទ    អស់ពីដួងចិត្តរាល់វេលា ។
៣- ឱពិណនិងឃឹមទាំងឡាយអើយ    ចូរកុំកន្តើយបាកនិទ្រា
ខ្ញុំនឹងទៅដាស់ព្រះសុរិយា    ឲ្យចរយាត្រាបំភ្លឺលោក ។

៤- បពិត្រព្រះអម្ចាស់ថ្លាថ្លៃ ខ្ញុំតម្កើងថ្វាយទាំងលើកយក
នៅក្នុងជនជាតិច្រើនគរគោក ខ្ញុំសូមស្មូត្រមកថ្វាយព្រះអង្គ ។
៥- ដ្បិតព្រះហឫទ័យធ្លាប់មេត្តា អាសូរករុណាដ៏ត្រចង់
ព្រះទ័យស្ម័គ្រស្មោះឥតមានហ្មង ទោះវេហាស៍ផងខ្ពស់មិនស្មើ ។
៦- ឱព្រះម្ចាស់សូមបង្ហាញឡើង ភាពស្រស់ថ្កានថ្កើងនៅស្ថានលើ
សិរីរុងរឿងបាំងផ្លេកភ្លឺ ល្បាញល្បីរន្ទឺទាំងផែនដី ។
៧- សូមយាងសង្គ្រោះដោយឫទ្ធា អំណាចចេស្ដានិងបារមី
ឆ្លើយតបមកខ្ញុំដោយឃ្មាតខ្មី ឲ្យជនប្រុសស្រីរួចជីវិត ។
៨- ព្រះម្ចាស់ទ្រង់មានបន្ទូលពី សក្ការៈទីដ៏វិសុទ្ធ
ថាយើងនឹងយកជ័យបំផុត រួចនឹងពិនិត្យបែងចែកស្រុក ។
យើងនឹងវាស់កាត់ចែកស៊ីគែម ជ្រលងបន្ថែមភ្នំស៊ូកូត
ចែកឲ្យប្រជារាស្ត្រត្រង់ស្លូត ទុកឲ្យរហូតជាមរតក ។
៩- ទឹកដីកាឡាតយើងយកជា ទ្រព្យគាប់ទ័យាមិនតំអក់
ទាំងម៉ាណាសេក៏យើងយក ជាទីជម្រករាស្ត្រយើងផង ។
អេប្រាអ៊ីមអើយអ្នកដូចជា មួកដែកការពារពេលចម្បាំង
យូដាក៏ដូចជាដំបង រាជ្យល្អហ្មត់ហ្មងឫទ្ធិថ្កុំថ្កើង ។
១០- ដើងយើងលាងលើដីម៉ូអាប់ អេដំសម្រាប់បោះស្បែកជើង
បញ្ជាក់ថាម្ចាស់ដីគឺយើង ប្រកាសប្រឆាំងភីលីស្ទីន ។
១១- នរណានាំខ្ញុំឲ្យចូលដល់ ទីក្រុងមង្គលរឹងមាំមួន
តើនរណានាំខ្ញុំដល់ស្ថាន ភូមិអេដំបានគ្មានភ័យព្រួយ ។
១២- បពិត្រព្រះជាម្ចាស់ខ្ញុំអើយ ព្រះអង្គនេះហើយអាចលើកស្ទួយ
ទ្រង់បានបោះបង់ហើយបណ្ដោយ ឈប់យាងមកជួយក្នុងកងទ័ព ។
១៣- សូមជួយយើងខ្ញុំប្រឆាំងត ពេលនេះរឹករវបាក់មុខអាប់
ការជួយពីមនុស្សពិតមិនគាប់ មានច្រើនតាន់តាប់គ្មានផលអ្វី ។
១៤- បើព្រះជាម្ចាស់គង់នឹងយើង នេះនឹងថ្កុំថ្កើងបានជោគជ័យ
ព្រះអង្គបង្ក្រាបពួកអប្រិយ៍ វិនាសអន្តរាយជារៀងរាប ។

## ទំនុកតម្កើងលេខ ១០៩ (១០៨) បទភាកគតិ

១- ឱព្រះអម្ចាស់ ខ្ញុំសូមប្រកាស សរសើរតម្កើង សូមកុំបង្អង់

កុំធ្វើឆ្មៃឆ្មើង យាងមកឆាប់ឡើង កុំនៅស្ងៀមឡើយ ។

២- ដ្បិតជនអាក្រក់ ភូតភរកុហក ប្រឆាំងមិនស្បើយ គេមួលបង្កាច់

គ្មានពេលល្ហែល្ហើយ គេមិនស្ងៀមឡើយ បង្ខូចឈ្មោះខ្ញុំ ។

៣- គេពោលសំអប់ រូបខ្ញុំគ្រប់សព្វ ដោយមិនសក្តិសម គេវាយប្រហារ

មកលើរូបខ្ញុំ ដូចមានគំនុំ មិនដឹងហេតុការណ៍ ។

៤- ខ្ញុំស្រឡាញ់គេ តែគេងាករេ បែកបែរសាវា គេចោទប្រកាន់

ខ្ញុំខុសតម្រា ទោះជាម្តេចម្តា ខ្ញុំមិនទោម្ទេញ ។

៥- គេធ្វើអាក្រក់ អំពើលាមក តបស្នងមកវិញ គេស្អប់រូបខ្ញុំ

តបក្តីស្រឡាញ់ ស្មោះឥតទោម្ទេញ តទៅឥតរា ។

៦- សូមមេត្តាដាក់ ជនកំណាចម្នាក់ មកកាន់ការងារ ពីលើអ្នកនោះ

ឈរខាងស្តាំវា គេនឹងត្រួតត្រា ចោទប្រកាន់ទោស ។

៧- ឲ្យគេទទួល ទោសកុំប្រែប្រួល នៅពេលជម្រះ ក្តីក្នុងជំនុំ

ដឹងចាញ់ដឹងឈ្នះ ពាក្យគេបន់ព្រះ ឲ្យក្លាយជាបាប ។

៨- សូមកុំឲ្យគេ រស់បានយូរខែ តទៅដរាប សូមឲ្យមានម្នាក់

មកនៅកាន់កាប់ តំណែងគួរគាប់ ជំនួសកុំខាន ។

៩- ឲ្យកូនឲ្យចៅ អស់ទាំងពង្សជៅ ទាំងញាតិសន្តាន ទៅជាកំព្រា

គ្មានគេរាប់អាន ប្រពន្ធគេបាន ក្លាយជាមេម៉ាយ ។

១០- ឲ្យទាំងចៅកូន ជីតាជីដូន បាក់បែកខ្ចាត់ខ្ចាយ ឲ្យអនាថា

ដើររើសកកាយ សុំដល់ស្រុកឆ្ងាយ ពីលំនៅស្ថាន ។

១១- សូមម្ចាស់បំណុល រឹបអូសកុំសល់ អ្វីទាំងប៉ុន្មាន ឲ្យជនបរទេស

ឆក់ប្លន់កុំខាន អ្វីគេរកបាន យកអស់កុំទុក ។

១២- សូមកុំឲ្យមាន អ្នកណាប្រទាន ឲ្យគេបានសុខ កុំគិតអាសូរ

ឲ្យស្គាល់តែទុក្ខ រស់មិនស្រណុក ជាកូនឯកា ។

១៣- សូមដកជីវិត ពូជគេកុំគិត ប្រណីករុណា លុបបំបាត់បោល
ត្រកូលឫស្សា កុំនៅមេត្តា ដល់ជំនាន់ក្រោយ ។
១៤- សូមព្រះម្ចាស់ចាំ កត់ត្រាចំណាំ ជូនតាទុកឲ្យ កំហុសប៉ុន្មាន
គេបានធ្វើហើយ រួមផងទាំងម្ដាយ អ្នកផ្សំគំនិត ។
១៥- សូមព្រះចងចាំ អំពើបាបកម្ម ពួកជនឧក្រិដ្ឋ ពេលគេស្លាប់ទៅ
កុំឲ្យមានមិត្ត ឬមានអ្នកគិត ដល់គេធ្វើអ្វី ។
១៦- ជននេះពុំបាន សម្ដែងសន្ដាន ចិត្តចេះប្រណី គេបៀតគេបៀន
អ្នកខ្សត់ក្រក្រី ព្រមទាំងប្រល័យ អ្នកសោកសង្រេង ។
១៧- គេចូលចិត្តឈ្លោះ មិនអនុគ្រោះ គ្មានគិតខ្លាចក្រែង រករឿងឥតឈប់
មិនថាចាស់ក្មេង ពួកគេវង្វេង នឹងបណ្ដាសា ។
គេមិនចូលចិត្ត ពាក្យពរប្រសិទ្ធិ រុងរឿងថ្លៃថ្លា ហេតុនេះកុំឲ្យ
មានមនុស្សណា ជូនពរធុកា ដល់ពួកវាឡើយ ។
១៨- សូមឲ្យគេយក បណ្ដាសាមក គ្របកុំកន្ដើយ ដូចអាវដែលពាក់
នៅលើខ្លួនហើយ កុំបណ្ដោយឡើយ ឧកខានសោះសូន្យ ។
សូមបណ្ដាសា ចូលក្នុងកាយា ដូចទឹកក្នុងខ្លួន ជ្រាបចូលក្នុងសាច់
រឹងប៉ឹងមាំមួន ដូចខ្លាញ់ចូលខ្លួន ជារៀងដរាប ។
១៩- ឲ្យបណ្ដាសា បានក្លាយទៅជា ខោអាវបាំងគ្រប បិទជិតជុំកាយ
ព័ទ្ធពេនជិតជាប់ ដូចខ្សែក្រវាត់ រុំសព្វកាយា ។
២០- អស់អ្នកដែលចោទ ប្រកាន់ខ្ញុំសោត និងអ្នកមុសា និយាយអាក្រក់
ប្រឆាំងឫស្សា សូមគ្រប់អាត្មា ទទួលទោសចុះ ។
២១- ឱព្រះម្ចាស់អើយ កុំនៅព្រងើយ សូមមេត្តាប្រោស យល់ដល់ព្រះនាម
អម្ចាស់លើកទោស ហឫទ័យសន្ដោស ធម៌ករុណា ។
២២- ខ្ញុំជនកម្សត់ ក្រីក្រទុរគត ដួងចិត្តឯកា សូមមេត្តាជួយ
ឲ្យជាជងណា ស្រាកស្រាន្តកាយា ផុតទុក្ខសោកសៅ ។
២៣- ជីវិតរសាត់ ដោយវាយោជាត់ ដូចស្រមោលខ្មៅ គេកម្ចាត់ខ្ញុំ
ឲ្យខ្ចាត់បាត់ទៅ ដូចសត្វល្អិតត្រូវ វិនាសអន្ដរាយ ។

២៤- ខ្ញុំហេវល្ហិតល្វៃ ទន់អស់ជើងដៃ ខ្សោះអស់ទាំងកាយ ព្រោះតមអាហារ
យូរថ្ងៃមកហើយ គ្មានសល់សាច់ឡើយ ស្បែកជណ្តប់ឆ្អឹង ។
២៥- មនុស្សម្នាឃើញខ្ញុំ ពេបជ្រាយសើចយំ ខ្ញុំស្គមកំព្រឹង អ្នកខ្លះងក់ក្បាល
សម្លក់សម្លឹង មើលខ្ញុំដូចខឹង ធ្វើមុខក្រញូវ ។
២៦- ឱព្រះអម្ចាស់ ព្រះអង្គជាព្រះ នៃខ្ញុំឥឡូវ សូមជួយរូបខ្ញុំ
ឲ្យផុតហ្មងសៅ កុំបង្អង់នៅ សូមទ្រង់សន្តោស ។
២៧-សូមឲ្យពួកវា ទទួលស្គាល់ថា ព្រះបានសង្គ្រោះ រូបទូលបង្គំ
បាកផុតទុក្ខទោស ដោយបារមីនោះ វិសេសអស្ចារ្យ ។
២៨- គេជេរប្រទេច ផ្តាសាពាក្យពេចន៍ រូបខ្ញុំឯកា ព្រះអង្គប្រទាន
ពរជ័យថ្លៃថ្លា ខ្ញុំមិនមរណា បានសុខថ្កើងថ្កាន ។
២៩- សូមឲ្យពួកអ្នក ប្រកាន់ចាប់ថ្នាក់ ខ្ញុំគ្រប់ទីស្ថាន ជួបតែអាម៉ាស់
ពុំស្គាល់សុខសាន្ត សោកសៅប៉ុន្មាន នៅជាប់រាល់ថ្ងៃ ។
៣០- ខ្ញុំលើកតម្កើង សំឡេងលាន់ឡើង ថ្កើងព្រះម្ចាស់ថ្លៃ សរសើរព្រះអង្គ
ជារៀងរាល់ថ្ងៃ ប្រជាប្រុសស្រី កកកុញកុះករ ។
៣១- ដ្បិតទ្រង់ការពារ អ្នកខ្សត់វេទនា ទុរគតក្រីក្រ ដើម្បីសង្គ្រោះ
ឲ្យរស់បន្ត ពីមនុស្សមិនល្អ ចង់ដាក់ទោសគេ ។

## ទំនុកតម្កើងលេខ ១១០ (១០៩) បទភាកគតិ

១- ព្រះអម្ចាស់មាន បន្ទូលមកកាន់ ព្រះរាជាខ្ញុំ ថាសូមអញ្ជើញ
អង្គុយខាងស្តាំ កុំនៅសិំងំ ចាំយើងបាត់បែង ។
ទំរាំយើងច្បាំង បង្ក្រាបពួកខ្មាំង ចិត្តធំឥតក្រែង យើងដាក់វានៅ
ក្រោមជើងព្រះស្តែង ឲ្យវាចំបែង អ្នកកុំខ្វល់ខ្វាយ ។
២- សូមព្រះប្រទាន ព្រះករុណាបាន លាតសន្ធឹងឆ្ងាយ ព្រះរាជ្យព្រះអង្គ
ពីស៊ីយ៉ូននាយ តទៅអន្លាយ បង្ក្រាបលើខ្មាំង ។
៣- ថ្ងៃព្រះករុណា កេណ្ឌទ័ពនោះណា ប្រជាទូទាំង រួមនិងយុវជន
ស្ម័គ្រស្មោះទៅច្បាំង ដូចសន្សើមខ្លាំង ធ្លាក់ចុះរាល់ថ្ងៃ ។

៤- ព្រះអម្ចាស់មាន បន្ទូលថ្កើងថ្កាន សន្យាថ្លាថ្លៃ យើងបូជាចារ្យ
ជាអចិន្ត្រៃយ៍ យកតាមនិស្ស័យ ម៉ែលគីសេដែក ។
៥- ព្រះអម្ចាស់គង់ ឈរនៅឃ្យូរលង់ ខាងស្តាំចាំស្រែក ពេលព្រះអង្គខ្ញាល់
គំរាមប្រកែក កម្ទេចបំបែក ពួកស្តេចនានា ។
៦- ព្រះអង្គវិនិច្ឆ័យ ជាតិសាសន៍ដទៃ ឲ្យភ័យគ្រប់គ្នា ព្រះអង្គទុកសព
គរជើងលើគ្នា ដេកដួលត្រៀបត្រា គ្រប់ទីកន្លែង ។
ព្រះអង្គបំបាក់ អ្នកធំគ្រប់ថ្នាក់ គ្មានខ្លាចរអែង ឲ្យគេបុះបេញ
បោះបង់តំណែង គេកោតស្ញប់ស្ញែង ទូទាំងប្រទេស ។
៧- ពេលស្តេចយាងទៅ សព្វតាមទីផ្លូវ ទ្រង់សោយទឹកជ្រោះ ដូចជាព្រះស្ងោយ
ចម្អែតក្រពះ រួចងើបព្រះភក្ត្រ ដោយជោគសិរី ។

## ទំនុកតម្កើងលេខ ១១១ (១១០) បទពាក្យ ៧

១- ចូរលើកតម្កើងព្រះជាម្ចាស់ ប្រសើរពេកណាស់លើលោកា
ខ្ញុំថ្កើងព្រះអង្គហួសសិរសា ក្នុងហ្វូងមនុស្សណាដែលទៀងត្រង់ ។
២- គ្រប់ស្នាព្រះហស្តព្រះអម្ចាស់ ប្រសើរពេកណាស់ខ្ពស់ឧត្តុង្គ
អ្នកពេញចិត្តស្នាព្រះហស្តទ្រង់ ស្វះស្វែងយល់ផងកុំរារែក ។
៣- គ្រប់ស្នាព្រះហស្តបានបញ្ចេញ រស្មីចិញ្ចែងភ្លឺអនេក
សេចក្ដីសុចរិតល្អពន់ពេក មិនប្រេះបាក់បែកនៅរហូត ។
៤- ព្រះអង្គទ្រង់សព្វព្រះហឫទ័យ ឲ្យយើងស្រមៃមិនរលត់
ដល់ការអស្ចារ្យខ្ពស់បំផុត ហឫទ័យអាណិតចិត្តអាសូរ ។
៥- ព្រះអង្គប្រទានទាំងអាហារ ដល់អ្នកវេទនាស្រែកទ្រហោរ
អ្នកដែលកោតខ្លាចទ្រង់អាសូរ សម្ពន្ធមានយូរធ្លាប់មេត្រី ។
៦- ព្រះអង្គសម្ដែងអានុភាព ឲ្យរាស្ត្រជ្រួតជ្រាបឥតសង្ស័យ
គឺព្រះអង្គបានឲ្យទឹកដី ប្រជាដទៃមកពួកគេ ។
៧- គ្រប់ស្នាព្រះហស្តព្រះអង្គធ្វើ សុទ្ធតែអំពើល្អឥតរេ
សុចរិតយុត្តិធម៌ឥតប្រួលប្រែ ដូច្នេះគួរតែជឿទាំងស្រុង ។

៨- បញ្ញាទាំងនោះឥតចន្លោះ មិនបាត់មួយសោះស្ថិតគង់វង្ស
សុចរិតល្អល្អះភ្លឺត្រចង់ ក្តីពិតទៀងត្រង់យ៉ាងប្រពៃ ។
៩- ព្រះអង្គរំដោះប្រជារាស្ត្រ ពួកគេទាំងអស់មានសេរី
ទ្រង់បានចងសម្ពន្ធមេត្រី នឹងរាស្ត្រប្រុសស្រីរហូតទៅ ។
ព្រះនាមព្រះអង្គគង់ទីខ្ពស់ វិសុទ្ធឥតមោះឥតហ្មងសៅ
បារមីគួរស្ញែងខ្លាចពេកក្រៃ រាល់យប់ថ្ងៃត្រូវតែគោរព ។
១០- អ្នកណាដែលចង់មានប្រាជ្ញា គួរតែគិតថាមានប្រភព
ប្រាជ្ញានឹងកើតមានសព្វគ្រប់ បើអ្នកគោរពខ្លាចព្រះម្ចាស់ ។
អ្នកប្រតិបត្តិតាមប្រាជ្ញានេះ គេអាចត្រិះរិះបានល្អល្អះ
យើងសូមតម្កើងព្រះអម្ចាស់ ជាព្រះខ្ពង់ខ្ពស់រហូតទៅ ។

## ទំនុកតម្កើងលេខ ១១២ (១១១) បទពាក្យ ៧

១- អ្នកឱនកោតខ្លាចព្រះអម្ចាស់ ប្រតិបត្តិច្បាស់តាមព្រះទ័យ
ស្មោះស្ម័គ្រគោរពតាមវិន័យ បានសុខពេកក្រៃមានមង្គល ។
២- ពូជរបស់គេមានអំណាច ចិត្តក្លាអង់អាចគ្មានកង្វល់
ដ្បិតព្រះជាម្ចាស់ប្រទានផល ព្រះពរពិតដល់អ្នកសុចរិត ។
៣- ក្នុងផ្ទះជនដែលមានចិត្តធម៌ មានទ្រព្យបវរល្អប្រណីត
សេចក្តីសុចរិតនៅស្ថេរស្ថិត ព្រះអង្គអាណិតឲ្យពរជាប់ ។
៤- ក្នុងទីងងឹតមានពន្លឺ លេចឡើងបំភ្លឺមិនស្រអាប់
ចិត្តគាត់ប្រណីល្អគួរគាប់ សន្តោសលើសព្វជនប្រុសស្រី ។
៥- ជនណាដែលមានចិត្តទូលាយ យកអ្វីទៅឲ្យអ្នកផងខ្ចី
ព្រមទាំងរករស៊ីមិនកេងកៃ អ្នកនោះប្រពៃល្អបំផុត ។
៦- កេរ្តិ៍ឈ្មោះរន្ទឺឮសុសសាយ ទីជិតទីឆ្ងាយមិនរលត់
ជនគ្រប់សម័យតែងចាំស្ទាត់ នឹកទៅដល់គាត់ជាប់ជានិច្ច ។
៧- អ្នកនោះមិនស្លុតមិនព្រឺខ្លាច មានចិត្តអង់អាចមិនខ្លាចល្បិច
មិនខ្លាចគេជេរលត្មះពន្លិច ហើយផ្ញើជីវិតលើព្រះម្ចាស់ ។

៨- គាត់មានចិត្តនឹងហើយអង់អាច មិនបេះភ័យខ្លាចអ្វីទាំងអស់
ទាល់តែគាត់ឃើញខ្មាំងទាំងនោះ បាក់ទ័ពរត់អស់ទើបស្កប់ចិត្ត ។
៩- គាត់តែងចែកទានដល់អ្នកក្រ ដោយចិត្តស្មោះសរស្ម័គ្រពិតៗ
ចិត្តគាត់ទូលាយត្រង់សុចរិត កម្លាំងគាត់ស្ថិតមិនបាត់បង់ ។
១០- ពេលជនអាក្រក់ឃើញដូច្នោះ ចិត្តគេទោមនស្សខាំធ្មេញផង
បាក់ធ្លាក់ទឹកចិត្តខូចបំណង ពុំសម្រេចម្តងណាសោះឡើយ ។

## ទំនុកតម្កើងលេខ ១១៣ (១១២) បទព្រហ្មគីតិ

១- អស់អ្នកបម្រើព្រះ ជាអម្ចាស់ចូរនាំគ្នា
សរសើរកុំរួញរា ថ្កើងនាមានៃព្រះម្ចាស់ ។
២- ចូរតម្កើងព្រះនាម ព្រះម្ចាស់ភ្លាមកុំក្រឡះ
កុំភ្លេចព្រះអម្ចាស់ ពីពេលនេះរហូតទៅ ។
៣- តាំងពីអារុណរះ ភ្លឺស្រឡះមានកម្តៅ
ទល់ពេលថ្ងៃលិចទៅ សរសើរនៅយ៉ាងស្ម័គ្រស្មោះ ។
៤- ព្រះអម្ចាស់គង់ស្ថិត លើប្រជាជាតិទាំងអស់
សិរីរុងរឿងខ្ពស់ ព្រះម្ចាស់ហួសផុតអាកាស ។
៥- តើមាននរណាមួយ អាចធ្វើឲ្យដូចព្រះម្ចាស់
ព្រះអង្គគង់ខ្ពស់ណាស់ លើអាកាសវិសុទ្ធក្រៃ ។
៦- ព្រះអង្គត្រួតពិនិត្យ យ៉ាងល្អិតល្អិតមកផែនដី
លើមេឃមិនសល់អ្វី សព្វផែនដីមិនកំបាំង ។
៧- ទ្រង់លើកអ្នកទន់ខ្សោយ មិនបណ្តោយឲ្យឈឺស្លាំង
លើកផុតពីភក់ជ្រាំ ផុតអស់ទាំងធូលីដី ។
៨- ដើម្បីឲ្យគេកាន់ អំណាចបានល្អប្រពៃ
នឹងពួកដឹកនាំនៃ រាស្ត្រប្រុសស្រីរបស់ទ្រង់ ។
៩- ព្រះអង្គប្រទានឲ្យ ស្ត្រីអារខ្សោយមានកូនផង
សប្បាយឥតសៅហ្មង កូនរហង់នៅក្នុងផ្ទះ ។

## ទំនុកតម្កើងលេខ ១១៤ (១១៣ ក) បទពាក្យ ៧

១- ពេលអ៊ីស្រាអែលបានចាកចេញ ពីអេស៊ីបវិញហើយពេលនោះ
ពូជពង្សយ៉ាកុបចេញទាំងអស់ ពីដីបរទេសមិនសល់នៅ ។
២- ឯប្រជាជនជាតិយូដា បានក្លាយទៅជាឥតហ្មងសៅ
ជាប្រជាជាតិមិនអាស្រូវ វិសុទ្ធពេកក្រៃផ្ទាល់ព្រះអង្គ ។
៣- ពេលទឹកសមុទ្រឃើញពួកគេ តក់ស្លុតម្ល៉េះទេមិនវេរវង់
គេចខ្លួនថយទៅមិនបង្អង់ ទាំងយ័រដាន់ផងក៏ថយដែរ ។
៤- ភ្នំធំភ្នំតូចភ្នំទាំងអស់ នៅមិនស្ងៀមសោះដូចពពែ
លោតទៅលោតមកមិនឈប់ទេ ភ្នំតូចលោតដែរដូចកូនចៀម ។
៥- ឱ! សមុទ្រអើយម្ដេចក៏អ្នក រត់គេចជាជាក់ទៅនៅស្ងៀម
អ្នកធ្លាប់រលកបោករវាម ម្ដេចសំងំស្ងៀមធ្មឹងដូច្នេះ ? ។
ឱ! ទឹកទន្លេយ័រដាន់អើយ ពេលនេះម្ដេចឡើយរត់លឿនម្ល៉េះ
ម្ដេចអ្នកដកខ្លួនឆាប់ដូច្នេះ តើរឿងទាំងនេះមកពីអ្វី ? ។
៦- ភ្នំអើយម្ដេចអ្នកមិនឈប់លោត ផ្លាស់ប្ដូររហូតដូចសត្វព្រៃ
ភ្នំតូចតើអ្នកលោតព្រោះអ្វី មិនស្គាល់យប់ថ្ងៃមិនសម្រាក ។
៧- ឱ! ផែនដីអើយចូរីករាយ ត្រេកអរសប្បាយចំពោះភក្ត្រ
ព្រះជាអម្ចាស់របស់អ្នក និងចំពោះភក្ត្រព្រះយ៉ាកុប ។
៨- គឺទ្រង់បានធ្វើឲ្យសិលា ប្រែក្លាយទៅជាបឹងសាយសព្វ
ឲ្យថ្មប្រែក្លាយជាប្រភព ទឹកហូរឥតឈប់ឥតស្រាកស្រាន្ត ។

## ទំនុកតម្កើងលេខ ១១៥ (១១៣ ខ) បទភាគគតិ

១- បពិត្រព្រះម្ចាស់ ខ្ញុំមិនគួរសោះ ឲ្យគេតម្កើង មានតែព្រះអង្គ
ទើបត្រូវលើកឡើង ឲ្យខ្ពស់ថ្កុំថ្កើង ព្រោះទ្រង់សប្បុរស ។
២- ម្ដេចក៏ប្រជា គ្រប់ជាតិនានា នាំគ្នាសួរខុស មកយើងខ្ញុំថា
«ពួកឯងទាំងអស់ តើព្រះឯងនោះ ស្ថិតនៅឯណា ?» ។
៣- ព្រះរបស់ខ្ញុំ នៅទីបរម សុខឥតឧបមា ទ្រង់សព្វព្រះទ័យ
ធ្វើកិច្ចអស្ចារ្យ អ្វីសព្វប្រការ បានឥតមានទាស់ ។

៤- ឯព្រះពួកអ្នក ប្រាកដជាជាក់ ព្រះក្លែងក្លាយស្មោះ ខ្លះធ្វើពីឈើ
គគីរកកោះ ពីប្រាក់ពីមាស ជាព្រះគេច្នៃ ។
៥- ព្រះនោះមានមាត់ និយាយមិនកើត មិនដែលចេញស្តី តាមតែជាងឆ្លាក់
ដាក់មកធ្វើអ្វី ភ្នែកឥតប្រស្រី មើលអ្វីមិនបាន ។
៦- រីឯត្រចៀក មានប្រាកដជាក់ តែមិនចំណាន ព្រោះស្តាប់មិនកើត
មិនដឹងដើមដាន ប្រមុះក៏មាន តែមិនដឹងក្លិន ។
៧- មានសព្វទាំងដៃ តែមិនអាចលៃ ប៉ះពាល់ឬកាន់ មានជើងនៅស្ងៀម
ព្រោះដើរមិនបាន បំពង់កមាន តែគ្មានសំឡេង ។
៨- សូមឲ្យអស់អ្នក ដែលបានជាប់ឆ្លាក់ រូបព្រះនោះឯង ហើយផ្ញើជីវិត
គ្មានគិតកោតក្រែង ឲ្យគេចំបែង ដូចព្រះទាំងនោះ ។
៩- អ៊ីស្រាអែលអើយ ចូរកុំកន្តើយ ផ្ញើជីវិតចុះ លើព្រះអម្ចាស់
ទ្រង់និងសង្គ្រោះ ជាខែលគ្រឿងក្រោះ ពាំងអ្នករាល់គ្នា ។
១០- ពូជពង្សរបស់ អរ៉ុនទាំងអស់ ចូរអ្នកម្នីម្នា ផ្ញើជន្មជីវ៉ា
លើព្រះនាមា ទ្រង់និងការពារ ឲ្យអ្នកបានសុខ ។
១១- អ្នកដែលកោតខ្លាច ព្រះមានអំណាច នឹងមិនជួបទុក្ខ បើផ្ញើជីវិត
អ្នកនឹងបានសុខ ពីនេះទៅមុខ ផុតទុក្ខល្ហើយល្ហែ ។
១២- ព្រះមិនបំភ្លេច សូម្បីបន្តិច ដល់ពួកយើងទេ ព្រះអង្គឲ្យពរ
យើងកើនឡើងទ្វេ អ៊ីស្រាអែលដែរ និងលោកអារ៉ុន ។
១៣- ព្រះអង្គប្រទាន ពរទាំងអ្នកមាន អ្នកតូចអ្នកធំ ដែលចេះកោតខ្លាច
ក្រាបថ្វាយបង្គំ យកព្រះជាធំ ជាម្លប់គ្រប់គ្រា ។
១៤- សូមព្រះប្រទាន ពរនោះឲ្យមាន ដល់អ្នករាល់គ្នា បានចម្រើនឡើង
គ្រប់ពេលវេលា បានសុខរមនា កូនចៅប្រុសស្រី ។
១៥- សូមអ្នកទទួល កុំបីអំពល់ ពីម្ចាស់មេឃដី ទ្រង់ប្រទានពរ
បវរសួស្តី ព្រះអម្ចាស់ថ្លៃ ជាព្រះយើងពិត ។
១៦- ផ្ទៃមេឃវែងឆ្ងាយ សន្លឹកអន្លាយ គឺជាកម្មសិទ្ធ របស់ព្រះម្ចាស់
តែមួយអង្គគត់ ព្រះអង្គអាណិត ឲ្យដីមកមនុស្ស ។

១៧- អ្នកស្លាប់ជាខ្មោច មានក្លិនអសោចិ៍ ពុំអាចថ្កើងយស អស់អ្នកដែលចុះ
ទៅស្ថានក្រោមនោះ ក៏ពុំមានឈ្មោះ តម្កើងសិរី ។
១៨- គឺយើងនេះហើយ គ្មានអ្នកផ្សេងឡើយ ដែលរស់លើដី បានលើកតម្កើង
ព្រះអង្គរាល់ថ្ងៃ ឥតមានសំចៃ ជារៀងរហូត ។

## ទំនុកតម្កើងលេខ ១១៦ (១១៥) បទព្រហ្មគីតិ

១- ខ្ញុំស្រឡាញ់ព្រះម្ចាស់ ដ្បិតទ្រង់ព្រះសណ្ដាប់ខ្ញុំ
សំឡេងសោកទួញយំ ទទូចសុំទូលអង្វរ ។
២- ព្រះអង្គផ្ទៀងព្រះកាណ៌ រាល់វេលាដោយស្មោះសរ
ខ្ញុំនឹងស្រែកអង្វរ មិនឈប់ឈរមួយជីវិត ។
៣- ខ្ញុំរងទុក្ខលំបាក គ្មានស្រាន្តស្រាកទាំងភ័យភិត
មច្ចុរាជមករួបរឹត ខ្ញុំតក់ស្លុតខ្លាចខ្លួនក្ស័យ ។
៤- ខ្ញុំខំអង្វរស្រែក ខ្លាំងពន់ពេករកម្ចាស់ថ្លៃ
អាណិតកុំឲ្យក្ស័យ សូមប្រណីសង្គ្រោះផង ។
៥- ព្រះអង្គតែងសន្ដោស ប្រណីប្រោសមិនដែលហ្មង
សុចរិតយុត្តិធម៌ផង ព្រះទ័យទ្រង់មេត្តា ។
៦- ព្រះអម្ចាស់បានជួយ អ្នកខ្សត់ឲ្យផុតខ្លោចផ្សា
ពេលខ្ញុំធ្លាក់កាយា អង្គក្សត្រាមកសង្គ្រោះ ។
៧- ខ្ញុំលែងគិតខ្វល់ខ្វាយ អ្វីទាំងឡាយសព្វទាំងអស់
ដ្បិតព្រះម្ចាស់ទ្រង់ប្រោស ទ្រង់សន្ដោសខ្ញុំសុខសាន្ត ។
៨- ព្រះអង្គបានរំដោះ ខ្ញុំផុតគ្រោះបានថ្កើងថ្កាន
ការពារជ្រែងទប់ប្រាណ ខ្ញុំដើរបានមិនភ័យសោះ ។
៩- ខ្ញុំដើរមិនឈរឈប់ ទាំងថ្ងៃយប់នៅចំពោះ
ព្រះភក្ត្រព្រះជាម្ចាស់ ភពមនុស្សក្នុងលោកនេះ ។
១០- ទោះជាខ្ញុំពោលថា រស់ខ្លោចផ្សាទ្រូងស្ទើរប្រេះ
គង់តែរូបខ្ញុំនេះ មិនបោលព្រះសង្ឃឹមជាប់ ។

១១- ពេលខ្ញុំមានកង្វល់ ចិត្តខ្វាយខ្វល់មិនបានស្ងប់
ខ្ញុំពោលឡើងគ្រប់សព្វ ថាខ្ញុំស្អប់ជនគ្រប់ប្រាណ ។
១២- តើខ្ញុំអាចយកអ្វី តបព្រះទ័យម្ចាស់ថ្កើងថ្កាន
ដែលព្រះអម្ចាស់បាន ប្រោសគ្រប់ប្រាណបានសមរម្យ ។
១៣- គឺខ្ញុំត្រូវលើកពែង ទាំងថ្លាថ្លែងនាមឧត្តម
ព្រះអង្គរំដោះខ្ញុំ យើងស្រែកសុំរកព្រះម្ចាស់ ។
១៤- ខ្ញុំនឹងយកតង្វាយ មកដាក់ថ្វាយក្រាបសំពះ
លាបំណន់ពីព្រះ ជាអម្ចាស់មុខប្រជា ។
១៥- ទ្រង់ព្រួយព្រះទ័យណាស់ ពេលមានរាស្ត្រស្លាប់វេទនា
ជនវិសុទ្ធគ្រប់គ្នា ទ្រង់ការពារមិនស្លាប់ឡើយ ។
១៦- ឱ! ព្រះម្ចាស់ប្រសើរ ខ្ញុំបម្រើព្រះអង្គហើយ
ព្រះអង្គមិនកន្តើយ ខ្ញុំបានស្បើយពីមរណា ។
១៧- ទូលបង្គំសូមថ្វាយ យញ្ញទាំងឡាយដោយជ្រះថ្លា
អង្វរព្រះបិតា ព្រះបុត្រាខ្ពស់ពេកពន់ ។
១៨- ខ្ញុំនឹងយកតង្វាយ មកដាក់ថ្វាយលាបំណន់
នៅមុខប្រជាជន ដែលបានបន់ដល់ព្រះអង្គ ។
១៩- គឺនៅក្នុងទីធ្លា ព្រះវិហារស្រស់បំព្រង
ស្ថិតនៅកណ្តាលក្រុង សូមផ្ចិតផ្ចង់លើកតម្កើង ។

## ទំនុកតម្កើងលេខ ១១៧ (១១៦) បទពាក្យ ៧

១- ឱ! ប្រជាជនទាំងឡាយអើយ ចូរសរសើរហើយលើកម្កើង
អស់ប្រជារាស្ត្រផ្នែផ្នើង តម្កើងសិរីនៃព្រះអង្គ ។
២- ដ្បិតព្រះអង្គមានហឫទ័យ ករុណាប្រណីពេកកន្លង
សប្បុរសស្មោះស្ម័គ្រឥតមានហ្មង នឹងយើងរហូតតរៀងទៅ ។

**ទំនុកតម្កើងលេខ ១១៨ (១១៧)** **បទពាក្យ ៧**

១- សូមលើកតម្កើងព្រះអម្ចាស់ ប្រសើរពេកណាស់ព្រះទ័យថ្លៃ
សប្បុរសករុណាត្រាប្រណី ស្ថិតស្ថេររាល់ថ្ងៃរហូតទៅ ។
២- សូមឲ្យប្រជាទ្រង់ប្រកាស សម្ដែងចេញច្បាស់កុំទុកនៅ
ព្រះទ័យមេត្តាដ៏ត្រឹមត្រូវ ស្ថិតស្ថេរគង់នៅដូចថ្ងៃរះ ។
៣- ឲ្យអស់ពូជពង្សលោកអរ៉ុន កុំនៅទំរន់ស្រែកឲ្យច្បាស់
ប្រកាសព្រះទ័យករុណាព្រះ ស្ថិតនៅយ៉ាងច្បាស់គ្រប់កន្លែង ។
៤- អស់អ្នកគោរពកោតខ្លាចព្រះ ក៏ត្រូវប្រកាសឲ្យក្ដែងៗ
ដូចអ៊ីស្រាអែលកុំបីក្រែង ហឫទ័យស្ងប់ស្ញែងនៅស្ថិតស្ថេរ ។
៥- ពេលខ្ញុំមានទុក្ខតប់ប្រមល់ ខ្ញុំអង្វរដល់ព្រះឥតប្រែ
ព្រះម្ចាស់ក៏តបមកវិញដែរ ទ្រង់ថ្នមបំពេរខ្ញុំបានសុខ ។
៦- ព្រះអម្ចាស់គង់កាន់ខាងខ្ញុំ ទុក្ខភ័យតូចធំចេញពីមុខ
លែងព្រួយលែងខ្លាចលែងកើតទុក្ខ តើមនុស្សលោកធ្វើអ្វីបាន ? ។
៧- ព្រះអង្គម្ចាស់គង់នៅជាមួយ ទ្រង់ការពារជួយខ្ញុំសុខសាន្ត
ឃើញអ្នកប្រឆាំងទាំងប៉ុន្មាន រត់ប្រាសបាកស្ថានដូចចិត្តប៉ង ។
៨- ខ្ញុំសង្ឃឹមជ្រកនិងពឹងពាក់ មានជំនឿជាក់និងបំណង
លើព្រះអម្ចាស់ពេកកន្លង ជាងពឹងផ្អែកជងជនក្បាលខ្មៅ ។
៩- ខ្ញុំសង្ឃឹមជ្រកនិងពាក់ពឹង មានជំនឿរឹងមាំទាំទៅ
លើព្រះអម្ចាស់ទើបត្រឹមត្រូវ ជាងយើងពឹងទៅលើអ្នកធំ ។
១០- ជនជាតិដទៃអ្នកប្រឆាំង បានឡោមព័ទ្ធពាំងលើរូបខ្ញុំ
តែដោយព្រះម្ចាស់អំណាចធំ ជួយប្រយុទ្ធខ្ញុំបានឈ្នះគេ ។
១១- គេបានរោមជិតរឹតឡោមព័ទ្ធ ចង់ចូលសង្កត់ឲ្យខ្ញុំប្រែ
តែដោយព្រះអម្ចាស់មើលថែ ជួយប្រយុទ្ធដែរខ្ញុំមានជ័យ ។
១២- វាមកឡោមព័ទ្ធខ្ញុំជិតជុំ ដូចជាហ្វូងឃ្មុំច្រើនជាសដី
តែវាត្រូវឆេះដូចភ្លើងព្រៃ ខ្ទេចខ្ទីម៉ត់ខៃដោយនាមព្រះ ។

១៣- ខ្មាំងបានប្រានជួលខ្ញុំយ៉ាងខ្លាំង ខ្ញុំដួលស្លេកស្លាំងប្រឹងសំពះ
រកឲ្យព្រះជួយឆាប់រហ័ស ពេលនោះព្រះម្ចាស់ទ្រង់យាងមក ។
១៤- ព្រះម្ចាស់ពិតជាកម្លាំងខ្ញុំ ខ្ញុំស្រែកខ្ញុំយំប្រឹងស្រែករក
មានព្រះនាមព្រះផុតទុក្ខសោក ព្រះអង្គចេញមកច្បាំងការពារ ។
១៥- មនុស្សសុចរិតចិត្តអង់អាច មិនចេះកោតខ្លាចស្រែកគ្រប់គ្នា
ច្រៀងថ្វាយព្រះអង្គមានឫទ្ធា សម្តែងតេជាអានុភាព ។
១៦- ព្រះអង្គសម្តែងបារមីខ្ពស់ ប្រសើរលើសលស់មិនទន់ទាប
ព្រះអង្គបង្ហាញឲ្យគេជ្រាប ឫទ្ធានុភាពអស្ចារ្យក្រៃ ។
១៧- ខ្ញុំត្រូវនៅរស់មានជីវិត មិនត្រូវស្លាប់ផុតបាកលោកីយ៍
ដើម្បីរៀបរាប់ពីសេចក្តី ស្នាព្រះហស្តថ្លៃព្រះអម្ចាស់ ។
១៨- ព្រះអង្គវាយប្រដៅអប់រំ ទះតប់រូបខ្ញុំប្រាកដណាស់
តែទ្រង់ស្រឡាញ់មិនឲ្យប្រាស មិនឲ្យមានគ្រោះឬត្រូវស្លាប់ ។
១៩- ចូរនាំគ្នាបើកទ្វារឲ្យមនុស្ស សុចិតស្រីប្រុសមកប្រញាប់
ខ្ញុំនឹងចូលទៅឲ្យបានឆាប់ នឹងថ្លែងរៀបរាប់អរគុណទ្រង់ ។
២០- ទ្វារនេះជាទ្វារព្រះអម្ចាស់ សូមជនស្រីប្រុសដើរតម្រង់
អ្នកសុចរិតអើយកុំបង្អង់ ទ្វារបើកបម្រុងនៅចាំអ្នក ។
២១- ខ្ញុំនឹងតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គត្រាស់ដោយច្បាស់ជាក់
តបឆ្លើយមកខ្ញុំពាក្យរាក់ទាក់ ថែមទាំងថ្នមថ្នាក់ខ្ញុំជិតដល់ ។
២២- ថ្មដែលជាងផ្ទះបោលខ្ទេចខ្ទាំ ប្រែជារឹងមាំបែរជាកល់
ជើងសសរផ្ទះមាំឥតខ្វល់ ល្បីល្បាញឮដល់សព្វជាតិសាសន៍ ។
២៣- ព្រះអង្គសម្រេចការអស្ចារ្យ ដោយឫទ្ធិថ្លៃថ្លានៃអម្ចាស់
អស្ចារ្យពេកក្រៃយើងឃើញច្បាស់ គួរស្ញប់ស្ញែងណាស់គួរគោរព ។
២៤- ថ្ងៃនេះជាថ្ងៃដែលព្រះម្ចាស់ កំណត់ទុកច្បាស់ឲ្យយើងឈប់
នាំគ្នាសប្បាយកុំនៅជ្រប់ ខេត្តស្រុកភូមិគ្រប់អរទាំងអស់ ។
២៥- ឱ! ព្រះអម្ចាស់សូមសង្គ្រោះ ឲ្យខ្ញុំល្បីឈ្មោះមានសម្រស់
មានជោគមានជ័យខ្លាំងឥតខ្ចោះ យើងនឹកអាឡោះអាល័យណាស់ ។

២៦- យើងសូមតម្កើងលើកព្រះអង្គ ដែលយាងមកក្នុងនាមព្រះម្ចាស់
យើងដែលស្ថិតក្នុងដំណាក់ព្រះ សូមពរតេជះល្អប្រពៃ ។
២៧- ព្រះអម្ចាស់បានបំភ្លឺយើង ភ្លឺផ្លេកប្បាស់ឡើងដូចពេលថ្ងៃ
ជាងទន្សែយើងកាន់នៅដៃ ហែក្បួនវែងក្រៃដល់អាសនៈ ។
២៨- ព្រះអង្គជាព្រះទូលបង្គំ ផ្ដល់ក្ដីសុខុមឥតមានអាក់
ខ្ញុំសូមតម្កើងដោយស្មោះស្ម័គ្រ ដោយការជឿជាក់អស់ពីចិត្ត ។
២៩- ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតទ្រង់មានព្រះទ័យអាណិត
សប្បុរសករុណាត្រង់សុចរិត អស់កល្បស្ថេរស្ថិតរហូតទៅ ។

## ទំនុកតម្កើងលេខ ១១៩ (១១៨)

**បទកាកគតិ**

១- អ្នកណាដែលមាន កិរិយាជាប់ប្រាណ ត្រឹមត្រូវឥតខ្ចោះ ប្រតិបត្តិតាម
ធម្មវិន័យព្រះ អ្នកនោះប្រទះ តែសុខមង្គល ។
២- អ្នកដែលប្រតិបត្តិ តាមផ្លូវល្អពិត បញ្ញានិម្មល ហើយស្វែងរកព្រះ
មិនខ្ជីខ្ជាខ្ជិល ពិតជាបានផល មង្គលពេកហោង ។
៣- អ្នកនោះមិនធ្វើ ប្រព្រឹត្តអំពើ នាំឲ្យសៅហ្មង អាក្រក់អាប់អួ
តែគេដើរឆ្លង តាមស្នាមគន្លង ព្រះអម្ចាស់វិញ ។
៤- ព្រះអង្គចេញច្បាប់ ដោយប្រកាសប្រាប់ ឲ្យយើងស្រឡាញ់ យកចិត្តទុកដាក់
ព្យាយាមទន្ទេញ ខិតខំបំពេញ ដានស្នាមព្រះអង្គ ។
៥- សូមជួយខ្ញុំផង ឲ្យដូចបំណង មានចិត្តរឹងប៉ឹង ដើម្បីប្រតិបត្តិ
តាមក្រឹត្យព្រះអង្គ វិន័យត្រឹមត្រង់ តាមទ្រង់បញ្ជា ។
៦- ប្រសិនដូច្នេះ ពេលណាខ្ញុំត្រិះ រិះពិចារណា វិន័យទាំងអស់
សព្វគ្រប់ប្រការ នោះខ្ញុំនេះណា មិនខកបំណង ។
៧- ខ្ញុំសូមតម្កើង ព្រះអង្គខ្ពស់ឡើង ដោយចិត្តស្មោះត្រង់ ដោយពិចារណា
ក្ដីសុចរិតផង ពេលដែលព្រះអង្គ សម្រេចឥតខ្ចោះ ។
៨- ខ្ញុំចង់កាន់តាម វិន័យបំរាម ដែលមានទាំងអស់ តែសូមព្រះអង្គ
កុំប្រែបង់បោះ បោលខ្ញុំស្រឡះ ឲ្យសោះឡើយណា ។

# សូមដូរទៅជាបទពាក្យ ៧

៩- តើពួកយុវជនធ្វើយ៉ាងណា ឲ្យមានកិរិយាល្អត្រឹមត្រូវ
គឺប្រតិបត្តិត្រង់តាមផ្លូវ មាគ៌ាតទៅនៃព្រះអង្គ ។

១០- ខ្ញុំខំស្វះស្វែងមិនមានឈប់ ទោះថ្ងៃឬយប់ចិត្តតម្រង់
កុំទុកឲ្យខ្ញុំនៅត្រមង់ វង្វេងវង្វង់ពីវិន័យ ។

១១- ខ្ញុំសូមតាំងចិត្តថែរក្សា បន្ទូលសន្យាដ៏ប្រពៃ
នៅក្នុងចិត្តខ្ញុំមិនធ្វើអ្វី ឲ្យទាស់ព្រហឫទ័យទ្រង់ឡើយណា ។

១២- បពិត្រព្រះម្ចាស់ដ៏ឧត្តម ទូលបង្គំខ្ញុំលើកហត្ថា
តម្កើងព្រះអង្គសូមមេត្តា បង្រៀនខ្ញុំណាស្គាល់វិន័យ ។

១៣- ខ្ញុំតែងតែពោលឥតឈប់ឈប់ រៀបរាប់សព្វគ្រប់នូវសេចក្ដី
ទាំងប៉ុន្មានដែលអម្ចាស់ថ្លៃ សម្រេចព្រះទ័យផ្ដល់ជាទាន ។

១៤- ទូលបង្គំត្រេកអរអនេក ដោយបានពឹងផ្អែកដំបូន្មាន
ប្រៀបដូចជាខ្ញុំទទួលបាន សម្បត្តិថ្កើងថ្កានដ៏ស្ដុកស្ដម្ភ ។

១៥- ទូលបង្គំនឹងពិចារណា ច្បាប់គ្រប់ប្រការទ្រង់ណែនាំ
សញ្ជឹងពីមាគ៌ាឧត្តម ព្រះអង្គរឹងមាំជាប់ជានិច្ច ។

១៦- ខ្ញុំពេញចិត្តណាស់នឹងវិន័យ ព្រះអម្ចាស់ថ្លៃមិនមានភ្លេច
បន្ទូលព្រះអង្គចាំជានិច្ច ចាំគ្រប់ពាក្យពេចន៍មិនភ្លេចឡើយ ។

១៧- សូមសន្ដោសខ្ញុំដែលជាអ្នក បម្រើស្មោះស្ម័គ្រព្រះអង្គហើយ
នោះជីវិតខ្ញុំបានធូរស្បើយ មិនលោកន្តើយគោរពតាម ។

១៨- សូមទ្រង់បើកភ្នែកទូលបង្គំ ពេលនោះរូបខ្ញុំនឹងឃើញស្នាម
ឃើញភាពថ្លៃថ្នូរគ្មានប្រេះស្រាំ អស្ចារ្យនៃធម្មវិន័យទ្រង់ ។

១៩- ខ្ញុំស្នាក់នៅលើផែនដីនេះ គឺគ្រាន់បណ្ដោះមិនយូរលង់
សូមកុំលាក់វិន័យព្រះអង្គ បង្ហាញខ្ញុំផងសូមប្រណី ។

២០- ចិត្តទូលបង្គំតែងនឹកភ្នក ផ្ដោតចិត្តទៅរកសព្វសេចក្ដី
ដែលទ្រង់សម្រេចព្រះហឫទ័យ ឲ្យជនប្រុសស្រីចាំជានិច្ច ។

២១- ព្រះអង្គគំរាមកំហែងមនុស្ស      ដែលអួតអាងខុសមានកលល្បិច
ត្រូវបណ្ដាសាជាប់ឥតភ្លេច      វង្វេងឆ្ងាយគេចពីវិន័យ ។
២២- សូមដកយកនូវការអាម៉ាស់      កុំឲ្យគេត្មះដៀលដេរស្តី
ព្រោះទូលបង្គំកាន់វិន័យ      ដំបូន្មានថ្លៃឥតថ្លោះធ្លោយ ។
២៣- ទោះមេដឹកនាំខំប្រឆាំង      ពុះពាររារាំងខ្ញុំក៏ដោយ
ខ្ញុំនៅសញ្ជឹងមិនកន្តើយ      ក្រឹត្យព្រះអង្គហើយជាប់ជានិច្ច ។
២៤- ខ្ញុំពេញចិត្តនឹងដំបូន្មាន      ឥតបីស្រាកស្រាន្តឥតកែគេច
ដំបូន្មានទ្រង់ចាំងរំលេច      នាំផ្លូវជីវិតខ្ញុំសុខសាន្ត ។
២៥- ឥឡូវនេះខ្ញុំដុនដាបខ្លាំង      ឥតមានកម្លាំងស្ទើរក្ស័យប្រាណ
សូមប្រោសឲ្យខ្ញុំរស់ឡើងបាន      តាមបន្ទូលថ្កានទ្រង់សន្យា ។
២៦- ខ្ញុំបានរៀបរាប់ពីជីវិត      ដំណើររឿងពិតគ្រប់ប្រការ
ទ្រង់សណ្ដាប់ហើយសូមមេត្តា      ឲ្យខ្ញុំនេះណាស្គាល់វិន័យ ។
២៧- ទាំងប្រោសប្រទានឲ្យខ្ញុំយល់      សព្វទាំងឫសគល់នូវអត្ថន័យ
បញ្ញាព្រះអង្គខ្ញុំរំពៃ      ការអស្ចារ្យក្រៃទ្រង់ទាំងអស់ ។
២៨- ខ្ញុំមានទុក្ខព្រួយយ៉ាងធំធេង      យំសោកសង្រេងមិនឈប់សោះ
សូមលើកទឹកចិត្តឲ្យស្រស់បស់      តាមបន្ទូលព្រះអង្គសន្យា ។
២៩- សូមឲ្យខ្ញុំចៀសចាកចេញផុត      ឆ្ងាយពីពាក្យភូតភរឫស្យា
សូមជួយបង្ហាញក្ដីករុណា      វិន័យថ្លៃថ្លាឲ្យខ្ញុំស្គាល់ ។
៣០- ខ្ញុំប្ដេជ្ញាចិត្តជឿស្មោះត្រង់      ទៅលើព្រះអង្គឥតមានខ្វល់
ជឿដោយចិត្តស្មោះឥតសេសសល់      តាមបង្គំគាល់ព្រះបញ្ញា ។
៣១- ខ្ញុំជំពាក់ចិត្តស្និតអនេក      ដំបូន្មានឯកឥតរួញរា
ឱ! ព្រះអម្ចាស់សូមមេត្តា      ខ្ញុំផុតទុក្ខាផុតអាម៉ាស់ ។
៣២- ខ្ញុំខំយកចិត្តទុកដាក់នឹង      មាគ៌ាព្រះអង្គពន់ពេកណាស់
ដ្បិតទ្រង់ប្រោសចិត្តខ្ញុំស្រឡះ      ឲ្យបានយល់ច្បាស់ភ្លឺថ្លាថ្លៃ ។
៣៣- ឱ! ព្រះម្ចាស់អើយសូមព្រះអង្គ      បង្ហាញខ្ញុំផងពីវិន័យ
ឲ្យខ្ញុំកាន់តាមរៀងរាល់ថ្ងៃ      តាមព្រះវិន័យដោយស្ម័គ្រស្មោះ ។

៣៤- សូមព្រះប្រទាននូវប្រាជ្ញា ឲ្យខ្ញុំភ្លឺថ្លាសព្វទាំងអស់
របស់ព្រះអង្គកុំចន្លោះ កាន់តាមឥតខ្ចោះដោយស្ម័គ្រចិត្ត ។
៣៥- សូមណែនាំខ្ញុំតាមមាគ៌ា វិន័យធម្មាច្បាប់ក្រមក្រឹត្យ
ដ្បិតខ្ញុំស្រឡាញ់ហើយពេញចិត្ត វិន័យនោះពិតល្អត្រជាក់ ។
៣៦- សូមទាក់ទាញចិត្តទូលបង្គំ ឲ្យធ្វើតាមដំបូន្មានទ្រង់
កុំឲ្យចិត្តខ្ញុំនៅវេរវង់ ឬមានបំណងរកកម្រៃ ។
៣៧- សូមទាក់ទាញអារម្មណ៍ខ្ញុំឲ្យ ងាកបកថយក្រោយចេញពីអ្វី
ដែលគ្មានខ្លឹមសារមិនប្រពៃ ជីវិតខ្ញុំថ្លៃព្រោះមាគ៌ា ។
៣៨- សូមសម្រេចមកទូលបង្គំ បម្រើឧត្តមដ៏ថ្លៃថ្លា
តាមព្រះបន្ទូលបានសន្យា សម្រាប់អ្នកណាកោតខ្លាចទ្រង់ ។
៣៩- សូមការពារខ្ញុំកុំឲ្យគេ មើលងាយដៀលដេរមិនទំនង
ដ្បិតការសម្រេចនៃព្រះអង្គ សុទ្ធតែត្រឹមត្រង់ត្រូវទាំងអស់ ។
៤០- ខ្ញុំមានបំណងចង់ធ្វើតាម វិន័យបំរាមល្អឥតខ្ចោះ
ដោយក្ដីសុចរិតព្រះអង្គនោះ ជួយខ្ញុំឲ្យរស់ឡើងវិញជង ។
៤១- ឱព្រះម្ចាស់អើយសូមប្រណី សម្ដែងព្រះទ័យឥតមានហ្មង
សង្គ្រោះមកទូលបង្គំជង តាមបន្ទូលទ្រង់បានសន្យា ។
៤២- សូមឲ្យខ្ញុំអាចតប ត ឆ្លើយ នឹងអ្នកណាហើយដែលមុសា
ដ្បិតខ្ញុំសង្ឃឹមផ្ញើវាសនា ជីវិតកាយាលើព្រះអង្គ ។
៤៣- សូមកុំបណ្ដោយខ្ញុំស្រដី ពាក្យមិនប្រពៃមិនត្រឹមត្រង់
ដ្បិតខ្ញុំសង្ឃឹមលើព្រះអង្គ ការសម្រេចទ្រង់ឥតសង្ស័យ ។
៤៤- ទូលបង្គំនឹងគោរពតាម បញ្ញត្តិបំរាមទាំងវិន័យ
របស់ព្រះអង្គរៀងរាល់ថ្ងៃ ជានិច្ចលុះក្ស័យសូន្យជីវី ។
៤៥- ខ្ញុំចង់រស់នៅដោយមានន័យ និងមានសេរីភាពពេញទី
ដ្បិតទូលបង្គំស្វែងសំភី រកច្បាប់គ្រប់ទីរបស់ទ្រង់ ។
៤៦- ខ្ញុំនឹងថ្លែងពីដំបូន្មាន គ្រប់ទិសទីស្ថានមិនបង្អង់
ទូលស្ដេចនានាទាំងអស់ជង នោះរូបខ្ញុំនឹងមិនខ្មាសឡើយ ។

៤៧- ខ្ញុំពេញចិត្តណាស់នឹងវិន័យ    ពេញចិត្តរាល់ថ្ងៃមិនកន្តើយ
ខ្ញុំស្រឡាញ់ណាស់ព្រះម្ចាស់អើយ    វិន័យនេះហើយខ្ញុំសុខសាន្ត ។
៤៨- ទូលបង្គំលើកដៃប្រណម្យ    គោរពទាំងព្រមមិនខកខាន
ស្រឡាញ់វិន័យមិនស្រាកស្រាន្ត    ចង់គិតចង់បានក្រឹត្យវិន័យ ។

## សូមដូរទៅជាបទកាកគតិ

៤៩- ឱព្រះអម្ចាស់    សូមនឹកដល់ព្រះ    បន្ទូលសន្យា    ជាមួយនឹងខ្ញុំ
កុំបីប្រែះឆា    ជនគ្រប់កាយា    សង្ឃឹមទុកចិត្ត ។
៥០- ពេលខ្ញុំមានទុក្ខ    នៅមិនស្រណុក    ព្រះអង្គអាណិត    ឲ្យខ្ញុំធូរស្បើយ
ទាំងកាយទាំងចិត្ត    ធ្វើឲ្យជីវិត    ខ្ញុំរស់វិញបាន ។
៥១- ទោះបីជនពាល    បាក់រុកឆ្កឹះឆ្កៀល    ចំអកសាមាន្យ    តែខ្ញុំមិនឃ្លាត
វិន័យថ្កើងថ្កាន    ឬចង់ប្រែប្រាណ    ក្រឡះបំភ្លៃ ។
៥២- បពិត្រព្រះម្ចាស់    ខ្ញុំនឹកទ្រង់ណាស់    បន្ទូលថ្លាថ្លៃ    សន្យាព្រះអង្គ
ពីដើមប្រពៃ    ខ្ញុំសុខឥតបី    ទុក្ខសោករសាយ ។
៥៣- ពេលពួកមនុស្ស    ពាលមិនស្គាល់ខុស    ឲ្យខ្ញុំខ្វល់ខ្វាយ    បាក់រុកឆ្កឹះឆ្កៀល
ឲ្យក្តៅក្រហាយ    គេចង់កម្ចាយ    វិន័យព្រះអង្គ ។
៥៤- ខ្ញុំស្នាក់អាស្រ័យ    នៅលើផែនដី    រាល់ថ្ងៃផ្ចិតផ្ចង់    ខ្ញុំយកវិន័យ
របស់ព្រះអង្គ    មកច្នៃតម្រង់    ធ្វើបទតម្កើង ។
៥៥- ព្រះអម្ចាស់អើយ    រាល់ពេលយប់ហើយ    ខ្ញុំរលឹកឡើង    ព្រះនាមព្រះអង្គ
ខ្ពង់ខ្ពស់ថ្កុំថ្កើង    វិន័យរុងរឿង    ខ្ញុំប្រតិបត្តិតាម ។
៥៦- រូបខ្ញុំបានសុខ    មង្គលគ្រប់មុខ    ព្រោះតែបំរាម    វិន័យបញ្ញត្តិ
ដែលទ្រង់បានហាម    ខ្ញុំខំធ្វើតាម    មិនហ៊ានបំពាន ។

## សូមដូរទៅជាបទពាក្យ ៧

៥៧- បពិត្រព្រះម្ចាស់អើយខ្ញុំសូម    បង្គំទូលព្រមព្រះអង្គថា
ធ្វើតាមបញ្ញារកុំសាវ៉ា    ជាកេរថ្លៃថ្លារបស់ខ្ញុំ ។

៥៨- ខ្ញុំខិតខ្ញុំខំទាំងយប់ថ្ងៃ　　ដោយគាប់ព្រះទ័យព្រះឧត្តម
សូមត្រាប្រណីសន្ដោសខ្ញុំ　　តាមការទូលសុំទ្រង់សន្យា ។

៥៩- ខ្ញុំរិះគិតអំពីមារយាទ　　គំនិតបោលម្សៀតឥតបានការ
បោះជំហានត្រង់ចរយាត្រា　　ឆ្ពោះឥតរួញរារកព្រះអង្គ ។

៦០- ប្រញាប់ប្រញាល់ប្រតិបត្តិ　　តាមវិន័យក្រឹត្យឥតមានឆ្គង
មិនធ្វេសប្រហែសមិនមានហ្មង　　ដោយចិត្តស្ម័គ្រជងមិនរួញរា ។

៦១- ពួកជនអាក្រក់ធ្វើឲ្យខ្ញុំ　　ជាប់អន្ទាក់រុំរបស់វា
តែទូលបង្គំខំពុះពារ　　គោរពមាគ៌ាច្បាប់ព្រះអង្គ ។

៦២- ពេលកណ្ដាលយប់អជ្រាតស្ងាត់　　ខ្ញុំក្រោកថ្វាយថ្វាត់ដៃផ្ចិតផ្ចង់
គោរពសរសើរថ្កើងព្រះអង្គ　　សម្រេចត្រឹមត្រង់ល្អពេកក្រៃ ។

៦៣- ខ្ញុំរួមកាយចិត្តគំនិតជាក់　　ជាមួយអស់អ្នកល្អត្រឹមត្រូវ
គឺអ្នកដែលប្រព្រឹត្តតាមផ្លូវ　　មាគ៌ាត្រឹមត្រូវព្រះនៃយើង ។

៦៤- ផែនដីពេញដោយព្រះហឫទ័យ　　ព្រះម្ចាស់ថ្លើមថ្លៃក៏ថ្កានថ្កើង
សូមទ្រង់បង្រៀនវិន័យផង　　ព្រះនាមព្រះអង្គឲ្យខ្ញុំស្គាល់ ។

៦៥- បពិត្រព្រះអម្ចាស់ខ្ញុំអើយ　　ទ្រង់សន្ដោសហើយខ្ញុំមិនខ្វល់
ខ្ញុំអ្នកបម្រើបង្គំគាល់　　តាមព្រះបន្ទូលទ្រង់សន្យា ។

៦៦- សូមប្រោសប្រណីឲ្យខ្ញុំចេះ　　គិតគូរវៃឈ្លាសមានប្រាជ្ញា
ឲ្យស្គាល់វិន័យសព្វប្រការ　　ដ្បិតខ្ញុំនេះណាមិនក្រឡះ ។

៦៧- កាលគ្រាមុននោះខ្ញុំវង្វេង　　កណ្ដោចកណ្ដែងវេទនាណាស់
តែឥឡូវនេះខ្ញុំយល់ច្បាស់　　ខ្ញុំខំរួតរះតាមបញ្ញា ។

៦៨- ទ្រង់មានព្រះទ័យសប្បុរស　　ករុណាសន្ដោសមនុស្សនានា
សូមទ្រង់បង្រៀនក្រឹត្យធម្មា　　វិន័យបញ្ញាតរៀងទៅ ។

៦៩- អ្នកអួតបំប៉ោងនាំគ្នាជុំ　　បង្ខូចឈ្មោះខ្ញុំឲ្យអាស្រូវ
តែទូលបង្គំឆ្ពោះសំដៅ　　ដើរទៅតាមផ្លូវច្បាស់ព្រះអង្គ ។

៧០- ពួកគេជាអ្នកដែលគ្មានបិត្ត　　មិនចេះរិះគិតដ្បិតគេល្ងង់
ឯខ្ញុំពេញចិត្តឥតរេរង់　　វិន័យព្រះអង្គល្អត្រចះ ។

៧១- ទូលបង្គំរងទុក្ខវេទនា　　នោះក៏គឺជាប្រពៃណាស់
ដើម្បីខ្ញុំបានរៀនឲ្យច្បាស់　　ពីវិន័យព្រះដ៏ថ្លាថ្លៃ ។
៧២- ធម្មវិន័យដែលទ្រង់បាន　　ប្រកាសឲ្យកាន់មានតម្លៃ
ប្រសើរជាងមាសពេជ្រចរណៃ　　ជាងប្រាក់ក្រាស់ក្រៃច្រើនលើសលប់ ។
៧៣- ព្រះអង្គបង្កើតទូលបង្គំ　　ឲ្យបានរឹងមាំមានសព្វគ្រប់
សូមឲ្យមានទាំងប្រាជ្ញាគាប់　　បានសិក្សាច្បាប់វិន័យផង ។
៧៤- អ្នកដែលគោរពកោតខ្លាចព្រះ　　បានឃើញខ្ញុំច្បាស់ឥតមួរម៉ង
គេនឹងសប្បាយពេកកន្លង　　ជីវិតខ្ញុំផងផ្ញើលើព្រះ ។
៧៥- បពិត្រព្រះម្ចាស់អើយខ្ញុំស្គាល់　　ខ្ញុំដឹងខ្ញុំយល់ថាព្រះម្ចាស់
សម្រេចពីអ្វីសុចរិតច្បាស់　　ទ្រង់ដាក់ទោសណាស់ក៏ត្រឹមត្រូវ ។
៧៦- សូមទ្រង់មេត្តាជួយសម្រាល　　ទុក្ខខ្ញុំឲ្យស្រាលកុំឲ្យនៅ
តាមទ្រង់សន្យាកុំហ្មងសៅ　　ដល់ខ្ញុំដែលត្រូវជាបម្រើ ។
៧៧- សូមទ្រង់បង្ហាញធម៌មេត្តា　　ឲ្យមានជីវ៉ារស់គ្រាន់បើ
លើលោកីយ៍នេះខ្ញុំបម្រើ　　តាមវិន័យធម៌ដោយរីករាយ ។
៧៨- ឲ្យអ្នកអួតអាងត្រូវអាម៉ាស់　　ដ្បិតគេពោលផ្តាសពាក្យមើលងាយ
បង្កាច់រូបខ្ញុំឲ្យអន្តរាយ　　ឯខ្ញុំមិនណាយពីច្បាប់ទ្រង់ ។
៧៩- សូមអ្នកគោរពព្រះមកជុំ　　នាំគ្នារកខ្ញុំកុំបង្អង់
ឲ្យខ្ញុំស្គាល់ពាក្យទូន្មានផង　　របស់ព្រះអង្គល្អពេកក្រៃ ។
៨០- សូមជួយរូបខ្ញុំឲ្យប្រព្រឹត្ត　　តាមវិន័យក្រឹត្យរៀងរាល់ថ្ងៃ
បានល្អឥតខ្មោះមិនក្រឡៃ　　រូបខ្ញុំគ្មានថ្ងៃត្រូវខ្មាសគេ ។
៨១- ខ្ញុំទន្ទឹងចាំព្រះសង្គ្រោះ　　ជាព្រះរបស់ខ្ញុំគ្មានល្ហែ
រូបខ្ញុំពឹងលើរាល់ថ្ងៃខែ　　សង្ឃឹមឥតប្រែលើព្រះអង្គ ។
៨២- ខ្ញុំខិតខំប្រឹងនៅរង់ចាំ　　បន្ទូលឧត្តមរបស់ទ្រង់
តើពេលណាទៅទើបព្រះអង្គ　　សម្រាលទុក្ខផងខ្ញុំល្ហែល្ហើយ ។
៨៣- រូបខ្ញុំជាអ្នកគ្មានគេរាប់　　រស់នៅអភ័ព្វណាស់ព្រះអើយ
ចាំតែវិន័យមិនកន្តើយ　　ឥតមានភ្លេចឡើយលុះមរណា ។

៨៤- តើឲ្យរូបខ្ញុំទ្រាំម្ដេចកើត ឬទ្រាំរហូតសូន្យសង្ខា
ម្ដេចទ្រង់មិនប្រទេចផ្ដាសា ដាក់ទោសជនណាដែលសាមាន្យ ។
៨៥- អ្នកមិនគោរពច្បាប់វិន័យ គេចង់ធ្វើអ្វីដែលរំខាន
គេជីករណ្ដៅចំារុញប្រាន ឲ្យខ្ញុំក្ស័យប្រាណនៅក្នុងនោះ ។
៨៦- វិន័យព្រះអង្គសុទ្ធតែពិត សូមទ្រង់អាណិតប្រណីប្រោស
សូមជួយរូបខ្ញុំនេះផងចុះ គេបៀតបៀនហួសគ្មានហេតុផល ។
៨៧- នៅតែបន្តិចគេប្រហារ ឲ្យខ្ញុំមរណាមិនទុកសល់
តែទូលបង្គំមិនខ្វាយខ្វល់ ឬមានកិច្ចកលបោលវិន័យ ។
៨៨- សូមប្រទានខ្ញុំមានជីវិត រស់ឡើងវិញពិតដោយហឫទ័យ
មេត្តាករុណាល្អប្រពៃ ព្រះបន្ទូលថ្លៃខ្ញុំប្រតិបត្តិ ។
៨៩- បពិត្រព្រះម្ចាស់ព្រះបន្ទូល គង់វង្សមុតមូលមិនខ្វាយខ្វាត់
នៅស្ថានបរមសុខមិនរលត់ អស់កល្បរហូតតរៀងទៅ ។
៩០- ព្រះអង្គមានព្រះទ័យស្ម័គ្រស្មោះ ប្រសើរសប្បុរសមិនអាស្រូវ
ព្រះអង្គតែងតាំងដែនដីនៅ រឹងប៉ឹងពេកកូវនៅស្ងប់ស្ងៀម ។
៩១- អ្វីៗទាំងអស់សព្វសារពើ ឥតប្រែប្រួលរើឬស្ថិតក្រៀម
មកដល់សព្វថ្ងៃឥតលាក់លៀម សុទ្ធតែនៅក្រោមអំណាចព្រះ ។
៩២- បើទូលបង្គំមិនពេញចិត្ត នឹងវិន័យក្រឹត្យព្រះជាម្ចាស់
នោះខ្ញុំមុខជារងទុក្ខទោស វេទនារងគ្រោះលុះក្សិណក្ស័យ ។
៩៣- ខ្ញុំមិនដែលភ្លេចច្បាប់ព្រះអង្គ ទាំងវិន័យផងដ៏ប្រពៃ
ដោយសារតែច្បាប់នេះឯងហើយ ទ្រង់ប្រទានឲ្យមានជីវិត ។
៩៤- ជីវិតខ្ញុំផ្ញើរលើព្រះអង្គ តម្រែតម្រង់តាមឱវាទ
ដ្បិតទូលបង្គំតែងឈ្លបឆ្លៀត មិនបង់មារយាទរកច្បាប់ផង ។
៩៥- មានជនអាក្រក់ជនពាលា វាចង់ផ្ដន្ទាខ្ញុំតែម្ដង
តែខ្ញុំនៅតែគិតបំណង រកច្បាប់ព្រះអង្គនិងវិន័យ ។
៩៦- ខ្ញុំយល់ឃើញថាគ្រប់ទាំងអស់ ដែលល្អឥតខ្ចោះនិងអ្វីៗ
គង់មានដើមចុងមានចាស់ថ្មី ឯព្រះវិន័យគ្មានព្រំដែន ។

## សូមដូរទៅជាបទកាកគតិ

៩៧- ខ្ញុំសែនពេញចិត្ត វិន័យក្រមក្រឹត្យ របស់ព្រះអង្គ ខ្ញុំតែងសញ្ជឹង
ពីវិន័យទ្រង់ សព្វប្រការផង ជារៀងរាល់ថ្ងៃ ។

៩៨- វិន័យព្រះអង្គ ឲ្យខ្ញុំត្រឹមត្រង់ ប្រាជ្ញាវាងវៃ ជាងពួកសត្រូវ
ដ្បិតខ្ញុំលកលៃ វិះគិតរំពៃ ពីវិន័យនេះ ។

៩៩- ខ្ញុំវាងវៃឆ្លាត ជាងគ្រូទៅទៀត ព្រោះតែខ្ញុំចេះ យកដំបូន្មាន
ទាំងប៉ុន្មាននេះ មកសញ្ជឹងវិះ គិតពិចារណា ។

១០០- កាន់តាមបញ្ញត្តិ វិន័យមិនបាត់ ខ្ញុំយល់ឃើញថា មានប្រាជ្ញវាងវៃ
ជាងយាយជាងតា ទោះចាស់យ៉ាងណា មិនដល់ខ្ញុំសោះ ។

១០១- ខ្ញុំគេចឲ្យឆ្ងាយ ពីផ្លូវអន្តរាយ អាក្រក់ទាំងអស់ គេចចេញឲ្យផុត
ប្រព្រឹត្តតាមព្រះ បន្ទូលអម្ចាស់ នៅជាប់ស្ថិតស្ថេរ ។

១០២- ខ្ញុំមិនងាកគេច អ្វីទ្រង់សម្រេច ត្រឹមត្រូវឥតប្រែ ដ្បិតទ្រង់ប្រដៅ
ខ្ញុំរាល់ថ្ងៃខែ ខ្ញុំមិនគេចកែ ចាកចោលទ្រង់ឡើយ ។

១០៣- បញ្ញានេះណា ប្រៀបបានអាហារ ឆ្ងាញ់ពិសេសហើយ សម្រាប់រូបខ្ញុំ
គ្មានអ្វីស្មើឡើយ ផ្អែមណាស់ព្រះអើយ លើសទឹកឃ្មុំផង ។

១០៤- គឺធម្មវិន័យ របស់ម្ចាស់ថ្លៃ ធ្វើឲ្យខ្ញុំត្រង់ ចេះពិចារណា
វិះគិតឥតឆ្គង ស្អប់ផ្លូវសៅហ្មង វៀចវេរបោកប្រាស ។

១០៥- បន្ទូលព្រះអង្គ គឺជាចង្កៀង ខ្ញុំបានឃើញច្បាស់ ពិតជាពន្លឺ
ត្រចង់ត្រចះ ឃើញផ្លូវស្រឡះ ឲ្យខ្ញុំសុខសាន្ត ។

១០៦- ខ្ញុំសូមសន្យា ឥតងាករេថា ធ្វើតាមមិនខាន ខ្ញុំនឹងប្រតិបត្តិ
សេចក្តីប៉ុន្មាន សុចរិតថ្កើងថ្កាន របស់ព្រះអង្គ ។

១០៧- បពិត្រព្រះម្ចាស់ ខ្ញុំវេទនាណាស់ សូមប្រោសខ្ញុំផង ឲ្យមានជីវិត
សូមកុំបោះបង់ ជួយឲ្យរស់ផង តាមទ្រង់សន្យា ។

១០៨- ឱ! ព្រះអម្ចាស់ សូមទទួលត្រាស់ ពាក្យខ្ញុំនេះណា ចាត់ដូចតង្វាយ
ដាក់ថ្វាយក្សត្រា ឲ្យស្គាល់បញ្ញា វិន័យម្ចាស់ថ្លៃ ។

១០៩- ខ្សែជីវិតខ្ញុំ ប្រឈមមុខចំ នឹងក្តីអន្តរាយ តែខ្ញុំមិនភ្លេច
ពីធម្មវិន័យ ចងចាំរាល់ថ្ងៃ ឥតបីងាករេ ។

១១០- មានជនអាក្រក់ គេលបចាំដាក់ អន្ទាក់ឥតល្ហែ ចាប់ទូលបង្គំ
រាល់ឆ្នាំថ្ងៃខែ ក៏ខ្ញុំមិនប្រែ ពីច្បាប់ព្រះអង្គ ។

១១១- ពាក្យដំបូន្មាន ព្រះបានប្រទាន ជាកេរដូរជង់ ឲ្យទូលបង្គំ
រីករាយកន្លង មានអំណរផង នៅក្នុងដួងចិត្ត ។

១១២- ខ្ញុំសូមប្តេជ្ញា ធ្វើតាមបញ្ញា វិន័យក្រមក្រឹត្យ របស់ព្រះអង្គ
ដោយអស់ពីចិត្ត លុះទីបំផុត ជីវិតក្សិណក្ស័យ ។

១១៣- ខ្ញុំស្អប់មនុស្ស អាក្រក់ទុរយស មានចិត្តពីរបី តែខ្ញុំស្រឡាញ់
ព្រះធម្មវិន័យ ព្រះអម្ចាស់ថ្លៃ គ្មានថ្ងៃភ្លេចឡើយ ។

១១៤- ទ្រង់ជាជម្រក ជាខែលឲ្យជ្រក ផុតទុក្ខល្ហែល្ហើយ សូមផ្ញើជីវិត
លើព្រះម្ចាស់ហើយ សូមកុំកន្តើយ ទទួលយកផង ។

១១៥- ជនអាក្រក់អើយ បើអ្នកចេញឆ្ងាយ ខ្ញុំអស់សៅហ្មង ឲ្យខ្ញុំប្រតិបត្តិ
វិន័យព្រះផង ល្អល្អះឥតហ្មង ជាព្រះនៃខ្ញុំ ។

១១៦- សូមព្រះអង្គជួយ គាំទ្រលើកស្ទួយ ជួយទូលបង្គំ តាមព្រះបន្ទូល
បញ្ជាមកខ្ញុំ កុំឲ្យសង្ឃឹម ខ្ញុំប្រែខកចិត្ត ។

១១៧- សូមធ្វើបង្អែក កុំបីរារែក ខ្ញុំមានជីវិត ខ្ញុំនឹងតម្រង់
ខំផ្ចង់ទាំងចិត្ត រកវិន័យក្រឹត្យ របស់ព្រះម្ចាស់ ។

១១៨- ព្រះអង្គមិនលះ បង់បោលអស់អ្នក ដែលវេទនាប្រាស ពីក្រឹត្យវិន័យ
នៃព្រះជាម្ចាស់ ធ្វើអ្វីទាំងអស់ ជាការកុហក ។

១១៩- ពួកអាក្រក់នោះ ព្រះអង្គជាត់អស់ មិនមានសល់ទុក ដូចជាសំរាម
គ្មានអ្វីសោយសោក ហេតុនេះខ្ញុំយក ដំបូន្មានទ្រង់ ។

១២០- រូបកាយខ្ញុំភ័យ ញ័រអស់ជើងដៃ ដោយខ្លាចព្រះអង្គ ទូលបង្គំកោត
សេចក្តីត្រឹមត្រង់ អ្វីដែលព្រះអង្គ បានសម្រេចយក ។

១២១- ខ្ញុំខំប្រព្រឹត្ត អំពើសុចរិត យុត្តិធម៌រៀងមក កុំឲ្យខ្ញុំធ្លាក់
រណ្តៅលាមក កុំឲ្យជួយអ្នក សង្កត់សង្កិន ។

១២២- សូមជួយធានា រូបខ្ញុំដែលជា អ្នកបម្រើទ្រង់ បានសេចក្តីសុខ
ក្រែមក្សាន្តយូរលង់ អ្នកអួតបំប៉ោង កុំមកជិះជាន់ ។

១២៣- យើងខ្ញុំទន្ទឹង  រង់ចាំព្រះអង្គ  សង្គ្រោះបន្ទាន់  បញ្ហានេះណា
កាលពីគ្រាមុន  មិននៅទំរន់  ខ្ញុំចងចាំគិត  ។
១២៤- សូមទ្រង់មេត្តា  ផ្តល់ក្តីករុណា  អាសូរអាណិត  មេត្តាប្រទាន
បង្រៀនទាំងក្រឹត្យ  វិន័យនោះពិត  ឲ្យខ្ញុំស្គាល់ផង  ។
១២៥- សូមមេត្តាព្រះ  ប្រទានខ្ញុំចេះ  កុំនៅបង្អង់  ចេះពិចារណា
ខុសត្រូវផ្គាំផ្គង  ដំបូន្មានផង  ទ្រង់ទូន្មានខ្ញុំ  ។
១២៦- បពិត្រម្ចាស់អើយ  ក្នុងពេលនេះហើយ  ជួយទូលបង្គំ  ដ្បិតគេរំលោភ
វិន័យព្រះអង្គ  កុំបីរេរង់  បង្អង់កែគេច  ។
១២៧- ខ្ញុំស្រឡាញ់ព្រះ  វិន័យអម្ចាស់  ពេកក្រៃមិនភ្លេច  ស្រឡាញ់ជាងមាស
រស្មីរំលេច  ជាងប្រាក់ជាងពេជ្រ  ទាំងឡាយទៅទៀត ។
១២៨- យើងខ្ញុំយល់ថា  ច្បាប់គ្រប់ប្រការ  ឥតបីឃ្លាងឃ្លាត  សុទ្ធតែត្រឹមត្រូវ
ឥតមានរវាត  ខ្ញុំតែងឈ្លបឆ្លៀត  ត្រងត្រាប់គ្រប់យ៉ាង ។

## សូមដូរទៅជាបទពាក្យ ៧

១២៩- ដំបូន្មាននៃព្រះអម្ចាស់  ល្អវិសេសណាស់គ្រប់ពាក្យពេចន៍
ហេតុនេះខ្ញុំធ្វើតាមជានិច្ច  ឥតបីមានភ្លេចភ្លាត់របេះ ។
១៣០- ការស្វែងរកព្រះបន្ទូលទ្រង់  ឲ្យចិត្តភ្លឺស្វាងប្រាកណាស់
ហើយធ្វើឲ្យអ្នកទន់ទាបចេះ  ពិចារណាត្រិះរិះគួរគិត ។
១៣១- ខ្ញុំខំយកចិត្តទុកដាក់ស្តាប់  ដោយក្តីត្រង់ត្រាប់អស់ពីចិត្ត
ដ្បិតខ្ញុំចង់ស្គាល់វិន័យក្រិត្យ  ព្រះម្ចាស់ពេកពិតឥតមានណាយ ។
១៣២- សូមបែរព្រះភក្ត្រទតមកខ្ញុំ  សូមប្រណីកុំបីរសាយ
ដូចទ្រង់ប្រណីជនទាំងឡាយ  ធ្លាប់ស្មោះឱនកាយថ្វាយព្រះអង្គ ។
១៣៣- សូមជួយពង្រឹងទូលបង្គំ  មានចិត្តរឹងមាំមិនឃ្លេងឃ្លោង
កុំបណ្តោយខ្ញុំធ្លាក់ទៅក្នុង  រណ្តៅអន្លង់ជ្រោះជ្រៅឡើយ ។
១៣៤- សូមជួយរំដោះខ្ញុំឲ្យរួច  ពីអ្នកខិលខូចខ្ញុំបានស្បើយ
អ្នកដែលជិះជាន់ឈប់មានហើយ  ខ្ញុំមិនកន្តើយធ្វើតាមច្បាប់ ។

១៣៥- សូមទ្រង់សម្តែងព្រះហឫទ័យ　អាណិតប្រណីមកឆាប់ៗ
អ្នកបម្រើទ្រង់ឲ្យបេះប្បាប់　វិន័យគ្រប់សព្វបានភ្លឺស្វាង ។
១៣៦- ទឹកភ្នែកខ្ញុំហូរឥតស្រាន្តស្រាក　យំឥតសម្រាកជាតឹកតាង
ដោយខ្ញុំឃើញអ្នកគ្មានទីអាង　មិនគោរពតាមធម្មវិន័យ ។
១៣៧- បពិត្រព្រះជាអម្ចាស់អើយ　ទ្រង់ប្រកបដោយសុចរិតក្រៃ
សេចក្តីសម្រេចទ្រង់ថ្លាថ្លៃ　ត្រឹមត្រូវប្រពៃពេកកន្លង ។
១៣៨- ព្រះជាអម្ចាស់បានប្រទាន　នូវដំបូន្មានល្អហ្មត់ហ្មង
សុចរិតត្រឹមត្រូវពេកកន្លង　ឥតមានឆ្គាំឆ្គងសោះឡើយណា ។
១៣៩- ខ្ញុំសែនក្តួលក្តៅមួម៉ៅខ្លាំង　ដោយឃើញពួកខ្មាំងចិត្តឫស្យា
បំភ្លេចព្រះបន្ទូលនោះណា　សូមទ្រង់មេត្តាជួយតតាំង ។
១៤០- បន្ទូលបញ្ជោពោលចេញជាក់　ឥតល្មៀមឥតលាក់ឥតកំបាំង
ទូលបង្គំអ្នកបម្រើទ្រង់　ស្រឡាញ់យ៉ាងខ្លាំងបន្ទូលនេះ ។
១៤១- ខ្ញុំជាមនុស្សក្រកូលតូចតាច　គ្មានទាំងអំណាចគ្មានសក្តិយស
តែខ្ញុំនៅចាំមិនភ្លេចសោះ　ពីច្បាប់ទាំងអស់ស្មោះឥតស្មើយ ។
១៤២- សេចក្តីសុចរិតនៃព្រះអង្គ　ស្ថិតស្ថេរយូរលង់អស់កល្បហើយ
ទោះធម្មវិន័យទ្រង់ក៏ដោយ　សុទ្ធតែនាំឲ្យប្រពៃពិត ។
១៤៣- ខ្ញុំកើតទោសទុក្ខធំក្រៃលែង　អន្ទះអន្ទែងចំបែងចិត្ត
វិន័យព្រះអង្គខ្ញុំនៃបនិត្យ　មានក្តីសុខពិតឥតសោយសោក ។
១៤៤- ដំបូន្មានទ្រង់សុចរិត　អស់កល្បអស់កប្បអង្វែងមក
សូមប្រទានឲ្យខ្ញុំបេះរក　ពិចារណារយកការខុសត្រូវ ។
១៤៥- ខ្ញុំសូមអង្វរព្រះអម្ចាស់　ព្រះអង្គជាព្រះល្អពេកកូវ
សូមឆ្លើយមកខ្ញុំកុំទុកនៅ　ខ្ញុំប្រព្រឹត្តត្រូវតាមវិន័យ ។
១៤៦- យើងខ្ញុំអង្វរសូមព្រះអង្គ　សូមសង្គ្រោះផងប្រញាប់ខ្មី
ខ្ញុំធ្វើតាមមិនបង្អង់អី　ពាក្យពេចន៍ថ្លាថ្លៃព្រះអង្គ ។

១៤៧- ខ្ញុំខំស្រែកទ្រហ៊ូអង្វរព្រះ មុនពេលថ្ងៃរះទៅទៀតផង
ទន្ទឹងរង់ចាំមិនមានហ្មង ស្ដាប់ពាក្យព្រះអង្គមានបន្ទូល ។
១៤៨- ខ្ញុំខំសញ្ជឹងនឹករិះគិត ព្រះបន្ទូលពិតដែលទ្រង់ពោល
បញ្ជាមកខ្ញុំនៅផុះដោល គឺព្រះបន្ទូលមុនភ្លឺច្បាស់ ។
១៤៩- សូមស្ដាប់ពាក្យដែលខ្ញុំអង្វរ ដោយករុណាធម៌ដ៏ត្រចះ
ឱព្រះម្ចាស់អើយជួយឲ្យរស់ តាមការទាំងអស់ទ្រង់សម្រេច ។
១៥០- ពួកអ្នកឃ្លាតចាកពីវិន័យ ធម៌ព្រះម្ចាស់ថ្លៃគេមានល្បិច
ខិតចូលមកជិតខ្ញុំជានិច្ច ចិត្តគេគួចកិច្ចគុំកម្លៅ ។
១៥១- បពិត្រព្រះម្ចាស់ពេលទ្រង់គង់ នៅជិតរូបខ្ញុំសែនកក់ក្ដៅ
វិន័យទាំងអស់ទ្រង់ប្រដៅ សែនត្រង់ត្រឹមត្រូវឥតមានខ្ចោះ ។
១៥២- យើខ្ញុំបានដឹងច្បាស់ហើយថា តាំងពីដូនតាមកហើយនោះ
ដំបូន្មានទ្រង់ល្អឥតខ្ចោះ គង់វង្សនៅអស់កល្បយូរយារ ។
១៥៣- សូមព្រះអង្គទតមើលឲ្យច្បាស់ ខ្ញុំរងទុក្ខទោសសោកគ្រាំគ្រា
សូមរំដោះខ្ញុំផុតវេរា មិនភ្លេចធម្មាក្រឹត្យវិន័យ ។
១៥៤- សូមរកយុត្តិធម៌ឲ្យរូបខ្ញុំ ការពារអប់រំដោយប្រណី
ឲ្យមានជីវិតរស់ជាថ្មី ដោយបន្ទូលថ្លៃជាប្រទាន ។
១៥៥- ព្រះអង្គទ្រង់មិនសង្គ្រោះអ្នក ដែលមិនជឿជាក់ចិត្តសាមាន្យ
មិនកាន់វិន័យល្អថ្កើងថ្កាន គេធ្វើមិនបានតាមបញ្ញត្តិ ។
១៥៦- បពិត្រព្រះម្ចាស់អើយព្រះអង្គ ព្រះហឫទ័យត្រង់តែងអាណិត
សូមប្រោសឲ្យខ្ញុំមានជីវិត តាមក្ដីសម្រេចនោះឡើងវិញ ។
១៥៧- អ្នកដែលបៀតបៀនទូលបង្គំ មានចិត្តគួនគុំខ្ញុំជ្រក់ជ្រេញ
តែខ្ញុំមិនព្រមឃ្លាតបែកចេញ វិន័យពោរពេញសែនវិសុទ្ធ ។
១៥៨- ពេលដែលខ្ញុំឃើញជនទុរយស ខ្ញុំសែនទើសទាស់ពេញក្នុងចិត្ត
ដ្បិតគេមិនធ្វើតាមបែបបទ បន្ទូលវិសុទ្ធព្រះអង្គទេ ។
១៥៩- សូមព្រះអម្ចាស់ឈ្វេងយល់ថា រូបខ្ញុំនេះណាគ្មានកែប្រែ
ស្រឡាញ់ច្បាប់ទ្រង់គ្មានពេលល្ហែ សូមប្រទានតែជីវិតផង ។

១៦០- បន្ទូលព្រះអង្គសុទ្ធតែពិត ពេញដោយសុចរិតទៀងស្មោះត្រង់
ការវិនិច្ឆ័យល្អកន្លង ស្ថិតស្ថេរយូរលង់អស់កប្បកល្ប ។
១៦១- ពួកអ្នកជិកនាំបៀតបៀនខ្ញុំ ដោយមិនសក្តិសមគ្មានហេតុផល
ខ្ញុំឥតមានព្រួយឥតខ្វាយខ្វល់ មានតែបន្ទូលទើបខ្ញុំខ្លាច ។
១៦២- ខ្ញុំរីករាយចិត្តនឹងទទួល បញ្ញាទ្រង់ផ្ទាល់ដែលសម្រេច
ដូចអ្នកទទួលបានមាសពេជ្រ ជយភណ្ឌរំលេចថ្លៃពន់ពេក ។
១៦៣- ខ្ញុំស្អប់ខ្ពើមការបោកកុហក ភូតភរគម្រក់ខ្លាំងអនេក
ដ្បិតខ្ញុំស្រឡាញ់នឹកឃ្លានស្រេក ធម្មវិន័យពេកព្រះអង្គថ្លៃ ។
១៦៤- ខ្ញុំសូមសរសើរកោតព្រះអង្គ បានប្រាំពីរដងក្នុងមួយថ្ងៃ
អ្វីទ្រង់សម្រេចល្អប្រពៃ សុចរិតពេកក្រៃមិនប្រែប្រួល ។
១៦៥- អ្នកណាស្រឡាញ់វិន័យធម៌ នឹងមានជោគល្អហើយទទួល
បានក្ដីសុខសាន្តរស់នៅស្រួល មិនជួបភ័យជ្រួលបានថ្កើងថ្កាន ។
១៦៦- ខ្ញុំជឿសង្ឃឹមថាព្រះម្ចាស់ មុខជាសង្គ្រោះខ្ញុំពុំខាន
ខ្ញុំសូមប្រព្រឹត្តតាមស្នាមដាន វិន័យថ្កើងថ្កាននៃព្រះអង្គ ។
១៦៧- ខ្ញុំប្រព្រឹត្តតាមដំបូន្មាន ខកខានមិនហ៊ានគឺស្មោះត្រង់
ស្រឡាញ់ដំបូន្មានព្រះអង្គ ឥតមានវាងវង់ឬកលកិច្ច ។
១៦៨- ទូលបង្គំប្រព្រឹត្តតាមច្បាប់ បញ្ញាបង្គាប់មិនមានភ្លេច
អ្វីដែលខ្ញុំធ្វើទ្រង់ជ្រាបខ្ទេច ឥតមានស្រពេចស្រពិលឡើយ ។

## សូមដង្ហោយទៅជាបទកាកគតិ

១៦៩- ឱ! ព្រះអម្ចាស់ សូមសណ្ដាប់ច្បាស់ សំឡេងខ្លាំងល្វើយ ដែលខ្ញុំបានស្រែក
ទ្រង់សណ្ដាប់ហើយ សូមប្រទានឲ្យ ខ្ញុំបេះរិះគិត ។
១៧០- សូមពាក្យទទូច អង្វរថ្ងូរថ្ងូច លាន់ឮទៅជិត សូមជួយរំដោះ
ឲ្យរួចជីវិត តាមបន្ទូលពិត សន្យាទ្រង់ផង ។
១៧១- សូមឲ្យរូបខ្ញុំ ពោលពាក្យឧត្ដម សរសើរព្រះអង្គ ដ្បិតទ្រង់បង្រៀន
វិន័យថ្កុំថ្កើង របស់ព្រះអង្គ ខ្ញុំបានយល់ច្បាស់ ។

១៧២- ខ្ញុំនឹងស្រែកច្រៀង បន្លឺសំនៀង សរសើរដល់ព្រះ បន្ទូលសន្យា
សក្តិសមឥតខ្ចោះ ធម្មវិន័យនោះ សុចរិតកន្លង ។
១៧៣- សូមសម្តែងព្រះ បារមីទាំងអស់ ហើយសង្គ្រោះផង ដ្បិតទូលបង្គំ
សម្រេចបំណង តាមច្បាប់ព្រះអង្គ មិនគេចកែឡើយ ។
១៧៤- បពិត្រព្រះម្ចាស់ ខ្ញុំចង់ឲ្យព្រះ សង្គ្រោះផុតក្ស័យ ខ្ញុំពេញចិត្តណាស់
នឹងធម្មវិន័យ ជារៀងរាល់ថ្ងៃ ពុំមានស្រាកស្រាន្ត ។
១៧៥- សូមឲ្យជីវិត ខ្ញុំនៅរស់ពិត ដើម្បីនឹងបាន សរសើរតម្កើង
ព្រះដ៏ថ្កើងថ្កាន សេចក្តីប្ញន្នាន ជួយលើកទឹកចិត្ត ។
១៧៦- ខ្ញុំដើរដូចសត្វ ចៀមវង្វេងបាត់ សូមយាងនៃបនិត្យ មករកខ្ញុំជា
បម្រើស្មោះពិត ដ្បិតខ្ញុំមិនភ្លាត់ ភ្លេចវិន័យទ្រង់ ។

## ទំនុកតម្កើងលេខ ១២០ (១១៩) បទព្រហ្មគីតិ

១- ពេលខ្ញុំមានអាសន្ន ភ័យស្លោស្លន់ខ្ញុំហៅរក
ព្រះម្ចាស់ឲ្យយាងមក ទ្រង់ឆ្លើយរកតបនឹងខ្ញុំ ។
២- ឱព្រះអម្ចាស់អើយ កុំកន្តើយគង់សំងំ
រំដោះផុតទុក្ខធំ កុំឲ្យខ្ញុំជួបបោកប្រាស ។
៣- អ្នកនិយាយមិនពិត ពោលបញ្ឆិតពាក្យផ្ដេសផ្ដាស
តើត្រូវទទួលទោស យ៉ាងណាខ្លះនៅពេលក្រោយ ។
៤- គឺត្រូវទទួលទុក្ខ ឈឺចាប់ចុកមិនផុតឡើយ
ផ្លែព្រួញមុតធ្លុះហើយ ភ្លើងឆេះកាយមិនប្រណី ។
៥- ខ្ញុំរស់មិនបានសុខ នៅក្នុងស្រុកមនុស្សព្រៃ
ជនពាលសាហាវក្រៃ ខ្ញុំស្ទើរក្ស័យសែនខ្វាយខ្វល់ ។
៦- ជាយូរឆ្នាំកន្លង ខ្ញុំរស់រងទុក្ខអំពល់
ពួកមនុស្សមិនយល់ មិនចង់ស្គាល់សន្តិភាព ។
៧- ពេលណាខ្ញុំហាស្ដី គេមិនខ្ចីបែរមកស្ដាប់
មិនចង់សន្តិភាព បែរជារៀបធ្វើសង្គ្រាម ។

## ទំនុកតម្កើងលេខ ១២១ (១២០) បទពាក្យ ៧

១- ខ្ញុំងើបមុខឡើងភ្នែកសម្លឹង ឯនាយល្ងើយល្ងឹងទៅដល់ភ្នំ
ថាតើនរណានឹងជួយខ្ញុំ ឲ្យផុតទុក្ខធំគ្រប់ៗគ្រា ។
២- គឺមានតែអង្គព្រះអម្ចាស់ ដែលប្រណីប្រោសរាល់វេលា
ទ្រង់បង្កើតដីផ្ទៃមេឃា ព្រះអង្គគឺជាព្រះសង្គ្រោះ ។
៣- សូមទ្រង់មេត្តាកុំបណ្ដោយ ឲ្យជើងអ្នកធ្លោយរងរបួស
ករុណាអាសូរជួយសង្គ្រោះ កុំឲ្យមានគ្រោះឬត្រូវដួល ។
៤- ព្រះអង្គដែលថែទាំការពារ ស្រាអែលគ្រប់គ្នាបានសុខស្រួល
ព្រះអង្គសង្គ្រោះមិនឲ្យដួល ទ្រង់មិនប្រែប្រួលផ្ទំលក់ឡើយ ។
៥- ព្រះអម្ចាស់តែងរក្សាថៃ ការពារឥតល្ហែមិនកន្តើយ
ទ្រង់គង់នៅខាងស្ដាំអ្នកហើយ កុំខ្វល់ខ្វាយឡើយទ្រង់ជាម្លប់ ។
៦- ព្រះអាទិត្យរះក្នុងពេលថ្ងៃ មិនធ្វើទុក្ខអ្វីភ្លឺគ្រងគ្រប់
ឯព្រះច័ន្ទចរនៅពេលយប់ ទុក្ខសោកក៏ឈប់ដល់អ្នកដែរ ។
៧- ព្រះអម្ចាស់នឹងថែរក្សា រារាំងបាំងការពារថ្នមថៃ
ហេតុការណ៍អាក្រក់ទ្រង់បង្វែរ មិនឲ្យកើតក្បែររូបអ្នកឡើយ ។
៨- ព្រះម្ចាស់ថែអ្នកគ្មានឈរឈប់ អ្វីៗសព្វគ្រប់មិនកន្តើយ
កិច្ចការអ្នកធ្វើនឹងធូរស្បើយ ពីពេលនេះហើយតរៀងទៅ ។

## ទំនុកតម្កើងលេខ ១២២ (១២១) បទកាកគតិ

១- គេប្រាប់ខ្ញុំថា យើងគ្រប់កាយា ទៅព្រះដំណាក់ ទីដែលព្រះជា
អម្ចាស់គង់ស្នាក់ ល្អស្អាតត្រជាក់ ខ្ញុំសប្បាយក្រៃ ។
២- យេរូសាឡឹម ភក្ត្រអ្នកប៉ប្រិម ឥតមានទាស់អ្វី យើងនាំគ្នាឈាន
ជើងចូលដល់ដី ដល់ទ្វារបុរី នៃអ្នកហើយណា ។
៣- យេរូសាឡឹម ជាក្រុងមួយធំ សែនស្រស់សង្ហា ដែលសង់ឡើងបាន
រឹងមាំក្រៃណា កំពែងអស្ចារ្យ ល្អព័ទ្ធជុំជិត ។
៤- គ្រប់កុលសម្ពន្ធ នានារួសរាន់ នាំគ្នាមកស្និត ច្រៀងលើកតម្កើង
ព្រះម្ចាស់មានឫទ្ធិ តាមច្បាប់នៃជាតិ ជនអ៊ីស្រាអែល ។

៥- ទីនេះក៏មាន បល្ល័ង្កថ្កើងថ្កាន នៃរាជវង្សដែល ជាស្តេចដាវីឌ
បារមីក្រាស់ក្រៃល គ្រប់គ្រងក្រវែល រាស្ត្រដោយយុត្តិធម៌ ។

៦- សូមព្រះអម្ចាស់ ប្រណីសន្តោស សន្តិភាពបវរ ដល់ក្រុងសាឡឹម
ឲ្យអ្នកស្មោះសរ ស្រឡាញ់ក្រុងល្អ រស់នៅសុខសាន្ត ។

៧- ឲ្យអ្នករស់ក្នុង កំពែងទីក្រុង បានសុខក្សេមក្សាន្ត សូមឲ្យវិមាន
ក្នុងក្រុងប៉ុន្មាន ជួបតែសុខសាន្ត ឥតមានទុក្ខភ័យ ។

៨- យល់ដល់សន្តាន ញាតិមិត្តភុំផាន បងប្អូនប្រុសស្រី ខ្ញុំពោលឡើងថា
សូមឲ្យសិរី បវរសួស្តី ដល់ក្នុងថ្កុំថ្កើង ។

៩- យល់ដល់ដំណាក់ ល្អស្រស់វលក្ខណ៍ ជាព្រះនៃយើង សូមឲ្យអ្នកបាន
សិរីរុងរឿង ខ្ពង់ខ្ពស់ថ្កុំថ្កើង សុភមង្គល ។

## ទំនុកតម្កើងលេខ ១២៣ (១២២) បទព្រហ្មគីតិ

១- ឱ! ព្រះជាអម្ចាស់ គង់ខ្ពស់ណាស់ស្ថានសុខអើយ
ខ្ញុំងើបមុខឡើងហើយ សម្លឹងងើយទៅព្រះអង្គ ។

២- យើងខ្ញុំក៏សម្លឹង និងទន្ទឹងរង់ចាំទ្រង់
ដូចបម្រើរំពឹង មើលដៃជើងម្ចាស់សន្តោស ។

៣- ឱ! ព្រះអម្ចាស់អើយ អាណិតហើយមេត្តាប្រោស
យើងខ្ញុំនេះផងចុះ ខ្ញុំឥតខុសគេមើលងាយ ។

៤- យើងខ្ញុំមិនអាចទ្រាំ គេសើចយំដោយពេបជ្រាយ
គេជេរពីជិតឆ្ងាយ អ្នកទាំងឡាយវាយឫកខ្ពស់ ។

## ទំនុកតម្កើងលេខ ១២៤ (១២៣) បទពាក្យ ៧

១- ប្រសិនបើគ្មានព្រះអម្ចាស់ មិនជួយសន្តោសគាំទ្រទេ
សូមអ៊ីស្រាអែលពោលហូរហែរ ពោលកុំទំនេរទាំងអស់គ្នា ។

២- ប្រសិនបើគ្មានព្រះអម្ចាស់ នៅខាងយើងនោះគ្រប់វេលា
ពេលណាសត្រូវលើកគ្នីគ្នា សម្រុកពុះពារវាយលើយើង ។

៣- ពេលណាគេមានកំហឹងខ្លាំង　　គេមកប្រឆាំងយើងនឹងបើង
គេនឹងត្របាក់លេបដូចភ្លើង　　មិនឲ្យពួកយើងសុខសាន្តឡើយ ។
៤- យើងនឹងលិចលង់ក្នុងសមុទ្រ　　ភិតភ័យតក់ស្លុតឥតមានស្បើយ
ទឹកហូរនាំយើងគ្មានកោះត្រើយ　　ទៅកាន់ទីឆ្ងាយគ្មានគោលដៅ ។
៥- ពេលយើងកំពុងអស់កម្លាំង　　មានទឹកកួចខ្លាំងពន្លិចទៅ
ដល់បាតជលសាដ៏សែនជ្រៅ　　ជីវិតយើងត្រូវលង់ក្សិណក្ស័យ ។
៦- សូមលើកតម្កើងព្រះអម្ចាស់　　ដ្បិតទ្រង់ជាព្រះមានបារមី
ទ្រង់ពុំប្រគល់យើងក្នុងដៃ　　ធ្វើរំពានៃពួកនោះឡើយ ។
៧- យើងរួចជីវិតដូចបក្សី　　គេចផុតពីដៃព្រានព្រៃហើយ
គឺលប់ផ្ទុះធ្លាយគ្មានសល់ឡើយ　　យើងបានធូរស្បើយរស់ជីវ៉ា ។
៨- ព្រះអម្ចាស់បានសង្គ្រោះយើង　　ដោយព្រះនាមថ្កើងមានបេស្ដា
គឺព្រះអង្គដែលមានមេត្តា　　បង្កតវេហានិនផែនដី ។

## ទំនុកតម្កើងលេខ ១២៥ (១២៤)　　បទកាកគតិ

១- អ្នកផ្ញើជីវិត　លើព្រះមានឫទ្ធិ　អ្នកនោះប្រៀបបាន　នឹងភ្នំស៊ីយ៉ូន
ស្រស់បស់ភុំផាន　ស្ថិតស្ថេរសុខសាន្ត　ជាទីសង្ឃឹម　។
២- ភ្នំព័ទ្ធជិតជុំ　ទីក្រុងឧត្ដម　យេរូសាឡឹម　ឯព្រះអម្ចាស់
ក៏គង់នៅជុំ　រាស្ត្រផុតទុក្ខធំ　បានសុខសិរី　។
៣- ដ្បិតស្ដេចយង់ឃ្នង　ពុំអាចគ្រប់គ្រង　នៅលើទឹកដី　នៃជនសុចរិត
គ្មានចិត្តព្រៃផ្សៃ　ចិត្តចង់ធ្វើអ្វី　ដែលជាកំហុស　។
៤- ឱ! ព្រះអម្ចាស់　សូមសម្ដែងព្រះ　ហឫទ័យសប្បុរស　ទៅលើអស់អ្នក
មានចិត្តត្រង់ស្មោះ　ល្អឥតមានទាស់　ជាមនុស្សទៀងត្រង់　។
៥- រីអ្នកចូលចិត្ត　ដើរផ្លូវទុច្ចរិត　វៀចវេរសៅហ្មង　សូមព្រះអម្ចាស់
ដេញគេទៅផង　ឲ្យទៅនៅក្នុង　ហ្វូងមនុស្សគម្រក់　។
សូមទ្រង់ប្រទាន　អ៊ីស្រាអែលបាន　ផុតគ្រោះអាក្រក់　រួចពីមនុស្សបាប
ភូតភរកុហក　ផុតមនុស្សគម្រក់　សុខសាន្តតទៅ　។

## ទំនុកតម្កើងលេខ ១២៦ (១២៥) បទព្រហ្មគីតិ

១- ពេលព្រះដឹកនាំអ្នក ដែលជំពាក់ខ្លួនជាឈ្លើយ
មកក្រុងស៊ីយ៉ូនហើយ យើងធូរស្បើយដូចយល់សប្តិ ៗ
២- យើងសើចហ៊ោរសប្បាយ អរក្អាកក្អាយឥតមានឈប់
ស្រែកជ័យឃោសន៍សាយសព្វ លាន់សូរស័ព្ទគ្រប់ទិសា ៗ
ពេលនោះក្នុងចំណោម ជាតិទាំងព្រមគេពោលថា ៖
«ព្រះម្ចាស់មានបេស្កា ធ្វើអស្ចារ្យចំពោះគេ» ៗ
៣- ព្រះអង្គបានធ្វើការ ដ៏អស្ចារ្យអ្វីម៉្លេះទេ
យើងលែងគិតគ្នាន់គ្នេរ បានល្ហើយល្ហែអរសប្បាយ ៗ
៤- ឱ! ព្រះម្ចាស់ឧត្តម សូមប្រោសខ្ញុំឲ្យរីកសាយ
ដូចរហោស្ថានឆ្ងាយ សូមប្រែក្លាយមានទឹកហូរ ៗ
៥- អ្នកណាសាបព្រោះស្រូវ ដោយសោកសៅគួរអាសូរ
ទាំងទឹកភ្នែកជន់ជោរ នឹងច្រូតយកទាំងសប្បាយ ៗ
៦- គេយកពូជទៅព្រោះ ទាំងស្រណោះយំសោកស្តាយ
ក្រោយមកគេប្រែក្លាយ ហ៊ោសប្បាយដោយអំណរ ៗ

## ទំនុកតម្កើងលេ ១២៧ (១២៦) បទពាក្យ ៧

១- ប្រសិនបើព្រះជាអម្ចាស់ មិនជួយសង់ផ្ទះនោះទេណា
អ្នកសង់ខំប្រឹតឥតបានការ គឺគ្មានវាសនាខ្វះលំនឹង ៗ
បើព្រះអម្ចាស់មិនរក្សា ទីក្រុងទេណាឲ្យរឹងប៉ឹង
អ្នកយាមទីក្រុងដែលខំប្រឹង យាមរាល់ថ្ងៃហ្នឹងអត់អសារ ៗ
២- អ្នករាល់គ្នាក្រោកពីព្រលឹម រកស៊ីចិញ្ចឹមជន្មជីវ៉ា
ខំទាំងលំបាកគ្រប់កាយា តែឥតបានការផលចំណេញ ៗ
ព្រះជាអម្ចាស់បានប្រទាន អាហារធនធានច្រើនពាសពេញ
ដល់អ្នកដែលព្រះអង្គស្រឡាញ់ ក្នុងពេលយប់យន់គេនិន្ទ្រា ៗ
៣- ព្រះអម្ចាស់ប្រទានកូនចៅ ស្ថិតស្ថេរគង់នៅបាត់ទុកជា
ចំណែកមរតកដ៏មហិមា ជាពរជ័យាពីព្រះអង្គ ៗ

៤- កូនប្រុសៗដែលកើតចេញមក ពេលដែលឪពុកពេញកម្លាំង
ដូចព្រួញដែលស្រួចមុតយ៉ាងខ្លាំង នៃអ្នកចម្បាំងពេលប្រយុទ្ធ ។
៥- អ្នកដែលមានកូនប្រុសយ៉ាងច្រើន នោះនឹងចម្រើនសុខបំផុត
ពេលមានបច្ចាមកប្រយុទ្ធ គេមិនតក់ស្លុតមិនអាម៉ាស ។

## ទំនុកតម្កើងលេខ ១២៨ (១២៧) បទកាកគតិ

១- អ្នកណាកោតខ្លាច គោរពអំណាច ព្រះជាអម្ចាស់ ដើរតាមគន្លង
មាគ៌ានៃព្រះ អ្នកនោះឥតទាស់ ពោរពេញមង្គល ។
២- អ្នកនឹងទទួល បានឥតប្រែប្រួល យកនូវភោគផល ចេញពីកិច្ចការ
គ្រប់ពេលវេលារាល់ នឹងមានមង្គល ចម្រើនពេកក្រៃ ។
៣- ឯភរិយាអ្នក ដែលនៅក្នុងផ្ទះ ដូចដើមស្រស់ខ្ចី មានស្លឹកមានផ្លែ
ស្រគាលទុំខ្ចី កូនប្រុសរញ៉ី ដូចដើមឈើតូច ។
៤- នេះជាអំណោយ ទ្រង់ប្រទានឲ្យ គេបានសម្រេច ដល់អ្នកកោតខ្លាច
ឫទ្ធីអំណាច ផលច្រើនពន់ពេក មិនពិបាករក ។
៥- សូមទ្រង់ប្រសិទ្ធិ ពរជ័យវិចិត្រ ពីស៊ីយ៉ូនមក ជារៀងរាល់ថ្ងៃ
កុំបាច់លែលក ដើរតត្រុករក ក្នុងជីវិតអ្នក ។
៦- អ្នកនឹងឃើញចៅ របស់អ្នកនៅ បីបមថ្នមថ្នាក់ ឲ្យអ៊ីស្រាអែល
បានសុខជាជាក់ គ្មានគ្រោះឧបសគ្គ ជួបតែសុខសាន្ត ។

## ទំនុកតម្កើងលេខ ១២៩ (១២៨) បទព្រហ្មគីតិ

១- គេតែងធ្វើបាប ខ្ញុំជាដរាប តាំងពីក្មេងខ្ចី ឲ្យអ៊ីស្រាអែល
ទាំងប្រុសទាំងស្រី ស្រែកពោលស្រដី តាមដូច្នេះថា៖ ។
២- «គេធ្វើបាបខ្ញុំ ដូចចងគំនុំ តាំងពីកុមារ គេចង់សម្លាប់
បាក់កាប់ប្រហារ តែទោះយ៉ាងណា ក៏មិនឈ្នះខ្ញុំ ។
៣- គេភ្ជួរគេរាស់ គេជាំគេជុះ ធ្វើគន្លងធំ គេភ្ជួរលើខ្នង
ដូចភ្ជួរដីភូមិ លើសាច់ឈាមខ្ញុំ ឲ្យឈឺគ្រាំគ្រា ។

៤- ប៉ុន្តែព្រះម្ចាស់ ទ្រង់សប្បុរសណាស់ ដល់យើងគ្រប់គ្នា ទ្រង់ស្រាយចំណង
ពួកជនពាល ចេញពីអង្គា ខ្ញុំសុខសាន្តណាស់ ។
៥- សូមឲ្យអស់ជន ស្អប់ក្រុងស៊ីយ៉ូន ជួបក្តីអាម៉ាស់ និងដកខ្លួនថយ
ចេញឆ្ងាយស្រឡះ វិនាសព្រាត់ប្រាស កុំបីសល់នៅ ។
៦- សូមឲ្យពួកគេ កុំបីល្ហើយល្ហែ ដូចជាដើមស្មៅ លើដំបូលផ្ទះ
ហើយត្រូវកម្តៅ ស្ងួតក្រៀមស្វិតទៅ មុនពេលលាស់ខ្ចី ។
៧- សូម្បីតែគេ ច្រូតស្មៅនោះដែរ ក៏មិនពេញដៃ មិនល្មមសម្រាប់
ចងកណ្តាប់អី ព្រោះស្មៅក្សិណក្ស័យ អស់ន័យខ្លឹមសារ ។
៨- សូមកុំឲ្យអស់ អ្នកដើរតាមនោះ ពោលទៅគេថា « សូមព្រះអម្ចាស់
ប្រទានជ័យា ដល់អ្នករាល់គ្នា » តទៅទៀតឡើយ ។

## ទំនុកតម្កើងលេខ ១៣០ (១២៩) បទពាក្យ ៧

១- បពិត្រព្រះជាអម្ចាស់អើយ ខ្ញុំស្រែកដង្ហើយរកព្រះអង្គ
ពីក្នុងរណ្តៅជ្រៅកន្លង មេត្តាជួយជងផុតពីស្លាប់ ។
២- សំឡេងខ្ញុំពុដូចចំរៀង សូមព្រះអង្គផ្ទៀងព្រះកាណ៌ស្តាប់
ពាក្យខ្ញុំអង្វរទទូចប្រាប់ រៀបរាប់រ៉ាយរ៉ាប់សូមសន្តោស ។
៣- បពិត្រព្រះម្ចាស់ដ៏ឧត្តម បើព្រះអង្គចាំពីកំហុស
អំពើបាបកម្មជនស្រីប្រុស គ្មានម្នាក់ណាសោះរួចខ្លួនឡើយ ។
៤- ប៉ុន្តែព្រះអង្គតែងអត់ទោស ប្រណីសន្តោសខ្ញុំធូរស្បើយ
រួចផុតទុក្ខទោសបានល្ហែល្ហើយ គឺព្រះអង្គហើយខ្ញុំគោរព ។
៥- ខ្ញុំទុកចិត្តលើព្រះអម្ចាស់ ជីវិតខ្ញុំនេះផ្ញើសព្វគ្រប់
សង្ឃឹមលើព្រះបន្ទូលគាប់ មិនឈរមិនឈប់ទេព្រះអង្គ ។
៦- ខ្ញុំទន្ទឹងចាំព្រះអម្ចាស់ ជាងអ្នកយាមផ្ទះទៅទៀតផង
ពេលឃើញថ្ងៃរះស្រស់បំព្រង រួចផុតទុក្ខផងមួយរាត្រី ។
៧- ឱ! អ៊ីស្រាអែលសូមទុកចិត្ត ព្រះល្អវិសុទ្ធដោយព្រះទ័យ
មេត្តាករុណាត្រាប្រណី ទ្រង់សព្វព្រះទ័យជួយជានិច្ច ។

៨- ព្រះអង្គរំដោះអ៊ីស្រាអែល    ពីកំហុសដែលមានច្រើនតិច
គេបានប្រព្រឹត្តជាប់ជានិច្ច    ព្រះអង្គសម្រេចបានសុខសាន្ត ។

## ទំនុកតម្កើងលេខ ១៣១ (១៣០)    បទកាកគតិ

១- បពិត្រព្រះម្ចាស់    ខ្ញុំជាមនុស្ស    ដែលមិនអំនួត    មិនវាយឫកខ្ពស់
មិនអាងមិនអួត    មិនចង់ប្រកួត    អ្នកតូចអ្នកទាប ។
ខ្ញុំមិនលោភលន់    ចង់បានទ្រព្យធន    គេជារៀងរាប    មិនចង់បានអ្វី
ដែលធំហួសប្រៀប    លើសសមត្ថភាព    របស់ខ្ញុំឡើយ ។
២- តែផ្ទុយទៅវិញ    ចិត្តខ្ញុំពោរពេញ    ស្ងៀមស្ងាត់ព្រងើយ    ដូចជាកូនក្មេង
ជាប់ទ្រូងម្ដាយហើយ    វាធ្វើកន្តើយ    នឹងអ្វីទាំងអស់ ។
៣- អ៊ីស្រាអែលអើយ    កុំបង្អង់ឡើយ    ទុកចិត្តលើព្រះ    តាំងពីឥឡូវ
តទៅឥតខ្ចោះ    រហូតដល់អស់    កប្បកល្បជានិច្ច ។

## ទំនុកតម្កើងលេខ ១៣២ (១៣១)    បទព្រហ្មគីតិ

១- ឱ! ព្រះអម្ចាស់អើយ    កុំកន្តើយសូមនឹកដល់
ដាវីឌសែនខ្វាយខ្វល់    នឿយហត់ជ្រុលគ្រប់កិច្ចការ ។
២- ព្រះរាជាបានស្បថ    ជាកំណត់ទ្រង់សន្យា
ព្រះដ៏មានចេស្ដា    នៃលោកយ៉ាកុបគ្រប់គ្នា ។
៣- ថាខ្ញុំមិនចូលជ្រក    ក្នុងជម្រកព្រះពន្លា
មិនព្រមចូលនិន្ទ្រា    លើគ្រែគ្រានេះឡើយណា ។
៤- ខ្ញុំមិនព្រមបិទភ្នែក    មិនព្រមដេកលង់នេត្រា
ដរាបខ្ញុំនេះណា    ចាត់ចែងការថ្វាយមិនបាន ។
៥- គឺព្រះតំណាក់ជ័យ    ថ្វាយយក្សត្រថ្លៃខ្លាំងក្លាហាន
ព្រះយ៉ាកុបថ្កើងថ្កាន    បើមិនបានខ្ញុំសោកា ។
៦- ហឹបសម្ពន្ធមេត្រី    ឮគេស្តីនិយាយថា
ឯភូមិអេប្រាតា    នៅយ៉ាអាឃើញហឹបជាក់ ។

| | | | |
|---|---|---|---|
| ៧- | ចូរយើងនាំគ្នីគ្នា | គ្រប់អង្គាចូលដំណាក់ | |
| | ក្រាបទាបបាទាព្រះ | ដោយស្មោះស្ម័គ្រគោរពថ្កើង | ។ |
| ៨- | ឱ! ព្រះជាអម្ចាស់ | មេត្តាប្រោសសូមតើនឡើង | |
| | ជាមួយហឹបព្រះអង្គ | សូមយាងគង់រហូតទៅ | ។ |
| ៩- | សូមឲ្យបូជាចារ្យ | គ្រប់ការយាកុំហ្មងសៅ | |
| | ធ្វើសុចរិតជាផ្លូវ | រាស្ត្ររស់នៅហ៊ោរសប្បាយ | ។ |
| ១០- | ដោយយល់ដល់ព្រះបាទ | នាមដាវីឌដ៏ស្រស់ស្រាយ | |
| | កុំបោលស្តេចនេះឡើយ | គឺទ្រង់ហើយបានអភិសេក | ។ |
| ១១- | ព្រះអង្គបានសន្យា | នឹងស្តេចដាវីឌល្អឯក | |
| | យើងនឹងតែងតាំងពូជ | ឲ្យគ្រងរាជ្យជាបន្ត | ។ |
| ១២- | ប្រសិនបើបុត្រអ្នក | កាន់បានជាក់សម្ពន្ធល្អ | |
| | មេត្រីយើងតៗ | គ្រប់តំណយើងប្រដៅ | ។ |
| | នោះពូជគេនឹងបាន | ល្អថ្កើងថ្កានមិនអាស្រូវ | |
| | ឡើងគ្រងរាជ្យតទៅ | តកូនចៅឥតស្រាកស្រាន្ត | ។ |
| ១៣- | ព្រះអម្ចាស់បានជ្រើស | ពិនិត្យរើសក្រុងថ្កើងថ្កាន | |
| | ជាទីល្អចំណាន | ស៊ីយ៉ូនបានជាលំនៅ | ។ |
| ១៤- | យើងនឹងស្នាក់សម្រាក | មួយរយៈមិនចេញទៅ | |
| | ចង់រស់ស្នាក់និត្យនៅ | មិនចេញទៅកន្លែងណា | ។ |
| ១៥- | យើងនឹងប្រទានពរ | ក្រុងបវរតាមត្រូវការ | |
| | ឲ្យអ្នកខ្សត់ខ្លោចជ្យា | មានអាហារមិនខ្វះទេ | ។ |
| ១៦- | យើងនឹងសង្គ្រោះក្រុង | ឲ្យរឿងរុងល្អឡើងទ្វេ | |
| | ដោយបូជាចារ្យគេ | រាស្ត្រិះរេអរអនេក | ។ |
| ១៧- | ទីនេះយើងឲ្យស្តេច | មានអំណាចខ្ពស់ពន់ពេក | |
| | កើតពីពូជដាវីឌ | ឲ្យស្នងរាជ្យពេលនេះណា | ។ |
| | យើងនឹងរៀបចំឲ្យ | ស្តេចអង្គក្រោយមានបេស្តា | |
| | គ្រងរាជ្យយូរវស្សា | ជួសក្យត្រាយើងអភិសេក | ។ |

១៨- យើងនឹងធ្វើឲ្យខ្មាំង បាក់មុខខ្លាំអន្ទាសពន់ពេក
តែយើងនឹងឲ្យរាជ្យ យើងអភិសេកបានថ្កុំថ្កើង ។

## ទំនុកតម្កើងលេខ ១៣៣ (១៣២) បទពាក្យ ៧

១- បងប្អូនទាំងអស់ចេះរួមរស់ ចេះស្រួលចេះស្រុះស្រោះសោភា
គឺល្អប្រពៃឥតគណនា សប្បាយគ្រប់គ្នាត្រេកត្រអាល ។
២- គឺប្រៀបបីដូចជាទឹកអប់ ក្រអូបឈ្ងុយឈ្ងប់ហូរសព្វក្បាល
មកពុកចង្កាហើយរាលដាល ចុះមកដាយអាវលោកអារ៉ុន ។
៣- ប្រៀបបីដូចជាធ្លាក់សន្សើម ពីហែរម៉ូនភ្នំនិងស៊ីយ៉ូន
ជាកន្លែងព្រះម្ចាស់ប្រទាន ជីវិតឲ្យមានអស់កល្បកប្ប ។

## ទំនុកតម្កើងលេខ ១៣៤ (១៣៣) បទពាក្យ ៧

១- អស់អ្នកបម្រើព្រះអម្ចាស់ នៅក្នុងដំណាក់ពេលរាត្រី
នាំគ្នាតម្កើងព្រះម្ចាស់ថ្លៃ ដ៏ខ្ពង់ខ្ពស់ក្រៃពេកអស្ចារ្យ ។
២- ចូរលើកដៃឡើងហើយប្រណម្យ បែរទៅឲ្យចំទីសក្ការ
ចូរច្រៀងសរសើរដោយជ្រះថ្លា ថ្កើងព្រះចេស្តានៃព្រះអង្គ ។
៣- សូមព្រះអម្ចាស់ដែលបង្កើត មេឃដីល្អឆើតកុំវេរង់
សូមប្រទានពរដល់អ្នកជង ពីក្រុងស៊ីយ៉ូនមកកុំខាន ។

## ទំនុកតម្កើងលេខ ១៣៥ (១៣៤) បទភាកគតិ

១- អាលេលូយ៉ា ចូរគ្រប់អាត្មា សរសើរតម្កើង ព្រះនាមអម្ចាស់
ជាព្រះនៃយើង អ្នកបម្រើជង នាំគ្នាអបអរ ។
២- អ្នកដែលស្ថិតក្នុង ដំណាក់ព្រះអង្គ មូលមីរកុះករ នៅក្នុងបរិវេណ
ដំណាក់បវរ នាំគ្នាឈូឆរ សរសើរព្រះម្ចាស់ ។
៣- ដ្បិតព្រះអង្គថ្លៃ ទ្រង់មានព្រះទ័យ សប្បុរសខ្លាំងណាស់ ចូរច្រៀងតម្កើង
ថ្វាយព្រះនាមព្រះ ដ្បិតព្រះអម្ចាស់ គាប់ចិត្តនឹងយើង ។

៤- ព្រះម្ចាស់ជ្រើសរើស មិនឲ្យមានទាស់ ពូជយ៉ាកុបថ្កើង ព្រះអង្គយកជាតិ
អ៊ីស្រាអែលឡើង ជារាស្ត្រព្រះអង្គ រុងរឿងប្រពៃ ។
៥- ខ្ញុំដឹងច្បាស់ថា ព្រះម្ចាស់នេះណា ឧត្តមថ្លាថ្លៃ ព្រះម្ចាស់នៃយើង
ប្រសើរពេកក្រៃ លើសព្រះដទៃ មានទាំងប៉ុន្មាន ។
៦- បើទ្រង់ពេញចិត្ត ធ្វើការអ្វីពិត ជាសម្រេចបាន លើមេឃលើដី
សមុទ្រគ្រប់ស្ថាន ជម្រៅប៉ុន្មាន ក៏ទ្រង់ឥតរា ។
៧- ព្រះអង្គនាំយក ទាំងដុំពពក ពីជើងមេឃា ទ្រង់ធ្វើឲ្យមាន
រន្ទះខ្ទ័រខ្ទារ ភ្លៀងច្រើនមហិមា ខ្យល់បក់សព្វសាយ ។
៨- នៅស្រុកអេស៊ីប ព្រះអង្គសម្លាប់ កូនច្បងទាំងឡាយ តាំងពីកូនមនុស្ស
កូនសត្វអន្តរាយ ព្រះអង្គគ្មានស្តាយ ខ្ទាត់ខ្ទាយគ្មានសល់ ។
៩- ព្រះអង្គសម្តែង បារដិហារិយ៍ផ្សេងៗ អេស៊ីបខ្វាយខ្វល់ ដើម្បីដាក់ទោស
ស្តេចផារ៉ោនផ្ទាល់ និងអស់មន្ត្រី នៃស្តេចផងដែរ ។
១០- ព្រះអង្គបានវាយ ប្រហារស្លាប់ពាយ ជាតិច្រើនហូរហែ រួមទាំងជីវិត
ស្តេចខ្លាំងពូកែ មិនបានសុខទេ ត្រូវក្ស័យជីវី ។
១១- គឺស្តេចស៊ីហុន គ្រប់គ្រងតំបន់ ស្រុកអាម៉ូរី ទាំងព្រះបាទអុក
ស្រុកបាសានទី និងស្តេចមូលមី នៃជាតិកាណាន ។
១២- ទ្រង់សព្វព្រះទ័យ ប្រគល់ទឹកដី ជាមរតកថ្កាន ឲ្យអ៊ីស្រាអែល
ជារាស្ត្រទ្រង់បាន រស់ដោយសុខសាន្ត ត្រចង់រឿងរុង ។
១៣-បពិត្រព្រះម្ចាស់ ព្រះនាមរបស់ ព្រះអង្គគង់វង្ស ជារៀងរហូត
ល្បីល្បាញយូរលង់ ត្រចះត្រចង់ អស់កល្បគ្រប់គ្រា ។
១៤- ដ្បិតព្រះអង្គរក យុត្តិធម៌នាំមក ឲ្យរាស្ត្រប្រជា ព្រះអង្គអាណិត
អាសូរគ្រប់គ្នា អស់កូនចៅជា អ្នកស្ម័គ្របម្រើ ។
១៥- ព្រះផ្សេងឯទៀត ជាព្រះមិនពិត កើតពីមនុស្សធ្វើ ពីមាសពីប្រាក់
ពីស្ពាន់ពីឈើ អ្វីសព្វសារពើ ជាព្រះក្លែងក្លាយ ។
១៦- ព្រះនោះមានមាត់ បើកបិទមិនកើត មិនអាចនិយាយ មាត់ដែលជាងឆ្លាក់
គេដាក់មកឲ្យ ភ្នែកដែលមានហើយ តែបើកមិនរួច ។

| | | | | |
|---|---|---|---|---|
| ១៧- | ត្រចៀកក៏មាន | តែស្ដាប់មិនបាន | ដូចត្រចៀកខូច | ស្រេចតែជាងធ្វើ |
| | តាមធំតាមតូច | ខ្យល់ចូលមិនរួច | ដង្ហើមក៏គ្មាន | ។ |
| ១៨- | សូមឲ្យអស់អ្នក | ដែលខំសូនឆ្លាក់ | ឥតមានស្រាកស្រាន្ត | ធ្វើព្រះក្លែងក្លាយ |
| | មានទាំងប៉ុន្មាន | ឲ្យពួកគេបាន | ដូចព្រះទាំងនោះ | ។ |
| ១៩- | អ៊ីស្រាអែលអើយ | កុំនៅកន្តើយ | នាំគ្នាទាំងអស់ | ខំលើកតម្កើង |
| | ព្រះជាអម្ចាស់ | ទាំងពូជរបស់ | លោកអរ៉ុនផង | ។ |
| ២០- | គ្រួសារលេវី | ចូរមកមូលមីរ | សរសើរដ្កុំផ្គង | និងអ្នកដែលធ្លាប់ |
| | គោរពព្រះអង្គ | សរសើរថ្កើងថ្កាន | ព្រះម្ចាស់នៃយើង | ។ |
| ២១- | ចូរយើងនាំគ្នា | គ្រប់ៗអង្គា | មូលផ្ដុំតម្កើង | ព្រះជាអម្ចាស់ |
| | គង់ភ្នំស៊ីយ៉ូន | និងនៅក្នុងក្រុង | យេរូសាឡឹម | ។ |

## ទំនុកតម្កើងលេខ ១៣៦ (១៣៥) — បទកាកគតិ

| | | | | |
|---|---|---|---|---|
| ១- | សូមតម្កើងព្រះ | ដែលជាអម្ចាស់ | គ្រប់ទីតំបន់ | ទ្រង់មានព្រះទ័យ |
| | សប្បុរសពេកពន់ | ប្រសើរលើសលន់ | រហូតរៀងទៅ | ។ |
| ២- | ចូរលើកតម្កើង | ព្រះដ៏ខ្ពស់ថ្កើង | មិនដែលអាស្រូវ | ដោយធម៌មេត្តា |
| | ករុណាជាផ្លូវ | ដែលស្ថិតស្ថេរនៅ | អស់កល្បរហូត | ។ |
| ៣- | សរសើរតម្កើង | ព្រះម្ចាស់ខ្ពស់ឡើង | លើសគេបំផុត | ដោយធម៌មេត្តា |
| | ករុណាមោះមុត | នៅជាប់រហូត | កប្បកល្បអនេក | ។ |
| ៤- | មានតែព្រះអង្គ | ធ្វើការឧត្ដុង្គ | ឧត្ដមក្រៃពេក | ដោយធម៌មេត្តា |
| | ករុណាល្អឯក | ប្រណីសង្វេគ | អស់កល្បជានិច្ច | ។ |
| ៥- | ព្រះអង្គបង្កើត | ផ្ទៃមេឃល្អឆើត | ដោយគ្មានកលកិច្ច | ដ្បិតព្រះហឫទ័យ |
| | មេត្តាជានិច្ច | ករុណាពន់ពេក | ស្ថិតនៅយូរលង់ | ។ |
| ៦- | ព្រះអង្គបានដាក់ | ផែនដីតាមថ្នាក់ | ស្ថិតស្ថេរគង់វង្ស | នៅលើផ្ទៃទឹក |
| | ដ្បិតហឫទ័យទ្រង់ | ស្ថិតនៅយូរលង់ | អស់កល្បប្រិមប្រិយ៍ | ។ |
| ៧- | ព្រះអង្គបង្កើត | ដុំពន្លឺឆើត | ចែងចាំងរស្មី | ដោយធម៌មេត្តា |
| | ករុណាប្រណី | ស្ថិតនៅពាសដី | អស់កល្បអន្លាយ | ។ |

៨- គឺព្រះអាទិត្យ ព្រះអង្គបង្កើត បំភ្លឺពេលថ្ងៃ ដោយធម៌មេត្តា
ករុណាប្រណី ស្ថិតនៅអាល័យ អស់កល្បសព្វគ្រប់ ។
៩- ព្រះច័ន្ទតារា គ្រប់គ្រងត្រៀបត្រា បំភ្លឺពេលយប់ ដោយធម៌មេត្តា
ករុណាគួរគាប់ ស្ថិតស្ថេរនៅជាប់ អស់កល្បវៀងរាប ។
១០- ព្រះអង្គប្រល័យ កូនច្បងគ្រប់កាយ របស់អេស៊ីប ជ្បិតធម៌មេត្តា
ចែងចាំងជរាប មិនចេះស្រអាប់ អស់កល្បរហូត ។
១១- ទ្រង់នាំប្រជា ស្រាអែលគ្រប់គ្នា ឲ្យរួចរបូត ពីស្រុកអេស៊ីប
ដោយព្រះទ័យក្បួច នាំគេឲ្យរួច អស់កល្បយូរលង់ ។
១២- ដោយឫទ្ធិបារមី តេជះខ្លាំងក្រៃ ទាំងមានអានុភាពផង ជ្បិតធម៌មេត្តា
ករុណាកន្លង នៅជាប់ឥតហ្មង ស្ថិតស្ថេរពេញទី ។
១៣-ទ្រង់ញែកសមុទ្រ គ្មានព្រឹតក់ស្លុត ចែកចេញជាពីរ ដោយធម៌មេត្តា
ករុណាកន្លង នៅជាប់ឥតហ្មង ស្ថិតស្ថេរពេញទី ។
១៤- ទ្រង់នាំជនជាតិ ស្រាអែលដើរកាត់ តាមបាតសមុទ្រ ដោយធម៌មេត្តា
ករុណាបំផុត នៅមិនរលត់ អស់កប្បកល្បហោង ។
១៥- ព្រះអង្គធ្វើឲ្យ ស្តេចផារ៉ោនឆ្លោយ ទាំងកងទ័ពផង លង់ក្នុងសមុទ្រ
ស្លាប់គ្រានោះម្តង ករុណាព្រះអង្គ ស្ថិតនៅឥតស្រាន្ត ។
១៦- ព្រះអង្គណែនាំ ប្រជាឲ្យទ្រាំ តាមរហោស្ថាន ដោយធម៌មេត្តា
ករុណាថ្កើងថ្កាន ស្ថិតគ្មានអវសាន អស់កល្បមានជោគ ។
១៧- ទ្រង់ប្រហារស្តេច ពេញដោយអំណាច ច្រើនអង្គជួលស្ទុក ដោយធម៌មេត្តា
ករុណាមានមក ស្ថិតនៅក្នុងលោក អស់កល្បកន្លង ។
១៨- ព្រះអង្គប្រហារ ស្តេចខ្លាំងអស្ចារ្យ ឲ្យក្ស័យគ្រប់អង្គ ដោយធម៌មេត្តា
ករុណាត្រចង់ ស្ថិតនៅគង់វង្ស អស់កល្បគ្រប់ទី ។
១៩- គឺមានព្រះបាទ ស៊ីហុនសោយរាជ្យ លើអាម៉ូរី ជ្បិតទ្រង់មេត្តា
ករុណាគ្រប់ទី ស្ថិតស្ថេរមូលមីរ រហូតប្រពៃ ។
២០- និងព្រះបាទអុក គ្រប់គ្រងលើស្រុក បាសាននោះនៃ ព្រោះតែព្រះអង្គ
ទ្រង់មានព្រះទ័យ ស្មោះស្ម័គ្រមេត្រី អស់កល្បស្ថិតស្ថេរ ។

២១- ព្រះអង្គប្រទាន អ៊ីស្រាអែលមាន ដីទុកជាកេរ ដ្បិតព្រះហឫទ័យ
ទ្រង់ឥតងាករេ ព្រះអង្គស្ថិតស្ថេរ អស់កល្បតទៅ ។
២២- ព្រះអង្គប្រទាន កូនចៅឲ្យមាន ស្រុករស់និត្យនៅ ដោយធម៌មេត្តា
ករុណាពេកកូវ ព្រះអង្គស្ថិតនៅ ជាអចិន្ត្រៃយ៍ ។
២៣- ពេលយើងមានទុក្ខ វេទនាគ្រប់មុខ ទ្រង់តែងប្រណី ដោយធម៌មេត្តា
ករុណាឥតបី ប្រសើរពេកក្រៃ គ្រប់សម័យកាល ។
២៤- ព្រះអង្គរំដោះ យើងផុតពីគ្រោះ លែងភ័យជ្រួលច្រាល ដោយព្រះហឫទ័យ
ករុណាត្រកាល ស្ថិតនៅវៀងរាល់ រហូតឥតឈប់ ។
២៥- ព្រះអង្គប្រទាន អាហារឲ្យមាន ឆ្អែតឆ្អន់សព្វគ្រប់ ដោយធម៌មេត្តា
ករុណាលើសលប់ ស្ថិតនៅតាំងជាប់ ឥតបីរលត់ ។
២៦- ចូរលើកតម្កើង ព្រះម្ចាស់ខ្ពស់ឡើង គ្មានទីបំផុត ដោយធម៌មេត្តា
ករុណាវិសុទ្ធ ស្ថិតមិនរលត់ អស់កល្បកប្បហោង ។

## ទំនុកតម្កើងលេខ ១៣៧ (១៣៦) បទពាក្យ ៧

១- យើងអង្គុយនឹកគិតរិះរេ នៅមាត់ទន្លេបាប៊ីឡូន
យំនឹកស្រណោះក្រុងស៊ីយ៉ូន ធ្មេចភ្នែកក៏ឃើញក្នុងនេត្រា ។
២- ព្រះច័ន្ទបោលរស្មីឆ្នៅឆ្និន យើងបានព្យួរពិណយើងនោះណា
ជិតមាត់ទន្លេដើមរុក្ខា រួចបោលភក្ត្រាមើលទៅឆ្ងាយ ។
៣- ពេលនោះពួកអ្នកដែលចាប់យើង គេសុំឲ្យច្រៀងបទសប្បាយ
គេពោលថាចូរច្រៀងបរិយាយ ក្រុងស៊ីយ៉ូនឲ្យយើងស្តាប់ផង ។
៤- តើឲ្យយើងច្រៀងបទតម្កើង ថ្វាយព្រះនៃយើងពេលនេះម្តង
នៅលើទឹកដីដ៏សៅហ្មង នៃបរទេសផងដូចម្តេចកើត ? ។
៥- ឱ! ក្រុងយេរូសាឡឹមអើយ ខ្ញុំមិនភ្លេចឡើយក្រុងល្អឆើត
បើខ្ញុំភ្លេចអ្នកភ្លេចកំណើត សូមដៃខ្ញុំពើតស្ពឹកចុកចាប់ ។
៦- ប្រសិនបើខ្ញុំមិនជឿជាក់ មិនបាត់ទុកអ្នកដូចខ្ញុំប្រាប់
ជាអំណរដ៏ខ្លាំងក្លាគាប់ សូមអណ្តាតជាប់រឹងជិតជុំ ។

៧- ឱ! ព្រះអម្ចាស់សូមកុំភ្លេច ពីអំពើល្បិចជាតិអេដុំ
បានប្រព្រឹត្តចំពោះយើងខ្ញុំ ដែលបានឮធំក្នុងសោតា ។
ថ្ងៃដែលក្រុងយេរូសាឡឹម ត្រូវអស់សង្ឃឹមគេពោលថា ៖
« ចូរកម្ទេចក្រុងនេះទៅវ៉ា កម្ទេចលុះត្រារលំគ្រឹះ » ។
៨- រីឯក្រុងបាប៊ីឡូនវិញ បន្តិចទៀតឯងវិនាសអស់
ត្រូវគេបំផ្លាញគ្មានចន្លោះ មិនសល់អ្វីសោះយ៉ាងប្រាកដ ។
អ្នកណាធ្វើបាបឯងពេលនេះ តបនឹងតម្រិះដែលឯងក្បត់
ចំពោះរូបយើងមិនកំណត់ អ្នកនោះគឺពិតមានមង្គល ។
៩- អ្នកណាចាប់កូនតូចៗឯង ចាប់មិនខ្ចីលែងមិនខ្វាយខ្វល់
បោកទៅនឹងថ្មខ្ទេចគ្មានសល់ នឹងមានមង្គលសុខរហូត ។

## ទំនុកតម្កើងលេខ ១៣៨ (១៣៧) បទកាកគតិ

១- ខ្ញុំសូមតម្កើង ព្រះម្ចាស់ខ្ពស់ឡើង អស់ពីដួងចិត្ត នៅមុខទេវតា
ខ្ញុំស្មូត្រជាបទ តម្កើងថ្វាយថ្វាត់ ដល់ព្រះអង្គថ្លៃ ។
២- ខ្ញុំក្រាបបែរមុខ តម្រង់ទៅរក វិហារប្រពៃ ខ្ញុំលើកតម្កើង
ព្រះនាមថ្លាថ្លៃ ដោយព្រះហឫទ័យ ស្មោះស្ម័គ្រឥតស្បើយ ។
៣- នៅថ្ងៃដែលខ្ញុំ ស្រែកអង្វរសុំ ព្រះអង្គតបឆ្លើយ ព្រះអង្គប្រទាន
ឥតមានកន្តើយ ឲ្យខ្ញុំបានស្បើយ ក្នុងចិត្តក្លាហាន ។
៤- ឱ! ព្រះម្ចាស់អើយ សូមទ្រង់ផ្តល់ឲ្យ ស្តេចទាំងប៉ុន្មាន នៅលើផែនដី
នាំគ្នាគ្រប់ប្រាណ តម្កើងពេលបាន ឮទ្រង់សន្យា ។
៥- សូមឲ្យគេនាំ គ្នីគ្នាច្រៀងរាំ តម្កើងកិច្ចការ ថា « ព្រះអម្ចាស់
រុងរឿងអស្ចារ្យ ឧត្តមថ្លៃថ្លា បំផុតគ្មានពីរ ។
៦- ទោះបីព្រះម្ចាស់ ខ្ពង់ខ្ពស់ខ្លាំងណាស់ ក៏ទ្រង់សំភី គិតមនុស្សលោក
គ្រប់វិនាទី ជនកាចយាយី ទ្រង់ស្គាល់ពីឆ្ងាយ ។
៧- ពេលទូលបង្គំ ជួបអាសន្នធំ ទ្រង់ឥតជិនណាយ ជួយការពារខ្ញុំ
វាយខ្មាំងខ្វាត់ខ្វាយ សង្គ្រោះខ្ញុំដោយ ឫទ្ធីបារមី ។

៨- បពិត្រព្រះម្ចាស់ ការគ្រប់យ៉ាងនេះ ពិតជាប្រពៃ ព្រះអង្គប្រកប
ដោយព្រះហឫទ័យ ករុណាក្រៃ ឥតបីបោះបង់ ។

## ទំនុកតម្កើងលេខ ១៣៩ (១៣៨) បទពាក្យ ៧

១- បពិត្រព្រះម្ចាស់ដ៏សប្បុរស ទ្រង់ឈ្វេងយល់អស់ជម្រៅចិត្ត
នៃទូលបង្គំដែលមានពិត ព្រះអង្គស្គាល់ឥតសល់ចន្លោះ ។
២- ទ្រង់ជ្រាបឥតបីមានសង្ស័យ ក្រោកឈរអង្គុយគ្រប់ទាំងអស់
ឈ្វេងយល់គំនិតខ្ញុំឥតខ្ចោះ ពីមុនទាំងអស់ស្រេចទៅហើយ ។
៣- ទោះបីដើរដេកធ្វើកិច្ចការ តិចច្រើនម្ដេចម្ដាមិនបាត់ឡើយ
ព្រះអង្គទ្រង់ជ្រាបអស់ទៅហើយ សម្រាកក៏ដោយមិនកំបាំង ។
៤- ទោះជាពាក្យពេចន៍ប្រុងនឹងស្ដី ទ្រង់យល់អត្ថន័យអស់តែម្ដង
សព្វទាំងសេចក្ដីដែលបម្រុង ទុកក្នុងចិត្តផងក៏មិនសល់ ។
៥- ព្រះអង្គនៅពាំងទាំងមុខក្រោយ ការពារមិនឲ្យមានកង្វល់
មិនឲ្យខ្ញុំជួបគ្រោះអំពល់ ព្រោះតែទ្រង់ផ្ដល់បារមីថ្លៃ ។
៦- នេះគឺព្រះអង្គទ្រង់ត្រាស់ញាណ ទើបទ្រង់ជ្រាបបានមិនសល់អ្វី
អស្ចារ្យពេកណាស់គួរស្ញែងក្រៃ ខ្ញុំមិនយល់ន័យដូចម្ដេចសោះ ។
៧- តើទូលបង្គំអាចទៅណា ឆ្ងាយពីភក្ត្រាព្រះអង្គនោះ
គេចទៅទីណាមិនផុតសោះ ព្រះអង្គជ្រាបអស់សព្វទិសា ។
៨- បើខ្ញុំនឹងឡើងទៅលើមេឃ ក៏មិនផុតភ្នែកផុតនេត្រា
បើទៅនៅស្ថានមនុស្សមរណា ក៏ជួបភក្ត្រាទ្រង់ជានិច្ច ។
៩- ទោះបីជាខ្ញុំពាក់ស្លាបហោះ ទៅកន្លែងរះព្រះអាទិត្យ
ឬទោះបីខ្ញុំចង់រត់គេច ទៅរស់ឯលិចនាយសមុទ្រ ។
១០- ក៏ព្រះអង្គគង់នៅទីនោះ ឥតមានចន្លោះឬគេចផុត
ជួយដឹកនាំខ្ញុំលែងតក់ស្លុត ដោយបារមីឫទ្ធិដ៏ឧត្ដម ។
១១- ប្រសិនបើខ្ញុំពោលឡើងថា សូមឲ្យអន្ធិកាគ្របលើខ្ញុំ
ពន្លឺថ្ងៃដែលនៅជិតជុំ ប្រែក្លាយយប់ជ្ដុំឥតពន្លឺ ។

១២- ទោះបីងងឹតយ៉ាងណាក្តី ព្រះអម្ចាស់ថ្លៃនៅតែភ្លឺ
ពេលយប់ដូចថ្ងៃជះរន្ទឺ ងងឹតប្រែភ្លឺមានរស្មី ។
១៣- ព្រះអង្គបង្កើតខ្ញុំបានសុខ ហើយទ្រង់បានទុកខ្ញុំក្នុងផ្ទៃ
អ្នកម្តាយមានគុណយូរខែថ្ងៃ សន្តោសប្រណីគ្រប់កាយា ។
១៤- ខ្ញុំសូមលើកតម្កើងព្រះអង្គ ស្នាព្រះហស្តទ្រង់ក៏អស្ចារ្យ
ខ្ញុំដឹងថាអ្វីគ្រប់ប្រការ សុទ្ធតែអស្ចារ្យកើតពីទ្រង់ ។
១៥- ពេលទូលបង្គំចាប់កំណើត នៅក្នុងទីស្ងាត់លាក់កំបាំង
ក៏មិនអាចពួននឹងព្រះអង្គ អ្វីៗក៏ទ្រង់ជ្រាបទាំងអស់ ។
១៦- កាលទូលបង្គំមិនមានខ្លួន រូបកាយមាំមួនសាច់ឈាមស្រស់
ព្រះអង្គទតឃើញខ្ញុំទាំងអស់ ឥតមានចន្លោះត្រង់ណាឡើយ ។
ព្រះអង្គកំណត់ពេលជងណា អាយុសង្ខារខ្ញុំរួចហើយ
កត់ទុកជាស្រេចមិនកន្តើយ មុននឹងដល់ថ្ងៃនោះមកទៀត ។
១៧- បពិត្រព្រះម្ចាស់ព្រះតម្រិះ ព្រះអង្គជ្រៅជ្រះជាងសមុទ្រ
ខ្ពស់ហួសអាកាសវេហាស៍ផុត មិនអាចកំណត់ដឹងប៉ុន្មាន ។
១៨- ប្រសិនបើចិត្តខ្ញុំចង់រាប់ ក៏មិនអាចគ្រប់ទាំងអស់បាន
ពីការអស្ចារ្យទាំងប៉ុន្មាន មានចំនួនច្រើនជាងគ្រាប់ខ្សាច់ ។
១៩- បពិត្រព្រះម្ចាស់ទ្រង់គួរតែ ប្រហារពួកគេឲ្យខ្ទីខ្ទេច
ទាំងពួកឃាតករសូមក្រញិច ឲ្យគេរត់គេចឆ្ងាយពីខ្ញុំ ។
២០- សត្រូវព្រះអង្គនាំគ្នាយក នាមព្រះអង្គមកបោកបន្លំ
គេពោលព្រះនាមទ្រង់ជាធំ ដើម្បីបន្លំធ្វើអាក្រក់ ។
២១- បពិត្រព្រះម្ចាស់អើយខ្ញុំស្អប់ អ្នកធ្វើមិនគាប់ចិត្តគម្រក់
ចង់ចងគំនុំព្រះសង្គ្រោះ បះបោរទុយ៌សប៉ងប្រឆាំង ។
២២-ខ្ញុំស្អប់ពួកគេខ្លាំងបំផុត ពួកអ្នកមានចិត្តហ៊ានប្រណាំង
ខ្ញុំបានចាត់ទុកគេជាខ្មាំង តែងតែប្រឆាំងរូបខ្ញុំផ្ទាល់ ។
២៣- ឱ! ព្រះម្ចាស់អើយសូមពិនិត្យ ឲ្យបានស្គាល់ចិត្តផុតកង្វល់
ទាំងល្បងមើលខ្ញុំឲ្យអស់ខ្វល់ ដើម្បីបានយល់អ្វីខ្ញុំគិត ។

២៤- សូមព្រះជាម្ចាស់ទតមើលតើ ខ្ញុំមិនបានដើរខុសពីក្រឹត្យ
ជួយដឹកនាំខ្ញុំឲ្យជួបជិត មាគ៌ាប្រណីតនៅអស់កល្ប ។

## ទំនុកតម្កើងលេខ ១៤០ (១៣៩) បទព្រហ្មគីតិ

២- ឱព្រះជាអម្ចាស់ សូមរំដោះខ្ញុំឲ្យផុត
ពីអ្នកមានពុតត្បុត ពួកទុច្ចរិតពាលឃោរឃៅ ។
៣- គេនាំគ្នាប្រព្រឹត្ត រឿងឧក្រិដ្ឋទាំងល្ងង់ខ្លៅ
មិនស្គាល់ពីរាក់ជ្រៅ ខុសឬត្រូវចង់តែឈ្លោះ ។
៤- អណ្ដាតគេសាហាវ មុតដូចដាវពោលទ្រគោះ
មាត់គេពេញដោយពិស ដូចសត្វពស់គួរឲ្យខ្លាច ។
៥- ឱ! ព្រះជាអម្ចាស់ សូមសន្ដោសដោយអំណាច
ការពារខ្ញុំឲ្យរួច ជនកំហូចចង់រំលំ ។
៦- គេខំអួតបំប៉ោង ដាក់ចម្រូងពួនសំងំ
អន្ទាក់ដាក់បន្លំ បំាចាប់ខ្ញុំរាល់តែថ្ងៃ ។
៧- ខ្ញុំទូលព្រះម្ចាស់ថា ទ្រង់គឺជាព្រះម្ចាស់ថ្លៃ
សូមមេត្តាប្រណី ស្ដាប់សម្ដីខ្ញុំវាចា ។
៨- បពិត្រព្រះអម្ចាស់ សូមសង្គ្រោះដោយចេស្ដា
ពេលច្បាំងនឹងបច្ចា ទ្រង់ពាំងការមិនឲ្យសូន្យ ។
៩- ឱ! ព្រះជាម្ចាស់អើយ សូមកុំឲ្យពួកទុរជន
សម្រេចផែនការមុន ឲ្យគេសូន្យបរាជ័យ ។
១០- កុំឲ្យអ្នកឡោមព័ទ្ធ ខ្ញុំមិនភ្ជាត់អរសប្បាយ
តែសូមជួយប្រែក្លាយ ក្ដីអន្ដរាយដាក់ទៅគេ ។
១១- ឲ្យមានភ្លើងឆ្អិនឆ្អៅ ឆេះសន្ធៅស្រោចបំបែរ
សូមប្រានទម្លាក់គេ មិនរួចទេភ្លើងឆេះប្រាណ ។
១២- ឯអ្នកបង្កាច់មួល នៅមិនស្រួលពុំសុខសាន្ដ
ទុក្ខសោកតាមរំខាន ញាំញីប្រាណមិនឈប់ឈរ ។

១៣- ខ្ញុំដឹងថាព្រះម្ចាស់   តាមសង្គ្រោះទាំងនគរ
ព្រះអង្គរកយុត្តិធម៌   អ្នកក្រីក្រមិនភ័យព្រួយ   ។
១៤- ឯអ្នកសុចរិត   គេខំខិតតម្កើងស្ងួយ
ព្រះម្ចាស់មានតែមួយ   គ្មានទុក្ខព្រួយពេលជួបភក្ត្រ   ។

## ទំតម្កើងលេខ ១៤១ (១៤០)   បទកាកគតិ

១- ឱព្រះអម្ចាស់   ខ្ញុំសូមប្រកាស   ទូលពាក្យអង្វរ   សូមផ្ទៀងព្រះកាណ៌
ស្តាប់ស្នូរថ្ងូចថ្ងូរ   កុំបង្អង់យូរ   យាងមកជួយខ្ញុំ   ។
២- សូមឲ្យវាចា   អធិដ្ឋានគ្រប់គ្រា   នៃទូលបង្គំ   បានឡើងទៅដល់
ព្រះម្ចាស់ឧត្តម   ដូចផ្សែងហុយធំ   ពីគ្រឿងក្រអូប   ។
រូបខ្ញុំលើកដៃ   អធិដ្ឋានរាល់ថ្ងៃ   ដូចតង្វាយគាប់   ថ្វាយនៅពេលល្ងាច
ក្រអូបឈ្ងុយឈ្ងប់   ជះក្លិនសាយសព្វ   ទៅគ្រប់ទិសា   ។
៣- ឱ! ព្រះអម្ចាស់   សូមមេត្តាខ្ទាស់   មាត់ខ្ញុំផងណា   កុំឲ្យនិយាយ
ពាក្យដែលមុសា   ពោលមិនបានការ   ជាពាក្យអាក្រក់   ។
៤- សូមកុំបណ្ដោយ   កាយចិត្តខ្ញុំឲ្យ   ធ្វើរឿងគម្រក់   ដែលមិនគប្បី
កុំទៅស្មោះស្ម័គ្រ   ជប់លៀងព័ទ្ធពាក់   ពួកអ្នកទុច្ចរិត   ។
៥- បើអ្នកជាល្អ   សុចរិតយុត្តិធម៌   ប្រដៅដោយចិត្ត   ស្មោះត្រង់ស្រឡាញ់
ពោរពេញអាណិត   ខ្ញុំមិនបាច់គិត   ការល្អសមរម្យ   ។
កុំឲ្យទឹកអប់   ពួកពាលហូរសព្វ   ស្រោចលើក្បាលខ្ញុំ   ខ្ញុំខំស្រែករក
ព្រះម្ចាស់ឧត្តម   ជួយទូលបង្គំ   ប្រឆាំងពួកពាល   ។
៦- មេដឹកនាំនោះ   ត្រូវគេប្រានចុះ   ទៅក្នុងជំរាល   តាមក្រហែងថ្ម
បច្ចាមិត្តយល់   ច្បាស់អស់គ្មានសល់   ពាក្យខ្ញុំស្ដីថា ៖   ។
៧- «ដូចដីដែលប្រេះ   រលួយរលេះ   ពីគ្នាយ៉ាងណា   ឲ្យស្ថានអ្នកស្លាប់
បើកចំហទ្វារ   លេបឆ្អឹងពួកវា   ដែលនៅរាយប៉ាយ   »   ។
៨- បពិត្រព្រះម្ចាស់   ខ្ញុំខំប្រឹងណាស់   សម្លឹងទៅឆ្ងាយ   រកព្រះជានិច្ច
ផ្ញើជីវិតកាយ   សូមកុំបណ្ដោយ   ឲ្យខ្ញុំបាត់បង់   ។

៩- សូមជួយការពារ  រូបខ្ញុំគ្រប់គ្រា  ពីគ្រោះទាំងពួង  ដែលគេលបដាក់
អន្ទាក់ខ្ញុំផង  កុំឲ្យខ្ញុំលង់  ក្នុងដៃទុច្ចរិត  ។
១០-តែសូមឲ្យគេ  ជាប់កុំគេចកែ  អន្ទាក់នោះពិត  ដែលគេចង់ដាក់
រូបខ្ញុំរួមរិត  ឲ្យពួកគេស្ថិត  ជាប់ខ្លួនឯងវិញ  ។
ឯទូលបង្គំ  រួចផុតទុក្ខធំ  ឥតមានទោម្នេញ  ផុតពីប្រវាក់
គេបាក់គេដេញ  រួចស្រឡះវិញ  ឥតមានព្រួយភ័យ  ។

## ទំនុកតម្កើងលេខ ១៤២ (១៤១) បទកាកគតិ

២- ខ្ញុំខំបន្លឺ  សម្លេងរន្ធឺ  អង្វរព្រះម្ចាស់  ស្រែកដោយទទូច
ឲ្យទ្រង់ឮច្បាស់  ព្រោះរូបខ្ញុំនេះ  វេទនាពេកក្រៃ  ។
៣- ខ្ញុំទូលព្រះអង្គ  ឲ្យបានជ្រាបផង  នូវអស់អត្ថន័យ  ពីពាក្យត្អូញត្អែរ
ទុក្ខសោករីងរៃ  វេទនារាល់ថ្ងៃ  ស្ទើរក្ស័យជីវិត  ។
៤- ពេលទូលបង្គំ  មានទុក្ខក្រៀមក្រំ  បាក់ធ្លាក់ទឹកចិត្ត  ព្រះអង្គជ្រាបច្បាស់
ពីដំណើរពិត  ពួកគេជុំជិត  ដាក់អន្ទាក់ខ្ញុំ  ។
៥- សូមទ្រង់ទតចុះ  គ្មាននរណាសោះ  ឃើញទូលបង្គំ  គ្មានទីជ្រកកោន
ឲ្យបានសមរម្យ  នរណាក៏ពុំ  រវល់ឡើយណា  ។
៦- បពិត្រព្រះម្ចាស់  ខ្ញុំស្រែកពោលនេះ  អង្វរទ្រង់ថា  « ទ្រង់ជាជម្រក
នៅក្នុងលោកា  គ្មានអ្វីអស្ចារ្យ  ជាងព្រះអង្គឡើយ  ។
៧- សូមទ្រង់ប្រណី  សម្ដែងហឫទ័យ  កុំបីបន្តើយ  ដ្បិតទូលបង្គំ
ទាល់ច្រកអស់ហើយ  រំដោះឲ្យស្បើយ  ពីជនអប្រិយ៍  ។
៨- សូមដោះលែងខ្ញុំ  ផុតពីទុក្ខធំ  មានសិទ្ធិសេរី  ដើម្បីខ្ញុំអាច
ថ្កើងព្រះនាមល្បី  ចំណោមប្រុសស្រី  នៃជនសុចរិត  ។

## ទំនុកតម្កើងលេខ ១៤៣ (១៤២) បទពាក្យ ៧

១- ឱ! ព្រះម្ចាស់អើយសូមសណ្ដាប់  ពាក្យខ្ញុំរ៉ាយរ៉ាប់ទូលអង្វរ
ផ្ទៀងព្រះកាណ៌ស្ដាប់កុំឈប់ឈរ  សូមឆ្លើយតបតដោយប្រណី  ។

២- សូមកុំចាប់ទោសយកកំហុស    អ្នកបម្រើស្មោះទៅកាត់ក្តី
ដ្បិតគ្មានជនសុចរិតប្រពៃ    ចំពោះភក្ត្រព្រះអង្គឡើយ ។
៣- ពួកខ្មាំងសត្រូវតាមយាយី    ពីគ្រប់ទិសទីមិនកន្តើយ
ឃុំខ្ញុំក្នុងទីងងឹតហើយ    ដូចអ្នកក្សិណក្ស័យយូរណាស់ណា ។
៤- ខ្ញុំបាក់ធ្លុះធ្លាក់អស់ទឹកចិត្ត    ទាល់ទាំងគំនិតក្នុងកាយា
ថយទាំងកម្លាំងខ្វះប្រាជ្ញា    មិនដឹងគិតថាត្រូវធ្វើម៉េច ? ។
៥- ខ្ញុំនឹកទៅដល់ជំនាន់មុន    សញ្ជឹងគូរគន់គ្រប់ភារកិច្ច
ជាស្នាព្រះហស្តល្អបណ្តាច់    ឥតមានកលល្បិចគ្មានទើសទាល់ ។
៦- ដៃខ្ញុំអង្វរខ្លួនបែរក្រាប    ដាក់កាយឲ្យទាបមុខព្រះម្ចាស់
ដូចដីហួតហែងបែកប្រេះអស់    ស្ងួតរីងរាំងខ្សោះព្រោះគ្មានទឹក ។
៧- ឱ! ព្រះជាអម្ចាស់ខ្ញុំអើយ    សូមជួយតបឆ្លើយឲ្យញយញឹក
ខ្ញុំបាត់បង់អស់ធ្លាក់ទឹកចិត្ត    កុំលាក់បាំងបិទភក្ត្រនឹងខ្ញុំ ។
ព្រោះតែខ្ញុំដូចជាមនុស្ស    ដែលធ្លាក់ក្នុងជ្រោះជ្រៅសន្លឹម
គ្មាននរណាជួយអស់សង្ឃឹម    ដូចមេឃរលឹមគ្មានរស្មី ។
៨- សូមទ្រង់បង្ហាញធម៌មេត្តា    សន្តោសករុណាត្រាប្រណី
ខ្ញុំផ្ញើរូបកាយជីវិតក្តី    លើព្រះម្ចាស់ថ្លៃរួចទៅហើយ ។
សូមប្រោសប្រទានឲ្យខ្ញុំស្គាល់    មាគ៌ានិមលកុំកន្តើយ
ដ្បិតទូលបង្គំផ្ចង់ចិត្តហើយ    ព្រះជាម្ចាស់អើយមិនបោះបង់ ។
៩- ឱ! ព្រះអម្ចាស់សូមរំដោះ    ខ្ញុំឲ្យផុតគ្រោះផុតពីខ្មាំង
សត្រូវយាយីតាមប្រឆាំង    ខ្ញុំសូមព្រះអង្គពួនជ្រកផង ។
១០- សូមជួយបង្ហាត់ពត់បង្រៀន    ខ្ញុំព្រមតាមបានព្រះបំណង
ដ្បិតទ្រង់ជាព្រះល្អម៉ត់ម៉ង    ដឹកនាំខ្ញុំផងដាក់ផ្លូវល្អ ។
១១- ឱ! ព្រះម្ចាស់អើយសូមគាំពារ    យល់ដល់នាមាព្រះបវរ
ប្រទានជីវិតខ្ញុំកំដរ    ឲ្យបានរស់តទៅទៀតផង ។
សូមជួយនាំខ្ញុំឲ្យចេញផុត    ពីភាពងងឹតអាប់អួរហ្មង
គ្រោះថ្នាក់តូចធំអាសន្នផង    ដោយហឫទ័យទ្រង់សុចរិត ។

១២- ដោយព្រះអង្គមានធម៌មេត្តា ហឫទ័យករុណាស្មោះអាណិត
សូមកម្ទេចពួកបច្ចាមិត្ត ឲ្យវិនាសផុតសាបសូន្យទៅ ។

## ទំនុកតម្កើងលេខ ១៤៤ (១៤៣) បទព្រហ្មគីតិ

១- សូមលើកតម្កើងព្រះ ជាអម្ចាស់ដ៏ឧត្ដម
ជាថ្មដានៃខ្ញុំ ដ៏រឹងមាំមួនបំផុត ។
ព្រះអង្គបានបង្ហាត់ ខ្ញុំចេះស្ទាត់ការប្រយុទ្ធ
ធ្វើសឹកឥតភ័យស្លុត ចេញតយុទ្ធខ្មាំងជិតជុំ ។
២- ទ្រង់សម្ដែងហឫទ័យ ករុណាក្រៃចំពោះខ្ញុំ
ជាកំពែងរឹងមាំ ការពារខ្ញុំយ៉ាងអង់អាច ។
ព្រះអង្គជាជម្រក ខ្ញុំមកជ្រកឥតភ័យខ្លាច
ទ្រង់ប្រគល់អំណាច ឲ្យខ្ញុំអាចមានជ័យដៃ ។
៣- ឱ! ព្រះជាអម្ចាស់ តើមនុស្សគឺជាអ្វី
ទើបទ្រង់យកព្រះទ័យ ត្រាប្រណីមិនឈរឈប់ ។
តើមនុស្សលោកីយ៍ គេជាអ្វីទើបទ្រង់សព្វ
ព្រះទ័យមិនឈរឈប់ ទោះថ្ងៃយប់នឹករិះរេ ។
៤- មនុស្សលោកប្រៀបផ្ទឹម មួយដង្ហើមប៉ុណ្ណោះទេ
អាយុជីវិតគេ មិនទៀងទេគ្រប់ៗគ្នា ។
៥- ឱ! ព្រះជាអម្ចាស់ សូមរូតរះផ្ទៀងមេឃា
សូមពាល់ភ្នំនានា ឲ្យខ្ទ័រខ្ទារផ្សែងហុយឡើង ។
៦- សូមធ្វើផ្លេកបន្ទោរ កម្ចាត់បោលខ្មាំងឲ្យបើង
សូមទ្រង់បាញ់ព្រួញភ្លើង ឲ្យរលើងទ័ពខ្មាំងផង ។
៧- សូមទ្រង់លាតព្រះហស្ដ មករំដោះនិងស្រោចស្រង់
ផុតសមុទ្រជ្រោះជ្រង អំណាចផងជនទុច្ចរិត ។
៨- គេមិនដែលនិយាយ សេចក្ដីអ្វីជាពាក្យពិត
មិនគោរពសម្បថ ដែលគេស្បថប្រែឥតន័យ ។

៩- បពិត្រព្រះម្ចាស់អើយ ខ្ញុំច្រៀងថ្វាយនូវបទថ្មី
និងប្រគុំតន្ត្រី ពិរោះក្រៃថ្វាយព្រះម្ចាស់ ។
១០- ព្រះអង្គបានប្រទាន ឲ្យស្តេចមានជ័យជម្នះ
ព្រះអង្គបានសង្គ្រោះ ដាវីឌរស់មានសិរី ។
១១- សូមសង្គ្រោះរំដោះ ខ្ញុំឲ្យរស់ផុតពីដៃ
ជនបរទេសអប្រិយ៍ ដែលនិយាយពាក្យមិនពិត ។
១២- សូមឲ្យកូនប្រុសៗ យើងទាំងអស់ស្រស់ប្រណីត
លូតលាស់ល្អម៉ងម៉ត់ ដូចរុក្ខជាតិស្រស់ខៀវខ្ចី ។
ឯកូនស្រីសំណព្វ ល្អគួរគាប់ស្រស់ប្រិមប្រិយ៍
ដូចទេពអប្សរស្រី ល្អប្រពៃស្រស់ផូរផង់ ។
១៣- សូមឲ្យក្នុងជង្រុក យើងមានផ្ទុកភោគផលជង
ចៀមក្នុងហ្វូងត្រសង កើនច្រើនដងរាប់ម៉ឺនពាន់ ។
១៤- ហ្វូងគោក៏ចម្រើន មានកូនច្រើនមិនថយអន់
គ្មានបាត់គ្មានគេប្លន់ គ្មានអាសន្នតាមទីផ្សារ ។
១៥- ប្រជាណាទទួល ពរនិមលដូច្នេះណា
កើតមានក្តីសុខា មង្គលថ្លាល្អត្រចះ ។
ប្រជាណាគោរព ព្រះម្ចាស់ទុកធ្វើជាព្រះ
នោះគេនឹងឃើញច្បាស់ ជួបប្រទះតែមង្គល ។

## ទំនុកតម្កើងលេខ ១៤៥ (១៤៤) បទព្រហ្មគីតិ

១- បពិត្រព្រះម្ចាស់ ជាក្សត្ររបស់ រូបទូលបង្គំ ពេលនេះខ្ញុំកោត
នាមព្រះឧត្តម អស់កល្បយូរលង់ ជារៀងដរាប ។
២- ខ្ញុំសូមតម្កើង ព្រះអង្គខ្ពស់ឡើង តទៅរៀងរៀប ខ្ញុំសូមសរសើរ
ព្រះនាមល្អគាប់ អស់កល្បដរាប រហូតតទៅ ។
៣- ព្រះម្ចាស់ឧត្តម ប្រសើរសក្តិសម ខ្ពង់ខ្ពស់ពេកក្រៃ យើងលើកតម្កើង
ព្រះនាមជាផ្លូវ ពេលនេះតទៅ រកអ្វីផ្ទឹមគ្មាន ។

៤- សូមឲ្យមនុស្ស ទាំងស្រីទាំងប្រុស នៅគ្រប់ជំនាន់ លើកតម្កើងស្នា
ព្រះហស្តព្រះអង្គ ការអស្ចារ្យផង ដែលទ្រង់ប្រព្រឹត្ត ។
៥- ខ្ញុំរាប់ខ្ញុំរៀប ពីអនុភាព បារមីមានឫទ្ធិ សិរីរុងរឿង
ព្រះអង្គមានពិត ខ្ញុំសញ្ជឹងគិត គ្រប់ស្នាព្រះហស្ត ។
៦- គេនឹងថ្លាថ្លែង អានុភាពស្ញប់ស្ញែង បារមីខ្ពង់ខ្ពស់ ខ្ញុំក៏ថ្លាថ្លែង
កិច្ចការទាំងអស់ ជាស្នាព្រះហស្ត ទ្រង់ធ្វើហូរហៃ ។
៧- គេនឹងរំលឹក ទាំងថ្ងៃយប់ព្រឹក តទៅឥតប្រែ ព្រមទាំងប្រកាស
ក្ដីសប្បុរសដែរ សុចរិតឥតល្ហែ របស់ព្រះអង្គ ។
៨- ព្រះជាអម្ចាស់ ប្រកបដោយព្រះ ហឫទ័យត្រចង់ ប្រណីសន្ដោស
ករុណាហ្មត់ហ្មង អត់ធ្មត់កន្លង អាណិតមេត្តា ។
៩- ព្រះជាអម្ចាស់ ព្រះទ័យសប្បុរស លើមនុស្សលោកា ទ្រង់មានព្រះទ័យ
សន្ដោសករុណា មនុស្សគ្រប់អាត្មា រស់ពេញដែនដី ។
១០- បពិត្រព្រះម្ចាស់ សត្វលោកទាំងអស់ មានច្រើនពេកក្រៃ នាំគ្នាតម្កើង
រុងរឿងសិរី រាស្ត្រទាំងប្រុសស្រី ក៏ថ្កើងទ្រង់ដែរ ។
១១- គេនឹងរៀបរាប់ ព្រះរាជ្យគួរគាប់ រុងរឿងស្ថិតស្ថេរ របស់ព្រះអង្គ
ឥតមានប្រួលប្រែ អានុភាពឥតកែ ព្រះអង្គនៅគង់ ។
១២- ដើម្បីឲ្យមនុស្ស ទាំងស្រីទាំងប្រុស គ្រប់គ្នាបានដឹង ពីការអស្ចារ្យ
របស់ព្រះអង្គ រស្មីរឿងរុង ចិញ្ចែងចិញ្ចាច ។
១៣- ព្រះរាជ្យព្រះអង្គ ស្ថិតនៅយូរលង់ ពេញដោយអំណាច គ្រងរាជ្យអស់កល្ប
ព្រោះទ្រង់ជាស្ដេច បារមីអង់អាច ស្ថិតយូរវស្សា ។
ព្រះអម្ចាស់តែង គោរពឥតក្លែង បន្ទូលសន្យា អ្វីដែលទ្រង់ធ្វើ
សុទ្ធតែអស្ចារ្យ សប្បុរសមេត្តា ករុណាអាសូរ ។
១៤- ព្រះអង្គលើកស្ទួយ អ្នកហេវហត់ព្រួយ ដួលយំស្រែកថ្ងូរ ទ្រង់លើកអ្នកអស់
សង្ឃឹមឲ្យឈរ ពង្រឹងជំហរ ឲ្យល្អវិញបាន ។
១៥- បពិត្រព្រះម្ចាស់ សត្វលោកទាំងអស់ ចាំមិនហ៊ានខាន ដោយចិត្តសង្ឃឹម
ពួកគេនឹងបាន អាហារគ្រប់ប្រាណ តាមពេលកំណត់ ។

១៦-ទ្រង់មានព្រះទ័យ ទូលាយពេកក្រៃ ពេញដោយប្រាកដ ព្រះអង្គប្រទាន
ដល់អ្នកក្រខ្សត់ បានឆ្អែតគ្រប់មាត់ តាមចិត្តប្រាថ្នា ។
១៧-ព្រះជាអម្ចាស់ ធ្វើសព្វទាំងអស់ នូវរាល់កិច្ចការ ដោយព្រះហឫទ័យ
សុចរិតថ្លៃថ្លា សន្ដោសករុណា ទ្រង់បានប្រព្រឹត្ត ។
១៨-ព្រះអម្ចាស់គង់ នៅជិតអែបអង្គ កៀកកើយនែបនិត្យនឹងអ្នកអង្វរ
ដោយសុទ្ធចិត្ត រកព្រះអង្គពិត មិនយាងទៅណា ។
១៩-ទ្រង់បានសម្រេច តាមបំណងកិច្ច ដែលគេប្រាថ្នា របស់អស់អ្នក
កោតខ្លាចបេស្មា ព្រះអង្គស្មុះស្មា ហើយសង្គ្រោះគេ ។
២០-អ្នកដែលស្រឡាញ់ ព្រះម្ចាស់ពោរពេញ ឥតក្រឡះប្រែ ទ្រង់នឹងគ្រប់គ្រង
ការពារថ្នមថៃ ហើយទ្រង់តែងតែ បំផ្លាញមនុស្សខូច ។
២១-ខ្ញុំសូមថ្លែងឡើង សរសើរតម្កើង គ្មានចិត្តលាក់លួច តម្កើងព្រះម្ចាស់
សត្វលោកធំតូច ទាំងអស់ជួយលើក ព្រះនាមព្រះអង្គ ។

## ទំនុកតម្កើងលេខ ១៨៦ (១៨៥) បទពាក្យ ៧

១- ឱ! ព្រះអម្ចាស់អើយខ្ញុំសូម តម្កើងទាំងព្រមដោយចិត្តស្មោះ
ឥតមានលាក់លៀមទុកកៀនកោះ បញ្ចេញដោយស្មោះអស់ពីចិត្ត ។
២- ខ្ញុំសូមសរសើរលើកតម្កើង ព្រះម្ចាស់ខ្ពស់ឡើងមួយជីវិត
ខ្ញុំស្មូត្រចម្រៀងមានបែបបទ ឲ្យបានចាំស្ទាត់ពេលនៅរស់ ។
៣- កុំទុកចិត្តពួកមនុស្សលោក មានច្រើនគរគោកចិត្តមិនស្មោះ
កុំទុកចិត្តមេដឹកនាំនោះ ពុំអាចសង្គ្រោះបានឡើយណា ។
៤- ពេលដែលដង្ហើមគេត្រូវផុត ជីវិតរលត់អស់សង្ខារ
ក្លាយជាធូលីដីអសារ ទាំងគម្រោងការរលាយព្រម ។
៥- អ្នកដែលព្រះលោកយ៉ាកុបជួយ សង្គ្រោះផុតព្រួយហើយសង្ឃឹម
ទុកចិត្តលើព្រះគ្មានអ្វីផ្ទឹម រស់ដោយញញឹមគ្មានភិតភ័យ ។
៦- ព្រះអង្គបង្កើតទាំងផ្ទៃមេឃ ផែនដីល្អឯកធំពេកក្រៃ
សមុទ្រព្រមទាំងអស់អ្វីៗ សន្យាថ្លាថ្លៃទ្រង់មិនភ្លេច ។

៧- ព្រះអង្គរកយុត្តិធម៌ឲ្យ ដល់អ្នកទន់ខ្សោយមិនកែគេច
បែកអាហារដល់អ្នកឃ្លានស្រេច ហើយទ្រង់សម្រេចលែងអ្នកទោស ។
៨- ព្រះអម្ចាស់ប្រោសមនុស្សខ្វាក់ ហើយលើកអស់អ្នកដែលនៅរស់
អស់ក្ដីសង្ឃឹមគ្មានអ្វីសោះ ស្រឡាញ់អ្នកស្មោះត្រង់ល្អជា ។
៩- ព្រះម្ចាស់គាំទ្រជនបរទេស មេម៉ាយនិងអស់ក្មេងកំព្រា
តែទ្រង់ធ្វើឲ្យកម្រោងការ ជនខូចពាលាវិនាសបង់ ។
១០- ព្រះអម្ចាស់ទ្រង់នឹងគ្រងរាជ្យ អស់កល្បជានិច្ចតយូរលង់
ឱ! ក្រុងស៊ីយ៉ូនដ៏រឿងរុង ព្រះអ្នកនឹងគ្រងរាជ្យតទៅ ។

## ទំនុកតម្កើងលេខ ១៤៧ (១៤៦) បទព្រហ្មគីតិ

១- យើងស្មូត្របទថ្វាយព្រះ ជាអម្ចាស់របស់យើង
សរសើរលើកតម្កើង ដ៏រុងរឿងល្អប្រពៃ ។
២- ព្រះម្ចាស់បានសង់ក្រុង ល្អឧត្ដុង្គឧត្ដមក្រៃ
យេរូសាឡឹមថ្មី អ្នកខ្ចាត់ខ្ចាយនាំមកវិញ ។
៣- អ្នកដែលមានវិបត្តិ គ្រាំគ្រាចិត្តគិតមិនចេញ
ទ្រង់ប្រោសជុតទោម្នេញ របួសវិញជាសះស្បើយ ។
៤- ព្រះអង្គអាចរាប់បាន ផ្កាយឥតមានខ្វះមួយឡើយ
ដាក់ឈ្មោះឲ្យរួចហើយ មិនភ្លេចឡើយស្គាល់ទាំងអស់ ។
៥- ព្រះម្ចាស់របស់យើង សែនថ្កុំថ្កើងឧត្ដមខ្ពស់
បេស្ដាខ្លាំងមុតមោះ ព្រះតម្រិះធំធេងក្រៃ ។
៦- ព្រះអម្ចាស់គាំទ្រ ជនក្រីក្រខ្សត់រីងរៃ
ទ្រង់បន្ទាបដល់ដី ជនអប្រិយ៍ធ្វើអាក្រក់ ។
៧- ចូរនាំគ្នាច្រៀងអរ ថ្លែងអំណរគុណព្រះម្ចាស់
ចូរដេញពិណថ្វាយព្រះ ជាអម្ចាស់នៃយើងផង ។
៨- ទ្រង់ឲ្យពពកបិទ គ្របជុំជិតអស់តែម្ដង
បាំងទាំងផ្ទៃមេឃផង អាប់មួរហ្មងគ្មានរស្មី ។

ព្រះអង្គបានឲ្យភ្លៀង ធ្លាក់ទាត់ទៀងលើផែនដី
ស្មៅលាស់ស្រស់ខៀវខ្ចី ពាសពេញដីនៅលើភ្នំ ។
៩- ទ្រង់ផ្តល់ទាំងអាហារ អស់សព្វសាសត្វតូចធំ
កូនក្អែកដែលស្រែកយំ ទ្រង់ថ្នាក់ថ្នមផ្តល់ចំណី ។
១០- ព្រះអង្គមិនដែលគាប់ ព្រះទ័យជាប់នឹងសេះថ្មី
ទ្រង់មិនពេញព្រះទ័យ មនុស្សពេញដីដែលខ្លាំងក្លា ។
១១- តែព្រះអង្គទ្រង់គាប់ ព្រះទ័យជាប់នឹងមនុស្សណា
កោតខ្លាចព្រះបេស្កា ផ្ញើជីវ៉ាលើព្រះអង្គ ។
១២- ក្រុងយេរូសាឡឹម កុំស្ងាត់ស្ងៀមនៅវេរវង់
ព្រមទាំងក្រុងស៊ីយ៉ូន ចូរត្រៀមខ្លួនថ្កើងព្រះម្ចាស់ ។
១៣- ដ្បិតព្រះអង្គការពារ អ្នករាល់គ្នាបានសុខណាស់
ទ្រង់ឲ្យពរដល់រាស្ត្រ ដែលរស់ពាសពេញទីក្រុង ។
១៤- ទ្រង់ប្រទានទឹកដី មានសេរីសុខត្រចង់
សន្តិភាពគ្រប់ជ្រុង ស្រូវបំរុងច្រើនមហិមា ។
១៥- នៅលើផ្ទៃផែនដី ស្រស់ប្រិមប្រិយ៍ទ្រង់បញ្ជា
ផ្សព្វផ្សាយគ្រប់ទិសា ពីបញ្ជាព្រះអម្ចាស់ ។
១៦- ព្រះអង្គឲ្យទឹកកក ធ្លាក់ចុះមកច្រើនដេរដាស
សន្សើមត្រជាក់ណាស់ ក៏ធ្លាក់ចុះតាមបញ្ជា ។
១៧- ព្រះអង្គធ្វើឲ្យព្រិល ធ្លាក់មិនខ្ជិលច្រើនមហិមា
ឲ្យមានធាតុរងា តើនរណាអាចទ្រាំបាន ? ។
១៨- ពេលទ្រង់មានបន្ទូល ធ្វើឲ្យព្រិលទាំងប៉ុន្មាន
ទឹកកកគ្រប់ទីស្ថាន រលាយបានជាទឹកអស់ ។
ធ្វើឲ្យមានទាំងខ្យល់ បោកវិលវល់មិនឈប់សោះ
បក់យកទឹកទាំងនោះ ហូរតាមជ្រោះទៅមិនសល់ ។
១៩- ទ្រង់សម្តែងឲ្យពូជ លោកយ៉ាកុបស្តាប់បន្ទូល
ក្រឹត្យវិន័យនិមល ឲ្យអ៊ីស្រាអែលបានដឹង ។

២០- ព្រះអង្គពុំបញ្ជា សព្វកិច្ចការអស់ទាំងហ្នឹង
ឲ្យជាតិសាសន៍ផ្សេងដឹង វិន័យទ្រង់នោះសោះឡើយ ។

## ទំនុកតម្កើងលេខ ១៤៨ បទពាក្យ ៧

១- ចូរលើកតម្កើងព្រះអម្ចាស់ ទ្រង់គឺជាព្រះដ៏វិសុទ្ធ
អ្នកដែលនៅស្ថានខ្ពស់បំផុត បញ្ចេញពាក្យពិតថ្កើងព្រះអង្គ ។
២- ឱ! ពួកទេវទូតទាំងអស់អើយ ចូរសរសើរហើយតម្កើងផង
ទាំងពួកទេវតាកុំវេរង់ សរសើរព្រះអង្គព្រះនៃអ្នក ។
៣- ឯព្រះអាទិត្យនិងព្រះច័ន្ទ កុំនៅអែរអន់ឬស្ទើរស្ទាក់
តម្កើងព្រះអង្គជាព្រះអ្នក ដាក់ខ្ពស់ដល់ថ្នាក់សួគ៌វិមាន ។
អស់ផ្កាយទាំងឡាយដែលផ្លេកភ្លឺ រស្មីរន្ទឺគ្រប់ទីស្ថាន
ចូរកោតសរសើរព្រះថ្កើងថ្កាន គោរពឲ្យបានដោយផ្ចិតផ្ចង់ ។
៤- ឱ! មេឃដែលនៅខ្ពស់បំផុត សរសើរក្រាបលុតថ្កើងព្រះអង្គ
ទាំងទឹកដែលនៅលើមេឃផង សូមជួយថ្កើងអង្គព្រះជាម្ចាស់ ។
៥- ចូរឲ្យអ្វីៗសព្វសារពើ តម្កើងសរសើរព្រះខ្ពង់ខ្ពស់
ពេលព្រះអង្គមានបន្ទូលនោះ អ្វីៗទាំងអស់កើតព្រោងព្រាត ។
៦- ព្រះអង្គបានតាំងសព្វអ្វីៗ ស្ថិតស្ថេរប្រពៃឥតបីឃ្លាត
ព្រះអង្គដាក់ច្បាប់មួយថែមទៀត មិនឲ្យវវាតប្រែប្រួលថ្មី ។
៧- ចូរលើកតម្កើងសរសើរព្រះ ទ្រង់ជាអម្ចាស់លើផែនដី
សមុទ្រនិងសត្វទាំងអស់ក្តី តម្កើងម្ចាស់ថ្ងៃកុំរួញរា ។
៨- ចូរព្រឹលផ្សេងអ័ព្ទនិងទឹកកក ដែលធ្លាប់ធ្លាក់មកច្រើនមហិមា
ភ្លើងដែលធ្លាប់ឆេះព្យុះព្យោមា ធ្វើតាមបញ្ជានៃព្រះអង្គ ។
៩- ភ្នំតូចភ្នំធំជិតឆ្ងាយ ដើមឈើទាំងឡាយកុំវេរង់
និងដើមគគីរទាំងឡាយផង កុំបីសៅហ្មងជួយតម្កើង ។
១០- សត្វព្រៃសត្វស្រុកទាំងម្រឹគា ទាំងសត្វលូនវារសត្វដើរជើង
បក្សាបក្សាចូរក្រោកឡើង សរសើរតម្កើងព្រះខ្ពង់ខ្ពស់ ។

១១- អស់ស្តេចទាំងឡាយលើផែនដី ប្រជាប្រុសស្រីគ្រប់ទាំងអស់
ទាំងអ្នកដឹកនាំថ្នាក់ទាបខ្ពស់ នាំគ្នាទាំងអស់ថ្កើងម្ចាស់ថ្លៃ ។
១២- យុវជននារីចាស់ជរា កូនក្មេងនាំគ្នាលើកសិរី
ព្រះម្ចាស់ខ្ពង់ខ្ពស់លើលោកីយ៍ មិនអាចរកអ្វីប្រៀបស្មើបាន ។
១៣- ចូរកោតសរសើរនាមព្រះម្ចាស់ ជាព្រះខ្ពង់ខ្ពស់លើសអស់ស្ថាន
ព្រះនាមព្រះអង្គល្អថ្កើងថ្កាន ពាសពេញទីស្ថានមេឃនិងដី ។
១៤- ព្រះអង្គបានប្រោសអស់ប្រជា រាស្ត្រទាំងអស់គ្នាមានសេរី
កម្លាំងមាំមួនខ្លាំងពេកក្រៃ មិនឲ្យមានអ្វីមមករំខាន ។
អស់អ្នកដែលជឿងលើព្រះអង្គ គឺជារាស្ត្រទ្រង់ដ៏ចំណាន
អ៊ីស្រាអែលអើយអ្នកនឹងបាន ខ្ពស់មុខសុខសាន្តទៅអើយ ។

## ទំនុកតម្កើងលេខ ១៤៩ — បទកាកគតិ

១- ចូរច្រៀងបទថ្មី ថ្វាយព្រះម្ចាស់ថ្លៃ ប្រសើរកន្លង ចូរច្រៀងតម្កើង
ព្រះនាមព្រះអង្គ ក្នុងចំណោមជង អ្នកដែលជឿព្រះ ។
២- ចូរឲ្យជនជាតិ ស្រាអែលខ្មីឃ្មាត រីករាយទាំងអស់ ដោយសារព្រះអង្គ
បានបង្កើតមនុស្ស ទាំងស្រីទាំងប្រុស ពាសពេញផែនដី ។
សូមប្រជាជន ក្នុងក្រុងស៊ីយ៉ូន អបអរប្រពៃ នឹងព្រះមហាក្សត្រ
គ្រងលើផែនដី ជាស្តេចល្បាញល្បី របស់ជងខ្លួន ។
៣- សូមនាំគ្នារាំ ថ្វាយព្រះឧត្តម កុំវេះគេចពួន តម្កើងព្រះនាម
ឲ្យបានសមសួន វាយក្រាប់ជូនៗ ទាំងដេញពិណថ្វាយ ។
៤- ដ្បិតព្រះអម្ចាស់ សព្វព្រះទ័យណាស់ នឹងរាស្ត្រទាំងឡាយ ទ្រង់តែងសង្គ្រោះ
ដឹកនាំត្រួសត្រាយ ហើយតែងខ្វល់ខ្វាយ ជួយអ្នកទន់ទាប ។
៥- សូមឲ្យអស់អ្នក សង្ឃឹមជឿជាក់ លើព្រះដរាប នាំគ្នាសប្បាយ
ប្រសើរលើសលប់ តម្កើងសាយសព្វ សិរីព្រះម្ចាស់ ។
ទោះជាពេលយប់ ក៏គេមិនឈប់ គេនៅប្រកាស ទាំងលើកតម្កើង
សិរីព្រះម្ចាស់ ឲ្យបានខ្ពង់ខ្ពស់ ទាំងអំណរជង ។

៦- សូមទាំងអស់គ្នា សរសើរគ្រប់គ្រា កុំបីរំលង មាត់ពោលពាក្យល្អ
ដៃកាន់ដាវផង ទុក្ខសោកមួរហ្មង វិនាសខ្ចាត់ខ្ចាយ ។
៧- ឯការសងសឹក ជាតិច្រើនសន្ធឹក ឲ្យគេអន្តរាយ និងការដាក់ទោស
ជនជាតិទាំងឡាយ វិនាសខ្ចាត់ខ្ចាយ រលាយបែកបាក់ ។
៨- គេយកមកផង ដើម្បីនឹងចង ស្តេចនឹងច្រវាក់ ហើយយកទាំងឃ្នាង
ទាំងខ្នោះអន្ទាក់ ដាក់ពួកអស់អ្នក ដឹកនាំពួកគេ ។
៩- ឯការដាក់ទោស ជាតិសាសន៍ទាំងនោះ ត្រឹមត្រូវឥតប្រែ តាមការសម្រេច
ព្រះមិនខុសទេ ពួកវាត្រូវតែ ទទួលទោសនោះ ។
កិច្ចការទាំងអស់ សក្តិសមឥតខ្ចោះ គឺជាកិត្តិយស ដ៏សែនរុងរឿង
ដល់អ្នកទាំងអស់ ដែលជឿលើព្រះ មិនសាបសូន្យឡើយ ។

## ទំនុកតម្កើងលេខ ១៥០ បទព្រហ្មគីតិ

១- ចូរកោតសរសើរព្រះ ជាអម្ចាស់ក្នុងវិហារ
ជាទីដ៏សក្ការ សែនអស្ចារ្យឥតមានហ្មង ។
ក្នុងលំហអាកាស វិសេសណាស់មាំមួនផង
ដំណាក់ល្អកន្លង នៃព្រះអង្គក្នុងអាកាស ។
២- ចូរសរសើរគ្រប់គ្នា អ្វីដែលជាស្នាព្រះហស្ត
តម្កើងព្រះអម្ចាស់ ដ៏ខ្ពង់ខ្ពស់គ្មានអ្វីស្មើ ។
៣- ចូរប្រគុំភ្លេងភ្លាត់ ច្រៀងសព្វបទកុំស្ទាក់ស្ទើរ
ចាប៉ីដេញបណ្តើរ ពិណសរសើរកំដរផង ។
៤- វាយក្រាប់រាំចាក់ក្បាច់ ល្អបណ្តាច់ថ្វាយព្រះអង្គ
វាយឃឹមផ្លុំខ្លុយផង លើកតម្កើងព្រះជាម្ចាស់ ។
៥- វាយស្គរឲ្យពិរោះ តម្កើងព្រះដោយស្ម័គ្រស្មោះ
វាយស្គរលាន់ទាំងអស់ សរសើរព្រះជាម្ចាស់យើង ។
៦- សូមឲ្យអ្វីទាំងអស់ ដែលនៅរស់មានដង្ហើម
ចូរសរសើរតម្កើង ព្រះម្ចាស់យើងរហូតទៅ ។

# បងប្អូន និងមិត្តអ្នកអានជាទីមេត្រី

ពាក្យកាព្យក្នុងទំនុកតម្កើងដែលបោះពុម្ពលើកទី ២ នេះ
ទំនុកតម្កើងខ្លះ យើងខ្ញុំបានកែសម្រួលពាក្យពេចន៍មួយចំនួន
ដើម្បីឲ្យឃ្លោងឃ្លា ចាប់ចុងចួនណែងណងគ្នាពិរោះ និងស្រួលសូត្រ ។
តែបទខ្លះទៀត យើងខ្ញុំទុកនៅដដែល ដោយសារតែពិបាករកពាក្យ
ដែលមានចុងចួន ឲ្យត្រូវនឹងអត្ថន័យដើមនៃអត្ថបទទំនុកតម្កើង
ដែលសរសេរជាពាក្យសម្រាយ ។
អាស្រ័យហេតុនេះ សូមបងប្អូនមេត្តាអភ័យទោសនូវរាល់កំហុសឆ្គង
ដែលកើតមានឡើងដោយអចេតនា និងសូមមេត្តាជួយរិះគិតរកពាក្យពេចន៍
បន្ថែម ឬបន្ថយឲ្យបានល្អតាមការគួរផងចុះ ។
បើបងប្អូនមានមតិម្ដេចម្ដា សូមមេត្តាផ្ញើមកយើងខ្ញុំនៅ
មណ្ឌលវប្បធម៌
កាតូលិកកម្ពុជា ។

សូមអរគុណ ។

# បទកោតសរសើរ

# ក្រៅពី

# ទំនុកតម្កើង

## ព្រះចេស្ដារបស់ព្រះជាម្ចាស់ បទព្រហ្មគីតិ

**( ដំណើរឆ្ពោះទៅកាន់សេរីភាព ១៥,១-៤-៧-១៣-១៧-១៨ )**

១- ខ្ញុំស្រែកច្រៀងថ្វាយព្រះ ជាអម្ចាស់ដែលមានជ័យ
លើទ័ពសេះល្បាញល្បី លិចលង់ក្ស័យក្នុងសមុទ្រ ។
២- ព្រះម្ចាស់ជាកម្លាំង ខ្ញុំឈ្នះខ្លាំងមិនភ័យស្លុត
ខ្ញុំសូមឲ្យក្រាបលុត ទាំងច្រៀងបទថ្កើងព្រះអង្គ ។
ព្រោះទ្រង់បានសង្គ្រោះ ខ្ញុំឲ្យរស់ផុតសៅហ្មង
ព្រះឪពុកខ្ញុំផង ព្រះខ្ពស់ខ្ពង់លើសអ្វីៗ ។
៣- ទ្រង់ជាវីរបុរស ប្រសើរខ្ពស់លើផែនដី
អង់អាចពូកែក្រៃ ព្រះនាមថ្លៃ "ព្រះអម្ចាស់ ។
៤- ព្រះអង្គបានធ្វើឲ្យ កងទ័ពជយវិនាសអស់
ទាំងទ័ពទាំងរទេះ ត្រូវវិនាសក្នុងសមុទ្រ ។
ទាហានអេស៊ីបខ្លាំង ពូកែច្បាំងចៀសមិនផុត
ជីវិតត្រូវរលត់ ក្នុងសមុទ្រជ្រៅក្រៃលែង ។
៧- ព្រះអង្គមានចេស្ដា ខ្លាំងអស្ចារ្យគួរស្ញប់ស្ញែង
រុងរឿងខ្លាំងក្រៃលែង អ្នកប្រឆាំងទ្រង់ដួលអស់ ។
ពេលព្រះអង្គពិរោធ ព្រះអង្គក្រោធដូចភ្លើងឆេះ
ពួកគេត្រូវរលេះ ដូចភ្លើងឆេះស្មៅចំបើង ។
៨- ពេលខ្យល់បក់បោកមក ទឹករលកជុំគ្នាឡើង
ទំនប់ទឹករលើង មកនៅគឿងសមុទ្រជាន់ ។
៩- ខ្មាំងសត្រូវពោលថា ខ្ញុំដេញគេតាមឲ្យទាន់
ខ្ញុំទទួលជយភណ្ឌ ច្រើនគ្រប់គ្រាន់ទើបបាត់ការ ។
១០- ព្រះអង្គទ្រង់ផ្លុំខ្យល់ ទឹកវិលវល់គ្រប់កាយា
ពួកគេលិចមរណា ក្នុងជលសាដូចសំណ ។
១១- បពិត្រព្រះអម្ចាស់ ប្រសើរណាស់ពេញបវរ
តើមានព្រះណាល្អ យុត្តិធម៌ដូចព្រះអង្គ ? ។

ទ្រង់វិសុទ្ធរឿងរុង អស្ចារ្យខ្លាំងពេកកន្លង
គួរស្ញែងខ្លាចព្រឺផង ហើយមានទាំងឫទ្ធិខ្ពស់ ។
១២- ព្រះអង្គក្តៅព្រះទ័យ គ្មានប្រណីគិតស្រណោះ
ពេលទ្រង់លើកព្រះហស្ត ផែនដីប្រេះស្រូបគេឈឹង ។
១៣- ព្រះអង្គបានលោះលា រាស្ត្រគ្រប់គ្នាមានរំពឹង
ដឹកនាំគេតម្រង់ ដំណាក់ទ្រង់ដ៏ឧត្តម ។
១៧- ព្រះអង្គនាំប្រជា រាស្ត្រគ្រប់គ្នាទៅលើភ្នំ
ជាចំណែកដ៏ធំ កន្លែងសំណាក់ព្រះអង្គ ។
ឱ! ព្រះអម្ចាស់អើយ ព្រះអង្គហើយដែលបានសង់
ទីសក្ការៈត្រចង់ ដោយហស្តទ្រង់កសាងផ្ទាល់ ។
១៨- ព្រះម្ចាស់នឹងគ្រងរាជ្យ ពេញអំណាចអស់កប្បកល្ប
ជានិច្ចគ្មានពិភាល់ ជារៀងរាល់អង្វែងទៅ ។

***ទំនុកតម្កើងរបស់លោកម៉ូសេ*** **បទពាក្យ ៧**

**( ទុតិយកថា ៣២-១-១២)**

១- ឱ! ផ្ទៃមេឃអើយចូរត្រងត្រាប់ ពាក្យខ្ញុំថ្លែងប្រាប់ជាដំណឹង
ផែនដីអើយចូរអ្នកខំប្រឹង ស្តាប់ឲ្យបានដឹងខ្ញុំបរិយាយ ។
២- សូមឲ្យពាក្យខ្ញុំទាំងប៉ុន្មាន ដែលបានទូន្មានរៀងរាល់ថ្ងៃ
ឲ្យដូចសន្សើមភ្លៀងធ្លាក់ថ្មី រុក្ខជាតិខៀវខ្ចីស្រស់បំព្រង ។
៣- ខ្ញុំនឹងប្រកាសពីព្រះនាម មិនព្រមនៅស្ងៀមមិនភ្លេចម្តង
លើកតម្កើងភាពខ្ពស់កន្លង រុងរឿងគ្មានហ្មងព្រះនៃយើង ។
៤- ព្រះអម្ចាស់ប្រៀបដូចថ្មជា ជាផ្ទាំងសិលាដ៏សែនរឹង
មាគ៌ាព្រះអង្គសុចរិតត្រង់ បរិសុទ្ធឥតហ្មងឥតមានខ្ចោះ ។
៥- ប៉ុន្តែព្រះអង្គទ្រង់ជ្រាបថា អ្នកទាំងអស់គ្នាក្បត់ទាំងអស់
ដោយអ្នកមានចិត្តមិនត្រង់ស្មោះ ព្រះអង្គជាត់អស់មិនទុកនៅ ។
លែងរាប់លែងរកលែងទុកថា ជាបុត្រាធីតាជាកូនចៅ
អ្នករាល់គ្នាមានចិត្តអាស្រូវ វៀចវេរមិនត្រូវក្បត់ព្រះអង្គ ។

៦- ឱ! ជនលេលាឥតប្រាជ្ញអើយ ចុះហេតុម្តេចឡើយមិនលះបង់
ព្រះគុណព្រះមានច្រើនកន្លង តោងគិតផ្ចង់ផ្គងគិតនឹកនា ។
ទ្រង់ជាបិតាដែលបង្កើត ឲ្យមានកំណើតកើតជន្មា
ឲ្យអ្នកបានក្លាយជាប្រជា ជាតិមាំអស្ចារ្យខ្លាំងទៀតផង ។
៧- ចូរអ្នករាល់គ្នានឹកនាចាំ គិតអំពីឆ្នាំដែលកន្លង
ឪពុកជូនតាកុំមានហ្មង រ៉ាយរ៉ាប់ប្រាប់ផងហេតុការណ៍គ្រប់ ។
៨- ពេលព្រះខ្ពង់ខ្ពស់ប្រទានដី ជាកេរថ្លាថ្លៃទ្រព្យសំណព្វ
ពេលទ្រង់បំបែកមនុស្សលោកសព្វ ថែមទាំងកំណត់ព្រំដែនឲ្យ ។
ព្រះអង្គប្រទានតាមចំនួន ឲ្យបានសមសួនមិនបណ្តោយ
គ្នាតិចបានតិចមិនឲ្យជ្លោយ គ្នាច្រើនទ្រង់ឲ្យធំល្វើយល្វឹង ។
៩- ព្រះម្ចាស់ជ្រើសយកអ៊ីស្រាអែល ទុកជារាស្ត្រផ្ទាល់នៃព្រះអង្គ
ទាំងពូជយ៉ាកុបថែមទៀតផង ទុកជាកេរទ្រង់ដ៏ថ្កើងថ្កាន ។
១០- ព្រះម្ចាស់រកឃើញអ៊ីស្រាអែល នៅតាមទីវាលរហោស្ថាន
ក្នុងដីហួតហែងព្រៃស្មសាន សុទ្ធតែតិរច្ឆានស្នាក់នៅជុំ ។
តែព្រះអង្គបានបីបាច់ថែ ថ្នាក់ថ្នមរូបគេហើយអប់រំ
ការពារក្រសោបឱបនៅជុំ គេរស់សុខដុមផុតវេទនា ។
១១- ព្រះអង្គការពារនិងណែនាំ ឲ្យដើរត្រង់ចំផ្លូវសាស្តា
ដូចសត្វឥន្ទ្រីយ៍ជាបក្សា ត្រដាងស្លាបវាបាំងកូនបាន ។
១២- មានតែព្រះម្ចាស់មួយព្រះអង្គ ដឹកនាំរាស្ត្រទ្រង់យ៉ាងចំណាន
ឲ្យគេរស់នៅយ៉ាងសុខសាន្ត ព្រះជ្សេងមិនបានដូចទ្រង់ឡើយ ។

***ទំនុកតម្កើងរបស់នាហាណ្ណា*** **បទភាគគតិ**

**(លោកសាមូអែលភាគមួយ ២-១-១០ )**

១- ព្រះម្ចាស់ប្រទាន ចិត្តខ្ញុំឲ្យមាន អំណរសប្បាយ ព្រោះព្រះអង្គលើក
ខ្ញុំខ្ពស់ពេកក្រៃ ខ្ញុំអាចនិយាយ តទល់ពួកខ្មាំង ។
២- គ្មាននរណាម្នាក់ វិសុទ្ធជាជាក់ ដូចជាព្រះអង្គ ឥតមាននរណា
ប្រសើរដូចទ្រង់ ជាថ្មជួយបាំង ដូចព្រះយើងទេ ។

៣- កុំអួតបំប៉ោង ពោលពាក្យកាចកោង ព្រហើនដៀលដេរ ដ្បិតព្រះជាម្ចាស់
ថ្លឹងថ្លែងរិះរេ វិនិច្ឆ័យឥតប្រែ តាមអំពើមនុស្ស ។
៤- អ្នកខ្លាំងពូកែ ព្រះអង្គបំបែរ បំបាក់ទាំងអស់ បំផ្លាញទាំងធ្នូ
តែទ្រង់សន្តោស ប្រទានដល់មនុស្ស កម្លាំងទន់ខ្សោយ ។
៥- ពួកអ្នកដែលមាន អាហារគ្រប់គ្រាន់ ឥឡូវគេឈ្លោយ ធ្លាក់ខ្លួនវេទនា
ខ្វះខាតមុខក្រោយ គ្មានអ្វីនឹងឲ្យ ចម្អែតក្រពះ ។
ឯអ្នកធ្លាប់ឃ្លាន បែរទៅជាមាន អាហារមិនខ្វះ គេបរិភោគឆ្អែត
បរិបូណ៌ពេញពាស មានច្រើនដេរដាស លែងមុខស្រពោន ។
មិនតែប៉ុណ្ណោះ ព្រះអង្គសន្តោស ស្រីអារគ្មានកូន មិនឲ្យដាច់ពូជ
វិនាសសាបសូន្យ អាចសម្រាលកូន បានប្រាំពីរដង ។
៦- ជីវិតមនុស្ស ត្រូវស្លាប់ឬរស់ ស្រេចលើព្រះអង្គ គេត្រូវធ្លាក់ទៅ
ស្ថានអ្នកស្លាប់ផង ឬក៏បានឡើង លើទ្រង់បាត់បែង ។
៧- មនុស្សមានក្រ អាក្រក់ឬល្អ មិនមែនខ្លួនឯង ព្រះម្ចាស់បន្ទាប
ឬក៏លើកឡើង ព្រះអង្គបាត់បែង តាមព្រះហឫទ័យ ។
៨- ទ្រង់លក់មនុស្ស ទុរគតស្រីប្រុស ពីធូលីដី ដកអ្នកកម្សត់
វេទនាក្រក្រី នោះគឺដើម្បី ឲ្យស្មើអ្នកធំ ។
ឲ្យបានគ្រងរាជ្យ ពេញដោយអំណាច រុងរឿងឧត្តម ដ្បិតព្រះអម្ចាស់
តាំងគ្រឹះរឹងមាំ ផែនដីដ៏ធំ មិនរលំឡើយ ។
៩- ព្រះអង្គមើលថៃ ជីវិតពួកគេ ផុតទុក្ខល្ហែល្ហើយ គឺអ្នកស្មោះត្រង់
ព្រះអង្គនោះហើយ ទ្រង់មិនកន្តើយ ថ្នាក់ថ្នមបមបី ។
ឯជនអាក្រក់ ចិត្តខ្មៅកខ្វក់ ទុយ៌សអប្រិយ៍ គេនឹងវិនាស
ក្នុងពេលដ៏ខ្លី ដ្បិតគេគ្មានជ័យ ដោយកម្លាំងទេ ។
១០- ព្រះអង្គបញ្ចេញ រន្ទះដេញបាញ់ ទៅលើពួកគេ ព្រះម្ចាស់វិនិច្ឆ័យ
ទៅផែនដីដែរ ទ្រង់គ្រប់គ្រងថៃ មិនប្រែទាល់សោះ ។
ព្រះអង្គប្រទាន អានុភាពឲ្យមាន ដល់ក្សត្រអង្គនោះ ប្រទានអំណាច
បេស្កាទាំងអស់ ដែលទ្រង់ថ្កើងយស ចាក់ប្រេងអភិសេក ។

## *យើងនាំគ្នាដើរក្រោមពន្លឺរបស់ព្រះជាម្ចាស់* **បទព្រហ្មគីតិ**

## (ព្យាការីអេសាយ ២,២-៥)

២- ថ្ងៃក្រោយព្រះអម្ចាស់ នឹងប្រែផ្លាស់ព្រះដំណាក់
លើកភ្នំធ្លាប់គង់ស្នាក់ ហើយទ្រង់ដាក់លើភ្នំថ្មី ។
ដើម្បីឲ្យភ្នំនោះ បានខ្ពង់ខ្ពស់លើសគេក្រៃ
ប្រជាជាតិទាំងឡាយ អរសប្បាយឡើងហូរហែ ។
៣- មានទាំងប្រជាជន ច្រើនពេកពន់ទៅផងដែរ
ពោលថាយើងដង្ហែ ឡើងទៅក្បែរភ្នំព្រះម្ចាស់ ។
យើងនាំគ្នាឡើងទៅ ដើរតាមផ្លូវមាគ៌ាព្រះ
ប្រញាប់ឆាប់រូតរះ ដំណាក់ព្រះលោកយ៉ាកុប ។
ព្រះអង្គនឹងប្រដៅ យើងស្គាល់ផ្លូវមាគ៌ាគ្រប់
ឲ្យស្គាល់ឲ្យសេពគប់ ឲ្យដើរសព្វតាមគន្លង ។
ដ្បិតការប្រៀនប្រដៅ អ្នកល្ងង់ខ្លៅគ្រាកន្លង
ចេញពីស៊ីយ៉ូនផង ល្អហ្មត់ហ្មងឥតមានទាស់ ។
ព្រះបន្ទូលប៉ុន្មាន ល្អថ្កើងថ្កានឥតមានខ្ចោះ
ចេញមកពីព្រះឱស្ឋ ដីស្ទ័គ្រស្មោះក្រុងសាឡឹម ។
៤- ព្រះអង្គជាចៅក្រម ដ៏ឧត្តមមិននៅស្ងៀម
សម្រុះសម្រួលភ្លាម ផ្អាកសង្គ្រាមកាប់ប្រល័យ ។
ឲ្យឈប់ទាស់ទែងគ្នា ចេះគំពារត្រាប្រណី
យកដាវធ្លាប់ប្រល័យ មករំលាយជាលនង្គ័ល ។
គ្រប់សាសន៍ឈប់តតាំង ឈប់ហាត់ច្បាំងនៅហ្នឹងថ្កល់
លែងចង់ឈ្នះចង់ជល់ លំពែងពលធ្វើកណ្តៀវ ។
៥- ឱ! បងប្អូនកូនចៅ ញាតិពង្សជៅរស់រញៀវ
លោកយ៉ាកុបស្រស់ស្រាវ ជ្រករញៀវក្រោមម្លប់ព្រះ ។

## *សូមអរព្រះគុណព្រះជាអម្ចាស់ដែលបានសង្គ្រោះប្រជាជនអ៊ីស្រាអែល* **បទពាក្យ ៧**

**(ព្យាការីអេសាយ ១២,១-៦ )**

១- ឱ! ព្រះម្ចាស់អើយទូលបង្គំ លើកហត្ថប្រណម្យសូមតម្កើង
គ្រាមុនព្រះអង្គពិរោធយើង ឥឡូវព្រះអង្គសម្រាលទុក្ខ ។
២- ព្រះអម្ចាស់ជាព្រះសង្គ្រោះ ជីវិតខ្ញុំរស់ស្គាល់តែសុខ
លែងភ័យលែងខ្លាចលែងកើតទុក្ខ ពីនេះទៅមុខពឹងលើព្រះ ។
ដ្បិតព្រះអម្ចាស់ជាកម្លាំង ខ្ញុំអាចតតាំងអាចយកឈ្នះ
ខ្ញុំនឹងច្រៀងថ្វាយព្រះអម្ចាស់ ព្រោះទ្រង់សង្គ្រោះដល់រូបខ្ញុំ ។
៣- ព្រះម្ចាស់សង្គ្រោះអ្នករាល់គ្នា ផុតទុក្ខគ្រប់គ្រារស់សុខដុម
ចូរទៅដងទឹកត្រជាក់ជុំ ចេញពីជើងភ្នំសង្គ្រោះផង ។
៤- ចូរអរព្រះគុណព្រះអម្ចាស់ ហើយចូរប្រកាសនាមព្រះអង្គ
ថ្លែងស្នាព្រះហស្តអស្ចារ្យទ្រង់ ប្រាប់ប្រជាជនផងទាំងឡាយ ។
៥- ចូរស្មូត្រទំនុកតម្កើងថ្វាយ ព្រះអម្ចាស់ថ្លៃគ្រប់ៗកាយ
ដ្បិតការអស្ចារ្យច្រើនពេកក្រៃ ឲ្យមនុស្សលើដីបានដឹងផង ។
៦- អុះឱ! អ្នកក្រុងស៊ីយ៉ូនអើយ ចូរកុំកន្តើយស្រែករំពង
ដោយអរសប្បាយដ្បិតព្រះអង្គ វិសុទ្ធឥតហ្មងព្រះនៃយើង ។

## *ព្រះជាម្ចាស់ផ្តល់សន្តិភាពឲ្យប្រជាជន* **បទកាកគតិ**

**(ព្យាការីអេសាយ ២៦,១-៤-៧-៩-១២)**

១- យើងមានក្រុងមួយ មាំឥតភ័យព្រួយ ព្រោះព្រះម្ចាស់បាន ប្រទាននូវការ
សង្គ្រោះគ្រប់ប្រាណ ដូចកំពែងបាន ការពាររ៉ាប់រង ។
២- ចូរយើងបើកទ្វារ កុំបីរួញរា កុំឲ្យមានហ្មង ឲ្យប្រជាជាតិ
សុចរិតទាំងពួង ស្ម័គ្រស្មោះកន្លង បានចូលមកជិត ។
៣- បពិត្រព្រះម្ចាស់ ព្រះអង្គទ្រង់ប្រោស ដល់ប្រជាជាតិ មានក្តីសុខសាន្ត
ឥតបីឃ្លាងឃ្លាត ទាំងជីវិតទៀត ផ្ញើព្រះឥតភ្លេច ។

៤- ចូរមានសង្ឃឹម ដោយក្ដីញញឹម លើព្រះជានិច្ច ទាំងកាយជីវិត
ឥតមានពេលភ្លេច ជាថ្មរំលេច ស្ថិតស្ថេរអស់កល្ប ។
៧- បពិត្រព្រះម្ចាស់ អស្ចារ្យពេកណាស់ ទ្រង់បង្ហាញដល់ មនុស្សសុចរិត
បានដឹងបានស្គាល់ មាគ៌ានិមល សែនល្អកន្លង ។
៨- ឱ! ព្រះអម្ចាស់ យើងខ្ញុំទាំងអស់ ជីវិតផ្ញើទ្រង់ ហើយសូមដើរតាម
មាគ៌ារឿងរុង ដែលព្រះអង្គទ្រង់ ត្រួសត្រាយទុកស្រាប់ ។
ចិត្តយើងគ្រប់គ្នា តែងតែប្រាថ្នា ថ្លែងមិនឈរឈប់ ព្រះនាមព្រះអង្គ
ដែលល្បីសាយសព្វ ពាសពេញលើភព ប្រសើរកន្លង ។
៩- ទោះជាពេលយប់ ចង់ជ្រកក្រោមម្លប់ បារមីនៃទ្រង់ ខ្ញុំខំស្វះស្វែង
រកតែព្រះអង្គ តាំងពីព្រឹកព្រាង ឥតមានសំចៃ ។
ព្រះអង្គដាក់ទោស ទៅដល់មនុស្ស នៅលើផែនដី ស្របទៅតាមការ
ដែលទ្រង់វិនិច្ឆ័យ នោះគេស្គាល់ក្ដី យុត្តិធម៌សុចរិត ។
១២- បពិត្រព្រះម្ចាស់ ប្រសើរពេកណាស់ ទ្រង់តែងអាណិត ផ្ដល់ក្ដីសុខសាន្ត
អ្វីខ្ញុំប្រព្រឹត្ត ដែលមានមកពិត គឺទ្រង់សម្រេច ។

## *ឱព្រះជាម្ចាស់អើយ! យើងខ្ញុំរង់ចាំតែព្រះអង្គមួយ* *បទកាកគតិ*

**( ព្យាការីអេសាយ ៣៣-១៣-១៦)**

១៣- ឱ! អ្នកដែលនៅ ស្រុកឆ្ងាយៗត្រូវ នាំគ្នាប្រុងស្ដាប់ អំពីកិច្ចការ
ដែលយើងធ្វើស្រាប់ ត្រូវខំត្រងត្រាប់ ស្ដាប់ទាំងអស់គ្នា ។
ឯអ្នកដែលនៅ ជិតៗនេះត្រូវ កុំនៅរួញរា ត្រូវទទួលស្គាល់
បារមីឫទ្ធា អានុភាពបេស្ដា យើងខ្លាំងក្លាក្រៃ ។
១៤- នៅក្រុងស៊ីយ៉ូន អ្នកបាបញ័រខ្លួន រន្ធត់ភិតភ័យ ពួកទមិឡតក់ស្លុត
ញ័រអស់ជើងដៃ គេពោលស្រដី ស្ដីតាមគំនិត ។
១៥- ថាមានតែអ្នក ដែលប្រព្រឹត្តដាក់ មាគ៌ាសុចរិត និងអ្នកនិយាយ
តែពាក្យដែលពិត ទើបអាចស្ថេរស្ថិត ក្បែកកិតនៅជាប់ ។
គឺអ្នកមិនធ្វើ ទៅតាមអំពើ ហឹង្សាមិនគាប់ មិនរកកំរៃ
ប្រវ័ញ្ចគេកិប មិនទទួលយក សំណូកទៀតផង ។

១៦- មនុស្សបែបនេះ នឹងបាននៅរស់ កន្លែងខ្ពស់ខ្ពង់ មានថ្មរឹងមាំ
ជ្រកកោនទៀតផង អាហារគ្រប់គ្រាន់ ទាំងទឹកមិនខ្វះ ។

**_ទំនុកតម្កើងរបស់ព្យាការីអេសេគីអែល_** **បទកាកគតិ**

**( ព្យាការីអេសាយ ៣៨,១០-១៥,១៧-២០ )**

១០- ខ្ញុំនឹកគិតថា នឹងមានវាសនា រស់ពាក់កណ្ដាល អាយុនៃមនុស្ស
មិនត្រេកត្រអាល នៅស្ថានកណ្ដាល ទៅទៀតបានឡើយ
១១- ខ្ញុំនឹកគិតថា លែងឃើញភក្ត្រា អម្ចាស់ទៀតហើយ លែងឃើញទាំងមុខ
លែងទាំងឆ្លងឆ្លើយ ឱមនុស្សម្នាអើយ ខ្ញុំលាក្សិណក្ស័យ ។
១២- ជីវិតខ្ញុំត្រូវ ឃ្លាតបាកឆ្ងាយទៅ ផុតអាយុខៃ ដូចជាគង្វាល
រើគ្មានសំបែ ជំរំអាស្រ័យ ស្នាក់នៅពេលមុន ។
ព្រះម្ចាស់ធ្វើឲ្យ ជីវិតខ្ញុំផុយ នាពេលសាយណ្ហ ដូចជាងតម្បាញ
ត្បាញចប់គ្រប់គ្រាន់រូតរះបន្ទាប់ មូរក្រណាត់ទុក ។
១៣- ខ្ញុំត្រូវវិនាស មុនពេលថ្ងៃរះ នៅមិនស្រណុក ឈឺពេញទាំងកាយ
រស់ដូចទូលទុក្ខ ដូចសិង្ហសម្រុក ចាប់ជាចំណី ។
ឱព្រះម្ចាស់អើយ ចាប់ពីថ្ងៃហើយ លុះដល់រាត្រី ព្រះអង្គធ្វើឲ្យ
ជីវិតខ្ញុំក្ស័យ ដេកនៅក្នុងដី ជារៀងដរាប ។
១៤- ខ្ញុំស្រែកខ្ញុំយំ ដូចត្រចៀកកាំ ខ្ញុំថ្ងូរដូចព្រាប ភ្នែកខ្ញុំស្រវាំង
មើលមិនឃើញទៀត សូមព្រះម្ចាស់ឆ្លៀតជួយជងព្រះអើយ ។
១៥- ឲ្យខ្ញុំនិយាយ អ្វីខ្លះទូលថ្វាយ ទើបព្រះអង្គឆ្លើយ គឺទ្រង់ធ្វើទុក្ខ
ពុំមានល្ហែល្ហើយ ប្រាសដេកលើខ្នើយ មិនលក់ព្រួយចិត្ត ។
១៧- ឥឡូវទ្រង់ប្រោស ឲ្យខ្ញុំជាសះ ព្រោះទ្រង់អាណិត ប្រទានឲ្យខ្ញុំ
រស់មានជីវិត ទុក្ខព្រួយខ្ញុំបាត់ សែនអរព្រើព្រួច ។
ទ្រង់សព្វព្រះទ័យ ករុណាប្រណី រំដោះខ្ញុំរួច ពីដៃមច្ចុរាជ
អំពើបាបខ្ចូច ខ្ញុំសែនអរព្រួច រួចផុតល្ហែល្ហើយ ។
១៨- អ្នកស្លាប់អស់ជន្ម មិនអាចអរគុណ ព្រះអង្គបានឡើយ រួមទាំងមច្ចុរាជ
ទៀតជងក៏ដោយ គ្មានសង្ឃឹមឡើយ ពឹងលើព្រះអង្គ ។

១៩- មានតែមនុស្ស មានជីវិតរស់ ស្ថិតស្ថេរគង់វង្ស ទើបគេអាចលើក
តម្កើងព្រះអង្គ ប្រាប់តកូនផង ពីព្រះទ័យស្មោះ ។
២០- ឱព្រះម្ចាស់អើយ សូមកុំកន្តើយ មេត្តាសង្គ្រោះ យើងខ្ញុំមិនភ្លេច
ដំណាក់របស់ ព្រះជាអម្ចាស់ លេងភ្លេងរាំថ្វាយ ។

## *ព្រះជាម្ចាស់ជាព្រះសង្គ្រោះ* បទកាកគតិ

**( ព្យាការីអេសាយ ៤០,៩-១៧)**

៩- អ្នកក្រុងស៊ីយ៉ូន ទាំងចៅទាំងកូន ចូរអ្នកកុំភ្លេច ឡើងលើភ្នំខ្ពស់
បែងចាំងរំលេច ចូរស្រែកកុំខ្លាច ប្រាប់ស្រុកយូដា ។
នុះហ្ន៎ៗ ព្រះម្ចាស់ ជាព្រះរបស់ អស់អ្នករាល់គ្នា ទ្រង់មានអំណាច
បារមីខ្លាំងក្លា ព្រះអ្នករាល់គ្នា តែមួយលើលោក ។
១០- មើលហ្ន៎! ព្រះជា អម្ចាស់រាល់គ្នា ទ្រង់បានយាងមក ដោយព្រះបារមី
ខ្លាំងក្រៃលើលោក ព្រះអង្គយាងមក ដើម្បីគ្រងរាជ្យ ។
១១- ព្រះអង្គប្រៀបបាន គង្វាលចំណាន ពេញដោយអំណាច នាំអស់ហ្វូងចៀម
រាល់ថ្ងៃព្រឹកល្ងាច ទាំងមេកូនតូច កំពុងបំបៅ ។
១២- តើនរណាចេះ អាចមានតម្រិះ នឹងវាស់ជម្រៅ មហាសមុទ្រ
ធំហើយសែនជ្រៅ វាស់រហូតទៅ ទាំងផ្ទៃមេឃា ។
តើនរណាអាច មានតម្រិះប្រាជ្ញ អាចនឹងគណនា ធូលីហ្មត់ល្អិត
ថ្លឹងទាំងព្រឹក្សា គិរីបព្វតា ដោយខ្លួនឯងបាន ។
១៣- តើនរណាអាច ស្ទង់នូវញាណប្រាជ្ញ នៃព្រះថ្កើងថ្កាន អាចធ្វើជាទី
ប្រឹក្សាចំណាន ផ្តល់គំនិតបាន ចំពោះព្រះអង្គ ។
១៤- ទ្រង់ឥតមានសួរ យោបល់គាប់គួរ ឬមួយផ្តោះផ្តង តែទ្រង់វិនិច្ឆ័យ
ត្រឹមត្រូវកន្លង ប្រាជ្ញាញាណផង ទ្រង់ចេះដឹងសព្វ ។
១៥- ប្រជាទាំងឡាយ ដូចទឹកហូរខ្វាយ ដែលគេកំពប់ គេមានតម្លៃ
បីដូចជាគ្រាប់ ធូលីគេចាប់ យកទៅដាក់ថ្លឹង ។
ម្យ៉ាងទៀតដូចកោះ ដែលមានទាំងអស់ មិនអាចនៅនឹង ដូចជាធូលី
ត្រូវខ្យល់បក់រឹង កោះគ្មានលំនឹង ខ្យល់ក្តួចទៅបាត់ ។

១៦- ព្រៃឈើក្នុងស្រុក   ក៏មិនល្មមទុក   ធ្វើជាសម្បត្តិ   ឬធ្វើជាអុស
រួមទាំងសព្វសត្វ   ទាំងអស់ត្រូវបាត់   ធ្វើយញ្ញពុំបាន   ។
១៧- បំពោះព្រះភក្ត្រ   ព្រះរបស់អ្នក   ប្រជាប៉ុន្មាន   គ្មានតម្លៃអ្វី
ថោកហួសការស្មាន   ប្រើការមិនបាន   ឥតមានប្រយោជន៍   ។

## *បទថ្មីថ្វាយចំពោះព្រះអម្ចាស់ដែលមានជ័យជម្នះ*   **បទពាក្យ ៧**

**(ព្យាការីអេសាយ ៤២,១០-១៦ )**

១០- ចូរច្រៀងបទថ្មីថ្វាយព្រះម្ចាស់   ទាំងអ្នកដែលរស់នៅទីឆ្ងាយ
ផ្លូវទឹកផ្លូវគោកកោះទាំងឡាយ   តម្កើងម្ចាស់ថ្លៃកុំបង្អង់   ។
១១- អ្នកភូមិក្នុងវាលរហោស្ថាន   អ្នកក្រុងប៉ុន្មានស្រែករំពង
ទាំងកុលសម្ពន្ធអ្នកភ្នំផង   ស្រែកឲ្យខ្លាំងឡើងកុំប្រណី   ។
១២- នាំគ្នាតម្កើងសិរីយស   របស់ព្រះម្ចាស់ទាំងយប់ថ្ងៃ
តាមភូមិកៀនកោះជិតឆ្ងាយក្ដី   តម្កើងម្ចាស់ថ្លៃដោយរីករាយ   ។
១៣- ព្រះម្ចាស់ស្រឡាញ់ប្រជាជន   ព្រះអង្គពេកពន់មិនជិនណាយ
ពេលដែលទ្រង់យាងចេញទៅឆ្ងាយ   ព្រះអម្ចាស់ថ្លៃដូចអ្នកច្បាំង   ។
ព្រះអង្គយាងចេញយ៉ាងអង់អាច   ការពារឥតខ្លាចជារនាំង
វាយសំរុកលើ សត្រូវខ្លាំង   ទទួលបានទាំងជ័យជម្នះ   ។
១៤- ព្រះអង្គមានព្រះបន្ទូលថា   យើងចាំវេលាមកយូរណាស់
ឥឡូវដល់ពេលយើងប្រកាស   ឲ្យបានដឹងច្បាស់ពេលនេះម្ដង   ។
១៥- យើងនឹងបំផ្លាញទាំងភ្នំធំ   ភ្នំតូចរលំមិនសល់ផង
រុក្ខជាតិក្រៀមស្វិតទាំងទឹកបឹង   ប្រែជាគោករឹងឥតមានសល់   ។
១៦- អ្នកខ្វាក់ប្រាកដជាអាចដើរ   គេធ្វើដំណើរមិនអំពល់
ទៅតាមផ្លូវដែលគេមិនស្គាល់   ជាកន្លែងដែលមិនធ្លាប់ដើរ   ។
យើងនឹងធ្វើឲ្យយប់ងងឹត   ប្រែជាភ្លឺពិតយ៉ាងប្រសើរ
ផ្លូវទួលគន្លុកបានរាបស្មើ   ប្រជាជនដើរដោយសុខសាន្ត   ។

## *ព្រះជាម្ចាស់ពុំព្រងើយកន្តើយឡើយ* **បទពាក្យ ៧**

**(ព្យាការីអេសាយ ៤៥,១៥-២៥ )**

១៥- ឱ! ព្រះជាម្ចាស់នៃយើងខ្ញុំ ជាព្រះឧត្តមព្រះសង្គ្រោះ
មនុស្សពិបាករកឃើញណាស់ កិត្តិនាមព្រះម្ចាស់ភ្លឺចិញ្ចែង ។
១៦- ឲ្យអស់អ្នកដែលធ្វើរូបព្រះ ឱនក្រាបសំពះគ្មានរអែង
ត្រូវអាម៉ាស់មុខខ្លាំងក្រៃលែង ចេញទៅទីផ្សេងទាំងអៀនខ្មាស ។
១៧- ចំណែកជនជាតិអ៊ីស្រាអែល គេបានដំណែលពីព្រះម្ចាស់
គឺការសង្គ្រោះយ៉ាងជាក់ច្បាស់ គេមិនអាម៉ាស់សោះឡើយណា ។
១៨- ព្រះម្ចាស់បង្កើតទាំងផ្ទៃមេឃ ដីធំអនេកលើលោកា
សត្វលោកស្នាក់នៅជួបជុំគ្នា សុខដុមរមនាគ្រប់ៗប្រាណ ។
ហើយទ្រង់មានព្រះបន្ទូលថា យើងនេះគឺជាព្រះថ្កើងថ្កាន
ព្រះក្រៅពីយើងនោះគឺគ្មាន ទាំងប្រាជ្ញាញាណទាំងបារមី ។
១៩- យើងមិននិយាយលាក់លៀមស្ងាត់ ក្នុងទីងងឹតនៃដែនដី
យើងមិនប្រាប់ពូជយ៉ាកុបអី ឲ្យឆាប់វិលវែរកយើងទេ ។
យើងជាព្រះម្ចាស់និយាយទៅ ពាក្យត្រឹមពាក្យត្រូវឥតវៀចវេរ
អ្វីដែលយើងប្រកាសប្រាប់គេ មិនភូតភរទេពិតត្រឹមត្រង់ ។
២០- ជនជាតិសេសសល់គ្រប់គ្នាអើយ កុំនៅកន្តើយធ្វើរេរង់
ត្រូវខំខ្មីឃ្មាតកុំបង្អង់ ខិតចូលមកជងឲ្យជិតគ្នា ។
ឱ! អ្នកដែលសែងព្រះខ្លួនធ្វើ ពីស្ពាន់ពីឈើគ្រប់អង្គា
បួងសួងដល់ព្រះដែលវេទនា ពួកនោះសុទ្ធជាមនុស្សល្ងង់ខ្លៅ ។
២១- ចូរអ្នករាល់គ្នាគិតមើលចុះ ឲ្យបានធ្លាយធ្លុះការនេះទៅ
តើនរណាបានប្រាប់ទុកនៅ ហេតុការណ៍ដែលត្រូវកើតមាននោះ ។
គឺមានតែយើងព្រះជាម្ចាស់ ដែលបានប្រកាសមុនប៉ុណ្ណោះ
យើងព្រះសុចរិតព្រះសង្គ្រោះ ក្រៅពីយើងនោះគ្មានផ្សេងឡើយ ។
២២- ឱ! អ្នកដែលរស់នៅទីឆ្ងាយ ចូរវិលមកអាយកុំកន្តើយ
ខិតមកជិតយើងនឹងបានស្បើយ គឺយើងនេះហើយព្រះនៃអ្នក ។

២៣- អ្វីៗដែលយើងនិយាយមក មិនមែនឆបោកសុទ្ធសច្ចៈ
មិនអាចក្រឡះភូតកុហក យើងសូមប្រាប់អ្នកដូច្នេះថា ៖ ៗ
«មនុស្សលោកទាំអស់នឹងមកសុំ ក្រាបថ្វាយបង្គំយើងគ្រប់គ្នា
មនុស្សគ្រប់សញ្ជាតិនឹងសច្ចា គោរពសន្យាបម្រើយើង » ៗ
២៤- គេនឹងពោលថាមានតែព្រះ ដែលជាអម្ចាស់មួយព្រះអង្គ
ដែលមានព្រះទ័យស្ម័គ្រស្មោះត្រង់ អ្នកប្រឆាំងទ្រង់ត្រូវអាម៉ាស់ ៗ
២៥- ពូជពង្សអ៊ីស្រាអែលទាំងអស់ នឹងបានខ្ពង់ខ្ពស់ភ្លឺត្រចះ
ហើយបានសុចរិតឥតប្រែផ្លាស់ ដោយសារព្រះម្ចាស់តរៀងទៅ ៗ

## ***ព្រះយេស៊ូសង្គ្រោះមនុស្សលោក*** **បទពាក្យ ៧**

**( ព្យាការីអេសាយ ៦១,១០-១១ )**

១០- ខ្ញុំមានអំណរសប្បាយខ្លាំង ព្រោះតែព្រះអង្គស្ដាប់អង្វរ
ព្រះអង្គសង្គ្រោះខ្ញុំកំជរ រហូតរៀងមកមិនដែលខាន ៗ
លំអខ្ញុំដូចកូនកំលោះ ពាក់មកុដស្រស់ល្អភុំជាន
ដូចកូនក្រមុំយ៉ាងចំណាន នៅលើវិមានថ្ងៃរៀបការ ៗ
១១- ដីធ្វើឲ្យគ្រាប់ពូជជៀងដុះ ពន្លកសក្បុសនៅក្នុងច្បារ
លូតលាស់ស្គុះស្គាយស្រស់យ៉ាងណា ក្ដីសុចរិតថ្លាមិនបាត់បង់ ៗ
និងការសរសើរលើកតម្កើង លូតលាស់ផុសឡើងមិនបង្អង់
ចេញពីទឹកដីល្អផូរផង់ នៅមុខទូទាំងជាតិទាំងឡាយ ៗ

## ***ព្រះយេស៊ូសង្គ្រោះមនុស្សលោក*** **បទពាក្យ ៧**

**( ព្យាការីអេសាយ ៦២,១-៥ )**

១- យើងតែងគិតគូរការពារក្រុង ឲ្យនៅគង់វង្សមានអ្នកថែ
យេរូសាឡឹមស៊ីយ៉ូនដែរ យើងមិនស្ងៀមទេមិនកន្ដើយ ៗ
ដរាបទាល់តែក្ដីសុចរិត បំាងបែងពេញពិតទើបធូរស្បើយ
ដូចថ្ងៃរះពេញពន្លឺហើយ ការសង្គ្រោះឲ្យភ្លឺដូចភ្លើង ៗ
២- ពេលនោះមនុស្សគ្រប់ជាតិសាសន៍ ឃើញសុចរិតច្បាស់មិនឆ្មៃឆ្មើង
ស្ដេចទាំងប៉ុន្មាននឹកឃើញឡើង សិរីរុងរឿងនៃអ្នកដែរ ៗ

ឈ្មោះចាស់ក្រុងឯងគេលែងហៅ គេពោលសំដៅតាមគេប្រែ
ឈ្មោះល្អសែនសមអ្វីម្លេះទេ ព្រះប្រទានគេឲ្យរុងរឿង ។
៣- ក្រុងឯងនឹងទៅជាភួងជ័យ ប្រណីតពេកក្រៃសែនថ្កុំថ្កើង
នឹងទៅជាមកុដរាជ្យរុងរឿង ព្រះហស្តព្រះយើងទ្រង់កាន់កាប់ ។
៤- គេនឹងលែងហៅអ្នកឯងថា ស្រីមិនបានការមិនចំណាប់
ស្រីប្ដីបោះបង់មិនគួររាប់ គេលែងបង្អាប់ដល់អ្នកទៀត ។
តំបន់ជុំវិញគេក៏លែង មើលងាយហៅឯងថាបោលម្សៀត
ថាស្ងាត់ជ្រងុំដូចព្រៃស្បាត ដែលមានដុះសុទ្ធស្មៅទៀតទេ ។
តែផ្ទុយទៅវិញគេនឹងហៅ ឯងថាពាលពៅបងសូមស្នេហ៍
តំបន់ជុំវិញគេបំពេរ ថាស្ងួនមាសមេភរិយាបង ។
ដ្បិតព្រះអម្ចាស់គាប់ព្រះទ័យ នឹងអ្នកពេកក្រៃគ្មានសៅហ្មង
ដូចពាក្យសម្ដីឆ្លើយសារសង ពាក្យអូនពាក្យបងត្រូវរ៉ូវគ្នា ។
៥- ព្រះម្ចាស់បង្កើតជារូបអ្នក ទ្រង់គង់ថ្នមថ្នាក់រាល់វេលា
សប្បាយឥតខ្វល់ដូចភរិយា ថ្មីថ្មោងជាគ្នានឹងស្វាមី ។

***ក្រុងយេរូសាឡឹមថ្មី*** **បទពាក្យ ៧**

**( ព្យាការីអេសាយ ៦១,១០-១១ )**

១០- ខ្ញុំមានអំណរសប្បាយខ្លាំង ព្រោះតែព្រះអង្គស្ដាប់អង្វរ
ព្រះអង្គសង្គ្រោះខ្ញុំកំដរ រហូតរៀងមកមិនដែលខាន ។
លំអខ្ញុំដូចកូនកំលោះ បាក់មកុដស្រស់ល្អភ្ញុំជាន
ដូចកូនក្រមុំយ៉ាងចំណាន នៅលើវិមានថ្ងៃរៀបការ ។
១១- ដីធ្វើឲ្យគ្រាប់ពូជជ្រៀងដុះ ពន្លកសក្បុសនៅក្នុងច្បារ
លូតលាស់ស្កុះស្កាយស្រស់យ៉ាងណា ក្ដីសុចរិតថ្លាមិនបាត់បង់ ។
និងការសរសើរលើកតម្កើង លូតលាស់ផុសឡើងមិនបង្អង់
ចេញពីទឹកដីល្អផូរផង់ នៅមុខទូទាំងជាតិទាំងឡាយ ។

## *ក្រុងយេរូសាឡឹមថ្មី*

*( ព្យាការីអេសាយ ៦២,១-៥ )* **បទពាក្យ ៧**

១- យើងតែងគិតគូរការពារក្រុង ឲ្យនៅគង់វង្សមានអ្នកថៃ
យេរូសាឡឹមស៊ីយ៉ូនដែរ យើងមិនស្ងៀមទេមិនកន្តើយ ។
ដរាបទាល់តែក្ដីសុចរិត ចាំងចែងពេញពិតទើបធូរស្បើយ
ដូចថ្ងៃរះពេលពន្លឺហើយ ការសង្គ្រោះឲ្យភ្លឺដូចភ្លើង ។
២- ពេលនោះមនុស្សគ្រប់ជាតិសាសន៍ ឃើញសុចរិតច្បាស់មិនឆ្មៃឆ្មើង
ស្ដេចទាំងប៉ុន្មាននឹកឃើញឡើង សិរីរុងរឿងនៃអ្នកដែរ ។
ឈ្មោះចាស់ក្រុងឯងគេលែងហៅ គេពោលសំដៅតាមគេប្រែ
ឈ្មោះល្អសែនសមអ្វីម្ល៉េះទេ ព្រះប្រទានគេឲ្យរុងរឿង ។
៣- ក្រុងឯងនឹងទៅជាភួងជ័យ ប្រណីតពេកក្រៃសែនថ្កុំថ្កើង
នឹងទៅជាមកុដរាជ្យរុងរឿង ព្រះហស្តព្រះយើងទ្រង់កាន់កាប់ ។
៤- គេនឹងលែងហៅអ្នកឯងថា ស្រីមិនបានការមិនចំណាប់
ស្រីប្ដីបោះបង់មិនគួររាប់ គេលែងបង្អាប់ដល់អ្នកទៀត ។
តំបន់ជុំវិញគេក៏លែង មើលងាយហៅឯងថាបោលម្សៀត
ថាស្ងាត់ជ្រងុំដូចព្រៃស្បាត ដែលមានដុះសុទ្ធស្មៅទៀតទេ ។
តែផ្ទុយទៅវិញគេនឹងហៅ ឯងថាពាលពៅបងសូមស្នេហ៍
តំបន់ជុំវិញគេបំពេរ ថាស្ងួនមាសមេភរិយាបង ។
ដូចពាក្យសម្ដីឆ្លើយសារសង ពាក្យអូនពាក្យបងត្រូវរ៉ូវគ្នា
៥- ព្រះម្ចាស់បង្កើតជារូបអ្នក ទ្រង់គង់ថ្នមថ្នាក់រាល់វេលា
សប្បាយឥតខ្វល់ដូចភរិយា ថ្មីថ្មោងជាគ្នានឹងស្វាមី ។

## *ការប្រជុំនៅថ្ងៃចុងក្រោយបំផុត* **បទកាកគតិ**

*( ព្យាការីអេសាយ ៦៦,១០-១៤ )*

១០- ឱអ្នកទាំងអស់ ដែលស្រឡាញ់ស្មោះ យេរូសាឡឹម ចូរអរសប្បាយ
ទាំងក្ដីសង្ឃឹម គ្រប់គ្នាញញឹម កុំបីសៅហ្មង ។

អស់អ្នកកាន់ទុក្ខ  អាណិតមុខជ្រប់  ដល់ក្រុងនេះផង  ចូរអរសប្បាយ
រីករាយវិញម្តង  រួមជាមួយក្រុង  សាឡឹមនេះដែរ ។
១១- សូមគ្រប់កាយា  ស្កប់ក្នុងចិន្តា  បានសុខល្ហើយល្ហែ  ដូចកូនដែលម្តាយ
បីបមថ្នមថៃ  បំបៅនៅក្បែរ  គ្មានពេលឃ្លាឃ្លាត ។
អ្នករាល់គ្នានឹង  បានសុខថ្កុំថ្កើង  ឥតបីរវាត  រុងរឿងសិរី
ដោយក្រុងនេះទៀត  អស់ទាំងមិត្តញាតិ  បានសុខគ្រប់គ្រា ។
១២- ដ្បិតព្រះអម្ចាស់  មានបន្ទូលច្បាស់  ថានឹងបង្ហៀរ  សេចក្តីសុខសាន្ត
លើក្រុងអ្នកជា  ដូចទន្លេហៀរ  ទឹកធ្លាក់មិនដាច់ ។
យើងនឹងបង្ហូរ  ធនធានបរិបូណ៌  មកឯងឥតភ្លេច  របស់ជនជាតិ
ដទៃជាស្រេច  ឥតមានកែគេច  ដូចទឹកលិចប្រាំង ។
យើងនឹងថ្នមថ្នាក់  ទៅដល់អស់អ្នក  ដូចម្តាយទូទាំង  បីបមថ្នមកូន
បំបៅគ្របបាំង  ក្រសោបព្រមទាំង  លើកដាក់លើភ្លៅ ។
១៣- ម្តាយតែងថ្នាក់ថ្នម  កូនដោយបីបម  មិនឲ្យអាស្រូវ  ដូចយើងថ្នមថ្នាក់
អ្នកឲ្យស្ថិតនៅ  ក្នុងក្រុងតទៅ  លែងមានព្រាត់ប្រាស ។
១៤- កាលណាឃើញក្រុង  យេរូសាឡឹម  សុខសាន្តដូច្នេះ  អ្នករាល់គ្នានឹង
សប្បាយពេកណាស់  សាច់ឈាមថ្លាស្រស់  ដូចស្មៅខៀវខ្ចី ។
ព្រះអង្គពុំភ្លេច  ទោះបីបន្តិច  សម្តែងបារមី  របស់ព្រះអង្គ
ជាប្រក្រតី  បម្រើប្រុសស្រី  ព្រះអង្គបានឃើញ ។

## *ព្យាការីយេរេមីអង្វរព្រះអម្ចាស់ឲ្យប្រជាជនអ៊ីស្រាអែល*  បទពាក្យ ៧

*( ព្យាការីយេរេមី ១៤,១៧-២១ )*

១៧- ទឹកភ្នែកខ្ញុំហូររាល់យប់ថ្ងៃ  ព្រោះតែស្រមៃឥតស្រាកស្រាន្ត
ទីក្រុងដែលធ្លាប់តែថ្កើងថ្កាន  ត្រូវខ្មាំងសាមាន្យបំផ្លាញអស់ ។
១៨- បើខ្ញុំចេញទៅទីវាលស្រែ  ឃើញសុទ្ធសឹងតែសាកសពសោះ
ពេលចូលដល់ក្រុងឃើញទាំងអស់  សុទ្ធអ្នករងគ្រោះដោយទុរ្ភិក្ស ។
អស់ព្យាការីដើរតត្រុក  ដើរឆ្លងកាត់ស្រុកពុំដែលនឹក
ទាំងបូជាចារ្យច្រើនសន្ធឹក  ស្រុកកើតទុរ្ភិក្សគេមិនខ្វល់ ។

១៩- ឱព្រះអម្ចាស់តើព្រះអង្គ ពិតជាបោះបង់យូដាចោល
ឬទុកស៊ីយ៉ូនឲ្យតែលតោល ឬមួយកាត់ចោលស្អប់លែងរាប់ ។
យើងខ្ញុំសង្ឃឹមថាបានសុខ តែជួបតែទុក្ខស្ទើរតែស្លាប់
ថាបានសះស្បើយជាឆាប់ៗ តែប្រែមិនគាប់ជួបអាសន្ន ។
២០- ឱព្រះម្ចាស់អើយខ្ញុំសូមក្រាប ទទួលសារភាពមិនអាក់អន់
ប្រព្រឹត្តអំពើបាបពីមុន អាក្រក់ពេកពន់មិនគប្បី ។
រួមទាំងដូនតានៃយើងខ្ញុំ ក៏ធ្វើមិនសមចិត្តអប្រិយ៍
យើងខ្ញុំសាងបាបរៀងរាល់ថ្ងៃ ទាស់នឹងព្រះទ័យនៃព្រះអង្គ ។
២១- ដោយយល់ព្រះនាមព្រះអម្ចាស់ មេត្តាសន្ដោសកុំបោះបង់
បំបាត់មុខខ្ញុំធ្វើឲ្យក្រុង ដែលធ្លាប់រឿងរុងត្រូវអាម៉ាស់ ។
សូមនឹកពីសម្ពន្ធមេត្រី ដែលព្រះអង្គលៃចងយូរណាស់
ជាមួយយើងខ្ញុំមិនគួរផ្លាស់ ផ្ដាច់ចោលស្រឡះដូច្នេះឡើយ ។

***ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់*** **បទព្រហ្មគីតិ**

**( ព្យាការី យេរេមី ១៧,៧-៨ )**

៧- រីអ្នកណាដែលជឿ ជីវិតលើព្រះអម្ចាស់
នឹងបានទទួលព្រះ ពរត្រចះល្អមិនខាន ។
៨- អ្នកនោះប្រៀបដូចជា រុក្ខាល្ងាល្អថ្កើងថ្កាន
ដុះនៅក្បែរទីស្ថាន ផ្លូវទឹកមានស្លឹកខៀវខ្ចី ។
នៅពេលរដូវប្រាំង ទោះរីងរាំងវាមិនភ័យ
មិនព្រួយបារម្ភអ្វី ទោះមេ្តចក្ដីនៅផ្លែផ្កា ។

***ប្រជាជនអ៊ីស្រាអែលមានអំណរសប្បាយនៅពេលត្រឡប់មកស្រុកវិញ*** **បទព្រហ្មគីតិ**

**( ព្យាការីយេរេមី ៣១,១០-១៤ )**

១០- ប្រជាជាតិទាំងឡាយ សូមខ្វល់ខ្វាយនាំគ្នាស្ដាប់
បន្ទូលព្រះផ្សាយផ្សព្វ ទៅដល់សព្វកោះនៅឆ្ងាយ ។

ចូរអ្នកប្រកាសថា ៖ «ព្រះដែលជាអ្នកកម្ចាយ
ស្រាអែលឲ្យទៅឆ្ងាយ តែពេលក្រោយទ្រង់ប្រមូល ។
ព្រះអង្គថែរក្សា ឲ្យគ្រប់គ្នាជុំត្រកូល
ដូចគង្វាលប្រមូល ចៀមមកមូលមិនឲ្យបាត់ » ។
១១- ព្រះអម្ចាស់បានលោះ ឲ្យរួចគ្រោះលែងខ្វាយខ្វាត់
រំដោះឲ្យរួចផុត ពួកទុច្ចរិតដែលខ្លាំងក្លា ។
១២- ពួកគេត្រឡប់វិញ គ្មានទោម្នេញស្រែកខ្សៀវខ្សា
ហើយគេគ្រប់កាយា ចាំត្រៀបត្រាទទួលទ្រព្យ ។
ដែលព្រះម្ចាស់ប្រទាន គេឲ្យមានលែងអភ័ព្វ
មានស្រូវស្រាល្អគាប់ ប្រេងក្រអូបទាំងចៀមគោ ។
ចិត្តពួកគេប្រៀបបាន សួនឧទ្យានមានទឹកហូរ
ស្រោចស្រពឡើងជន់ជោរ គេលែងថ្ងូរលែងហេវហត់ ។
១៣- គ្រានោះស្រីក្រមុំ ចូលមករាំតាមបែបបទ
ក្មេងចាស់មិនកំណត់ គេមិនហត់រាំសប្បាយ ។
យើងប្រែទុក្ខវេទនា គេទៅជាសើចក្អាកក្អាយ
ឲ្យពួកគេសប្បាយ គេរីករាយលែងលំបាក ។
១៤- អស់លោកបូជាចារ្យ បានភោគ្គាគ្មានសម្រាក
សាច់ឆ្ងាញ់មិនស្រាន្តស្រាក មិនលំបាកដើររុករក ។
យើងនឹងផ្ដល់អំណោយ ទានទៅឲ្យរាស្ត្រគ្រប់ស្រុក
លែងព្រួយលែងកើតទុក្ខ រស់បានសុខសាន្តតទៅ ។

## *សម្ពន្ធមេត្រីថ្មី* **បទពាក្យ ៧**

### ( ព្យាការីអេសេគីអែល ៣៦,២៤-២៨ )

២៤- យើងនឹងនាំយកអ្នករាល់គ្នា ចេញពីប្រជាជាតិទាំងឡាយ
ប្រមូលមិនឲ្យនៅរាយប៉ាយ ពីស្រុកជិតឆ្ងាយមកមាតុភូមិ ។
២៥- យើងនឹងប្រោះទឹកដ៏បរិសុទ្ធ លើអ្នកប្រាកដដោយថ្នាក់ថ្នម
ជម្រះឲ្យអ្នកស្អាតទាំងព្រម ផុតពីសៅហ្មងជងទាំងឡាយ ។

លែងឲ្យអ្នករាល់គ្នាជាប់ចិត្ត លើព្រះមិនពិតព្រះក្លែងក្លាយ
ឲ្យអ្នកផុតទុក្ខជួបសប្បាយ ក្ដីសោកទាំងឡាយវិនាសបង់ ។
២៦- យើងនឹងប្រគល់ចិត្តគំនិត ថ្មីល្អប្រណីតវិញ្ញាណផង
ដកចិត្តដូចថ្មរឹងកន្លង ផ្លាស់ប្ដូរវិញម្ដងបេះដូងគ្នា ។
២៧- យើងដាក់វិញ្ញាណយើងទៅក្នុង អ្នករាល់គ្នាផងមិនរួញរា
ឲ្យអ្នកធ្វើតាមបទបញ្ជា វិន័យធម្មាដំបូន្មាន ។
២៨- អ្នករាល់គ្នានឹងរស់ក្នុងស្រុក ជួបតែក្ដីសុខមិនរំខាន
ទឹកដីដែលយើងប្រទានបាន ដល់ទៅតាដូនរបស់អ្នក ។
ហើយយើងនឹងព្រមទទួលយក អ្នកទាំងអស់មកប្រាកដជាក់
ធ្វើជារាស្ត្រយើងគ្មានសល់ម្នាក់ ព្រោះយើងជាព្រះអ្នកឯងហើយ ។

### *យុវជនបីនាក់នៅក្នុងឡភ្លើង លើកតម្កើងព្រះជាម្ចាស់* **បទពាក្យ ៧**

**( ព្យាការីដានីអែល ៣,២៦-២៧-២៩-៣៤-៤២ )**

២៦- ព្រះអម្ចាស់ជាព្រះរបស់ បុព្វបុរសនៃយើងខ្ញុំ
យើងសូមតម្កើងទាំងប្រណម ព្រះនាមឧត្ដមតរៀងទៅ ។
២៧- ដ្បិតអីព្រះអង្គបានប្រព្រឹត្ត លើយើងខ្ញុំពិតមិនអាស្រូវ
ព្រះទ័យសុចរិតត្រង់ត្រឹមត្រូវ ជ្លាប់វិនិច្ឆ័យនូវក្ដីយុត្តិធម៌ ។
២៩- អំពើបាបច្រើនខ្ញុំប្រព្រឹត្ត មិនប្រណិប័តន៍តាមផ្លូវល្អ
ឃ្លាតពីព្រះអង្គចាកយុត្តិធម៌ យើងនៅបន្តខុសគ្រប់យ៉ាង ។
៣៤- ឱ! ព្រះអម្ចាស់សូមកុំបោល ឲ្យយើងតែលតោលគ្មានទីអាង
សម្ពន្ធមេត្រីថ្មីស្រឡាង គឺជាភស្ដុតាងមិនបាត់បង់ ។
៣៥- សូមកុំដកយកក្ដីមេត្តា នឹកទៅដល់គ្រាដែលកន្លង
នឹកដល់លោកអប្រាហាំផង មិនដែលសៅហ្មងសម្លាញ់ស្និទ្ធ ។
នឹកដល់អ៊ីសាកជាបម្រើ ស្រាអែលធ្លាប់ដើរតាមប្រកិត
ទៅណាមកណាជាប់នៃបនិត្យ ដូចបងប្អូនឥតដែលមានខ្វោះ ។
៣៦- ពីដើមព្រះអង្គបានសន្យា ដោយបន្ទូលថាទ្រង់នឹងប្រោស
ឲ្យអ្នកទាំងបីមានកូនប្រុស កូនស្រីចម្រុះឥតគណនា ។

ច្រើនពេកអនេករាប់ពុំបាន ដូចផ្កាយដែលមានលើមេឃា
ដូចគ្រាប់ខ្សាច់តាមឆ្នេរជលធារ សមុទ្រនានាច្រើនក្រៃក្រាស់ ។
៣៧- បពិត្រព្រះអម្ចាស់ថ្លៃអើយ គឺថ្ងៃនេះហើយយើងព្រួយណាស់
ធ្លាក់ខ្លួនមកជាពូជអាម៉ាស់ ខ្វាត់ខ្វាយព្រាត់ប្រាសថោកបំផុត ។
ទៅជាជនជាតិតូចជាងគេ ទុក្ខធំឡើងទ្វេសែនស្រយ៉ុត
ឥឡូវទន់ទាបស្ទើររលត់ មកពីយើងល្វិតល្វង់សាងបាប ។
៣៨- ពេលនេះយើងខ្សត់អត់ទាំងអស់ ជីវិតកក្រោះប្រៀបដូចស្លាប់
គ្មានស្តេចមន្ត្រីសែនអភ័ព្វ ព្យាការីគាប់ក៏មិនមាន ។
យើងមិនអាចថ្វាយយញ្ញបូជា ថ្វាយយញ្ញសក្ការទាំងប៉ុន្មាន
ទាំងគ្រឿងក្រអូបម្សៅភ៌ុជាន ផលផ្លែមិនបានយកមកថ្វាយ ។
៣៩- សូមព្រះអង្គជួយទទួលយក ទុក្ខព្រួយសោយសោកផងទាំងឡាយ
និងចិត្តសុភាពរាបស្រស់ស្រាយ ទុកជាតង្វាយគាប់ព្រះទ័យ ។
៤០- គឺតង្វាយដុតទាំងមូលមាន កូនចៀមរាប់លានជាត់ពេកក្រៃ
ពពែគោឈ្មោលនៅក្នុងព្រៃ យើងខ្ញុំដាក់ថ្វាយនៅថ្ងៃនេះ ។
សូមឲ្យយើងខ្ញុំអាចដើរតាម មាគ៌ាដានស្នាមដ៏វិសេស
របស់ព្រះអង្គមិនប្រហែស អ្នកសង្ឃឹមព្រះមិនខកចិត្ត ។
៤១- ឥឡូវយើងខ្ញុំប្រែប្រួលប្រាណ ប្រព្រឹត្តឲ្យបានគ្មានរខិត
គន្លងព្រះអង្គធម៌ប្រណីត កោតខ្លាចដាក់ចិត្តស្គាល់ព្រះភក្ត្រ ។

## ***បទលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់*** **បទកាកគតិ**

**( ព្យាការីដានីអែល ៣,៥២-៨៨ )**

៥២- បពិត្រព្រះម្ចាស់ ជាព្រះរបស់ ដូនតាយើងខ្ញុំ សូមកោតសរសើ
ទាំងថ្វាយបង្គំ ថ្កើងព្រះឧត្តម អស់កល្បតទៅ ។
ខ្ញុំសូមតម្កើង លើកព្រះនាមឡើង ពុំមានអាស្រូវ សុចរិតយុត្តិធម៌
ទ្រង់គង់ជាផ្លូវ អង្វែងតទៅ សរសើរព្រះអង្គ ។
៥៣- សូមកោតសរសើរ ព្រះគ្មានអ្វីស្មើ ក្នុងគ្រានេះម្តង ទ្រង់ប្រកបដោយ
សិរីរឿងរុង ក្នុងវិហារទ្រង់ កុំនៅទីមទាម ។

៥៤- សូមលើកតម្កើង ព្រះម្ចាស់យាងឡើង លើខេរ៉ូប៊ីន ខ្ពង់ខ្ពស់បំផុត
គ្មានអ្វីប្រៀបផ្ទឹម ស្មូត្រទាំងញញឹម តម្កើងជានិច្ច ។
៥៥- សូមតម្កើងទ្រង់ ដែលយាងឡើងគង់ លើបល្ល័ង្ករាជ្យ សូមច្រៀងតម្កើង
រាល់ថ្ងៃព្រឹកល្ងាច ព្រះម្ចាស់ជានិច្ច កុំប្រែក្រឡះ ។
៥៦- សូមថ្កើងសរសើរ ព្រះអង្គនៅលើ វេហាស៍អាកាស ព្រះអង្គគ្រប់គ្រង
ស្ថានបរមសុខខ្ពស់ លើកសិរីយស ព្រះអង្គរហូត ។
៥៧- គ្រប់ស្នាព្រះហស្ត ព្រះម្ចាស់ទាំងអស់ នៅមិនរបូត ជារៀងដរាប
សូមនាំគ្នាស្មូត្រ តម្កើងរហូត អស់កល្បអន្លាយ ។
៥៨- ឱផ្ទៃមេឃអើយ កុំនៅកន្តើយ ហាក់ដូចជិនណាយ ស្មូត្របទតម្កើង
ដោយចិត្តសប្បាយ អស់កល្បអន្លាយ តទៅកុំឈប់ ។
៥៩- សូមឲ្យទេវទូត តម្កើងរហូត ទាំងថ្ងៃទាំងយប់ ព្រះម្ចាស់ជុំថ្កើង
អស់កល្បអស់កប្ប តម្កើងកុំឈប់ តទៅរាល់ថ្ងៃ ។
៦០- ចូរទឹកទាំងឡាយ អបអរសប្បាយ លើនភាល័យ នាំគ្នាសរសើរ
តម្កើងម្ចាស់ថ្លៃ កុំបង្អង់អី អស់កល្បអង្វែង ។
៦១- ហ្វូងតារារះ នៃព្រះអម្ចាស់ នាំគ្នាសម្តែង តម្កើងព្រះអង្គ
សរសើរស្ញប់ស្ញែង គ្រប់ទីកន្លែង តទៅឥតដាច់ ។
៦២- សូមព្រះអាទិត្យ ព្រះច័ន្ទមានឫទ្ធិ ពន្លឺចិញ្ចាច តម្កើងព្រះអង្គ
ដោយចិត្តអង់អាច កុំភ័យកុំខ្លាច តទៅកុំប្រែ ។
៦៣- សូមអស់ទាំងផ្កាយ ដែលនៅរាត់រាយ លើមេឃផងដែរ សរសើរតម្កើង
កុំបីប្រួលប្រែ កុំក្រឡះកែ រាល់ថ្ងៃខែឆ្នាំ ។
៦៤- សូមឲ្យសន្សើម ទឹកភ្លៀងដ៏ឆ្នើម ធ្លាក់ជាប្រចាំ ចូរលើកតម្កើង
ទាំងថ្វាយបង្គំ ព្រះម្ចាស់ឧត្តម ជានិច្ចកុំរា ។
៦៥- ចូរអស់ទាំងខ្យល់ ធ្លាប់បក់វិលវល់ រាល់ប្រាំងវស្សា គ្រប់ទីគ្រប់ទិស
តម្កើងព្រះជា ម្ចាស់អ្នករាល់គ្នា កុំបីផ្អែផ្អើង ។
៦៦- ចូរឲ្យកម្តៅ ទាំងក្នុងទាំងក្រៅ ឲ្យមានទាំងភ្លើង នាំគ្នាជួយលើក
សរសើរតម្កើង ព្រះអង្គខ្ពស់ឡើង តទៅឥតអាក់ ។

៦៧- ចូរឲ្យខ្យល់ក្តៅ ពេលនេះតទៅ និងខ្យល់ត្រជាក់ សរសើរតម្កើង
ព្រះជាម្ចាស់អ្នក កុំបីអន់អាក់ ជានិច្ចតទៅ ។
៦៨- សន្សើមនិងព្រឹល សូមអ្នកកុំខ្ជិល កុំបង្អង់នៅ ស្មូត្រលើកតម្កើង
ព្រះម្ចាស់ជាផ្លូវ អង្វែងតទៅ អស់កល្បជានិច្ច ។
៦៩- ចូរថ្ងៃនិងយប់ កោតកុំឈរឈប់ សរសើរកុំភ្លេច ស្មូត្រលើកតម្កើង
ព្រះម្ចាស់ជានិច្ច កុំបីកែគេច អស់កល្បស្ថេរស្ថិត ។
៧០- ចូរឲ្យពន្លឺ រន្ទាលរន្ទឺ និងភាពងងឹត សរសើរតម្កើង
អម្ចាស់មានឫទ្ធិ រាល់ថ្ងៃកុំគិត ខ្វល់ខ្វាយឡើយណា ។
៧១- អាកាសត្រជាក់ ខ្យល់រងាធ្លាក់ មកជាធម្មតា ចូរលើកតម្កើង
អម្ចាស់ក្សត្រា ព្រះអ្នករាល់គ្នា កុំបីឃ្លាងឃ្លាត ។
៧២-សូមឲ្យទឹកកក កុំបីខានខក ទាំងសន្សើមទៀត ចូរលើកតម្កើង
ព្រះម្ចាស់ទាំងឆ្លៀត កុំបីរវាត រហូតតទៅ ។
៧៣-សូមដុំពពក ផ្លេកបន្ទោរមក កុំបង្អង់នៅ តម្កើងព្រះអង្គ
កុំបីហ្មងសៅ ស្មូត្ររហូតទៅ អស់កល្បយូរលង់ ។
៧៤-សូមឲ្យផែនដី ទាំងមូលលកលៃ តម្កើងព្រះអង្គ សរសើរកុំឈប់
កុំនៅរេរង់ កោតសរសើរទ្រង់ កុំប្រែសាវ៉ា ។
៧៥-សូមឲ្យភ្នំធំ កុំនៅសំងំ ភ្នំតូចជងណា ស្មូត្របទតម្កើង
ព្រះម្ចាស់រាល់គ្នា ថ្កើងព្រះនាមា អស់កល្បជានិច្ច ។
៧៦-សព្វអស់អ្វីៗ ដែលដុះលើដី កុំបីមានភ្លេច ចូរលើកតម្កើង
ព្រះម្ចាស់ជានិច្ច កុំប្រែមានល្បិច អស់កល្បជានិច្ច ។
៧៧-ចូរសមុទ្រស្ទឹង ទន្លេល្វើយល្វឹង តូចធំទាំងឡាយ នាំគ្នាតម្កើង
ដោយក្តីរីកសាយ សរសើរម្ចាស់ថ្លៃ ឲ្យលាន់រងំ ។
៧៨-ចូរប្រភពទឹក មានច្រើនសន្ធឹក ព្រែកទាំងតូចធំ ទឹកហូរពីជ្រោះ
ទឹកធ្លាក់ពីភ្នំ កុំនៅសំងំ តម្កើងព្រះអង្គ ។
៧៩-ចូរអស់ទាំងត្រី តូចធំម្តេចក្តី និងសត្វរស់ក្នុង ទន្លេសមុទ្រ
តាមព្រែកបួរបឹង កុំសំងំឈឹង តម្កើងព្រះម្ចាស់ ។

| | | | |
|---|---|---|---|
| ៨០- សូមបក្សីសត្វ | ដែលរស់ខ្មៃងខ្វាត់ | ច្រើនមីរដេរដាស | ស្មូត្របទតម្កើង |
| ព្រះជាអម្ចាស់ | កុំបីចន្លោះ | អស់កល្បយូរលង់ | ។ |
| ៨១- សូមឲ្យសត្វស្រុក | រស់នៅអែរអុក | ទាំងសត្វព្រៃផង | នាំគ្នាសរសើរ |
| តម្កើងព្រះអង្គ | អស់កល្បយូរលង់ | តទៅអន្លាយ | ។ |
| ៨២- ចូរឲ្យមនុស្ស | ទាំងស្រីទាំងប្រុស | កុំបីឃ្លាតឆ្ងាយ | សរសើរព្រះអង្គ |
| ជាព្រះម្ចាស់ថ្លៃ | រៀងរាល់យប់ថ្ងៃ | កុំបីអល់អែក | ។ |
| ៨៣- ឱអ៊ីស្រាអែល | អ្នកជាជាតិដែល | វិសុទ្ធពន់ពេក | ចូរលើកតម្កើង |
| ព្រះខ្ពស់អនេក | ហួសទាំងផ្ទៃមេឃ | កុំសំងំនៅ | ។ |
| ៨៤- ចូរបូជាចារ្យ | គ្រប់ៗកាយា | ឆ្ពោះតម្រង់ទៅ | តម្កើងព្រះអង្គ |
| ទាំងថ្ងៃយប់ជ្រៅ | កុំសងំនៅ | សរសើរកុំឈប់ | ។ |
| ៨៥- ចូរអ្នកទាំងឡាយ | ដែលតែងខ្វល់ខ្វាយ | បម្រើគោរព | ស្មូត្រតម្កើងព្រះ |
| ទាំងថ្ងៃទាំងយប់ | កុំឈរកុំឈប់ | នៅស្ងៀមឲ្យសោះ | ។ |
| ៨៦- ចូរវិញ្ញាណក្ខ័ន្ធ | អ្នកស្លាប់ប៉ុន្មាន | កុំបីចន្លោះ | ព្រលឹងនៃអ្នក |
| សុចរិតទាំងអស់ | តម្កើងដោយស្មោះ | កុំនៅកន្តើយ | ។ |
| ៨៧- អស់អ្នកគោរព | ប្រណិប័តន៍សព្វគ្រប់ | ព្រះអម្ចាស់អើយ | និងអ្នកដាក់ចិត្ត |
| ជាអ្នកខ្សត់ហើយ | កុំបង្អង់ឡើយ | តម្កើងព្រះអង្គ | ។ |
| ៨៨- លោកអណានីយ៉ា | រួមជាមួយគ្នា | អសារីយ៉ាផង | និងមីកាអែល |
| តម្កើងព្រះអង្គ | ស្មូត្រសរសើរផង | តទៅជរាប | ។ |
| ព្រះអង្គរំដោះ | យើងខ្ញុំឲ្យរស់ | ផុតពីក្តីស្លាប់ | ហើយទ្រង់សង្គ្រោះ |
| ខ្ញុំជាប្រញាប់ | រួចផុតទុក្ខសព្វ | ទាំងភ្លើងសន្ធៅ | ។ |

## *ព្រះជាម្ចាស់វិនិច្ឆ័យមនុស្សលោក* **បទព្រហ្មគីតិ**

**(ហាបាគូក ៣,២-៤-១៣-១៥-១៨ )**

| | | |
|---|---|---|
| ២- ឱ! ព្រះជាអម្ចាស់ | ខ្ញុំឮច្បាស់សព្វសេចក្តី | |
| ស្នាព្រះហស្តថ្លាថ្លៃ | រៀងរាល់ថ្ងៃខ្លាំងអស្ចារ្យ | ។ |
| សូមទ្រង់ប្រោសប្រណី | ដោយសេចក្តីករុណា | |
| សម្តែងឫទ្ធិបាដិហារិយ៍ | ឲ្យគ្រប់គ្នាស្គាល់ផងចុះ | ។ |

ប៉ុន្តែពេលព្រះអង្គ ពិរោធខ្លាំងសូមសន្តោស
ព្រះទ័យដែលធ្លាប់ស្មោះ ធ្លាប់ស្រណោះគ្រាកន្លង ។

៣- ព្រះម្ចាស់យាងមកពី ភ្នំជាទីឥតមានហ្មង
វិសុទ្ធពេកកន្លង បារមីទ្រង់ភ្លឺចែងចាំង ។
សូមឲ្យដែនពសុធា កុំរួញរាស្រែកឲ្យខ្លាំង
លើកតម្កើងព្រះអង្គ យប់ថ្ងៃផងកុំសោកា ។

៤- ព្រះអង្គភ្លឺពណ្ណរាយ ចាំងពីនាយល្អអស្ចារ្យ
ចែងចាំងរស្មីថ្លា ព្រះចេស្តាបង្កប់ទុក ។

១៣- ព្រះអង្គចេញសង្គ្រោះ មនុស្សទាំងអស់នៅលើលោក
ទាំងស្តេចដែលចេញមក ទ្រង់អភិសេកចាក់ប្រេងឲ្យ ។
ព្រះអង្គបានប្រហារ មេគ្រួសារមិនបណ្តោយ
កម្ទេចមិនទុកឲ្យ នៅសល់ឡើយទាំងអស់គ្នា ។

១៥- ព្រះអង្គត្រួសត្រាយផ្លូវ សេះដើរទៅលាន់ខ្ទ័រខ្ទារ
នៅក្នុងបាតជលធារ ដែលពុះពារកញ្ជ្រោលខ្លាំង ។

១៦- ខ្ញុំឮសន្ធឹកនេះ ទ្រូងស្ទើរប្រេះភ័យភាន់ភាំង
ឆ្អឹងឆ្អែងពុកអស់ទាំង ដៃជើងគាំងនៅស្ងៀមឈឹង ។
ខ្ញុំរស់ចាំតែថ្ងៃ អាសន្នភ័យទាំងទន្ទឹង
ពេលពួកឈ្លានពានខឹង ពួកវានឹងកាប់ប្រហារ ។

១៧- ឈើព្រៃលែងឲ្យផ្លែ ស្រូវក្នុងស្រែស្ពកអាសារ
សត្វគោចៀមផងណា ត្រូវមរណាគ្មានសល់ដែរ ។

១៨- ឯខ្ញុំសែនរីករាយ អរសប្បាយបានល្ហើយល្ហែ
ព្រោះព្រះម្ចាស់នៅក្បែរ ទ្រង់តាមថែសង្គ្រោះខ្ញុំ ។

***ចូរអរព្រះគុណនិងលើកតម្កើងព្រះនាមព្រះជាម្ចាស់*** **បទកាកគតិ**

**( របាក្សត្រភាគមួយ ២៩,១០-១៣ )**

១០- ឥឡូវនេះខ្ញុំ មានបំណងធំ ចង់ចងសម្ពន្ធ មេត្រីជាមួយ
ព្រះអង្គបន្ទាន់ ជាព្រះនៃជន ជាតិអ៊ីស្រាអែល ។

ខ្ញុំសូមអង្វរ ព្រះម្ចាស់បវរ បារមីក្រាស់ក្រៃល សូមទ្រង់ពង្វាង
ព្រះពិរោធដែល គ្រប់គ្រងក្រវែល លើយើងគ្រប់គ្នា ។
១១- ពេលនេះកូនចៅ ទាំងអស់គ្នាត្រូវ ឈប់ធ្វើខ្ជីខ្ជា ដ្បិតព្រះអម្ចាស់
ជ្រើសអ្នករាល់គ្នា បំពេញមុខងារ បម្រើព្រះអង្គ ។
ទ្រង់សព្វព្រះទ័យ លើអ្នកពេកក្រៃ ឈរពីមុខទ្រង់ បម្រើកិច្ចការ
តាមព្រះបំណង គ្រឿងក្រអូបផង ដាក់ថ្វាយគ្មានទាស់ ។
១២- ពេលនោះកូនចៅ លេវីមិននៅ ក្រោកឡើងទាំងអស់ ជម្រះដំណាក់
វិសុទ្ធឥតទាស់ ថែមទាំងជម្រះ ខ្លួនពួកគេផង ។
១៣- អំបូរទាំងអស់ គ្មានសល់ម្នាក់សោះ គ្រប់គ្នាតែម្តង គេបានញែកខ្លួន
ឲ្យអស់សៅហ្មង វិសុទ្ធជូវផង់ តាមបញ្ជាស្តេច ។

***ទំនុកតម្កើងរបស់លោកតូប៊ីត*** **បទកាកគតិ**

**(លោកតូប៊ីត ១៣,២-១៦-១៨ )**

២- សូមលើកតម្កើង សិរីរុងរឿង របស់ព្រះម្ចាស់ ដែលមានព្រះជន្ម
គង់នៅយ៉ាងច្បាស់ កោតសរសើរណាស់ អស់កល្បជានិច្ច ។
ព្រះអង្គធ្វើឲ្យ មនុស្សស្លាប់ទៅហើយ ចុះស្ថានមច្ចុរាជ ក្រោយមកព្រះអង្គ
ប្រោសឲ្យបានរួច គ្មានអ្វីដែលអាច គេពីបារមី ។
៣- អ៊ីស្រាអែលអើយ កុំនៅកន្តើយ តម្កើងរាល់ថ្ងៃ នៅមុខជនជាតិ
ផ្សេងៗទាំងឡាយ ដែលទ្រង់កម្ចាយ ឲ្យអ្នកទៅនៅ ។
៤- នៅទីនោះឯង ព្រះអង្គសម្តែង មិនមានអាស្រូវ ឫទ្ធាបារមី
មានច្រើនពេកកូវ ទ្រង់សម្តែងនៅ មុខអស់សត្វលោក ។
ព្រះអង្គពិតជា ព្រះយើងរាល់គ្នា អង្វែងវេងមក ជាព្រះបិតា
តែមួយលើលោក ពីនេះទៅមុខ អស់កល្បតទៅ ។
៥- ព្រះអង្គបានដាក់ ទោសដល់ពួកអ្នក ជារឿងត្រឹមត្រូវ ព្រោះអ្នករាល់គ្នា
បានប្រព្រឹត្តនូវ អំពើអាស្រូវ អាក្រក់អប្រិយ៍ ។
ប៉ុន្តែព្រះអង្គ ទ្រង់មិនបោះបង់ តែងតែប្រណី អាណិតអាសូរ
ប្រជាប្រុសស្រី នាំអ្នកវិលវៃ ឥតបីខ្វាត់ខ្វាយ ។

៦- ប្រសិនបើអ្នក រាល់គ្នាស្មោះស្ម័គ្រ ដោយចិត្តរីករាយ វិលរកព្រះអង្គ
នឹងផុតអន្តរាយ រស់នៅសប្បាយ ប្រព្រឹត្តស្មោះត្រង់ ។
ព្រះអង្គមុខជា រកអ្នករាល់គ្នា ក្រសោបត្រកង ឈប់គេចព្រះភក្ត្រ
ឈប់ប្រែបែរខ្នង មិនឲ្យមានហ្មង អង្វែលភក្ត្រា ។
៧- ឥឡូវពេលនេះ ចូរគិតត្រិះរិះ អំពីកិច្ចការ ព្រះអង្គប្រព្រឹត្ត
ដល់គ្រប់អាត្មា តម្កើងក្សត្រា ឲ្យពេញទំហឹង ។
សូមលើកតម្កើង កុំធ្វើឆ្មៃឆ្មើង ថ្កើងទាំងរំពឹង ដែលទ្រង់ប្រព្រឹត្ត
យុត្តិធម៌លំនឹង ចូរកោតព្រះអង្គ អស់កល្បឥតបី ។
៨- រីឯខ្ញុំវិញ ខ្ញុំឃ្លាតចាកចេញ ពីដែនបុរី ហើយបានមករស់
នៅលើទឹកដី ពួកខ្មាំងអប្រិយ៍ ក៏មិនភ្លេចដែរ ។
ខ្ញុំបង្ហាញប្រាប់ ឲ្យអស់អ្នកបាប ស្គាល់ជាហូរហែរ ថាព្រះអង្គមាន
ឫទ្ធាពូកែ បារមីគ្មានប្រែ ខ្លាំងក្លាឧត្តម ។
អ្នកបាបប្រុងប្រៀប កាន់ចិត្តសុភាព វិលមកជួបជុំ ប្រព្រឹត្តសុចរិត
កុំនៅសំងំ ទ្រង់នឹងថ្នាក់ថ្នម មេត្តាប្រណី ។
៩- ខ្ញុំលើកតម្កើង ព្រះដ៏រុងរឿង ដោយចិត្តមេត្រី អំណរសប្បាយ
លើសលប់ពេកក្រៃ ដោយមហាក្សត្រថ្លៃ នៃស្ថានសួគ៌ា ។
១០- សូមឲ្យអស់អ្នក ដែលបាននៅស្នាក់ ក្នុងក្រុងគ្រប់គ្នា ប្រកាសអំពី
បារមីឫទ្ធា ព្រះអម្ចាស់ជា ព្រះរបស់យើង ។
យេរូសាឡឹម ក្រុងជំស្តែស្កឹម ទ្រង់នឹងបំបើង ដាក់ទោសពួកអ្នក
រលំរលើង ធ្វើឫកឆ្មៃឆ្មើង សាងអំពើបាប ។
ប៉ុន្តែព្រះម្ចាស់ មិនព្រមបង់បោះ បោលជាដរាប ព្រះអង្គមុខជា
អាណិតអ្នកទាប កូនចៅសុភាព សុចរិតមិនខាន ។
១១- សូមលើកតម្កើង ព្រះម្ចាស់ខ្ពស់ឡើង ផុតអស់ពីស្ថាន ជាមហាក្សត្រ
វិសុទ្ធថ្កើងថ្កាន ដែលព្រះអង្គបាន សោយរាជ្យយូរលង់ ។
ព្រះអង្គមុខជា ឲ្យគេគ្រប់គ្នា សង់ដំណាក់ទ្រង់ ឡើងវិញម្តងទៀត
មិនឲ្យបាត់បង់ នៅក្នុងទីក្រុង យេរូសាឡឹម ។

១២- សូមព្រះម្ចាស់ប្រោសប្រណីសន្ដោស អ្នកអស់សង្ឃឹម អ្នកត្រូវគេកៀរ
ប្រែជាញញឹម ដូចភ្លៀងរលឹម រដូវវស្សា ។
សូមទ្រង់អាណិត អស់អ្នកសុចរិត អ្នកខ្សត់ខ្លោចផ្សា មានទុក្ខសព្វកាយ
លំបាកម្ល៉េះណា សូមជួយពាំងការ ផុតអស់ទុក្ខភ័យ ។
១៣- ពន្លឺចិញ្ចាច ភ្លឺដល់ទីដាច់ ស្រយាលដែនដី ចុងកាត់មាត់ញក
ប្រជាប្រុសស្រី នាំគ្នាឃ្មាតខ្មី មករកព្រះអង្គ ។
មានកាន់តង្វាយ នៅគ្រប់ៗដៃ ឱនកាយក្រាបផង ថ្វាយមហាក្សត្រ
ស្ថានបរមសុខផង ប្រជាទាំងពួង សប្បាយរីករាយ ។
អ្នកជំនាន់ក្រោយ នឹងមិនបណ្ដោយ ឬឲ្យរលាយ គេនឹងនឹកចាំ
ក្រុងល្បីសុះសាយ ដែលព្រះម្ចាស់ថ្លៃ ជ្រើសរើសទុកដាក់ ។
១៤- សូមជនទាំងឡាយ ដែលធ្លាប់សប្បាយ គំរាមពួកអ្នក រលំកំពែង
បំផ្លាញទីស្នាក់ ផុតបោលផ្ទះអ្នក ទទួលកម្មពា ។
តែសូមព្រះអង្គ ប្រទានពរផង អស់កល្បយូរយា ដល់អស់អ្នកណា
ខ្លាចអ្នករាល់គ្នា ផុតអស់វេទនា អង្វែងតទៅ ។
១៥- ចូរអរសប្បាយ សើចលេងក្អាកក្អាយ ព្រោះតែកូនចៅ មនុស្សសុចរិត
រួមគ្នាក្នុងក្រៅ ប្រមូលគ្នានៅ មិនឲ្យខ្ចាត់ខ្ចាយ ។
គេលើកតម្កើង សិរីរុងរឿង ព្រះម្ចាស់រាល់ថ្ងៃ ដែលមានព្រះជន្ម
គង់នៅវែងឆ្ងាយ អស់កល្បអន្លាយ ស្ថិតស្ថេរជានិច្ច ។
ជនណាសប្បាយ រីករាយក្អាកក្អាយ ឥតមានពេលភ្លេច គេជួយអបអរ
ដល់អ្នកជានិច្ច ព្រះម្ចាស់មិនភ្លេច ឲ្យគេបានសុខ ។
១៦- អ្នកផងទាំងឡាយ ដែលមិនសប្បាយ ពេលអ្នកកើតទុក្ខ គេពិតជាបាន
មង្គលគ្រប់មុខ ដ្បិតគេរួមសុខ ទុក្ខជាមួយអ្នក ។
១៨- អ្នកក្រុងនឹងច្រៀង បន្លឺសូរសៀង លាន់ឮឥតអាក់ សរសើរតម្កើង
ព្រះរបស់អ្នក គង់នៅជាដាក់ អស់កល្បតទៅ ។

## ***ព្រះជាម្ចាស់ដែលបង្កើតពិភពលោកទ្រង់ការពារប្រជាជន*** **បទកាកគតិ**

**(នាងយូឌីត ១៦,១-២-១៣-១៥ )**

១- ចូរអ្នករាល់គ្នា បង្គំវន្ទា ច្រៀងរាំទូលថ្វាយ ព្រះជាអម្ចាស់
ប្រគុំភ្លេងលាយ ឈឹងស្គរឱនកាយ សរសើរតម្កើង ។
២- ព្រះម្ចាស់ពិតជា មានឫទ្ធិចេស្ដា ពន្លត់ភ្នក់ភ្លើង សង្គ្រាមរលត់
ព្រះនាមទ្រង់ថ្កើង សុលសាយឮឡើង គឺព្រះអម្ចាស់ ។
ព្រះអង្គរំដោះ ខ្ញុំផុតភ័យគ្រោះ សត្រូវច្រើនណាស់ វាដេញតាមខ្ញុំ
តែព្រះជាម្ចាស់ នាំខ្ញុំវិលប្រាស មកវិញសុខសាន្ដ ។
១៣- ខ្ញុំនឹងច្រៀងបទ ថ្មីហើយវិសុទ្ធ ថ្វាយព្រះថ្កើងថ្កាន ព្រះអង្គពិតជា
ប្រសើរហួសស្មាន បារមីចំណាន ខ្លាំងក្លាអស្ចារ្យ ។
១៤- សូមឲ្យសត្វលោក ក្នុងទឹកលើគោក កុំនៅសោកា សុខចិត្តបម្រើ
ព្រះមានចេស្ដា ឥតមាននរណា ជំទាស់បានឡើយ ។
១៥- ពេលទ្រង់យាងមក ភ្នំក៏កក្រើក រង្គើអស់ហើយ ធ្លាក់ក្នុងសមុទ្រ
នៅមិនបានឡើយ ទោះថ្មក៏ដោយ រលាយជាដី ។
ប៉ុន្តែព្រះម្ចាស់ តែងតែសន្ដោស អាណិតប្រណី អាសូរដល់រាស្ត្រ
អ្នកទាបក្រក្រី គោរពរាល់ថ្ងៃ កោតខ្លាចព្រះអង្គ ។

## ***បទអង្វរព្រះជាម្ចាស់ សូមទ្រង់ប្រទានព្រះប្រាជ្ញាញាណ*** **បទពាក្យ ៧**

**(ព្រះប្រាជ្ញាញាណ ៩,១-៦-៩-១១ )**

១- ឱ! ព្រះជាម្ចាស់ថ្លៃឧត្ដម ប្រសើរសក្តិសមពន់ពេកណាស់
ព្រះអង្គជាព្រះបុព្វបុរស ទ្រង់ធ្លាប់សន្ដោសស្ម័គ្រមេត្តា ។
ព្រះអង្គបង្កើតពិភពលោក ក្នុងទឹកលើគោកពេញត្រៀបត្រា
ដោយព្រះបន្ទូលពោលវាចា រស់ពេញលោកាច្រើនរាល់លាន ។
២- ព្រះអង្គបានសូនរូបមនុស្ស ទាំងស្រីទាំងប្រុសដោយវិញ្ញាណ
ឲ្យគ្រប់គ្រងសត្វលោកប៉ុន្មាន ដែលព្រះអង្គបានបង្កើតស្រេច ។

៣- ឲ្យត្រួតកាន់កាប់តាមសុចរិត ដោយភាពវិសុទ្ធល្អបណ្ដាច់
ព្រមទាំងឲ្យវិនិច្ឆ័យសម្រេច កុំឲ្យក្រឡាប់ពីយុត្តិធម៌ ។
៤- សូមទ្រង់មេត្តាប្រោសប្រទាន ព្រះប្រាជ្ញាញាណដ៏បវរ
ដល់ខ្ញុំជាអ្នកនៅកំដរ ហើយសូមអង្វរកុំកាត់កាល ។
៥- ទូលបង្គំជាអ្នកបម្រើ ម្ដាយខ្ញុំក៏ធ្វើគ្មានពិភាល់
ខ្ញុំអ្នកឆោតល្ងង់មិនសូវយល់ វិន័យនិមលច្បាប់ព្រះអង្គ ។
៦- ទោះបីជាមានមនុស្សណា ល្អគ្រប់ប្រការឥតសៅហ្មង
តែគ្មានប្រាជ្ញាញាណតម្រង់ ជីវិតគេជងក៏គ្មានន័យ ។
៩- បពិត្រព្រះម្ចាស់ព្រះប្រាជ្ញា ញាណដ៏ថ្លៃថ្លាគង់សព្វថ្ងៃ
ជាមួយព្រះអង្គជ្រាបអស់ន័យ ស្នាព្រះហស្ដថ្លៃទាំងប៉ុន្មាន ។
ពេលទ្រង់បង្កើតពិភពលោក ប្រាជ្ញាញាណមកគង់សុខសាន្ត
ជាមួយព្រះអង្គគ្មានរំខាន ព្រះអង្គជ្រាបបានអ្វីទាំងអស់ ។
១០- សូមទ្រង់ប្រទានព្រះប្រាជ្ញា ញាណវិសុទ្ធថ្លាដោយសន្ដោស
ឲ្យចុះពីស្ថានបរមសុខខ្ពស់ ពីបល្ល័ង្កយសដ៏ឧត្ដម ។
សូមឲ្យព្រះប្រាជ្ញាញាណរួម ធ្វើការទាំងព្រមជាមួយខ្ញុំ
បង្ហាត់បង្រៀនការតូចធំ កិច្ចការដែលល្មមគាប់ព្រះទ័យ ។
១១- ដ្បិតព្រះប្រាជ្ញាញាណជ្រាបសព្វ ទ្រង់ឈ្វេងយល់គ្រប់ទាំងឈ្លាសវៃ
ណែនាំរូបខ្ញុំទាំងរំពៃ ការពារផុតភ័យខ្ញុំរុងរឿង ។

## *ពាក្យអធិដ្ឋាន* **បទពាក្យ ៧**

**(លោកបែនស៊ីរ៉ាក ៣៦,១-៥-៧-១០-១៣ )**

១- ឱ! ព្រះជាម្ចាស់ដែលគ្រប់គ្រង លើលោកឥតហ្មងទាំងមូលអើយ
សូមអាណិតអាសូរយើងហើយ ទតកុំកន្ដើយយើងខ្ញុំផង ។
២- សូមធ្វើឲ្យគ្រប់ជាតិទាំងឡាយ រស់ទាំងខ្វល់ខ្វាយកុំបង្អង់
ឲ្យគេបានឃើញឫទ្ធិព្រះអង្គ ស្ញប់ស្ញែងខ្លាចផងអានុភាព ។
៣- សូមព្រះអង្គលើកព្រះហស្ដវាយ ប្រជាជិតឆ្ងាយជាដរាប
ដើម្បីឲ្យគេស្គាល់អានុភាព ឲ្យគេជ្រួតជ្រាបពីបារមី ។

៤- ដោយព្រះអង្គដាក់ទោសយើងខ្ញុំ ពិតជាសក្តិសមគ្មានទាស់អ្វី
តែសូមសម្តែងព្រះបារមី ឲ្យជាតិដទៃឃើញច្បាស់ថា ។
ព្រះអង្គជាព្រះវិសុទ្ធ វិសេសបំផុតលើលោកា
សូមសម្តែងឲ្យខ្ញុំដឹងថា ទ្រង់ដាក់ទោសាពួកគេដែរ ។
៥- សូមឲ្យមនុស្សគ្រប់ជាតិសាសន៍ ទទួលស្គាល់ច្បាស់គ្មានកែប្រែ
ក្រៅពីព្រះអង្គគ្មានព្រះទេ ត្រូវបេះរិះរេស្គាល់ព្រះអង្គ ។
៧- សូមទ្រង់សម្តែងថ្លៃងសិរី រុងរឿងម្ចាស់ថ្លៃកុំវេរង់
បារមីខ្លាំងក្លានៃព្រះអង្គ ឲ្យអ្នកទាំងពួងកោតស្ញប់ស្ញែង ។
១០- សូមពេលចុងក្រោយឆាប់មកដល់ ព្រះអង្គកុំខ្វល់ភ្លេចសម្តែង
គេនឹងរៀបរាប់ដោយកោតក្រែង អស្ចារ្យជាក់ស្តែងទ្រង់ប្រព្រឹត្ត ។
១១- សូមឲ្យភ្លើងនៃព្រះពិរោធ កំហឹងក្រេវក្រោធឆេះបំបាត់
ផុតកម្ទេចពួកអ្នកទុច្ចរិត កុំឲ្យវារត់រួចសោះឡើយ ។
១២- សូមទ្រង់បំបែកក្បាលសត្រូវ កុំទុកឲ្យនៅពួកនោះហើយ
វាពោលក្តែងៗគ្មានគិតឡើយ ថាវានេះហើយសំខាន់ណាស់ ។
១៣- សូមទ្រង់ប្រមូលកុលសម្ពន្ធ័ ឲ្យឆាប់រួសរាន់កុំក្រឡះ
ពូជពង្សយ៉ាកុបមានច្រើនណាស់ រស់នៅដេរដាសឲ្យមកជុំ ។

***ទំនុកតម្កើងរបស់នាងម៉ារី*** **បទព្រហ្មគីតិ**

**(លូកា ១-៤៧-៥៥ )**

៤៧- ខ្ញុំមានចិត្តអំណរ សប្បាយអរពន់ពេកណាស់
ព្រោះខ្ញុំបានដឹងច្បាស់ ថាព្រះម្ចាស់ទ្រង់សង្គ្រោះ ។
៤៨- ព្រះអង្គទតមកខ្ញុំ ជាអ្នកបម្រើស្ម័គ្រស្មោះ
តទៅមនុស្សទាំងអស់ ថាខ្ញុំនេះសែនសុខក្រៃ ។
៤៩- ព្រះដ៏មានឫទ្ធា ខ្លាំងអស្ចារ្យលើលោកីយ៍
សម្តែងឫទ្ធិបារមី ព្រះនាមថ្លៃថ្លាវិសុទ្ធ ។
៥០- ទ្រង់មានព្រះហឫទ័យ ត្រាប្រណីខ្ពស់បំផុត
ដល់អ្នកបរិសុទ្ធ គោរពកោតទ្រង់រហូត ។

៥១- ព្រះអង្គសម្ដែងឫទ្ធិ    អស្ចារ្យពិតមិនរបូត
ការពារមនុស្សស្លូត    កម្ចាត់ហួតអ្នកឫកខែង ។
៥២- ទ្រង់បានប្រានទម្លាក់    អ្នកជំធ្លាក់ពីតំណែង
ឥតមានខ្លាចរអែង    ហើយទ្រង់តែងលើកអ្នកទាប ។
៥៣- ព្រះអង្គប្រោសប្រទាន    ឲ្យអ្នកឃ្លានឆ្អែតពេញប្រៀប
អ្នកមានធនជានពាប    ទ្រង់ដេញរាបដៃទទេ ។
៥៤- ព្រះអង្គបានជួយរាស្ត្រ    ទ្រង់ទាំងអស់ឥតប្រួលប្រែ
ស្រាអែលដែលនៅក្បែរ    អ្នកពូកែបម្រើខ្លាំង ។
៥៥- ទ្រង់តែងមានព្រះទ័យ    ករុណាក្រៃមិនថ្នាក់ថ្នាំង
ជាមួយអប្រាហាំ    និងពូជពង្សលោកជានិច្ច ។
ដូចទ្រង់បានសន្យា    នឹងជូនតាឥតមានភ្លេច
ព្រះអង្គចាំជានិច្ច    គ្មានកលកិច្ចប្រែប្រួលឡើយ ។

### *ទំនុកតម្កើងរបស់លោកសាការី* **បទពាក្យ ៧**

**( លូកា ១-៦៨-៧៩ )**

៦៨- សូមលើកតម្កើងព្រះអម្ចាស់    ប្រសើរពេកណាស់ព្រះរបស់
ជាតិអ៊ីស្រាអែលធ្លាប់ស្មោះ    យាងមករំដោះរាស្ត្រព្រះអង្គ ។
៦៩- ទ្រង់បានប្រទានព្រះសង្គ្រោះ    ដែលមានឫទ្ធិខ្ពស់ដ៏ត្រចង់
ពីក្នុងចំណោមព្រះញាតិវង្ស    ដាវីឌជាពង្សបម្រើជាក់ ។
៧០- ព្រះម្ចាស់ប្រទានព្រះសង្គ្រោះ    យើងមិនដែលលោះមិនដែលលាក់
ដូចបានសន្យាតាមរយៈ    ព្យាការីស្ម័គ្រកាលគ្រាមុន ។
៧១- ព្រះអង្គសង្គ្រោះយើងឲ្យរួច    ចេញពីអំណាចខ្មាំងលើសលន់
និងផុតពីដៃពួកទុរជន    ដែលធ្លាប់ជិះជាន់ស្អប់ខ្ពើមយើង ។
៧២- ព្រះអង្គសម្ដែងព្រះហឫទ័យ    ករុណាប្រណីមិនឆ្មៃឆ្មើង
ដល់បុព្វបុរសដែលតម្កើង    សម្ពន្ធព្រះអង្គមិនភ្លេចសោះ ។

៧៣- គឺព្រះអង្គហើយបានសន្យា ពាក្យពិតសត្យាមិនចន្លោះ
នឹងអប្រាហាំបុព្វបុរស ជូនតាយើងនោះដូច្នេះថា ។
៧៤- ទ្រង់នឹងរំដោះយើងឲ្យរួច ផុតពីអំណាចខ្មាំងឫស្យា
ដើម្បីយើងអាចក្រាបកាយា វន្ទាគ្រប់គ្រាគ្មានភ័យភិត ។
៧៥- ព្រមទាំងឲ្យយើងបានរស់នៅ ឥតមានអាស្រូវដោយសុចរិត
ជារៀងរាល់ថ្ងៃមួយជីវិត គាប់ព្រះទ័យពិតព្រះម្ចាស់ថ្លៃ ។
៧៦- ចំណែកឯរូបរបស់កូន នឹងក្លាយជាខ្លួនព្យាការី
ព្រោះកូនដើរមុខព្រះម្ចាស់ថ្លៃ រៀបផ្លូវល្អក្រៃថ្វាយព្រះអង្គ ។
៧៧- កូននឹងធ្វើឲ្យអស់ប្រជា រាស្ត្រទាំងអស់គ្នាគេបានដឹង
ថាព្រះសង្គ្រោះគឺព្រះអង្គ ទាំងលើកទោសផងរួចពីបាប ។
៧៨- ព្រះរបស់យើងមានព្រះទ័យ ករុណាប្រណីជាជរាប
ទ្រង់ប្រទានថ្ងៃរះរៀងរាប រំដោះរួចបាបយើងពិតៗ ។
៧៩- សម្រាប់បំភ្លឺដល់អស់អ្នក ដែលបាននៅស្នាក់ទីងងឹត
ព្រមទាំងតម្រង់ផ្លូវជីវិត យើងឆ្ពោះរកពិតក្ដីសុខសាន្ត ។

### *ពាក្យអរព្រះគុណព្រះជាម្ចាស់របស់លោកតាស៊ីម៉ូន* បទពាក្យ ៧

**( លូកា ២-២៩-៣២ )**

២៩- « បពិត្រព្រះម្ចាស់ជាចៅហ្វាយ ពេលនេះឯងហើយទ្រង់សម្រេច
តាមព្រះបន្ទូលគ្មានកលកិច្ច សន្យាឥតភ្លេចលុះឥឡូវ ។
ដូច្នេះសូមឲ្យរូបខ្ញុំជា បម្រើគ្រប់គ្រាផុតហ្មងសៅ
សូមឲ្យខ្ញុំចាកលោកនេះទៅ ឲ្យខ្ញុំជួបនូវក្ដីសុខសាន្ត ។
៣០- ព្រោះដ្បិតភ្នែកខ្ញុំបានឃើញច្បាស់ ពីការសង្គ្រោះមិនដែលខាន
៣១- ដែលព្រះអង្គទ្រង់ប្រោសប្រទាន ដល់ជនគ្រប់ប្រាណគ្រប់ជាតិសាសន៍ ។
៣២- គឺជាពន្លឺដែលនាំឲ្យ គ្រប់ជាតិជិតឆ្ងាយស្គាល់ព្រះម្ចាស់
និងជាសិរីរុងរឿងច្បាស់ ស្រាអែលជារាស្ត្រនៃព្រះអង្គ » ។

## *សុភមង្គលដ៏ពិតប្រាកដ* — បទពាក្យ ៧

( ម៉ាថាយ ៥-៣-១២ )

៣- អ្នកណាដាក់ចិត្តជាអ្នកខ្សត់ — អ្នកនោះប្រាកដផុតទុក្ខា
មានសុខមង្គលគ្រប់ប្រការ — មានរាជ្យបេស្ដាសួគ៌ាផង ។
៤- អ្នកណាដែលមានចិត្តសុភាព — ស្លូតបូតរាបទាបសុចរិតត្រង់
នឹងមានមង្គលដ៏ត្រចង់ — ទាំងផែនដីផងបានជាកេរ ។
៥- រីអ្នកដែលមានចិត្តសោកសៅ — នោះមុខជាត្រូវបានល្ហើយល្ហែ
មានសុខមង្គលគ្មានកែប្រែ — ដ្បិតទុក្ខពួកគេព្រះសម្រាល ។
៦- អ្នកដែលស្រេកឃ្លានក្ដីសុចរិត — អ្នកនោះប្រាកដបានធូរស្រាល
មានសុភមង្គលដ៏ត្រកាល — ដ្បិតព្រះម្ចាស់ផ្ដល់ឲ្យគេឆ្អែត ។
៧- អ្នកដែលមានចិត្តករុណា — នោះប្រាកដថាខ្ពស់ត្រដែត
នឹងមានមង្គលច្បាស់ក្រឡែត — ព្រោះទ្រង់នៅអែបគេគ្រប់ពេល ។
៨- អ្នកដែលមានចិត្តស្មោះបរិសុទ្ធ — អ្នកនោះគឺពិតមានមង្គល
ដ្បិតគេនឹងបានឃើញបានយល់ — ព្រះជាម្ចាស់ផ្ទាល់ច្បាស់នឹងភ្នែក ។
៩- ឯអ្នកកសាងសន្តិភាព — បានសុខរៀងរាបល្អអនេក
ដ្បិតគេមានឈ្មោះជាបុត្រឯក — ជាទីគាប់ភ្នែកព្រះជាម្ចាស់ ។
១០- អ្នកណាដែលត្រូវគេបៀតបៀន — ព្រោះតែគេបានធ្វើឥតខ្ចោះ
តាមក្ដីសុចរិតទៀងត្រង់ស្មោះ — អ្នកនោះមានឈ្មោះសុខឥតខ្វល់ ។
១១- ប្រសិនបើមានគេតិះដៀល — បាក់រុកឆ្កឹះឆ្កៀលនាំអំពល់
បង្ខូចឈ្មោះព្រោះរូបខ្ញុំផ្ទាល់ — នឹងមានមង្គលកើតដល់អ្នក ។
១២- ចូរនាំគ្នារីករាយសប្បាយ — អបអរក្អាកក្អាយកុំអន់អាក់
នឹងបានទទួលរង្វាន់ជាក់ — យ៉ាងធំដល់អ្នកនៅបរមសុខ ។
ដ្បិតព្យាការីគ្រាកន្លង — មិនដែលថ្កុំថ្កើងស្គាល់តែទុក្ខ
ត្រូវគេបៀតបៀនមិនបានសុខ — នៅមិនស្រណុកដូច្នេះដែរ ។

## *ព្រះគ្រីស្តជាម្ចាស់នៃពិភពលោក* **បទពាក្យ ៧**

**(កូឡូស ១,១២-២០ )**

១២- ចូរអរព្រះគុណព្រះបិតា ដោយចិត្តជ្រះថ្លាអរសប្បាយ
ព្រោះព្រះអង្គប្រោសប្រទានឲ្យ បងប្អូនទាំងឡាយគ្រប់តំបន់ ។
មានសមត្ថភាពបានចំណែក មរតកល្អឯកមិនអាក់អន់
រួមជាមួយនឹងប្រជាជន វិសេសពេកពន់សែនវិសុទ្ធ ។
១៣- ព្រះអង្គរំដោះយើងឲ្យរួច ផុតពីអំណាចក្តីងងឹត
ចម្លងយើងចូលពន្លឺពិត ព្រះរាជ្យនៃបុត្រដ៏ស្រឡាញ់ ។
១៤- ដោយរួមក្នុងអង្គព្រះបុត្រា ទ្រង់បានលោះលារូបយើងចេញ
លើកលែងផុតទោសទុក្ខទោម្នេញ យើងរួចខ្លួនវិញផុតពីបាប ។
១៥- ព្រះគ្រីស្តតំណាងព្រះជាម្ចាស់ ដែលយើងទាំងអស់បានជ្រួតជ្រាប
តែមើលពុំឃើញជាដរាប ព្រោះអានុភាពខ្ពស់មហិមា ។
១៦- ដ្បិតអ្វីទាំងអស់ព្រះម្ចាស់បាន បង្កើតក្នុងប្រាណអង្គបុត្រា
ទាំងលើដែនដីស្ថានសួគ៌ា មានច្រើនមហិមារាប់មិនអស់ ។
ហើយព្រះជាម្ចាស់បានបង្កើត ឲ្យមានកំណើតមិនចន្លោះ
សម្រាប់ព្រះគ្រីស្តជាអម្ចាស់ និងដោយព្រះគ្រីស្តជារៀមច្បង ។
១៧- ព្រះគ្រីស្តមានព្រះជន្មមុនអ្វី ទាំងអស់រាល់ថ្ងៃមិនកន្លង
ស្ថិតស្ថេររួមគ្នានឹងព្រះអង្គ នោះគឺទ្រង់គាំទ្រដែរ ។
១៨- ព្រះគ្រីស្តជាសិរសាឧត្តម ប្រសើរសក្តិសមអ្វីម្លេះទេ
គឺព្រះសហគម៍តែងតែ បង្កើតឥតប្រែអ្វីមិនខ្វះ ។
ក្នុងចំណោមអ្នកដែលបានស្លាប់ ព្រះអង្គមានភ័ព្វមានជន្មរស់
មុនគេក្នុងអ្នកស្លាប់ទាំងអស់ ដឹកនាំឥតខ្ចោះគ្រប់វិស័យ ។
១៩- ដ្បិតព្រះជាម្ចាស់ព្រះអង្គគាប់ ព្រះហឫទ័យជាប់គ្រប់អ្វីៗ
លក្ខណៈសម្បត្តិដ៏ប្រពៃ ស្ថិតនៅរាល់ថ្ងៃក្នុងព្រះគ្រីស្ត ។
២០- ដ្បិតព្រះអម្ចាស់សព្វព្រះទ័យ បង្រួមអ្វីៗទាំងអស់នេះ
ទាំងលើដែនដីស្ថានសួគ៌ខ្ពស់ ឲ្យមកស្រួលស្រុះនឹងព្រះអង្គ ។

គឺព្រះជាម្ចាស់បានធ្វើឲ្យ សន្តិភាពកើតហើយដោយសារទ្រង់
បង្ហូរព្រះលោហិតព្រះអង្គ នៅលើឈើឆ្កាងដើម្បីរាស្ត្រ ។

## *ព្រះជាម្ចាស់មានព្រះហឫទ័យគេត្តាករុណាដ៏លើសលប់* **បទកាកគតិ**

**(អេភេសូ ១-៣-១០ )**

៣- សូមលើកតម្កើង ព្រះម្ចាស់ខ្ពស់ឡើង ជាព្រះបិតា នៃយេស៊ូគ្រីស្ត
ជាអង្គសាស្តា ម្ចាស់យើងនេះណា វិសេសពេកក្រៃ ។
ទ្រង់ប្រោសប្រទាន ព្រះពរឲ្យមាន វិសុទ្ធឥតបី ផ្នែកខាងវិញ្ញាណ
មករាស្ត្រប្រុសស្រី ពីសួគ៌ាលៃ ក្នុងអង្គព្រះគ្រីស្ត ។
៤- ព្រះអង្គជ្រើសយក យើងទាំងអស់មក វិសាលវិសេស ពីមុនកំណើត
ពីភពលោកម្ល៉េះ ក្នុងអង្គព្រះគ្រីស្ត ឥតមានសៅហ្មង ។
ចំពោះព្រះភក្ត្រ ព្រះអម្ចាស់ជាក់ ព្រោះតែព្រះអង្គ ទ្រង់មានព្រះទ័យ
ស្ម័គ្រស្មោះកន្លង ស្រឡាញ់ឥតហ្មង មិនប្រែសាវ៉ា ។
៥- ទ្រង់តម្រូវយើង ទាំងលើកតម្កើង ជាបុត្រធីតា របស់ព្រះអង្គ
នោះក៏ដោយសារ ព្រះគ្រីស្តនេះណា ស្របតាមបំណង ។
៦- ដើម្បីតម្កើង សិរីរុងរឿង នៃព្រះទ័យទ្រង់ ដែលធ្លាប់ប្រណី
សន្តោសឥតហ្មង ប្រទានមកយើង ក្នុងអង្គបុត្រា ។
៧- ព្រះជាម្ចាស់បាន លោះយើងគ្រប់ប្រាណ រស់រានដោយសារ លោហិតព្រះគ្រីស្ត
ជាអង្គបុត្រា ព្រោះគ្រប់កាយា រួមនឹងព្រះអង្គ ។
ទ្រង់តែងលើកទោស ពួកយើងទាំងអស់ ផុតទុក្ខសៅហ្មង តាមព្រះហឫទ័យ
សន្តោសព្រះអង្គ លើសលប់កន្លង មិនមានអាស្រូវ ។
៨- ព្រះម្ចាស់ប្រណី សន្តោសពេកក្រៃ ដឹងខុសស្គាល់ត្រូវ ឲ្យមានតម្រិះ
ខ្លាំងក្លាពេកកូវ មាំមិនអាស្រូវ ពេញដោយប្រាជ្ញា ។
៩- ព្រះម្ចាស់បានប្រោស ឲ្យយើងទាំងអស់ ស្គាល់គម្រោងការ តាមព្រះបំណង
សប្បុរសថ្លៃថ្លា គឺទ្រង់នេះណា ជាអ្នកសម្រេច ។

១០- ព្រះអង្គបាត់បែង គ្រោងការនេះឯង រួចរាល់ស្រេចបាច់ នៅគ្រាបំផុត
ឥតមានកលកិច្ច គ្មានអ្វីត្រូវភ្លេច ប្រមូលគ្មានសល់ ។
ទាំងលើផែនដី ទាំងសួគ៌ាលៃ ដោយមិនកង្វល់ ឲ្យរួមក្នុងអង្គ
ព្រះគ្រីស្តមិនសល់ គឺព្រះអង្គផ្ទាល់ ជាម្ចាស់តែមួយ ។

## *ព្រះគ្រីស្តមានព្រះហឫទ័យសុភាពរាបសា* **បទពាក្យ ៧**

**(ភីលីព ២,៦-១១ )**

៦- ទោះបីព្រះគ្រីស្តមានឋានៈ ស្មើព្រះជាម្ចាស់ដូចម្តេចក្តី
ក៏ទ្រង់មិនដែលសព្វព្រះទ័យ ក្តោបយកអ្វីៗជាកម្មសិទ្ធ ។
៧- តែផ្ទុយទៅវិញព្រះអង្គលះ បង់បោលស្រឡះមិនដែលគិត
យកព្រះឋានៈទាសករពិត រស់ក្នុងជីវិតមនុស្សធម្មតា ។
៨- ព្រះអង្គបន្ទាបព្រះកាយទៀត ធ្វើតាមឱវាទឥតមុសា
ដែលព្រះជាម្ចាស់បញ្ជាថា លុះផុតសង្ខារឈើឆ្កាងចង ។
៩- ដោយហេតុនេះហើយទើបព្រះម្ចាស់ តម្កើងព្រះគ្រីស្តពេកកន្លង
ហើយប្រោសប្រទានព្រះនាមផង ប្រសើរគ្មានហ្មងសែនថ្លាថ្លៃ ។
១០- ដើម្បីឲ្យអ្វីៗទាំងអស់ ទាំងនៅស្ថានខ្ពស់សួគ៌ាលៃ
ទោះនៅលើមេឃឬក្រោមដី បង្គំក្សត្រថ្លៃព្រះអម្ចាស់ ។
១១- និងឲ្យមនុស្សគ្រប់ភាសា គ្រប់ៗកាយាស្រែកប្រកាស
ថាព្រះគ្រីស្តជាព្រះអម្ចាស់ ថ្កើងសិរីយសព្រះបិតា ។

## *ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ* **បទព្រហ្មគីតិ**

**( ១ ធីម៉ូថេ ៣,១៦ )**

១៦- យើងត្រូវតែស្គាល់ថា គម្រោងការលាក់កំបាំង
ការប្រណិប័តន៍ក្លាខ្លាំង នៃព្រះអង្គធំធេងណាស់ ។
ព្រះគ្រីស្តបានយាងមក ទ្រង់ជ្រើសយកធ្វើឋានៈ
មនុស្សសុចរិតស្ម័គ្រ ដោយជឿជាក់ព្រះវិញ្ញាណ ។

ព្រះអង្គបង្ហាញច្បាស់ ទេវទូតអស់ទាំងប៉ុន្មាន
បានឃើញមិនខកខាន ហើយគេបានប្រកាសពី ។
ព្រះអង្គក្នុងចំណោម សាសន៍ផ្សេងព្រមនៅមូលមីរ
គេជឿគ្រប់ទិសទី គ្រប់ជីវិលោកទាំងអស់ ។
ព្រះជាម្ចាស់ទ្រង់បាន លើកអង្គប្រាណព្រះគ្រីស្តនោះ
ឲ្យមានសិរីយស រុងរឿងខ្ពស់ពេកកន្លង ។

## *ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ* **បទពាក្យ ៧**

**( ២ ធីម៉ូថេ ២,៨-១១-១៣ )**

៨- ចូរនឹកដល់ព្រះយេស៊ូនោះ មានព្រះជន្មរស់ឡើងវិញផង
ព្រះអង្គជាប់ព្រះញាតិវង្ស នៃដាវីឌអង្គម្ចាស់ក្សត្រា ។
១១- ពាក្យនេះគួរឲ្យយើងជឿជាក់ ដោយឥតល្មៀមលាក់យ៉ាងច្បាស់ថា
ប្រសិនបើយើងគ្រប់កាយា ព្រមរួមវាសនានឹងព្រះអង្គ ។
បើយើងព្រមរួមរស់រួមស្លាប់ នោះពិតជាគាប់ពេកកន្លង
យើងនឹងបានរស់ជីវិតផង រួមនឹងព្រះអង្គគ្មានកែប្រែ ។
១២- បើយើងជាអ្នកចេះស៊ូទ្រាំ ទោះជាយូរឆ្នាំយូរថ្ងៃខែ
នោះព្រះជាម្ចាស់នឹងគង់ក្បែរ ឲ្យសោយរាជ្យដែរជាមួយទ្រង់ ។
តែបើយើងមិនព្រមទទួល មិនព្រមស្រុះស្រួលស្គាល់ព្រះអង្គ
ពេលនោះព្រះជាអម្ចាស់ទ្រង់ នឹងមិនស្គាល់យើងវិញម្តងដែរ ។
១៣- ប្រសិនបើយើងមិនស្មោះត្រង់ នោះព្រះអង្គគង់មិនកែប្រែ
ស្មោះត្រង់ជានិច្ចក៏ព្រោះតែ ទ្រង់មិនងាកបែរនៅតែស្មោះ ។

## *ព្រះគ្រីស្តជាព្រះសង្គ្រោះ* **បទពាក្យ ៧**

**( ១ សិលា ២,២១-២៥ )**

២១- ព្រះបិតាហៅបងប្អូនមក ឲ្យរងទុក្ខសោកគ្មានល្ហែល្ហើយ
ព្រោះតែព្រះគ្រីស្តយើងនេះហើយ រងទុក្ខឥតស្បើយគំរូស្រាប់ ។

២២- ព្រះអង្គពុំដែលបានប្រព្រឹត្ត អំពើឧក្រិដ្ឋនាំមានបាប
ទាំងព្រះបន្ទូលធ្លាប់ថ្លែងប្រាប់ គួរឲ្យត្រង់ត្រាប់រហូតទៅ ។
២៣- ទោះបីត្រូវគេជេរប្រមាថ ពាក្យបកអាក្រាតនាំហ្មងសៅ
ក៏ទ្រង់វិនិច្ឆ័យរាល់វេលា យុត្តិធម៌គ្រប់គ្រាគ្មានសង្ស័យ ។
ព្រះអង្គបានផ្ញើខ្សែជីវិត លើព្រះម្ចាស់ពិតមិនរួញរា
ដែលទ្រង់វិនិច្ឆ័យរាល់វេលា យុត្តិធម៌គ្រប់គ្រាគ្មានសង្ស័យ ។
២៤- ព្រះគ្រីស្តបានផ្ទុកអំពើបាប យើងទុកជរាបពេញអង្គកាយ
ដែលជាប់ឈើឆ្កាងលុះក្សិណក្ស័យ ឲ្យជនប្រុសស្រីជ្រះស្រឡះ ។
ព្រមទាំងឲ្យយើងមានជីវិត ដោយរួមប្រព្រឹត្តសុចរិតច្បាស់
បងប្អូននឹងបានស្បើយជាសះ ស្នាមរបួសចាស់នៃព្រះអង្គ ។
២៥- ដ្បិតបងប្អូនដូចជាហ្វូងចៀម មានទុក្ខក្រំក្រៀមដោយខុសឆ្គង
វង្វេងប្រាសចាកពីគន្លង មាគ៌ាព្រះអង្គខ្ពស់បំផុត ។
ឥឡូវបងប្អូនជួបនឹងអ្នក ដែលធ្លាប់ថ្នមថ្នាក់ជីវិតសុទ្ធ
គង្វាលដ៏សែនល្អមោះមុត ថែទាំនៅជិតបងប្អូនវិញ ។

### *ចូរគោរពថ្វាយបង្គំព្រះជាម្ចាស់* **បទព្រហ្មគីតិ**

**( វិវរណៈ ៤,១១ )**

១១- បពិត្រព្រះអម្ចាស់ ទ្រង់ជាព្រះអស់យើងខ្ញុំ
ព្រះអង្គសែនសក្តិសម នឹងកិត្តិនាមអានុភាព ។
ព្រះអង្គបង្កើតគ្រប់ អ្វីមានសព្វជាជរាប
ដោយសារអានុភាព ដែលពេញប្រៀបដោយហឫទ័យ ។

### *កូនចៀមរបស់ព្រះជាម្ចាស់* **បទព្រហ្មគីតិ**

**( វិវរណៈ ៤,១១ )**

១១- បពិត្រព្រះអម្ចាស់ ទ្រង់ជាព្រះអស់យើងខ្ញុំ
ព្រះអង្គសែនសក្តិសម នឹងកិត្តិនាមអានុភាព ។

ព្រះអង្គបង្កើតគ្រប់ អ្វីមានសព្វជាដរាប
ដោយសារអានុភាព ដែលពេញប្រៀបដោយហឫទ័យ ។

**( វិវរណៈ ១១,១៧-១៨ )**

កូនចៀមសមទទួល ក្រាំងនិមលមិនបង្អង់
ទាំងបកត្រាទៀតផង ព្រោះតែទ្រង់ត្រូវសម្លាប់ ។
មកធ្វើយញ្ញបូជា ទ្រង់លោះលាមនុស្សសាយសព្វ
គ្រប់ពូជឥតមានស្អប់ ភាសាគ្រប់លើដែនដី ។
ប្រជាជនគ្រប់សាសន៍ យកថ្វាយព្រះជាម្ចាស់ថ្លៃ
ដោយសារឫទ្ធិបារមី លោហិតជ័យទ្រង់ជឿជាក់ ។
១០- ព្រះអង្គបានបង្វែរ ឲ្យគេប្រែអាណាចក្រ
ឲ្យបូជាចារ្យស័ក្រ សោយរាជ្យជាក់លើដែនដី ។
១២- កូនចៀមគេសម្លាប់ នោះទើបគាប់ពន់ពេកក្រៃ
ទទួលឫទ្ធិបារមី សម្បត្តិនៃប្រាជ្ញាញាណ ។
ប្រកបដោយឥទ្ធិឫទ្ធិ ខ្លាំងបំផុតរកផ្ទឹមគ្មាន
កិត្តិនាមល្បីថ្កើងថ្កាន សិរីបានរុងរឿងខ្ពស់ ។

***ចូរសរសើរព្រះជាម្ចាស់*** **បទភាកគតិ**

១៧- បពិត្រព្រះម្ចាស់ ដ៏មានតេជះ បេស្តាខ្លាំងក្រៃ លើអ្វីទាំងអស់
លើភពដែនដី គង់នៅសព្វថ្ងៃ និងពីដើមមក ។
យើងខ្ញុំសូមអរ ព្រះគុណបវរ ព្រោះទ្រង់បានយក ឫទ្ធានុភាព
ដ៏ថ្លៃថ្លាមក តាំងជាជម្រក រាជ្យព្រះអង្គឡើង ។
១៨- ជាតិសាសន៍នានា បបួលគ្នីគ្នា ចាប់ប្រឡោតខឹង ព្រមជាមួយនោះ
ជាពេលព្រះអង្គ ទ្រង់បានពង្រឹង ព្រះពិរោធដែរ ។
គឺដល់កំណត់ ពេលទ្រង់សន្មត ដោយគ្មានប្រួលប្រែ កាត់ក្ដីអ្នកស្លាប់
ឥតមានគេចកែ ពីដើមហូរហែ ឲ្យភ័យស្លោស្លន់ ។

នៅពេលនោះឯង ព្រះអង្គបាត់ថែង ប្រទានរង្វាន់ ដល់ព្យាការី
ឲ្យមានគ្រប់គ្រាន់ មិនឲ្យអាក់អន់ និងជនវិសុទ្ធ ។
ឲ្យទាំងអស់អ្នក ដែលកោតខ្លាចជាក់ ព្រះនាមមោះមុត ទាំងតូចទាំងធំ
ព្រះអង្គមិនគិត ឲ្យអស់កម្រិត ឲ្យឥតសំចៃ ។

**( *វិវរណៈ ១២,១០-១២* )** **បទកាកគតិ**

១០- ឥឡូវព្រះម្ចាស់ ទ្រង់បានសង្គ្រោះ មនុស្សលើផែនដី ព្រមទាំងអំណាច
ឫទ្ធាបារមី ព្រះគ្រីស្តថ្លាថ្លៃ ក៏យាងមកដែរ ។
ដ្បិតអ្នកប្រកាន់ ចាប់ទោសបងប្អូន គ្មានពេលល្ហើយល្ហែ ត្រូវគេទម្លាក់
បោលមិននៅក្បែរ គឺអ្នកតែងតែ ចោទដោយមិនគិត ។
១១- បងប្អូនយើងបាន ឈ្នះមិនដែលខាន ដោយព្រះលោហិត របស់កូនចៀម
ជាសក្ខីពិត បងប្អូនស្ម័គ្រចិត្ត ប្តូរជីវិតកាយ ។
១២- ហេតុនេះអស់អ្នក ដែលរស់នៅស្នាក់ ស្ថានបរមសុខអើយ ចូរមានអំណរ
រីករាយសប្បាយ អបអរគ្រប់កាយ កុំបីរួញរា ។

***ទំនុកតម្កើងរបស់នាងម៉ារី*** **បទព្រហ្មគីតិ**

**( *វិវរណៈ ១៥,៣-៤* )**

៣- ឱព្រះជាអម្ចាស់ បេស្កាខ្ពស់គ្មានអ្វីផ្ទឹម
ស្នាព្រះហស្តឧត្តម ស្រស់ប៉ប្រិមពន់ពេកណាស់
ឱព្រះមហាក្សត្រ នៃប្រជាជាតិទាំងអស់
មាគ៌ាល្អឥតខ្ចោះ នៃព្រះម្ចាស់សែនវិសុទ្ធ ។
៤- ឱព្រះជាអម្ចាស់ ទ្រង់ជាព្រះខ្ពស់បំផុត
ខ្មាំងសត្រូវតក់ស្លុត ត្រូវតែកោតនាមព្រះអង្គ ។
មនុស្សគ្រប់ជាតិសាសន៍ នាំគ្នាស្រុះគោរពទ្រង់
ប្រណិប័តន៍ថ្វាយផ្ចិតផ្ចង់ ដ្បិតព្រះអង្គសែនវិសុទ្ធ ។

## *ចូរច្រៀងចំរៀងជោគជ័យ* — បទកាកគតិ

**( វិវរណៈ ១៩,១-២-៥-៧ )**

១- អាលេលូយ៉ា ចូរឱនកាយា តម្កើងព្រះម្ចាស់ ទ្រង់បានស្រោចស្រង់
ព្រមទាំងសង្គ្រោះ ជីវិតយើងរស់ ដោយឫទ្ធិបារមី ។
២- ដ្បិតព្រះជាម្ចាស់ ទ្រង់វិនិច្ឆ័យច្បាស់ យុត្តិធម៌ប្រពៃ សូមអ្នករាល់គ្នា
ទោះជិតឆ្ងាយក្តី សូមនឹកមមៃ កុំនៅស្ងៀមស្ងាត់ ។
៥- អ្នករាល់គ្នាជា បម្រើគ្រប់គ្រា ទាំងអ្នកប្រណិប័តន៍ ទាំងតូចទាំងធំ
សូមគោរពកោត បង្គំថ្វាយថ្វាត់ កុំនៅបង្អង់ ។
៦- អាលេលូយ៉ា ព្រះម្ចាស់ក្សត្រា ប្រពៃត្រចង់ ព្រះអង្គសោយរាជ្យ
ព្រះទ័យស្មោះត្រង់ សុចរិតផូរផង់ ពាសពេញលោកីយ៍ ។
៧- ចូរយើងរីករាយ ត្រេកអរសប្បាយ ឲ្យខ្ទ័រជែនដី ចូរលើកតម្កើង
រុងរឿងសិរី ព្រះអម្ចាស់ថ្លៃ កុំធ្វើកន្តើយ ។
ដ្បិតដល់វេលា អាពាហ៍ពិពាហ៍ នៃកូនចៀមហើយ ភរិយាថ្មោងថ្មី
មិននៅព្រងើយ តែងខ្លួនស្រេចហើយ សក្តិសមគ្មានទាស់ ។

****